

## កម្រងអត្ថបទជ្រើសរើស

# សិក្សាតំបន់អាស៊ីអាគ្នេយ៍

# ស្វែងយល់ពីទីក្រុង និងជនបទ
# ក្នុងតំបន់អាស៊ីអាគ្នេយ៍


បកប្រែពីភាសាអង់គ្លេសដោយ

សេង សារី, ភី សុភាដា, ឈាត ស្រាង, សាយ ពុទ្ធី


**An Understanding of Urban and Rural in Southeast Asia**


Translated from English by SENG Sary, PHY Sopheada, CHHEAT Sreang, SAY Puthy

ជំពូកទី ១ ៖ វប្បធម៌សម្ភារៈ

*អត្ថបទទាំងនេះដកស្រង់ចេញពី ÷ អាស៊ីអាគ្នេយ៍ក្នុងយុគសម័យពាណិជ្ជកម្ម ១៤៥០-១៦៨០*

*រក្សាសិទ្ធិ គ.ស. ១៩៦៧ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យយេល ។*

**Chapter 1: Material Culture**

**Seleted from: Southeast Asia in the Age of Commerce 1450-1680,**

**Copyright © 1967 by Yale University Press**

ជំពូកទី ២ ៖ ទីក្រុង និងពាណិជ្ជកម្ម

*អត្ថបទទាំងនេះដកស្រង់ចេញពី ÷ អាស៊ីអាគ្នេយ៍ក្នុងយុគសម័យពាណិជ្ជកម្ម ១៤៥០-១៦៨០*

*រក្សាសិទ្ធិ គ.ស. ១៩៦៧ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យយេល ។*

**Chapter 1: The City and its Commerce**

**Seleted from: Southeast Asia in the Age of Commerce 1450-1680,**

**Copyright © 1967 by Yale University Press**

ជំពូកទី ៣ ៖ បម្រែបម្រួលលំហទីក្រុង ការធ្វើនគរូបនីយកម្មអាស៊ីអាគ្នេយ៍ក្នុងយុគសម័យសកលភាវូបនីយកម្មដ៏ងាយនឹងប្រែប្រួល

*អត្ថបទទាំងនេះដកស្រង់ចេញពីសៀវភៅ÷អាស៊ីអាគ្នេយ៍ក្នុងការប្រែប្រួល : ការផ្លាស់ប្តូរភូមិសាស្ត្រ*

*រក្សាសិទ្ធិ គ.ស. ២០០០ ដោយគ្រឹះស្ថានបោះពុម្ព វិទ្យាស្ថានសិក្សាតំបន់អាស៊ីអាគ្នេយ៍*

**Chapter 3: Changing Spaces: Southeast Asian Urbanization in an Era of Volatile Globalization**

**Seleted from: Southeast Asia Transformed: A Geography of Change**

**Copyright © 2000 by Institute of Southeast Asian Studies**

ជំពូកទី ៤ ៖ ឥទ្ធិពលប្រជាសាស្ត្រក្នុងការកំណត់ចំនួនយុវជននៅក្នុងបណ្តាទីក្រុងនៅអាស៊ី

*អត្ថបទទាំងនេះដកស្រង់ចេញពីសៀវភៅ ÷ យុវជន ភាពក្រីក្រ ហើយនិងជម្លោះក្នុងទីក្រុងអាស៊ីអាគ្នេយ៍*

*រក្សាសិទ្ធិ គ.ស. ២០០៤ ដោយគ្រឹះស្ថានបោះពុម្ព វូតត្រូ វីលសុន*

**Chapter 4: Demographic Forces Shaping Youth Populations in Asian Cities**

**Seleted from: Youth, Poverty and Conflict in Southeast Asian Cities**

**Copyright © 2004 by Woodrow Wilson Center Press**

រក្សាសិទ្ធិក្នុងការបកប្រែ និងចេញផ្សាយជាភាសាខ្មែរ © គ.ស. ២០០៩ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។

**Copyright © 2009 Center for Khmer Studies for the Khmer translation.**

**រូបភាពក្របមុខដោយ** ◢ **Cover picture**

មជ្ឈមណ្ឌលខេមរសិក្សា(រក្សាសិទ្ធិ) គ.ស. ២០០៩ **Copyright © 2009 Center for Khmer Studies**

ការបកប្រែ និងបោះពុម្ពសៀវភៅនេះ ទទួលបានការឧបត្ថម្ភពីមូលនិធិ រ៉ក់ហ្វេល្ល័រ នៅញូយ៉ក ។

**The publication of this book was supported by the Rockefeller Foundation (New York).**

លសខអ ១៣ ៖ ៩៧៨-៩៩៩៥០-៥១-១០-៥ ISBN-13: 978-99950-51-10-5

បោះពុម្ពនៅភ្នំពេញ ។ **Printed in Phnom Penh.**

# សារបញ្ញា

**កថាមុខ** ០៥

**ជំពូកទី ១ ៖ ចប្បធម៌សម្ភារៈ** ០៩

*ផ្ទះសាមញ្ញតូចៗ និងប្រាសាទដ៏ស្កឹមស្កៃ* ១១

*ការបំពាក់គ្រឿងសង្ហារិម និងភ្លើងពណ៌* ២៥

*សោភ័ណ្ឌភាពរាងកាយ* ២៦

*ការតុបតែងសក់* ៣២

*ការស្លៀកពាក់* ៣៧

*ផលិតកម្មវាយនភ័ណ្ឌ និងពាណិជ្ជកម្ម* ៤៤

*ការធ្វើមាស និងប្រាក់* ៥១

*ជំនាញអាជីព* ៥៥

*កុលាលភាជន៍* ៥៩

*ការផលិតលោហៈដែលជាគន្លឹះនៃអំណាច* ៦១

*ដែក* ៦២

*ទង់ដែង សំណប៉ាហាំង និងសំណ* ៧០

**ជំពូកទី ២ ៖ ទីក្រុង និងពាណិជ្ជកម្ម** ៧៥

*ទីក្រុងកំពង់ផែ និងបណ្ដាញពាណិជ្ជកម្ម* ៧៩

*វិសាលភាពទីក្រុង* ៨៣

*រចនាសម្ព័ន្ធនៃទីក្រុងអាស៊ីអាគ្នេយ៍* ៩៤

*ទីផ្សារ* ១០៨

*ការបោះប្រាក់ និងពាណិជ្ជនីយកម្ម (ភាពជោគជ័យរបស់ប្រាក់)* ១១១

*ការចាត់ចែងផ្នែកហិរញ្ញវត្ថុ* ១២៦

*អូរ៉ង់កាយ៉ា (Orangkaya) —ឈ្មួញលំដាប់ខ្ពស់* ១៣៣

*ក្រុមភាគតិចនៅក្នុងវិស័យពាណិជ្ជកម្ម និងជាតិពិន្ទុ* ១៤៤

*នគរូបនីយកម្មនិយម និង មូលធននិយម* ១៥១

**ជំពូកទី ៣ ៖ បម្រែបម្រួលលំហទីក្រុង ការធ្វើនគរូបនីយកម្មអាស៊ីអាគ្នេយ៍ក្នុងយុគសម័យ សកលភាវូបនីយកម្មដ៏ខ្លាំងនឹងប្រែប្រួល** ១៥៥

*សេចក្ដីផ្ដើម* ១៥៧

*ការវិវឌ្ឍជាប្រវត្តិសាស្ត្រនៃដំណើរការនគរូបនីយកម្មនៅអាស៊ីអាគ្នេយ៍* ១៥៩

*នគរូបនីយកម្មនៅអាស៊ីអាគ្នេយ៍សម័យក្រោយសង្គ្រាម ១៩៤៥-១៩៩០* ១៦១

*ដំណាក់កាលទី ១ ÷ នគរូបនីយកម្មនិងជាតិនិយមថ្មីនៅអាស៊ីអាគ្នេយ៍ ១៩៤៥-៦០* ១៦១

ដំណាក់កាលទី ២៖ សមាហរណកម្មសាកលលោក និងនគរូបនីយកម្ម១៩៦០-៩០ ១៦៣
នគរូបនីយកម្មក្នុងទសវត្សឆ្នាំ ១៩៩០៖ សកលភាវូបនីយកម្មពុំទៀងទាត់និងទីក្រុងនៅអាស៊ីអាគ្នេយ៍ ១៦៦
ការបង្ហាញអំពីទីក្រុងដែលកំពុងធ្វើសកលភាវូបនីយកម្មនៅអាស៊ីអាគ្នេយ៍ ១៧០
ទីក្រុងលំដាប់ពិភពលោក ១៧១
ទីក្រុងរីកលូតលាស់តាមបែបពហុកោណ ១៧២
តំបន់ទីក្រុងពង្រីក និងក្រុងរបៀង ១៧២
នគរូបនីយកម្ម និងយន្តកម្មពហុកម្រិត ១៧៤
ទិសដៅទៅអនាគត៖នគរូបនីយកម្ម និងសាកលភាវូបនីយកម្មដែលងាយនឹងប្រែប្រួល ១៧៥
សេចក្តីសន្និដ្ឋាន៖ ឥទ្ធិពលលើគោលនយោបាយ ១៧៨

**ជំពូកទី ៤ ៖ ឥទ្ធិពលប្រជាសាស្ត្រក្នុងការកំណត់ចំនួនយុវជននៅក្នុងបណ្តាទីក្រុងនៅអាស៊ី ១៨១**
បម្រែបម្រួលតំបន់ទីក្រុង និងយុវជននៅអាស៊ី ១៨៨
យុវជននៅក្នុងប្រព័ន្ធអន្តោប្រវេសន៍ជាតិ ១៩២
ដំណើរប្រែប្រួលប្រជាសាស្ត្រ និងការផ្ទុះឡើងនៃចំនួនយុវជន ១៩៤
ការហូរចូលរបស់យុវជនមកកាន់តំបន់ទីក្រុង ១៩៨
ទំរង់បែបបទសង្គមមួយនៃយុវជនទីក្រុង ២០៣
សេចក្តីសន្និដ្ឋាន ២០៦

**កំណត់ចំណាំ ២១៣**
ជំពូកទី ២ ២១៣
ជំពូកទី ៣ ២១៤
ជំពូកទី ៤ ២២៣

# អារម្ភកថា

ខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំងដែលបានបង្ហាញសៀវភៅបកប្រែវគ្គទី ៥ ពីកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ឧត្តមសិក្សាវ័យក្មេង របស់មជ្ឈមណ្ឌលខេមរសិក្សា ក្រោមការឧបត្ថម្ភរបស់ មូលនិធិ រ៉ក្គីហ្វេល្ល័រ ស្តីពីប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍សម័យដើម និងសម័យទំនើប ។ វគ្គសិក្សាទី ៥ នេះមានឈ្មោះថា «ការសិក្សាអំពីទីក្រុង និងជនបទនៅតំបន់អាស៊ីអាគ្នេយ៍» ដោយផ្តោតលើឥទ្ធិពលប្រជាសាស្ត្រ វប្បធម៌ និងពាណិជ្ជកម្មដែលបានកំណត់ការអភិវឌ្ឍន៍នគរូបនីយកម្ម និងជនបទ នៅក្នុងតំបន់ អាស៊ីអាគ្នេយ៍ចាប់តាំងពីសតវត្សទី ១៦ ជាពិសេសនោះគឺនៅក្នុងប្រទេសកម្ពុជា។

នៅក្នុងយុគសម័យដែលសាកលភាវូបនីយកម្មមានសារសំខាន់ក្រៃលែងសម្រាប់ការអភិវឌ្ឍន៍ កម្ពុជាចំណេះដឹងពីប្រវត្តិសាស្ត្រសម័យដំបូងនៅតែមានភាពចាំបាច់ដដែល សម្រាប់ការជជែកវែកញែក សំខាន់ៗ ។ ដូច្នេះហើយសៀវភៅវគ្គទី ៥ នេះមានអត្ថបទជ្រើសរើសចំនួន ៤ បង្ហាញពីមូលបទនៃការផ្លាស់ប្តូរដែល បានកំណត់ទៅលើប្រវត្តិសាស្ត្រទីក្រុងនិងជនបទរបស់តំបន់អាស៊ីអាគ្នេយ៍ចាប់តាំងពីសតវត្សទី ១៧ មក។

នៅក្នុងវគ្គសិក្សា អ្នកស្រាវជ្រាវនិងសាស្ត្រាចារ្យវ័យក្មេងទទួលបាននូវការបង្ហាញពីទ្រឹស្តីសង្គមវិទ្យា នរវិទ្យា និងប្រវត្តិវិទ្យា ដើម្បីស្វែងយល់ពីសង្គមជនបទ ពីការកកើតក្រុង ពីឥទ្ធិពលដែលបានកំណត់ ការអភិវឌ្ឍន៍ទីប្រជុំជនដំបូងៗ នៃទីក្រុងទាំងឡាយក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ តើអ្នកណាខ្លះបានរស់នៅក្នុងទីក្រុងទាំងនេះ? តើអ្នកណាខ្លះបានចូលមករស់នៅ និងអ្នកណាខ្លះដែលមិនបានចូលមក? តើទីតាំង ភូមិសាស្ត្រតំបន់អាស៊ីអាគ្នេយ៍ដែលថិតនៅលើផ្លូវពាណិជ្ជកម្មមានឥទ្ធិពលយ៉ាងដូចម្តេចទៅលើ ទីតាំងហើយនិងតួនាទីរបស់មជ្ឈមណ្ឌលក្រុងទាំងនោះ? តើរបបអាណានិគមនិយមបានកំណត់ពីលក្ខណៈជាតិសាសន៍ ពាណិជ្ជកម្មនិង ស្ថាបត្យកម្មរបស់ទីក្រុងភ្នំពេញ បាងកក និង ទីក្រុង របស់ប្រទេសអាស៊ីអាគ្នេយ៍ដ៏ទៃទៀត យ៉ាងដូចម្តេច? តើការផ្លាស់ប្តូរផ្នែកប្រជាសាស្ត្រដែលកើតឡើងដោយសារតែឧស្សាហូបនីយកម្មនៅអឺរ៉ុបបាន កំណត់ទម្រង់រីកលូតលាស់នៃទីក្រុងក្នុងប្រទេសអាស៊ីអាគ្នេយ៍ក្នុងកំឡុងសម័យអាណានិគម យ៉ាងដូចម្តេច? ទីបញ្ចប់តើសាកលភាវូបនីយកម្មមានឥទ្ធិពលយ៉ាងដូចម្តេចទៅលើការរីកចំរើនក្រុង ដូចជាការរីកលូតលាស់ធនធាន និងភាពក្រីក្រ?

អត្ថបទចំនួនពីររបស់ អាធីនី រ៉េដ និយាយអំពី «វប្បធម៌សម្ភារៈ» » និង «ទីក្រុងនិងពាណិជ្ជកម្ម » ដកស្រង់ចេញពីសៀវភៅរបស់គាត់ដែលមានចំណងជើងថា « **អាស៊ីអាគ្នេយ៍ក្នុងយុគសម័យពាណិជ្ជកម្ម** » ទាំងក្នុងវគ្គទី ១ និង ទី ២ ។ អត្ថបទទាំងនេះបានផ្តល់នូវចំនេះដឹងប្រវត្តិសាស្ត្រ ខាងផ្នែកវប្បធម៌ និង នរវិទ្យា យ៉ាងសម្បើម ពីការអភិវឌ្ឍន៍ក្រុង និងជនបទទាំងនៅអាស៊ីអាគ្នេយ៍ដីគោកនិងដីកោះ មុនការមកដល់របស់ ពួកអាណានិគម ។ នៅត្រង់នេះ យើងបានរៀនពីឥទ្ធិពលរបស់បរិដ្ឋាន និងវប្បធម៌ដែលបានកំណត់ នគរូបនីយកម្មនាពេលដំបូង ហើយនិងតួនាទីរបស់ក្រុងជាមជ្ឈមណ្ឌលពាណិជ្ជកម្មសម្រាប់ពាណិជ្ជករ មកពីឥណ្ឌាខាងកើត (ពាណិជ្ជករមកពីអឺរុប) និងមជ្ឈឹមបូពាទៅកាន់ចិន។

ក្នុងចំនោមអត្ថបទពីរទៀត មានអត្ថបទមួយនិពន្ធដោយ លោក ហ្វីលីព ឃីលី និងធីរី ម៉ាកហ្គី ។ អត្ថបទនោះមាន ចំណងជើងថា «បម្រែបម្រួលលំហានគរូបនិយកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងយុគសម័យ សាកលភាវូបនីយកម្ម» ដកស្រង់ចេញពីសៀវភៅ « **អាស៊ីអាគ្នេយ៍ក្នុងការប្រែប្រួល» ការផ្លាស់ប្តូរផ្នែកភូមិសាស្ត្រ** » បោះពុម្ពនៅឆ្នាំ ២០០៣។ រីឯអត្ថបទទី២ និពន្ធដោយ ភីតធី ស៊ីនុស មានចំណងជើងថា « ឥទ្ធិពលប្រជាសាស្ត្រក្នុងការកំណត់ចំនួនយុវជនក្នុងទីក្រុងនៅតំបន់អាស៊ី » ដកស្រង់ចេញពីសៀវភៅដែលមាន ចំណងជើងថា «**យុវជន ភាពក្រីក្រ និងជម្លោះ នៅទីក្រុងក្នុងតំបន់អាស៊ីអាគ្នេយ៍** » បោះពុម្ពឆ្នាំ ២០០៤ ។ អត្ថបទទាំងនេះនឹងផ្លាស់ប្តូរការចាប់អារម្មណ៍របស់អ្នកអានទៅកាន់យុគសម័យទំនើបក្រោយរបបអាណានិគម ហើយនឹងផ្តល់នូវការមើលឃើញរបស់អ្នកភូមិសាស្ត្រអំពីរបៀបដែលទីក្រុងបាន ក្លាយជាអតិសុខុមលោកនៃការ

ផ្លាស់ប្តូររាប់ជំនាន់ ពីរបៀបដែលទីក្រុងបើកចំហសម្រាប់ការហូរចូលនៃឥទ្ធិពលសាកល និងផ្ទេរបន្ទុកនៃការរីកលូតលាស់ទៅលើយុវជនពន្លកថ្មី ។

ខ្ញុំសង្ឃឹមថា អ្នកដែលចាប់អារម្មណ៍ពីប្រវត្តិសាស្ត្រសម័យដើមដំបូងនិងការប្រឈមជាមួយបញ្ហា ប្រជាសាស្ត្រសម័យទំនើបរបស់កម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍នឹងបានអានសៀវភៅនេះ។

ជាចុងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលមួយចំនួនដែលខិតខំប្រឹងប្រែងដើម្បីសម្រេចកិច្ចការ ទាំងនេះបានប្រកបដោយជោគជ័យ ។ ដំបូងបង្អស់គឺលោក ឈាន មែន នាយកកម្មវិធីបណ្តុះបណ្តាលដែល ទស្សនៈហើយនិងការប្តេជ្ញាចិត្តរបស់លោកបានបង្កើតឲ្យមានលទ្ធផលទាំងនេះឡើង។ សូមអរគុណជាពិសេស ចំពោះក្រុមអ្នកបកប្រែ ដែលបានចូលរួមចំណែកយ៉ាងច្រើនសន្ធឹកសន្ធាប់មានដូចជា សេង សារី, ឈាត ស្រ៊ាង, សាយ ពុទ្ធី និងភី សុភាដា ។ សូមអរគុណចំពោះអ្នកស្រី តាន់ សូដានី ជាអ្នកសម្របសម្រួលកម្មវិធីបកប្រែ ដែលធ្វើការប្រកបដោយស្មារតីប្រុងប្រយ័ត្ន និងចាត់ចែងក្រុមបានល្អ ។ ខ្ញុំសូមសម្តែងការ ដឹងគុណចំពោះការជួយជ្រោមជ្រែងរបស់ លោក ខេង ពិទូកេត្យា ដែលជាអ្នកសម្របសម្រួលការងារទំនាក់ទំនង និងបោះពុម្ព សំរាប់ស្នាដៃដ៏ល្អក្នុងការចាត់ចែង រឿងបណ្ណាធិការ និងការបោះពុម្ពផ្សាយ ។

យេត ហ្វ្រីសិន

សាស្ត្រាចារ្យដឹកនាំការបង្រៀន

## PREFACE

It is with great pleasure that I introduce this fifth volume of translated texts from the Junior Faculty Training Program of the Center for Khmer Studies supported by the Rockefeller Foundation on early and modern Southeast Asian history. This course entitled Rural and Urban Studies of Southeast Asia focused on demographic, cultural and commercial forces shaping urbanization and rural development in Southeast Asia from the 16$^{th}$ century, with a particular focus on Cambodia.

In the era where globalization is pivotal to Cambodia's development, knowledge about early history remains essential in shaping key debates. Therefore, this volume of translations represents a selection of four texts representing the themes of transformation shaping Southeast Asian urban and rural history since the 17$^{th}$ century.

During the course, the young researchers and junior faculty were exposed to sociological, anthropological, and historical frameworks for learning about rural societies, the gravitational pull of the cities, and the forces shaping early urban developments in Southeast Asian cities. Who lived in these cities? Who had access and who did not? How did Southeast Asia's geographic location on the trade routes influence the location and role of urban centers? How did colonialism shape the ethnic, commercial and architectural characteristics of Phnom Penh, Bangkok, and other Southeast Asian cities? How did the demographic changes arising from European industrialization shape growth patterns of Southeast Asian cities during the high colonial era. Finally, how did globalization affect the growth, wealth and poverty aspects of urban developments.

The two chapters by veteran scholar Anthony Reid on Material Culture and The City and Its Commerce are drawn from his book: *Southeast Asia in the Age of Commerce 1450-1680*, Vol 1. This seminal work provides an enormous amount of ethnographic and cultural history about both rural and urban developments within mainland and peninsular Southeast Asia prior to the colonial period. Here we learn about environmental and cultural forces that shaped early urbanization and its role as a commercial hub for East Indies and Middle East traders en route to China.

The latter two articles are by Philip Kelly and Terry McGee. Changing Spaces: Southeast Asian Urbanization in an Era of Volatile Globalization, From *Southeast Asia Transformed: A Geography of Change,* 2003, and Peter Xenos, Demographic Forces Shaping Youth Populations in Asian Cities. From *Youth, Poverty and Conflict in Southeast Asian Cities,* 2004, these texts shift the gaze to the modern post colonial era and provide a geographer's view of how cities become a microcosm of generational change, opening up spaces for global forces to enter, and further shifting burdens of growth onto burgeoning youthful populations.

It is hoped that these works will be read by all those interested in early history and modern demographic challenges facing Cambodia and Southeast Asia.

In closing, there are several key people to thank for ensuring the success of this program. First and foremost is Mr. Chean Men, Director of the Rockefeller Junior Faculty Training program, whose vision and commitment has made this endeavor possible. The translators have contributed a great

deal and deserve special thanks. They are SENG Sary, SAY Puthy, CHHEAT Sreang, and PHY Sopheada. Ms. Tan Sodany, the CKS Translation Coordinator was ever vigilant and served the team well. Finally, many thanks are given to Kheng Pytou Kethya, Publishing Coordinator, for his excellent work in managing the editorial and publishing aspects of this truly collective undertaking.

Kate Frieson,
Visiting Scholar

# ជំពូកទី ១

# វប្បធម៌សម្ភារៈ

*ដោយ អាន់ថូនី រីដ*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* Material Culture។
*អត្ថបទនេះ ដកស្រង់ចេញពីសៀវភៅ ៖ អាស៊ីអាគ្នេយ៍ក្នុងយុគសម័យពាណិជ្ជកម្ម ១៤៥០-១៦៨០ ភាគទី ១។*
*រក្សាសិទ្ធិ គ.ស. ១៩៦៧ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យយេល ។*

# CHAPTER 1:

Material Culture

Anthony Reid

(*Southeast Asia in the Age of Commerce 1450 -1680 Volume One*)

**Copyright © 1967 by Yale University.**

បកប្រែដោយ សេង សារី

# ជំពូកទី ១
# វប្បធម៌សម្ភារៈ

ជនជាតិភូមាបានចំណាយទៅលើម្ហូបអាហារ កន្លែងដេក និងផ្ទះសំបែងតិចតួចណាស់បើប្រៀបធៀបទៅនឹងការចំណាយដ៏ខ្ជះខ្ជាយទៅលើសម្លៀកបំពាក់របស់ពួកគេ ។ ជានិច្ចកាលពួកគេនិយាយថា គេងាយនឹងមើលឃើញពីសម្លៀកបំពាក់របស់មនុស្សគ្រប់គ្នា ក៏ប៉ុន្តែគ្មាននរណាម្នាក់បានចូលទៅក្នុងផ្ទះរបស់ពួកគេដើម្បីសង្កេតមើលថាតើពួកគេបរិភោគអ្វីខ្លះ ហើយរស់នៅយ៉ាងណានោះទេ ។

សាំងហ្គឺម៉ាណូ (Sangermano) គ.ស. ១៨១៨ ទំ. ១៥៩

## ផ្ទះសាមញ្ញតូចៗ និងប្រាសាទដ៏ស្កឹមស្កៃ

*ប្រជាជននៅអាស៊ីអាគ្នេយ៍មិនចំណាយពេល និងធនធានច្រើនទៅលើការសាងសង់លំនៅស្ថានរបស់ពួក ពីព្រោះថាអាកាសធាតុមានលក្ខណៈល្អប្រសើរ ហើយដោយសារតែមានភាពងាយស្រួលស្វែងរកដើមឈើ ដើមត្នោត និងដើមឫស្សីដែលជារុក្ខជាតិរីកលូតលាស់យ៉ាងរហ័ស ។ ដោយសារតែផ្ទះងាយស្រួលនឹងសាងសង់អស់កម្រៃតិច ពួកគេគិតថាផ្ទះមិនមែនជាកន្លែងរស់នៅគង់វង្ស និងសមរម្យ ដូចទីកន្លែងសម្រាប់តាំងទីក្រុងនោះទេ ។ទោះជាសម្ភារៈសំណង់ទាំងនោះងាយស្រួលរក និងប្រើប្រាស់ក៏ដោយ ប៉ុន្តែវាក៏ឆាប់ពុកផុយដែរដូចជាដំបូលស្បូវក្តារជញ្ជាំងរនាបឫស្សីជាដើម ត្រូវតែផ្លាស់ ប្តូរក្នុងអំឡុងពេល ១០ឆ្នាំ ប្រសិនបើផ្ទះទាំងនោះមិនត្រូវបានបោះបង់ចោលយ៉ាងឆាប់រហ័សដោយសារភ្លើងឆេះ សង្គ្រាម កសិកម្មពនាចរ ឬជំងឺឧបទ្រពចង្រៃ និងជំងឺតម្កាត់ផ្សេងៗទេនោះ (ង្វៀយេន (Nguyen) គ.ស.១៩៣៤ ទំ.១៨៨) ។ គេឃើញថាសសរផ្ទះមិនបានធ្វើឡើងដោយកប់ចូលទៅក្នុងដីនោះទេ ប៉ុន្តែត្រូវបានសង់បណ្តាក់ពីលើដីនោះតែម្តង ដើម្បីឲ្យប្រាកដថាពួកគេអាចរំកិលផ្ទះនោះចុះឡើងបាននៅពេលពួកគេត្រូវការ ។ ឡាលូប៊ែរ(គ.ស.១៦៩១ ទំ. ២៩) បានឃើញផ្ទះជនជាតិសៀមចំនួនបីខ្នង ដែលបានសង់បាំងមុខព្រះបរមរាជវាំងត្រូវបានគេសែងទៅកន្លែងមួយផ្សេងទៀត «ដោយប្រើរយៈពេលតិចជាងមួយម៉ោង» នៅខណៈពេលដែលផ្ទះចំនួន ២០ ខ្នងផ្សេងទៀតត្រូវបានម្ចាស់ផ្ទះសែងចេញដោយសារតំបន់មួយនោះស្ថិតនៅក្នុងតំបន់ម៉ាកាសសា ដែលគេត្រូវការសាងសង់រោងចក្រឲ្យពួកអង់គ្លេសនៅក្នុង គ. ស. ១៦១៣ (ជួរដាំង (Jourdain) បោះពុម្ពនៅគ. ស. ១៦១៧ទំ. ទី) ។*

*ការសាងសង់ផ្ទះដ៏សាមញ្ញមួយឡើងវិញ មិនស្មុគស្មាញជាងការសែងរំកិលផ្ទះនោះឡើយ ។ ហ្ក្រាហ្វូដ (Crawfuid គ.ស.១៨២០ ទំ.១៦២) យល់ថា ផ្ទះធម្មតាមួយអាចឲ្យគេសង់ក្នុងប៉ុន្មានថ្ងៃដោយមិនចាំបាច់ប្រើកម្លាំងមនុស្សលើសពី ៦០ នាក់នោះឡើយ ។ ជនជាតិភូមាចំនួន ៥០ នាក់បានសងលំនៅស្ថានដែលមាន ៤ បន្ទប់ដ៏ស្អាត (ស៊ីម្ស (Symes) គ.ស.១៨២៧ ទំ.២៨៣) នៅក្នុងរយៈពេលតែ ៤ ម៉ោងប៉ុណ្ណោះ ។ ជនជាតិអឺរ៉ុបមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះល្បឿននៃការកសាងទីក្រុងដ៏ធំមួយឡើងវិញ បន្ទាប់ពីបានបំផ្លាញដោយអគ្គីភ័យ។ ឡាលូប៊ែរ (គ.ស.១៦៩១*

ទំ.២៩) បានប្រទះឃើញផ្ទះនៅក្រុងអយុធ្យាចំនួន ៣០០ ខ្នងត្រូវបានសាងសង់ឡើងវិញក្នុងរយៈពេលតែ ២ ថ្ងៃប៉ុណ្ណោះ រីឯលូដូវីស្គស់ (គ.ស.១៥៩៨ ទំ.១០៨) ក៏ប្រទះឃើញផងដែរនូវការសាងសង់ផ្ទះឡើងវិញនៅតាមបណ្តោយឆ្នេរ បាន់ទែន (Banten) ទាំងមូលដោយប្រើរយៈពេលតែ ៣ ទៅ ៤ ថ្ងៃតែប៉ុណ្ណោះ ។

ទោះបីជាមានអ្នកឯកទេសខាងការសាងសង់ និងជាងឈើខ្វះក៏ដោយ ក៏ប្រជាជនគ្រប់គ្នាមានចំណេះដឹងជាមូលដ្ឋានក្នុងការសាងសង់ផ្ទះដែរ មានន័យថា «មនុស្សម្នាក់ៗគឺជាជាងឈើ» (ដាំពែរ គ.ស.១៦៩៧ ទំ.២២៧) ។ សាច់ញាតិនិងអ្នកជិតខាងជួយគ្នាទៅវិញទៅមក នៅពេលដែលពួកគេត្រូវការសាងសង់ផ្ទះ ។ ការផ្លាស់ប្តូរលំនៅជាញឹកញាប់ និងភាពងាយស្រួលក្នុងការសាងសង់ ឬការសង់គេហដ្ឋានឡើងវិញទាំងនេះគឺជាកត្តាសំខាន់នៅក្នុងរចនាសម្ព័ន្ធសង្គមនៅតំបន់អាស៊ីអាគ្នេយ៍ ។

នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ទម្រង់រួមមួយបានលេចឡើង បើទោះជារចនាបទគេហដ្ឋានមានភាពប្លែកគ្នានៅក្នុងចំណោមជាតិសាសន៍ និងឋានៈសង្គមខុសៗគ្នាក៏ដោយ ។ ការសង់ជំបូលរាងចោទខ្លាំងគឺ ធ្វើឡើងជាចាំបាច់សម្រាប់ទប់ទល់នឹងភ្លៀងមូសុងដ៏ជោគជាំ ហើយសង់ផ្ទះនៅខ្ពស់ពីដីនៅលើសសរឈើដ៏រឹងមាំនោះ គឺដើម្បីការពារទឹកជំនន់ផងដែរ (សូមមើលរូបភាពទី ៦) ។ ការសង់ផ្ទះបន្ទីតខ្ពស់ពីដីដែលមានជណ្តើរជាផ្លូវនៅលើផ្ទះនោះគឺជាលក្ខណៈរួមមួយនៅក្នុងតំបន់ ។ នៅក្នុងភាសា ម៉ាឡេ ពាក្យដែលមានន័យថា «ជណ្តើរផ្ទះ» គឺ (rumah-tangga) ។

កម្ពស់នៃការសាងសង់ផ្ទះមានភាពផ្សេងៗគ្នា ទោះជាកម្ពស់ផ្ទះដែលគេនិយមច្រើនជាងគេនោះ គឺមានចាប់ពី ១ ទៅ ៣ ម៉ែត្រ ដែលជាទូទៅ នេះជាកម្ពស់ខ្ពស់នៅតំបន់ដីកោះ និងនៅស្រុកសៀម ជាជាងនៅប្រទេសភូមា និងនៅឥណ្ឌូចិន ។ តែដោយឡែក ផ្ទះរបស់មេដឹកនាំប្រទេស និងពួកអភិជនត្រូវតែខ្ពស់ជាងរាស្ត្រសាមញ្ញ ។ បរមរាជវាំងមានកម្ពស់ខ្ពស់រហូតដល់ ៦ ម៉ែត្រនៅ មិនដាណាវ (Mindanao) ហើយកម្ពស់ ១២ ម៉ែត្រនៅប៉ែកខាងជើងនៃកោះស៊ូម៉ាត្រា (ដាំពែរ គ.ស.១៦៩៧ ទំ.២២៥ និងម៉ាហួន (Ma Huan ) គ.ស.១៤៣៣ ទំ. ១២៣ និងសូមប្រៀបធៀបឯកសាររបស់ឡាលូ-ប៊ែរ គ.ស.១៦៩១ទំ.១៦៥, ស៊ីម្ស គ.ស.១៨២៧ ទំ.២១៨, ដេវីស (Davis) គ.ស.១៦០០ ទំ.១៤៧ និងកាលិទទី (Carletti) គ.ស.១៦០៦ ទំ.៨៦) ។ នៅសតវត្សទី ១៦ និង១៧ មានតែប្រជាជនរស់នៅវៀតណាមខាងជើង ជ្វា និងបាលី នោះទេដែលបានចាប់ផ្តើមសាងសង់ផ្ទះផ្ទាល់ទៅនឹងដី ទោះបីជាដំបូងឡើយ ពួកគេក៏ប្រើប្រាស់សសរក្នុងការសាងសង់ផ្ទះរបស់ពួកគេដែរនោះក៏ដោយ (ធ្វីយែន គ.ស.១៩៣៤ ទំ.១៨៦ និងពីហ្គូដ (Pigeaud) គ.ស.១៩៦២ ទំ.ទី៥០៩) ។ នៅវៀតណាមខាងត្បូង និងពួកម៉ូលូកាន់ (Moluccans) នៅសម័យទំនើបប្រជាជននៅតែសាងសង់ផ្ទះផ្ទាល់ដីដោយប្រើសសរជាទំរដដែល ។ «ផ្ទះរបស់ប្រជាជននៅកូសាំងស៊ីន គឺបានសាងសង់យ៉ាងផ្ចិតផ្ចង់ ដោយទុកប្រឡោះខាងក្រោមដើម្បីឲ្យទឹកអាចហូរកាត់បានហើយដោយសារមូលហេតុនេះហើយ ទើបផ្ទះទាំងនោះត្រូវបានសង់នៅលើសសរធំៗ (រ៉ូដេស (Rhodes) គ.ស.១៦៥៣ ទំ.៤៤ និងសូមប្រៀបធៀបឯកសាររបស់ បូរី (Borri) គ.ស.១៦៣៣ ទំ.និងហ្គាល់វៅ (Galvao) គ.ស.១៥៤៤ ទំ.១០៥) ។ ទាំងនេះធ្វើឲ្យយើងងាយយល់ថា តើហេតុអ្វីបានជាប្រជាជនដែលនៅតំបន់ទីប្រជុំជន (ជាទីដែលដើមឈើធំៗត្រូវបានបាត់បង់មុនគេនោះ) បានចាប់ផ្តើមបន្ទាបផ្ទះរបស់គេមកសង់ផ្ទាល់លើដី ។

សរសេទម្រទាំងនោះក៏បានបង្កើតជារចនាសម្ព័ន្ធកណ្តាលមួយសម្រាប់ផ្ទះទាំងមូល ដោយដំបូងឡើយភ្ជាប់សរសេទាំងនោះទៅនឹងជើងសរសេរ រួចហើយទៅនឹងកម្រាល(រនាប) ជញ្ជាំង និងចុងក្រោយភ្ជាប់ទៅនឹងដំបូល (រូបទី ៧) ។ ក្តារបន្ទះត្រូវបានគេរៀបជាចន្លោះឲ្យឃ្លាតពីគ្នាដើម្បីឲ្យផ្ទះស្រាល និងស្រឡះ ។ «សូម្បីតែចំពោះ

*ពួកព្រីនស៊ីពល*(Principales) *(ពួកវីរជន ហ្វីលីពីន) ក៏គេមិនយកក្ដាបន្ទះមកក្រាលជារនាបផ្ទះដែរ ។ ព្រោះថាពួកគេអាចចំណាយពេលតិចតួចក្នុងការសម្អាត... មិនថាពេលមានទឹកកំពប់ហើយធ្វើឲ្យរនាបប្រលាក់កខ្វក់ មិនថារនាបផ្ទះមានកម្រាស់ក្រាស់ក៏ដោយ ក៏ទឹក និងភាពកខ្វក់ទាំងនោះងាយនឹងឲ្យគេសម្អាតបានដែរ ដោយសារតែកម្រាលផ្ទះមានទម្រង់ដូចជាចង្អើរគ្រើ ដែលអាចឲ្យទឹកហូរចេញបានយ៉ាងស្រួល» (អាល់ស៊ីណា* (Alcina) *គ.ស. ១៦៦៨ ទំ. ទី៣៨) ។ លើសពីនេះទៀតដោយសារតែគ្មានរណាជាឧបករណ៍ការច្រៀកឈើគឺជាការងារយ៉ាងលំបាក ជាពិសេសក្នុងការច្រៀកឈើហ៊ុបដោយប្រើពូថៅ និងការចាំងតម្រង់ដោយកាំបិត ទោះជា «ប្រណីតភាពនៃដំរៀកឈើដ៏រឹងមាំនោះពិតជាធ្លុះបញ្ជាំងពីការប្រឹងប្រែង និងការនឿយហត់របស់អ្នកកសាងទាំងនោះក៏ដោយ» (ដាំពែរ គ.ស. ១៦៩៧ ទំ. ២២៧) ។*




រូបគំនូស៦ ក ៖ ផ្ទះជនជាតិថៃដ៏សាមញ្ញមួយនៅក្នុងរដូវវស្សា



រូបគំនូស ៦ ខ៖ ទិដ្ឋភាពនៅភូមិ នៅប្រាសាទ ធន់បូរី (Thonburi ស្រុកសៀម) នៅវត្តសូវ៉ាន់ណារ៉ាម (Wat Suwannaram) យកពីគំនូរនៅដើមសតវត្សទី ១៩



រូបគំនូស ៧ ៖ ផ្ទះជនជាតិវិស័យ៉ាត់ ដ៏សាមញ្ញមួយ ដែលមានផ្ទះលើដើមឈើដែលប្រហែលជាប្រើជាជម្រុកស្រូវ ឬក៏ជាជម្រកពេលមានអសន្ត

លក្ខណៈរួមផ្សេងៗទៀតរបស់ផ្ទះប្រជាជននៅអាស៊ីអាគ្នេយ៍ ទី១គឺចង្ក្រានបាយដែលដាក់ផ្ទាល់នឹងក្តារក្រាលដែលជាទូទៅនៅផ្នែកខាងក្រោយនៃផ្ទះឬនៅកន្លែងស្ត្រី និងទី២ រានហាល ឬក៏បន្ទប់ផ្សេងៗសម្រាប់ទទួលភ្ញៀវដែលស្ថិតនៅខាងមុខផ្ទះ ។ ចង្ក្រានបាយ កន្លែងទទួលភ្ញៀវ ឬរានហាល ជាញឹកញាប់នៅទាបជាងកន្លែងដេកដែលស្ថិតនៅផ្នែកកណ្តាលនៃផ្ទះ (យោងតាមឯកសាររបស់ អាល់ស៊ីណា (Alcina) គ.ស. ១៦៦៨ IV.ទំ. ៣៨ និងឡាលូប៊ែរ គ.ស. ១៦៩១ ទំ. ៣២) ។សសរដែលនៅជួរកណ្តាលទ្រមេដំបូល មានលក្ខណៈពិសេសទាំងខាងជំនឿ និងខាងរចនាសម្ព័ន្ធ ហើយសម្រាប់ពិធីបូជា ឬសែនព្រេនផ្សេងៗ ញឹកញាប់ប្រព្រឹត្តទៅនៅតាមសសរណាមួយក្នុងចំណោមសសរទាំងនេះ (ង្វៀន(Nguyen) គ.ស. ១៩៣៤ ទំ. xii-xiv និង ១៧៩ និងតឺតុង (Turton) គ.ស. ១៩៧៨ ទំ. ១១៦–១៧) ។

សូម្បីតែអ្នកសង្កេតការណ៍ដំបូងគេខ្លះៗក៏យល់ថារចនាសម្ព័ន្ធក្នុងការសាងសង់ផ្ទះមានហេតុផលខាងជំនឿសាសនាផង និងភាពជាក់ស្តែងផង ទោះបីជានវិទ្យាសម័យថ្មីបានបង្ហាញឲ្យកាន់តែច្បាស់លាស់ណាស់ទៅហើយ ។ ពួកជនជាតិអឺរ៉ុបដែលមានចម្ងល់អំពីផ្ទះមួយជាន់ដែលសង់ខ្ពស់ពីដី ត្រូវបានគេពន្យល់អំពីសារៈសំខាន់ដ៏សក្តិសិទ្ធិនៃកម្ពស់ ។ ជនជាតិភូមាបានពន្យល់ទៅសាំងហ្គឺម៉ាណូ (គ.ស. ១៨១៨ ទំ. ១៦២) ថា «ជាការអាម៉ាស់ណាស់ដែលនៅក្រោម ឬទាបជាងអ្នកដទៃ ជាពិសេសទាបជាងស្ត្រី» ខណៈពេលដែលជនជាតិថៃបានប្រាប់ទៅ ឡា លូប៊ែរ (គ.ស. ១៦៩១ ទំ. ៣០) ថា ព្រះមហាក្សត្រ មិនត្រូវនៅទាបជាងប្រជារាស្ត្រទេ នៅពេលដែលព្រះអង្គជិះដំរីឆ្លងកាត់ប្រជារាស្ត្រទាំងនោះ (ទោះបីជាការពិតនោះ ព្រះអង្គនៅទាបជាងក៏ដោយ នេះតាមការសង្កេតរបស់ជនជាតិបារាំងរូបនេះ) ។ ការរៀបចំទៅតាមកម្ពស់ថ្នាក់នេះធ្វើឲ្យផ្ទះនីមួយៗក្លាយទៅជាលោកធាតុតូចៗដែលចែងថា ជាន់ទាបបំផុត ឬជាន់ផ្ទាល់ដី គឺសម្រាប់សត្វធាតុ ឬលាមកសំរាមជាដើម (ទោះបីជាជាទូទៅគេប្រើប្រាស់ជាន់នេះសម្រាប់កិច្ចការផ្ទះដូចជា តម្បាញ ក៏ដោយ) ។ នៅជាន់កណ្តាល គឺសម្រាប់មនុស្សរស់នៅ ដែលជាជាន់ថ្នាក់ដើម្បីចែកឲ្យដាច់រវាងជាន់សម្រាប់សាធារណៈ ឬការងារផ្សេងៗ និងជាន់សម្រាប់ធ្វើពិធីបូជា ឬសម្រាប់ដំណេក ។ ជាន់ដែលសំខាន់បំផុតនោះគឺមេដំបូលដែលជាទីអាស្រ័យនៃព្រះមេរសក្តិសិទ្ធិ និងជាទីកន្លែងសម្រាប់ពិធីសែនព្រេនឲ្យបុព្វការីជន (ង្វៀន គ.ស. ១៩៣៤ ទំ. ៤៧១ និងអឺរ៉ាំងតុង (Errington) គ.ស. ១៩៧៩ ទំ. ១៣)។ ជាធម្មតាគេបែងចែកផ្ទះជាជួរទៅតាមខ្សែអ័ក្សបូព៌ាបស្ចឹម ដែលមួយផ្នែកចែកជាពិសេសសម្រាប់ស្ត្រីហើយមួយផ្នែកទៀតរបស់បុរស (វ៉េស៊ីង (Wessing) គ.ស. ១៩៧៨ ទំ. ៥៣–៥៩, តឺតុង គ.ស. ១២៨ និងហីលតុន (Hilton) គ.ស. ១៩៥៦)។

កម្រណាស់ដែលផ្ទះសម្រាប់ស្នាក់នៅមានគំរូខុសពីផ្ទះឈើខ្ពស់ពីដីនោះ ។ ផ្ទះរបស់អភិជន និងអ្នកដឹកនាំប្រទេសគឺសង់ឡើងខ្ពស់ជាង ធំជាង និងធេងធាយជាងផ្ទះរបស់ប្រជាជនសាមញ្ញធម្មតា ក៏ប៉ុន្តែផ្ទះទាំងនោះធ្វើឡើងពីសម្ភារៈស្រដៀងគ្នាដែរ ។ អាគាររបស់ស្តេចស៊ុលតង់ នៅក្នុងវាំងអាចេនៅឆ្នាំ ១៥៩៩ «ត្រូវបានកសាងឡើងដូចអាគារផ្សេងទៀតដែរ ប៉ុន្តែមានកម្ពស់ខ្ពស់ជាងយ៉ាងច្រើន» (ដេវីស Davis គ.ស. ១៦០០ ទំ. ១៤៨) ។ រាជវាំងរបស់ស្តេចស៊ុលតង់ នៅទីឌ័រ (Tidore) គឺមានលក្ខណៈគួរឲ្យស្ញើចសរសើរណាស់ ដែលសង់លើសសរឈើចំនួន ៤៦(វ៉ាន់ ឌៃ ហាហ្គែន គ.ស. ១៦០៧ ទំ. ៣៨) ខណៈពេលដែល វិមានអារុង្គប៉ាឡាក់កា (Arung Palak ka) នៅបូន (Bone) មានសសរចំនួន ៩១ រីឯវិមាន ស៊ុលតង់ ម៉ាន់ស៊ួរ (Sultan Mansur)នៅម៉ាឡាកាវិញ មានសសរប្រហែល ៩០ និងមហាសាលនៃអាគាររាជធានីរបស់ភូមា នៅសតវត្សទី ១៨ មានសសរចំនួន ៧៧ (វ៉ាឡែនទីយីន Valentijn គ.ស. ១៧២៦ III ទំ. ១២២ សេយ្យារ៉ា ម៉េលាយូ (Sejarah Melayu) គ.ស. ១៦១២ ទំ. ៨៦–៨៧ និង ស៊ីមស៍ គ.ស. ១៨២៧ I ទំ. ១០៦)។ នៅទីក្រុង មីនជាណាវ ដំណាក់របស់ស្តេច ស៊ុលតង់ បានសង់ឡើងនៅលើ «សសរធំៗចំនួនប្រហែល ១៨០ ដើម

ដែលជារាជដំណាក់មានកម្ពស់ខ្ពស់ខ្ពាំងជាងអាគារធម្មតា ដោយមានជណ្ដើរដ៏ធំទូលាយសម្រាប់ឡើងទៅកាន់ដំណាក់នោះ» (ដាំពៀរ គ.ស. ១៦៩៧ ទំ. ២២៥) ។ ក្នុងឆ្នាំ ១៦៣៦ ជណ្ដើររបស់រាជវាំងក៏ជាលក្ខណៈពិសេសមួយផងដែរ ដែលសង់ឡើងនៅលើសសរឈើធំៗ នៅក្នុងប្រាសាទនៃតំបន់សមបាវពុយ នៅទីក្រុង ម៉ាកាសសារ ។ ជណ្ដើរនោះដូចជា «ស្ពានដ៏ធំវែងមួយ យ៉ាងស្អាត ដែលគេអាចឡើងជណ្ដើរនោះ ដោយជិះសេះ ឬដោយថ្មើរជើងក៏បាន (ផែនទីឆ្នាំ ១៩៣៨ នៅក្នុងឯកសាររបស់ រីដ (Ried) គ.ស. ១៩៨៣ ទំ. ១៤៥ និងសូមធ្វើការប្រៀបធៀបទៅនឹងឯកសាររបស់ ឡុងតារា-ប៊ីឡង់ហ្គូវ៉ា Lontara-bilangGowa ទំ. ៩២) ។

សំណង់សម្រាប់ការរស់នៅធម្មតា គឺមិនរឹងមាំ និងមិនស្ថិតស្ថេរបានយូរទេ ប៉ុន្តែសំណង់បែបសាសនាគឺ រឹងមាំ និងស្ថិតស្ថេរបំផុត ។ ដូចដែលយើងបានដឹងអំពីអាណាចក្រដ៏រុងរឿងនៃចក្រភពអង្គរ បាហ្គាន (Pagan) និង ប៊ូរ៉ូប៊ូដួរ (Borobodur) រួចមកហើយ ការប្រើបច្ចេកទេសសាងសង់អាគារអំពីថ្ម ឬដុំឥដ្ឋមិនមែនជារឿងប្លែកសម្រាប់ប្រជាជននៅអាស៊ីអាគ្នេយ៍នោះទេ យ៉ាងហោចណាស់ក៏នៅពេលដែលប្រព័ន្ធសាសនានយោបាយរបស់ពួកគេតម្រូវឲ្យសាងសង់ប្រាសាទមិនចេះចប់មិនហើយ ដើម្បីបញ្ជាក់ពីកិត្តិសព្ទរបស់ព្រះរាជាអង្គណាមួយ និងកិត្តិសព្ទរបស់ព្រះ ឬទេវតាដែលព្រះរាជអង្គនោះ និងទេវតានេះត្រូវគេទទួលស្គាល់ថាបុគ្គលតែមួយ ។ សាសនាអ៊ីស្លាមនៅភាគខាងត្បូង និងព្រះពុទ្ធសាសនា ថេរវាទ នៅភាគខាងជើងមានអាទិភាពថ្មី ខណៈដែលតួនាទីរបស់ពាណិជ្ជកម្មអន្តរជាតិដែលកំពុងរីកចម្រើន បានធ្វើវិទ្ធង្សនាទៅលើអធិបតេយ្យដ៏អស្ចារ្យនោះ ដែលបានកែប្រែធនធានដ៏លើសលុបឲ្យទៅជារាជប្រាសាទសាសនាជាច្រើន ។ រចនាបថនៃសំណង់ប្រាសាទបានផ្លាស់ប្តូរយ៉ាងអស្ចារ្យដែលនៅសតវត្សទី ១៧ បានធ្វើឲ្យ «ប្រវត្តិសាស្ត្រដ៏ចំណាស់មួយរបស់ជនជាតិសៀមលើកឡើងថា អង្គរគឺជាប្រាសាទដ៏ល្អឆើតឆតខ្ទោះដែលមនុស្សលោកមិនអាចធ្វើបាន ។ ដូច្នេះពួកគេនិយាយថាមានទេវតាបានចុះមកជួយកសាងទីក្រុងដ៏រុងរឿងនេះនៅក្នុងប្រទេសកម្ពុជា» (វ៉ាន់ វីលីយៀត (van Vliet) គ.ស. ១៦៤០ ទំ. ៦០) ។

ប្រាសាទ និងចេតិយនៅតែបន្តកសាងឡើងអំពីឥដ្ឋ និងថ្មដដែលទោះបីជាបរិមាណនៃការប្រើប្រាស់តិចជាមុនក៏ដោយ ។ កំពូលប្រាសាទដែលស្រោបមាសដែលរក្សាទុកនូវសារីរិកធាតុរបស់ព្រះពុទ្ធ គឺជាមហិច្ឆតាដ៏ធំបំផុតក្នុងការសាងសង់ប្រាសាទរបស់ប្រជាជនអាស៊ីអាគ្នេយ៍នាសម័យនោះ ខណៈពេលដែលទីក្រុងអយុធ្យា (រូបភាពទី ៨) ភីគូ(Pegu) និងរាជធានីព្រះពុទ្ធសាសនាផ្សេងៗទៀតបានរចនាប្រាសាទជាច្រើនពីឥដ្ឋ និងបាយអ និងដំបូលក្បឿងដ៏ប្រណីត (ហ្វ្រេដេរីស៊ី (Fredieric) គ.ស. ១៥៨១ ទំ. ២៤៩, ស្សូតែន (Schouten ) គ.ស. ១៦៣៦ ទំ. ១២៤ និងឡា លូប៊ែ គ.ស. ១៦១៩ ទំ. ៣១-៣២) ។ វិហារអ៊ីស្លាមជាទូទៅកសាងពីឈើ និងប្រក់ស្បូវ ប៉ុន្តែវិហារធំៗនៅក្រុងម៉ាឡាកា និងនៅក្រុងអាចេ យ៉ាងហោចណាស់ក៏គ្រឹះ និងរបងខាងក្រៅធ្វើអំពីថ្ម និងបាយអដែរ (អ៉ាល់បុយគ្វែគ (Albuquerque) គ.ស. ១៥៥៧ III ទំ. ១៣៦ និងដាំពែរ គ.ស. ១៦៩៩ ទំ. ៩០) ។ ដំបូលនៃវិហារអ៊ីស្លាម និងចេតិយសក្តិសិទ្ធិជាច្រើននៅជ្វា នៅតែបន្តប្រក់ក្បឿង ហើយរចនាបថសំណង់ដែលធ្វើពីឥដ្ឋនៃសម័យកាល ម៉ាចាប៉ាហ៊ិត (Majapahit) នៅតែត្រូវបានគេបន្តរយកមកប្រើប្រាស់ដូចជា ធ្វើខ្លោងទ្វារចូល ប៉មព្រះវិហារ និងរបងខាងក្រៅ (វ៉ាន់ ណែក (van Neck) គ.ស. ១៥៩៩ ទំ. ៨៧) ដូចដែលអាចមើលឃើញនៅតាមទីក្រុង ស៊ីរីប៊ុន (Cirebon) ដឺម៉ាក់ (Demak) គូឌូស (Kudus) អាំពែល (Ampel) និង សិនដាំងឌូវ័រ (Sendangduwur) (សូមមើលរូបភាព ទី ១០ក -១០ខ) ។

ទោះបីជាសំណង់ទាំងនេះ និងសំណង់ផ្សេងទៀត បានសឲ្យឃើញនូវការបន្តក្បាច់រចនាសំណង់ពីអតីតហិណ្ឌូ-ជ្វាក៏ដោយ ក៏វិហារអ៊ីស្លាមនៅអាស៊ីអាគ្នេយ៍ក្នុងសតវត្សទី ១៦ និង១៧ មានទម្រង់រចនាបថមួយផ្សេងពីនេះដែល



រូបទី ៨ ៖ វិហារនៃវត្ត ណាប្រ៉ាម៉ែន Na Phra Men នៅអយុធ្យា ដែលជាអគារមួយក្នុងចំណោមអគារបព្វជិតបុរាណនៃសម័យអយុធ្យា

*ជាពិសេសទម្រង់រចនាបថទីក្រុងអាចេ នេះស្រដៀងទៅនឹងរចនាបថនៅ ម៉ាលូគូ នៅតំបន់ភាគបស្ចិម និងម៉ាន់ដឹណាវ នៅភាគបូព៌ា ។ អាគារសំខាន់មានរាងបួនជ្រុង ដែលជាញឹកញាប់បានបន្ថែមរានហាល* (serambi) *ជញ្ជាំងពន្ទឹ និងសសរឈើធំៗ (ជាធម្មតាមានចំនួនបួន) នៅផ្នែកខាងកើតអាគារ ដើម្បីទ្រដំបូលប្រកស្បូវជាច្រើនជាន់នោះ (សូមមើលរូបទី ៩ក និង ៩ខ) ។ ជាធម្មតាតែងតែមានជញ្ជាំងថ្មដ៏រឹងមាំ ហ៊ុមពទ្ធទីធ្លាទាំងមូល ។ ដើមកំណើតនៃសំណង់នេះត្រូវបានគេយកមកពិភាក្សាវែកញែក ជាពិសេសថាតើដំបូលប្រកស្បូវជាច្រើនជាន់នោះ ធ្វើតាមពួកហិណ្ឌូ-ជ្វា ដែលតំណាងឲ្យភ្នំព្រះសុមេរុ ដូចដែលយើងអាចមើលឃើញនៅក្រុងបាលីនោះដែរទេ (ហ្គូលីយុត* Guillot *គ.ស. ១៩៨៥ ទំ. ៨-១១ និងសាន់ដ្រាសាស្មីតា* (Candrasasmita) *គ.ស. ១៩៨៥ ទំ. ២០៤-២០៦) ។ ការពិភាក្សានោះក៏បានចោទសួរថាតើរចនាបថនោះបានមកពីស្ថាបនិកជនជាតិចិនអ៊ីស្លាម ដែលគេគិតថាមានឥទ្ធិពលយ៉ាងខ្លាំងនៅ*

សតវត្សទី ១៥ ទៅលើ ក្រុងដឺម៉ាក និងចាប៉ារ៉ា (Japara) (ស្លាមិតមុលយ្យាណា (Slametmulja) នា គ.ស. ១៩៧៦ ទំ. ២៤៤-២៤៧ និងឌឺ ហ្គ្រាវ និង ពីហ្គូដ (de Graaf & Pigeaud) គ.ស. ១៩៨៤ ទំ.២៨-២៩ និង ១៧៩-១៨០) ។ ស្ថាបនិកជនជាតិចិនប្រហែលជាបានជួយកសាងវិហារអ៊ីស្លាមធំៗជាច្រើន ប៉ុន្តែរចនាបថវិហារអ៊ីស្លាមស្រដៀងនេះនឹងមិនអាចត្រូវបានគេយកមកប្រើប្រាស់នៅតាមបណ្តាប្រជុំកោះ (Archipelago) នៅសតវត្សទី ១៦ នោះទេ ប្រសិនបើរចនាបថនោះមិនរួមបញ្ចូលគ្នាជាមួយរចនាបថ និងសាសនាបុរាណជាងនេះទេនោះ ។

យ៉ាងណាក៏ដោយវត្តមានដ៏ច្រើននៃជនជាតិចិន ជនជាតិអាស៊ីប៉ែកខាងលិច និងជនជាតិអឺរ៉ុបនៅតាមបណ្តាកំពង់ផែនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្រោយឆ្នាំ ១៥០០ បានពង្រីកនូវការប្រើប្រាស់ឥដ្ឋជាសម្ភារៈសំណង់ ។ វិហារអ៊ីស្លាមដ៏សំខាន់មួយនៅ ប៉ាតានី បានកសាងឡើងដោយកម្មករជនជាតិចិននៅចុងសតវត្សទី ១៦ (វ៉ាន់ ណើក គ.ស. ១៦០៤ ទំ. ២២) ហើយនេះគឺជាលក្ខណៈលើកលែងដែលជា៖ «សំណង់អគារសង់អំពីឥដ្ឋដ៏ធំសម្បើមអស្ចារ្យ ដែលផ្ទៃខាងក្នុងស្រោបទៅដោយមាស ទ្វារដោយសសរដ៏ស្រស់ស្អាត ដែលបង្កើតមកជាមួយនូវលក្ខណៈពិសេសជាច្រើន» (នីវហូវ (Nieuhoff) គ.ស. ១៦៦២ ទំ. ២១៨) ។ អ្នកដឹកនាំជាតិសៀមនៃសតវត្សទី ១៧ មានអាគារព្រះរាជវាំងដែលសាងសង់ពីឥដ្ឋជាច្រើន ដែលប្រហែលជាសំណូមពររបស់ជនបរទេស ទោះបីជាការសាងសង់បែបនេះមិនមានភាពងាយស្រួលដូចការសាងសង់ដោយប្រើឈើដែលពួកគេធ្លាប់ប្រើប្រាស់ពីមុនមកនោះក៏ដោយ (ឡា លូប៊ែរ គ.ស. ១៦៩១ ទំ. ៣១) ។ នៅពាក់កណ្តាលសតវត្សទី ១៧ អ្នកដឹកនាំប្រទេស និងពួកអភិជនជាន់ខ្ពស់ ទាំងនៅបាន់តិន (Banten) និងអាចេ ហាក់ដូចជាបានសាងសង់មហាគ្រឹះដ៏រឹងមាំរបស់ពួកគេអំពីឥដ្ឋដែរ (ហ្វ្រីក Fryke គ.ស. ១៦៩២ ទំ. ៦០ និងរបស់ ដឺ ហ្គ្រាហ្វត៍ (de Graaft) គ.ស. ១៧០១ ទំ. ១២-១៣) ។ គេឃើញថា ថ្ម និងបាយអត្រូវបានប្រើប្រាស់បន្ថែមទៀតយ៉ាងប៉ិនប្រសប់ នៅក្នុងសួនកម្សាន្តតាមភ្នំ និងតាមសមុទ្រយ៉ាងច្រើន ដែលដាក់ខ្ទែងសម្រាប់ព្រះមហាក្សត្រនៅអាស៊ីអាគ្នេយ៍ធ្វើសក្ការៈ និងលំហែព្រះកាយ (ប្រាក់អែល (Brakel) គ.ស. ១៩៥ ទំ. ៦០-៦១ របស់ឡំបាដ (Lombard) គ.ស. ១៩៧៤ របស់ឌុម៉ាកៃ (Dumarcay) គ.ស. ១៩៨២ និងរបស់ អេរេដៀរ (Eredia) គ.ស. ១៦១៣ ទំ. ២៤-២៥)។

គ្រឿងសម្រាប់ប្រក់ដំបូលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាងឥដ្ឋ ។ នៅសម័យអង្គរ អភិជនដ៏ស្តុកស្តម្ភបានប្រើប្រាស់គ្រឿងទាំងនេះតាំងពីសតវត្សទី ១៣ មកម្ល៉េះ (ជីវ តាក្វាន់ គ.ស. ១២៩៧ ទំ. ១២-១៣) ហើយការប្រើប្រាស់បែបនេះបានបន្តនៅក្នុងរាជវាំងកម្ពុជា ថៃ និងភូមា ។ ដំបូលរបស់រាជវាំង ម៉ាស់លីហៃ (Mahligai) នៅម៉ាឡាកាបានរចនាដោយទង់ដែង និងសំណប៉ាហាំងផ្ទេកផ្ទាំង (សេរ៉ាច្យា ម៉េឡៃយូ (Sejarah Melayu) គ.ស. ១៦១២ ទំ. ១៣៨) ។

ប្រសិនបើក្នុងពេលមានជីវិតព្រះមហាក្សត្រ ប្រាថ្នាគង់នៅវិមានធ្វើអំពីឈើដ៏ត្រជាក់ដែលមានផាសុកភាពនោះនៅពេលដែលសោយទិវង្គត ពួកគាត់ក៏រំពឹងថាបានស្នាក់នៅក្នុងប្រាសាទដែលធន់នៅបានយូរអង្វែង ។ នៅម៉ាឡាកា ពួកជនជាតិព័រទុយកាល់អាចរកថ្មបានគ្រប់គ្រាន់ដើម្បីសាងសង់បន្ទាយយ៉ាងធំឈ្មោះថា អាហ្វ៉ាម៉ូស្សា (A Famosa) ដោយរុះរើ «ផ្នូរបុរាណខ្លះៗរបស់ព្រះមហាក្សត្រដែលបានសោយទីវង្គតមកហើយនោះ» និងរុះរើជញ្ជាំងនិងគ្រឹះនៃវិហារអ៊ីស្លាមជាច្រើនផងដែរ (អាល់ប៊ូឃែក (Albuquerque) គ.ស. ១៥៥៧ ទំ. ១៣៦) ។ វ៉ាន់ ណើក(គ.ស. ១៥៩៩ ទំ. ៨៧) បានរកឃើញថា ផ្នូររាជវង្សធ្វើអំពីថ្ម ស្ថិតនៅជិតព្រះវិហារអ៊ីស្លាម ដែលគាត់ពោលថា «គឺជាអាគារដ៏ស្កឹមស្កៃ និងរឹងមាំ ដែលខ្ញុំធ្លាប់ឃើញនៅបានតង់ (Banten)» ។



រូបភាព ៩ ក ៖ ទេសភាពនៃព្រះវិហារអ៊ីស្លាមដ៏ធំមួយនៃក្រុង អាឆេ គូសនៅ គ.ស.ប្រមាណ ១៦៥០ ។ រូបភាព ទី ២៤ គឺជាគំនូសសម័យទំនើបរបស់ព្រះវិហារអ៊ីស្លាមដូចគ្នានេះ។



រូបភាព ៩ ខ ៖ ព្រះវិហារអ៊ីស្លាមអាឆេបុរាណមួយ (នៅសូម៉ាត្រា) ថតនៅចុងសតវត្សទី ១៩

*ការប្រើប្រាស់ជាទូទៅនៃសម្ភារៈដែលឆាប់ពុកផុយដូចជា ឈើ ស្បូវ និងស្លឹកត្នោត សម្រាប់ផ្ទះស្នាក់នៅ គឺបង្ហាញពីការចូលចិត្តធម្មជាតិ ភាពត្រជាក់ត្រជុំ និងខ្យល់អាកាសបរិសុទ្ធ ។ យ៉ាងណាមិញ អ្នកខាងក្រៅជាច្រើនបាននិយាយថាទម្លាប់បែបនេះ គឺជាលទ្ធផលនៃបម្រាមទៅលើអាគារដែលសង់អំពីថ្ម ឬឥដ្ឋដោយព្រះមហាក្សត្រនៅអាស៊ីអាគ្នេយ៍ ។ រាជវាំងដែលមានឥទ្ធិពលខ្លាំងជាងនេះ ប្រហែលជាចង់រក្សានូវរចនាបថសម្រាប់ព្រះរាជវង្ស ។ អ្នកដឹកនាំអ៊ីស្លាមដំបូងបង្អស់នៅម៉ាឡាកា បានហាមឃាត់រាល់សំណង់អគារទាំងអស់ លើកលែងតែអាគាររបស់រាជវង្ស (សេច្បារ៉ា ម៉ាឡៃយូ គ.ស.១៦១២ ទំ.៥៤) ខណៈពេលដែលនៅអយុធ្យាមានតែអាគាររាជវង្ស ឬក៏សំណង់អគារសាសនាតែប៉ុណ្ណោះដែលអាចបិទពណ៌ ឬលាបពណ៌បាន (វ៉ាន់ វីល្បីត គ.ស. ១៦៣៦ ទំ. ៨៣) ។ ច្បាប់ទម្លាប់របស់ប្រទេសភូមានៅសតវត្សទី ១៨ បានកំណត់ថា គ្រប់ឋានៈនៅក្នុងសង្គមត្រូវសាងសង់អគារទៅតាមការដាក់បញ្ញត្តិ ដោយដំបូលប្រក់ក្បឿងគឺ សម្រាប់អ្នកមានឋានៈខ្ពស់ក្នុងសង្គម (សង់ហ្គឺម៉ាណូ គ.ស.១៨១៨ ទំ. ១៦១ និងរបស់ ស៊ីមស៍ គ.ស. ១៨២៧ I ទំ. ២៨២) ។ ហើយការអនុវត្តច្បាប់ទម្លាប់បែបនេះហាក់ដូចជាមាននៅប្រទេសកម្ពុជា តាំងពី ៥ សតវត្សមុននេះមកម្ល៉េះ (ជីវតាក្វាន់ គ.ស.១២៩៧ ទំ.១២-១៣) ។ ប៉ុន្តែអាចមកពីការផ្ទាញ់ផ្ទាលរបស់ជនជាតិអឺរ៉ុបដែលធ្វើឲ្យមានបម្រាមមិនឲ្យនរណាម្នាក់អាចសាងសង់អគារធ្វើអំពីសម្ភារៈដែលអាចស្ថិតស្ថេរបានយូរបាន ក្រៅពីព្រះមហាក្សត្រនោះ ។*

*មុនឆ្នាំ ១៦០០ អ្នកអង្កេតការជាច្រើនបានកំណត់ជាឯកច្ឆន្ទថា ទោះបីជាសំណង់របស់ប្រជាជនធម្មតាទាំងអស់ គឺសាងសង់ពីសម្ភារៈឆាប់ពុកផុយក៏ដោយ ក៏អ្នកជំនួញនៅក្នុងទីក្រុងបានសាងសង់ឃ្លាំងទំនិញរបស់ពួកគេពីឥដ្ឋដែរ ដើម្បីការពារទំនិញរបស់ពួកគេពីភ្លើងឆេះ ។ ម៉ា ហួន* (Ma Huan) *(គ.ស.១៤៣៣ ទំ. ៨៧) បានសម្គាល់ពីជនជាតិជ្វាថា «រាល់គ្រួសារនីមួយៗសុទ្ធតែមានឃ្លាំងផ្ទុកទំនិញមួយធ្វើពីឥដ្ឋនៅក្រោមដី ដែលមានកម្ពស់ពី ៣ ទៅ ៤* ch'ih *(ប្រមាណពី ៩៣ ទៅ១២០ សង់ទីម៉ែត) ។ នៅក្នុងឃ្លាំងនេះ ពួកគេផ្ទុកនូវសម្ភារៈផ្ទាល់ខ្លួនរបស់គ្រួសារ ហើយពួកគេរស់នៅពីលើឃ្លាំងនេះ» ។ ទាំងនេះគឺជាសម្អាងសម្រាប់ឃ្លាំងដែលកប់នៅក្នុងដីនៅប្រទេសម៉ាឡេ ដែលគេហៅថាហ្គូដាង* (gudang) *ហើយដែលពាក្យនេះហៅជាភាសាអង់គ្លេសថា ហ្គូដោន* (godown) *(មានន័យថា ចុះក្រោមទៅក្នុងដី) ។ ពួកជនជាតិព័រទុយហ្គាល បានសង្កេតទៅលើឃ្លាំងទាំងនេះនៅម៉ាឡាកា និងនៅកំពង់ផែនៅភូមានៅដើមសតវត្សទី ១៦ ដែលថា ÷ «ហ្គូដូស* (Gudoes) *គឺជាសំណង់ក្រោមដីដែលពួកឈ្មួញសាងឡើងដើម្បីរក្សាទុកកំណាត់ដែលនាំមកពីកូរ៉ូម៉ង់ដែល* (Coromandel) *ឲ្យជៀសផុតពីភ្លើងឆេះ» (អេរេដៀរ គ.ស.១៦១៣ ទំ. ៣២ ។ សូមប្រៀបធៀបឯកសាររបស់ បារ៉ូស៍* (Barros) *គ.ស.១៥៦៣* II.*ទំ.* ii *និង ៥៥ អាល់ប៊ូហ្កែក គ.ស.១៥៥៧ ទំ. ១២៧, ហ្វ្រិជីរីស៊ី គ.ស.១៥៨១ ទំ. ២៤៤-២៤៥ និងប៊ូឈុន* (Bouchon) *គ.ស.១៩៧៩ ទំ. ១៤១) ។ នៅបាតង់ កំលុងគ.ស. ១៦០០ អ្នកជំនួញធំៗនៅតែបន្តប្រើអុដានង សម្រាប់ផ្ទុកទំនិញរបស់ពួកគេដដែល ខណៈពេលដែលសំណង់នៅតាមតំបន់ក្នុងទីក្រុងបានសាងសង់ឡើងភាគច្រើនអំពីឥដ្ឋទៅហើយ (ស្កត់* (Scott) *គ.ស.១៦០៦ ទំ. ១៦៩-១៧០ និងលូដូវីស្គស៍ គ.ស.១៥៩៨ ទំ. ១០៨) ។*



រូបភាពទី ១០ ក ៖ ផ្នូរនៅសតវត្សទី១៦ របស់ សូណង់ ហ្គីរី (Suna Giri) នៅលើភ្នំសក្តិសិទ្ធិតូចមួយនៅជិតហ្គ្រេសឹក (Gresik) នៅជ្វា (Java)។ រូបនេះគូសព្រាងដោយខ្មៅដៃតាំងពី គ.ស. ១៨៤០ ។

*យ៉ាងណាក៏ដោយ អ្នកជំនួញអឺរ៉ុបបានព្យាយាមជារឿយៗដើម្បីពង្រីកឃ្លាំងតូចៗដែលមិនមានបន្ទួចទាំងនេះឲ្យទៅជាបន្ទាយដែលមិនគ្រាន់តែអាចការពារភ្លើងឆេះបានប៉ុណ្ណោះនោះទេ ថែមទាំងអាចការពារពីការវាយប្រហារផ្សេងៗបានទៀតផង ។ អ្នកដឹកនាំនៅអាចេ និងបាតង់ ដំបូងឡើយ បានអនុញ្ញាតឲ្យពួកអង់គ្លេស និងហូឡង់ទិញឬសាងសង់ gudang តាមបែបជាលក្ខណៈចិត្តធម៌ ដូចដែលពួកគេឲ្យពួក ពរ័ទុយហ្គាលធ្វើយ៉ាងដូច្នោះដែរ ។ ពួកហូឡង់ បានព្យាយាមសាងសង់ឃ្លាំង gudang ធំជាងនេះមួយនៅក្នុង គ.ស. ១៦០៤ «ឲ្យមានលក្ខណៈសមស្របសម្រាប់ធ្វើជាបន្ទាយនៅពេលដែលត្រូវការ» ដែលបំណងសាងសង់នេះបានធ្វើឲ្យមានការសង្ស័យយ៉ាងខ្លាំងពី តំបន់ បាតង់ (វ៉ាវីចក្ខ៍ (Warwijck) គ.ស. ១៦០៤ ទំ. ៥៣ ។ សូមប្រៀបធៀបឯកសាររបស់ ឡឺមីត (L'Hermite) គ.ស. ១៦១២ ទំ. ៣៨៤) ។ ពួកហូឡង់ទទួលបានជោគជ័យច្រើនជាងនៅតំបន់ជិតខាង ចាកាតា (Batavia) ជាតំបន់ដែលពួកគេទទួលបានការអនុញ្ញាតដើម្បីសាងសង់សំណង់ពីរជាន់ធ្វើអំពីថ្ម នៅគ.ស.១៦១៥ ហើយដែលបានប្រែក្លាយតំបន់នេះទៅជាបន្ទាយការពារសត្រូវដោយគ្មានការអនុញ្ញាតនៅគ.ស. ១៦១៨ ម៉ាស់សែលម៉ង់ (Masselman) គ.ស. ១៩៦៣ ទំ. ៣២១-៣២២ និងទំ. ៣៦០-៣៨៥) ។ ស៊ុល់តង់ អាហ្គូង (Sultan Agung) អ្នកដឹកនាំដ៏ខ្លាំងក្លាជាងគេមួយរូបនៅ*



រូបភាពទី ១០ខ ៖ ព្រះវិហារអ៊ីស្លាម សួរ៉ាការតា ដែលជាគំនូសព្រាងដោយខ្មៅដៃនៅគ.ស. ១៨៧៤

*ដ្វា បានយល់ឃើញថា «តំបន់ច្បាកាត្រា មានបន្ទាដាប់ដើង ដែលតម្រូវឲ្យដកចេញទាំងឈើចាប់ ពីព្រោះភ័យក្លាច ថាតំបន់ទាំងមូលនឹងមានគ្រោះថ្នាក់ ។ បន្ទានេះគឺ ÷ ប្រាសាទរបស់ពួកហូឡង់ ដែលឥឡូវនេះបានហ៊ុមពទ្ធពួកគេ ហើយនោះ(តាមរយៈការស៊ីសំណូក) ដែលពួកគេមិនចាត់ទុកតំបន់នេះថាជាព្រះមហាក្សត្រ ឬក៏ជាប្រទេសរបស់ គាត់នោះទេប៉ុន្តែបែជាចាត់ទុកថាជាតំបន់អ្នកប្រឆាំងទៅវិញ (លើកឡើងនៅក្នុងឯកសាររបស់ ព្រីង (Pring) គ.ស. ១៦១៩)» ។ នៅក្នុងព្រឹត្តិការណ៍នោះ ពួកហូឡង់ មិនអាចបញ្ឈាក់បានទេ សូម្បីតែដើម្បីឲ្យ ស៊ុល់តង់ អាហ្គុង ចុះចេញ ឬក៏បន្តគ្រប់គ្រងប្រទេសតទៅទៀត ។ បញ្ហានោះគឺថា គ្មានអ្នកដឹកនាំប្រទេសណាមួយធ្វើខុសម្តងហើយម្តងទៀត នោះទេ ។ ក្រោយមក ពួកអង់គ្លេសនៅបាតង់ បានទទួចត៉វ៉ាថា រដ្ឋាភិបាល ស៊ុល់តង់ (Sultan) «មានភាពភ័យខ្លាច នឹងឲ្យពួកយើង(ពួកអង់គ្លេស) សាងសង់ផ្ទះថ្មី ដើម្បីចងចាំនូវការចូលមកដល់ដំបូងរបស់ពួកហូឡង់ មកក្នុងតំបន់ ច្បាកាត្រា លុះត្រាណាពួកយើងសាងសង់ផ្ទះម្ខាងអំពីឥដ្ឋ និងម្ខាងទៀតអំពីឈើហ៊ុប»(វីលលូប៊ី (Willoughby)គ.ស. ១៦៣៦) ។ ដូចគ្នានេះដែរនៅម៉ាកាសារ(Makarssar) ពួកព័រទុយហ្គាល់ និងពួកអង់គ្លេសមិនត្រូវអនុញ្ញាតិឲ្យសាងសង់ សំណង់ធ្វើអំពីថ្ម «ដែលដាក់បន្តប់លើគ្នា» (បុកសឺរ គ.ស. ១៩៦៧ ទំ. ៣០) ឬសូម្បីតែការប្រេកក្បឿងនៅលើដំបូល ក៏ត្រូវបានគេហាមឃាត់ដែរ (រោងចក្រម៉ាកាសារ គ.ស. ១៦៥៩) ។ នៅប៉េ៉រ៉ាក (Perak) ពួកហូឡង់បានព្យាយាមកសាង*

*សង់សំណង់ធ្វើអំពីថ្មនៅគ.ស.១៦៥១ ដែលបានធ្វើឲ្យមានការខឹងសម្បាយ៉ាងខ្លាំង និងបានបណ្ដាលឲ្យជនជាតិហូឡង់ចំនួន ២៨ នាក់ ត្រូវបានគេសម្លាប់នៅទីនោះ (បេ. អង់ដាយ៉ា* (B. Andaya) *គ.ស. ១៩៧៩ ទំ. ៤៦) ។*

នៅពេលដែលហេតុការណ៍បែបនេះបានជាមេរៀនសម្រាប់អ្នកដឹកនាំនៅអាស៊ីអាគ្នេយ៍ហើយនោះ នេះក៏ជាមេរៀនសម្រាប់ប្រជាជនព្រមទាំងជនបរទេសផ្សេងទៀតផងដែរ ។ តាមពិតទៅ ឲ្យតែគ្រួសារ ឬក៏សហគ្រាសអ្នកជំនួញណាប្រលូកជាមួយនឹងព្រឹត្តិការណ៍ក្នុងស្រុក នៅពេលនោះពួកគេនឹងទទួលបាននូវការទុកចិត្តតិចជាងមុនក្នុងការបង្កើតជារបាំងការពារដ៏រឹងមាំមួយ ។

*នៅក្នុងសតវត្សទី ១៨ អ្នកជំនួញបរទេសនៅភូមាមានពេលខ្លះត្រូវបានអនុញ្ញាតឲ្យសាងសង់សំណង់ធ្វើអំពីឥដ្ឋ ប៉ុន្តែអ្នកអភិជនភូមាមិនដែលត្រូវបានគេអនុញ្ញាតនោះទេ ។ ទង្វើបែបនេះគឺដើម្បីធានាថា «ប្រសិនបើមានករណីក្បត់ជាតិ ឬក៏ឧក្រិដ្ឋកម្មណាមួយ ឧក្រិដ្ឋជននឹងមិនមានទីទ្រនង់ដើម្បីលាក់ខ្លួនពួនអាត្មាឡើយ» (ហាមីលតុង* (Hamilton) *គ.ស.១៧២៧ ទំ.២៦, ស៊ីមស៍ គ.ស.១៨២៧* II *ទំ. ១១–២១ និង ១០០ និងសង់ហ្គឺម៉ាណូ គ.ស.១៨១៨ ទំ. ១៦២ ផងដែរ) ។ ប្រសិនបើយើងជឿទៅលើ ប៊ូលីយ៉ូ* (Beaulieu) *ដែលបានកត់ត្រានូវព្រឹត្តិការណ៍ដែលកើតឡើង ៣០ ឆ្នាំក្រោយមកនោះមានសេចក្ដីថា បម្រាមដែលនៅលើសំណង់អចិន្ត្រៃយ៍នៅ ក្រុងអាចេនោះ គឺកើតឡើងចេញពីក្រុមរាជវង្សមួយក្រុមដែលធ្វើការវាយប្រឆាំងទៅនឹងពួកជំនួញអភិជនមានអំណាចដែលបានត្រួតត្រាទៅលើតំបន់ទីក្រុងរហូតដល់គ.ស.១៥៨៩ ។ ពួក អ័រ៉ាំងកៃយ៉ា* (Orangkaya)*ទាំងនេះដែលគេចោទថាយករដ្ឋាភិបាលស៊ាល់តង់ជាឧបករណ៍លេងសើចរបស់ពួកគេនោះមាន «គេហដ្ឋានដ៏ធំទូលាយ យ៉ាងស្រស់ស្អាត ពោរពេញទៅដោយសុវត្ថិភាព ដោយមានកាំភ្លើងធំដាក់នៅមាត់ទ្វាររបស់ពួកគេថែមទៀតផង» ។ អ្នកដឹកនាំថ្មីម្នាក់ឈ្មោះអាល់លូដដាំងរីយ៉ាត់ស្យា អាល់ម៉ូកាមីល* (Alaud-din Riayat Shah al-Mukammil) *(១៥៨៩–១៦០៤) បានសម្លាប់ពួកអឺរ៉ុបទាំងនោះដោយប្រើកលល្បិចដ៏ល្អមួយ ។ បន្ទាប់មក «គាត់បញ្ជាឲ្យកម្ទេចផ្ទះប្រមូលយកកាំភ្លើងធំ សព្វាវុធ និងគ្រឿងសម្ភារិមយ៉ាងច្រើនរបស់ពួក* Orangkaya *ដែលត្រូវបានគេសម្លាប់នោះ យកទៅទុកនៅក្នុងប្រាសាទរបស់គាត់ ។ ហើយគាត់បានដាក់បម្រាមដល់មនុស្សរាល់គ្នា មិនឲ្យសាងសង់ផ្ទះធ្វើអំពីថ្ម មិនឲ្យមានកាំភ្លើងធំនៅក្នុងផ្ទះ ឬប្រឡាយសម្រាប់ការពារទាំងនៅក្នុង និងនៅក្រៅផ្ទះនោះឡើយ... គាត់បានផ្ដល់គំរូផ្ទះដែលគួរតែសាងសង់សម្រាប់អនាគតដែលផ្ទះនោះមានតែមួយជាន់ទេ ដោយមានឈើក្រងធ្វើជាជញ្ជាំង ដូចដែលផ្ទះនាពេលបច្ចុប្បន្ននេះអ៊ីចឹងដែរ» (ប៊ូលីយ៉ូ គ.ស. ១៦៦៦ ទំ. ១១០–១១២) ។ ទៅតាមភាពជាក់ស្ដែងវិញ ការផ្លាស់ប្ដូររចនាបថក្នុងការសាងសង់នោះមិនមែនជារឿងសាមញ្ញ និងអាចធ្វើឡើងយ៉ាងឆាប់រហ័សនោះឡើយ ពីព្រោះថាផ្ទះភាគច្រើនមានលក្ខណៈធម្មតា និងអចិន្ត្រៃយ៍ ។ ទោះបីយ៉ាងណាក៏ដោយ ដំណើររឿងរបស់លោក ប៊ូលីយ៉ូបានបន្ថែមការចាប់អារម្មណ៍បន្ថែមទៀតដែលថា ការអនុវត្តនៃការសាងសង់អគារការពារចំបាំងដោយពួកអឺរ៉ុបដ៏កឃ្លើនទាំងនោះ (ហើយក៏ប្រហែលជាពួកទួគី* (Turks) *ហ្គូចេរ៉ាទីស* (Gujeratis) *ជប៉ុន និងក្រុមដទៃទៀតផងដែរ) បានធ្វើឲ្យពួកអាស៊ីអាគ្នេយ៍មានទស្សនៈប្រឆាំងនឹងពួកគេនោះកាន់តែខ្លាំងថែមទៀត ។ ជាលទ្ធផល (មួយក្នុងចំណោមលទ្ធផលឯទៀត) នៃនិន្នាការនេះគឺការធ្វើឲ្យគម្លាតខុសគ្នារកាន់តែខ្លាំងឡើងរវាងពួកអ្នកដឹកនាំដែលរស់នៅបរិវេណមានរបងបិទជិត និងប្រជានុរាស្ត្រដែលរស់នៅដោយមានផាសុខភាពប៉ុន្តែជាមួយផ្ទះដែលមិនសូវមាំរឹង ។*

## ការបំពាក់គ្រឿងសង្ហារិម និងភ្លើងពណ៌

គ្រប់ផ្ទះទាំងអស់បំពាក់ដោយគ្រឿងសង្ហារិមដ៏សាមញ្ញ ដូចដែលផ្ទះដែលសាងសង់យ៉ាងសាមញ្ញដូច្នេះដែរ ។ ដោយគេបរិភោគអាហារដោយអង្គុយផ្ទាល់ទៅនឹងរនាប ទើបគេពុំឃើញមានតុ និងកៅអីអ្វីនោះទេ រហូតដល់ពេលមានពួកចិន និងអឺរ៉ុបចូលមកហើយនែនាំឲ្យប្រើតុ និងកៅអីនេះទៅដល់ពួកអភិជន ទើមគេឃើញមានតុនឹងកៅអីនៅពេលនោះ ។ លោក ជីវតាខ្វាន់ (គ.ស.១២៩៧ ទំ. ៣១) បានកត់ត្រាថា តុទាបៗ «នៅពេលថ្មីៗនេះ ត្រូវបានគេយកមកប្រើ» នៅក្នុងប្រទេសកម្ពុជា ហើយពួក ហូឡង់ មានការរីករាយជាមួយនឹងការប្រើប្រាស់កៅអីមួយចំនួននៅកោះម៉ូលូកាស (Moluccas) នៅគ.ស.១៥៩៩ (ទ្វីដឺ ប៊ែក(Tweede Boeck) គ.ស.១៦០១ ទំ. ៦៧) ។ ពាក្យទាំងនេះ គឺខ្ចីពីពួកចិន ឬក៏ពួក ព័រទុយហ្គាល់ ។ គ្រែ គឺជាសង្ហារិមដ៏សាមញ្ញជាងនេះ ដែលមានគេដាក់បន្ថើតឡើងខ្ពស់ នៅក្នុងគ្រួសារដែលមានទ្រព្យស្តុកស្តម ថ្វីដ្បិតតែប្រជាជនភាគច្រើនចូលចិត្តក្រាលកន្ទេលគេងនៅផ្ទាល់រនាបក៏ដោយ ។

កាំបិត (សម្រាប់ប្រើនៅពេលញុំាអាហារ) សម និងស្លាបព្រា មិនមានភាពចាំបាច់ប៉ុន្មាននោះទេ ហើយស្លឹកចេកជាទូទៅប្រើធ្វើជាចាន ។ គ្រឿងឧបករណ៍ ឬប្រដាប់ប្រដាដែលប្រើប្រាស់នៅក្នុងផ្ទះធម្មតា គឺមានចង្ក្រានធ្វើអំពីដីធុង ឬប្រអប់ដែលធ្វើអំពីឫស្សី និងកុលាលភាជន៍ (សេរាមិក) និងមានឧបករណ៍ជាធុងតៗដែលធ្វើអំពីទង់ដែង (ឧបករណ៍ទាំងនោះរួមមានប្រអប់ដាក់ស្លាម្លូ ជាដើម) មានកំសៀវ និងថាស ផងដែរ ។

ការបែងចែកភាពខុសគ្នារវាងអ្នកមានទ្រព្យស្តុកស្តម្ភ មានឋានៈខ្ពស់ និងអ្នកអត់ គឺបង្ហាញចេញតាមរយៈការប្រើប្រាស់វាយនភណ្ឌ និងចានក្បានធ្វើអំពីមាស ទាំងឡាយ ។ ពេលមានពិធីសំខាន់ៗ ឬនៅពេលដែលមានភ្ញៀវមកលេងផ្ទះ គេឃើញថាគ្រួសារដែលមានទ្រព្យស្តុកស្តមបានព្យួរកំណាត់សំពត់សូត្រ (ពីហ្គាហ្វែតតា (Pigafetta) គ.ស.១៥២៤ ទំ. ៥៧, អាល់ប៊ុក្វែក គ.ស.១៥៥៧ ទំ. ១០៧ និងដាវីស គ.ស.១៦០០ ទំ. ១៤៨) ។ ជនជាតិហូឡង់បានកត់សម្គាល់នៅ បាតង់ថា «ពួកគ្រួសារអ្នកមាន សុទ្ធតែបែងចែកបន្ទប់របស់ពួកគេបាំងដោយសំពត់សូត្រ ឬសំពត់ធ្វើពីកប្បាស» (វើរហាល់ (Verhael) គ.ស.១៥៩៧ ទំ. ២៣) ។ ផ្ទះដែលបានសាងសង់ជូនបេសកជនជនជាតិបារាំងនៅទីក្រុងអយុធ្យា គឺជាផ្ទះដែលមានជញ្ជាំង «បាំងជាមួយនឹងសំពត់ដែលមានរូបគំនូរ និងពិដានសំពត់មីសាលីន (Muslin) ពណ៌ស» (ឡា លូប៊ែ គ.ស.១៦៩១ ទំ. ៣០) ។ នៅតាមដងផ្លូវនៅទីក្រុងរបស់ប្រទេសវៀតណាមបានតុបតែងដោយមានកំណាត់សូត្រនៅក្នុងឱកាសបដិសណ្ឋារកិច្ចដ៏សំខាន់ណាមួយ (ង្វី យែន គ.ស.១៩៧០ ទំ. ៩៣) ។ រីឯ រនាបផ្ទះរបស់គ្រួសារអ្នកស្តុកស្តមនោះក៏មានក្រាលដោយកម្រាលព្រំ ភ្នើយ និងកន្ទេលដ៏ប្រណិតផងដែ ។ ឋានៈរបស់ព្រះអង្គម្ចាស់ មូស្សាហ្វឺរ (Muzaffer) នៅបាតង់ ពិនតាននៅអំឡុងគ.ស.១៥២០ គឺត្រូវធ្វើឡើងដោយដកហូតយកនូវ ភ្នើយ កន្ទេលក្រាលអង្គុយ និងកម្រាលព្រំ ដែលគាត់ទម្លាប់អង្គុយនោះ ។ ព្រឹត្តិការណ៍នេះបានកត់ត្រានៅក្នុងឯកសារកាលប្បវត្តិរបស់ម៉ាឡេ ។ «គេមិនបន្សល់ទុកអ្វីឲ្យព្រះអង្គនោះទេ ក្រៅពីកន្ទេលមួយដូចដែលប្រជារាស្ត្រសាមញ្ញប្រើយ៉ាងដូច្នោះដែរ» (សេច្យារ៉ា មែឡៃយូន (Sejarah Melayun) គ.ស.១៦១២ ទំ. ១៧១) ។ សាច់ញាតិរាជវង្សជាន់ខ្ពស់បានប្រកួតប្រជែងគ្នាតាមរយៈភាពសម្បូរបែបនៃវាយនភណ្ឌរបស់ពួកគេហើយនិងទំហំ និងចំនួនចានមាសដែលគេអាចយកប្រើប្រាស់ឲ្យបានគ្រប់គ្រាន់នៅក្នុងបុណ្យទានម្តងៗ (ពីហ្គាហ្វែតតា គ.ស.១៥២៤ ទំ. ២៩ និង ៥៩ ឡាំងកាស្ទើរ ឡានចាសតរ គ.ស.១៦០៣ ទំ. ១៣១ និង សេច្យារ៉ា មែឡៃយូ គ.ស.១៦១២ ទំ. ១៨៧) ។

នៅក្នុងតំបន់មួយដែលពេលល្ងាចគឺជាពេលដែលរីករាយបំផុត ហើយពិធីបុណ្យទាន និងពិធីកម្សាន្តផ្សេងៗ

ជានិច្ចកាលចាប់ផ្ដើមនៅពេលល្ងាច ហើយបញ្ចប់នៅពេលទាបភ្លឺនោះ ការតបតែបំពាក់ភ្លើងបំភ្លឺគឺជាបញ្ហាចាំបាច់បំផុត ។ ការប្រើប្រាស់ទៀនសម្រាប់បំភ្លឺ គឺមានតិចតួចជាងការប្រើប្រាស់ចង្កៀងប្រេងនោះទេ ។ ព្រៃឈើបានផ្ដល់ឲ្យនូវប្រេង និងជ័រឈើយ៉ាងច្រើនប្រភេទដែលអាចដុតបញ្ឆេះបានដែលប្រេង និងជ័រទាំងនោះបានមកពីគ្រាប់ផ្លែឈើម្យ៉ាងឈ្មោះថា កែមីរី (Kemiri) ដែលមាននៅភាគខាងកើតនៃប្រទេសឥណ្ឌូនេស៊ី (យ៉ឺវ៉ាស្ស (Gervaise) គ.ស. ១៧០១ ទំ. ២០) និងឈើម្យ៉ាងទៀតឈ្មោះថា ដាម៉ារ (Damar) (ដែលជាជ័របានពីប្រភេទឈើហ៊ុបជាច្រើនប្រភេទ) មាននៅប្រទេសភូមា និងប៉ែកខាងលិចតំបន់ដីកោះ ។ នៅពេលដែលមានពិធីបុណ្យទានពិសេសម្ដងៗ ទីក្រុងទាំងមូលនឹងមានពន្លឺដោយភ្លើងភ្លឺចិញ្ចែងចិញ្ចាច ហើយចង្កៀងដែលដុតដាក់នៅក្នុងសំបកដូងនឹងត្រូវគេបណ្ដែតទៅតាមទន្លេ ឬក៏ចាក់ទៅសមុទ្រ (ឡា លូប៊ែ គ.ស. ១៦៩១ ទំ. ៤៨, ស្វេ យ៉ូ (Shway Yoe) គ.ស. ១៨៨២ ទំ. ២២៥-២៦ និងហ្គាល់វ៉ៅ (Galvao) គ.ស. ១៥៤៤ ទំ. ៨៧) ។

នៅតំបន់អាស៊ីអាគ្នេយ៍មានតំបន់បុរាណពីរដែលមានប្រេងហូរនៅរាក់ៗ ដែលងាយស្រួលក្នុងការជីកយក (សូមមើលផែនទី ៤) ។ តំបន់នីមួយៗ នៅសម័យនោះប្រាកដជាបានក្លាយជាមូលដ្ឋានគ្រឹះនៃឧស្សាហកម្មប្រេងដ៏ទំនើបមួយជាក់ជាមិនខាន ទោះបីជាវិស័យពាណិជ្ជកម្មនាសម័យនោះ ប្រេងគឺប្រើប្រាស់ជាចម្បងសម្រាប់ដុតបំភ្លឺក៏ដោយ ។ នៅក្នុងសតវត្សទី ១៨ អណ្ដូងប្រេងនៅតំបន់ យែណាងយ៉ូង (Yenangyaung) ស្ថិតនៅភូមាកណ្ដាលផលិតបានប្រេងរាប់រយតោនក្នុងមួយថ្ងៃដែលប្រេងទាំងនោះត្រូវបានដឹកជញ្ជូនចុះឡើងទៅតាមទន្លេ អៀរ៉ាវ៉ាដី (Irrawaddy) សម្រាប់ដុតបំភ្លឺ «នៅទូទាំងអាណាចក្រភូមា និងនៅតំបន់ជាច្រើននៃប្រទេសឥណ្ឌា» (ស៊ីមស៍ គ.ស. ១៨២៧ I ទំ. ៣០១-០២ និងកុកស៍ (Cox) គ.ស. ១៨២១ ទំ. ៣៣-៤៥) ។ ដូចគ្នានេះដែរ នៅប៉ែកខាងជើងនៃកោះសូម៉ាត្រាភាគច្រើនបូមប្រេងសម្រាប់ដុតបំភ្លឺចេញពីអណ្ដូងប្រេងធម្មជាតិនៅពែឡាក់ (Perlak) ដែលធ្វើឲ្យអាណាចក្រ ប៉ាសៃ (Pasai) និងក្រោយមកនៅអាចេ មានការរីកចម្រើននោះ (អេរេដៀរ គ.ស. ១៦០០ ទំ. ២៣៨, បារ៉ូស (Barros)គ.ស. ១៥៦៣ II ទំ. ii និង ៣៤ និងគ.ស. ១៥៦៣ III ទំ. ii និង ២៧៧) ។ ប្រេងទាំងនេះត្រូវបានពួកជនជាតិ អាចេ ចាត់ទុកថាជា អរិយធម្មជាតិប្រទានមកពីព្រះឲ្យដល់ប្រទេសរបស់ (ហ៊ីកាយ៉ាត់ អាចេ (Hikayat Aceh) គ.ស. ១៦៣០ ទំ. ១៦៤) ។ ខណៈពេលនោះអ្នកវិទ្យាសាស្ត្រជនជាតិហូឡង់កត់សម្គាល់ថា ប្រេងនេះ គឺជាឱសថព្យាបាលរោគម្យ៉ាងឈ្មោះថា ប៊ែរី ប៊ែរី (beri-beri) ដែលមិនត្រូវយកមកដុតនោះទេ (ប៊ុងទ្យាស់ (Bontius) គ.ស. ១៦២៩ ទំ. ៤-៥)។

## សោភណភាពរាងកាយ

> ដងខ្លួនព័ណលឿងរបស់គាត់រលោងដូចមាសខាត់ ហើយសក់រួញរបស់គាត់ដូចផ្កាពាក់នៅលើក្បាល ។ ដៃរបស់គាត់កោងទៅក្រោយក្នុងទ្រង់ទ្រាយដូចដងសន្ទូច រីឯស្នារបស់គាត់បើកត្រង់ដូចតួអាយ៉ង ហើយចង្កេះរបស់គាត់រាវតូចប៉ុនមួយក្ដាប់ដៃ ។ ភ្លៅទាំងគូរបស់គាត់ដូចជាជើងចង្រិតលាតសន្ធឹងដូចជាកណ្ដូបអ៊ីចឹង ។
>
> —Hikayat Banjar: 365

ដងខ្លួនគឺជាកត្តាទីមួយ និងដ៏សំខាន់បំផុតសម្រាប់សិល្បៈ ។ ពេលតុបតែងទៅនឹងធ្វើឲ្យគេអាចបែងចែកមនុស្សពេញវ័យ គ្រប់លក្ខណៈខុសពីសត្វ ឬពីកូនក្មេង ។ ប្រសិនបើការតុបតែងខ្លួន សម្អាតរៀងកាយឲ្យមានក្លិនក្រអូបគឺជាសារៈសំខាន់សម្រាប់មនុស្សគ្រប់រូបនោះ នោះមានន័យថាការឈានចូលដល់ពេញវ័យតម្រូវឲ្យមានការ

តុបតែងខ្លួនដែលជាទូទៅគឺជារឿងគួរឲ្យឈឺចាប់ណាស់ ។

ការលាបម្រក្សធ្វើឲ្យធ្មេញខ្មៅ គឺជាឧបករណ៍ទូទៅជាងគេសម្រាប់តំបន់អាស៊ីអាគ្នេយ៍ ។ តាមការកត់ត្រារបស់ហ្វីតច៍ (Fitch) (គ.ស. ១៥៩១ ទំ. ៣០៩) បានឲ្យដឹងថា ជនជាតិភូមា «និយាយថាឆ្កែមានធ្មេញសដូច្នេះពួកគេត្រូវតែលាបធ្មេញរបស់ពួកគេឲ្យមានពណ៌ខ្មៅ» ។ ជនជាតិវៀតណាមក៏មានទស្សនៈដូចគ្នាបែបនេះដែរ (ដាំពែរ គ.ស. ១៦៩៩ ទំ. ៣៤) ។ មិនគ្រាន់តែសត្វកាចសាហាវ ឬសត្វគួរឲ្យស្អប់ខ្ពើមប៉ុណ្ណោះទេ ដែលជាសត្វមានធ្មេញវែងពណ៌សនោះសូម្បីតែពួកព្រាយបិសាចក៏គេជឿថាមានធ្មេញពណ៌សដែរ ។ ហេតុដូច្នេះហើយនេះគឺជាការបកស្រាយមួយដែលគេលាបធ្មេញឲ្យខ្មៅនៅក្នុងពិធីពេញវ័យ គឺដើម្បីបញ្ជាក់ឲ្យច្បាស់ថា មនុស្សនឹងមិនត្រូវគេច្រឡំថាជាព្រលឹងព្រាយបីសាចទេ នៅពេលដែលគេស្លាប់នោះ (កូវ៉ារូប្យាស់ (Covarrubias) គ.ស. ១៩៣៧ ទំ. ១៣៥, ហ្វ័ស្ស (Forth) គ.ស. ១៩៨១ ទំ. ១៦៤ និងហ្គែវ៉ាស់ (Gervaise) គ.ស. ១៦៨៨ ទំ. ១១៣) ។ នៅទូទាំងប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីនគេខាត់ធ្មេញនៅដែលគេពេញវ័យ (គ្រប់ការ) ទោះបីជាវិធីខាត់ទាំងនោះខុសៗគ្នានៅតាមតំបន់ក្ដី ដូចជានៅបាលី គេគ្រាន់តែខាត់ធ្មេញមុខបន្តិចតែប៉ុណ្ណោះ ឬឯនៅផ្នែកខ្លះនៅកោះស៊ូម៉ាត្រា វិញគេនិយមខាត់រាល់ធ្មេញមុខរបស់ពួកគេឲ្យខ្លីទាំងអស់ ។ ការខាត់ធ្មេញមិនត្រូវបានគេអនុវត្តនៅតំបន់អាស៊ីអាគ្នេយ៍ដីគោកនោះទេ ប៉ុន្តែការលាបធ្មេញជាមួយនឹងពណ៌ពីបន្ទៃច្រើនមុខនោះមានការពេញនិយមនៅតាមប្រទេសភូមា សៀម និងវៀតណាមមិនចាញ់ការខាត់ធ្មេញនៅតំបន់កោះនោះទេ ។ ការទំពារស្លាម្លូជាប្រចាំជួយធ្វើឲ្យធ្មេញមានពណ៌ខ្មៅជាប្រចាំផងដែរ ប៉ុន្តែយុវជនក្មេងៗដែលតែងតែគិតគូពីសម្រស់របស់ពួកគេនោះ តែងតែចង់ឲ្យធ្មេញរបស់គេមានពណ៌ខ្មៅនិលបានមកពីពណ៌បន្ថែមផ្សេងទៀត (ម៉ាសដែន (Marsden) គ.ស. ១៧៨៣ ទំ. ៥២–៥៣ និងឡា លូប៊ែរ គ.ស. ១៦៩១ ទំ. ២៩) ។

ការចោះទងត្រចៀក និងធ្វើឲ្យប៉ោងហើមនោះគឺជាការតុបតែងមួយបែបទៀត ដែលអនុវត្តទាំងបុរស និងនារី ជាពិសេសអ្នកដែលមានឋានៈខ្ពស់អាចមានលទ្ធភាពរកគ្រឿងអលង្ការមកបិទបញ្ចិទ រន្ធទងត្រចៀកនោះបាន ។ រូបសំណាក់ និងរូបបដិមា នៅកម្ពុជានាសម័យអង្គរបុរាណ បានបង្ហាញថា «ការដែលទងត្រចៀកកាន់តែហើមប៉ោងបុគ្គលនោះមានកាន់តែមានមុខមាត់ខ្លាំងក្នុងសង្គម» (ហ្វ្រេដឺរីក គ.ស. ១៩៨១ ទំ. ២៥០) ។ ត្រចៀករបស់ស្ដេចជនជាតិភូមា ត្រូវបានគេពណ៌នាថាយារធ្លាក់ «ពាក់កណ្ដាលបាតដៃ» ឯណោះ ដោយសារតែទម្ងន់នៃគ្រឿងអលង្ការពាក់នៅនឹងត្រចៀកនោះ (វ៉ាសែម៉ា (Varthema) គ.ស. ១៥១០ ទំ. ២២០) ។ ការធ្វើឲ្យយារទងត្រចៀករហូតដល់យារប៉ះទៅនឹងស្មានេះមានទំនាក់ទំនងជាមួយនឹងឥណ្ឌាសម័យបុរាណ ។ ទោះជាយ៉ាងណាក៏ដោយ យើងមិនគួរធ្វើការសន្និដ្ឋានថា ការអនុវត្តបែបនេះបានមកពីជនជាតិឥណ្ឌានោះទេ ពីព្រោះថានៅតំបន់អាស៊ីអាគ្នេយ៍ដែលមានឥទ្ធិពលឥណ្ឌាតិចបំផុត ដូចជានៅបរ៉័ណេអូ (Borneo) និងនៅហ្វីលីពីនកណ្ដាល គឺជាតំបន់ដែលអនុវត្តការតុបតែងនេះខ្លាំងជាងគេបំផុត ។ ខាងក្រោមនេះគឺជាការពណ៌នារបស់ អាល់ស៊ីណា (គ.ស. ១៦៦៨ a ទំ. ២០) ស្ដីអំពីរបៀបនៃការធ្វើឲ្យត្រចៀកហើមនៅវីស័យយ្យាស៍ និងនៅតំបន់ដីកោះឯទៃទៀត ដែលវិធីនេះមានភាពខុសគ្នាពីការតុបតែងនៅពេលពេញវ័យរបស់អ្នកនៅតំបន់ដីគោក៖

> សម្រាប់ក្មេងដែលទើបនឹងកើតទោះស្រី ឬប្រុស អាយុមួយឆ្នាំ ឬពីរឆ្នាំក្ដីបានចោះត្រចៀក ដោយប្រើម្ជុល ឬក៏ខ្សែ. . .។ គេបន្សល់ទុកសរសៃអំបោះមូរនៅក្នុងរន្ធត្រចៀក រហូតដល់ពេលដែលត្រចៀកនោះជាសះស្បើយ ។ បន្ទាប់មកគេបិតឬស្សី ឬឈើ ឲ្យតូចដើម្បីចាក់ចូលរន្ធនោះ ។ ឈើទាំងនោះត្រូវបានថែទាំជារៀងរាល់ពេល នៅពេលដែលគេដកឈើនោះចេញ រហូតទាល់តែរន្ធនៅទងត្រចៀកនោះធំអាចដាក់ម្រាមកូនដៃចូលចុះ ។

> រួចមក គេយកស្លឹកឈើមកហាលឲ្យស្ងួត ហើយកាត់ស្លឹកឈើនោះឲ្យបានប៉ុនបីម្រាមដៃ រួចហើយមូរបំណែកកាត់នោះ ហើយយកទៅស៊កក្នុងរន្ធនៅទងត្រចៀកនោះទៅ. . . ស្លឹកឈើនោះក៏រលាមកវិញសើៗ ដែលអ្នកពាក់នោះមិនអាចដឹងខ្លួននោះទេ. . . រន្ធនោះមានសភាពកាន់តែធំទៅៗ. . . រហូតទាល់តែធំអាចដាក់ក្រវិលបានគ្រប់ប្រភេទ. . . អ្នកពាក់ទាំងនោះផ្លាស់ប្តូរក្រវិលរហូត ទាល់តែរន្ធនៅទងត្រចៀកនោះធំយ៉ា ហើយធ្លាក់មកក្រោមចង្កា ។

*ដូចជាការតុបតែខ្លួនកាយផ្នែកឯទៀតនៅអាស៊ីអាគ្នេយ៍យ៉ាងដូច្នោះដែរ ការតុបតែងត្រចៀកបែបនេះមានការពេញនិយមទាំងបុរស និងស្ត្រី យ៉ាងហោចណាស់ក៏រហូតដល់សតវត្សទី ១៤ ដែរ ។ ការប្រាស្រ័យទាក់ទងគ្នាយ៉ាងញឹកញាប់រវាងពួកមូស្លីម និងពួកអ៊ឺរ៉ុប ហាក់បីដូចជាធ្វើឲ្យការតុបតែងត្រចៀកនេះមានការថយចុះជាពិសេសសម្រាប់បុរស ។ បុរសនៅតំបន់ទំនាបនៅប្រទេសថៃ និងជ្វា ក៏ដូចជាជនជាតិម៉ាឡេ និងជនជាតិផ្សេងទៀតដែលក្លាយជាជនជាតិមូស្លីមនោះ បានបោះបង់ការអនុវត្តការចោះត្រចៀកនេះ នៅសតវត្សទី ១៧ ។ ជនជាតិភូមាទាំងបុរសទាំងស្ត្រីសុទ្ធតែពាក់មាសស្តើងមូរតូចៗនៅនឹងត្រចៀករបស់ពួកគេនៅក្នុងសតវត្សទី ១៨ (សាំងហ្គឺម៉ាណូ គ.ស. ១៨១៨ ទំ. ១៥៨ និងកុកស៍ គ.ស. ១៨២១ ទំ. ៣) ។ ប៉ុន្តែពួកបុរសៗបោះបង់ការតុបតែងរបៀបនេះក្រោយមួយសតវត្សបន្ទាប់មកទៀត ។ ការចោះត្រចៀកលើកដំបូងបង្អស់បន្តជាពិធីពេញវ័យដ៏សំខាន់សម្រាប់ស្ត្រីជនជាតិភូមា (ស្វាយ យ៉ូ (Shway Yoe) គ.ស. ១៨៨២ ទំ. ៤៨-៥១) និងបន្តជាមោទនភាពសម្រាប់ស្ត្រីជនជាតិ បាលី (កូវ៉ារូប្បាស គ.ស. ១៩៣៧ ទំ. ១១៥-១៦) ។ ប៉ុន្តែមានតែនៅតាមតំបន់ដាច់ស្រយាលដូចជានៅប័រណេអូ និងនៅតំបន់ បាតាក់ ពាតាកនៃកោះ សូម៉ាត្រា នោះទេ ដែលបុរសក៏បង្ហាញពីភាពពេញកំលោះ និងឋានៈស្តុកស្តមរបស់ពួកគេ ដោយការពាក់គ្រឿងអលង្ការធំៗនៅនឹងរន្ធត្រចៀករបស់ពួកគេនោះ ។*

*ការសាក់លើខ្លួនប្រាណគឺ សិល្បៈតុបតែខ្លួនមួយបែបទៀតនៅតំបន់អាស៊ីអាគ្នេយ៍ហើយក៏ដូចជាសម្រាប់បណ្តាប្រជាជនអូស្ត្រូនេស៊ីដែរ ដែលបានបន្សល់សិល្បៈនេះទុកឲ្យប្រជាជនប៉ាស៊ីហ្វិចខាងត្បូង ។ ប្រជាជនភាគច្រើននៅអាស៊ីអាគ្នេយ៍ប្រើសិល្បៈសាក់នេះយ៉ាងខ្លាំងនៅក្នុងប្រវត្តិសាស្ត្ររបស់ពួកគេ ។ យ៉ាងណាមិញឥទ្ធិពលរបស់លិទ្ធិខុងជឺ សាសនាអ៊ីស្លាម សាសនាគ្រិស្ត បានបំបាត់ការអនុវត្តការសាក់នេះនៅតាមតំបន់វាលទំនាបជាច្រើននៅក្នុងសម័យពាណិជ្ជកម្ម ។ នៅសតវត្សទី ១៤ ជនជាតិវៀតណាមបានហាមឃាត់ការសាក់ ដែលពួកគេចាត់ទុកថាជាអំពើមិនល្អ ឬមិនទាន់សម័យ ខណៈពេលដែលសមាជិនសាសនាកាត់តូលិកបំបាត់ការអនុវត្តនេះនៅវីស័យយ៉ាស់ និងនៅ បីកុល (Bikol) ដែលនៅទីនោះការអនុវត្តសាក់រាងកាយនេះមានយ៉ាងច្រើនរហូតដល់សតវត្សទី ១៧ (កូលីន គ.ស. ១៦៦៣ ទំ. ៦៣-៦៤) ។ ពួកអ៊ីស្លាមរឹតតែប្រឆាំងជំទាស់ខ្លាំងជាងនេះទៅទៀត ទៅនឹងការតុបតែងបែបមន្តអាគមបែបនេះ ។ ពួកអាចេជនជាតិមូស្លីមបានបំបាត់ចោលនូវការសាក់នៅក្នុងចំណោមប្រជាជននៅកោះសូម៉ាត្រាខាងជើងដែលបានក្លាយជាមូស្លីមហើយនោះ ។ ក្រមច្បាប់មួយរបស់ពួកគេនៅសតវត្សទី ១៧ ដែលហៅថា ស៊ីរ៉ាត អាល់-មូសស្តាកា (M.Sirat al-Mustakim) បានចែងថា «ជាកាតព្វកិច្ចដែលត្រូវបោះបង់ចោលការសាក់ដោយយកម្ជុលទៅចាក់សាច់ឲ្យមានឈាមចេញ ហើយបញ្ចូលនូវទឹកខ្មៅ ឬទឹកប្រភេទស្រដៀងគ្នានេះទៅក្នុងស្បែក» (ដកស្រង់នៅក្នុងវែលត៍ម៉ង់ (Veltman) គ.ស. ១៩១៩ ទំ. ២១) ។ មិនមានភស្តុតាងអ្វីបញ្ជាក់ពីការសាក់នៅក្នុងចំណោមពួកមូស្លីមម៉ាឡេ ឬពួកជ្វានោះទេ ។ នេះអាចមកពីពួក ជ្វាមានសម្លៀកបំពាក់ម្យ៉ាង ហៅថា បាតឹក (Batik) ដែលមានជ្រលក់ពណ៌ដោយចាប់ផ្តើមពីការបន្តក់ក្រមួនទៅលើកំណាត់នោះ ។ ការតុបតែងលើសម្លៀកបំពាក់នេះ គឺប្រើ*

ជំនួសការសាក់ដែលពួកគេចាត់ទុកថាជាវត្ថុសក្តិសិទ្ធិ និងជាកំណត់សម្គាល់ឋានៈសង្គមរបស់ពួកគេ ។ «បាតឹក» គឺជាពាក្យដ៏សាមញ្ញមួយសម្រាប់ការសាក់នៅក្នុងភាសាឥណ្ឌូនេស៊ីខាងកើត និងហ្វីលីពីន ហើយក្បាច់រចនា និងមុខងាររបស់បាតឹក របស់ជនជាតិជ្វា បានធ្វើឲ្យមានការសាក់ក្បាច់លើរាងកាយមនុស្ស (វូម៉ឺរេម និងវីលសាន់ (Wilson) គ.ស. ១៩៨៣ ទំ. ២១៤ និងចា្យាស្ពឺរ (Jasper) និង ពឹងហ្គាឌី (Pirngadie) គ.ស. ១៩១៦ ទំ. ៧–៨)។

មុខងារចម្បងរបស់ការសាក់ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍អាចជាការតំណាងឲ្យវត្ថុសក្តិសិទ្ធិ ។ ការពេញចិត្តរបស់ពួកជ្វា និងពួកម៉ាឡេ ទៅនឹង រ៉ាចា្យាស (Rajah) ឬហៅថាការតុបតែងដ៏មានមន្តអាគមដ៏អស្ចារ្យ (ពីហ្គោដ (Pigeaud) គ.ស. ១៩៦៧ ទំ. ២៦៨–៧៣)អាចមានទំនាក់ទំនងជាមួយនឹងការអនុវត្តសាក់រាងកាយនៅសម័យដើម ។ រូបសត្វព្រៃកាចសាហាវមានឥទ្ធិពល ក្បាច់គំនូសដែលមានមនុស្សតិចតួចចេះ និងក្បួនយ័ន្តសាសនា គឺតំណាងឲ្យថាមពលពិសេសនៅលើដងខ្លួន ដូចជាថាមពលដែលអាចឲ្យគេគេចផុតពីគ្រោះថ្នាក់អន្តរាយបាន (សាំងហ្គឺម៉ាណូ គ.ស. ១៨១៨ ទំ. ១៤៨, ហ្វីតច៍ គ.ស. ១៥៩១ ទំ. ៣០៨–០៩, ស្វាយ យ៉ូ គ.ស. ១៨៨២ ទំ. ៤១–៤៧,តែវែល (Terwiel) គ.ស. ១៩៨០ ទំ. ៦៤ និង ហ្វ័រស៍ គ.ស. ១៩៨១ ទំ. ១៦៥) ។ ការសាក់ក៏ជានិមិត្តសញ្ញានៃភាពក្លាហាន ដូច្នេះនេះ គឺជាពិធីសម្រាប់បុរសវ័យក្មេង ។ នៅក្នុងប្រទេសហ្វីលីពីន (សូមមើលរូបភាព ១១) «មិនមានការអនុវត្តសាក់នោះទេតាំងពីដើមមករហូតទាល់តែមាននរណាម្នាក់បានធ្វើអ្វីមួយដែលជាទង្វើក្លាហាន ហើយបន្ទាប់មកនេះដើម្បីឲ្យគ្រប់ផ្នែកនៅលើដងខ្លួនមានរូបសាក់ បុគ្គលនោះត្រូវតែបន្តធ្វើទង្វើក្លាហានថ្មីបន្ថែមទៀត» (កូលីន គ.ស. ១៦៦៣ទំ. ៦៤ តែសូមអានប្រៀបធៀបឯកសាររបស់ អែលីស (Ellis) គ.ស. ១៩៨១ទំ. ២៤៩) ។ ស្រដៀងគ្នានេះដែរនៅបរំណេអូ ក្បាច់សាក់ជាពិសេសមួយចំនួន គឺសម្រាប់អ្នកប្រមាញ់ទទួលបានជោគជ័យតែប៉ុណ្ណោះ (រូតតឺរ (Rutter) គ.ស. ១៩២៩ ទំ. ១១៧–១៩) ។

ខណៈពេលដែលរដ្ឋតំបន់វាលទំនាបសំខាន់ៗមួយចំនួន ចាត់ទុកការសាក់ជាទំនៀមទម្លាប់ដ៏សាហាវមិនត្រឹមត្រូវនោះ អ្នកឯទៃទៀតចាត់ទុកការសាក់រូបនោះ គឺជានិមិត្តសញ្ញាដ៏ស្រួលមួយដើម្បីកំណត់ឋានៈសង្គម ។ នៅប្រទេសភូមានៅសតវត្សទី ១៦ (ហ្វីតច៍ គ.ស. ១៥៩១ ទំ. ៣០៩) និងនៅប្រទេសសៀមនៅសតវត្សទី ១៧ (ឡាលូប៊ែរ គ.ស. ១៦៩១ ទំ. ២៧–២៨) ការយកសំពត់ «ទ្រូស័រ(trouser)» មកហ៊ុមពន្ធត្រគាក និងជើងដែលមានសាក់រូមនោះ (សូមមើលរូប ១២) អាចត្រូវបានគេទុកសម្រាប់អ្នកដែលមានឋានៈខ្ពស់តែប៉ុណ្ណោះ ។ រូបសាក់ដែលខុសដាច់ពីនេះក៏ត្រូវបានគេតម្រូវតាមផ្លូវការឲ្យពួកទាសករ និងអ្នកបម្រើ ទាំងនៅភូមា និងនៅប្រទេសសៀម (លីប៊ែម៉ង់ (Lieberman) គ.ស. ១៩៨៤ ទំ. ៤១, ១០៥ និងតែវែល គ.ស. ១៩៨២ ទំ. ១២៤) ។

ដើម្បីបញ្ជាក់ឲ្យថាមនុស្សម្នាក់ៗស្ថិតនៅក្នុងឋានៈខុសៗគ្នា ការសាក់រូបលើខ្លួន គឺជាមធ្យោបាយដ៏ប្រសើរ និងគួរឲ្យទុកចិត្តជាងការចេញច្បាប់ឲ្យមានការស្លៀកពាក់ខុសៗគ្នា ។



រូបភាព ១១ ៖ ការសាក់រូបនៅតំបន់ វីស័យយ៉ាស់ (Visayas) នៅកំលុងគ.ស. ១៥៩០



រូបភាព ១២ ៖ សម្លៀកបំពាក់របស់ពួកថៃខាងជើង និងការសាក់រូបនៅលើជើងរបស់ពួកប្រុសៗ ដកស្រង់ពីផ្ទាំងគំនូរនៅវត្ត ប្រាសាំង (Wat Phra Sing) នៅឆៀងម៉ៃ (Chiengmai) នៅសតវត្សទី ១៩ ។ រចនាបថតុបតែងសក់របស់នារីៗ មានលក្ខណៈដូចទៅនឹងពួកភូមា ជាងពួកថៃតំបន់កណ្ដាល ។

## ការតុបតែងសក់

*មានប្រធានបទពីរដែលសំខាន់សម្រាប់បកស្រាយចំពោះសក់របស់ប្រជាជននៅអាស៊ីអាគ្នេយ៍ ។ ការតុបតែងសក់របស់បុរស និងនារីមានលក្ខណៈខុសគ្នាតិចតួចណាស់ (សូមមើលរូបភាពទី១៣) ហើយសម្រាប់បុរស និងនារី សក់គឺជានិមិតសញ្ញា និងការបង្ហាញឲ្យឃើញដ៏សំខាន់មួយ របស់បុគ្គលម្នាក់ៗ ។ សក់របស់មនុស្សម្នាក់ៗពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការធ្វើមន្តអាគម ។ កម្ទិចសក់កាត់របស់អ្នកដឹកនាំត្រូវបានគេតម្កល់ទុកជាកំណប់ ពីព្រោះថាកំទិចសក់ទាំងនោះមានបន្សល់ទុកអំណាចបូរណៈភាពទឹកដីបន្តិចបន្តួចពីអ្នកដឹកនាំនោះ ។ ការថែរក្សាសក់ត្រូវតែធ្វើឡើងដោយយកចិត្តទុកដាក់ជាចាំបាច់ ដើម្បីឲ្យប្រាកដថាសក់ត្រូវតែពណ៌ខ្មៅ ក្រើរលោង ក្រាស់ និងមានក្លិនផ្អែមទៀតផង ។ (រ៉ូដស៍ (Rhodes) គ.ស.១៦៥៣ ទំ. ១៥៧) បានកត់សម្គាល់យ៉ាងច្បាស់ថា ជនជាតិវៀតណាមស្រលាញ់សក់របស់ពួកគេ «ដូចស្រលាញ់ក្បាលរបស់ពួកគេដូច្នោះដែរ» ។ ម្យ៉ាងទៀត សក់ក៏អាចជាផ្នែកមួយនៃភាពសក្តិសិទ្ធិរបស់ក្បាល នៅក្នុងជំនឿរបស់ប្រជាជននៅអាស៊ីអាគ្នេយ៍ ។ នៅក្នុងភាសាថៃ ពាក្យថា សក់ (អានថា «ផុំ») បានក្លាយទៅជាសព្វនាមបរិស័ទ (មានន័យថា សក់គឺមានឋានៈស្មើនឹងរូបបុគ្គលនោះ) ។*



រូបភាព ១៣ ៖ គំនូសឃ្មៀក អំពីបុរសក្រីក្រសាមញ្ញម្នាក់ជនជាតិភូមា និងប្រពន្ធរបស់គាត់ នៅសតវត្សទី ១៨

*ដោយមូលហេតុនេះការតុបតែងសក់ គឺត្រូវធ្វើឡើងទាំងចំពោះបុរស និងចំពោះស្ត្រី រហូតដល់យុគសម័យពាណិជ្ជកម្មដែលពួកគេត្រូវទុកសក់ឲ្យវែង និងក្រាស់តាមដែលពួកគេអាចធ្វើទៅបាន ។ នៅប្រទេសភូមា (ស្វាយ*

យ៉ូ គ.ស.១៩៨១ ទំ. ៧២) នៅប្រទេសហ្វីលីពីន (អាល់ស៊ីណា គ.ស.១៦៦៨ A ទំ. ១៨) និងនៅកន្លែងឯទៀត ប្រជាជនគេនិយមពាក់សក់បន្ថែមដើម្បីបង្ហាញឲ្យឃើញនូវភាពគ្រាស់គ្រាសាយនៃសក់របស់គេ ។ «ជាទូទៅទាំងបុរស ទាំងស្ត្រីសុទ្ធតែចាត់ទុកថាសក់គួរតែមានពណ៌ខ្មៅងិល និងមានការថែរក្សាបានល្អ ។ ដើម្បីឲ្យបានសក់យ៉ាងដូច្នេះពួកគេប្រើប្រេងម្យ៉ាងដែលធ្វើឡើងពីសំបកឈើ ឬអំពីប្រេង» (កូលីន គ.ស.១៦៦៣ ទំ. ៦០ ប៉ុន្តែសូមអានប្រៀបធៀប រ៉ាហ្វូលស៍ គ.ស.១៨១៧ ទំ.៨៩-៩០ និងរបស់ វ៉ាល់ឡង់ទីយីន (Valentijn) គ.ស.១៧២៦ III ទំ. ៣០៨) ។

ការកាត់សក់មិនមែនជានិមិត្តសញ្ញានៃការផ្លាស់ប្តូរភេទ ឬគ្រាន់ដូចដែលបានអះអាងពីមុនមកនោះទេ (ប៊ឺហ្គ (Berg) គ.ស.១៩៥១ និងរបស់ លីច (Leach) គ.ស.១៩៥៨)ប៉ុន្តែនោះជាការលះបង់នូវរូបបុគ្គលទៅវិញទេ ។ អាល់ស៊ីណា (គ.ស.១៦៦៨ A ទំ. ១៨) បកស្រាយអំពីស្ត្រីជនជាតិហ្វីលីពីនថា៖ «ការឈឺចាប់ធំបំផុតដែលគេជួបប្រទះនោះ គឺត្រូវគេកាត់សក់ចេញ ។ ដូច្នេះហើយ ដើម្បីបង្ហាញថាពួកគេឈឺចាប់យ៉ាងខ្លាំងនោះ គឺតាមរយៈការកាត់សក់របស់ពួកគេ... ដែលជាសញ្ញាមួយប្រាប់ថា ពួកគេកំពុងតែទួញសោកចំពោះការបាត់បង់ឪពុកម្តាយ ឬក៏ប្តីជាទីស្រឡាញ់របស់ពួកគេ...សម្រាប់បុព្វហេតុសាសនា ឬសម្រាប់ការលាចាកលោក» ។ ពិធីកាត់សក់ដ៏វែងរបស់អារុង ប៉ាឡាកកា (Arung Palakka) នៅគ.ស.១៦៧២ បន្ទាប់ពីបានទទួលជ័យជម្នះលើ ម៉ាកាសារ (អង់ដាយ៉ា (Andaya) គ.ស. ១៩៨១ ទំ. ១២៨ និងម៉ាតទេស (Matthes) គ.ស.១៨៧៥ ទំ. ៦៧) ហើយនិងការកាត់សក់របស់ សូស៊ូហូនង់ ប៉ាគូប៊ូវ៉ាណា (Susuhunan Pakubuwana) នៅគ.ស.១៧១៥ (រីកលីហ្វស៍ គ.ស.១៩៧៨ ទំ. ១៩៥) នោះ ប្រហែលជាអាចនិយាយបានថា ធ្វើឡើងដោយសារពួកគេបានស្បថ៌ថានឹងបូជាសក់របស់ពួកគេជាថ្នូរទៅនឹងជ័យជម្នះនោះ ។ ការកាត់ឬកោរសក់របស់ប្រជាជនសាមញ្ញជាពិសេសស្ត្រីនៅក្នុងរាជវាំង នៅពេលមរណភាពរបស់រាជវង្សានុវង្សដូចដែលបានឲ្យដឹងរួចមកហើយ នៅអាចេ នៅប៉ាតានី សៀម និងចូហូរ (Johor) នាសតវត្សទី ៧ នោះ(ម៉ូនឌី (Mundy) គ.ស.១៦៦៧ ទំព័រ ១៣១, ហីកាយ៉ាត់ ប៉ាតានី (Hikayat Patani) ទំ. ១០៦, បូរី Bowreyគ.ស.១៦៨០ ទំ. ៣១១, ហ្គ្រួណឺវែលដ៍ (Groeneveldt) គ.ស.១៨៨០ ទំ. ១៣៥ និងអ៊ីប្រាហ៊ីមី (brahim) គ.ស.១៦៨៨ ទំ. ១២៧) អាចបង្ហាញអំពីការបូជាជានិមិត្តរូបដែលបានប្រារព្ធឡើងនៅបុព្វសម័យសាសនាអ៊ីស្លាម នៅក្នុងដំណើរជីវិតមនុស្សលោក ។

មុននឹងការទទួលយកសាសនាអ៊ីស្លាម និងសាសនាគ្រិស្តនោះការតុបតែងសក់របស់បុរស និងស្ត្រីមានភាពខុសគ្នាតិចតួចណាស់ហាក់បីដូចជាមិនមានការយកចិត្តទុកដាក់ក្នុងការបែងចែកភេទនោះទេ ។ ប៉ុន្តែការបែងចែកឋានៈតាមអាយុមានភាពខុសគ្នាខ្លាំង ។ នៅផ្នែកខ្លះនៃដីកោះនៅអាស៊ីអាគ្នេយ៍ខណៈពេលដែលសក់របស់យុវជនត្រូវទុកឲ្យវែងជានិច្ច រហូតដល់សម័យទំនើប ក្មេងៗត្រូវកាត់សក់ឲ្យខ្លី ដែលពេលកាត់សក់ឲ្យខ្លីលើកដំបូងនោះ ត្រូវធ្វើឡើងនៅក្នុងពិធីសាសនាដ៏ឱឡារិកមួយ (ហូរស៍ គ.ស.១៩៨១ ទំ. ១៥៧-៥៩ កុងវ៉ារូប៊ីយ៉ាស់ (Convarrubias) គ.ស.១៩៣៧ ទំ. ១២៩-៣០ និងស្កៀត (Skeat) គ.ស.១៩០០ ទំ. ៤២) ។ ដោយលែកនៅក្នុងប្រទេសកម្ពុជា និងប្រទេសសៀម នៅពេលដែលយុវជនយកការកាត់សក់ខ្លីបែបថ្មី ស្ត្រីដែលមិនទាន់រៀបការនោះត្រូវបានគេចំណាំដោយការកាត់សក់ទម្លាក់មកត្រឹមស្មា (ឡា លូបែរ គ.ស.១៦៩១ ទំ. ២៨ និងរបស់ អាយម៉ង់ណែរ (Aymanier) គ.ស.១៩០០ ទំ. ៣០) ។

សម្រាប់ពួកប្រវត្តិសាស្ត្រសង្គម ការប្រែប្រួលយ៉ាងសំខាន់ និងគួរឲ្យចាប់អារម្មណ៍នោះ គឺការប្តូរពីការទុកសក់ឲ្យវែងមកខ្លីវិញ ក្នុងកំលុងសតវត្សទី ១៦ និង ១៧ ដែលចំពោះបុរសនៅតំបន់ដីកោះបានទទួលឥទ្ធិពលពីសាសនាអ៊ីស្លាម និងសាសនាគ្រិស្ត និងនៅកម្ពុជា និងសៀម ទទួលឥទ្ធិពលនេះទាំងប្រុសទាំងស្រី ។ ដោយយោងតាមទំនាក់

ទំនងរវាងការទុកសក់វែង ទៅនឹងភាពពេញវ័យ និងសារៈសំខាន់នៃសាសនា ការប្រែប្រួលនេះអាចត្រូវបានគេចាត់ទុកថាជាសញ្ញាមួយនៃការកែប្រែតវិយាបថខាងការកំណត់ភេទ ដោយសង្កត់ធ្ងន់ជាងនេះទៅលើច្បាប់ និងលក្ខខណ្ឌសម្រាប់ការកំណត់ភេទ និងទៅលើការបែងចែកភេទដោយបំផ្លើស រវាងបុរស និងស្ត្រី (ក្នុងចំណោមពួកអ៊ីស្លាម និងពួកគ្រិស្ត) (សូមអានប្រៀបធៀបឯកសាររបស់ លីច គ.ស.១៩៥៨ ទំ. ១៥៣ និង ហ្វឹស៍ គ.ស.១៩៧៣ ទំ. ២៦២-៦៧) ។

ពិតប្រាកដណាស់ហើយ ការកាត់សក់របស់បុរសបានក្លាយទៅជានិមិត្តរូបដ៏សំខាន់មួយនៃការប្រកាន់ខ្ជាប់នៃជំនឿសាសនាអ៊ីស្លាម ។ ពួកជ្វាមូស្លីមចាស់គំរឹលដែលមានតួនាទីបញ្ចុះបញ្ចូលមនុស្ស តាំងពីសតវត្សទី ១៦ មកនោះ បានដាក់បណ្ដាសារចំពោះសាវៈថ្មីរបស់មូស្លីម ដែលបដិសេធទៅនឹងដំបូន្មានដែលតំរូវឲ្យកោរសក់ និងពាក់ឈ្នួតលើក្បាល «ក្នុងនាមជាអ្នកនាំសាររបស់ព្រះ» (យោងតាម «ច្បាប់របស់ជ្វា» ទំ. ៣៤-៣៥) ។ នៅពេលដែលបេសកជនអ៊ីស្លាមមកពី មេកា (Mecca) បង្ហាញឲ្យក្សត្ររបស់ បាលី នៅសតវត្សទី ១៦ នូវកន្ត្រៃ និងប្រដាប់កោរនោះ ព្រះអង្គទ្រង់តម្រិះថា នេះគឺជាការអញ្ជើញទ្រង់ឲ្យចូលជាសមាជិកសាសនាអ៊ីស្លាម ហើយទ្រង់បានតបទៅនឹងការអញ្ជើញនោះដោយកំទិចអំណោយនោះទៅជាបំណែកតូចៗ (ឌ្រូវស៍ (Drewes) គ.ស.១៩៧៨ ទំ. ៦៦) ។ ពួកអ្នកក្រុងនៅម៉ាឡេ ដែលមានអត្តសញ្ញាណជនជាតិភាគតិចថាជាពួកអ៊ីស្លាម នៅសតវត្សទី ១៦ បានទទួលយកការកាត់សក់ខ្លីដោយមានឈ្នួតក្បាលជារចនាបថជាតិរបស់ពួកគេ ហើយពួកកាន់អ៊ីស្លាមនៅគ្រប់ទីកន្លែងនៅតំបន់ទីក្រុងនៅអាស៊ីអាគ្នេយ៍ទទួលយករចនាបថនេះធ្វើជាសញ្ញាណមួយនៃការចូលកាន់សាសនាអ៊ីស្លាម ។ ជាតួយ៉ាងដូចជាពួកចិនមូស្លីមនៅបាតង់ ត្រូវបានគេស្គាល់ថាជា «ពួកចិនសក់ខ្លី» ព្រោះពួកគេបានបោះបង់ចោលរចនាបថទុកសក់វែងនៃរាជវង្សម៉េង ទៅហើយ ។ «ហើយប្រសិនបើពួកគេកាត់សក់របស់ពួកគេហើយនោះពួកគេនឹងមិនអាចវិលត្រលប់មកកាន់ប្រទេសពួកគេវិញនោះទេដាច់ខាត» (ស្កត់ គ.ស.១៦០៦ ទំ. ១៧៦)។

ការផ្លាស់ប្ដូរសាសនាដ៏ធំមួយនៅកោះជ្វា និងស៊ូលាវ៉េស៊ីខាងត្បូង (South Sulawesi) មិនមានការប៉ះពាល់ដូចគ្នានេះទេ ។ ការទុកសក់វែងនៅតែជាទំនាមទម្លាប់សម្រាប់ពួកជ្វា ពួកប៊ូហ្គីស និងពួកម៉ាកាសាភាគច្រើនដដែលរហូតដល់សតវត្សទី ១៩ ។ សូម្បីតែនៅតំបន់អាចេអ៊ីស្លាម ប្រជាជនភាគច្រើននៅតែបន្តជឿថាសក់វែងតំណាងឲ្យអំណាចដ៏ពិសេសមួយ (ហ៊ីកាយ៉ាត់ ពូកាត់ មហាម៉ាត់ (Hikayat Pocut Muhamat) ទំ. ២៣៣) ។ ទោះជាយ៉ាងណាក៏ដោយសម្រាប់ពួកដែលមានបំណងចង់បង្ហាញពីលក្ខណៈតឹងរ៉ឹងរបស់សាសនាអ៊ីស្លាម រួមមានពួកកូនសិស្សសាសនាអ៊ីស្លាម ឬពួកអ្នកធ្វើសង្គ្រាមសាសនា បានកាត់សក់របស់ពួកគេ ។ ចលនាប្រឆាំងនឹងពួកហូឡង់ពួកឌីប៉ូណេហ្គូរ៉ូ (Diponegoro) នៅសតវត្សទី ១៩ ធ្វើការបែងចែកពួកជឿសាសនាជំនាន់ក្រោយចេញពីពួកជ្វា ដែល«បោះបង់ចោលសាសនា»ហើយទៅចូលរួមជាមួយនឹងពួកហូឡង់ (ការី ដារយេគ.ស.១៩៨១ ទំ. ២៥៤ ប៉ុន្តែសូមអានប្រៀបធៀបឯកសាររបស់ឡឺណង់ (Lennon) គ.ស.១៧៩៦ ទំ. ២៩៦)។

ប៉ុន្តែផ្ទុយទៅវិញ ការនិយមទុកសក់វែងសម្រាប់បុរសបានត្រលប់ទៅទ្វីបអឺរ៉ុបវិញនៅសតវត្សទ ១៧ ហើយក្ដី ក៏ពួកសាសនទូតសាសនាគ្រិស្តជាបន្តបន្ទាប់ដាក់កម្រិតឲ្យពួកប្រុសៗហ្វីលីពីន និងចិនដែលបានចូលក្នុងសាសនាហើយនោះ ឲ្យកាត់សក់ខ្លីវិញ (អាល់ស៊ីណា គ.ស.១៦៦៨A ទំ. ១៨-១៩ និងស៊ីរីណូ (Chirino) គ.ស.១៦០៦ ទំ. ៣០៧ និង ៣២៤) ។ ការផ្លាស់ប្ដូរដែលប៉ះពាល់ទាំងពីរភេទនៅប្រទេសសៀម និងកម្ពុជាមានលក្ខណៈអាថ៌កំបាំងជាងនេះទៅទៀត ។ លក្ខណៈនៃការ «កោរផុក» ដោយកាត់សក់ខាងលើចេញប្រមាណជាបីសង់ទីម៉ែត្រហើយកោរជុំវិញ

ក្បាលនៅតែមានប្រជាប្រិយភាពនៅក្នុងទាំងពីនៅក្នុងសតវត្សទី ១៩ ។ ការកាត់សក់បែបនេះត្រូវបានគេថាជាការជះឥទ្ធិពលរបស់ខ្មែរនៅក្នុងប្រទេសសៀម និងថាជាការជះឥទ្ធិពលរបស់សៀមនៅក្នុងប្រទេសកម្ពុជា (តែវែល គ.ស. ១៩៨០ ទំ. ៤០ និងអាយម៉ូនៀរ (Aymonier) គ.ស. ១៩០០ ទំ. ៣០) ។ ជាក់ស្ដែងណាស់ដែលថារចនាបថនៃការកាត់សក់នៅក្នុងប្រទេសទាំងពីរនេះមានការផ្លាស់ប្ដូរលើសពីមួយដង ប៉ុន្តែមិនមានម្ដងណាឡើយដែលថាការរៀបចំសក់របស់បុរស នឹងស្ត្រីមានលក្ខណៈខុសគ្នាគួរឲ្យកត់សម្គាល់នោះ ។ នៅសម័យអង្គរ និងនៅសម័យព្រះរាជាណាចក្រថៃ មុនសម័យកាលក្រុងអយុធ្យារបៀបតុបតែងសក់ដែលមានប្រជាប្រិយភាពដល់វណ្ណៈអភិជននោះហាក់ដូចជាការមូរ និងចងជាកំពូល ដោយមានការតុបតែងជាច្រើនបែបទៀត ទៅតាមវណ្ណៈរបស់ពួកគេនោះ (ជីវតាក្វាន់ គ.ស. ១២៩៧ ទំ. ១៣, ហ្វ្រេដេរីក គ.ស. ១៩៨១ ទំ. ២៤៧–៤៨ និងទែវៀល គ.ស. ១៩៨០ ទំ. ៣៩–៤១) ។ នៅចុងសតវត្សទី ១៦ ប្រជាជនកម្ពុជានៅតែត្រូវបានគេពណ៌នាថាមានសក់វែង «ប៉ុន្តែមិនវែងដូចសក់របស់ពួកជនជាតិចិននោះទេ» (សង់ អង់ទីនីយូ (San Antinio) គ.ស. ១៦០៤ទំ. ៨) ខណៈពេលដែលមកដល់គ.ស. ១៦៤៧ ពួកគេហាក់ដូចជានិយមការកោរផុកនៃពីរសតវត្សខាងមុខទៀតម (ពែលីយុត (Pelliot) គ.ស. ១៩៥១ ទំ. ១៥៨) ។ អ្នកសង្កេតនៅទីក្រុងអយុធ្យាជាច្រើនអ្នកនៅក្នុងសតវត្សទី១៧ (វ៉ាន់ វីលីយែង ១៦៣៦ ទំ. ៨៤, ឡា លូប៊ែរ គ.ស. ១៦៩១ ទំ. ២៨ និងកាអែមហ្វែរ (Kaempfer) គ.ស. ១៧២៧ ទំ. ៦៩) ពណ៌នាអំពីការកាត់សក់យ៉ាងខ្លីសម្រាប់បុរស និងស្ត្រីខណៈពេលដែលកាលប្បវត្តិរបស់ក្រុងឈៀងម៉ៃ (លេខ ១១៥) កត់ត្រានៅក្នុងសតវត្សទី ១៥ (តែប្រហែលជាមានការកត់ត្រាពេលវេលាខុស) ស្ដីអំពីរឿងនិទានរបស់អ្នកស៊ើបការណ៍ឈៀងម៉ៃម្នាក់ ដែលត្រូវតែកាត់សក់របស់គាត់ឲ្យខ្លីដើម្បីកុំឲ្យគេងាយចំណាំនៅក្នុងទីក្រុងអយុធ្យា ។ ទោះជាយ៉ាងណាមិញ អ៊ីប្រាហ៊ីម (Ibrahim គ.ស. ១៦៨៨ ទំ. ៥៦) បានអះអាងថាមានតែពួកអ្នកក្រនៅអយុធ្យាប៉ុណ្ណោះដែល «ពុំមានសក់ទាល់តែសោះ» ខណៈពេលដែលពួកអភិជនអ្នកមានប្រដែងគ្នាក្នុងការតុបតែងសក់របស់ពួកគេ ។

ទំនងជាសមហេតុផលហើយក្នុងការសន្និដ្ឋានថា (សូមមើលរូបទី ១៤ a និង ១៤ b) ដើមដំបូងឡើយ មានការដាក់ឲ្យកាត់សក់ដក់ចំពោះប្រជាជនកម្ពុជា (ប្រហែលជាមុនដំបូងគេ) ចំពោះប្រជាជនថៃ ធ្វើជាសញ្ញានៃឋានៈទាបដែលប្រហែលជាទំនាក់ទំនងជាមួយនឹងចំនួនដ៏ច្រើននៃឈ្លើយសឹកកម្ពុជា ដោយរួមទាំងជនជាតិថៃខ្លះដែលត្រូវបានចាប់ជាឈ្លើយសឹកដោយកម្ពុជាដែលធ្វើដួយឲ្យកើនចំនួនប្រជាជនសៀមឡើងវិញនៅទសវត្ស ១៥៩០។ ក្សត្រអង្គបន្តបន្ទាប់ក្រោយមកអាចយកការកាត់សក់នោះ ធ្វើជា «រចនាបថសក់សម្រាប់ជាតិ» ។ នៅប្រទេសភូមា អំឡុង គ.ស. ១៧០០ ការកំណត់ឲ្យអ្នកមានឋានៈជាទាសករមានសក់ខ្លី នៅតែអនុវត្តនៅឡើយ (ហាំមីុលតុង (Hamilton) គ.ស. ១៧២៧ ទំ. ២៨) ។ មិនថាមូលហេតុពិតប្រាកដជាអ្វីនោះទេ ពួកអ្នកនិពន្ធមូស្លីម និងគ្រិស្ត យល់ឃើញថា នេះជាការចាំបាច់ណាស់ដើម្បីពន្យល់ដោយប្រឌិត នូវការកាត់សក់យ៉ាងខ្លីចំពោះស្ត្រីជនជាតិថៃ ដែលការដែលមានសក់ខ្លីមានលក្ខណៈ «ចម្លែក» ណាស់ ។ មានការបកស្រាយមួយថា មាននារី (hikayat) ជនជាតិម៉ាឡេម្នាក់បានធ្វើឲ្យស្ដេចសៀមមួយអង្គខ្វាល់យ៉ាងខ្លាំង នៅពេលដែលឃើញសក់ដ៏វែងមួយសរសៃនៅក្នុងបាយរបស់ព្រះអង្គ (រិកលែហ្វស៍ (Ricklefs និងវូរហូវ (Voorhoeve) គ.ស. ១៩៧៧ ទំ. ១០០) ។ រីឯការពន្យល់មួយបែបទៀតនោះ គឺថា ការកាត់សក់នារីឲ្យខ្លីនោះគឺដើម្បីបញ្ឆោតពួកប្រហារភូមា ថានារីសក់ខ្លីនៅចាំពីក្រោយនៅទីក្រុងដែលហ៊ុំព័ទ្ធនោះ គឺជាអ្នកចំបាំងបុរសៗ (ស្មីតស៍ (Smith) គ.ស. ១៩៤៦ ទំ. ៨០) ។

សាសនាអ៊ីស្លាម និងសាសនាគ្រិស្តគឺជាកត្តាចម្បងមួយ តែមិនមែនជាកត្តាតែមួយគត់នោះទេ ក្នុងការធ្វើឲ្យ

មានការបោះបង់ចោលជាបន្តបន្ទាប់ នូវការទុកសក់វែង ការសាក់រូបលើដងខ្លួន និងការធ្វើឲ្យទងត្រចៀកយារវែង នៅក្នុង សតវត្សទី ១៦ និង ១៧ ។ ការទុកក្រចកឲ្យវែង ដែលទទួលឥទ្ធិពលដោយពួកមិនធ្វើការដោយកម្លាំង ក៏សាបរលាបនៅកំលុងពេលដូចគ្នានេះដែរ ព្រោះពួកអ៊ីស្លាម និងពួកគ្រិស្តសាសនាមិនចូលចិត្តការទុកក្រចកឲ្យវែងនោះទេ ( ដ្រូវស៍ (Drewes) គ.ស. ១៩៧៨ ទំ. ៦៦ និងបូរី (Borri) គ.ស. ១៦៣៣ ទំ. F) ។ ទោះបីជាការប្រែប្រួលទាំងនេះកើតឡើងក្នុងនាមសាសនាទូទៅក៏ដោយ ក៏ការប្រែប្រួលនេះអាចចាត់ទុកថាជាផ្នែកមួយនៃដំណើរការលទ្ធិមិនចូលរួមក្នុងសាសនាដែលជាទូទៅទាក់ទងទៅនឹងកំណើននគរូបនីយកម្មដ៏គំហុក ។ រូបរាងកាយបានចាប់ផ្តើមក្លាយជាប្រភពមួយដែលមិនមែនជាកម្លាំងមន្តអាគម ដែលអាចឲ្យគេបែងចែកឲ្យដាច់ចេញពីពិភពលោកដ៏សមញ្ញរបស់មនុស្សលោក ។ ផ្ទុយទៅវិញ រូបរាងកាយគ្រាន់តែជាយានតសម្រាប់ចម្លងវិញ្ញាណអព្ភូហារិកតែប៉ុណ្ណោះ ។ ដូចជាវិស័យឯទៀតដែរ បម្រែបម្រួលទៅរកឥរិយាបថបែបទំនើបនេះបានចាប់ផ្តើមនៅយុគសម័យពាណិជ្ជកម្ម ក៏ប៉ុន្តែត្រូវកកស្ទះគាំង រីត្រូវពន្យឺតជាបន្តបន្ទាប់ ដោយសារការដួលរលំនៃជីវិតរស់នៅទីក្រុងនៅអាស៊ីអាគ្នេយ៍ ។



រូបភាពទី ១៤ a ៖ រចនាបថសក់បុរសថៃ មានឋានៈខ្ពស់ នៅពាក់កណ្តាលសតវត្សទី ១៩



១៤ b ៖ រចនាបថសក់ស្ត្រីថៃសម្រាប់ម្ចាស់ក្សត្រី មកុដ (King Mongkut) ។ ស្ត្រីកោរសក់ខាងកៀនក្បាលតិចជាងបុរស ប៉ុន្តែតម្រឹមរង្វង់មូលយ៉ាងខ្លីជុំវិញសក់ជក់នោះ ។ នៅពេលខ្លះសក់ស្ត្រីត្រូវបានគេប្រៀបប្រដូចទៅនឹងផ្កាឈូករីកមួយ ។

## ការស្លៀកពាក់

បន្ទាប់ពីពេលបាយរួច គាត់នឹងស្លៀកសារុង របស់គាត់ ហើយគាត់នឹងប្រែសារុងនោះម្តងហើយម្តងទៀតពី ១២ ទៅ ១៣ ដងទាល់តែដល់គាត់ពេញចិត្ត ។ បន្ទាប់មកគាត់ពាក់អាវ និងកំណាត់ផ្សេងៗសម្រាប់ពាក់លើក្បាលហើយការតម្រូវចុះឡើងក៏ត្រូវធ្វើដូចពេលដែលគាត់ធ្វើពេលស្លៀកសារុងដូច្នោះដែរ  រហូតទាល់តែគាត់ពេញចិត្ត ។ ដូចគ្នាដែរ ជាមួយនឹងក្រមាដែលគាត់ត្រូវយកតុបតែងខ្លួន. . .នៅពេលដែលកំពុងរៀបចំនោះគាត់ដើរចុះដើរឡើងអាចទៅដល់មាត់ទ្វាររួចហើយ ក៏ត្រលប់មកវិញ មកសួរប្រពន្ធរបស់គាត់ថាតើមានខុសទាស់អ្វីដែរ ឬអត់ចំពោះសម្លៀកបំពាក់របស់គាត់នោះ។

—*Sejarah Melayu* គ.ស. ១៦១២ ទំ.  ១២៧

ការយកចិត្តទុកដាក់ដ៏សំខាន់មួយ គឺចំណាយទៅលើការតុបតែងកាយដោយសម្លៀកបំពាក់ និងជាពិសេសគ្រឿងអលង្ការ ។ ទ្រព្យសម្បត្តិត្រូវបានចំណាយយ៉ាងខ្ជះខ្ជាយទៅលើវត្ថុទាំងពីរនេះ ហើយ សូម្បីតែអ្នកក្រក៏ខិតខំរកយកមកពាក់ឲ្យបានមើលទៅអស្ចារ្យនៅក្នុងពិធីសំខាន់ម្ដងៗ (សង់ហ្គឺម៉ាណូ គ.ស.១៥១៣ ទំ. ១៥៩ និងហ្វាំងឡៃសង់ (Finlayson) ១៥២៦ ទំ. ៣៧៣) ។ ជនជាតិអឺរ៉ុបតែងតែមានការងឿងឆ្ងល់ និងភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះការតុបតែងខ្លួនរបស់ប្រជាជនអាស៊ីអាគ្នេយ៍ មានតម្លៃរាប់រយដុល្លារៗ (អាល់ស៊ីណា គ.ស.១៦៦៨ A ទំ. ២១-២២ និងរបស់ ម៉ាក់ម៉ុកឃីង (MacMicking) គ.ស.១៨៥១ ទំ. ១៣៤) ។ អ្នកដឹកនាំឋានៈខ្ពស់ គឺជាអ្នកដែលចំណាយច្រើនជាងគេមានដូចជា ស្ដេចស៊ុលតង់ នៃ ទែរណាត់ (Ternate) ដែលបានជួបជាមួយនឹងដ្រេក ឧរាកក្នុងសម្លៀកបំពាក់ស្រោបដោយមាសដ៏ល្អប្រណិត គ្រឿងអលង្ការ និងខ្សែកដ៏សម្បើមដែលធ្វើពី «មាសដ៏ប្រណិតៗ» (ដ្រេក គ.ស. ១៥៣០ ទំ. ៧០) និងមានដូចជា ស្ដេចស៊ុលតង់នៅចូហូរនៅ គ.ស.១៦០៦ ដោយមានការពណ៌នាដូចតទៅ÷«ជុំវិញករបស់គាត់មានប្រវាក់មាសបីខ្សែភ្ជាប់ជាមួយនឹងក្រវិលអលង្ការជាច្រើន ។ នៅជុំវិញដៃខាងឆ្វេងរបស់គាត់មានខ្សែដៃមាសពីរខ្សែនិងមានមួយខ្សែទៀតពាក់នៅដៃខាងស្ដាំរបស់គាត់ ។ លើសពីនេះទៅទៀតនៅលើម្រាមដៃរបស់គាត់មានពាក់ចិញ្ចៀនដ៏ស្រស់ស្អាតចំនួនប្រាំមួយហើយនៅនឹងចង្កេះមានពាក់កាំបិតស្នៀតដែលធ្វើយ៉ាងពិសេស ដែលគេហៅថាគ្រីស (Kris) ។ ដង និងស្រោមកាំបិតនោះធ្វើពីមាសដោយមានដាំពេជ្រ ត្បូងក្រហមនិងត្បូងកណ្ដៀងផងដែរដែលធ្វើឲ្យពួកហូឡង់ប៉ាន់ប្រមាណតម្លៃនៃកាំបិតនោះរហូតដល់ទៅ ៥០.០០០ (Guilder) (លុយរបស់ហូឡង់) ។ (វើរកែន (Verken) គ.ស.១៦០៦ ដកស្រង់ដោយ ក្រាតស៍ (Kratz) គ.ស.១៩៨១ ទំ. ៧០)។

ទោះបីជាគេខ្ជះខ្ជាយក៏ដោយ ភាពខុសគ្នាក្នុងការស្លៀកពាក់រវាងអ្នកមាន និងអ្នកក្រ អ្នកបម្រើ និងចៅហ្វាយនាយរវាងព្រះមហាក្សត្រ និងប្រជារាស្ត្រ មិនសូវត្រូវបានគេសម្គាល់ដូចនៅសម័យបុរេឧស្សាហកម្មនៅអឺរ៉ុបនោះទេ ដែលទីតាំងរបស់មនុស្សម្នាក់ៗអាចឲ្យគេដឹងបានដោយមើលពីរបៀបស្លៀកពាក់របស់គេនោះៗ (សង់ណែត (Sennet) គ.ស.១៩៧៧) ។ ហ្វ្រេដេរិកស៊ី (គ.ស.១៥៨១ ទំ. ២៦៨) បានកត់ត្រាថា «នៅពៃហ្គូ (Pegu) ការតប់តែងសម្លៀកបំពាក់របស់ពួកគេមានលក្ខណៈដូចគ្នាតែមួយមិនថាសម្រាប់អភិជន ឬក៏ជនធម្មតាក៏ដោយ ។ ភាពខុសគ្នាមានតែមួយគត់ គឺគុណភាពរបស់កំណាត់សម្លៀកបំពាក់នោះ» ។ ច្បាប់ដែលចែងពីការប្រើប្រាស់សម្ភារៈតែងតែកំណត់ទុកពណ៌ ឬក៏ប្រភេទកំណាត់ដាក់លាក់ណាមួយសម្រាប់តែពួកអភិជនតាមលំដាប់ថ្នាក់តែប៉ុណ្ណោះ ដូចគ្នានេះដែរក៏មានការដាក់បញ្ញាទៅលើការប្រើប្រាស់គ្រឿងអលង្ការតាមប្រភេទផងដែរ ។ ការហាមឃាត់នៅប្រទេសមាឡេដែលមិនឲ្យប្រជាជនសាមញ្ញស្លៀកសម្លៀកបំពាក់ពណ៌លឿង គឺធ្វើឡើងដោយអ្នកដឹកនាំជនជាតិអ៊ីស្លាមដំបូងគេម្នាក់នៅម៉ាឡាកា នៅដើមសតវត្សទី ១៥ (សេចារ៉ា ម៉េល័យយូ (Sejarah Melayu) គ.ស.១៦១២ ទំ. ៥៤ និងពៀរស៍ (Pires) គ.ស.១៥១៥ ទំ. ២៦៥) ថ្វីដ្បិតតែមានការបន្តរចាត់ទុកថាមាសមានទំនាក់ទំនងជាមួយនឹងព្រះមហាក្សត្រនៅអាស៊ីអាគ្នេយ៍ក៏ដោយ (ស៊ីមស៍ គ.ស.១៨២៧ I ទំ. ៣០០ និងប្រ៊ូអេរ (Bruére) គ.ស.១៨២៩ទំ. ១៩២) ។ ទោះជាយ៉ាងណាក៏ដោយ កំណាត់សម្លៀកបំពាក់ទាំងអស់នោះមានលក្ខណៈដូចៗគ្នា ដោយមានការភ្ញាក់ផ្អើលពីអ្នកសង្កេតមកពីប្រទេសខាងលិច (យោងតាមឯកសារស្ដីអំពី «ទំនាក់ទំនង» គ.ស.១៥៧២ ទំ. ១៦៦៦ និងម៉ង់ដែស្លូ (Mandeslo) គ.ស.១៦៦២, ទំ. ១១៥ និងអ៊ីប្រាហ៊ីម គ.ស.១៦៨៨ ទំ. ៥៦) ។

សម្រាប់អ្នកមកទស្សនាទាំងអស់នៅអាស៊ីអាគ្នេយ៍ ទោះបីជាមកពីអឺរ៉ុប ចិន ឬអាស៊ីខាងលិចក៏ដោយ «ភាពអាក្រាត» របស់អ្នកស្រុកនៅអាស៊ីអាគ្នេយ៍ គឺជាការភ្ញាក់ផ្អើលមួយ ។ ពួកគេចង់មានន័យថា ប្រជាជននៅអាស៊ី

អាគ្នេយ៍ស្ទើរតែទាំងអស់គ្នាដើរដោយជើងទទេ មិនមានពាក់មួក (លើកលែងតែពួកម៉ូស្លីម និងពួកអភិជនមួយចំនួនប៉ុណ្ណោះ) ហើយតែងតែមិនមានពាក់អ្វីនៅល្វែងខាងលើចាប់ពីចង្កេះទៅ (សូមមើលរូបភាព ១៥a និង១៥b) ។ សម្រាប់ពួកអេស្ប៉ាញ «ពួកម៉ូរ៉ូ (ពួកស៊ុលតង់នៅអាចេ) ដែលមិនមានពាក់ស្បែកជើងពាក់សម្លៀកបំពាក់រយីរយៀកបន្តិចបន្តួចស្ទើរតែអាក្រាតនោះ» ហាក់ដូចជាចម្លែកណាស់ ព្រោះថាពួកម៉ូរ៉ូនេះគួរតែបានជនជាតិពាំទុយហ្គាល់មានភាពរំបាកនៅសមរភូមិ (សាំងឌេ (Sande) គ.ស. ១៥៧៦ ទំ. ៦៥) ។ រាល់ពេលដែលពួកគេសំលឹងមើល «សុដន់ដ៏សខ្ចី» របស់នារីកម្ពុជា ដូច ជីវតាក្វាន់ (គ.ស. ១២៩៧ ទំ. ១៥) ប៉ុន្តែនៅពេលដែលពួកគេព្យាយាមគ្របដណ្ដប់សុដន់ទាំងនោះ ដូចពួកអាចារ្យអេស្ប៉ាញ នៅក្នុងប្រទេសហ្វីលីពីននោះ ពួកមកពីក្រៅហាក់បីដូចជាយល់ថាការបង្ហាញសាច់ដូច្នេះ គឺជាការបង្ហាញនូវភាពរីករាយខាងផ្លូវភេទ ។ ការសង្កេតដោយប្រុងប្រយត្នដាងនេះបានកត់សម្គាល់ថាប្រជាជនរស់នៅអាស៊ីអាគ្នេយ៍តាមពិតទៅ គឺជាអ្នកមានចរិតរម្យទមបំផុត «គឺហ្មត់ចត់បំផុតក្នុងពិភពលោក» ចំពោះប្រដាប់ភេទរបស់ពួកគេ ។ ជាតួយ៉ាង ពួកនារីកបារាំងត្រូវតែស្លៀកសារុងមុននឹងចុះមុជទឹកនៅក្នុងទន្លេ បើមិនដូច្នេះនោះទេពួកសៀម នឹងមិនអនុញ្ញាតនោះទេ (ឡា លូប៊ែរ គ.ស. ១៦៩១ ទំ. ២៦)។

សម្លៀកបំពាក់ដែលដេរមានដៃ ប៉ុន្តែហាក់ដូចជាចូលមកក្នុងតំបន់អាស៊ីអាគ្នេយ៍យឺតក្រោយមកទៀត ដោយមានការលើកលែងសម្រាប់ប្រទេសវៀតណាម ។ នៅពេលជនជាតិពាំទុយហ្គាល់មកដល់ អ្នកពាក់អាវផាយមានតែពួកមូស្លីម ប៉ុន្តែអ្នកដែលមានទំនាក់ទំនងជាមួយពួកគេជិតស្និទ្ធតែប៉ុណ្ណោះ (ដូចជាពួក តាហ្គាឡុក (Tagalogs) នៅហ្វីលីពីន) និងពួកភូមាថ្នាក់ខ្ពស់ បើមិនអ៊ុចឹងទេ គឺពួកអ្នកដែលមានលទ្ធភាពទិញអាវនោះបានតែប៉ុណ្ណោះ ។ ហេតុផលពីរដែលអាចពន្យល់ព្រឹត្តិការណ៍នេះបាន គឺថាសីតុណ្ហភាពមធ្យម និងបច្ចេកវិទ្យាដេរប៉ាក់នៅមានកម្រិតនៅឡើយនាសម័យនោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ការទទួលយកនូវការប្រើប្រាស់អាវផាយនេះមានភាពយឺតយ៉ាវផងដែរ ដោយសារតែរាងកាយបុគ្គលផ្ទាល់នេះឯងគឺជាលក្ខណៈសិល្បៈ។ ក្រោយពីភាពជឿនលឿននៃការដេរសម្លៀកបំពាក់ និងសូម្បីតែអាវដែលដេរដោយម៉ាស៊ីននោះ ពួកជ្វា បាលី និងថៃ ចំហរផ្នែកខាងលើនៃដងខ្លួនរបស់ពួកគេសម្រាប់ទុកលាបទឹកអប់ និងលាបម្សៅ ពេលមានពិធីផ្លូវការម្ដងៗ ។ ក្រលហ្វឺឌ (Crawfurd) (គ.ស. ១៨២០I ទំ. ២៩) នៅតែអាចនិយាយបានអំពី ពួកជ្វា ថា «នៅពេលស្លៀកពាក់ពេញលេញហើយ ពួកគេនៅតែមស្ទើតែស្ថិតក្នុងសម្លៀកបំពាក់អាក្រាតទាំងអស់ដដែល» ។ ដូចគ្នានេះដែរនៅពិធីរៀបអាពាហ៍ពិពាហ៍របស់ជនជាតិ ស៊ូឡាវេស៊ី ខាងត្បូងនៅសតវត្សទី ១៩ កូនកំលោះនៅតែមិនមានពាក់អាវធំ ខណៈពេលដែលកូនក្រមុំ និងស្ត្រីមិនទាន់រៀបការដទៃទៀតពាក់ បាជូ (អាវផាយ) ស្ដើងមែនទែនដែលអាវនោះមិនបានបិទបាំងអ្វីទាល់តែសោះ (វ៉ាឡង់ទិញ (Valentijn) គ.ស. ១៧២៣ III ទំ. ១១៨ និងរបស់ ប្រូក (Brooke) គ.ស. ១៨៤៨ ទំ. ៨១) ។ នៅក្នុងពិធីបុណ្យទានម្ដងៗសូម្បីតែ កេបាយ៉ា (Kebaya) កំណាត់រលុងសម្រាប់រុំពទ្ធខាងលើរបស់ស្ត្រីម៉ាឡេ ដែលប្រហែលជាទទួលឥទ្ធិពលពីពួកពាំទុយហ្គាល់ (វីនស្ទឺដត៍ (Winstedt) គ.ស. ១៩៣៥ ទំ. ៩៨) ក៏ជាកំណាត់ស្ដើងអាចមើលឃើញធ្លុះដែរ ។

ក្មេងៗមិនស្លៀកសម្លៀកបំពាក់ក្នុងរយៈពេលពី ៦ ទៅ ៩ ឆ្នាំដំបូងទេ តែគេមានវត្ថុម្យ៉ាងហៅថា កាសេ–ស៊ីច (cache-sexe) សម្រាប់បិទបាំងកេរ្តិ៍ខ្មាសរបស់ពួកគេ ។ ក្រោយមកទៀត សម្លៀកបំពាក់សម្រាប់បុរស និងស្ត្រី គឺជាក្រណាត់ដែលមិនដេរភ្ជាប់គ្នានោះទេដែលគេរុំមួយ ប៉ុន្តែរជុំខ្លួនរបស់ពួកគេទៅបានហើយ ។ ពេលខ្លះស្ត្រី (ជាពិសេសបន្ទាប់ អ៊ីស្លាម) បានលើកកំណាត់នោះឡើងមកក្រោមក្លៀកដើម្បីគ្របសុដន់ ។ រីឯកន្លែងដទៃទៀត គេផុតកំណាត់ជុំវិញចង្កេះដូចដែលការស្លៀកពាក់បុរសដែរ ។ បុរសជនជាតិថៃ និងភូមា (ក្រោយមកមាននារីថៃផង

*ដែរនោះ) បានចងក្បិនដូចពួកឥណ្ឌា ស្លៀកដូតី (dhoti) ដូច្នោះដែរ ។ ស្ត្រីភូមា រុំកំណាត់ជុំវិញខ្លួនពួកគេតែមួយជុំប៉ុណ្ណោះ ដែលធ្វើឲ្យមើលឃើញដល់គល់ភ្លៅពេលកំពុងដើរ (សូមមើលរូបភាព ១៣) ។ អ្នកសង្កេតជាច្រើនមកពីអឺរ៉ុបបានពត៌នាការអនុវត្តបែបនេះទៅឲ្យម្ចាស់ក្សត្រីជំនាន់ដើមម្នាក់ ដែលចង់បញ្ឈាស់ពួកបុរសភូមាឲ្យងាកចេញពីទំនោររួមភេទជាមួយមនុស្សភេទដូចគ្នា (ហ្វ្រេដេរិក គ.ស. ១៥៨១ ទំ. ២៦៩ និងសង់ហ្គឺម៉ាណូ គ.ស. ១៥១៨ ទំ. ១៥៧-៥៨) ។ ដូចរឿងនិទានដទៃទៀតដែរ រឿងមួយនេះប្រាប់យើងឲ្យដឹងពីអាកប្បកិរិយារបស់ជនជាតិអឺរ៉ុបច្រើនជាងរបស់ពួកភូមា ។*



រូបភាព ១៥ A៖ សម្លៀកបំពាក់របស់បុរស និងស្ត្រីសាមញ្ញ (ខាងឆ្វេង) កំពុងធ្វើដំណើរទៅផ្សារនៅបាតង់និងសម្លៀកបំពាក់របស់ឈ្មួញអ្នកមានជនជាតិជ្វា ជាមួយនិងអ្នកបម្រើរបស់គាត់ (ខាងស្តាំ) គូសដោយជាងគំនូសហូឡង់ ដែលផ្អែកគំនូសនេះទៅលើការពណ៌នានៅក្នុងឯកសាររបស់ ឡូដឺវីស្កស៍ គ.ស. ១៥៩៨




រូបភាព ១៥ B.៖ សម្លៀកបំពាក់របស់ស្ត្រីសាមញ្ញម្នាក់  និងកូនរបស់គាត់

នៅកោះជ្វា រហូតដល់ការជឿនលឿននៃសាសនាអ៊ីស្លាម នៅសៀមរហូតដល់សតវត្សទី ១៨ និងនៅកម្ពុជា បាលី និងនៅឡាំប៊ុក (Lombok) រហូតដល់ពេលថ្មីៗនេះ បន្ថែមទៅលើការស្លៀកសារុងសម្រាប់ស្ត្រី គឺការរុំក្រមាយ៉ាងរលុង ដែលជាទូទៅគេរុំគ្របនៅលើសុដន់ ដោយចុងទាំងសងខាងរបស់ក្រមានោះទម្លាក់ទៅលើស្មាទាំងសងខាងដែរ (ពីហ្គោដ (Pigeaud) គ.ស. ១៩៦២ ទំ. ១៥៨, ឡា លូប៊ែរ គ.ស. ១៦៩១ទំ. ២៦ និងស្សូលីងហ្គឺរ (Zollinger) គ.ស. ១៨៤៧ទំ. ៣៣៤) ។ ជាមួយនឹងការមកដល់នៃសាសនាអ៊ីស្លាមស្ត្រីជនជាតិជ្វាមានការប្រើកំណាត់បន្ថែមមួយទៀតដែលមាននៅឥណ្ឌាបុរាណផងដែរនោះ គឺកំណាត់តូចមានក្រឡា ដែលយកមករុំយ៉ាងតឹងជុំវិញដើមទ្រូងធ្វើឲ្យសង្កត់ឬបសុដន់(វើហែល (Verhael) គ.ស. ១៥៩៧ ទំ. ២៩, ក្រូលហ្វីង គ.ស. ១៨២០ I ទំ. ២១០ និងសូមមើលរូបភាព ១៥A)។

គំរូមូលដ្ឋាននៃសម្លៀកបំពាក់របស់ប្រជាជននៅអាស៊ីអាគ្នេយ៍ត្រូវបានគេកែប្រែជាច្រើនរចនាបថរវាងសតវត្សទី ១៥ និង ១៧ ។ មូលហេតុនៃការប្រែប្រួលផ្នែកសម្លៀកបំពាក់នេះក៏ដូចជាផ្នែកដទៃទៀតដែរនោះគឺជាលក្ខណៈនៃជំនួញពាណិជ្ជកម្ម និងនគរូបនីយកម្ម ។ កាលប្រវត្តិរបស់ប្រទេសពេហ្គូ (Pegu) ទាក់ទងទៅនឹងរជ្ជកាលរបស់ម្ចាស់ក្សត្រី ស៊ីណាវប៊ុយ (Shinawbu) (គ.ស. ១៤៥៣–៧២) ដែលមានអ្នកជំនួញបរទេសជាច្រើនបានមកដល់និង «មានស្លៀកសម្លៀកបំពាក់ប្លែកៗជាច្រើន ហើយមនុស្សម្នាមានកំណាក់ល្អប្រណីតយ៉ាងសម្បូរបែប» (លីប៊ែម៉ង់ (Lieberman) គ.ស. ១៩៨៤ ទំ. ២៦) ។ កំណត់ត្រាប្រវត្តិសាស្ត្រប្រចាំឆ្នាំរបស់ម៉ាឡេស៊ីបង្ហាញរិតតែច្បាស់អំពីតួនាទីដ៏សំខាន់សម្រាប់ ស៊ុលតង់ ម៉ានូដ (Sultan Mahnud) នៃក្រុងម៉ាឡាកា (គ.ស. ១៤៨៨–១៥១១) ក្នុងការបញ្ជូនគណៈប្រតិភូទៅឥណ្ឌាខាងត្បូងដើម្បីប្រមូលយកសម្លៀកបំពាក់ដែលកម្រចំនួន ៤០ ប្រភេទ (សេច្បារ៉ា មេហ្គូ (Sejarah Megu) គ.ស. ១៦១២ ទំ. ១៤០–៤១) ។ អ្នកជំនួញអឺរ៉ុប(ក៏ដូចជាពួកឥណ្ឌា និងចិនដែលចូលមកមុននោះដែរ) ត្រូវបានពួកមានអំណាចនៅក្នុងព្រះរាជវាំងបង្ខំឲ្យយកសម្លៀកបំពាក់ប្លែកៗបន្ថែមមកទៀត៖ «ជារឿងគួរឲ្យចម្លែកណាស់សម្រាប់ការទាមទាររបស់ពួកក្សត្រា បានតង់ ទាំងនេះ ដែលចង់បាននូវអ្វីដែលកម្រ ដែលអ្នកដទៃមិនមាននោះដើម្បីបង្ហាញអំពីអំនួតដ៏អស្ចារ្យរបស់ទាំងខុសឆ្គង... គ្រឿងតុបតែងលម្អដូចជា ចិញ្ចៀន គ្រឿងអលង្ការ និងបំណែកចានបុរាណៗ មិនមានតម្លៃសម្រាប់ពួកក្សត្រាទាំងនោះឡើយ» (របស់ ហលលី (Hawly) គ.ស. ១៦២៧ ទំ. ៣៧៤) សម្លៀកបំពាក់អឺរ៉ុបមិនអាចប្រជែងជាមួយនឹងសម្លៀកបំពាក់ឥណ្ឌា និងចិនបានទេក្នុងភាពលេចធ្លោ ប៉ុន្តែសម្លៀកបំពាក់ដែលធ្វើពីកំណាត់ល្អៗសម្រាប់ពួកថ្នាក់ខ្ពស់ពិតជាមានទីផ្សារ ។ «អាវកាក់ដែលបានលក់ក្នុងតម្លៃ ៣០០ ដុល្លាអេស្ប៉ាញ នៅក្រុងបានតង់» ត្រូវបានកត់ត្រាទុកនៅក្នុង គ.ស. ១៦៦៣ ដោយជនជាតិអង់គ្លេស (អែសភី SP គ.ស. ១៦៣០–៣៤ ទំ. ៤៤៩)។

ការកែប្រែថ្មីជាញឹកញាប់ គឺការពាក់អាវធំរបស់ពួកអឺរ៉ុប ឬពួកអាស៊ីខាងលិចពីលើកំណាត់សម្លៀកបំពាក់ដ៏មានតម្លៃថ្លៃ ដែលប្រើជំនួសសារុងបុរាណ ។ ការប្រែប្រួលនេះហាក់ដូចជាមិនស៊ីគ្នាជាមួយនឹងអ្វីដែលអ្នកសង្កេតឯទៃទៀតដូចជា ណាវ៉ារ៉ែត (Navarrete) គ.ស. ១៦៧៦ I ទំ. ១១៦) ដែលគាត់បានជួបជាមួយនឹងអ្នកដឹកនាំនៅម៉ាកាសា «ពាក់អាវធំបែបអឺរ៉ុប ពីលើខ្លួនទទេរបស់ពួកគេ ហើយដៃរបស់ពួកគេមិនមានពាក់អ្វីទាំងអស់... និងក្បាលពោះរបស់ពួកគេចំហចោល» ។ កំណាត់សម្លៀកបំពាក់ដេរដែលមានភាពងាយស្រួលជាងនេះត្រូវបានគេប្រឌិតឡើងបន្ទាប់ពីនោះមក ។ មិនជ្រុលពេកទេដែលថារចនាបថសម្លៀកបំពាក់សម័យទំនើបភាគច្រើនមានដើមកំណើតមកពីការពិសោធសម្លៀកបំពាក់សម័យដើមពីសតវត្សទី ១៥ ទៅដល់សតវត្សទី ១៧ ។

*ការបញ្ជាក់គួឲ្យចាប់អារម្មណ៍មួយអំពីការធ្វើពិសោធន៍សម្លៀកបំពាក់នេះមាននៅក្នុងកាលប្បវត្តរបស់បាន់ច្យាម៉ាស៊ីន* (Banjamarsin)*នៃសតវត្សទី ១៧ ដែលធ្វើឡើងដើម្បីដាក់បញ្ហាខាងសង្គមអភិរក្សឲ្យពួកមានចរិតមិនល្អ និងជាពួកពិបាកគ្រប់គ្រងធ្វើតាម ។ បទបញ្ជានេះ គឺផ្អែកទៅលើអ្វីដែលគេយល់ថា ជាគំរូរបស់ពួកជ្វាសុទ្ធសាធ ។ កាលប្បវត្តនេះបានផ្តល់ឱវាទដល់អគ្គក្សត្រាដើម (យ៉ាងចាស់គំរិល) ដូចតទៅ÷*

> មិនត្រូវមាននរណាម្នាក់ស្លៀកសម្លៀកបំពាក់តាមជនជាតិ ហូឡង់ ចិន សៀម អាឆេ ម៉ាកាសារ ឬពួកប៊ូហ្គីស (Bugis) នោះទេ ។ មិនត្រូវត្រាប់តាមនរណាម្នាក់ក្នុងចំណោមពួកទាំងនេះឡើយ ។ អ្នកមិនត្រូវស្លៀកពាក់តាមសម្លៀកបំពាក់ប្រពៃណីចាស់នៅពេលដែលយើងរស់នៅក្នុងតំបន់ កែឡាំង (Keling)(ឥណ្ឌាខាងត្បូង) នោះឡើយ ព្រោះវាមិនមែនជាប្រទេសរបស់យើងទៀតទេ ។ ឥឡូវយើងបានបង្កើតប្រទេសផ្ទាល់របស់យើង ទៅតាមវិធី និងរបៀបរបស់ ម៉ាច្យាប៉ាហ៊ីត (Majapahit) ។ ដូចនេះយើងទាំងអស់គ្នាត្រូវតែស្លៀកពាក់តាមជនជាតិជ្វា ។ យោងតាមរឿងព្រេងនិទានរបស់មនុស្សជាយូរមកហើយនៅពេលដែលមាននរណាម្នាក់ស្លៀកពាក់តាមជនជាតិដទៃនោះ ទុក្ខវេទនានឹងធ្លាក់មកប្រទេសខ្លួនដោយខានពុំបាន (ហ៊ីកាយ៉ាត បានច្យារ (Hikayat Banjar) ទំ. ២៦៤)។

*សម្រាប់រដ្ឋថ្មីៗភាគច្រើន ដំណើរការក្នុងការកំណត់រចនាបថ (សម្លៀកបំពាក់) ជាតិរបស់ខ្លួនគឺទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការផ្លាស់ប្តូរសាសនា ។ ការចូលក្នុងសាសនាអ៊ីស្លាម ឬក៏សាសនាគ្រីស្ត ត្រូវបានគេសម្គាល់បានថាមានការផ្លាស់ប្តូរសម្លៀកបំពាក់ក៏ដូចជាការតុបតែងសក់ និងរាងកាយដោយជៀសមិនបានដែរ ។ សម្រាប់ប្រជាជនជាច្រើន (ទោះបីមិនមែនសម្រាប់ជនជាតិជ្វាក៏ដោយ) ការស្រុះស្រួលខាងវប្បធម៌ម៉ាឡេស៊ី បានក្លាយទៅជាសម្លៀកបំពាក់សម្រាប់សាសនាអ៊ីស្លាម ។ អាវផាយ (ដែលគេហៅថា បាច្យូ* (baju) *ឬកេបាច្យា* (kebaya) *នោះ) ត្រូវបានគេចាត់ទុកជារួមជាមួយនឹងសារុងសាមញ្ញសម្រាប់ស្ត្រី និងជាអាវធំរលុងៗ និងកំណាត់ទទូលក្បាលសម្រាប់បុរសផងដែរ ។ ក្រមារបស់ស្ត្រី (ដែលគេហៅថា សេឡែនដង់* (selengdang)*) អាចប្រើសម្រាប់គោលបំណងផ្សេងទៀត ។ ការផ្លាស់ប្តូរទម្លាប់ដ៏ឆាប់រហ័សមួយបានកើតមាននៅសតវត្សទី ១៧ នៅក្រុងម៉ាកាសារ ដែលប្រហែលមកពីនៅសម័យកែប្រែនោះ ទីក្រុងនោះគឺជាទីក្រុងជំសម្បូរមនុស្សសាសន៍ខុសៗគ្នារួចទៅហើយ ដែលតាមកត្តាសង្គមនៅពេលនោះការផ្លាស់ប្តូរតាមទិសដៅគាំទ្រមូលធននិយមនោះមានការ «យឺតយ៉ាវ» ទៅហើយ ។ ការពណ៌នាអំពីទីក្រុងនោះនៅក្នុងគ.ស. ១៦០៧ ពីរឆ្នាំក្រោយពីការទទួលយកសាសនាអ៊ីស្លាមដោយមេដឹកនាំរបស់ទីក្រុងនោះ បានកត់សម្គាល់ថា ការប្រើប្រាស់ពងស្វាស (សូមមើលជំពូកបន្ទាប់) និងការកាត់សក់របស់នារី មានការថយចុះរួចទៅហើយដោយសារការផ្លាស់ប្តូរ និងការចូលមកដល់នូវរចនាបថការតុបតែងសក់របស់ម៉ាឡេ ។ យ៉ាងណាមិញ ទាសករ និងស្ត្រីក្រីក្រនៅតាមចិញ្ចឹមផ្លូវ នៅតែទុក «ផ្នែកខាងលើនៃដងខ្លួនរបស់ពួកចំហចេញសុដន់» ដដែល (វ៉ង់ ឌែរ ហាហ្គែន* (van der Hagen) *គ.ស. ១៦០៧ ទំ. ៨២) ។ រយៈពេល ៤០ ឆ្នាំក្រោយមក មានអ្នកទេសចរម្នាក់ទៀតមកកាន់ទីក្រុងនោះ បានកត់សម្គាល់ថា «រាល់ស្ត្រីត្រូវបានបិទបាំងយ៉ាងជិតពីក្បាលរហូតដល់ចុងជើងដែលសូម្បីតែមុខមាត់របស់ពួកគេក៏មើលមិនឃើញដែរ» (រ៉ូដេស គ.ស. ១៦៥៣ ទំ. ២០៦-០៧) ។*

*នៅហ្វីលីពីន មានការប៉ាន់ស្មានដូចគ្នានេះដែរ ដែលថាការផ្លាស់ប្តូរអត្តសញ្ញាណសាសនា ទាមទារឲ្យមានការផ្លាស់ប្តូរសម្លៀកបំពាក់ ។ ជនជាតិអេស្ប៉ាញបានចាត់ទុកថារចនាបថនៃការសាក់ខ្លួនបុរស និងការខ្វះសម្លៀកបំពាក់ដ៏ស្តើងរបស់ស្ត្រីវីស័យយ៉ាស់* (Visayan) *គឺជារឿងមួយដែលខុសឆ្គង និងគួរឲ្យស្តីបន្ទោសប៉ុន្តែសូម្បីតែ*

*សម្លៀកបំពាក់ពួកអ្នកទទួលឥទ្ធិពលពីសាសនាអ៊ីស្លាមតាហ្គាឡុក* (Tagalog) *ក៏បញ្ចេញក្បាលពោះដើម្បីបំពេញចិត្តពួកអេស្ប៉ាញដែរ ។ ក្នុងកំលុងពេលមួយសតវត្ស កូលីន (គ.ស.១៦៣៣ ទំ. ៦៣) អាចរាយការណ៍ដោយសេចក្ដីរីករាយមកថា៖*

> «ឥឡូវនេះពួកគេបានចាប់ផ្ដើមស្លៀកសម្លៀកបំពាក់ និងតែងខ្លួនតាមបែបអេស្ប៉ាញហើយ ដោយមានប្រើច្រវ៉ាក់ខ្សែកសំពត់ខ្លីត្រឹមជង្គង់ ស្បែកជើង និងកំណាត់ប៉ាក់សម្រាប់គ្របស្មា ឬក្បាល ឬស្បៃមុខពណ៌ខ្មៅ ។ ប្រុសៗពាក់មួក អាវធំខ្លី ខោជើងវែង និងស្បែកជើង ។ ជាលទ្ធផល សម្លៀកបំពាក់បច្ចុប្បន្នរបស់ពួកជនជាតិដើម Indios ក្នុងតំបន់ទាំងនេះ គឺស្មើរតែដូចពួកអេស្ប៉ាញ អ៊ីចឹងដែរ»។

*ជនជាតិវៀតណាមហាក់ដូចជាមានការផ្លាស់ប្ដូរមុនគេ ក្នុងការតុបតែងខ្លួនដោយសម្លៀកបំពាក់ជាច្រើនប្រភេទ ។ បូរី* Borri *បានហៅស្ត្រីជនជាតិវៀតណាមទាំងនោះថាជា «ស្ត្រីរម្យទមជាងគេបង្អស់នៅក្នុងតំបន់ឥណ្ឌា» ដោយមានសម្លៀកបំពាក់ច្រើនស្រទាប់ដែលមិនអាចឲ្យគេមើលឃើញខ្លួនប្រាណផ្នែកណាទាល់តែសោះ (គ.ស. ១៦៣៣:* F) *។ ផ្ទុយទៅវិញ គេអាចចាត់ទុកសម្លៀកបំពាក់របស់ជនជាតិវៀតណាម សម្រាប់ទាំងពីរភេទ ថាជាការកែច្នៃនៃគំរូសារុងសមញ្ញ មុនពេលដែលដាក់បញ្ជាឲ្យប្រើប្រាស់អាវផាយ និងខោជើងវែង ដែលមានរចនាបថចិន ដោយព្រះចៅអធិរាជ វ៉ូវ៉ួង* (Vo Vuong) *ក្នុងគ.ស. ១៧៧៤ (ហ្វូអាដ* (Huard) *និង ឌុរានដូវ៉ង់ គ.ស.១៩៥៤ ទំ. ១៧៧–៧៨ និង វូដសាដ* (Woodside) *គ.ស.១៩៧១ ទំ. ១៣៤) ។*

## ផលិតកម្មវាយនភណ្ឌ និងពាណិជ្ជកម្ម

*ដោយស្ថិតនៅចន្លោះប្រភពសម្លៀកបំពាក់ដ៏ធំនៃពិភពលោកចំនួនពីរ ដែលជាប្រទេសឥណ្ឌាដែលសម្បូរដោយកប្បាស និងប្រទេសចិនដែលសម្បូរដោយសូត្រតំបន់អាស៊ីអាគ្នេយ៍បានក្លាយទៅជាតំបន់ដ៏ល្បីខាងប្រើប្រាស់ជាជាងបង្កើតផលិតផលវាយនភណ្ឌជាអន្តរជាតិ ។ ប្រសិនបើគ្មានតម្រូវការជាបន្តបន្ទាប់នូវកប្បាសឥណ្ឌាជាពិសេសនោះ នឹងមិនវត្តមានពាណិជ្ជករឥណ្ឌារួចមកអឺរុប នៅតំបន់អាស៊ីអាគ្នេយ៍នោះឡើយ ។ សម្លៀកបំពាក់ត្បាញនៃតំបន់ឥណ្ឌាខាងលិច ហ្គូចារ៉ាត អុញរាតតំបន់ខាងត្បូងនៃឆ្នេរខាងកើតឥណ្ឌា និងនៅតំបន់ភាគឦសាននៅឥណ្ឌា បែងហ្គាល់ ភាគច្រើនចំណាយទៅលើគ្រឿងទេស និងម្រេចដែលពួកនៅកោះឥណ្ឌូនេស៊ីបានបញ្ជូនទៅកាន់ប៉ែកខាងលិច ។*

*ទង្វើនេះអាចធ្វើទៅបានដោយការចំណាយយ៉ាងខ្ជះខ្ជាយនៃពួកអាស៊ីអាគ្នេយ៍ទៅលើសម្លៀកបំពាក់ និងការតុបតែងច្រើនជាងការចំណាយផ្សេងៗទៀត តែដោយមិនមកពីកង្វះខាតនៃផលិតផលវាយនភណ្ឌអ្វីនោះទេ ។ សំលៀកបំពាក់ គឺជាឧស្សាហផលនាំមុខគេបង្អស់នៅអាស៊ីអាគ្នេយ៍ រីឯកប្បាសគឺជាកសិផលនាំមុខគេបន្ទាប់ពីគ្រឿងបរិភោគ ។ នៅតំបន់ខ្លះនៃស៊ូឡាវេស៊ី* (Sulawesi) *និងបាតង់ចម្រៀកកំណាត់ក្នុងស្រុកត្រូវបានគេប្រើធ្វើជារូបិយវត្ថុ ខណៈពេលដែលនៅជ្វា នៅម៉ាកាសារ និងនៅលូស្សុន* (Luzon) *ការទាមទារដំបូងបង្អស់របស់អាណានិគមអឺរ៉ុបសម្រាប់ការដឹងគុណ គឺជាកំណាត់ក្នុងស្រុក (កូតេ* (Cote) *គ.ស.១៩៧៩ ទំ. ៥៦, រូហ្វែរ* (Roufaer)*គ.ស. ១៩០៤ ទំ.១២–១៣, រេកែល* (Requel) *គ.ស.១៥៧៣ ទំ. ២៤១ និង ស្តាវ័រីនូស* (Stavorinus) *គ.ស.១៧៩៨* II *ទំ. ២៦១) ។ កំណាត់សម្លៀកបំពាក់របស់ឥណ្ឌា និងចិនត្រូវបានទិញដោយពួកអ្នកមានសម្បត្តិស្តុកស្តម្ភ ដោយសារតែកំណាត់*

ទាំងនោះមានពណ៌ស្រស់ថ្លា ក្បាច់ដ៏ស្រស់ស្អាត និងជាកំណាត់ដ៏កម្រទៀតផង ប៉ុន្តែប្រជាជនភាគច្រើនតែងតែស្លៀកសម្លៀកបំពាក់កាត់ចេញពីកំណាត់ក្នុងស្រុក ឬក្នុងតំបន់របស់ខ្លួន ។

ក្រលហ្វឹដ (គ.ស.១៨២០ ទំ. ១៧៦-៧៨) ប្រហែលជាត្រូវយ៉ាងហោចណាស់ចំពោះពួកនៅតំបន់ដីកោះដែលគាត់សន្និដ្ឋានថា ការតម្បាញគឺធ្វើឡើងជាលើកដំបូងបង្អស់សម្រាប់កំណាត់ដែលធ្វើចេញពីសរសៃឈើ ពីព្រោះថាពាក្យ «ត្បាញ» គឺជាពាក្យរបស់តំបន់ដីកោះអូស្ត្រូនេស៊ី (ដែលរួមមាន ឥណ្ឌូនេស៊ី ម៉ាឡេនេស៊ី មីក្រូនេស៊ី ប៉ូលីនេស៊ី និងកោះក្បែរៗនោះ នៅក្នុងមហាសមុទ្រប៉ាស៊ីភិច) ខណៈពេលដែលពាក្យសម្រាប់ផលិតផលកប្បាស និងសូត្រគឺជាពាក្យសំស្ក្រឹត ។ ទោះជាយ៉ាងណាក៏ដោយ អំណោះអំណាងមានភាពចំណាស់ពេកទៅហើយ ។ ដល់សតវត្សទី ១៦និង ទី១៧ កប្បាសត្រូវបានប្រជាជនដាំពាសពេញដែនដីអាស៊ីអាគ្នេយ៍រួចទៅហើយ ។ ស្លាកស្នាមនូវអ្វីដែលអាចជាប្រព័ន្ធដ៏ចំណាស់មួយ នៅតែស្ថិតនៅក្នុងតំបន់ទាំងនោះ ដែលមិនមានរដូវប្រាំងគ្រប់គ្រាន់ដែលអាចដាំកប្បាសឲ្យរីកលូតលាស់បាន ហើយដែលមិនអាចធ្វើការនាំចូលកប្បាសបានផងដែរ ។ ភាគច្រើននៃមឡាយ៉ា (Malaya) (លើកលែងតែ កែឡាតង់) ជាប្រទេសដែលមិនមានរដូវប្រាំងគ្រប់គ្រាន់សម្រាប់ដាំកប្បាសបានតែប្រទេសនេះបាននាំចូលកំណាត់មកពីឥណ្ឌា ជ្វា និងស៊ូឡាវេស៊ី (អេរេដៀរ គ.ស.១៦១៣ ទំ. ៣៩) ។ នៅតំបន់មិនសូវអនុគ្រោះ នៃកោះសូមាត្រាខាងត្បូង នៃប៊័រណេអូ ស៊ូឡាវេស៊ី និងម៉ាលូហ្គាស់ (Malugas) កំណាត់សម្លៀកបំពាក់ដែលមិនជាប់បានយូរស្រដៀងទៅនឹងសំបកឈើ ប៉ូលីនេស៊ីដែរនោះគឺធ្វើឡើងដោយជ្រលក់សំបកឈើខាងក្នុងនៃដើមឈើម្យ៉ាងឲ្យសើមរួចហើយវាយសំបកឈើនោះរហូតដល់សំប៉ែតហើយទន់ ។ តែពេលមានភ្លៀង គេត្រូវយកសំបកឈើនោះទុក ដើម្បីជៀសវាងការរបកបែកចេញ (ពីហ្គាហ្វេតតា (Pigafetta) គ.ស.១៥២៤ ទំ. ៧២, ណាវ៉ារ៉ែតេ . គ.ស.១៦៧៦ ទំ. ១១០ និងម៉ាសដែន (Marsden) គ.ស.១៧៥៣ ទំ. ៤៩)។

កំណាត់សម្លៀកបំពាក់ដែលល្អជាងនេះអាចត្រូវបានគេធ្វើឡើងដោយអ្នកណាដែលអាចរកបាននូវសរសៃដើមអាបាកា (ចេកម្យ៉ាងមាននៅហ្វីលីពីន) ដែលជាសរសៃឈើយកចេញមកពីបណ្តូលដើម (Musa textilis) ។ ដើមឈើប្រភេទដូចដើមចេកនេះ មានកំណើតនៅប្រទេសហ្វីលីពីន ហើយប្រជាជននៅសេប៊ូ ណេហ្គ្រូស (Cebu Negros) សាម៉ាឡៃតេ (SamarLeyte) និងនៅមីនដាណាវ ក៏ដូចជានៅស៊ូឡាវេស៊ី ភាគខាងជើងដែរ ស្លៀកពាក់ដើមចេកប្រភេទនេះជាសម្លៀកបំពាក់បឋម ។ នៅតំបន់ស្ងួតជាងនេះដូចជា លូស្សន់ និងប៉ាណៃ (Panay) កប្បាសអាចដាំលូតលាស់បាន ហើយមានការនិយមប្រើប្រាស់ច្រើនទៀតផង (អាល់ស៊ីណា គ.ស.១៦៦៨ III ទំ. ៩៩, លួរ៉ា (Loara) គ.ស.១៥៨២ ទំ. ៤៣-៧៣, ដាំពែរ គ.ស.១៦៩៧ ទំ. ២១៧ និង សាស្ពែរ (Sasper) និង ពឹងហ្គាឌី (Pirngadie) គ.ស. ១៩១២ ទំ. ៥៥)។

កប្បាសមានដាំនៅអាស៊ីអាគ្នេយ៍ ហើយត្រូវបានគេនាំចេញទៅប្រទេសចិនជាយូរយារណាស់មកហើយ ។ កំណត់ត្រាជនជាតិចិនបានបញ្ជាក់ថា ដំណាំនេះអាចត្រូវបានមកពីប្រទេសវៀតណាមទៅតំបន់ចិនខាងត្បូង នៅសតវត្សទី ៧ (ឆ្លីយែន គ.ស.១៩៧០ ទំ. ៥២) ។ តាំងពីសតវត្សទី ១៣ ដល់ទី ១៧ ពួកឈ្មួញចិនបានទិញអំបោះ និងកំណាត់កប្បាស ពីកំពុងផែជាច្រើននៅអាស៊ីអាគ្នេយ៍ ជាពិសេសកំពុងផែនៅប្រទេសវៀតណាម លូស្សន់ និងជ្វា (ជីវចូក្វា គ.ស.១២៥០ ទំ. ៤៦-៤៨, ៧៨ និង ១៦០-៦១, ម័រហ្គា (Morga) គ.ស.១៦០៩ ទំ. ២៦៣ និងវីតលី (Wheatley) គ.ស.១៩៦១ ទំ. ៧៧-៨៣) ។ នៅពេលមានព័ត៌មានលម្អិតនោះ គេដឹងថាយ៉ាងហោចណាស់ក៏នៅក្នុងសតវត្សទី ១៦ ដែរដែលភូមាកណ្តាលផលិតបានកប្បាសជាច្រើន យកទៅ អ៊ីរ៉ាវ៉ាឌី (Irrawady) បន្តទៅទីផ្សារកណ្តាលនៅ

*សាហ្គាំង* (Sagaing) ។ *នៅទីនោះគេសម្អាតកប្បាសនោះឲ្យស្អាត ហើយធ្វើទៅជាសរសៃអំបោះ ដើម្បីលក់ឲ្យពួកឈ្មួញ ដែលពួកឈ្មួញនោះនាំបន្តទៅលក់នៅយុនណាន* (Yunnan) *និងតំបន់ផ្សេងៗទៀតនៅប្រទេសចិន (ស៊ីមស៍ គ.ស.១៨២៧*II *ទំ. ១៨៧ និងកុកស៍ គ.ស.១៨២១ ទំ. ៤៦)*។

*តំបន់ដាំកប្បាសធំៗផ្សេងទៀតដែលនាំចេញទៅទីផ្សារជិតៗនៅតំបន់ដីកោះនោះរួមមាន ឆ្វាខាងកើត បាលី (សូមមើលរូបភាព ១៦) ស៊ូមបាវ៉ា* (Sumbawa) *ប៊ូតង់* (Buton) *និង ជ្រុងអាគ្នេយ៍នៃស៊ូឡាវេស៊ីខាងត្បូង* ។ *កប្បាសគឺជាផលិតផលនាំចេញមួយរបស់កម្ពុជាក្នុងអំឡុងគ.ស.១៦០០ ដែលនាំចេញទៅកាន់ទីផ្សារឆ្ងាយភាគខាងត្បូងរហូតដល់ប៉ាតានី (ហ្គ្រូសឡែរ* (Groslier) *គ.ស.១៩៥៨ ទំ. ១៥២ និងវ៉ាន់ណែកគ.ស.១៦៩៤ ទំ. ២២៩)* ។ *កប្បាសប្រភេទនេះប្រហែលជាត្រូវបានគេដាំនៅតាមច្រាំងខាងលិចនៃទន្លេមេគង្គប៉ែកខាងលើរាជធានីភ្នំពេញ ដែលនៅសតវត្សទី ១៩ បានផ្តល់កប្បាសជាច្រើនដែល «អាចផ្គត់ផ្គង់ដល់កូសាំងស៊ីន* (Cochin-China) *ទាំងមូល»(ម៉ូហត់* (Mouhot) *គ.ស.១៨៦៤* II *ទំ. ២២ តែសូមអានប្រៀបធៀប ប៊ូអ៊ីណាស់* (Bouinais) *និង ពូឡៃ* (Puley) *គ.ស.១៨៨៥* I *ទំ.៣៣៣, ៥៣៣ និង ៥៦៩)* ។ *តំបន់សៀម និងកោះសូមាត្រាក៏បានផលិតកប្បាសសម្រាប់ប្រើប្រាស់ក្នុងស្រុកផងដែរ* ។ *តំបន់ផលិតកប្បាសសំខាន់មួយរបស់សូមាត្រា គឺជាក្បាលឆ្នេរនៅចន្លោះប៉ាដង់* (Padang) *និងអាំងជ្រាពូរ៉ា* (Indrapura) *ដែលនៅលើឆ្នេរប៉ែកខាងលិច ដែលផលិតផលកប្បាសបានពីតំបន់នេះអាចផ្គត់ផ្គង់តំបន់មីណាងហ្កាប៊ូ* (Minangkabau) *ទាំងមូលរហូតដល់ពេលពួកហូឡង់បានបញ្ចប់ការដាំកប្បាសនេះ ហើយបែរមករកការដាំដុះម្រេចវិញនៅចុងសតវត្សទី ១៧ (អូគី* (Oki) *គ.ស.១៩៧៩ ទំ. ១៤៧-៤៨)* ។



រូប ១៦ ៖ គំនូសរបស់បាលី នៅទសវត្សទី ៤០ ស្តីអំពីការប្រមូលផលកប្បាសតាមបែបបុរាណ

សូត្រនៅមានប្រជាប្រិយភាពតិចជាងកប្បាសច្រើនណាស់ ទោះបីជាទាំងដើមមន និងដង្កូវនាង អាចមានកំណើតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក៏ដោយ ។ វត្ថុធាតុដើមទាំងពីរប្រភេទនេះកើតមានដោយធម្មជាតិនៅតាមតំបន់នៃប្រទេសឥណ្ឌូនេស៊ីដែលជាទីកន្លែងដែលដង្កូវនាងត្រូវបានសន្មត់ថាជាប្រភេទសត្វដែលអាចផ្ដល់ផលបាននៅពេលណាក៏បានក្នុងមួយឆ្នាំៗ ។ ចំពោះជនជាតិចិនដែលបានអភិវឌ្ឍការផ្សាំដើមឈើ និងបង្កាត់ពូជដង្កូវនាងឲ្យក្លាយជាប្រពលវប្បកម្មនោះវិធីសាស្ត្ររបស់ឥណ្ឌូនេស៊ីដែលគេសង្កេតមើលនៅសូម៉ាត្រាភាគខាងជើងហាក់ដូចជាមិនមានជំនាញ និងគម្រោងច្បាស់លាស់ ដែលផលិតបានសូត្រពណ៌លឿងគ្រើមៗ (ម៉ា ហួន (Ma Huan) គ.ស. ១៤៣៣ ទំ. ១១៩ និងហ្គ្រូអែនវែលដ៍ (Groeneveldt)គ.ស. ១៨៨០ ទំ. ៩៣) ។ លូដូវីកូ ឌី វ៉ារសឺណា (Ludovico di Varthena) (គ.ស. ១៥១០ ទំ. ២៣៤) (១៥១០ : ២៣៤) បានរាយការណ៍ថាដង្កូវនាងនៅទីនោះរស់ធំធាត់ ដោយធម្មជាតិនៅលើដើមឈើក្នុងព្រៃក៏ដូចជានៅក្នុងសួនច្បារដែរ ។ កំណត់ត្រាប្រវត្តិសាស្ត្ររបស់ម៉ាឡេស៊ីពីរច្បាប់ កត់ត្រារឿងដំណាលមួយថាអ្នកបង្កើតរដ្ឋដែលមានកំពង់ផែមូស្លីម នៅឯ ប៉ាសៃ នៅក្នុងតំបន់ស៊ូម៉ាត្រាភាគខាងជើង មានសមត្ថភាពពិសេសអស្ចារ្យដែលអាចធ្វើឲ្យដង្កូវនាងឲ្យក្លាយជាមាស និងប្រាក់បាន (ហ៊ីកាយ៉ាត់ រ៉ាច្យា-រ៉ាច្យា ប៉ាសៃ (Hikayat Raja-Raja Pasai) ទំ. ៥១ និងសេច្យារ៉ា មេឡាប៊ុយ (Sejarah Melabu) គ.ស. ១៦១២ ទំ. ៤០-៤១) ។ នេះអាចជាការឆ្លុះបញ្ចាំងពីសារៈសំខាន់ក្នុងការផ្សាំដង្កូវនាង នៃដំណាក់កាលអភិវឌ្ឍដំបូងរបស់ប៉ាសៃ ។ សូត្រនៅតំបន់នោះគឺប្រភពដ៏សំខាន់ក្នុងការផ្គត់ផ្គង់តម្រូវការនៅស៊ូម៉ាត្រា និងសូម្បីតែនៅឥណ្ឌាផងដែរ បានរហូតដល់ ត្រីមាសដំបូងនៃសតវត្សទី ១៧ (បារ៉ូស (Barros) គ.ស. ១៥៦៣III ទំ. ៥០៨, បូល្យឺ (Beaulie)គ.ស. ១៦៦៦ ទំ. ៩៩ និងនីកូលស៍ (Nicholls) គ.ស. ១៦១៧ ទំ. ៧៣) ។ អាល់ប៊ុយកែ្វក (Albuguerque) បានដឹងអំពីសូត្រនៅប៉ាសៃ នៅពេលដែលគាត់ធ្វើដំណើរទៅកាន់ដីចំបាំងនៅម៉ាឡាកាក្នុង គ.ស. ១៥១១ ។ គាត់បានបញ្ជូនអ្នកដោះស្រាយបញ្ហារបស់គាត់ជនជាតិហ្សេណូវ៉ា ឈ្មោះថា ហ្សីអូវ៉ាន់នី ដា អែមប៉ូលី (Giovanni da Empoli) ពីឥណ្ឌាទៅកាន់ប៉ាសៃដើម្បីចរចាអំពីការលក់សូត្រ ដែលប៉ាសៃភាសិអាចផលិតបាន ។ អ្នកដឹកនាំ រ៉ាច្យា(Raja) បានប្រាប់អែមប៉ូលី (Empoli fa) សូត្រទាំងអស់នេះលក់ឲ្យជនជាតិព័រទុយហ្គាល់ក្នុងតម្លៃ ១០០០ Duckat΄ s_ ducats«ដែលជាតម្លៃដូចគ្នា ពេលដែលលក់ឲ្យទៅពួក ហ្គូ ច្សឺរ៉ាឌីស(Gujeradis)» (អែមប៉ូលី (Empoli) គ.ស. ១៥១៤ ទំ. ១៤៨) ។ ទោះបីជាតម្លៃនោះគឺជាកាបំភ្លើសខ្លាំងយ៉ាងណាក៏ដោយ ក៏ផលិតផលសូត្រនៅស៊ូម៉ាត្រាភាគខាងជើង (ដែលត្រូវបានពួកអាចេដណ្ដើមបាននៅក្នុងទសវត្សឆ្នាំ ១៥២០) បានធ្លាក់ចុះយ៉ាងលឿននៅក្នុងសតវត្សបន្តបន្ទាប់នោះ ដោយសារសូត្ររបស់ចិនមានកាន់តែច្រើនហើយដោយសារដីដាំដើមមនមួយចំនួនត្រូវបានគេទន្ទ្រានយកមកដាំស្រូវ និងម្រេចវិញ ។

ស៊ូឡាវេស៊ី ខាងត្បូងគឺជាប្រភពដ៏សំខាន់មួយផ្សេងទៀតនៃការផលិតសូត្រពណ៌លឿងប្រភេទដើមនេះ ហើយនៅទីនោះការដាំដុះនៅតែបន្តអនុវត្តនៅក្នុងរដ្ឋប៊ូហ្គីស (Bugis) នៃវ៉ាច្យូ (Wajo) រហូតដល់សម័យទំនើប ។ ការធ្វើកសិកម្មសូត្រនេះ ដែលផ្ដល់ឲ្យនូវសារុង ប៊ូហ្គីសដែលមានពណ៌ដ៏ស្រស់ស្អាតត្រូវបានកត់សម្គាល់ដោយគូតា (Couta) (គ.ស. ១៦៤៥ V ទំ. ii និង ៨៦)ដោយផ្អែកលើរបាយការណ៍ ពីទសវត្សឆ្នាំ ១៥៤០ មក ។

នៅក្នុងបណ្ដាប្រទេសដីគោកបច្ចេកវិទ្យាផលិតសូត្រហាក់ដូចជាបានទទួលឥទ្ធិពលពីវិធីសាស្ត្រដ៏ផ្ចិតផ្ចង់របស់ប្រទេសចិន ។ ទំនៀមទម្លាប់ប្រពៃណីនៅភូមាបានពន្យល់ពីហេតុផលនៃការនាំចូលដង្កូវនាងសូត្រ ថាមកពីប្រទេសចិនក្នុងសតវត្សទី ១១ នៃរជ្ជកាលស្ដេច អាណាហ្រ្វាតា (Anawhrata) (ស្វ័យ យ៉ូ គ.ស. ១៨៨២ ទំ. ២៦៥) ។ ជនជាតិថៃដែលប្រហែលជានាំសូត្រមកពីប្រទេសចិនក្នុងកំលុងពេលសហវត្សមុននោះ ក៏បាននាំសូត្រនោះ

មកកម្ពុជា ក្នុងកំលុងពេលដែលជីវតាក្វាន់ ធ្វើទស្សនកិច្ចមកកម្ពុជានៅពេលនោះ (គ.ស. ១២៩៧ ទំ. ៣០) ដែលទោះជានៅតំបន់ទំនាបកណ្តាលនៃប្រទេសថៃមិនអាចដាំដើមមនបាននោះ (ឡា លូប៊ែរ គ.ស. ១៦៩១ ទំ. ១៣) ។ មានតែនៅប្រទេសវៀតណាមទេ ដែលផលិតផលសូត្រមានវត្តមានមុនផលិតផលកប្បាសនោះ ។ «ប្រជាជនទាំងអស់ស្លៀកសម្លៀកបំពាក់ធ្វើអំពីសូត្រ» (សាន អង់តូនីយ៉ូ (San Antonio) គ.ស. ១៦០៤ ទំ. ២៤) ។ បច្ចេកទេសក្នុងការត្បាញ និងការជ្រលក់ពណ៌សូត្ររបស់វៀតណាមឃើញថាមានភាពជឿនលឿន និងល្អិតល្អន់ដូចបច្ចេកទេសរបស់ចិន និងជប៉ុន នៅក្នុងសតវត្សទី ១៧ ដែរ ហើយផលិតផលគឺជាតម្រូវការដ៏សំខាន់របស់អ្នកជំនួញបរទេស ។ ប៉ុន្តែការនាំចេញធំៗគឺស្ថិតក្នុងរូបភាពជាសូត្រសុទ្ធមិនទាន់ថ្មៃដែលពួកឈ្មួញទិញយកទៅក្នុងទ្រង់ទ្រាយធំរហូតទាល់តែជំនួញនេះត្រូវបានបញ្ឈប់ដោយពួកមេដឹកនាំ ទុកុហ្គាវ៉ា (Tokugawa) នៅក្នុងគ.ស. ១៦១៧ (ធ្វី យែន គ.ស. ១៩៧០ ទំ. ៥២, ៩៣–៩៤, ១៩០) ។

ការរវៃអំបោះមិនថាដោយកង់ធម្មតា ឬក៏ផ្ទៃរហាត់ និងខ្នារការជ្រលក់ពណ៌អំបោះជាមួយពណ៌រមៀតធ្ងុះថ្វាជាមួយសំបកកប្បាសពណ៌ក្រហម និងជាមួយបុសឈើផ្សេងៗទៀត និងការត្បាញកំណាត់ជាមួយនឹងកី សុទ្ធតែជាកិច្ចការរបស់ស្ត្រីទាំងអស់ ។ ក្បាច់តម្បាញបឋមមានប្រជាប្រិយភាព សម្រាប់សង្គមបុរេឧស្សាហកម្ម ដែលគ្រប់ផ្ទះនីមួយៗមានបំណងផ្គត់ផ្គង់សម្លៀកបំពាក់ដោយខ្លួនឯងឲ្យគ្រប់គ្រាន់ ។ «នៅក្នុងខ្ទមជនជាតិជ្វា នីមួយៗមានកង់រវៃអំបោះ និងកីមួយ» (រ៉ាហ្វលស៍ សគ.ស. ១៥១៧ I ទំ. ៨៦ តែសូមអានប្រៀបធៀបឯកសាររបស់ ស៊ីមស៍ គ.ស. ១៥២៧ I ទំ. ២២៩ និងរបស់ ហ្គឺវ៉ាស់ (Gervaise) គ.ស. ១៧០៧ ទំ. ៧៤) ។ ផ្ទុយទៅវិញសូម្បីតែនៅទីណាដែលមានជំនាញផលិតកំណាត់ជាពិសេសនៅតាមតំបន់សម្រាប់នាំចេញក៏ដោយ ក៏ការធ្វើជំនួញនៅតែជាការកាន់កាប់របស់ស្ត្រីដដែល ដែលរបៀបរបបនេះខុសពីនៅប្រទេសចិន និងប្រទេសឥណ្ឌានោះ ។ ក្រលហ្វ័ដ (Crawfurd) (គ.ស. ១៨២០ I ទំ. ១៧៨) បានចាត់ទុកសកម្មភាពនេះជាសន្ទស្សន៍បង្ហាញពីការអភិវឌ្ឍផ្នែកវាយនភណ្ឌមានកម្រិតទាបនៅអាស៊ីអាគ្នេយ៍ ។ នេះគួរតែជាទស្សនៈទ្វិកភាព ដែលបញ្ជាក់ថាការងារភាគច្រើនសម្រាប់បុរស ឬនារីយ៉ាងជាក់លាក់ ។

បច្ចេកវិទ្យានៃផលិតកម្មវាយនភណ្ឌមានលក្ខណៈរួមដូចគ្នាតែមួយគួរឲ្យភ្ញាក់ផ្អើល ។ កង់រវៃអំបោះហាក់ដូចជាមិនមាននៅប្រទេសហ្វីលីពីន រហូតដល់គ.ស. ១៦០០ (ស្កត់ គ.ស. ១៩៥២ ទំ. ៥២៨) តែកង់រវៃនេះមាននៅចុងខាងកើតនៃ ស៊ូឡាវេស៊ី ខាងត្បូង និងនៅម៉ាលូកូ (Maluku) ។ នៅកម្ពុជា កីតម្បាញប្រើខ្សែពាន ដែលជីវតាក្វាន់គិតថាតូចពេកសឹងតែមិនមែនជាកីតម្បាញនោះ ត្រូវបានប្រើដោយស្ត្រីនៅទូទាំងតំបន់ ។ ការផលិតមានសភាពយឺតយ៉ាវ ។ គេអាចវាស់វែងនៅជ្វា នាសតវត្សទី ១៨ ថាស្ត្រីម្នាក់ចំណាយពេល ១ ខែដើម្បីត្បាញរវៃអំបោះឲ្យបាន ១ ផោន ហើយមួយខែទៀតដើម្បីត្បាញកំណាត់ប្រវែង ១០ យ៉ាត (១ យ៉ាតស្មើនឹង ០,៩១៤៤ ម៉ែត្រ) (ហូអួចម៉ង់ (Hooijman) គ.ស. ១៧៨០ ទំ. ៤២៣–២៥ តែសូមអានប្រៀបធៀបឯកសាររបស់ ក្រលហ្វ័ដ គ.ស. ១៨២០I ទំ. ៧៩) ។ បញ្ហាដែលសំខាន់នោះគឺថា កីតម្បាញនោះមានខ្សែពានដ៏តូច ដែលអាចត្បាញតែ «សរសៃអំបោះតូចឆ្មារខ្ទីៗ» តែប៉ុណ្ណោះ (ហ្គាលវៅ (Galvao) គ.ស. ១៥៤៤ ទំ. ១២៣) ។ កំណាត់សម្លៀកបំពាក់ពីរទទឹង ដេរភ្ជាប់គ្នាទើបអាចធ្វើសារុងមួយ ដែលមានប្រវែងអាចប្រើប្រាស់បានតាមបែប ម៉ាឡេយ៉ូ–មូស្លីម (Malayo-Muslim) ថ្មីបាន ។

យ៉ាងណាមិញ ការប្រើពណ៌ និងរចនាក្បាច់នៅលើកំណាត់សម្លៀកបំពាក់នោះ មានកម្រិតឯកទេសខ្ពស់ ។ នៅសតវត្សទី ១៦ គេអាចមើលឃើញថា ពួកជ្វាខាងកើត ពួកបាលី និងពួកសាំបាវ៉ា (Sumbawa) គឺជាអ្នកនាំចេញ

*កំណាត់សម្លៀកបំពាក់ធំជាងគេ ដែលទទួលផលប្រយោជន៍ពីកប្បាសខ្នាត FMI ការដាំដុះនៅតំបន់ក្ដៅនៅលើកោះទាំងនេះ ។ កំណាត់របស់ជ្វា វាបានទៅដល់ស៊ូម៉ាត្រាខាងជើងទៅហើយ នៅដើមសតវត្សទី ១៥ (ហ្គ្រូអង់ណែវែឌត៍ (Groeneveldt) គ.ស. ១៨៨០ ទំ. ៨៨) ហើយនៅចុងសតវត្សទី១៦ កំណាត់សូត្រ លូ ឬកឡូរិករបស់ បានារូកាន (Panarukan) និងប៉ាស៊ូរួន (Pasuruan) នៅតែពេញមានការពេញនិយមនៅមេឡាកាដដែល(ឡូឌឺវាយស៍ (Lodewayck) គ.ស. ១៥៩៨ ទំ. ១០០-០១)។ ទោះបីជាយ៉ាងណាក៏ដោយចំពោះទីផ្សារម៉ូឡុក (kan Muloccan) ដ៏សំខាន់នោះ សូម្បីតែអ្នកជំនួញជ្វាក៏ឈប់នៅហ្គ្រេស៊ីក (Gresik) ដើម្បីទិញកំណាត់សម្លៀកបំពាក់ ម៉ាឌួ (Madurese)ដែរ ឬក៏ដើម្បីបានកំណាត់សម្លៀកបំពាក់ល្អជាងទៅទៀត គឺត្រូវឈប់នៅបាលីពាលិ ឬនៅសាំបាវ៉ាដែលអាចទិញបានកំណាត់កប្បាសមានពណ៌ដ៏ស្រស់បំព្រង ដែលត្បាញដោយប្រើវិធីសាស្ត្រ អ៊ីកាត់ (Ikat) ដែលជាវិធីសាស្ត្រដ៏ល្បីល្បាញឈ្មោះមួយរួចទៅហើយ (ហ៊ីមស្គឹក (Heemskerk) គ.ស. ១៦០០ ទំ. ៤៤៨ និង ៤៥២ និងឡូឌឺវាយស៍ (Lodewycks) គ.ស. ១៥៩៨ ទំ. ១១៩-២០) ។ អ្នកតម្បាញជនជាតិជ្វាមិនមានសមត្ថភាព ក្នុងការត្បាញកំណាត់សម្លៀកបំពាក់ជាមួយ និងសរសៃអំបោះពណ៌ខុសៗគ្នានៅខណៈពេលដែលវិធីសាស្ត្រ បាតិក ក្នុងការគូសគំនូសក្បាច់នៅលើកំណាត់សម្លៀកបំពាក់ដោយលាបក្រមួននោះ នៅមិនទាន់អាចប្រជែងជាមួយគេតាមបែបសន្សំសំចៃបានទេ ពីព្រោះតែការប្រើកម្លាំងពលកម្មដ៏ច្រើនរបស់វិធីសាស្ត្រនេះ ។*

*នៅក្នុងដំណើរការនៃសតវត្សទី ១៧ ស៊ូឡាវេស៊ី ខាងត្បូង ក្លាយទៅជាអ្នកនាំចេញកំណាត់នាំមុខគេនៃតំបន់ដីកោះ ។ ដំណើរការនេះត្រូវជួយសម្រួលដោយភាពជោគជ័យរបស់ ម៉ាកាសារ ដែលបានក្លាយទៅជាតំបន់ផលិតសំខាន់សម្រាប់អ្នកជំនួញដែលមិនមែនជាជនជាតិហូឡង់ដែលឆ្លងដំណើរទៅកាន់ ម៉ាលូកូ និងដោយការដណ្ដើមយកបាននូវមជ្ឈមណ្ឌលអាហារនៃណ៍ ដូចជាស៊ូបាវ៉ា (នៅគ.ស. ១៦១៧) និងសេឡាយ៉ា (Selaya) ជាដើម ។ តំបន់ម៉ូលូកាស (Moluccas) បានផ្ដល់ទីផ្សារសំខាន់មួយនៅក្នុងដំណាក់កាលដំបូងនៃការពង្រីកការនាំចេញនេះ ។ ការសរសើរមួយចំនួនក៏គួរតែផ្ដល់ទៅឲ្យ ការបង្កើតថ្មីដែលពួកម៉ាកាសារសេទទួលបានភាពល្បីជាថ្មីនៅក្នុងសតវត្សទី ១៧ និងពួកប៊ូហ្គីស (Bugis) នៅក្នុងសតវត្សទី ១៨ ពីព្រោះកំណាត់សម្លៀកបំពាក់របស់ពួកគេទទួលបានកេរ្ដិ៍ឈ្មោះដ៏ល្បីល្បាញមួយទៅលើគុណភាពភាពជាប់លាប់បានល្អនៃកំណាត់ និងហើយពណ៌ស្រស់ច្បាស់ល្អជាពិសេសក្បាច់ក្រឡាដែលពួកមូស្លីមចូលចិត្ត (វូហ្វែរ គ.ស. ១៩០៤ ទំ. ៤ និងហ្វ័ររេសទ៍ (Forrest)គ.ស. ១៧៩២ ទំ. ៧៩) ។ ការដាំដុះ និងការត្បាញកប្បាសត្រូវបានផ្ដួតសំខាន់នៅលើកោះនៃតំបន់ សេឡាយ៉ា និងនៅតំបន់ដីគោក ស៊ូឡាវេស៊ី ខាងត្បូងនៃបាលូគុមបា (Balukumba) និង ប៊ីរ៉ា (Bira) ។ តំបន់ទាំងពីនេះមានទីតាំងនៅតាមផ្លូវទៅកាន់ ម៉ាលូកូ ប៉ុន្តែតំបន់ទាំងនេះក្ដៅពេកដែលមិនអំណោយផលដល់ការដាំស្រូវ និងបន្លែ ។ ដូច្នេះហើយបុរសៗរស់នៅតំបន់នោះបានដាក់កាយដាក់ចិត្តទៅលើការសាងសង់កប៉ាល់ហើយពួកស្រ្តីៗដាក់ចិត្តដាក់កាយទៅលើតម្បាយកំណាត់វិញ ។ មកដល់ទសវត្សឆ្នាំ ១៦០០ កំណាត់របស់សេឡាយ៉ា ត្រូវបានគេដួញឆ្លងកាត់ម៉ាកាសារ ទៅកាន់កំពុងផែប៊ីរ៉ៃណេអូ តំបន់ ឡេសឺ សាន់ដាស់ (Lasser Sundas) និងទីក្រុងម៉ានីល (ស្ពៀលម៉ង់ Speelman គ.ស. ១៦៧០A ទំ. ១០៣-០៧ និង១១២-១៣) ។ ដោយមានការដួលរលំរបស់ម៉ាកាសារទៅក្រោមការគ្រប់គ្រងរបស់ពួកហូឡង់ ក្នុងគ.ស. ១៦៦៩ នោះពួកអ្នកជំនួញប៊ូហ្គីស បានចាប់ផ្ដើមគ្រប់គ្រងជំនួញខាងកប្បាសរបស់ពួកមាកាសារ ដោយនាំកប្បាសទាំងនោះទៅកាន់កោះនៃពិភពម៉ាឡេស៊ី (ឡេនណុង (Lennon) គ.ស. ១៧៩៦ ទំ. ២៧១-៧២ និង៣២, ម៉ាសដែន (Marsden) គ.ស. ១៧៨៣ ទំ. ៥២ និងឌុងសែឡារ (Donselaar) គ.ស. ១៨៥៧ ទំ. ៣០២) ។*

ទោះជាយ៉ាងណាក៏ដោយ ក៏កំណាត់នៅក្នុងស្រុកមិនអាចមានតម្លៃខ្ពស់ដូចកណាត់ល្អៗរបស់ ស្ហ៊ូជ៊ែរ៉ាទី (Gujerati) ដែលពណ៌ដ៏ស្រស់ថ្លារបស់កំណាត់ទាំងនោះមានគូប្រៀបបាន ។ ចំពោះអំណាចព្រះរាជាដ៏មហិមា ត្រូវតែជាតម្បាញសូត្រនាំចូលមកពីក្រៅ «ដោយមិនមានលាយសរសៃអំបោះថៃមួយឡើយ» ដូចពន្យល់នៅក្នុងកាលប្បវត្តិរបស់ថៃមួយ (ត្រៃភូមិកថា (Traibhumikatha) គ.ស. ១៣៤៥ ទំ. ១៧៦) ។ ព្រះមហាក្សត្រដែលសម្បូរទៅដោយផ្កាក្លាំងពូ មួយអង្គនៅម៉ាលូគូ បានប្រទានកំណាត់ ៥០០ គី ឲ្យទៅក្សត្រមួយអង្គទៀតជាអំណោយអាពាហ៍ពិពាហ៍ ។ កំណាត់សម្លៀកបំពាក់នោះ គឺជាកំណាត់សូត្រ ប៉ាតូឡា (patola) ដែលមានការតុបតែងដោយពណ៌ល្អប្រណិតយកមកពី ស្ហ៊ូជ្យារ៉ាត អុញរោត ទោះជាកំណាត់មួយគីៗត្រូវបានគេប្រកែកគ្នាថាមានតម្លៃស្មើនឹងផ្កាក្លាំពូកន្លះតោននោះ (ពីហ្គាហ្វេតតា គ.ស. ១៥២៤ ទំ. ៧៦ តែសូមអានប្រៀបធៀបឯកសាររបស់ បាបូសា (Barbosa) គ.ស. ១៥១៨ ទំ. ១៩៨-៩៩) ។

ដោយសារកំណាត់សម្លៀកបំពាក់ដែលកម្រគឺជាសម្ភារៈធំជាងគេ ដែលគេចំណាយច្រើនទៅលើនោះកម្រិតនៃការនាំចូល គឺជាសន្ទស្សន៍ដ៏ល្អមួយនៃកម្រិតភាពរីកចម្រើន ។ ក្នុងកំលុងពេលដែលគ្មានការហាមឃាត់ការនាំចេញគ្រឿងទេស និងផលិតផលក្នុងស្រុកដទៃទៀតការនាំចូលកំណាត់ឥណ្ឌាដ៏ច្រើនសន្ធឹកសន្ធាប់នោះប្រហែលជាអាចបំពេញតម្រូវការភាគច្រើនរបស់ប្រជាជននៅទីក្រុង និងអ្នកមានៗនៅតាមជនបទផងដែរ ។ ទំនិញភាគច្រើននៃកប៉ាល់ធំៗចំនួន ១៥ គឺផ្ទុកកំណាត់នាំចូលមកកាន់មឡាកា ក្នុងកំលុង គ.ស. ១៥១០ ដឹកមកពី ស្ហ៊ូជ្យារ៉ាត (Gujerat) កូរ៉ូម៉ាងដែល (Coromandel) និងពីបង់ហ្គាល់ (Bengal) ដែលសរុបតម្លៃលើសកន្លះលាន គ្រូស្សាដូ (cruzados) ដូចតាមការប៉ាន់ស្មានរបស់ ពែរស៍ (Pires) (គ.ស. ១៥១៥ ទំ. ៩២ និង ២៦៩-៧២ តែសូមអានប្រៀបធៀបឯកសាររបស់ម៉ីឡាំង-រូលូស្ស (Meilink-Roelofsz) គ.ស. ១៩៦២ ទំ. ៨៧-៨៨) ។ ប្រមានជាពាក់កណ្តាលនៃចំនួនកប៉ាល់ទាំងនេះដឹកកំណាត់ឥណ្ឌាទៅកាន់ អេឆេ ក្នុងរយៈពេលពាក់កណ្តាលដំបូងនៃសតវត្សទី ១៧ (វើហូហ្វ (Verhoeff) គ.ស. ១៦១១ ទំ.២៤២, ម៉ាន់ឌី (Mundy) គ.ស. ១៦៦៧ ទំ. ៣២៩-៣០ និង ៣៣៥ និងក្លាក (Clark) គ.ស. ១៦៤៣ ទំ. ២៨២) នៅពេលដែលជនជាតិអង់គ្លេសម្នាក់នៅទីនោះជឿជាក់ថា គាត់អាចលក់កំណាត់ឥណ្ឌា បានសរុប ៤៥០០ corges (ស្មើនឹង៩០.០០០ គី) ក្នុងមួយឆ្នាំ ក៏ដូចជាកប្បាសសុទ្ធចំនួន ១០០ bahar (ស្មើនឹង ១៧ តោន) (នីកូលស៍ (Nicholls) គ.ស. ១៦១៧ ទំ. ៧១) ។ នៅសតវត្សទី ១៧ គេបានប៉ាន់ប្រមាណថា ក្រុងអយុធ្យា បាននាំចូលកំណាត់ឥណ្ឌា ដែលមានតម្លៃប្រមាណ ៧៥០០ guilders ក្នុងមួយឆ្នាំៗ (ស្មីតស៍ គ.ស. ១៩៧៤ ទំ. ២៥៩) ។ នៅក្នុងទសវត្សឆ្នាំ១៦៣០ ម៉ាកាសារនាំចូលច្រើនជាងនេះទៀតមានការប្រមាណ ១២០.០០០ រៀល (ខ្វះសម្រាប់ការនាំចេញបន្ត) តាមតម្លៃឥណ្ឌា និងថ្លៃជាងនេះពីរដងសម្រាប់តម្លៃម៉ាកាសារ (កូលសាន់ (Coulson) និង អាយវី Ivy គ.ស.១៦៣៦ ទំ. ២៩៤) ។ ផ្ទុយទៅវិញនៅពេលដែលជំនួញត្រូវបានកាត់បន្ថយ ដូចដែលបានកើតឡើងនៅតបន់ បាតង់ ក្នុងកំលុងពេលប្រត្តិបត្តិការយោធារបស់ហូឡង់ តម្បាញក្នុងតំបន់កាន់តែរវល់ខ្លាំងឡើងហើយក៏មានផាកទៅភាពដើមវិញយ៉ាងឆាប់រហ័សក្នុងការផ្គត់ផ្គង់ខ្លួនឯង (កូអេន គ.ស. ១៦១៧ ទំ. ២៩៣ និង មីឡាំង-រូលូសស៍ គ.ស. ១៩៦២ ទំ. ២៤៤-២៥៨) ។

# ការធ្វើមាស និងប្រាក់

Paduka Sri Sultan ជាស្តេចតែមួយគត់នៃកោះសូម៉ាត្រា. . . ដែលវត្ថុមានរបស់ទ្រង់តំណាងឲ្យមាសដ៏ឆ្អិនឆ្អៅ ។ ជាស្តេចនៃ Priaman និងជាស្តេចនៃភ្នំមាស. . . ជាស្តេចនៃទ្វេឆ័ត្រ នៃមាសស្ល ដែលមានកម្រាលអង្គុយជាមាស. . .ព្រះសង្ហាពាក់កណ្តាលមាសពាក់កណ្តាលប្រាក់ និងភាជន៍សម្រាប់ងូតទឹកធ្វើអំពីមាសសុទ្ធ ហើយស្តូបរបស់ព្រះអង្គក៏ធ្វើអំពីមាស. . . និយាយជារួមអ្វីៗដែលព្រះអង្គប្រើប្រាស់គឺធ្វើអំពីមាស និងប្រាក់ ទាំងអស់ ។

—Sulan Iskandar Muda's letter in Copland គ.ស. ១៦១៤ ទំ. ២១១-១២

*ការតុបតែងផ្ទាល់ខ្លួន គឺជារឿងសំខាន់ក្នុងការចំណាយ បន្ទាប់ពីការចំណាយទៅលើសម្លៀកបំពាក់ ។ ជាពិសេសគ្រឿងអលង្ការធ្វើពីមាស គឺជាតម្រូវការជាប្រចាំសម្រាប់សន្សំទុក ដើម្បីបញ្ជាក់អំពីទ្រព្យសម្បត្តិ និងឋានៈ និងដើម្បីធ្វើជាគ្រឿងតុបតែងមួយប្រភេទ ។ ចំពោះគោលបំណងនេះប្រជាជននៅអាស៊ីអាគ្នេយ៍បានប្រើមាសសុទ្ធ ដែលអាចកែច្នៃឡើងវិញម្តងទៀតបាន ដែលអាចកាត់ ដែលអាចយកទៅលក់ជាដុំ ឬជារាយបានតាមតាមតម្រូវការពាណិជ្ជកម្មណាមួយ ។ ទោះបីជាមានតែអ្នកមានអំណាចទើបអាចបង្ហាញពីទ្រព្យសម្បត្តិរបស់ពួកគេក្នុងសភាពខ្ជះខ្ជាយក៏ដោយ ក៏សូម្បីតែកូនក្មេងមិនស្លៀកពាក់អ្វីដែលមានឋានៈខ្ពះដែលនោះ ក៏អាចតុបតែងខ្លួនដោយពាក់កងដៃ កងជើង ខ្សែក ក្រវិលមាស និងប្រាក់ដែរ (ឡា លូប៊ែរ គ.ស.១៦៩១ ទំ. ២៧ និងហ្គូដស្វាដ* (Goudswaard) *គ.ស.១៨៦០ ទំ. ៣៤៧) ។*

*ប្រទេសនៅអាស៊ីអាគ្នេយ៍ខ្លះមិនបានធ្វើមាស ឬប្រាក់កាក់ជារូបិយប័ណ្ណនោះទេ ។តម្លៃទិញអ្វីមួយ គឺត្រូវគិតជាមាស ឬប្រាក់ដោយប្រុងប្រយត្នតែម្តង ។ ដូច្នេះហើយឈ្មួញត្រូវតែដឹងពីរបៀបថ្លឹងមាស (ដូចនៅតំបន់ដីកោះ) និងថ្លឹងប្រាក់ (ដូចនៅតំបន់ដីគោក) ដើម្បីធ្វើជំនួញរបស់ពួកគេ ។ ជីរីណូ* (Chirino) *(គ.ស.១៦០៤ ទំ. ៣៦៣) បានអះអាងថា រាល់ប្រជាជនជាតិហ្វីលីពីនសុទ្ធតែកាន់កូនជញ្ជីងតូចមួយតាមខ្លួនដើម្បីបុព្វហេតុនេះ ហើយពួកតាហ្គាឡុក (នៅហ្វីលីពីន) ធ្វើឲ្យពួកអេស្ប៉ាញមានការភ្ញាក់ផ្អើលនៅពេលដែលពួកគេយកចេញមកនូវថ្មពិនិត្យមាសរបស់ពួកគេ ហើយពិនិត្យមើលពីគុណភាពរបស់មាសដែលប្រើសូម្បីតែក្នុងជំនួញដ៏តូចមួយ (សាន់ដេ* (Sande) *គ.ស.១៥៧៧ ទំ. ១០០)។*

*សារៈសំខាន់ដែលឲ្យទៅលើមាសនៅតំបន់ដីកោះនោះ គឺថាមាសសម្បូរនៅគ្រប់ទឹកទន្លេទាំងអស់ជាពិសេសនៅស៊ូម៉ាត្រា ឧបទ្វីបម៉ាឡេ* (Malay Penisula) *លូស្សុន* (Luzon cam Champa) *និងនៅស៊ូឡាវេស៊ី ខាងជើង (សូមមើលផែនទីលេខ ៣)។*

*រហូតមកដល់ដើមសតវត្សទី ១៧ រ៉ែនៅតំបន់ មីណាំងកាប៊ូ* (Minangkabau) *នៃស៊ូម៉ាត្រាកណ្តាល គឺជាតំបន់ដែលផ្តល់ផលឲ្យច្រើនជាងគេបង្អស់នៅក្នុងតំបន់ ដែលដូចរឿងព្រេងនិទាននិយាយអំពីទ្រព្យសម្បត្តិរបស់ព្រះរាជាណាចក្រដើមនៃអាណាចក្រស្រី វីជ័យ* (Sri Vijaya) *។ មាសត្រូវបានគេត្រងចេញពីខ្សាច់នៃទន្លេបូពាំ និងត្រូវបានគេជីករកនៅតាមភ្នំមីណាំងកាប៊ូ ។ មានតំណាលមួយថាមានរ៉ែចំនួន ១២០០ ប្រភេទនៅទីនោះ (ម៉ាសដែន* (Marsden)*គ.ស.១៧៨៣ ទំ. ១៦៨ តែសូមអានប្រៀបធៀបឯកសាររបស់ អេរេដៀរ គ.ស.១៦០០ ទំ. ២៣៨–៣៩ ។ អ្នកដាប់គុក ព័រទុយហ្គាល់ម្នាក់នៅ មេឡាកា ដឹងថាមាសចំនួន ៩ ការពារក្នុងចំណោម ១០ បាហារ នាំចូលមកទីក្រុងនោះជារៀងរាល់ឆ្នាំ ខ្លះយកមកពីមីណាំងកាប៊ូ និងខ្លះទៀតយកមកពី ប៉ាហាំង* (Pahang) *នៅក្នុងម៉ាឡេយ៉ា*


Gold
Silver
Cities
LUZON
Manila
Camarines Norte
MINDANAO
Butuan
Magindanao
SULAWESI
Gorontalo
Makassar
BORNEO
Brunei
Kapuas
Sukadana
JAVA
Tuban
Banten
BURMA
Irrawaddy
Pegu
LAOS
Thang-long (Hanoi)
Red
VIETNAM
Mekong
CHAMPA
SIAM
Ayutthaya
Chaophraya
MALAY PENINSULA
Pahang
Melaka
Kampar
Kota Gedang
Inderagiri
Musi
Tiku
Pariaman
SUMATRA
Aceh

បូញាំ (អារ៉ូហ្យូ (Araujo) គ.ស. ១៥១០ ទំ. ២៨) ។ បន្ទាប់ពីការយកបាននូវក្រុងម៉ាឡាកា ដោយពួកព័រទុយហ្គាល់ និង បន្ទាប់ពីការពង្រីកទឹកដីរបស់អាចេ ចុះមកឆ្នេរខាងលិចនៃកោះស៊ូម៉ាត្រា មាសមីណាំងកាប៊ូភាគច្រើនត្រូវបញ្ជូនទៅ អាចេ តាមរយៈកំពុងផែនៅ ទីកូ (Tiku) និង ប៉ារៀម៉ង (Pariaman) ។ នេះធ្វើឲ្យក្សត្រ អ៊ីស្កានដា មូដា (I skanda Muda) នៅអាចេក្លាយទៅជាក្សត្រមានទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភខ្លាំងជាងគេបង្អស់ ដែលម្តងនោះត្រូវបានគេជំនាស់ មិនឲ្យមានមាស ១០០ បាហារទេនោះ (បូល្យឺ គ.ស. ១៦៦៦ ទំ. ៥៥ និង ៤៤ តែសូមអានប្រៀបធៀបឯកសាររបស់ ឌូបប៊ីន (Dobbin) គ.ស. ១៩៨៣ ទំ. ២៣-២៦) ។ ទោះបីជាការជីកយករ៉ែមីណាំងកាប៊ូ របស់ អាចេ បានអស់ នៅក្នុងទសវត្សឆ្នាំ ១៦៦០ រ៉ែថ្មីទៀតត្រូវបានគេរកឃើញនៅភាគខាងជើងនៃជួរភ្នំសម្បូរមាសប៊ូកឹត បារីសាន (Bukit Barisan) នៅក្នុងដែនដីអាចេ ។ ដូចកាលនៅមីណាំងកាប៊ូដែរ ការងាររបស់អ្នកជីករករ៉ែ គឺជាការងារធ្វើឲ្យ ឈឺខ្លួន គ្រោះថ្នាក់ និងឈឺដោយសារជំងឺ ប៉ុន្តែអត្ថប្រយោជន៍សម្រាប់ពួកគេក៏ច្រើនណាស់ដែរ ដែលធ្វើឲ្យអាចេ ក្លាយទៅជាទីក្រុងដែលពោរពេញទៅដោយមនុស្សរស់នាធ្វើការច្រើនជាងគេបង្អស់ នៅក្នុងតំបន់នៅចុងសតវត្ស ទី ១៧ (ដាំពែរ គ.ស. ១៦៩៩ ទំ. ៩៣-៩៤, អ៊ីប្រាហ៊ីម គ.ស. ១៦៨៨ ទំ. ១៧៤-៧៥, ហ៊ីកាយ៉ាត ពូកាត់ មោហាម៉ាត់ ទំ. ១១៤-១៥ និងវែលម៉ង់ គ.ស. ១៩១៩ ទំ. ៧២-៧៦) ។

ភាគច្រើននៃជំនួញមាសនៅប្រទេសហ្វីលីពីន គ្រប់គ្រងដោយពួកអ៊ីហ្គូរូតស៍ នៃជួរភ្នំ លូស្សុន៍÷ «ពួកគេមិន បានឆ្នៃមាសនោះទេ ហើយពួកគេក៏មិនអាចធ្វើមាសឲ្យល្អឥតខ្ចោះបានដែរ ។ ពួកគេយកមាសនោះទៅកន្លែងមួយ ចំនួននៅតំបន់ អ៊ីលូកូស (Ilocos) ជាទីកន្លែងដែលពួកគេដូរញមាសសម្រាប់ដូរយកអង្ករ ជ្រូក ក្របី ក្ដួយនិងវត្ថុ ផ្សេងទៀតដែលពួកគេមិនមាន ។ ប្រជាជននៅអ៊ីលូកូស បង្កើយការឆ្នៃមាសនោះ ហើយតាមរយៈពួកគេមាសនោះ នឹងត្រូវចែកចាយបន្តទៅទៀត» (ម័រហ្គា (Morga) គ.ស. ១៦០៩ ទំ. ២៦១) ។ គេអាចជីក និងរែងរកមាសបាននៅជួរ ភ្នំភាគខាងជើងនៃអាស៊ីអាគ្នេយ៍ដីគោកដែរ ទុកជាតំបន់ក្បែរយូណាន (Yunnan) ដែលសម្បូរទៅដោយមាស ។ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមប្រទេសនៅតំបន់ដីគោកទាំងអស់ មានតែប្រទេសចាម និងប្រទេសវៀត-ណាមដឹកនាំដោយ ង្វៀន ទេដែលជាអ្នកនាំចេញធំនោះ ។ បន្ទាប់ពីការពង្រីកទឹកដីរបស់ពួកវៀតណាម ចូលទៅ ក្នុងអតីតខេត្តរបស់ប្រទេសចាម ហៅថា ក្វាងណាម (Quangnam) នៅសតវត្សទី ១៥ រួចហើយនោះ ពួកអ្នកដឹកនាំ សម័យង្វៀន មានលទ្ធភាពអាចជីក និងនាំយកមាសកម្រិតខ្ពស់ទៅកាន់ មេឡាកា( ពែរស៍ គ.ស. ១៥១៥ ទំ. ១១៥, ង្វៀន គ.ស. ១៩៧០ ទំ. ៩០-៩១ និងវីតម័រ (Whitmore ) គ.ស. ១៩៨៣ ទំ. ៣៧៦)។ ប្រទេសសៀម និងប្រទេស ភូមា ទទួលមាសមកពីប្រភព ឡាវ និងស្យាន (Shan) នៅភាគខាងជើង ហើយប្រើមាសពួកគេបានទាំងប៉ុន្មានសម្រាប់ ការតុបតែងខ្លួន ឬក៏សម្រាប់ស្រោបវិមានសាសនា ដែលចាំងពាសពេញផ្ទៃដីរបស់ពួកគេ ។ ប្រទេសភូមា អាចជា អ្នកនាំចូលមាសធំមួយ ដែលគួរឲ្យកត់សម្គាល់នោះគឺមកពី យួនណាន ។ ប្រាកដណាស់ ប្រទេសជ្វា ក៏ជាអ្នកនាំចូល មាសធំមួយដែរ ព្រោះថាជាប្រទេសតែមួយគត់នៃតំបន់ទាំងមូល ដែលមិនមានប្រភពរកបានមាសផ្ទាល់ខ្លួនឡើយ នៅសម័យកាលនោះ ។ យ៉ាងណាក៏ដោយ វ៉ាន់ ហ្គូនែស៍ (Van Goens) (គ.ស. ១៦៥៦ ទំ. ១៨២-៨៣) មានការងឿងឆ្ងល់ ថាតើហេតុអ្វីបានជាមាសនៅតែមានតម្លៃថោកនៅប្រទេសជ្វា បើប្រៀបទៅនឹងប្រាក់ ។គាត់គ្រាន់តែអាចពន្យល់ បានថាមានការជីកគាស់ផ្នូរពួកបុរេអ៊ីស្លាម ដែលមានមាសជាច្រើនកប់នៅក្នុងនោះ ហើយដែលមាសទាំងនោះ ប្រហែលជាត្រូវបានគេជីករុករក ឬក៏នាំចូលមកយ៉ាងសន្ធឹកសន្ធាប់ហើយ ។

ប្រាក់មានតម្លៃថោកជាងនេះ ហើយមិនសូវសម្បូរនៅអាស៊ីអាគ្នេយ៍ទៀតផង ទោះបីជាគេឃើញមានប្រាក់

នៅពេលដែលគេជីករុករកមាស នៅកន្លែងជាច្រើន ដូចជាស៊ូម៉ាត្រា និងដួរភ្នំ ដែលសព្វថ្ងៃ គឺនៅភូមា ឡាវ វៀតណាមភាគខាងជើងក៏ដោយ ។ ប្រភពធំជាងគេគឺ តំបន់រ៉ែ បូឌវីន (Bawdwin) នៅតំបន់ស្យាន តាមដងព្រែកមួយក្នុងចំណោមដងព្រែកនៅអ៊ីរ៉ាវ៉ាឌី (Irrawaddy) ដែលតាមការរាស់ស្ទង់ទៅអាចផ្តល់ឲ្យជាមធ្យមនូវប្រាក់ប្រមាណជា ៣.០០០ គីឡូក្រាម ក្នុងមួយឆ្នាំ ពីសតវត្សទី ១៥ ដល់សតវត្សទី ១៨ ពេលដែលកន្លែងនោះត្រូវពួកចិនជីករុករករ៉ែ (ដេឌយែល (Deyell) គ.ស. ១៩៨៣ ទំ. ២២២-២៣) ។

រួមសេចក្តីមក អាស៊ីអាគ្នេយ៍គឺជាតំបន់ដែលសម្បូរទៅដោយមាស ហើយជាតំបន់ដែលមិនមានប្រាក់ច្រើននោះទេ ។ គេឃើញមានការចំណាយមាសដូចតទៅ÷ គឺពីស៊ូម៉ាត្រាទៅកាន់ម៉ាឡៃយ៉ា ដើម្បីចំណាយទៅលើសម្លៀកបំពាក់ឥណ្ឌា (បូល្យឹ គ.ស. ១៦៦៦ ទំ. ៥៧-៥៨) ពីប្រទេសហ្វីលីពីន ទៅកាន់ប្រទេសម៉ិចសិកកូ ធ្វើជា «អំណោយដឹងគុណ» កំណត់ដោយអ្នកទទួលជ័យជម្នះក្នុងសង្គ្រាមអេស្ប៉ាញ (ស្ហូស (Schurz) គ.ស. ១៩៣៩ ទំ. ៣២) និងពីវៀតណាមខាងជើង យកទៅចំណាយទៅលើស៊ុលផ្ទ និងទំនិញនាំចូលផ្សេងៗទៀត ។ ប្រាក់ដែលមិនសូវមានការចាប់អារម្មណ៍ច្រើន មុនសតវត្សទី ១៦ លើកលែងតែនៅប្រទេសឡាវ និងភូមាបានចាប់ផ្តើមហូរចូលមកនៅតំបន់នេះបន្ទាប់ពីនោះមក ។ សម្រាប់ពួកជប៉ុន នៅកំលុងពេលដំណើរការខ្ទីៗរបស់ពួកគេមកក្នុងជំនួញអាស៊ី នៅក្នុងទសវត្សទី ១៦ និងដើមសតវត្សទី ១៧ និងសម្រាប់ពួកព័រទុយហ្កាល់ ពួកអេស្ប៉ាញ និងពួកហូឡង់ ដែលមានប្រាក់មកពីពិភពថ្មីយ៉ាងច្រើននោះ លោហៈពណ៌ប្រផេះ គឺជាគន្លឹះបើកភាពសម្បូរស្តុកស្តម្ភរបស់អាស៊ីអាគ្នេយ៍ ។ ក្នុងកំលុងពេលសតវត្សទី ១៧ កាក់ប្រាក់បានវិវឌ្ឍបន្តិចម្តងៗ ហើយគ្របដណ្តប់ពាសពេញទីផ្សារក្នុងស្រុកទាំងអស់ ។ ជាលទ្ធផលប្រាក់ក៏មានពាសពេញគ្រប់ទីកន្លែងសម្រាប់យកមកធ្វើជាប្រដាប់ប្រដាប្រើប្រាស់ក្នុងផ្ទះបាយ ។

តួនាទីរបស់មាស និងប្រាក់ធ្វើជាគ្រឿងតុបតែងខ្លួន និងការបញ្ជាក់ពីឋានៈក៏ដូចការវិនិយោគ បញ្ជាក់បានថា ទីណាមានទ្រព្យសម្បត្តិ ទីនោះមានជាងមាស ។ ជាងដដែលនេះធ្វើលោហធាតុទាំង ហើយប្រាក់ត្រូវបានជាញឹកញាប់យកមកធ្វើបញ្ចូលជាមួយមាសតាមសមាមាត្រ មួយ លើ ពីរ (វែលម៉ង (Velt man) គ.ស. ១៩០៤ ទំ. ៣៤៦) ។ រាល់រាជធានីទាំងអស់សុទ្ធតែមានជាងមាស ដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកដឹកនាំ និងពួកអភិជនឈ្មួញអ្នកមានទ្រព្យ ។ តាមគេនិយាយមកថា ស៊ូលតង់ អ៊ីស្កានដា មូដា តែម្នាក់មានជាងមាសរហូតដល់ទៅ ៣០០ នាក់សម្រាប់បម្រើនៅឯអាចេ ហើយគាត់អាចបញ្ចុះបញ្ចូលជនជាតិបារាំងម្នាក់ឲ្យចេញពីឧត្តមនាវីឯក ប៊ូល្យឹ បាន (ប៊ូល្យឹ គ.ស. ១៦៦៦ ទំ. ៩០ និង ១០០) ។ មជ្ឈមណ្ឌលរាជវាំងដ៏ស្តុកស្តមភាគច្រើន ដូចជា ស៊ួរ៉ាកាតា (Surakarta) យូកច្យាកាតា (Jogjakarta) តួបាន (Tuban) និងស៊ីដាយូ (Sidayu) នៅជ្វា បង្កើតទម្លាប់មួយឲ្យមានការងារធ្វើមាស ដែលនេះជួយឲ្យរាជវាំងដែលដួលរលំហើយនោះឈរវិញបាន និងបន្តបញ្ជូនជាងមាសឲ្យចេញទៅលក់ ឬធ្វើការទូតជាលក្ខណៈបណ្តោះអាសន្ននៅមណ្ឌលថ្មីៗ ។ ស៊ីដាយូ នៅក្នុងគ.ស. ១៨៦៨ នៅតែមានជាងមាសចំនួន ១២៥ នាក់នៅឡើយដោយមានកូនជាងចំនួន ១៩៧ នាក់ផងដែរ (ឌឹ ហាអាន គ.ស. ១៩១២ III ទំ. ២១៧ និង រូហ្វហ្វែរ គ.ស. ១៩០៤ ទំ. ៩១-៩៥) ។ កូតាហ្គេដាំង (Kota Gedang) ភូមិមួយក្នុងចំណោមភូមិដែលធ្វើមាសយូរយារណាស់មកហើយនៅមីណាំងកាប៊ូ នៅតែមានជាងមាសចំនួន ៣៤៧ នាក់ ធ្វើការក្នុងកំលុងគ.ស. ១៨៩០ («អ៊ីនឡែនឆេន (landsche)» គ.ស. ១៨៩៤ ទំ. ៣១៥)។

ការត្បាញសរសៃមាស និងសរសៃប្រាក់ចូលទៅក្នុងកំណាត់សម្លៀកបំពាក់សូត្រលម្អប្រណីត ក្លាយទៅជាសិល្បៈអភិវឌ្ឍរៀងលឿនមួយបែបទៀត ។ រាជធានីអ៊ីស្លាមដែលនៅជិតតំបន់យកមាស ដូចជា អាចេ ស៊ីអាក់

(Siak) និង កូតា ហ្គេដាង (Kota Gedang) នៅស៊ូម៉ាត្រា សុទ្ធតែល្បីអំពីភាពសម្បូរហូរហៀរនៃសារុង ក្រមា និង កំណាត់ដុកក្បាល ។ បេសកជនទៅតំបន់ព្រះរាជវាំង អាចេ ត្រូវបានគេបង្ហាញពីកំណាត់សម្លៀកបំពាក់ដែល«ធ្វើយ៉ាងល្អប្រណិតដោយមានមាសជាច្រើន»(ឡានកាស្ទ័រ (Lancaster) គ.ស.១៦០៣ ទំ. ១១២) ។ថ្វីបើ អាចេ ជាក្រុងដែលសម្បូរទៅដោយមាសជាទ្រព្យក៏ដោយ ក៏មានពេលខ្លះអាចេនៅតែនាំសរសៃអំបោះមាសមកពី ហ្គ្រេស៊ីក (Gresik) នៅជ្វាភាគខាងកើតដែរ (ឡាម៉ីង (Vlamingh) គ.ស.១៦៤៤ ទំ. ១១២) ។ បើសន្និដ្ឋានទៅពលករជនជាតិជ្វា មានលទ្ធភាពអាចរកប្រាក់ចំណេញដោយធ្វើមាសដែលនាំចូលនោះទៅជាសរសៃអំបោះ ហើយនាំមាសនោះបញ្ចេញតទៅទៀត។

ការប៉ិនប្រសប់នៃការងារធ្វើមាស និងប្រាក់នៅអាស៊ីអាគ្នេយ៍បានទទួលការសរសើរទូទាំងពិភពលោក ។ សូម្បីតែ ក្រូហ្វឺដ (គ.ស.១៨២០ I ទំ. ១៨៣) ដែលជាមនុស្សម្នាក់សើចចំអកឲ្យការងារធ្វើមាស និងប្រាក់នោះក៏ទទួលស្គាល់ថា «ពួកជាងមាសទាំងនោះមានការប៉ិនប្រសប់ក្នុងការធ្វើមាស និងប្រាក់ជាងសិល្បៈយន្តការឯទៀត» ។ ពាក្យថា«ជាងមាស» ត្រូវបានគេប្រើប្រាស់ដើម្បីពន្យល់ស្ទើរតែពាក់កណ្ដាលសំណុំពាក្យដែលទាក់ទងទៅនឹងការងារធ្វើលោហធាតុទៅហើយ នៅក្នុងវចនានុក្រមតាហ្គាឡុក (ភាសាជាតិរបស់ប្រទេសហ្វីលីពីន) នៅ គ.ស.១៦១៣ (ស្កុត គ.ស.១៩៨២ ទំ. ៥៣៣) ។ ទោះបីជាឧបករណ៍ចំនួនទាំង ២២ ដែលធ្វើដោយជាងមាសនៅ អាចេ ហាក់ដូចជាមានភាពសាមញ្ញសម្រាប់ពួកអឺរ៉ុបនៅសតវត្សទី ១៩ ក៏ដោយ ក៏ឧបករណ៍ទាំងនោះបង្ហាញនូវបច្ចេកទេសជាច្រើនបែប និងភាពប៉ិនប្រសប់ក្នុងការងារធ្វើគ្រឿងតុបតែង ដែលមិនអាចមានផលិតផលហត្ថកម្មឯណាប្រៀបធៀបបានដែរ (វែលម៉ង់ គ.ស.១៩០៤ ទំ. ៣៤៣-៤៥ តែសូមអានប្រៀបធៀបឯកសាររបស់ម៉ាសដែន គ.ស.១៧៨៣ ទំ. ១៧៨-៨០) ។ សាសនទូតជនជាតិបារាំងម្នាក់ ឈ្មោះថា វ៉ាឆេត៍ មានការភ្ញាក់ផ្អើលទៅលើសមត្ថភាពរបស់ជាងមាសប្រចាំព្រះរាជវាំងក្នុងការជួសជុលទ្រនិចនាឡិកាខូចមួយ នៅពេលដែលគាត់បានជួបនឹងក្បត្រាធ្វ៉ៃយែន សតវត្សទី ១៧ នៃកូសាំងស៊ីន ម្នាក់ដែលមាននាឡិកាមានមុខធ្វើអំពីប្រាក់ ។ មិនតែប៉ុណ្ណោះ គាត់រឹតតែភ្ញាក់ផ្អើលខ្លាំងជាងនេះទៅទៀត «នៅពេលដែលខ្ញុំ (ជាសាសនទូតបារាំងនោះ) ដាក់នាឡិកាចំនួនពីរគ្រឿងដែលដូចគ្នាបេះបិត នៅលើបាតដៃរបស់ខ្ញុំ ខ្ញុំពុំអាចបែងចែកមួយណាជារបស់ចាស់មួយណាជារបស់ថ្មីនោះឡើយ ។ ទាំងនេះហាក់ដូចជាមិនគួរឲ្យជឿទាល់តែសោះ នេះដូចជាសុបិន្តយ៉ាងដូច្នោះដែរប្រសិនបើខ្ញុំមិនបានឃើញនឹងភ្នែកផ្ទាល់ទេនោះ ។ នាឡិកាទាំងពីរនោះ គឺដូចគ្នាមែនទែន» (ធ្វ៉ៃយែន គ.ស.១៩៧០ ទំ. ៩៨)។

## ជំនាញអាជីព

ប្រពលភាពនៃពាណិជ្ជកម្មតាមទន្លេ និងតាមសមុទ្របានជុំរុញឲ្យមានភាពជំនាញខាងផលិតឧបករណ៍ និងសម្ភារៈធ្វើអំពីកុលាលភាជន៍ និងលោហធាតុ ។ នៅតាមភូមិដែលផ្ដោតទៅលើការធ្វើថ្នាំង ការធ្វើគ្រឿងថ្ម ការយកថ្មកំបោរ ឬក៏ការរំលាយលោហធាតុទាំងអស់គ្នា គឺប្រហែលជាមានទីតាំងនៅជិតទៅនឹងប្រភពនៃធនធានរ៉ែសំខាន់ៗហើយ ។ ទីតាំងសម្រាប់ការងារធ្វើកំណាត់សម្លៀកបំពាក់ ការងារធ្វើសម្លៀកបំពាក់រោមសត្វ ឬក៏ការងារសាងសង់ទូក ភាគច្រើនស្ថិតនៅតំបន់ដែលមិនមានអំណោយសម្រាប់ការដាំស្រូវឲ្យបានផលចំណេញនោះទេ ដូចជាតំបន់ស្ងួតនៅស៊ូឡាវេស៊ី ភាគខាងអាគ្នេយ៍ ឬនៅជ្វាភាគខាងកើតក្ដី ។

ប៉ុន្តែ អ្វីដែលទាក់ទាញឲ្យមានការផ្ដោតសំខាន់ធ្ងន់ទៅលើផ្នែកផលិតនោះ គឺទីក្រុងធំៗនៃយុគសម័យ

ពាណិជ្ជកម្មឯណោះទេ ។ នៅតាមទីក្រុងទាំងនោះមាន អតិថិជនដ៏មានទ្រព្យច្រើនដាងគេ ដែលទិញប្រើប្រាស់ទំនិញសិប្បកម្មល្អៗ រួមមាន រាជវាំង ហើយនៅទីក្រុងទាំងនោះក៏មានផ្លូវសម្រាប់ធ្វើជំនួញទាំងក្នុង និងក្រៅស្រុកប្រសព្វគ្នា ដែលអាចឲ្យផលិផលជំនាញក្នុងស្រុកអាចឲ្យគេនឹកដឹកជញ្ជូន និងធ្វើការដោះដូរបាន ។ ដូច្នេះហើយបានជាកន្លែងផលិតផលជំនាញដោយសប្បកម្មជាច្រើនជាទូទៅសមានទីតាំងនៅតាមជាយនៃក្រុងនីមួយៗ ។ នៅរាជធានីនៃអាចេ មាន «ជាងមាស អ្នកផលិតកាំភ្លើង ជាងធ្វើ និងដួសដុលកប៉ាល់ ជាងកាត់ដេរសម្លៀកបំពាក់ ជាងតម្បាញ អ្នកធ្វើមួកលក់ អ្នកធ្វើថ្នាំ និងអ្នកបិតស្រា...អ្នកធ្វើសម្ភារៈផ្ទះបាយ និងជាងលោហៈ» (ដាវីស គ.ស. ១៦០០ ទំ. ១៥១)។ ស្រដៀងគ្នានេះដែរ «ពួកសៀមដែលរស់នៅតាមទីក្រុង និងតំបន់ប្រជុំជនទាំងឡាយគឺជា អភិជនចេញចូលរាជវាំង មន្ត្រី អ្នកជំនួញ អ្នករកស៊ីដួលទូក អ្នកនេសាទ ពាណិជ្ជករ ឬក៏ជាអ្នកធ្វើការជំនាញដែលម្នាក់ៗសុទ្ធតែធ្វើការងារឲ្យខ្លួនឯង» នេះតាមការសង្កេតរបស់ ស្សូតង់ (Schouten) (គ.ស. ១៦៣៦ ទំ. ១៤៧) ។ នៅ ថាំង-ឡុង (Thang-long) (នៅទីក្រុងហាន់នូយ (Hanoi) ) ក៏មានអាជីព ឬរបររកស៊ីប្រភេទដូចគ្នានេះដែរ ប៉ុន្តែមានបន្ថែមការងារ អ្នកធ្វើក្រដាស និងអ្នកធ្វើសូត្រ និងថ្នាំលាបម្រក្សុ (ដាំពែរ គ.ស. ១៦៩៩ ទំ. ៤៦) ។

នៅពេលដែលបេសកជនអង់គ្លេសម្នាក់ ធ្វើដំណើរទៅកាន់អ៊ីរ៉ាវាឌី (Irrawaddy) នៅក្នុងគ.ស. ១៧៩៥ គាត់បានសម្គាល់ថា ភូមិនៅទីនោះមានសភាពមមាញឹកខ្លាំងឡើង នៅពេលដែលគាត់ធ្វើដំណើរឆ្ពោះទៅកាន់រាជធានីភូមា របស់ អាម៉ារ៉ាពូរ៉ា (Amarapura) ដែលទីបញ្ចប់បានរួមគ្នាក្លាយទៅជាតំបន់តែមួយ ។ «កន្លែងនីមួយៗ...មានអ្នករស់នៅដែលមានឋានៈដាក់លាក់មួយ ដែលមានពាណិជ្ជកម្មដោយឡែកពីគ្នាខ្លះៗ ឬប្រកបមុខរបរចម្លែកមួយចំនួន» (ស៊ីមស៍ គ.ស. ១៨២៧ I ទំ. ១០) ។ ភួង (phuong) (ទីស្នាក់ការរដ្ឋបាល) ជាច្រើនក្នុងចំណោមភួងទាំង ៣៦ នៅថាង-ឡុងនោះ ត្រូវបានគេដាក់ឈ្មោះឲ្យទៅតាមមុខរបរដែលគេមាននៅតាមទីស្នាក់ការនោះ ។ ទីស្នាក់ការនីមួយៗគ្រប់គ្រងផ្លូវដាក់លាក់មួយដែលមានហាងដែលផលិតតែផលិតផលជំនាញរបស់ពួកគេនោះ (ង្វៀន គ.ស. ១៩៧០ ទំ. ១១៦) ។ទីក្រុងទាំងនោះដែលជាមជ្ឈមណ្ឌលផលិតកម្មដ៏អស្ចារ្យនោះបន្តទម្រង់នេះរហូតដល់សតវត្សទី ១៩។ ជាតួយ៉ាងទីក្រុងនៅប្រ៊ុយនេ មានកំពុង «Kampung» មួយសម្រាប់អ្នកធ្វើគ្រីស (Kris) កម្មករធ្វើគ្រឿងទង់ដែង និងអ្នកផលិតប្រេង កំពុងពីរសម្រាប់កម្មករធ្វើដែក និងកំពុងបីសម្រាប់ផលិតជញ្ជាំង និងដំបូលប្រក់ស្លឹក នីប៉ា (nipah) (សេន ចន គ.ស ១៨៦២ ទំ. ២៥៤-៥៦) ។ ស្រដៀងគ្នានេះដែរ នៅស៊ូរ៉ាបាយ៉ា (Surabaya) នៅសតវត្សទី ១៩ អ្នកមានជំនាញអាជីពបន្តមានវត្តមាននៅក្នុងកំពុងជំនាញរបស់ពួកគេ ដែលមានដូចជា អ្នកធ្វើកំណាត់សម្លៀកបំពាក់ពេមសត្វនៅទូកានហ្គាន (Tukangan) ជាងទង់ដែង នៅ ក្រាងហ្គាង (Kranggan) ជាងឆ្លាក់ឈើនៅ ប៊ូប៊ុតាន (Bubutan) ជាងសង្ហារិមនៅ តំបាក់-ហ្គ្រាំងស៊ីង (Tambak-gringsing) ជាងតម្បាញ សុងកិត (songket) នៅអំពែល (Ampel) (ច្បាស្ពែរ (Jasper) គ.ស. ១៩០៤ ទំ. ១ និងហែចម៉ង់ (Hageman) គ.ស. ១៨៥៩ ទំ. ១៤១)។

ផ្ទុយពីជំនាញខ្ពស់របស់ពួកគេ អ្នកជំនាញអាជីពមានបានក្លាយទៅជាអ្នកផលិតក្នុងទ្រង់ទ្រាយធំនោះទេ ជាមួយ និងរាជធានីដ៏មានសារៈសំខាន់របស់ពួកគេនោះ ។ ក្រុមកម្មករចាំបាច់នៃផលិតកម្មនៅទូទាំងអាស៊ីអាគ្នេយ៍នោះគឺបណ្តាសមាជិកក្នុងផ្ទះ ដែលមានសាច់ញាតិបងប្អូនពឹងពាក់មួយចំនួន និងកូនជាងដែលធ្វើការឲ្យសិប្បករជំនាញនោះ ។ ជាជាងធ្វើការជាប្រចាំដើម្បីបង្កើនសម្ភារៈឲ្យច្រើននោះ ក្រុមកម្មករពួកកូនជាងទាំងនោះហាក់ដូចជាធ្វើការផលិតតែនៅពេលណាដែលពួកគេទទួលបានប្រយោជន៍តែប៉ុណ្ណោះ ។ ដាំពែរ (គ.ស. ១៦៩៧ ទំ. ២២៧) កត់ចំណាំថានៅក្នុងរាជធានីរបស់ ម៉ាហ្គីនដូណាវ (Magindanao) (នៅភាគខាងត្បូងនៃប្រទេសហ្វីលីពីន) មានពួកជាង

មាស និងដាំងប្រាក់ «ចាំធ្វើអ្វីដែលយើងប្រាថ្នាចង់បាន ប៉ុន្តែពួកគេមិនមានហាងដែលពោរពេញទៅដោយសម្ភារៈ ឬឧបករណ៍ដែលធ្វើហើយសម្រាប់លក់នោះឡើយ» ។ ដូចគ្នានេះដែរ អ្នកធ្វើគ្រឿងតម្បាញលាបម្រក្សស្ស សូត្រ និងកុលាលភាជន៍ជាច្រើននៅរាជធានីភាគខាងជើងនៃប្រទេសវៀតណាមនោះនឹងត្រូវបានគេចាត់ឲ្យធ្វើការនៅពេលដែលមាននាវាពាណិជ្ជកម្មមកដល់តែប៉ុណ្ណោះ ហើយពួកគេនឹងត្រូវបានគេបង់ប្រាក់ឲ្យមុនដើម្បីធ្វើឲ្យទំនិញនាំចេញទាំងនេះហើយរួចរាល់ (ដាំពែរ គ.ស.១៦៩៩ ទំ. ៤៩) ។ អ្នកជំនាញអាជីពហាក់ដូចជាមានការស្ទាក់ស្ទើរក្នុងការប្រមូលយកលោហៈមានតម្លៃថ្លៃមកប្រើ ដោយមិនមានការបង់ប្រាក់ជាមុននោះ ។ ទោះបីបន្ទាប់ពី ២ សតវត្សក្រោយមកក៏ដោយ នៅស៊ូរ៉ាបាយ៉ា នៅទសវត្សឆ្នាំ១៨៥០ពួកអ្នកជំនាញអាជីពជនជាតិជ្វា ត្រូវបានគេចាត់ថានឹងធ្វើការងារតែពេលណាដែលពួកគេទទួលបានការបង់ប្រាក់ទុកជាមុនតែប៉ុណ្ណោះដែលទង្វើនេះបង្កើតបានជាចំណងនៃម្ចាស់ និងការការពារជាមួយអ្នកទិញ ។ នៅពេលដែលការងាររួចរាល់សព្វគ្រប់ហើយ ចំណងនេះនឹងត្រូវបញ្ចប់ដែរ ហើយជាងក៏ឈប់ធ្វើការងារនោះដែរ (ហេច្សម៉ង់ (Hag eman) គ.ស.១៨៥៩ ទំ. ១៤២) ។ ប្រភពនៃការអនុវត្តបែបនេះអាចមួយផ្នែកមកពីការចែកដាច់គ្នានូវតួនាទីរវាងពាណិជ្ជករ និងជាងប៉ុន្តែកត្តាចម្បងនោះ គឺមកពីការខ្វះខាតខាងសន្តិសុខសម្រាប់រាជធានីរបស់អ្នកធ្វើការឯករាជ ។ ដោយមិនម្ចាក់ ឬថៅកែដើម្បីការពារលទ្ធផលការងាររបស់ជាងនោះអ្នកជំនាញអាជីពមិនអាចប្រមូលបង្កើនសម្ភារៈទុកដែលអាចទាក់ទាញការចង់បានរបស់អ្នកមានអំណាចនោះឡើយ ។

ជាទូទៅអ្នកជំនាញអាជីពត្រូវបានគេពណ៌នាដោយអ្នកខាងក្រៅស្រុកថាជាទាសករ ឬមនុស្សមានចំណង ហើយតាមពិតទៅមានការពិបាកក្នុងការកំណត់បែងចែកភាពខុសគ្នារវាងទាសករដែលគេទិញដែលត្រូវរកប្រាក់ចំណាយទៅលើការថែខ្លួនដោយម្ចាស់នោះ និងជាងជំនាញដែលត្រូវប្រឈមមុខធ្វើកិច្ចសន្យាជាមួយនឹងម្ចាស់របស់ពួកគេនោះ ។ «ប៉ុន្តែមិនមានភាពលំបាកអ្វីក្នុងការនិយាយស្តីរបស់ចៅហ្វាយនាយទៅកាន់ទាសកររបស់គាត់នោះទេគ្រាន់តែជាភាពគ្មានក្តីមេត្តា ដូចនៅពេលដែលនិយាយថា ធ្វើរាល់ប្រភេទការងារទៅតាមបង្គាប់ទៅបានហើយ ។ ប៉ុន្តែអ្នកដែលអាចធ្វើការក្រៅពីការងារដ៏ធុញទ្រាន់នោះនឹងរស់នៅបានស្រួលល្មមដោយសារភាពឧស្សាហ៍ព្យាយាមរបស់ពួកគេ ។ ប៉ុន្តែមិនមែនទេ ពួកគេត្រូវចៅហ្វាយនាយរបស់ពួកគេឲ្យខ្ចីលុយហើយជំរុញឲ្យចាប់ផ្តើមពាណិជ្ជកម្ម ឬជំនួញខ្លះទៀតផង» (ដាំពែរ គ.ស.១៦៩៩ ទំ. ៩៨ ដោយសំដៅទៅលើ ស្ថានភាពនៅអាចេះ) ។ នៅបាតង់ នៅ គ.ស.១៥៩៦ ទាសករដែលជាស្ត្រីជាញឹកញាប់ត្បាញកំណាត់ដែលធ្វើជាទំនិញសម្រាប់លក់ឲ្យចៅហ្វាយនាយរបស់ពួកគេ (លូដូវីស្គស៍ គ.ស.១៥៩៨ ទំ.១២៩) ។ នៅម៉ាឡាកា មុនពេលពួកព័រទុយហ្គាល់ វាយយកបាននៅ គ.ស.១៥១១នោះមានប្រជាជនជ្វារស់នៅទីនោះយ៉ាងច្រើន ដែលពួកនោះ គឺជាទាសករ ឬអ្នកស្នាក់អាស្រ័យពួកឈ្មួញជ្វាដែលផ្គត់ផ្គង់ម៉ាឡាកា ដោយគ្រឿងម្ហូបអាហារ និងជំនួញភាគច្រើននៅទីក្រុងនោះ ។ ឈ្មួញអ្នកមានជាងគេ ដែលមានងារថា អ៊ូតាម៉ាឌិរ៉ាច្យា (Utama Diraja) ត្រូវបានគេអះអាងថាគ្រប់គ្រងទាសករចំនួន ៨.០០០នាក់ (អែមប៉ូលី (Empoli) គ.ស.១៥១៤ ទំ. ១៣០-៤០ និងបារ៉ូស (Barros) គ.ស.១៥៦៣ II ទំ. ii និង ៥២) ។ ពួកជ្វាទាំងនេះ គឺជាអ្នកជំនាញអាជីពនាំមុខគេនៃមជ្ឈមណ្ឌលពាណិជ្ជកម្ម៖ «ពួកគេឆ្លាតវៃណាស់ក្នុងផលិតទូ ។ ពាណិជ្ជកម្មផ្សេងទៀតដែលពួកគេមានគឺការផលិតកាំភ្លើងមានទម្ងន់ធ្ងន់ និងអាវុធគ្រប់ប្រភេទ» (បាប៊ូសា (Barbosa) គ.ស.១៥១៨ II ទំ. ១៩៣) ។ អាល់ប៊ូកែ្គក(Albuquerque) មានការកោតសរសើរយ៉ាងខ្លាំងទៅលើស្នាដៃជំនាញ ដែលនេះធ្វើឲ្យគាត់នាំយកជាងឈើជនជាតិជ្វាចំនួន ៦០ នាក់មកពី មេឡាកា តាមកប៉ាល់មកប្រទេសឥណ្ឌា បន្ទាប់ពីគាត់បានទទួលជោគជ័យលើ

ទីក្រុងនោះដោយមានជំនឿថា «ពួកកម្មករនៅក្បែរដៃទាំងនេះ» នឹងអាចដួសផុលកប៉ាល់របស់ពួកព័រទុយហ្គាលនៅឆ្លងសមុទ្រឥណ្ឌាឡើងវិញ ។ ពួកជាងឈើទាំងមិនបានទៅដល់ប្រទេសឥណ្ឌាទេ ព្រោះពួកគេធ្វើការបះបោរប្រឆាំង ហើយយកនាវាពួកព័រទុយហ្គាល់នោះទៅបាំសែ ភាសា ដែលជាកន្លែងពួកគេទទួលការស្វាគមន៍យ៉ាងខ្លាំង (អាល់ប៊ូកែ្កក គ.ស.១៥៥៧ ទំ. ១៦៨) ។

នៅតាមទីក្រុងរបស់រាជវង្ស ការផ្តោតសំខាន់ទៅលើការផលិត ដែលជាព្រះរាជរាំងផ្ទាល់នោះ គឺជាអ្នកទាមទាដ៏ធំមួយដែរ ។ អ្នកជំនាញអាជីពតែងតែទទួលបាននូវការយកចិត្តទុកដាក់ ហើយនិងទទួលបាននូវកិត្តិយស ដែលចៅហ្វាយនាយដ៏មានអំណាចរបស់ពួកគេបានផ្តល់ឲ្យផងដែរ ។ ប៉ុន្តែការងាររបស់ពួកគេត្រូវបានគេចាត់ទុកថាជាការបញ្ជាក់ពីការដឹងគុណដល់ព្រះមហាក្សត្រ ឬដល់ពួកមន្ត្រីពាណិជ្ជកម្មទៅវិញ ។ ពួកគេមិនទទួលបានកម្រៃលើពលកម្មការងាររបស់ពួកគេប៉ុន្មាននោះទេ ដោយសារតែត្រូវបានចៅហ្វាយនាយរបស់ពួកគេផ្គត់ផ្គង់ហើយនោះ ។ ស្ថិតនៅក្រោមលក្ខខណ្ឌតាមទំនើងចិត្ត ដែលមាននៅរាជធានីមួយចំនួននោះ ប្រព័ន្ធបែបនេះមានការប៉ះពាល់យ៉ាងខ្លាំងទៅលើផលិតកម្មសម្រាប់ទីផ្សារ ។ ជាតួយ៉ាង នៅកំលុងគ.ស.១៦៤៣-៤៤ «ជាងធ្វើឧបករណ៍ភ្លេងឈើ (សម្រាប់វង់ភ្លេងនៅឥណ្ឌូនេស៊ី) និងជាងដែក» មួយរំពេចនោះត្រូវបានគេបង្ខំឲ្យធ្វើការក្នុងសេវាកម្ម ដោយស៊ុលតង់ អាហ្គុង (Sultan Agung) នៃទីក្រុងម៉ាតារ៉ាម (Mataram) ដើម្បីសាកល្បងធ្វើកាំភ្លើងធំ (បាបាដ អាំង សាងកាឡា (Babad ing Sangkala) គ.ស. ១៧៣៨ ទំ. ៤៤-៤៥) ។ នៅសម័យអឺរ៉ុបសៀម (Siam Europeans) គេឃើញមានជាសម័យសក្តិភូមិ ដែលជាឧបសគ្គដ៏ធំមួយសម្រាប់ការអភិវឌ្ឍវិស័យសិប្បកម្ម៖ «មិនមាននរណាម្នាក់នៅក្នុងប្រទេសនេះហ៊ានចេញមកអះអាងថាខ្លួនមានលក្ខណៈខុសពីគេតាមបែបបទណាមួយឡើយ ព្រោះក្លាចគេចាប់បង្ខំឲ្យធ្វើការអស់មួយជីវិតដោយមិនមានកំរៃ ដែលជាការបម្រើឲ្យក្សត្រាអង្គនេះ» (ឡា លូបែរ គ.ស.១៦៩១ ទំ. ៦៩ តែសូមអានប្រៀបធៀបឯកសាររបស់ ព័រវ៉ឺរ (Poivre) គ.ស. ១៧៤៧ ទំ. ៥៧-៦០ និងក្រលហ្វ៊ដ គ.ស. ១៨២៨ ទំ. ៣២២) ។

នៅតំបន់ដែលយើងដឹងថាមានការផ្តោតសំខាន់ទៅលើអ្នកជំនាញអាជីព អាចលក់ផលិតផលរបស់ពួកបានយ៉ាងសកម្មតាមរយៈប្រព័ន្ធទីផ្សារដែលនៅសែនឆ្ងាយ ហាក់ដូចជាជាអតីតរាជធានីដែលម្ចាស់ជារាជវង្សបានចាកចេញអស់ទៅហើយ ។ ករណីមានដូចនៅមជ្ឈមណ្ឌលផលិតនៅឈូងសមុទ្រភាគខាងជើងនៃជ្វា ដែលនៅសតវត្សទី១៩ មានផលិតផលហ្គ្រេស៊ីក (Gresik) និងស៊ួរ៉ាបាយ៉ា (ដែលជាទង់ដែង) ទូបាន (Tuban) និង ស៊ីដាយូ (ដែលជាមាស) និងច្បាប៉ារ៉ា (Japara) (ដែលជាគ្រឿងសង្ហារិម) ។ ពួកជាងទង់ដែងជនជាតិស៊ូដង់ នៃក្រុងសៀនជួរ (Cian-jur) និងស៊ូមេដង់ (Sumedang) ពួកអ្នកផលិតលោហៈមាស និងគ្រឿងសពាវុធ នៅមីណាំងកាប៊ូ និងពួកជាងលោហៈឲ្យប្រជាជននៅតំបន់ដីគោកនៅពាសពេញអាស៊ីអាគ្នេយ៍ បានរំដោះខ្លួនពួកគេចេញពីភាពជាទាសករដោយសារភាពដាច់ស្រយាលរបស់ពួកគេ ។ ប៉ុន្តែនៅក្នុងអតីតកាលរបស់ពួកគេ យើងនៅតែអាចតាមដានដឹងថាមានពេលណាមួយនោះដែលពួកគេធ្លាប់ជាទាសករ ហើយផ្តល់សារអាករឲ្យទៅរាជវាំង ។ តំបន់ផលិតកម្មទង់ដែង និងគ្រឿងសព្វាវុធដែលសកម្មជាងគេនៅសតវត្សទី ១៩ នៅប្រទេសឥណ្ឌូនេស៊ី គឺតំបន់ណេហ្គារា (Negara) ដែលនៅឆ្ងាយតាមព្រែកនៃទន្លេ បារីតូ (Barito) នៅប័រណេអូ ខាងត្បូង ។ ទោះបីជាយើងមិនមានព័ត៌មានអ្វីស្តីអំពីជាងលោហៈនៅតំបន់ណេហ្គារ៉ា នេះនៅមុនសតវត្សទី ១៩ ក្តីក៏យើងអាចក្រឡេកមើលទៅក្រោយនៅសតវត្សទី ១៦ នៅពេលដែលណេហ្គារ៉ា គឺជារាជធានីបុរអ៊ីស្លាម នៅតំបន់នោះ ។ មានម្តងនោះស៊ុលតង់ណាត (Sultanate) នៃ បាន

ច្យាម៉ាស៊ីន (Banjarmasin) ត្រូវបានបង្កើតឡើងនៅក្បែរមាត់ទន្លេបារីតូ ហើយសិប្បករនៃតំបន់ណេហ្គារ៉ាមានសេរីភាពក្នុងការផលិតដើម្បីយកទៅទីផ្សារ ដែលហេតុនេះធ្វើឲ្យមានសិប្បករកាន់តែច្រើនឡើងៗ ។ ទោះបីជាស៊ុលតង់មិនមើលការលើពួកគេទៀតក៏ដោយ ក៏គាត់នៅតែទាមទាឲ្យពួកគេផលិតអាវុធសម្រាប់គាត់ដោយមិនគិតថ្លៃ ដែលធ្វើក្នុងនាមជាសាអាករថ្វាយដែរ (ម៉ាសស្យាល់ (Marschall) គ.ស. ១៩៦៨ ទំ.១៣៧-៣៩, ឡំបាដ (Lombard) គ.ស. ១៩៧៩ ទំ. ២៤០-៤១ និងរ៉ាស់ (Ras) គ.ស. ១៩៦៨ទំ. ៦២៦) ។

# កុលាលភាជន៍

ឆ្នាំងដីដែលគេធ្វើនៅពាសពេញអាស៊ីអាគ្នេយ៍អស់រយៈពេលរាប់ពាន់ឆ្នាំហើយនោះ បានរាយប៉ាយទៅដល់ទីឆ្ងាយដាច់ស្រយាលដោយសារការមកដល់នៃយុគសម័យពាណិជ្ជកម្ម ។ បច្ចេកធ្វើឆ្នាំងដីនោះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ប៉ុន្តែមិនមានលក្ខណៈដូចគ្នាទាំងស្រុងនោះទេ ។ នៅភាគខាងកើតនៃតំបន់ដីកោះ និងប្រទេសហ្វីលីពីន ប្រដាប់ប្រដារប្រើក្នុងផ្ទះនៅតែត្រូវបានធ្វើឡើងដោយប្រើបច្ចេកទេស «ច្រវ៉ា និងដែកបន្ទះ» (ស្កត់ គ.ស. ១៩៨២ ទំ. ៥៣១ និងអេឡែន (Ellen) និងហ្គ្រូវើរ Groverគ.ស. ១៩៧៤ ទំ. ៣៥៧) ។ ផលិតផលកុលាលភាជន៍សំខាន់ៗរួមមាន៖ ផុងដាក់ទឹក ផុងផ្ទុកទឹកដែលមានដំពួយ ហៅថា ខេនឌី (kendi) អំពូលភ្លើង និងចំហេះធូប ផុងផ្ទុកប្រេង និងចានធំសម្រាប់លាយគ្រឿងផ្សេងៗ ។ ផុងទាំងអស់នេះត្រូវគេដុតដោយកំដៅកម្រិតទាប ។ ផុងទាំងអស់នេះមិនមានលាបថ្នាំរលោងភ្លឺដូចកញ្ចក់ដើម្បីការពារការលិចទឹកនោះទេ ប៉ុន្តែគេលាបជ័របន្ទាប់ពីដុតរួច ។

រាល់ដំណាក់កាលនៃដំណើរការនៃការផលិតឆ្នាំនេះគឺសុទ្ធតែជាតួនាទីរបស់ស្ត្រីទាំងអស់ យ៉ាងហោចណាស់សម្រាប់ស្ត្រីរស់នៅតំបន់ដីកោះដែរ ។ សព្វថ្ងៃនេះ នៅម៉ាលូកូ ប្រសិនបើបុរសណាម្នាក់ធ្វើការងារនេះ ឬសូម្បីតែទៅកាន់ទីកន្លែងដែលគេជីកយកដីឥដ្ឋមកធ្វើឆ្នាំនេះ ក៏ត្រូវគេចាត់ថាជាការប្រឆាំងទៅនឹងសង្គម ឬប្រពៃណីដែរ (អេឡែន និងហ្គ្រូវើរ គ.ស. ១៩៧៤ ទំ. ៣៥៦) ។ រាល់ទីកន្លែងណាដែលមានដីឥដ្ឋល្អអាចយកមកធ្វើឆ្នាំបានកន្លែងនោះនឹងកើតមានជាភូមិនៃអ្នកជំនាញធ្វើឆ្នាំ ហើយដែលកន្លែងសម្រាប់ស្ត្រីធ្វើឆ្នាំនោះត្រូវមានចម្ងាយឆ្ងាយពីភូមិរហូតដល់ទៅ ១០០ គីឡូម៉ែត្រឯណោះ ។ ជាតួយ៉ាង នៅភូមិដែលផលិតឆ្នាំមួយចំនួនដែលនៅជិតតំបន់ពាណិជ្ជកម្មនោះ ដឹងជញ្ជូនផលិតផលល្អៗរបស់ពួកគេទៅរឹតតែឆ្ងាយជាងនេះទៅទៀត ដូចជាដឹកពីផ្វាខាងជើងទៅកាន់កំពុងផែនៅជុំវិញម៉ាលូកូ (Meluku) និងប៊ុរណេអូ (យោងតាមឯកសារដដែលខាងលើនេះ ទំ. ៣៥៤-៥៥ និងហ្វុក់ស៍ (Fox) គ.ស. ១៩៥៩ ទំ. ៣៧៣-៧៤ និងច្យាកុបស៍ (Jacobs) គ.ស. ១៨៩៤ ទំ. ១៣៧-៣៨)។

កុលាលភាជន៍ដែលលាបថ្នាំរលោងភ្លឺថ្លា ហើយមានគុណភាពខ្ពស់របស់ពួកចិនគឺជាទំនិញពាណិជ្ជកម្មធំមួយសម្រាប់តំបន់ដាច់ឆ្ងាយ ។ ដោយមានការតុបតែងយ៉ាងស្អាត និងត្រូវបានដុតដោយកំដៅក្តៅខ្លាំងជាងដែលគេអាចធ្វើទៅបាននៅក្នុងឡក្នុងស្រុក ចានរាប និងចានក្រលោមធំៗទាំងនេះបានក្លាយទៅជាវត្ថុមានតម្លៃ និងឋានៈដ៏ខ្ពស់ ។ នៅប្រទេសហ្វីលីពីន ស៊ូឡាវេស៊ី និងតំបន់មូលូកាស ចានទាំងនេះត្រូវបានគេតម្កល់ទុកនៅជុំវិញសាកសប់នៅកន្លែងកប់ខ្មោច ដើម្បីជូនដំណើរវិញ្ញាណអ្នកស្លាប់នោះឲ្យទៅពិភពមួយទៀត ។ នៅជ្វា បាលី និងនៅស៊ូឡាវេស៊ីខាងត្បូង ចានទាំងនោះត្រូវគេបញ្ចូលទៅក្នុងផ្ទៃជញ្ជាំងនៅតាមវិហារសាសនាអ៊ីស្លាម ផ្នូរតម្កល់សប់ និងនៅតាមព្រះរាជវាំង ។ សម្រាប់ពួកអាស៊ីអាគ្នេយ៍ដែលមានទ្រព្យច្រើនបំផុតនោះ ចានទាំងនេះត្រូវបានគេយកមកប្រើសម្រាប់ដាក់ទឹកផឹក ចានលាងម្រាមដៃ និងចានបាយ ។ របកគំហើញបានមកពីការជីករាវរកពីក្នុងដីនៅតំបន់

កូតា ចិន (Kota China) និងម្វ៉ារ៉ា ចម្បាំប៊ី (Muara Jambi) នៅក្នុងស៊ូម៉ាត្រា និងនៅតាមដីសណ្ដនៃទន្លេប្រ៊ុយនេ និងសារ៉ាវ៉ាក (Sarawak) និងនៅម៉ានីល និងបាតាំងហ្គាស ពាតានងាស នៅក្នុងលូស្សន់ និងនៅបានតង់ និងតួបាននៅផ្វា និងនៅតំបន់ក្រោមទឹកខ្ទេចខ្ទីនៅឈូងសមុទ្រប្រទេសថៃជាច្រើនទៀត អាចធ្វើឲ្យយើងដឹងពីដឹកជញ្ជូននាំចូលកុលាលភាជន៍ដែលបានចាប់ផ្ដើមយ៉ាងយឺតៗនៅកំលុងសតវត្សទី ១០ ហើយកើនឡើងដល់ចំណុចខ្ពស់បំផុតនៅរវាងចុងសតវត្សទី ១៣ និងដើមសតវត្សទី ១៦ (លូកស៊ីន (Locsin) គ.ស. ១៩៦៧, ម៉ីលណែរ (Milner), ម៉ាក់គីនណុង (McKinnon) និងស៊ីណារ (Sinar) គ.ស. ១៩៧៨ ទំ. ២៥-៣០, ហាត់តែ ប៉ុរ (Hutterer) គ.ស. ១៩៧៧ ទំ. ១៧៨-៧៩, បាកឺរ (Parker) គ.ស. ១៩៧៩ និងអ៊ីនតាកូសៃ(In takosai) គ.ស. ១៩៨៤) ។

រយៈពេលតម្រូវការដ៏ច្រើនដល់កំពូលនៅតំបន់ដីកោះនៅអាស៊ីអាគ្នេយ៍នេះមិនមែនមានមកតែពីប្រទេសចិននោះទេ ។ នៅចុងសតវត្សទី ១៣ សមាមាត្រនៃពរ័សឺឡែន (ភាជន៍ដីខ្សាច់ម៉ត់) កើនឡើងដ៏គួរឲ្យចាប់អារម្មណ៍មួយបានចាប់ផ្ដើមមានមកពីឡដុតផ្នាំប្រើសីតុណ្ហភាពខ្ពស់ថ្មីនៅអាស៊ីអាគ្នេយ៍ នៅក្នុងតំបន់ដីគោកភាគខាងជើង ។ តាមប្រពៃណីថៃ បានអះអាងថាការមកដល់នូវអ្នកជំនាញធ្វើផ្នាំងជនជាតិចិនមួយចំនួន នៅតំបន់ដាក់ឡដែលនៅក្រៅតំបន់ សុខោថៃ (Sukhothai) នៅក្នុងរជ្ជកាល មហាក្សត្ររាំ កំហែង (Ram Kamheng) (ពីគ.ស. ១២៩២ ដល់ ១២៩៧) បានធ្វើឲ្យពួកធ្វើផ្នាំក្នុងស្រុកអាចផលិតថ្នាំលាបកុលាលភាជន៍ល្អៗបានសម្រាប់នាំចេញ (ស្ពីងស៍ Spinks គ.ស. ១៩៦៥ទំ. ១៤-១៧) ។ ប៉ុន្តែ ឡដុតផ្នាំងចំនួនរាប់រយដែលមានអាយុកាលនៅសតវត្សទី ១០ ត្រូវបានគេរកឃើញនៅតំបន់ស៊ី សាត់ចាណាឡៃ (Si Satchanalai) ភាគខាងជើងនៃសុខោថៃ ហើយអាចបញ្ជាក់ឲ្យកាន់តែច្បាស់ថាផលិតផលរបស់ថៃអស្ចារ្យយូមកហើយ មុនពេលការទទួលឥទ្ធិពលរបស់ចិនទៅទៀត (ហេន (Hein) គ.ស. ១៩៨៥) ។ នៅក្នុងសតវត្សទី ១៤ និង ១៥ ថ្នាំពណ៌ប្រផេះស្រាលល្អៗត្រូវបានគេនាំចេញពី ស៊ី សាត់ចាណាឡៃ និងសុខោថៃ ដែលប្រជែងជាមួយនឹងថ្នាំល្បីៗរបស់ខេត្ត ស្ស៊ីចៀង (Zhejiang) នៅ ឡុងក្វាន់ (Longquan) នៃប្រទេសចិន ។ ផ្ទុយទៅវិញខេនឌី (kendis) ដែលមានរូបពណ៌តែមួយរបស់ថៃ ដូចជា ចានគម្រប និងវត្ថុផ្សេងៗទៀតសម្រាប់ទីផ្សារនៅអាស៊ីអាគ្នេយ៍ មានភាពខុសប្លែកគេទាំងក្បាច់រចនា និងពណ៌ ។

ផលិតផលកុលាលភាជន៍របស់វៀតណាម មានប្រើបច្ចេកទេសខ្ពស់ដូចរបស់ចិនដែរ យ៉ាងហោចណាស់ក៏តាំងពីការគ្រប់គ្រងរបស់រជ្ជកាល ហាន មាននៅប្រទេសវៀតណាមនោះដែរ ។ ប៉ុន្តែ ទាល់តែដល់សតវត្សទី ១៤ ទើបប្រទេសវៀតណាមមានវត្តមានចូលមកក្នុងពាណិជ្ជកម្មនាំចេញ ទៅកាន់ប្រទេសជប៉ុន និងបណ្ដាកោះនៃអាស៊ីអាគ្នេយ៍ ។ រយៈពេលដែលមានការកែច្នៃខ្លាំងជាងគេសម្រាប់ឡរបស់វៀតណាមនៅហាន់ណូយ និងនៅធាញ់-ហួនោះគឺនៅសតវត្សទី ១៤ និងទី ១៥ នៅពេលដែលពណ៌ខ្មៅចេញពីដែក និងពណ៌ខៀវចេញពីលោហៈម្យ៉ាងត្រូវបានគេប្រើដើម្បីបង្កើតក្បាច់រចនាសម្រាប់ផលិតផលប្រភេទស្តើងប្រើដៃធ្លាក់ ។ នៅកំលុងចុងសតវត្សទី ១៥ ការប្រឹងប្រែងដើម្បីផ្គត់ផ្គង់ដល់ទីផ្សារអាស៊ីអាគ្នេយ៍បានទម្លាប់ទៅនឹងទំនិញរបស់ចិនរួចទៅហើយដែលធ្វើឲ្យមានភាពកាន់តែងាយស្រួលដល់រចនាក្បាច់របស់ចិន (ហ្គាយ អុយ គ.ស. ១៩៨៦) ។

ពីសតវត្សទី ១៥ ទៅដល់សតវត្សទី ១៧ កុលាលភាជន៍របស់វៀតណាម និងថៃ គ្រប់ដណ្ដប់ភាគច្រើននៃពាណិជ្ជកម្មអាស៊ីអាគ្នេយ៍ ដោយផ្គត់ផ្គង់សមាមាត្រសំខាន់នៃទីផ្សារដោយទំនិញនាំចូលមានគុណភាពខ្ពស់ ។ ព័ត៌មានស្ដីអំពីទំហំពាណិជ្ជកម្មនេះ គឺបានមកពីមតិយោបល់របស់ ដាំពែរ នៅចុងសតវត្សទី ១៧ ដែលពាណិជ្ជកររអង់គ្លេសម្នាក់បានទិញ «ចំណែកល្អៗនៃចានថោកៗចំនួន ១០០.០០០» នៅក្នុង ថាង-ឡុង (ហាន់នូយ (Hanoi) ) ដោយលក់

ទំនិញនោះភាគច្រើនទៅវិញនៅ ស៊ូម៉ាត្រាខាងលិច ដោយបានប្រាក់ចំណេញយ៉ាងច្រើន (ដាំពែរ គ.ស. ១៦៩៩ ទំ. ៤៨) ។ការជីករុករកកំហើញនៅតំបន់កប់ខ្មោចនៅប្រទេសហ្វីលីពីន និងភាគខាងកើតនៃឥណ្ឌូណេស៊ី នាពេលថ្មីៗនេះ បានបង្ហាញអំពីសមាមាត្រដ៏ក្រាស់ក្រៃនៃទំនិញរបស់វៀតណាម និងថៃ ដែលទំនិញថៃមានប្រជាប្រិយជាពិសេសនៅតំបន់ភាគខាងត្បូងយ៉ាងឆ្ងាយ ។ ក្នុងចំណោមរបកគំហើញចំនួន ១៤ ពាន់ ដែលបែងចែកដោយក្រុមសេវាកម្មវត្ថុបុរាណរបស់ស៊ូឡាវេស៊ី ពី គ.ស. ១៩៧៣–៧៧ មាន ២១% ជាទំនិញរបស់ថៃ និង៦% ជារបស់វៀត-ណាម និង២៦%ជារបស់សម័យម៉ីង (Ming) ២៨% របស់ «ស្វាតាវ (Swatow)» និងតិចជាង ១% ជារបស់ យួន (Yuan) (ហាឌីមូលចូណូ (Hadimuljono) និង ម៉ែកណែត៍ (Mack) និងហត គ.ស. ១៩៨៣ ទំ. ៧៧) ។ នៅក្នុងសតវត្សទី ១៥ នៅឯតំបន់កាតាលាហ្គាន ជាតាលាងាន នៅភាគខាងត្បូងនៃ លូសុន ប្រមាណជា១៧%នៃកុលាលភាជន៍នាំចូលត្រូវបានគេរកឃើញនៅក្នុងដីថាជារបស់ថៃ និង២%ជារបស់វៀតណាម (ហ្វកស៍ គ.ស. ១៩៥៩ ទំ. ៣៦១)។

## ការផលិតលោហៈ ដែលជាគន្លឹះនៃអំណាច

> ដែកនេះជារបស់ រ៉ាចា្យ ចែ្យជ្យឌុង Raja Jegedong ដែលអាចជត់ដែកធ្វើឲ្យនៅឋិតថេរបានយូរ ឲ្យស្វិត និងស្រួចបាន ។ ដែកនេះជារបស់ រ៉ាចា្យ ចែ្យជ្យឌុង ដែលជាបង្កើតអក្សរ និងអ្នកអានត្រីវិស័យ។
>
> —Iban Knife-sharpening chant, in Harrisson and O'Connor ១៩៦៩ : ៨០

ការងារធ្វើលោហៈ គឺជាការបង្កើតអំណាច ពីព្រោះឧបករណ៍លោហៈត្រូវគេយកមកប្រើប្រាស់ជាបឋមសម្រាប់ធ្វើសង្គ្រាម និងរួចមកសម្រាប់កសិកម្ម ។ លោហធាតុ ជាពិសេសដែក ត្រូវបានគេចាត់ទុកថាជាតំណាងឲ្យកម្លាំងនឹងសុចរិត ។ ទម្លាប់ទាំងនោះដែលមានន័យថាភាពអមតៈ ឬរៀងរហូតនោះ តែងតែមានវត្ថុធ្វើពីលោហៈដែលសារៈសំខាន់របស់លោហៈនោះជ្រៀបចូលទៅក្នុងខ្លួនអ្នកប្រយុទ្ធ (ធ្វើសង្គ្រាម) ដើម្បីឲ្យគាត់ខ្លាំងក្លា (អែនឌីកូត - Endicott) គ.ស. ១៩៧០ ទំ. ១៣៣–៣៤, ហ្វស៍ស៍ គ.ស. ១៩៨១ ទំ. ១២៥–២៧ និងហ៊ីកគី (Hickey) គ.ស. ១៩៨២ ទំ. ១៣២–៣៥) ។ ទោះបីជាជាងដែកមានឋានៈទាបស្មើនឹងពលករហត្ថកម្មដទៃទៀតនៅគ្រប់ទីកន្លែងក៏ដោយ ក៏មានកម្លាំងពិសេសសក្តិសិទ្ធិអំពីពួកគេផងដែរ ។ ផ្ទះសំបែងដែលមានអំណាចដ៏អស្ចារ្យ ហៅថា ណាត នាត របស់ជនជាតិភូមិថ្នាក់លើ គឺជាវិញ្ញាណរបស់ជាងដែកដ៏មានអំណាចម្នាក់ដែលត្រូវសម្លាប់ដោយស្តេចមួយអង្គដោយមានសេចក្តីច្រណែន (ណាស្ស (Nash) គ.ស. ១៩៦៥ ទំ. ១៦៩) ។ ជាងដែកតែងតែជាបុរស ដោយមានជំនាញទទួលពីក្រុមគ្រួសារនិងភូមិជាក់លាក់ណាមួយ ។ ពាក្យថា បីតាជាងដែក ដូចជាពាក្យ ប៉ានដេ (pande) នៅក្នុងភាសាជ្វា និងបាលី ពាក្យប៉ានដាយ (pandai) នៅក្នុងភាសាម៉ាឡេ ពាក្យ ប៉ាន ឬ panre នៅក្នុងភាសាប៊ូហ្គីស បានយកមកប្រើប្រាស់ដែលមានន័យថាចំណេះដឹងជ្រៅជ្រះនៅក្នុងសិល្បៈ ឬវិទ្យាសាស្ត្រណាមួយក្តី ។

ការងារធ្វើលោហៈជានិច្ចកាលមានតួនាទីក្នុងការបង្កើតរដ្ឋ ។ នៅក្នុងប្រពៃណីជ្វា ការបែងចែកកោះរវាងព្រះរាជាណាចក្រ ម៉ាច្បាបាហ៊ីត (Majapahit) នៅភាគខាងកើត និងប៉ាច្យាច្យារ៉ាន ភាញាញារាន នៅភាគខាងលិច គឺដោយសារជាងដែកដ៏មានថាមពលពិសេសម្នាក់នៅក្នុងរាជវាំងដែលសម្លាប់ឪពុករបស់គាត់ហើយប្រយុទ្ធជាមួយបងប្រុសរបស់គាត់ (បាបាដ តាណា ច្យាវ៉ា (Babad Tanah Jawa) ទំ. ១៤–១៧ និងរ៉ាហ្វល៍ស៍ គ.ស. ១៨១៧ II ទំ. ៩៧–១០៣) ។ ស្តេចទីពីររបស់ បូន ពៀនរ ដែលដឹកនាំរដ្ឋប៊ូហ្គីស នៃស៊ូឡាវេសុ មានឈ្មោះថា ប៉េតា បានរឺ បេស៊ី (Petta Panre Bessi)

ឬក៏«ស្តេចរបស់ពួកយើង គឺជាជាងដែក«(ស៊ូឡៃម៉ង់ (Sulaiman) គ.ស.១៩៧៩ ទំ. ៥៤) ។ នៅតំបន់វិស័យយ៉ាសជាទីកន្លែងដែលព្រះអាធិបតេយភាពកំពុងតែមានប្រជាប្រិយភាពនៅក្នុងសតវត្សទី ១៦ នោះ ពួកជាងដែកត្រូវបានគេយកមករាជធានីដើម្បីឲ្យប្រាកដថាអំណាចរបស់ព្រះរាជវង្សនៅឋិតថេរ ។ ភូមិ និងតំបន់នៅជាយក្រុងដែលមានជំនាញធ្វើលោហៈ និងស្ថិននៅក្រោមការគ្រប់គ្រងរបស់រាជវង្ស គឺជាលក្ខណៈនៃរដ្ឋធំមួយ ។

ដែក ទង់ដែង សំណប៉ាហាំង ដែកនីកែល និងសំណ សុទ្ធតែមានយ៉ាងសម្បូរហូរហៀរនៅអាស៊ីអាគ្នេយ៍ (សូមមើលផែនទី៤) ទោះជាពុំសូវអាចរកបាននៅតំបន់សំខាន់ៗនៃប្រជាជនរស់នៅដូចជាជ្វា បាលី និងតំបន់លិចទឹកនៃចៅប្រាយ៉ា និងមេគង្គ ។ ទោះជាយ៉ាងណាក៏ដោយ បច្ចេកវិទ្យាជីកយករ៉ែ ពិនិត្យមើលដីក្រែងមានរ៉ែ ស្ងួចំរាញ់ និងរំលាយដែកមានការអភិវឌ្ឍតិចជាងនៅប្រទេសចិន ឬនៅអឺរ៉ុប ។ យុទ្ធសាស្ត្រប្រើកម្លាំងកម្មករច្រើនដែលធ្វើការរំលាយរ៉ែដែលមានគុណភាពទាបឲ្យអាចយកមកប្រើប្រាស់បាន ធ្វើឲ្យលោហៈនៅអាស៊ីអាគ្នេយ៍នៅតែមានតម្លៃខ្ពស់ និងមានតម្លៃដដែល បើប្រៀបធៀបទៅនឹងទំនិញនាំចូលមកពីចិន ជប៉ុន ឬអឺរ៉ុប ។ ដូច្នេះហើយ អាស៊ីអាគ្នេយ៍ គឺជាអ្នកនាំចូលធំនូវពាល់លោហៈសម្រាប់ឧស្សាហកម្ម លើកលែងតែសំណប៉ាហាំង ដែលជាលោហធាតុងាយនឹងផលិត និងដែលអាចជីករកបាននៅឧបទ្វីបម៉ាឡេ ហើយធ្វើការនាំចេញទៅបានយ៉ាងងាយយ៉ាងហោចណាស់ដល់ប្រទេសឥណ្ឌាដែរ ។

ជាងលោហៈដែលអាចកែច្នៃទង់ដែង ឬដែកទៅជាឧបករណ៍មានប្រយោជន៍នោះ មានពាសពេញគ្រប់ទីកន្លែង ហើយវត្ថុធាតុដើមតែងតែមានតម្រូវការខ្ពស់ដើម្បីផ្គត់ផ្គង់ពួកគេ ។ នៅពេលដែលពួកហូឡង់ផុតកប៉ាល់របស់ពួកគេមួយនៅបាវៀន (Bawean) ស្ថិតនៅភាគឦសាននៃកោះជ្វា នៅគ.ស.១៥៩៧ នោះមានទូកកប៉ាល់ជាច្រើនមកពីគ្រប់ទិសទីដើម្បីសង្គ្រោះយកដែកពីកប៉ាល់កំពុងតែឆេះនោះ (លូដូវីស្គស៍ គ.ស.១៥៩៨ ទំ. ១៧៨) ។ នៅពេលដែលពួកអេស្ប៉ាញត្រូវផុតកប៉ាល់មួយរបស់ពួកគេនៅមីដានាវ ពួកគេបានយកចេញឲ្យអស់នូវនុកទ្វា ខ្ទៅ និងដែកគោល ដើម្បីការពារកុំឲ្យលោហៈទាំងនេះធ្លាក់ក្នុងដៃពួកមូស្លីមដែលជាសត្រូវរបស់ពួកគេ (ម័រហ្គា (Morga) គ.ស.១៦០៩ ទំ. ២៣៣)។ ពួកពាណិជ្ជករអឺរ៉ុបជំនាន់ក្រោយមកបានដឹងថា ដែក សំណ ទង់ដែង និងផលិតផលដែលធ្វើអំពីលោហធាតុទាំងនេះ ស្ថិតនៅក្នុងចំណោមប្រភេទទំនិញអឺរ៉ុបមួយក្តាប់តូចដែលអាចលក់បាន ។

## ដែក

ផ្ទះ និងទូកនៅអាស៊ីអាគ្នេយ៍សុទ្ធតែមិនប្រើដែក ដែលជាសញ្ញាមួយបង្ហាញពីភាពមានតម្លៃរបស់ដែក ។ គេត្រូវការពួកជាងដែកជាបឋមឲ្យផលិតឧបករណ៍សំខាន់ៗសម្រាប់សង្គ្រាម និងកសិកម្មដូចជាធ្មេញនង្គ័ល កន្តៀវ ចបកាប់ ទំពក់សន្ទូច កាំបិតផ្គាក់ ដាវ ផ្លែលំពែង និងកាំបិតស្នៀតមុខពីដំល្បីរបស់អាណាចក្រម៉ាឡេ ។ ផ្សារធំៗភាគច្រើនសុទ្ធតែមានផ្នែកមួយសម្រាប់ដាក់លក់ឧបករណ៍ទាំងនេះ ដែលមានសារៈសំខាន់សម្រាប់ផ្ទះសំបែង ។ នៅតាមភូមិឆ្ងាយៗភូមិនៅតាមភ្នំដែលការប្រាស្រ័យទាក់ទងគ្នាមានការលំបាក ហើយចំបាំងក្នុងតំបន់កើតឡើងជាញឹកញាប់នោះ ភូមិធំៗនឹងឲ្យជាងដែករបស់ខ្លួនផលិតឧបករណ៍បែបទាំងនេះ ។ នៅតាមជ្រលងភ្នំ និងទីក្រុងនៅតាមដងទន្លេវិញ ផលិតកម្មប្រភេទនេះគឺធ្វើឡើងនៅតាមភូមិជាក់លាក់ណាមួយ ឬនៅតាមតំបន់ក្រុងដែលអាចលក់ផលិតផលរបស់ពួកគេនោះទៅឲ្យទីផ្សារដែលនៅចម្ងាយរាប់រយគីឡូម៉ែត្រពីនោះ ។

ប្រទេសភូមា សៀម កម្ពុជា វៀតណាមខាងជើង និងតំបន់កណ្តាលនៃស៊ូម៉ាត្រា ហាក់ដូចជាមានសម្រាប់


Iron
Tin
Copper
Naptha (petroleum)
Lead
BURMA
Yenangyaung
Irrawaddy
Pegu
Kamphaengphet
Tavoy
Phuket
Chao phraya
Uttaradit
LAOS
Ayutthaya
Nakhon Sithammarat
Patani
CAMBODIA
Mekong
VIETNAM
Thang-long (Hanoi)
Aceh
Meuke
SUMATRA
Minangkabau
Padang Luar
Melaka
Selangor
Priangan
Banten
BANGKA
BELITON
Karimata
JAVA
Gresik
Kapuas
BORNEO
Brunei
LUZON
Igorots
Manila
Makassar
Luwu
SULAWESI
Banggai
Tobungku
Ternate
MINDANAO
NEW GUINEA

ប្រទេសខ្លួននីមួយៗនូវដែកយ៉ាងគ្រប់គ្រាន់ ទោះបីជាគេឃើញមានការស្វាគមន៍ចំពោះការនាំចូលផលិតផលថោកៗមកពីចិន និងភាគខាងជើងនៃអឺរ៉ុបក៏ដោយ ។ សៀមក៏នាំចេញដែកមួយចំនួនទៅកាន់ប្រទេសហ្វីលីពីនផងដែរ នៅទសវត្សឆ្នាំ ១៦៧០ (វាយត៍ (White)គ.ស. ១៦៧៨ ទំ. ៤២៤) ។ ហាក់ដូចជាមានការហាមប្រាមទៅលើការរំលាយលោហៈចំពោះអ្នកណាដែលរស់នៅក្បែរតំបន់រ៉ែដែលអាចយកមកធ្វើការបាន ជាទូទៅ គឺពួកអ្នករស់នៅតាមជងភ្នំ ដែលជាពួកមិនទាន់មានវប្បធម៌សម្រាប់ការសរសេរនៅឡើយ ។ ជាតួយ៉ាង ដែកនៅអង្គរ និងកម្ពុជា ប្រហែលជាផលិតឡើងដោយពួកជនជាតិភាគតិច «គួយ» ដែលរស់នៅតាមជួរភ្នំដែលសម្បូរទៅដោយរ៉ែដែក ដែលតំបន់នោះជាប់ព្រំប្រទល់ជាមួយនឹងប្រទេសឡាវ នៅភាគខាងជើង (ហ្វ្រេដរីក គ.ស. ១៩៨១ ទំ. ១៦១) ។ ពួកភូមា និងពួកសៀមជាបឋមជីកយករ៉ែដែករបស់ពួកគេចេញពីតំបន់ជួរភ្នំនៅជិតព្រំប្រទល់របស់ពួកគេ ហើយយកមកចម្រាញ់នៅភូមិជំនាញក្បែរ ក្រំ (Prome) និងតាវួយ (Tavoy) នៅភូមា និងនៅក្បែរកំពុងភែត (Kampongphet) និងសុខោថៃ (Sukhotha) នៅសៀម (សាងហ្គឺម៉ាណូ គ.ស. ១៨១៨ ទំ. ២០៥, កុកស៍ គ.ស. ១៨២១ ទំ. ២៩, ឡា លូប៊ែរ គ.ស. ១៦៩១ ទំ. ១៤ និងស៊ូជិតា (Suchitta) គ.ស. ១៩៨៣ ទំ. ១៨) ។ ក៏មានការជីកយករ៉ែដែកនៅតំបន់ ឡំប៊ូរី (Lopburi) ដែរដែលមិននៅឆ្ងាយពីភាគខាងជើងនៃរាជធានីអយុធ្យា នៃប្រទេសថៃ នោះទេ ខណៈពេលដែលរ៉ែដែកជាប់ជ័យលាភីខាងយកមកធ្វើដាវ ដែលមានជាតិដែកម៉ង់ហ្គាណែហ្ស (Manganese) ធ្វើឲ្យរឹងមាំនោះ គឺត្រូវបានគេជីកយកមកនៅក្នុងតំបន់ អ៊ុតារ៉ាឌីត (Uttaradit) នៅភាគខាងជើងនៃសុខោថៃ (សូជីតា គ.ស. ១៩៨៣ ទំ. ១៦-១៨)។

នៅស៊ូម៉ាត្រា ហាក់ដូចជាមានការជីកយករ៉ែដែកភ្នំ (ហៅថា ហ្គូនូង បេស៊ី (Gunung Besi) ) នៅតំបន់មីុណាំងកាប៊ូ (Minangkabau) អស់រយៈពេលរាប់សតវត្សរួចមកហើយ មុនពេលដែលមានការពណ៌នាអំពីឧស្សាហកម្មរ៉ែដែកដែលផ្អែកលើដែកប្រភេទនេះ នៅក្នុងឯកសាររបស់ ម៉ាសដែន នៅចុងសតវត្សទី ១៨ នោះ ។ ទម្រាំដល់ពេលនោះ ឈើដែលអាចយកមកដុតធ្វើធ្យូង ដើម្បីដំណើរការរំលាយរ៉ែដែកនោះបានអស់ទៅហើយ ដែលតម្រូវឲ្យមានការផ្លាស់ទីក្នុងរយៈមួយថ្ងៃទៅកាន់ សាលីមពូង (Salimpaung) (ឌូបប៊ីន (Dobbin) គ.ស. ១៩៧៤ ទំ. ៣៣០-៣៣)។ ម៉ាសដែន (គ.ស. ១៧៨៣ ទំ. ៣៤៧) ទទួលស្គាល់ថា ពួកជំនាញអាជីពនៅមីុណាំងកាប៊ូ ពិតជា «បានផលិតអាវុធសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងលក់ឲ្យពួកអ្នកស្រុកនៅភាគខាងជើងនៃកោះ តាំងពីដើមមកម្ល៉េះ» ។ នៅភាគខាងត្បូងឆ្ងាយទៅទៀតនៅបែលីតង់ (Beliton) និងបាំងកា (Bangka) សុទ្ធតែនាំចេញដែក និងឧបករណ៍ធ្វើពីដែក តាមរយៈអ្នកដឹកនាំរបស់ពួកគេនៅបាលែមបាំង (Palembang) (ពែរស៍ គ.ស. ១៥១៥ ទំ. ១៥៦-៥៧, ស្ទៀលម៉ង់ គ.ស. ១៦៧០ ទំ. ១១៣ តែសូមអានឯកសាររបស់ ក្រូលហ្វ៊ដ គ.ស. ១៨២០ ទំ. ៤៨៩ និងខ្វ័ត គ.ស. ១៨២១ ទំ. ១៣៦ និង ១៦០)។

តំបន់ដីកោះនៅភាគខាងកើតផ្តល់ឲ្យនូវបញ្ហារឹតតែគួរឲ្យចាប់អារម្មណ៍ជាងនេះទៅទៀត ដែលថាពាណិជ្ជកម្មរ៉ែដែក និងការធ្វើដែកតាមផ្លូវទឹកដ៏សន្ធឹកសន្ធាប់ ត្រូវតែបំពេញតម្រូវការឲ្យតំបន់ជាច្រើនដែលមិនមានអំណោយផលតាមធម្មជាតិ ។ កំណត់ត្រានាសតវត្សទី ១៧ របស់ប្រទេសហ្វីលីពីន បង្ហាញថាមានការទាមទារថា ពួកជាងដែកនៅលូស្សុន និងនៅតំបន់វីស័យយ៉ាស ត្រូវតែពឹងផ្អែកទៅលើការដែកនាំចូលមកពីប្រទេសចិន (អាល់ស៊ីណា គ.ស. ១៦៦៨III ទំ. ១០៤, ស្កត់ គ.ស. ១៩៨២ ទំ. ៥៣២ និងសាន់ដេ គ.ស. ១៥៧៦ទំ. ៧៤) ទោះបីជាសំណល់សល់ពីការដុតរំលាយរ៉ែដែកនៅសេប៊ូ (Cebu) និងកន្លែងផងទៃទៀត បង្ហាញថា មានការរំលាយរ៉ែប្រភេទដីក្រហមក្នុងស្រុកនៅមុនពេលនោះក៏ដោយ (ហាត់តែរ៉ឺ (Hutterer) គ.ស. ១៩៧៣ ទំ. ៣៧ និងហារីសាន់ (Harrisson) និងអូ កុងណ័រ (O'Connor) គ.ស. ១៩៦៩ ទំ. ៣១៥) ។ បច្ចេកវិទ្យានៃការរំលាយរ៉ែទាំងនេះដោយដុតរោលដោយធ្យូង

ហាក់ដូចជាមាននៅពាសពេញគ្រប់ទីកន្លែង ដែលមានន័យថាមានតែដែករបស់ចិនដែលមានតម្លៃថោក និងគុណភាពល្អនោះទេដែលអាចជំនួសរ៉ែដែកទាំងនេះបាន ។ នៅតំបន់ខ្ពង់រាប លូស្សុន ខ័រឌីឡេរ៉ា (Luzon Cordillera) ដែលនៅឆ្ងាយដាច់នេះ មានការរាយការណ៍នៃការរំលាយដែកដោយអ្នកធ្វើដំណើរម្នាក់ដែលបានចូលមកដល់សតវត្សទី ១៩ ដែរ (ម៉ៃយើរ (Meyer) គ.ស.១៨៩០ ទំ. ៦៣) ។

ផ្ទាមានឈ្មោះល្បីទៅលើការដោរផលិតដែកដ៏ស្អាតរបស់ខ្លួន ហើយកូនកាំបិតខ្វៃមុខពីរនិងដាវរបស់កោះនេះត្រូវបានគេនាំចេញបានទៅយ៉ាងឆ្ងាយរហូតដល់ប្រទេសឥណ្ឌា (ពៃរេស៍ គ.ស.១៥១៥ ទំ. ៩៣ និង ១៧៩) ។ ទោះបីជាទំនាក់ទំនងជាប្រភេទព្រេងនិទាននៃព្រះរាជាណាចក្រផ្ទាខាងលិចនៃបុរេ គ.ស.១៥០០ នៅប៉ាច្យាច្យាប៉ាំនជាមួយនឹងជាងធ្វើដែក ហាក់ដូចជាមានន័យថាមានការប្រើប្រាស់រ៉ែទីតានាម (Titanium) នៃតំបន់ភ្នំនៅផ្ទាភាគនិរតីក៏ពិតមែន ក៏មិនមានភស្តុតាងអ្វីបញ្ជាក់ថាឧស្សាហកម្មផលិតកូនកាំបិតខ្វៃមុខពីរនៃតំបន់ម៉ាច្យាប៉ាហ៊ិត ឬក៏ការដោរធ្វើដែកឯទៀតរបស់ជនជាតិផ្ទានោះ យកវត្ថុធាតុដើមរបស់ខ្លួននៅក្នុងស្រុកនោះដែរ ។ ប៉័រណេអូ និងស៊ូឡាវេស៊ីស្ទើរតែផ្តល់ឲ្យកោះផ្ទានូវរ៉ែដែករបស់ខ្លួនស្ទើរតែទាំងអស់ទៅហើយ ។

ប្រភពដែលអាចយករ៉ែដែកសម្បូរនូវជាតិនីកែលបានមកប្រើប្រាស់នៅក្នុងការផលិតកូនកាំបិតខ្វៃមុខពីរស្រោបថ្នាំនៃម៉ាច្យាប៉ាហ៊ិត គឺមកពីស៊ូឡាវេស៊ីកណ្តាល ។ រ៉ែដែកនៅដីក្រហមដែលមានជាតិដែករហូតដល់ទៅ ៥០% និងជាតិនីកែលសំខាន់ដែរនោះ ត្រូវបានគេរកឃើញនៅជៀបនឹងផ្ទៃដី ដែលគួរឲ្យកត់សម្គាល់នោះគឺនៅបឹងម៉ាតាណូ (Lake Matano) និងនៅតំបន់ទន្លេកាឡេណា (Kalaena River) (គ្រូអ៊ីថ (Kruijt) គ.ស.១៩០១ ទំ. ១៤៩–៥០) ។ គេអាចនាំចេញរ៉ែដែកស៊ូឡាវេស៊ី តាមរយៈឈូងសមុទ្ររបស់ បូន ដែលត្រួតត្រាដោយអាណាចក្រស្តេចលូវូ (Luwu) ឬក៏នាំចេញតាមឆ្នេរខាងកើតនៃស៊ូឡាវេស៊ី គ្រប់គ្រងដោយអាណាចក្រស្តេច បាំងហ្គៃ (Ba nggai) នៅសតវត្សទី១៦ និងមុននោះ (ម៉ាស្ការ៉េនហាស (Mascarenhas) គ.ស.១៣៦៤ ទំ. ៤៣៣–៣៤)។ ទាំង បាំងហ្គៃ និងលូវូ ត្រូវលើកឡើងនៅក្នុងឯកសារ នាហ្គារ៉ា–កែតាហ្គាម៉ា (គ.ស.១៣៦៥ ទំ. ១៧) ថាជាបរិវាររបស់ ម៉ាច្យាប៉ាហ៊ិតដែលនេះហាក់មានន័យថា ការនាំចេញរ៉ែដែករបស់ពួកគេអាចមានសារៈសំខាន់ ។ នៅក្នុងសតវត្សទី ១៦ ព្រះរាជាណាចក្រខាងនាំចេញគ្រឿងទេស មូលូកាស ដឹកយករ៉ែដែក និងចម្រាញ់ធ្វើសព្វាវុធរបស់ពួកគេចេញពីប្រភពដូចគ្នានេះដែរ ។ «រ៉ែដែកជាច្រើនបានមកពីខាងក្រៅ ពីកោះនៃបាំងហ្គៃ មានដូចជាដុំថៅដែក កាំបិតតាំងតោ ដាវ និងកាំបិត» (ពៃរេស៍ គ.ស.១៥១៥ ទំ. ២១៥–១៦ តែសូមអានប្រៀបធៀបឯកសាររបស់ បាបូសា (Barbosa) គ.ស.១៥១៨ II ទំ. ២០៥) ។ មកទល់ចុងសតវត្សនេះកំពុងផែសំខាន់ៗនៃស៊ូឡាវេស៊ី ភាគខាងកើត ត្រូវគ្រប់គ្រងជាលក្ខណៈនយោបាយដោយ តែណាត (Ternate) ។ បាំងហ្គៃពានផងដែរ បានក្លាយទៅជាតំបន់មួយក្នុងចំណោមតំបន់ទាំងនេះហើយ ទូបូងកូ (Tobungku) ដែលជាទីផ្សារផ្ទាល់សម្រាប់រ៉ែដែកដឹកយកពីបឹងម៉ាតាណា ឥឡូវនោះបានក្លាយជាតំបន់សំខាន់ដាងនេះទៅទៀត ។ ទូបូងកូ បាននាំចេញដាវ និងលំពែងដ៏មានឈ្មោះល្បីរបស់ខ្លួនទៅឲ្យតែនាត និងម៉ាកាសារធ្វើជាសាអាករ និងទៅពាសពេញឥណ្ឌូនេស៊ីភាគខាងកើត (ស្តៀលម៉ង់ គ.ស.១៦៧០ ទំ. ១០៣–០៤, ស្តាប់ប៉ែល (Stapel) គ.ស.១៩២២ ទំ. ៥–៦ និង ទូប្យ៉ាស់ (Tobias) គ.ស.១៨៥៧ ទំ. ២៤) ។

លូវូអាចដើរតួជាតំបន់រំលាយដែកសម្រាប់ ព្រះរាជាធិបតេយ្យគាពររបស់ ប៊ូហ្គីស (នៅកំលុងសតវត្សទី ១៤) ដែលដែកទាំងនោះយកមកពីពួកប្រជាជនរស់នៅតាមជងភ្នំដែលពួកនោះដឹករកដែកលក់ឲ្យទៅពួកផ្ទា និងពួកពាណិជ្ជករដទៃទៀត ។ នៅពាក់កណ្តាលសតវត្សទី១៧ «ដែកលូវូ» នៅតែជាទំនិញនាំចេញធំមួយពី ម៉ាកាសារ

ទៅផ្នាភាគខាងកើត (ស្តៀលម៉ង់ គ.ស. ១៦៧០A ទំ. III)។ នៅពេលនោះ មានដែកមានតម្លៃថោកមកពីចិន និងពីអឺរ៉ុប ប៉ុន្តែពួកអ្នកផលិតកូនកាំបិតខ្វីនៅជ្វា ហាក់ដូចជានៅមានការពេញចិត្តប្រើប្រាស់ដែកស៊ូឡាវេស៊ី ដែលសម្បូរទៅដោយជាតិនីកែល ដើម្បីពួកគេអាចផលិតបាននូវរចនាក្បាច់រលក (ដែលហៅថា ប៉ាម័រ (pamor)) នៅលើផ្ទៃកាំបិតរបស់ពួកគេ ។ សូម្បីតែមកទល់ គ.ស.១៨០០ ដែកបានពីស៊ូឡាវេស៊ីកណ្តាលនេះ នៅតែត្រូវការពីពួកអ្នកផលិតកូនកាំបិតខ្វីមុខពីរនៅប៊័រណេអូខាងត្បូង ដែលពួកគាត់ត្រូវការយកដែកប្រភេទនេះបញ្ចូលរួមជាមួយ «ដែកសុទ្ធ» នាំចូលមានតម្លៃថោកជាងនេះ ដើម្បីឲ្យជាតិនីកែល ធ្វើឲ្យចេញក្បាច់រចនារលកបាន (ម៉ាសស្សល (Marschall) គ.ស. ១៩៦៨ ទំ. ១៣៨) ។

ការនាំចេញដែករបស់ ប៊័រណេអូ រឹតតែមិនសូវមានពត៌មានអំពីនេះឡើយ ដែលនៅតំបន់នេះ គឺជាប្រភពនៃរ៉ែនៅដីរាក់ៗមានគុណភាពទាប នៅក្នុងតំបន់ដីកោះ ។ គុណភាពរបស់សំណល់ក្រោយពីការស្លដែកនៃសតវត្សពីទី១០ ទៅទី ១៤ នៅដីសណ្តទន្លេ សារ៉ាវ៉ាក់ នៃប៊័រណេអូភាគខាងជើង ដែលប៉ាន់ស្មានដោយ ហារីសាន់ និងអូ កង់ណរ័ (គ.ស.១៩៦៩ ទំ. ៣៨៥) ថាមានទំហំ ៤០.០០០ តោន ធ្វើឲ្យគេច្បាស់ថាប្រភពដ៏ធំមួយនៃការនាំចេញដែកគឺស្ថិតនៅទីនោះ នាសម័យកាលនោះ ។ តំបន់នេះប្រហែលជាអាចផ្គត់ផ្គង់ជាងដែកនៃតំបន់ភាគខាងកើតនៃឧបទ្វីបម៉ាឡេ នៅស៊ូម៉ាត្រាខាងត្បូង និងនៅជ្វាខាងលិច បានយ៉ាងគ្រប់គ្រាន់ ។ ប៉ុន្តែនៅកំលុងគ.ស. ១៦០០ តំបន់នាំចេញដ៏ធំមួយនៅប៊័រណេអូ គឺជាកោះនៃការីម៉ាតា (Karimata) ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជាណាចក្រដ៏តូចមួយរបស់ សូកាដាណា (Sukadana) នៅប៊័រណេអូភាគនារតី ។ ពួកម៉ាឡេ នៅតំបន់ម៉ាឡាកា មានពាក់កូនកាំបិតមុខពីរដែលធ្វើអំពី «ដែកថែប ការីម៉ាតា» (អេរ៉េដៀ គ.ស. ១៦០០ ទំ. ២៣២) ។ បានតង់ ក្លាយជាផែដ៏អស្ចារ្យជាងគេនៅជ្វា បាននាំចូលនូវ «ដែកមានចំនួនច្រើនពី ការីម៉ាតា» (លូដូវីស្គស៍ គ.ស. ១៥៩៨ ទំ. ១១៩) ។ ពួកហូឡង់បន្ទាប់មកចាត់ទុកថាពូថៅ និងប៉ារ៉ាង្ស (parangs) (ដែលជាកាំបិតធ្ងន់) ជា «លក្ខណៈសម្បត្តិរបស់ បុរសសាមញ្ញ» (វឹហូវេន (Verhoeven) គ.ស. ១៦០៩ ទំ. ១០៥) ។ កងនាវាពួកជ្វា ដែលកាន់កាប់ ស៊ូកាដាណា (Sukadana) នៅគ.ស. ១៦២២ ដែលជាតំបន់ពាណិជ្ជកម្មតែមួយគត់របស់ ម៉ាតារ៉ាមរំតាពាម នៅក្រៅជ្វា ប្រាកដជាមានបំណងថែរក្សាទុកប្រភពដែក និងពេជ្រទាំងនេះ ។ ការកាន់កាប់របស់ ម៉ាតារាម បន្ទាប់មកមានការផ្លូវរលង់វិញ ហើយ ការីម៉ាតា (Karimata) ក៏បាននាំចេញឧបករណ៍លោហៈរបស់ខ្លួនចេញទៅពាសពេញតំបន់ដីកោះសារជាថ្មីម្តងទៀត ។ ពួកហូឡង់បានទិញយកពូថៅ និងកាំបិតធ្ងន់ៗរបស់ ការីម៉ាតា មានចំនួនស្មើតែ ១០.០០០ នៅក្នុងគ.ស. ១៦៣១ (ដាហ-រីជីស្ទ័រ (Dagh-Register) គ.ស. ១៦៣១ ទំ. ២៨ និង ៤៧) និងចំនួន ៨.០០០ នៅគ.ស. ១៦៣៧ ដោយមើលឃើញថាទំនិញទាំងនេះមានសារៈសំខាន់នៅក្នុងពាណិជ្ជកម្មតណ្ឌនេស៊ីក្នុងស្រុក ក៏ដូចជាទៅទីឆ្ងាយរហូតដល់ ទិម័រ (Timor) ផងដែរ (វ៉ាន់ ឌែម៉ង់ (van Diemen) គ.ស. ១៦៣៧ ទំ. ៦២៩) ។ ផ្ទុយទៅនឹងប្រភពផ្គត់ផ្គង់ក្នុងស្រុកនៅស៊ូឡាវេស៊ី កប៉ាល់មកពីម៉ាកសារធ្វើដំណើរជាប្រចាំទៅកាន់ ស៊ូកាដាណា ពីទសវត្សក្រោយមកដើម្បីប្រមូល «ពូថៅ និងកាំបិតធ្ងន់ៗរបស់ ការីម៉ាតា» ។ កប៉ាល់ពីរបីដងដែលនោះក្នុងមួយឆ្នាំៗ នឹងមានពេលខ្លះយកឧបករណ៍លោហៈពីកោះនៃ បែលីតង់ (Beliton) នៅភាគខាងលិចឆ្ងាយជាងនេះទៅទៀត ដែលបានផលិត «កាំបិតធ្ងន់ៗចំនួនច្រើន និងពូថៅចំនួនតិច» ជាជាងយកពី ការីម៉ាតា (Karimata) (ស្តៀលម៉ង់ គ.ស. ១៦៧០ ទំ. ១១៣ ។

ដែកនៅបែលីតង់ ប្រហែលជាត្រូវបានគេជីកយកមកពី ភ្នំសែលូម៉ារ ដែលជាផ្ទាំងថ្មធំដូចដញ្ចាំងផុសចេញពីដីនៃរ៉ែដែកម៉ាញេទិច ដោយមានជាតិសំណប៉ាហាំង ទង់ដែង និងសំណ (វ៉ាន់ បែមម៉ែឡាំង វាន(Bemmeling)

គ.ស.១៩៤៩II ទំ. ២១២) ។ ដូចគ្នានេះដែរ ផលិតផលរបស់ការីម៉ាតា ដ៏ធ្វើចេញពីរ៉ែដែកពណ៌ប្រផេះ ដែលអាចរកបាននៅកោះការីម៉ាតា ផ្ទាល់ដែរ (ម៉ាសស្យល (Marschall) គ.ស.១៩៦៨ ទំ. ២៤៩ និងអេនី ៣ ENI III ទំ. ១៩៦) ទោះជាយ៉ាងណាក៏ដោយ មានតំបន់ជាច្រើនរាប់មិនអស់នៅប៊័រណេអូ ដែលទ្រាប់រ៉ែបានហូរចាក់ស្រះផ្ទៃដី ហើយមួយចំនួននៃស្រទាប់រ៉ែទាំងនោះត្រូវបានគេជីកយករ៉ែប្រើក្នុងស្រុក ។ នៅសតវត្សទី ១៩ គឺប្រជាជននៅតំបន់ខ្ពង់រាបដាច់ស្រយាលនៅប៊័រណេអូ ដែលនៅមានចំណេះដឹងខាងរំលាយលោហៈ ដូចជាពួក កាយ៉ាន់ (Kayans) យេនយ៉ា (Kenyahs) និងពួកដាយ៉ាក់ (Dayak) នៅតំបន់លើនៃទន្លេ បារីតូ (Barito) កាតីងហ្គាន (Katingan) គូតៃ (Kutai) កាយ៉ាន់ (Kayan) រ៉េចាង (Rejang) និងបារ៉ាម (ហារីសាន់ និង អូកង់ណរ័ គ.ស.១៩៦៩ ទំ. ៣៤២-៤៧) ។ ការពណ៌នាដ៏ក្បោះក្បាយបំផុតនោះ មាននៅក្នុងឯកសាររបស់ ស្វាវ៉ាណែរ( Schwaner) (គ.ស.១៨៥៣ ទំ. ១០៩-១៥)ដែលជាអ្នកឃើញនៅក្នុងគ.ស. ១៨៤៧ ថាមានឡសម្រាប់ស្ងួដែកចំនួនប្រមាណជា ១០ ឡ នៅតាមតំបន់ទន្លេ ម៉ងតាឡាត (Mantalat) ដែលជាព្រែកតូចមួយនៃទន្លេ បារីត ហើយឡទាំងនោះអាចផ្គត់ផ្គង់ឲ្យនូវដែកពាសពេញប៊័រណេអូ ភាគអាគ្នេយ៍ ។ រ៉ែដែលប្រើនោះជារ៉ែដីឥដ្ឋយកចេញពីច្រាំងទន្លេ ។ ដោយសារតែតម្លៃថោក និងភាពសម្បូរបែបនៃលោហៈ និងទំនិញលោហៈរបស់ចិន ការជីករករ៉ែ និងការដុតរំលាយរ៉ែនៅអាស៊ីអាគ្នេយ៍មានការថយចុះតាមសម្រួលនៅតំបន់ដីកណ្តាល នៅពេលដែលការប្រាស្រ័យទាក់ទងគ្នាមានការរៀងរលឿន ។ នៅក្នុងរជ្ជកាលសុង (Sung) រ៉ែដែក និងទំនិញដែក គឺជា «ទំនិញពាណិជ្ជកម្មប្រជាប្រិយបំផុតក្នុងចំណោមទំនិញដែលដឹកមកពីប្រទេសចិនទៅទន្លេខាងត្បូង South Seas» (វីតលី (Wheatley) គ.ស.១៩៥៩ ទំ. ១១៧) ហើយបានចូលទៅក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មធំៗ ដូចជា ស្រីវិជ្ជាយ៉ា ។ នៅម៉ាឡាកា នៅកំលុងគ.ស.១៥១០ ទំនិញនាំចូលមកពីប្រទេសចិន រួមមាន «ទង់ដែង ដែក... ចូធ្វើអំពីទង់ដែង និងហ្វូសេលីរ៉ា (fuseleira) កំសៀវដែក ចានក្រលោម ផង់ទឹកប្រអប់ផ្ចិត ម្ជុលរាប់រយប្រភេទ ដែលមួយចំនួនមានគុណភាពខ្ពស់ និងមួយចំនួនទៀតមានគុណភាពទាបដែលយកមកពី ហ្វ្លែនដឺស (Flanders) ទៅកាន់ព័រទុហ្គាល់ និងកងដៃចំនួនរាប់មិនអស់ទៀត» (ពែរស៍ គ.ស.១៥១៥ ទំ. ១២៥) ។ដូចគ្នានេះដែរនាំយកនូវ«ព័រសឺឡែន ដែក ទង់ដែង និងទំនិញថោកៗយ៉ាងច្រើនដែលប្រជាជននៅប៉ាតានី ត្រូវការ» ដែលធ្វើប៉ាតានី មានតួនាទីសម្រាប់នាំចេញបន្តទៅទៀត ដូចជា ម៉ាឡាកា ។ ពួកពាណិជ្ជករមកពីប៊័រណេអូយកទៅវិញនូវផលិតផលដែករបស់ចិន ពីប៉ាតានី (វ៉ាន់ ណែក គ.ស.១៦០៤ ទំ. ២២៩-៣០) ។ ដែកឥណ្ឌាមានភាពល្បីរន្ទឺជាងនេះ ដែលផ្តល់ឲ្យជាទំនិញនាំចូលលើសពី ២៥០ បាហារ (ស្មើនឹង ៤៥ តោន) ទៅកាន់ អាចេ និង ទីគូ (Tiku) រហូតទាល់មានទំនិញដែករបស់អឺរ៉ុបមកជំនួសវិញ នៅក្នុងសតវត្សទី១៦ (អ៊ីតូ តៀ គ.ស.១៩៨៤ ទំ.៤៣៩) ។ ទោះបីជាប៊័រណេអូ និងស៊ូឡាវេស៊ី ផ្តល់ឲ្យភាគច្រើននូវតម្រូវការរបស់ ពួកជ្វា និងពួកកោះឡេសែ សាន់ដា (Lesser Sunda) នៅដើមសតវត្សទី ១៧ ក៏ដោយ ក៏ពួកឈប់នាំបន្តទៀតនៅចុងសតវត្សនោះដែរ ។

អ្នកជីករករ៉ែដែក និងអ្នកដុតរំលាយដែក នៅការីម៉ាតា ដែលត្រូវតែប្រជែងដោយផ្ទាល់ជាមួយដែកពួកចិន និងអឺរ៉ុបនៅលើទីផ្សារនៅតំបន់ដីកោះនោះ ចុងបញ្ចប់បញ្ឈប់ជំនួញរបស់ខ្លួននៅក្នុងគ.ស.១៨០៨ (អេនី ៤ Eni IV ទំ. ៧៩០) ។ ពួកនរវង្សវិទូនៅសតវត្សទី ១៩ បានរកឃើញថា ប្រពៃណីរំលាយរ៉ែក្នុងស្រុកមានបន្តនៅមានតែនៅតំបន់ខ្ពង់រាបដែលមិនងាយអាចទៅបាននៃស៊ូម៉ាត្រាកណ្តាល ប៊័រណេអូកណ្តាល និងស៊ូឡាវេស៊ីកណ្តាល (សូមមើលរូបភាព ១៧ កនិង ១៧ ខ) ។



រូបភាព ១៧ ក ៖ ការរំលាយដែកដោយពួក ដាយ៉ាក់ នៃតំបន់ ឌូសុន អូលូ នៅផ្នែកខាងលើតាមដងទន្លេ បារីតូ
នៅក្នុងប័រណេអូកណ្ដាល នាសតវត្សទី ១៩

*បុស្សីពីដើម ដែលមានអង្កត់ផ្ចិតប្រវែង ២ អ៊ីច និងបណ្ដោយប្រវែង ៥ វីត ដោតបញ្ឈរត្រង់នៅក្បែរភ្លើង ចំហផ្នែកខាងលើ និងបិទជិតនៅខាងក្រោម ៗ ប្រវែងប្រមាណជា ១ អ៊ីច ខ្វាតពីគ្នានៅផ្នែកខាងក្រោម គេភ្ជាប់បុស្សីនោះចូលគ្នាដែលចំណុចភ្ជាប់នោះដើរតួនាទីជាទុយោ ចង្អុលទៅកាន់ និង ជួបនៅកន្លែងភ្លើង ៗ*

*ដើម្បីបង្កើតឲ្យមានចំហាយខ្យល់នោះ គេប្រើរោមសត្វស្វាបមួយដុំធំ ឬក៏វត្ថុទន់ផ្សេងទៀត ចងជាប់ទៅនឹងដងដៃមួយដ៏វែង សំយោងចុះឡើងនៅពីលើផ្នែកខាងលើនៃបំពង់បុស្សីនោះ ដូចជាបិស្តុងស្នប់អ៊ីចឹងឯង ៗ នៅពេលរុញរោមសត្វស្វាបនោះចុះមកក្រោម ធ្វើឲ្យខ្យល់ផុសចេញមកក្រោយតាមបំពង់បញ្ឈរនោះ ហើយដោយទាញរោមសត្វស្វាបទាំងនោះចុះឡើងៗទៅនឹងមានចរន្តបន្តបន្ទាប់កើតឡើង ដែលការងារនេះតម្រូវឲ្យមានកូនក្មេងម្នាក់អង្គុយនៅលើទីខ្ពស់ចាំធ្វើ (ម៉ាសដែនរំសេដនេ គ.ស. ១៧៨៣ ទំ. ១៨១) ។*

*ពិពណ៌នាអំពីបំភ្លឺភ្លើងរបស់ជាងដែកនៅស៊ូម៉ាត្រាដូចការពណ៌នាខាងលើនេះស្ទើតែបេះបិទ នៅទូទាំងកោះនៅឥណ្ឌូនេស៊ី និងហ្វីលីពីន នៅភូមា សៀម និងសូម្បីតែនៅសាយហ្គុន (ម៉ៃយឺរ គ.ស. ១៨៩០ ទំ. ៦២–៦៣, រ៉ាហ្វ័រស៍ គ.ស. ១៨១៧ ទំ. ១៧៣, ដាំពែរ គ.ស. ១៦៩៧ ទំ. ២២៧, គ្រូអ៊ីជ (Kruijt) គ.ស. ១៩០១ ទំ. ១៥២, សាំងហ្គឺមាណូ គ.ស. ១៨១៨ ទំ. ១៨៧, ស៊ូចីតា គ.ស. ១៩៨៣ ទំ. ៣៨ និង ៤០ និងវាយត៍ គ.ស. ១៨២៤ ទំ. ២៧៨) ។ បំពង់ទាំងពីរនោះភាគច្រើនធ្វើឡើងអំពីគល់ឈើ ជាជាងពីបុស្សី ហើយបញ្ជាប់បុស្សីតូចនោះភ្ជាប់នៅក្នុងបំពង់ដីឥដ្ឋមុននឹងចូលទៅក្នុងភ្លើង ៗ ទោះបីជាបំពង់ទាំងពីរនោះជាឧបករណ៍ធម្មតាសម្រាប់ឡរបស់ជាងដែកក៏ដោយ ក៏គេត្រូវការរហូតដល់ទៅ ១២ បំពង់ដែលអាចប្រើយកទៅដុតឡដើម្បីរំលាយដែក (សារ៉ាណែរ គ.ស. ១៨៥៣ ទំ. ឯកសាររបស់*

ហារីសាន់ និង អូ កុងណរ័. គ.ស.១៩៦៩ ទំ. ៣៤៥) ។ បុរាណភាពនៃប្រព័ន្ធនេះនៅអាស៊ីអាគ្នេយ៍ក៏បញ្ជាក់បាន-តាមការរកឃើញនៅម៉ាដាហ្គាស្ការាំងផាសចារ ដែលពួកឥណ្ឌូនេស៊ីធ្វើអន្តោប្រវេសន៍ទៅរស់នៅទីនោះយ៉ាងរ-ហាចណាស់អស់រយៈពេលមួយពាន់ឆ្នាំរួចមកហើយ ។ ភាពមានប្រសិទ្ធភាពក្នុងការបញ្ជាទិសដៅចរន្តខ្យល់នៅក្នុងឡរបស់សម័យមុននោះក៏អាចបញ្ជាក់តាមរយៈការចងចាំរបស់ជាងដែកនៅស៊ូឡាវេស៊ី និងប័រណេអូ នៅសព្វថ្ងៃនេះដែរ នៅពេលដែលមានឡសម័យទំនើបនេះ ។




រូបភាព ១៧ ខ ៖ ឧបករណ៍ធ្វើដែកនៃពួកនៅស៊ូឡាវេស៊ីកណ្តាល គ.ស. ១៩០០

# ឧជំដែជ សំណាថាំហាំជ ឆិជសំណា

*តាំងពីគ.ស.១៩៦០ មក បុរាណវត្ថុវិទូដែលធ្វើការនៅភាគឦសាននៃប្រទេសថៃ និងប្រទេសវៀតណាម បានស្រាវជ្រាវពីដើមកំណើតរបស់វិទ្ធិ នៅអាស៊ីអាគ្នេយ៍ ថាមានអាយុចំណាស់រហូតដល់ទៅ ២០០០ ឆ្នាំមុនគ.ស. ដែលជាកាលបរិច្ឆេទមុនកាលបរិច្ឆេទដទៃទៀតនៃការសិក្សាស្តីអំពីលោហធាតុនៅអាស៊ីខាងត្បូង ។ ទោះបីជាមិនមានការជំទាស់ក្តី ក៏មានការអះអាងជាច្រើនបាន លើកឡើងថាប្រជាជននៅអាស៊ីអាគ្នេយ៍ ប្រហែលជាបានរកឃើញនូវការធ្វើលោហៈដោយខ្លួនឯង មុនអ្នកជិតខាងរបស់ពួកគេដោយសារតែការរកឃើញនូវសំណាប៉ាហាំង និងទង់ដែងនៅជិតៗតំបន់ដែលពួកគេរស់នៅ (សូលហែម (Solheim) គ.ស.១៩៦៨, បាយាដ Bayard គ.ស.១៩៨០ និងលូហ្វស៍-វីស្សូវ៉ា (Loofs-Wissowa) គ.ស.១៩៨៣) ។ តាមពិតទៅវិទ្ធិនៅអាស៊ីអាគ្នេយ៍ជាទូទៅមានជាតិសំណច្រើនជាងសំណប៉ាហាំងលាយចូលគ្នា ទោះបីជាជាតិទង់ដែងកម្រធ្លាក់ចុះដល់ក្រោម៧០% ដែរនោះ (វ៉ាន់ហែកែរ៉ែន (van Heekeren) គ.ស.១៩៥៨ ទំ. ៥,៣៣ និង ៣៥) ។ វិធីសាស្ត្រប្រើដើម្បីជីកយក និងស្ល លោហៈទាំងនេះមានលក្ខណៈស្រដៀងទៅ និងវិធីស្លដែកដែរ ទោះបីជាការដុតដើម្បីទាញយកលោហៈរលាយចេញពីរ៉ែ មិនសូវចាំបាច់ក៏ដោយ ។*

*យ៉ាងហោចណាស់ក៏ចាប់តាំងពីកំលុងពេល រដ្ឋកាលម៉ីងដែលធ្វើពាណិជ្ជកម្មសកម្មនៅដើមសតវត្សទី ១៥ នោះ ប្រាក់កាក់ស្ពាន់របស់ចិនត្រូវបាននាំចូលយ៉ាងទូលាយ មកកាន់អាស៊ីអាគ្នេយ៍ដើម្បីប្រើជារូបិយវត្ថុ (វាយត៍ម័រ គ.ស.១៩៨៣ ទំ. ៣៦៣ និង ៦៥) ។ នៅសតវត្សទី ១៨ កាក់ប្រាក់របស់ហូឡង់មានទីផ្សារយ៉ាងខ្លាំង (ឌូប៊ីន (Dobbin) គ.ស.១៩៨៣ ទំ. ៧០-៧១) ។ ដោយសារតែកាក់ស្ពាន់ ដែលត្រូវបានគេលាយជាមួយសំណ និងសំណប៉ាហាំងមានតម្លៃថោកមានគ្រប់ទីកន្លែងនោះ ប្រាក់កាក់ទាំងនេះអាចបានក្លាយទៅជាជាប្រភពដ៏សំខាន់មួយសម្រាប់ការផលិតទង់ដែង នៅយុគសម័យពាណិជ្ជកម្ម ។*

*ទោះបីជាយ៉ាងណាសារធាតុរ៉ែទាំងអស់នេះនៅតែត្រូវគេបន្តទាញយកនៅទីតាំងពិតប្រាកដនៅអាស៊ីអាគ្នេយ៍ ហើយត្រូវបានដួញទៅទីជិតឆ្ងាយ ។*

*ចំណែកដ៏ធំសម្បើមនៃសំណប៉ាហាំងនៅលើពិភពលោកលាតសន្ធឹងពីជើងទៅត្បូងដែលថយចុះពីកំពូលភ្នំនៅភូមាភាគខាងកើតតាមឧបទ្វីបម៉ាឡា ទៅកោះនៃតំបន់បាងកា និងបីលីតុន (Beliton) ។ ទំនុកបំរុងដ៏ច្រើនរបស់កោះទាំងពីរចុងក្រោយនេះនៅតែគ្មាននរណាជីងរហូតដល់ឆ្នាំ ១៧០៩ ប៉ុន្តែឧបទ្វីប ភាគកណ្តាល មនៅថន្ទោះតាវ៉ូយ និងស៊ីឡុំហ្គ័រ បានផ្គត់ផ្គង់មួយផ្នែកធំចំពោះតម្រូវការសំណប៉ាហាំងនៅអាស៊ីចាប់តាំងពី សតវត្សទី ១០ មក ។ សំណប៉ាហាំង គឺជាផលិតផលមួយក្នុងចំនោមផលិតផលនាំចេញរបស់មឡាកា ក្នុងសតវត្សទី១៥ ដែលបានមកពីតំបន់ត្រួតត្រារបស់ខ្លួនផ្ទាល់ ហើយរូបិយវត្ថុរបស់វារួមមានដុំសំណប៉ាហាំងស្និតតូចៗជាច្រើន (Ma Huan ១៤៣៣, III; Pires ១៥១៥ : ២៧០-៧១-២៧៥) ។ សំណប៉ាហាំងភាគច្រើនដែលត្រូវបានគេទាញយកពីជុំវិញទំបន់ទាវ៉ៀយត្រូវបានគេផ្គត់ផ្គង់ឲ្យប្រទេសភូមា តែរ៉ែដែលទាញយកបាននៅឆ្នេរខាងកើតឧបទ្វីបផ្គត់ផ្គង់ទៅប្រទេសថៃ ។ វាជារ៉ែចុងខាងត្បូងនៅលើឆ្នេរខាងលិចនៃប្រទេសឧបទ្វីប ដែលផលិតសម្រាប់នាំចេញ ហើយយើងដឹងច្រើនអំពីពួកគេ ។ ពេរ៉ាក់ និងស៊ីឡុំហ្គ័រ ជាអ្នកផ្គង់ផ្គង់សំណប៉ាហាំងសំខាន់ជាងគេដែលបានចែកចាយទៅមឡាកា ហើយមួយផ្នែកធំនៃសំណប៉ាហាំងនេះត្រូវបាននាំចេញទៅឥណ្ឌា ។ Jumkceylon (កោះភូកេត) ជាអ្នកផ្គត់ផ្គង់មួយរបស់ប្រទេសសៀមពីដំបូងត្រូវបានគេចាត់ទុកថាជាប្រភពសម្រាប់ ការនាំចេញសំណប៉ាហាំង ក្នុងសតវត្ស*

ទី ១៦ ហើយតាមរយៈការផលិតរបស់តំបន់មួយនេះ វាបានចូលរួមចំណែកក្នុងគោគទ្រព្យតាមប្រាល៊ីង្គា (Tambralinga) យូរមកហើយ (Gerini ១៩០៥:១៣៦-៤១, Whealtey ១៩៦៤:១៥១៥) ។ ក្នុងឆ្នាំ ១៥៩៦ សំណប៉ាហាំងដែលមាននៅក្នុងឃ្លាំងនៅប៉ង់តង់ បានមកពី ពីរ៉ាក់ (បន្ទាប់មកទទួលឯករាជ្យ) និងកោះភូកេត (លូដូវីស្គស៍ ១៥៩៨: ១១៩) ។ ទោះបីជាយ៉ាងណាពីរ៉ាក់ នៅតែមិនអាចការពារធនធានដ៏មានតម្លៃនេះបាន ហើយក្នុងឆ្នាំ ១៦២០ វាបានធ្លាក់ក្រោមកណ្ដាប់ដៃពួកអាឆេ ។ សម្រាប់រយៈពេល ៤០ ឆ្នាំបន្ទាប់មកទៀត អ្នកជំនួញឥណ្ឌា និងអឺរ៉ុប ដែលបានលក់សំណប៉ាហាំងឲ្យទីផ្សារឥណ្ឌា និងទីផ្សារដទៃទៀតបានទាក់ទងទាំងជាមួយអាឆេទាំងរដ្ឋចំណុះភាគខាងត្បូងរបស់សៀម ។ តាំងពី Dutch បានរាយការណ៍ពីផលចំណេញ ៨៤% ក្នុងការលក់សំណប៉ាហាំងនៅឥណ្ឌា (Mactsuyker ១៦៧១: ៧៤៣) មកពួកគេបានធ្វើដំណើរឆ្ងាយដើម្បីទទួលបានវា ។

វិធីសាស្ត្រក្នុងការបង្ហូរ និងរំលាយរ៉ែរបស់ម៉ាលេ និងថៃ ត្រូវបានរៀបរាប់ដោយហ្គីរឺដ័រ (Geredor ១៦០០: ២៣៥)ក្នុងករណីរបស់ពីរ៉ាក់ «ដីត្រូវបានជីកចេញពីភ្នំហើយដាក់នៅលើតុ ដែលដីត្រូវបានពន្រ្លាយដោយទឹកដែលមានតែសំណប៉ាហាំងដែលមានទម្រង់ជាគ្រាប់ៗ ដែលនៅសល់លើតុ ។ បន្ទាប់មកវារលាយនៅក្នុងពុម្ពដីឥដ្ឋ និងនៅក្នុងដំណើរការសិតត្រូវបានបំលែងទៅជាបន្ទះៗ» ។ នៅប៉ែកខាងជើងមានកន្លែងជាច្រើនដែលជាធម្មតាស្ត្រីបានប្រមូលបំណែករ៉ែសំណប៉ាហាំងដែលលេចឡើងតាមដងភ្នំបន្ទាប់ពីភ្លៀងធ្លាក់ខ្លាំង (Gerini ១៩០៥: ១៥៩-៦០) ។ តែយ៉ាងណាក៏ដោយបរិមាណដ៏ច្រើនត្រូវបានគេទាញយកតាមវិធីទាំងពីរ ។ អេរេដៀរ (១៦០០: ២៣៤)បានប៉ាន់ប្រមាណថា ពីរ៉ាក់ បានផលិត ៣០០ បាហា ឬ ៥០ តោនក្នុងមួយឆ្នាំ ហើយកំពង់ផែភាគខាងត្បូងភាគច្រើនផលិតបានប្រហែលៗគ្នានេះដែរ ។ ក្នុងកំលុងទសវត្សឆ្នាំ ១៦៤០ ការដឹកសំណប៉ាហាំងតាមកប៉ាល់ពីពីរ៉ាក់ទៅអាឆេ ត្រូវបានប៉ាន់ស្មានខុសៗគ្នាពី ៨០០ ទៅ ២.០០០ បាហា (១៣០-៣៣០តោន) (van der Lijn ១៦៤៨:៤៣០; I to ១៩៨៤: ១៤០) ។ ក្នុងឆ្នាំ ១៦៥៧ កប៉ាល់របស់Dutch បាននាំទំនិញ ១០០ បាហាពី Junkceylon មួយទៀតនាំទំនិញ ៤៥១ បាហាពី នគរស៊ីធម្ម (Mactsyker ១៦៥៧: ១២៦) ។ ហ្វរិស បានអះអាងថា Junkceylon បានផលិត ៥០០ តោន ក្នុងមួយឆ្នាំក្នុងកំលុងទសវត្សឆ្នាំ ១៧៨០ ហើយបានផលិតច្រើនជាងនេះទៅទៀតនៅកំលុងពេលមុននេះ មុនពេលដែលសំណប៉ាហាំងរបស់វាបានក្លាយជាដំណើរផ្ដាច់មុខសម្រាប់អ្នកស្ទូជនជាតិចិន (ដិតដេ Gerini ១៩០៥: ១៧៥) ។

មានតែសំណនៅអាស៊ីអាគ្នេយ៍ទេដែលមាននៅក្នុងវៀតណាមខាងជើង និងសៀម ។ សំណរបស់សៀមត្រូវបាននាំចេញទៅមឡាកា ភូមា ឥណ្ឌូចិន និងនាំតាម ទេណាស៊ីរ៉ុម (Tenasserim) ទៅអាឆេ និងប៉ង់តង់ (Pires ១៥១៥, ១០៥, Sangerman ១៨១៨: ២០៥, White ១៦៧៨: ៤២៥, Compostel ១៦៣៦: ១២១៦, លូដូវីស្គស៍ ១៥៩៨: ១១៩) ។ គ្មានពត៌មានលម្អិតណាដែលបានបញ្ជាក់ថា តើសំណនេះយកមកពីប្រភពណា និងយកដោយវិធីណានោះទេ រហូតដល់គ្រូហ្វ័រេ៉ល (១៨២៨: ៤១៩) បានអះអាងថាជំនាន់គាត់ រ៉ែត្រូវបានគេធ្វើការដោយកុលសម្ព័ន្ធដ៏ព្រៃផ្សៃរបស់ឡាវ៉ា នៅជិតប៉ាក់ព្រែក ដែលពួកគេផលិតប្រហែល ២០០០ ភិកសីល ស្មើនឹង ១១០ តោនក្នុងមួយឆ្នាំ ។

ប្រភពទង់ដែងដ៏សម្បូរបែបនៅអាស៊ីអាគ្នេយ៍គឺមាននៅតំបន់ភ្នំភាគខាងជើងនៃប្រទេសវៀតណាម ដែលជាកន្លែងកកើតឡើងនៃស្ពាន់ដុងសុង (Dong-Song) ដ៏ល្បីល្បាញនៅមុនសម័យគ្រិស្ត ។ តួលេខនៃការផលិតទង់ដែង ២៨០ និង ២២០ តោនក្នុងមួយឆ្នាំសម្រាប់តែរ៉ែពីរនៅក្នុងតំបន់ ទូ លុង ត្រូវបានរាយការណ៍សម្រាប់សតវត្សទី ១៨ ហើយផលិតផលមានសារៈសំខាន់ជាងសតវត្សមុន (១៩៧០: ៨៩) ។ នៅពេលដែលក្រុមកម្មករចិនបានទាញយកទង់ដែងទាំងនេះរ៉ែដ៏ទៃទៀតនៅចុងខាងជើង និងចុងខាងត្បូងនៃប្រទេសឡាវសព្វថ្ងៃ នៅជួរភ្នំខាង

ដើងប្រទេសកម្ពុជានិងជួរភ្នំចន្ទោះសៀម និងភូមាត្រូវបានទាញយកដោយក្រុមកុលសម្ព័ន្ធភ្នំ ។ ពួកគេស្លលោហៈទាំងនេះហើយប្តូរវាជាមួយពួកសិប្បករតំបន់ទំនាបដែលច្នៃវាឲ្យទៅជារូបចម្លាក់ ប្រដាប់ប្រដាផ្ទះបាយ និងឧបករណ៍ភ្លេង(Frédéric ១៩៨១ : ១៦០, Pallegoix ១៨៥៤ I :១១៧)។

ជំនាញក្នុងការស្វែងរកអណ្តូង ការជីក និងស្លរ៉ែទង់ដែងបានបង្ហាញដោយប្រជាជនភ្នំដែលមិនចេះអក្សរនៅតំបន់អ៊ីហ្គូរ៉ុតស៍ (Igorots) នៃជួរភ្នំលូស្សុន់ បច្ចេកទេសរបស់ពួកគេ ត្រូវបានគេរៀបរាប់នៅក្នុងសតវត្សទី ១៩។ វិស្វករជនជាតិអេស្ប៉ាញម្នាក់ដែលបាន ត្រួតពិនិត្យរ៉ែរបស់គេក្នុងឆ្នាំ ១៩៥០ បានសន្និដ្ឋានពីសំណល់ដ៏សម្បើមថាវាត្រូវបានគេទាញយកយ៉ាងហោចណាស់តាំងពី ពីរសតវត្សមុន (Scott ១៩៧៤ : ២៤៦) ។ អ៊ីហ្គូរ៉ុតស៍ បានស្រទាប់រ៉ែដោយ បង្ហូរទឹកហើយបំបែកកម្ទេចរ៉ែដោយប្រើភ្លើងដុតវា ។ រ៉ែនេះត្រូវបានដុតជាមួយ ដែលបានចាក់នៅជុំវិញវាបន្ទាប់មកដុតវាជាលើទីពីរ ។ ការរំពឹងរបស់វិស្វករជនជាអេស្ប៉ាញ និងកម្មករចិនក្នុងការចម្រាញ់រ៉ែទង់ដែងបន្ទាប់ពីឆ្នាំ ១៨៥៦ ជាការខាតបង់គួរឲ្យកត់សម្គាល់ ដែលនាំឲ្យគណៈកម្មាធិការរដ្ឋាភិបាលមួយសន្និដ្ឋានក្នុងឆ្នាំ ១៨៦៤ ថា៖

> «លើការសញ្ជឹងគិត កម្មករដែលមានចម្ងល់ ដែលអ៊ីហ្គូរ៉ុតស៍ បានបង្កើតឡើងមុនពេលក្រុមហ៊ុននេះត្រូវបានបង្កបង្កើតឡើង យើងមិនដឹងថាអ្វីដែលគួរឲ្យស្ងើចសរសើរ តើភាពមាំមួនរបស់កម្មករដ៏សកម្មនេះ ឬភាពឈ្លាសវៃក្នុងការជ្រើសរើសរ៉ែដ៏សម្បូរបែប ហើយចម្ងល់នេះជាវិធីសាស្រ្តដែលគេបញ្ឈប់ ការជីកដែលពួកគេបានធ្វើជាមួយនឹងការទុកចោលខាងក្នុងអណ្តូង ដែលលាក់បាំងការងារដែលគេបានធ្វើរួច ។ បើធ្វើការប្រៀបធៀបយើងនឹងឃើញមានកំហុសគួឲ្យទាស់ភ្នែកមួយដែលធ្វើដោយវិស្វករក្លែងបន្លំតាំងខ្លួនជាអ្នកមានចំណេះដឹងក្នុងការជីកយករ៉ែតែមានលក្ខណៈអន់ថយជាងអ្វីដែលយើងបានចាត់ទុកយ៉ាងហួសហេតុថាជាអំពើឃោរឃៅ (cited Scott ១៩៧៤ :២៤៧) ។»

នេះជាការពិតប៉ុន្តែមានឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍ជាច្រើនដែលគេប្រើម៉ាស៊ីនជីករ៉ែទំនើបដែលមានទំហំធំ បញ្ជាក់ថាការជីកយករ៉ែដែលត្រូវបានជីករាប់សតវត្សមកហើយដោយប្រជាជនខ្ពង់រាបនៅអាស៊ីអាគ្នេយ៍នោះមិនអាចរកបានផលចំនេញច្រើនទេ ។ វាបានរំលឹកពីការឯកភាពរបស់លោកហ្វ្រេង ស្វីតតាហាម (Frank Swettanham) សង្កត់ធ្ងន់លើការរកទីតាំងរ៉ែទង់ដែងមានប្រភេទទង់ដែងដូចគ្នា ដែលគេអាចរកបានដោយកម្រ (Cited B Andaya ១៩៧៩ : ៣៩៩) ។ អវត្តមានរ៉ែទង់ដែងនៅតាមតំបន់នីមួយៗ នៅពេលដែលទង់ដែងនាំចូលមានតម្លៃថោកនោះយើងសន្និដ្ឋានថា គេមិនអាចជីករ៉ែទង់ដែងបានទេនៅសម័យដើម ។

ស៊ូម៉ាត្រា និងជ្វាជាឧទាហរណ៍ ។ ទោះបីដាដាវិស (១៦០០: ១៤៧) សង្កត់ធ្ងន់លើរ៉ែទង់ដែងនៅអាចេ ក៏ដោយព័ត៌មានពិតប្រាកដអំពីទង់ដែងក្នុងកោះផ្សេងៗនោះជា សេចក្តីបញ្ជាក់របស់ម៉ាសដិន (Marsden ១៧៨៣ : ១៧២) ចំពោះការផាររ៉ែដោយអាចេ នៅឆ្នេរខាងលិចស៊ូម៉ាត្រា នៅ មឹក (Meuke) ។ ក្នុងទម្រង់ជាម៉ាឡាឈិត (Malachite) ទង់ដែងនៅតែត្រូវប្រជាជននៅទីនោះនាំគ្នាប្រមូលក្នុងឆ្នាំ ១៩១៦ (Van Bemmelin ១៩៤៩ II :១៤៨) ។ ដូចគ្នាដែរអ្នករុករករ៉ែមាសមីណាង កាប៊ូ (Minang Kabau) តែងតែជួបប្រទះរ៉ែទង់ដែងនៅជុំវិញបឹងសិង្ការៈ (Singkarak) នៅចុងសតវត្សទី១៩ (ibid: ១៥១) ។ យើងឃើញយ៉ាងច្បាស់ថាភាពរីកចម្រើននៃអ្នកផលិតគ្រឿងស្ពាន់នៅក្រុងអាចេ និងសុង្គី (Sungei) ក្នុងមីណាង កាប៊ូ នាំទង់ដែងភាគច្រើនមកពីប្រភពក្នុងស្រុក ។ ដោយសារទង់ដែងរបស់

ស៊ូម៉ាត្រា  កកើតជាមួយមាស វាអាចជួយផងដើម្បីពន្យល់ពីសេចក្ដីស្រលាញ់របស់ជនជាតិ អាឆេ ចំពោះស៊ូសា (Suasa or tembanga Suasa), ដែលជាសំលោហៈរវាងមាសនិងទង់ដែង(Beautieu ១៦៦៦ : ១០០, Lancaster ១៦០៣ : ៩៣, Copland ១៦១៦ : ២១០, ២១៣, Jasper and Pirngadie ១៩៣០ : ៧-៨: Withinson ១៩០៣ : ១១២៥) ។ស៊ូម៉ាត្រា និងជ្វា មិនត្រូវបានរាប់ក្នុងចំណោមអ្នកនាំចូលរបស់ជប៉ុន និងចិនដោយលោកថម ផាយស៍ (Tome Pires) នោះទេ ប៉ុន្តែ អាឆេក៏ដូចជា ជ្វាបាននាំចេញទង់ដែងជាច្រើនកាប៉ាល់ (Pires ១៥១៥ :១៨០, Compostel ១០៣៦ : ១២០០) ។ ជនជាតិថៃប្រើពាក្យរបស់ម៉ាឡេ “tembaga” សម្រាប់សំលោហៈមាសស្ពាន់ដែលពួកគេមានការលើកតម្កើនដំណើរនោះ . (Laloubere ១៦៩១ : ១៤) បាននិយាយថា រ៉ែទាំងនេះពិតនាំចូលពី ស៊ូម៉ាត្រា ឬប័រណេអូ ។

ទោះបីជាវ៉ាន់ បឺមឹលេន (Van Bemmelen ១៩៤៩ II : ១៥៥) សង្ស័យថាតើការផ្គត់ផ្គង់រ៉ែទង់ដែងដោយខ្លួនឯងអាចកើតមានរហូតទេនៅជ្វា។ ក្នុងឆ្នាំ ១៦០៣ គង ឬឃ្មោះធ្វើពីទង់ដែងដែលនាំចេញពី ជ្វាមានតម្លៃថោកជាងគង ឬឃ្មោះដែលធ្វើនៅប៉ាតានី ដោយជនជាតិចិន ជិតពាក់កណ្ដាលដោយសន្មត់ទៅលើវត្ថុធាតុដើមរបស់ចិន (Rouffaer ១៩០៤ : ៩៧) ។ លើសពីនេះទៅទៀតមជ្ឈមណ្ឌលច្នៃទង់ដែងចាស់ៗរបស់ ជ្វា ខ្លះមានទីតាំងនៅតែកន្លែងដែលនៅជិតប្រភពរបស់ទង់ដែង ។ ដូច្នោះហើយតំបន់កំពិនឆាននៅខាងលិច ជ្វាដែលជាតំបន់ស្រទាប់រ៉ែទង់ដែងសំខាន់ៗនោះជាតំបន់ដែលមានជាងផលិតទង់ដែងសំខាន់ៗ ។ ការស្រាវជ្រាវតាមភូមិនៅក្នុងតំបន់មួយក្នុងឆ្នាំ ១៦៨៦ បង្ហាញថាការងារទង់ដែងជាមុខរបរតែមួយគត់សម្រាប់ ៣៣ ភូមិនៅតំបន់សុមេដាង (Sumedang) នៅខាងកើតបានដុង (Bandung) ទំនើប តែមានភូមិពីរ កាំពើង សាយាំង (Kampueng Sayang) ដែលមានទីតាំងនៅទីក្រុង ព្រីហ្គង់ (Priangan) ថ្មីដែលជារាជធានីនៃ ស្យង់ហ្សួរ (Cianjur) (de Haan ១៩១២ III :២១៦-១៥) ។ ទីតាំងទាំងនេះនៅមិនឆ្ងាយពីតំបន់កកើតរ៉ែទង់ដែងថ្នាក់ទាបក្នុងតំបន់គុរ៉ុង រ៉ារាំង (Cunung Rarang) និងគុរ៉ុង សាវ៉ាល (Cunung Sawal) (Van Bemmelen ១៩៤៩ II :១៥៧ : ៥៨) ។ កន្លែងដែលងាយរកកម្មកររ៉ែទង់ដែងរបស់ព្រះរាជាណាចក្រម៉ាតារាំ (Mataram) គឺមានទីតាំងនៅចុងខាងលិចដែនដីរបស់ព្រះជាណាចក្រនេះដែលនៅជិត ស៊ីរីបូន ហើយនិងក្រាវ៉ាង (Ceribon and Krawang) ដែលគេមិនអាចពន្យល់បានប្រសិនបើគេមិននិយាយពីទង់ដែងរបស់ ព្រីហ្គង់ ទេនោះ (de Haan១៩១២ III :២១៣, ៣៤៧-៤៨) ។ ប្រភពទង់ដែងសម្រាប់ភាគខាងកើត ឬភាគកណ្ដាល ជ្វាគឺនៅជិតតេហ្គាលុមបូរ (Tegalombo) ចម្ងាយតែ ២៥ គីឡូម៉ែតភាគអាគ្នេយ៍សារ៉ាកាតា (Surakarta) (Van Bemmelen ១៩៤៩ II: ១៥៧) ដែលប្រហែលជាដែកតួក្នុងការអភិវឌ្ឍន៍ សារ៉ាកាតា ឲ្យជាមជ្ឈមណ្ឌលផលិតផលទង់ដែងធំមួយ ។

ទោះបីជាយ៉ាងណាក៏ដោយក៏គ្មានចម្ងល់ដែរ ដែលថាការហូរចូលដ៏សន្ធឹកសន្ធាប់នូវទង់ដែងរបស់ជប៉ុន ចិន និងអឺរ៉ុបជាពិសេសក្នុងសតវត្សទី ១៧ បានធ្វើឲ្យរ៉ែក្នុងស្រុក និងមានទំហំតូចភាគច្រើនលើសតម្រូវការ ។ ជប៉ុនដែលជាអ្នកផ្គត់ផ្គង់ធំជាងគេនៅចុងសតវត្សទី ១៧ បាននាំចេញជាមធ្យមលើសពី ៣.០០០ តោន ក្នុងមួយឆ្នាំក្នុងអំឡុងឆ្នាំ ១៦៧០-១៧១៥ (Innes ១៩៨០ : ៥២៨-២៩) ។ កម្មកររ៉ែទង់ដែងដែលបានប្រមូលផ្ដុំនៅគ្រប់រាជធានី និងមជ្ឈមណ្ឌលមួយចំនួនបានធ្វើការបង្កើតវត្ថុធាតុដើមរបស់គេដោយការនាំចូលថោកៗ ។ ទង់ដែងដែលផ្សំពីលោហៈច្រើនប្រភេទនៅតែជាលោហៈសំខាន់សម្រាប់ធ្វើកាំភ្លើងតូច ក៏ដូចជាប្រដាប់ប្រដារផ្ទះបាយដូចជាកំសៀវ ចង្កៀង ថាស និងប្រអប់ម្លូ ។ ក្នុងប្រទេសកាន់សាសនាព្រះពុទ្ធនៅភាគខាងជើង មហិច្ឆិតាធំរបស់ការងារទង់ដែង គឺសម្រាប់គោលបំណងសាសនា រួមមាន រូបចម្លាក់ដ៏ធំរបស់ព្រះពុទ្ធជាដើម (Pallegoix ១៨៥៤I :៣៥)។ ជំនាញដ៏អស្ចារ្យមួយគឺការផ្ដុំឧបករណ៍ភ្លេងដែលមានគុណភាពសូរត្រឹមត្រូវ និងខ្លាំងល្អ ។ ផលិតកម្មភាគច្រើននៅហ្គ្រើស៊ិក

(Gresik) នៅជិតសារ៉ាបាហ្កា (Surabaga) គងរបស់ផ្លា គឺជាវត្ថុនាំចេញសំខាន់ដែលនាំចេញដោយអ្នកជំនួញ ផ្លា ទៅម៉ាលុគុ (Maluku) ប៊័រណេអូ បាលី និងឡេស័រ សុនដាស (Lesser Sundas) ដែលជាកន្លែងពួកគេក្លាយជាសញ្ញារបស់ព្រះរាជា(Galvao ១៥៤៤ : ១០៥, ១៤១, Barbosa ១៥១៣II :១៩៨, ២០២–០៣, Hangeman ១៨៦០ : ៤៣) ។ ដូចគ្នាដែរគងរបស់កម្ពុជា និងតុងកឹងត្រូវបានគេបញ្ជូនទៅកាន់ខ្លង់រាបតណ្ហូចិនដែលជាកន្លែងពួកគេត្រូវបានលេងក្នុងក្បួនយ៉ាងពិសេស (Hichey ១៩៨២ : ១៣៦–៨៧, ៤៤៩)។

# ជំពូកទី ២

# ទីក្រុង និងពាណិជ្ជកម្ម

*ដោយ អាធូនី រីដ*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា ÷ The City and Its Commerce ។ អត្ថបទនេះ ដកស្រង់ចេញពីសៀវភៅ ÷ អាស៊ីអាគ្នេយ៍ក្នុងយុគសម័យពាណិជ្ជកម្ម ១៤៥០-១៦៨០ ភាគទី ២ ។ រក្សាសិទ្ធិ គ.ស. ១៩៦៧ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យយេល ។*

## CHAPTER 2:

The City and Its Commerce

Anthony Reid

(*Southeast Asia in the Age of Commerce 1450 -1680 Volume Two*)

**Copyright © 1967 by Yale University.**

បកប្រែដោយលោក ភី សុភាដា

# ជំពូកទី ២
# ទីក្រុង និងពាណិជ្ជកម្ម

គ្រប់ទិសទីមានទីផ្សារក្នុងចំណោមលំនៅដ្ឋានជាច្រើន ប្រៀបដូចជាផ្ទាំងគំនូរមួយផ្ទាំងដ៏ធំ ។ សង្កាត់ទាំងឡាយមានភាពមមាញឹកចំរុះទៅដោយពណ៌ផ្សេងៗ. . . តាមពិតនេះគឺជារាជធានីដ៏រុងរឿងអស្ចារ្យ ។

—Nguyen Gian Thanh 1508, on Thang-long

*សម័យកាលពាណិជ្ជកម្ម គឺជាពេលវេលានៃការរីកលូតលាស់ក្រុងប្រកបដោយនិរន្តភាព ។ សតវត្សរ៍ទី ១៥ បានបង្ហាញឲ្យឃើញនូវបម្រែបម្រួលផ្នែកអំណាច ដ៏ច្បាស់លាស់មួយទៅរកទីក្រុងផ្អែកលើវិស័យជំនួញដោយធ្វើឲ្យសាបសូន្យដល់រាជធានីចាស់ៗ ដែលធ្លាប់តែពឹងផ្អែកភាគច្រើនទៅលើពន្ធអាករកម្លាំងពលកម្ម និងផលិតផលកសិកម្ម ។ អយុធ្យា ដោយមានវិស័យជំនួញ និងទំនាក់ទំនងការទូតយ៉ាងទូលំទូលាយ តាមរយៈការគ្រប់គ្រងទន្លេចៅផាយ៉ា នោះបានវាយកម្ទេចរាជធានីអង្គរបុរាណនៅឆ្នាំ ១៤៣២ ហើយទីក្រុងដែលសម្បូរទៅដោយប្រាសាទនេះក៏ត្រូវគេបោះបង់ចោល ។ នៅពេលដែលគេស្ថាបនាទីក្រុង ប្រទេសកម្ពុជាថ្មីមួយឡើងវិញ ទីក្រុងនេះឈប់ស្ថិតនៅជុំវិញសំណង់ជាពាសាស្រ្តចាស់ទៀតហើយ ។ ប៉ុន្តែវាស្ថិតនៅកន្លែងកំពុងផែដ៏សំខាន់មួយសម្រាប់ការធ្វើជំនួញជាមួយចិននិងជប៉ុនដែលស្ថិតនៅចំណុចប្រសព្វនៃទន្លេសាប និងទន្លេមេគង្គគឺស្ថិតនៅក្បែរទីក្រុងភ្នំពេញសព្វថ្ងៃនេះ។*

*នៅភូមា និងថៃ រយៈកាលដ៏វែងនៃសតវត្សរ៍ទី ១៦ ជារយៈកាលតែមួយគត់នៅមុនសតវត្សរ៍ទី ២០ដែលកំពង់ផែសមុទ្រដើរតួនាទីយ៉ាងសំខាន់ផ្នែកនយោបាយ និងវប្បធម៌ ។ ទីក្រុងកំពង់ផែពេគូរបស់មន មានការរីកលូតលាស់ពេញមួយសតវត្សរ៍ទី ១៥ ដោយបានទាក់ទាញឈ្មួញយ៉ាងច្រើន និងកសាងលម្អទីក្រុងឲ្យមានភាពទាក់ទាញឡើងតាមរយៈបូជនីយដ្ឋានព្រះពុទ្ធសាសនាដ៏ច្រើន ។ រីឯតំបន់ក្នុងរបស់ប្រទេសមានភាពច្របូកច្របល់ៗ ក្នុងឆ្នាំ ១៥៣៩ រាជវង្សភូមាដែលមានគំនិតវាទទីនិយមបានវាយលុកដើម្បីគ្រប់គ្រងទីក្រុងនេះពីជនជាតិមន ហើយប្រើប្រាស់នូវភោគទ្រព្យរបស់ទីក្រុងនេះដើម្បីបង្រួបបង្រួមនូវជ្រលងអ៊ីរ៉ាវ៉ាដឌី ទាំងមូល ។ នៅរវាងឆ្នាំ ១៥៥៥ និង ១៥៩៩ ទីក្រុងពេគូ គឺជារាជធានីដ៏រុងរឿងរបស់អាណាចក្រមួយដែលរួមមានជនជាតិភូមា និងជនជាតិមន (និងរួមទាំងជនជាតិថៃជាច្រើនផងដែរ) ។ នៅប្រទេសថៃ ចម្បាំងរវាងទីក្រុងអ៊ីស្លាមទាំងឡាយនៅតំបន់ឆ្នេរសមុទ្រខាងជើងជាមួយ និងរាជាណាចក្រហិនឌូមាចាប៉ាហ៊ិត គឺជាចម្បាំងដ៏អូសអន្លាយមួយ ដោយធ្វើឲ្យរាជធានីហិណ្ឌូបានដកថយជាបន្តបន្ទាប់ឆ្ពោះទៅទិសខាងកើត ។ ភោគទ្រព្យដែលបានមកពីជំនួញ និងបច្ចេកវិជ្ជាយោធា បានផ្តល់នូវអទិភាពពេញមួយសតវត្សទី ១៦ ដល់ទីក្រុងជាប់សមុទ្រមួយចំនួនដូចជា ដឹម៉ាក់ ចាប៉ារ៉ា ទុយបាន់ (Tuban) ហ្គ្រេស៊ីក និង ស៊ូរ៉ាបាយ៉ា ។*

*គេឃើញមានតែការលើកលែងតែមួយគត់ចំពោះទម្រង់បែបនេះ ដោយក្នុងនោះការរីកលូតលាស់យ៉ាងខ្លាំងផ្នែកជំនួញ បានផ្តល់ជាគំនិតផ្តួចផ្តើមនាំឲ្យមានទីក្រុងពាណិជ្ជកម្មសកលប្រភេទថ្មីមួយ ។ នៅប្រទេសវៀតណាម*

សតវត្សរ៍ទី ១៥ គឺជាសម័យកាលដ៏រុងរឿងមួយនៃការរំដោះ និងបង្រួបបង្រួមជាតិក្រោមការគ្រប់គ្រងរបស់រាជវង្ស ឡឺ (Le) ដែលបានពង្រីក និងកសាងលម្អរាជធានីនៅថាំងឡុង (Thang-long) (ក្រុងហាណូយនាពេលបច្ចុប្បន្ន) ។ ប៉ុន្តែ គ្រឹះមនោគមវិជ្ជាសម្រាប់រៀបចំរដ្ឋឡើងវិញ គឺជាលទ្ធិខុងជឺ ដែលគ្មានការជឿជាក់ចំពោះវិស័យពាណិជ្ជកម្ម ដោយផ្តោតជាសំខាន់តែទៅលើវិស័យកសិកម្មជាគ្រឹះតែមួយគត់សម្រាប់រដ្ឋ ។ ព្រះរាជា ឡឺ ថាញ់តុង (Le Thanh Tong)(១៤៦០-៩៧) ដែលជាព្រះរាជាដ៏ឆ្នើមជាងគេក្នុងចំណោមព្រះរាជារាជវង្សឡឺ បានប្រើប្រាស់នូវពាក្យស្លោក «ផ្តោតនូវកម្លាំងពលកម្មរបស់យើងទាំងប៉ុន្មាននៅលើវិស័យកសិកម្ម និងធ្វើឲ្យសក្តានុពលរបស់យើងរីកធំឡើង (សេចក្តីសំរង់ក្នុងង្វៀន ១៩៨៧ : ៨៧) ហើយភាសិតខុងជឺដែលនិយាយថា «ផ្តោតជាសំខាន់ទៅលើវិស័យកសិកម្ម ឯវិស័យពាណិជ្ជកម្មវិញគ្រាន់តែជាវិស័យបន្ទាប់បន្សំតែប៉ុណ្ណោះ» បានចាប់ផ្តើមមានប្រជាប្រិយភាពឡើង ។ ទោះបីជាការនាំចេញកុលលាភាជន៍របស់ប្រទេសវៀតណាមមានការរីកចម្រើនដល់កំពូលនៅចុងសតវត្សរ៍ទី ១៤ ក៏ដោយ ក៏ការនាំចេញនេះមានការធ្លាក់ចុះទៅវិញនៅចុងសតវត្សរ៍បន្ទាប់ ដោយសារតែប្រទេសវៀតណាមបានផ្លាស់ប្តូរទឹកមុខទៅជាមិនពេញចិត្ត ឬក៏ចាប់អារម្មណ៍ចំពោះចរន្តដែលចេះតែកើនឡើងនៃពាណិជ្ជកម្មក្រៅប្រទេស ។ ជារឿយៗ គេមិនទទួលឈ្មួញបរទេស ហើយរាល់មុខទំនិញដឹកជញ្ជូនលើសំពៅទាំងប៉ុន្មានតែងតែត្រូវគេពិនិត្យឆែកឆេរគ្រប់សព្វ ។ មុខទំនិញល្អបំផុត ត្រូវមន្ត្រីលោភលន់ដកហូត ។ នៅពេលដែលជនជាតិអង់គ្លេសបានតវ៉ាចំពោះសកម្មភាពដូចនេះ នៅឆ្នាំ ១៦៧២គេបានប្រាប់ពួកអង់គ្លេសនោះថា «ព្រះរាជាគឺជាព្រះរាជាតុងកឹង មុនពេលដែលពួកយើងបានមកដល់ និងបន្ទាប់ពីពេលដែលយើងបានចាកចេញទៅវិញផងដែរ ហើយប្រទេសរបស់ព្រះអង្គមិនត្រូវការនូវរបស់របរបរទេសណាមួយនោះទេ» (សេចក្តីសំរង់ក្នុង Farrington ១៩៩២) ។

វៀតណាម (ខាងជើង) អាចទទួលជោគជ័យក្នុងគន្លងនេះ ពីព្រោះតែប្រទេសនេះជាប្រទេសដែលមានប្រជាជនច្រើន និងអាចផ្គត់ផ្គង់ខ្លួនឯងក្នុងទ្រង់ទ្រាយធំបាន ហើយមានទីតាំងនៅដាច់ឆ្ងាយពីផ្លូវពាណិជកម្មអន្តរជាតិសំខាន់ៗជាងរដ្ឋអាស៊ីអាគ្នេយ៍ដទៃទៀត ។ ទោះជាយ៉ាងនេះក្តី ជ័យជម្នះផ្នែកយោធារបស់ប្រទេសនេះទៅលើរាជាណាចក្រចម្ប៉ាដែលនៅជាប់សមុទ្រ ជាពិសេសនៅឆ្នាំ ១៤៧១ បានផ្តល់លទ្ធភាពឲ្យជនជាតិវៀតណាមបានគ្រប់គ្រងតំបន់តាមបណ្តោយឆ្នេរសមុទ្រ ដែលតំបន់នេះធ្លាប់បានដើរតួនាទីស្នូលក្នុងវិស័យពាណិជ្ជកម្មអាស៊ីអស់រយៈពេលមួយសហសវត្សរ៍ ឬក៏លើសពីនេះទៀត ។ នៅពេលដែលក្រុមជនអាណានិគមវៀតណាមថ្មីបានបោះទីតាំងឈរជើងនៅទួង ហ្វា (Thuan Hao) និងគង់ ណាម (Quang Nam) ស្ទើរតែមិនទាន់ស្រួលបួលផងចំបាំង ក៏កើតឡើងរវាងតំបន់ខាងត្បូង និងខាងជើង ហើយមកទល់ឆ្នាំ១៦០០ជម្លោះបែកបាក់គ្នានេះកាន់តែមានសភាពធ្ងន់ធ្ងរមិនអាចផ្សះផ្សាបាន ។ កត្តារាជវង្ស និងកត្តាបុគ្គល ដើរតួមួយផ្នែកនាំទៅរកជំលោះនេះ (សូមមើលជំពូកទី ៤) ក៏ប៉ុន្តែគេមិនអាចមិនគិតដល់កត្តាតវិយាបថខុសប្លែកគ្នាយ៉ាងខ្លាំងរបស់រាជាណាចក្រខាងត្បូងចំពោះវិស័យជំនួញបានដែរ ។ គេបានកត់ត្រាអំពី ង្វៀន ហ័ង (Nguyen Hoang) ដែលជាស្ថាបនិកចុងក្រោយនៃរាជវង្សថ្មីមួយនៅតំបន់ខាងត្បូង ពេលដែលគេបញ្ជូនគាត់ជាលើកដំបូងនៅក្នុងឆ្នាំ ១៥៥៨ ឲ្យធ្វើជាចៅហ្វាយខេត្តនៃបណ្តាខេត្តភាគខាងត្បូងដ៏សម្បូរភោគទ្រព «គាត់ដឹកនាំអាណាខេត្តទាំងនេះដោយក្តីមិត្តភាពឈ្មួញទាំងឡាយរកស៊ីតាមផ្លូវសមុទ្រមានការស្រលាញ់រាប់អានគាត់...ឈ្មួញរកស៊ីតាមសមុទ្រធ្វើដំណើរពីគ្រប់រាជាណាចក្របរទេសទាំងឡាយមកទិញ និងលក់នូវរបស់របរផ្សេងៗ ដែលធ្វើឲ្យទីក្រុងជំនួញក៏កកើតឡើង» (សេចក្តីសំរង់ក្នុង Taylor ១៩៩៣: ៤៩) ។ ទីក្រុងដែលកើតឡើង

នេះ គឺឈ្មោះហ៊ុយ អាន (Hoi An) (ពួកអឺរ៉ុបហៅថា Faifo) ហើយនៅកន្លែងនេះជនជាតិជប៉ុន និងចិនបានមកផ្តុំគ្នាដើម្បីធ្វើជំនួញដូរទៅវិញទៅមក ហើយវៀតណាមជាបន្ទួចចំហសម្រាប់ពិភពលោកនៅក្នុងសម័យរាជាណាចក្រង្វៀន(Nguyen)ដែលពួកបស្ចិមប្រទេសហៅថាកូសាំងស៊ីននោះ ។ ព្រះរាជា ង្វៀន ហ័ង ផ្ទាល់បានគាំទ្រចំពោះវិស័យជំនួញដោយបានសរសេរសារលិខិតទៅកាន់ឈ្មួញជប៉ុនមួយចំនួន ដែលបានធ្វើជំនួញដូរនេះ បើទោះបីជាព្រះអង្គ គឺជាអ្នកកាន់លទ្ធិខុងជឺដែលគួរតែអះអាងថា ដែនដីរបស់ព្រះអង្គគឺជា «ទឹកដីនៃកំណាព្យប្រវត្តិសាស្ត្របៀបរបបល្អ និងយុត្តិធម៌ មិនមែនជាទឹកដីដែលកកកុញទៅដោយឈ្មួញ និងទំនិញនោះទេ» (Fujiwara Seika: ៣៤៨) ។

## ទីក្រុងកំពង់ផែ និងបណ្តាញពាណិជ្ជកម្ម

> ម៉ាឡាកាជាទីក្រុងបង្កើតឡើងសម្រាប់ជំនួញ ដែលមានលក្ខណៈសាកសម្បជាងទីក្រុងណាៗទាំងអស់នៅលើពិភពលោកយើងនេះ ។ វាក៏ជាទីក្រុងស្ថិតនៅគោលចុងក្រោយបំផុតនៃដំណើរខ្យល់មូសុង និងចំណុចផ្តើមនៃដំណើរខ្យល់ផ្សេងៗទៀត ។ ម៉ាឡាកាហ៊ុំព័ទ្ធ និងលាតសន្ធឹងនៅចំណុចកណ្តាល ហើយ ជំនួញជួញដូររវាងប្រជាជាតិផ្សេងៗ រាប់ពាន់យោជន៍ត្រូវតែធ្វើដំណើរមកកាន់ម៉ាឡាកា ។
>
> Pires ១៥១៥ : ២៨៦

មូស៊ីម (Musim) គឺជាពាក្យម៉ាឡេដែលមានន័យថា រដូវកាលជាបាតុភូតសាចុះសាឡើងដដែលជារៀងរាល់ឆ្នាំដែលក្នុងនោះខ្យល់ប្រចាំរដូវដែលកំណត់ឲ្យមានទឹកភ្លៀងធ្លាក់មានសារៈសំខាន់បំផុត ។ ពួកបស្ចិមប្រទេសបានហៅខ្យល់នេះថា ខ្យល់មូសុង ដើម្បីពិពណ៌នាអំពីប្រក្រតីភាពខុសប្លែកពីធម្មតាដែលពួកគេបានពើបប្រទះចំពោះខ្យល់នៅតំបន់អាស៊ីត្រូពិច ។ ចាប់ពីខែ មេសា ដល់ ខែ សីហា ខ្យល់មូសុងបក់សំដៅទៅទិសខាងជើង ឆ្ពោះទៅកាន់តំបន់ដីគោកអាស៊ី ហើយចាប់ពីខែធ្នូ ដល់ ខែមិនា វាបក់សំដៅទៅទិសខាងត្បូងវិញ ពីតំបន់ដីគោកអាស៊ីឆ្ពោះទៅកាន់មហាសមុទ្រឥណ្ឌា និងសមុទ្រចិនខាងត្បូង ។ ការអាចប៉ាន់ស្មានបាននេះហើយដែលជាអ្នកកំណត់នូវបែបផែននៃការធ្វើជំនួញតាមផ្លូវសមុទ្រក្នុងតំបន់អាស៊ី ។ ម្ចាស់នាវាព្យាយាមកាត់បន្ថយនូវគ្រោះថ្នាក់តាមផ្លូវសមុទ្រដោយការធ្វើដំណើរផ្លូវឆ្ងាយក្នុងពេលវេលាអំណោយផលតាមចរន្តខ្យល់បក់នេះ ហើយត្រឡប់មកវិញ ក្នុងរយៈពេលដែលខ្យល់មូសុងបក់ប្តូរទិសមកវិញក្នុងកំលុងឆ្នាំដដែល ។ ដោយសារមូលហេតុនេះហើយ បានជានាវាមិនមានបំពាក់នូវឧបករណ៍ឲ្យបានរឹងមាំសម្រាប់ការបញ្ឆោ និងបើកបរទល់ និងខ្យល់ៗ

នាវាចិន ជប៉ុន និងយ្យុកយ៉ុនដែលធ្វើដំណើរសំដៅទិសខាងត្បូងទៅកាន់តំបន់ណានយ៉ាង (Nanyang) តែងតែពឹងផ្អែកលើខ្យល់មូសុងខាងជើងនៅខែ មករា ឬក៏ខែកុម្ភៈ ហើយត្រឡប់ទៅកាន់កន្លែងដើមវិញនៅពេលដែលខ្យល់បក់មកពីទិសខាងត្បូងវិញនៅក្នុងខែមិថុនា កក្កដា ឬក៏សីហា ។ នាវាមកពីឥណ្ឌាខាងត្បូង យល់ឃើញថា ខ្យល់មូសុងនិរតីបក់ពីមហាសមុទ្រឥណ្ឌានៅរវាងខែមេសា និងសីហា គឺជាដំណើរខ្យល់ដែលអាចពឹងពាក់បានល្អបំផុតសម្រាប់ការធ្វើដំណើរសំដៅទៅកាន់ទិសខាងកើត ។ នាវាឥណ្ឌាទាំងនោះអាចត្រឡប់ទៅកាន់កន្លែងដើមវិញតាមដំណើរនៃខ្យល់មូសុងដដែល បន្ទាប់ពីការចតនៅគោលដៅរយៈពេលខ្លីរួចមក ប៉ុន្តែភាគច្រើន នាវាទាំងនោះនៅចតយូរដើម្បីធ្វើជំនួញនៅ «តំបន់ស្ថិតនៅខាងក្រោមចរន្តខ្យល់មូសុង» យ៉ាងហោចណាស់រហូតដល់ខែធ្នូ

ដែរ ដើម្បីជៀសវាងបម្រែបម្រួលខ្យល់មូសុងដែលអាចបង្កជាព្យុះស៊ីក្លូនបានក្នុងខែ តុលា ហើយនាវាទាំងនោះធ្វើដំណើរត្រឡប់មកកាន់កន្លែងដើមវិញតាមរយៈខ្យល់មូសុងខាងជើង (Arasaratnam ១៩៨៦: ៣៤–៣៧) ។

នាវាអុញ្ញាពាតិបានជួបប្រទះនូវការលំបាកជាច្រើនរួមទាំងចម្ងាយផ្លូវដ៏វែង ក្នុងការធ្វើដំណើរមកកាន់តំបន់អាស៊ីអាគ្នេយ៍ ។ រយៈកាលនៃខ្យល់មូសុងនិរតី គឺជាដំណាក់កាលដ៏ល្អបំផុតសម្រាប់ការធ្វើដំណើរមកកាន់កោះស៊ូម៉ាត្រា ឬក៏ម៉ាឡាយ៉ា កំប៉ុន្តែនាវាទាំងនេះអាចមានជម្រើសពីរ គឺថាអាចចាកចេញពីកំពង់ផែដើមនៅក្នុងខែ មិនានៅមុនពេលដែលខ្យល់នេះធ្វើឲ្យមានការបិទកំពង់ផែឥណ្ឌា ឬក៏អាចរង់ចាំរហូតដល់ ខែ សីហា ឬកញ្ញានៅពេលដែលគេបើកកំពង់ផែឡើងវិញ ។ នាវាអុញ្ញាពាតិតែងតែឃ្លាតចេញពីកំពង់ផែដើមយ៉ាងហោចណាស់ក៏រយៈពេលមួយឆ្នាំដែរ ដោយទៅចតនៅទីផ្សារនៅតំបន់អាស៊ីអាគ្នេយ៍ ដើម្បីរង់ចាំនូវការធ្វើដំណើរមកដល់របស់នាវាចិននៅក្នុងខែមករា ឬក៏កុម្ភៈ។

ដំណើរតាមផ្លូវសមុទ្រដោយផ្អែកតាមរដូវនេះ ធ្វើឲ្យមានការកកើតឡើងនូវកំពង់ផែនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលពួកឈ្មួញអាចស្នាក់នៅរង់ចាំនូវការផ្លាស់ប្តូរនៃដំណើរខ្យល់មូសុង ឬក៏ការធ្វើដំណើរមកដល់នៃដៃគូធ្វើជំនួញទាំងឡាយ ។ ទោះបីជាឈ្មួញនីមួយៗរួមទាំងទំនិញរបស់ខ្លួនអាចឃ្លាតទៅឆ្ងាយរយៈពេលរាប់ឆ្នាំដោយលើកទំនិញផ្លាស់ពីនាវាមួយទៅនាវាមួយរវាងទីក្រុងកៃរ៉ូ និងខេត្តគង់តុងក៏ដោយ ក៏នាវាអាស៊ីទាំងឡាយមិនបានធ្វើដំណើរផ្លូវឆ្ងាយៗដូចនេះទេ នៅសម័យពាណិជ្ជកម្ម ។ ម្ចាស់នាវាទាំងនេះចង់ឃើញពួកវាធ្វើដំណើរវិលត្រឡប់មកកាន់កំពង់ផែដើមវិញ នៅពេលដែលខ្យល់មូសុងបក់ត្រលប់មកវិញ ។ ក្នុងកំលុងពេលប៉ុន្មានខែនោះ កម្មករនាវា និងអ្នកធ្វើដំណើរតាមនាវាទាំងឡាយ បានចតសំរាកតាមនៅកំពង់ផែនានានៃតំបន់អាស៊ីអាគ្នេយ៍ ហើយពួកគេបានរស់នៅកកកុញនៅគ្រប់សង្កាត់ទាំងអស់នៃទីក្រុង ដោយធ្វើឲ្យទីផ្សារនានាមានភាពអ៊ូរអរស់រវើក និងថែមទាំងបានចូលរួមនៅក្នុងពិធីបុណ្យបែបសាសនាផ្សេងៗទៀតផង ។

កំពង់ផែសំខាន់ៗនៅតាមតំបន់ទាំងឡាយក្រោមដំណើរខ្យល់មូសុងចាំបាច់ត្រូវមានទីតាំងស្ថិតនៅឯចំណុចប្រសព្វនៃតំបន់ធ្វើជំនួញផ្អែកលើដំណើរខ្យល់មូសុងទាំងនេះ ដោយស្ថិតនៅតំបន់ជម្រកនៅសមុទ្រ អាន់ដាម៉ាន់ (Andaman) ឈូងសមុទ្រថៃ និងសមុទ្រជ្វា ហើយជាពិសេសគឺនៅច្រកសមុទ្រម៉ាឡាក់កា (Malacca) ។ សិលាចារឹក និងកំណត់ត្រាចិនបានអះអាងថា ហ្វូណន (មានកំពង់ផែអូកែវដ៏ធំនៅដែនដីសន្ដទន្លេមេគង្គ) ចម្ប៉ា និងស្រីវិជ័យបានដើរតួនាទីនេះជាបន្តបន្ទាប់នៅប្រមាណមួយពាន់ឆ្នាំដំបូង ។ ចម្ប៉ា និងស្រីជ័យគឺមានភាសានៅក្នុងក្រុមអូស្ត្រូអាស៊ី ដូច្នេះហើយ បានជាធ្វើឲ្យភាសាម៉ាឡេក្លាយជាភាសាសម្រាប់ទំនាក់ទំនងជំនួញនាសម័យពាណិជ្ជកម្មនោះ ។ នៅក្នុងសតវត្សរ៍ទី ១៥ ប៉ាសៃ (ស៊ូម៉ាត្រាខាងជើង) និង ម៉ាឡាកា បានក្លាយជាកំពង់ផែពាណិជ្ជកម្មអន្តរជាតិដ៏សំខាន់ ហើយការដែលពួកគេផ្តល់នូវសន្តិសុខល្អនៅតាមច្រកសមុទ្រនេះជួយកាត់បន្ថយនូវតម្រូវការនៃថ្លៃដឹកជញ្ជូនដ៏លំបាកឆ្លងកាត់ឧបទ្វីបម៉ាឡេ ។ ការវាយដណ្តើមកាន់កាប់ក្រុងកំពង់ផែម៉ាឡាការបស់ពួកព័រទុយហ្កាល់នៅក្នុងឆ្នាំ ១៥១១ ហើយនិង ការប៉ុនប៉ងជាបន្តបន្ទាប់របស់ពួកគេដើម្បីគ្រប់គ្រងច្រកសមុទ្រនេះ ជាហេតុបណ្តាលឲ្យការធ្វើជំនួញប្តូរទៅតាមផ្លូវផ្សេង ដោយអ្នកធ្វើដំណើរតាមរទេះឆ្លងកាត់ឧបទ្វីប ឬក៏ធ្វើដំណើរចុះតាមតំបន់ឆ្នេរស៊ូម៉ាត្រាខាងលិចឆ្ពោះទៅកាន់ច្រកសមុទ្រស៊ុនដា (Sunda) វិញ ។ ការផ្លាស់ប្តូរផ្លូវធ្វើដំណើរនេះបាននាំឲ្យកើតមាននូវទីក្រុងកំពង់ផែថ្មីៗ ឬក៏អាចពង្រីកទីក្រុងកំពង់ផែដែលមានស្រាប់នៅអាចេះ, តេណាសីរីម, អយុធ្យា, ប៉ាតានី, ប៉ាហាំង, ចូហូរ, ប៉ាន់តង់, ឲ្យមានដំណើរការដែរ ។ ទីក្រុងម៉ានីល ម៉ាកាសសា ប្រ៊ុយណេ កម្ពុជា ចម្ប៉ានិងកំពង់

ផែរបស់ស្ដេចផ្សៀន នៅហ៊ុយ អាន ក្នុងសតវត្សរ៍ទី ១៧ ស្ថិតនៅឆ្ងាយពេកនាទិសខាងកើតជាហេតុធ្វើឲ្យនាវាឥណ្ឌាពិបាកទៅដល់ ប៉ុន្តែតំបន់ទាំងនោះបានក្លាយជាទីក្រុងកំពង់ផែពាណិជ្ជកម្មអន្តរជាតិដ៏សំខាន់សម្រាប់ការធ្វើជំនួញរវាងអ្នកធ្វើជំនួញតាមនាវា ដែលមានដូចជាពួកចិន ជប៉ុន អាស៊ីអាគ្នេយ៍ និងអឺរ៉ុប ។ បន្ទាប់ពីរយៈកាលមួយសតវត្សរ៍កន្លះដែលមានជនជាតិចំរុះជាតិសាសន៍ច្រើនមករស់នៅប្រមូលផ្ដុំគ្នាមក កំពង់ផែបាតាវៀ (Batavia) ដែលគ្រប់គ្រងដោយហូឡង់នៅប្រហែលឆ្នាំ ១៦៥០ បានចាប់ផ្ដើមដើរតួយ៉ាងសំខាន់នៅក្នុងវិស័យជំនួញអន្តរអាស៊ីដូចគ្នានិងអ្វីដែលម៉ាឡាកាធ្លាប់មានកាលពីឆ្នាំ ១៥០០ ដែរ ។

ប្រសិនបើតម្រូវការរបស់ឈ្មួញបរទេសទាំងឡាយ ជាកត្តាចម្បងកំណត់នូវទីតាំងនៃកំពង់ផែអស់ទាំងនេះ កំពង់ផែទាំងនោះ ក៏បានបង្កើតយ៉ាងឆាប់រហ័សនូវនាវាផ្ទាល់ខ្លួន សម្រាប់ធ្វើការដឹកជញ្ជូន ដែលមានលក្ខណៈស្រដៀងគ្នា និងនាវាបរទេសផងដែរ ។ ដំណើរធ្វើជំនួញតាមផ្លូវសមុទ្ររបស់វីរបុរស ហាំង តួ (Hang Tuah) នៅក្នុងវីរកថាម៉ាឡេពីម៉ាឡាកាទៅកាន់ប្រទេសឥណ្ឌាភាគខាងត្បូង និងប្រទេសចិនភាគខាងត្បូង គឺមិនមែនជារឿងប្រឌិតទេ ។ ហើយជនជាតិព័រទុយហ្គាល់ក៏បានកត់សម្គាល់ផងដែរថា ដំណើរតាមផ្លូវសមុទ្រឆ្ងាយៗទាំងនេះ គឺមានជារៀងរាល់ឆ្នាំនៅម៉ាឡាកា ដោយបានបរិយាយថា៖ «ម៉ាឡាកាបានបញ្ជូនសំពៅជាច្រើនចេញទៅ ហើយសំពៅផ្សេងទៀតក៏ធ្វើដំណើរចូលមក» (Pires 1515: 285; cf. ibid.: 93; Thomaz 1986: 13) ។ នៅប្រមាណឆ្នាំ ១៥០៤ នៅពេលដែលលុដូវីកូ ឌី វ៉ាធីម៉ា (Ludovico di Varthema 1510: 151) ស្ថិតនៅក្រុងកាលីកុ (Calicut) (ម៉ាឡាបា(Malabar) នៃប្រទេសឥណ្ឌាភាគខាងត្បូង) គាត់បានប្រទះឃើញនូវឈ្មួញចំរុះជាតិសាសន៍ជាច្រើននៅទីនោះដែរ «ឈ្មួញខ្លះមកពីពេគូ...និងឈ្មួញភាគច្រើនទៀតមកពីស៊ូម៉ាត្រា [ប៉ាសៃ]» ។ នៅពាក់កណ្ដាលទី ២ នៃសតវត្សរ៍ទី ១៦ ឈ្មួញដែលមានមូលដ្ឋាននៅអាចេបានបញ្ជូននាវារបស់ខ្លួនដែលផ្ទុកទៅដោយម្រេចជាច្រើនគ្រឿងឆ្ពោះទៅកាន់សមុទ្រក្រហម ហើយឆ្នាំ ១៦២០ ស្ដេចស៊ុលតង់បានបញ្ជាឲ្យគេកសាងនាវាមួយដ៏ធំដើម្បីបន្តសកម្មភាពជំនួញនេះតទៅទៀត (Coen 1621:607; Boxer 1969: 418-24)។ គេក៏បានរាយការណ៍ឲ្យដឹងផងដែរថា នាវាដែលសាងសង់ឡើងតាមគំរូឥណ្ឌា «ជាកម្មសិទ្ធិរបស់ពួកម៉ាឡេ»នៅអាចេបានធ្វើដំណើរត្រឡប់មកពីការធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌាភាគខាងត្បូងនៅក្នុងទសវត្សរ៍ឆ្នាំ ១៦៣០ (Compos tel 1636: f. 1198) ។ នៅពាក់កណ្ដាលសតវត្សរ៍ទី ១៦ ព្រះរាជានៃទីក្រុងអាចេ អយុធ្យា បង់តេន និងម៉ាកាសសារបានបញ្ជូននាវារបស់ព្រះអង្គក្នុងដំណើរផ្លូវឆ្ងាយឆ្ពោះទៅកាន់ទីក្រុងម៉ានីល ប្រទេសជប៉ុន និងប្រទេសឥណ្ឌាភាគខាងត្បូង ។

បេសកកម្មនាំសួយសារអាករទៅកាន់ប្រទេសចិន បានផ្ដល់ជាមូលដ្ឋានបណ្ដុះបណ្ដាលមួយសម្រាប់នាវិកអាស៊ីអាគ្នេយ៍ក្នុងដំណើរឆ្ពោះទៅកាន់ខេត្តគង់តុង ។ មិនមានចម្ងល់ទេ គេក៏បានរួមបញ្ចូលជនជាតិចិនដែលមានទីលំនៅក្នុងស្រុកទៅក្នុងបេសកកម្មទាំងនេះផងដែរ ពីព្រោះថាចំណេះដឹងរបស់ពួកគេផ្នែកភាសា និងបែបបទផ្សេងៗរបស់ប្រទេសចិន គឺមានសារៈប្រយោជន៍យ៉ាងខ្លាំង ។ ជាធម្មតា គេបញ្ជូនបេសកជនខ្លះតាមរយៈនាវាចិនដែលធ្វើដំណើរត្រឡប់មកវិញ ប៉ុន្តែដោយសារតែអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្មនៃដំណើរតាមផ្លូវសមុទ្រអស់ទាំងនេះ បានធ្វើឲ្យរដ្ឋភាគច្រើនបញ្ជូននាវាផ្ទាល់ខ្លួន ដែលមានដឹកទំនិញក្នុងស្រុក ហើយនិងនាវិកចំរុះទៅកាន់ខេត្តគង់តុង ។ ជនជាតិផ្សេងៗ មិនមែនចិនដែលមានចំនួនកាន់តែច្រើនឡើងៗបានទៅដល់មិនត្រឹមតែខេត្តគង់តុងប៉ុណ្ណោះទេ តែក៏បានទៅដល់ទីក្រុងប៉េកាំងផងដែរ ។ ករណីនេះបានឆ្លុះឲ្យឃើញតាមរយៈការចាប់អារម្មណ៍របស់ចិននៅក្នុងការិយាល័យបកប្រែភាសាផ្លូវការប្រចាំទីក្រុងប៉េកាំង ចំពោះភាសាអាស៊ីអាគ្នេយ៍ដោយការបង្កើតឲ្យមាន

នៅទីនោះនៅឆ្នាំ ១៥៧៩ នូវផ្នែកពិសេសសម្រាប់បកប្រែភាសាថៃ (Ishii ១៩៨៩: ៣) ។

ដូច្នេះលំហូររបស់នាវាដែលផ្អែកតាមរដូវខ្យល់មូសុងឆ្លងកាត់តំបន់និមួយៗនៃផ្លូវធ្វើជំនួញតំបន់អាស៊ី គឺរួមមានទាំងនាវាដែលមានមូលដ្ឋាននៅចុងសងខាងនៃផ្លូវធ្វើដំណើរ ។ ចំពោះម៉ាឡាកាវិញ គេបានប៉ាន់ប្រមាណថាក្នុងចំណោមសំពៅធ្វើដំណើរឆ្លងកាត់មហាសមុទ្រមួយរយគ្រឿង ដែលចតនៅកំពង់ផែនេះក្នុងកំលុងពេលរដូវធ្វើជំនួញដ៏មមាញឹកនោះ យ៉ាងហោចណាស់ក៏មានសំពៅចំនួន ៣០គ្រឿងដែរជាកម្មសិទ្ធិរបស់មេដឹកនាំ និងឈ្មួញនៃទីក្រុងនេះផ្ទាល់ ហើយសំពៅដទៃទៀត គឺជាសំពៅដែលធ្វើដំណើរមកពីប្រទេសឥណ្ឌា ចិន ពេគូ ជ្វា និងតំបន់ផ្សេងៗទៀត (Araujo ១៥១០: ២២) ។ បើទោះជាកំពង់ផែនៅតំបន់អាស៊ីអាគ្នេយ៍សំខាន់ៗទាំងប៉ុន្មានដើរតួយ៉ាងសកម្មក្នុងវិស័យជំនួញអន្តរជាតិក៏ដោយ ក៏មិនមែនមានន័យថា ប្រជាជាតិ និងជាតិសាសន៍សំខាន់ៗទាំងអស់នៃតំបន់នេះដើរតួយ៉ាងសកម្មនោះដែរ ។ ជាទូទៅគេចាត់ទុក ជាតិពិន្ទុមួយចំនួនដូចជាម៉ាឡេ, មីណាងកុបុ (Minangkabau), ជ្វា, ចាម, លូហ្សុន, ពេរូ និងចិន ទៅក្នុងក្រុមអ្នកធ្វើជំនួញនៅអាស៊ីអាគ្នេយ៍ដូចមានការរៀបរាប់ជាបន្តបន្ទាប់ខាងក្រោមនេះ ។ នៅត្រង់ចំណុចនេះវាសំខាន់ណាស់ក្នុងការយល់ថាទីក្រុងជំនួញនៅអាស៊ីអាគ្នេយ៍ គឺជាចំណុចជួបគ្នានៃមនុស្សចំរុះជាតិសាសន៍មកពីគ្រប់តំបន់ជាប់មាត់សមុទ្រនៅអាស៊ី ។

ជនជាតិហូឡង់បានរៀបរាប់អំពីឈ្មួញចំរុះជាតិសាសន៍ទាំងឡាយ ដែលបានពាក់ទាក់ស្វាគមន៍ពួកគេ នៅទីក្រុងបង់តេនក្នុងឆ្នាំ ១៥៩៦ ថា៖ ពួកពែរ (Persians) ដែលនៅជ្វាគេហៅថាខូរ៉ាសាស៍ (Khorasans) នោះគឺជាអ្នកប្រកបរបរចិញ្ចឹមជីវិតដោយការលក់ដូរនូវត្បូងមានតម្លៃ និងឱសថផ្សេងៗ... ពួកអារ៉ាប់ និង ពេគូ គឺជាអ្នកដែលភាគច្រើនធ្វើជំនួញតាមផ្លូវសមុទ្រ ដោយការដឹកជញ្ជូនទំនិញទៅវិញទៅមកពីទីក្រុងមួយទៅទីក្រុងមួយទៀត ហើយទិញទំនិញចិនក្នុងបរិមាណយ៉ាងច្រើនមកវិញ ដើម្បីដោះដូរជាមួយនឹងទំនិញមកពីតំបន់ដីកោះជុំវិញ ហើយនិងដូរម្រេចផងដែរ ដើម្បីយកទៅលក់ឲ្យពួកជនជាតិចិននៅពេលដែលគេធ្វើដំណើរមកទិញនូវរបស់ទាំងនោះ ។ ពួកម៉ាឡេ និងក្លីង(ពួកឥណ្ឌាខាងត្បូង) ជាឈ្មួញដែលវិនិយោគដោយការចងការប្រាក់ និងវិនិយោគទុនទៅក្នុងការដឹកជញ្ជូនតាមសមុទ្រ និងសម្រាប់ម្ចាស់នាវាដែលដាក់នាវាបញ្ចាំ ។ ពួកអញ្ញាពាតិសដោយសារតែភាពក្រីក្រជាធម្មតាត្រូវគេប្រើឲ្យធ្វើជាកម្មករនាវា ហើយពួកនោះអាចរកចំណូលបានពីម្ចាស់នាវាដែលដាក់នាវាបញ្ចាំ ពីម្តងពីរដង ទៅបីដង(លូដូវីស្គស៍–Lodewycksz ១៥៩៨: ១២០–២១) ។

ប្រសិនបើជំនួញផ្លូវឆ្ងាយពីប្រទេសចិន ឥណ្ឌា និងគ្រឿងទេសរបស់ម៉ាលុកាន់ នាំមកនូវភាពចំរុះគ្នានេះ ជាលទ្ធផលវាធ្វើឲ្យវិស័យជំនួញក្នុងស្រុកកាន់តែមានភាពមមាញឹកឡើង នៅក្នុងការផ្គត់ផ្គង់នូវចំណីអាហារ សម្ភារៈសំណង់ និងរបស់របរក្នុងស្រុក ដល់ទីក្រុងកំពង់ផែទាំងនេះ ។ ចរាចរដឹកជញ្ជូនទំនិញភាគច្រើន ប្រព្រឹត្តិទៅតាមរយៈនាវាអាស៊ីអាគ្នេយ៍តូចៗដោយ

– ដឹកមកនូវអង្ករ បន្លែបង្កា ត្រីងៀត បសុសត្វ ទឹកត្នោតជូរ ស្ករ និងអំបិល ដើម្បីផ្គត់ផ្គង់តំបន់ទីក្រុង និងកសិដ្ឋានដាំដំណាំសម្រាប់លក់

– ដឹកជញ្ជូននូវគ្រឿងលោហៈ កុលលាភាជន៍ និង ក្រណាត់ ពីអ្នកផលិតទៅកាន់អ្នកប្រើប្រាស់

– ប្រមូលនូវទំនិញសម្រាប់ការនាំចេញទាំងឡាយ និង

– ចែកចាយបន្តនូវទំនិញដែលបាននាំចូល ។

អ្នកដែលផ្តល់សេវាកម្មដល់បណ្តាញតាមផ្លូវសមុទ្រដ៏ធំល្វឹងល្វើយក្នុងដែនសមុទ្រ ដ៏ស្ងប់ស្ងាត់របស់តំបន់

*អាស៊ីអាគ្នេយ៍ គឺភាគច្រើនបំផុតជាម្ចាស់ស្រុក ។ ពួកគេបង្កើតបានជាសរសៃឈាម ដែលភ្ជាប់ទីក្រុងទៅនឹងតំបន់ខាងក្នុងឆ្ងាយៗជាប់នឹងមាត់ទឹក ហើយទៅវិញទៅមកនាំនូវទេសន្រ្ទះផ្សេងៗ មនុស្សម្នា និងទំនិញទាំងឡាយ ។*

## វិសាលភាពនៃក្រុង

*ប្រហែលជាក្នុងឆ្នាំ ១៩០០ ពេលដែលគេធ្វើជំរឿនប្រជាជនតាមបែបទំនើបជាលើកដំបូងបង្អស់ បណ្តាប្រទេសអាណានិគមនៅអាស៊ីអាគ្នេយ៍ ស្ថិតក្នុងចំណោមប្រទេសមានការរីកចម្រើនទីក្រុងតិចតួចបំផុតនៅលើពិភពលោក*[១]*។ ជាទូទៅគេសន្និដ្ឋានថា ការរីកចម្រើននៃទីក្រុងដ៏ឆាប់រហ័សចាប់តាំងពីការទទួលបានឯករាជ្យមក គឺជាដំណើរវិវឌ្ឍន៍ថ្មីមួយនៅក្នុងតំបន់ជនបទ «បុរាណនេះ» ។ ទោះជាយ៉ាងនេះក្តី មានភស្តុតាងជាច្រើនបញ្ជាក់ថាអាណានិគមនេះឯង គឺជាមូលហេតុចម្បងដែលធ្វើឲ្យមានប្រជាជនអាស៊ីអាគ្នេយ៍តិចតួចណាស់រស់នៅក្នុងទីក្រុងនៅ ស.វ មុនឆ្នាំ ១៩៤០ ។ ភីតឋឺ ប៊ូមហ្គាន (*Peter Boomgaard *១៩៨៩ : ១១) បានចង្អុលបង្ហាញថា ប្រទេសជ្វា ដែលនៅទីនោះបានទទួលរងនូវឥទ្ធិពលអាណានិគមខ្លាំងក្លាជាងគេនោះ សមាមាត្រប្រជាជនដែលរស់នៅតាមទីប្រជុំជនដែលមានចំនួនជាងពីរម៉ឺននាក់បានថយចុះក្នុងកំលុងសតវត្សរ៍ទី ១៩ ពីប្រមាណ ៧% ក្នុងឆ្នាំ ១៨១៥ មក ៣% ក្នុងឆ្នាំ ១៨៩០ ។*

*មូលហេតុគឺថា ទីក្រុងដែលស្ថិតក្រោមអាណានិគមអឺរ៉ុប គឺជាការប្រមូលផ្តុំកោះ ដែលគ្រប់គ្រងវិស័យពាណិជ្ជកម្មរបស់តំបន់ ដោយមិនបានលើកទឹកចិត្ត (ឬពេលខ្លះអនុញ្ញាតិឲ្យជនជាតិអាស៊ីទាំងឡាយ បានធ្វើដំណើរមកកាន់កោះទាំងនេះ ដើម្បីធ្វើជំនួញឡើយ ។ ពេលដែលមណ្ឌលពាណិជ្ជកម្មសំខាន់ៗស្ថិតក្រោមការគ្រប់គ្រងរបស់ជនជាតិអាស៊ី មណ្ឌលទាំងនេះបានទាក់ទាញយ៉ាងច្រើនសន្ធឹកសន្ធាប់នូវពួកវណ្ណៈអភិជន និងអ្នកបម្រើការនៅវាំង ក្រុមពាណិជ្ជករបច្ចេកទេសផ្សេងៗ អ្នករៀនសូត្រសាសនា អ្នកដើរលក់ដូរតវ៉ាន់ សិល្បករ និងពលករ ។ ចំណុចទាំងនេះអាចបញ្ជាក់បានយ៉ាងច្បាស់ តាមរយៈតំបន់ដែលគេចផុតពីការធ្វើអាណានិគម ។ យោងតាមជំរឿនប្រជាជនឆ្នាំ ១៩០៩ ទីក្រុងបាងកកមានប្រជាជនសរុបស្មើនឹង ១០% នៃចំនួនប្រជាជនសរុបក្នុងប្រទេសថៃទាំងមូល ហើយប្រហែលជាមិនតិចជាងនេះច្រើនទេក្នុងកំលុងពេលមួយសតវត្សរ៍ទី ១៩ បើទោះជាពេលនោះ វិស័យពាណិជ្ជកម្មរបស់ទីក្រុងនេះមានលក្ខណៈធម្មតាក៏ដោយ (ដកស្រង់ពីស្គីននឺរ –* Skinner *១៩៥៧ : ៦៨–៨៧)។ បើយោងតាមការរាប់ចំនួនប្រជាជនឆ្នាំ ១៧៨៣ រាជធានីភូមា (នៅអមរាបុរៈ (*Amerapura*) ដែលលាតដល់សាហ្គែ (*Sagaing*) នៅត្រើយម្ខាងទន្លេ) មានប្រជាជនស្មើនឹង ១០% នៃចំនួនប្រជាជនភូមាសរុប ហើយចំនួននេះបានកើនដល់ ១៣% ក្នុងឆ្នាំ ១៨០២ (*Koe *និង ១៩៩០ : ៥៩) ។ បើប្រៀបនឹងមណ្ឌលពាណិជ្ជកម្មនៃបណ្តាប្រទេសអាស៊ីដែលជណ្តើមបានការគ្រប់គ្រងដំណើរការសេដ្ឋកិច្ចទីក្រុងស្ថិតក្រោមអាណានិគមមានទំហំតូចជាងឆ្ងាយណាស់ ។ មកទល់នឹងសតវត្សរ៍ទី ១៩ ក្រុង* Batavia *ដែលគ្រប់គ្រងដោយហូឡង់មិន មានប្រជាជនលើសចំនួនប្រជាជនក្នុងរាជធានីចាស់របស់ជ្វានៅយ៉កយ៉ាកាតា (*Yogyakarta*) និងសុរ៉ាកាតា (*Surakarta*) ទេ ។ ហើយចំណែកឯទីក្រុងរង់ហ្គូនវិញមានទំហំធំជាងរាជធានីភូមាបុរាណ(នៅម៉ាន់ដាឡេ) តែបន្តិចប៉ុណ្ណោះ បើយោងតាមជំរឿនឆ្នាំ ១៨៩១ ។*

*បន្ទាប់ពីមណ្ឌលពាណិជ្ជកម្មត្រូវត្រាដោយពួកអង់គ្លេសគ្រប់គ្រងផ្នែកពាណិជ្ជកម្ម និងនយោបាយនៅរយៈពេលដ៏យូរក្នុងប្រទេសនាពេលនោះ ប្រជាជននៅវានជាលាយ មានចំនួន ១៧០.០០០ នាក់ បានថយចុះមកនៅត្រឹមតែ ១៣៥.០០០ នាក់ ក្នុងឆ្នាំ ១៩៣១ នៅក្រោមការគ្រប់គ្រងរបស់ពួកអង់គ្លេស ។*

| តារាងលេខ ៦.ការប៉ាន់ស្មានចំនួនប្រជាជនរស់នៅក្នុងទីក្រុងនាសតវត្សរ៍ទី ១៦ | | | |
|---|---|---|---|
| | | ការប៉ាន់ស្មាន | ចំនួនប្រជាជន ប្រហាក់ប្រហែលa |
| អយុធ្យា | ១៥៤០ | ផ្ទះ ៤០០,000 ខ្នង (Pinto 1578: 420) | ៤,៦០០,000 |
| | ១៥៤៥ | ផ្ទះ/ផះ ១០,០៥០ ខ្នង(Luang Prasoet: 10) | >១០០,000 |
| ពេគូ | ១៥៤០ | ផ្ទះ ៤០០,000 ខ្នង (Pinto 1578: 362) | |
| | ១៥៩៦ | «មនុស្សប្រុស»b ១៥០,០០០ នាក់ (du Jarric 1608 I: 624) | |
| ម៉ាឡាកា | ១៥១០ | ផ្ទះ ១០,000 ខ្នង (Araujo 1510: 21) | ៦៥,000 |
| | | ទាហាន ៤០០០ នាក់ (ibid: 21) | ១៦,000 |
| | | ផ្ទះ ៣០,000 ខ្នង (Castanheda)c | ១៩៥,000 |
| | | ស្មើនឹងទីក្រុងប៉ាសៃ ១០ ដង (Pires 1515: 144) | ២០០,000 |
| | | ប្រជាជន ១០០,000 នាក់ (Albuquerque.1557:.84) | ១០០,000 |
| | | ទាហាន ២០,000 នាក់ (ibid.: 99) | ៨០,000 |
| | | ប្រជាជន ២០០,000 នាក់នៅវេលាដែលមានមនុស្សច្រើនបំផុត (Correia: 284)c | <២០០,000 |
| | | ប្រជាជន ១៩០,000 នាក់ (Sejarah Melayu 1612: 181; 1831: 247) | ១៩០,000 |
| | | ប្រជាជន ៩០,000 នាក់ គិតតែក្នុងទីក្រុង (Sejarah Melayu 1612: 180) | ៩០,000 |
| ប៉ាសៃ | ១៥១២ | ប្រជាជន ២០,000 នាក់ (Pires 1515: 143) | ២០,000 |
| | ១៥១៨ | អ្នកយាម ៣០០០ នាក់ (Barros 1563 III, v: 522-23) | >១២,000 |
| ប្រ៊ុយណេ | ១៥២១ | ផ្ទះ ២៥,000 ខ្នង (Pigafetta 1524: 58) | ១៦២,000 |
| | | ផ្ទះ ២០,000 ខ្នង (Maximilian 1522: 301) | ១៣០,000 |
| | ១៥៧៩ | ចំណាប់ខ្មាំង ៤-៥០០០ នាក់ (de Sande 1579: 126) | >១៨,000 |
| | ១៥៨០s | អ្នកបង់ពន្ធអាករ ៨០០០ នាក់ (Dasmariňas.1590B) | ៣២,000 |
| ដឺម៉ាក់ | ១៥១២ | ផ្ទះ ៨-១០,000 ខ្នង (Pires 1515: 184) | ៥៨,៥០០ |
| | | ទាហាន ៣០,000 នាក់ (ibid.: 185) | ១២០,000 |
| ហ្គ្រេស៊ីក | ១៥១២ | «មនុស្សប្រុស» ៦-៧០០០ នាក់ (ibid.: 194) | >២៥,000 |

កំណត់សម្គាល់ ៖

- A នៅក្នុងតារាងលេខ ៦ និង លេខ ៧ កូឡោនចុងក្រោយនេះបានមកដោយការប្រើនូវកត្តា ៦,៥ ដើម្បីប្តូរចំនួនខ្នងផ្ទះ និង កត្តា ៤ ដើម្បីប្តូរចំនួនទាហាន ។ ជំរឿនប្រជាជនដែលធ្វើឡើងដោយពួកហូឡង់នៅទីក្រុងម៉ាឡាកានាឆ្នាំ ១៦៧៨ បានបង្ហាញថាមានប្រជាជនចំនួន ៤៨៨៤ នាក់ រស់នៅក្នុង «ផ្ទះថ្ម ១៥០ ខ្នង និង ៥៨៣ ខ្នង ធ្វើពីatap (ស្បូវ)» ឬក៏យើងអាចនិយាយម៉្យាងទៀតបានថា មានដង់ស៊ីតេប្រជាជនចំនួន ៦,៧ នាក់ ក្នុងផ្ទះមួយខ្នងក៏ដូចជាអ្នកបម្រើរបស់ក្រុមហ៊ុនហូឡង់ ២១៩ នាក់ នៅក្នុងអត្រា ៤,៦ នាក់ ក្នុងផ្ទះមួយខ្នង (van Goens១៦៧៩:២៨១)។ ទីក្រុងនៅអាស៊ីប្រហែលជាមានអត្រាប្រជាជនក្នុង «មួយខ្នងផ្ទះ» ខ្ពស់ជាងនេះព្រោះដោយសារតែមានបរិវេណរស់នៅធំៗរបស់ពួកអភិជន ក៏ដូចជាមាននូវកំពែងការពារព្រះរាជវាំងផ្ទាល់ផងដែរដែលអាចផ្ទុកមនុស្សបានច្រើន ។

- B ចំនួនដែលគួរអោយកត់សម្គាល់នេះសំដៅទៅដល់មនុស្សដែលការពារទីក្រុងក្នុងពេលដែលមានសត្រូវឡោមព័ទ្ធ ដូច្នេះហើយវាមិនមែនជាតំណាងអោយចំនួនប្រជាជននៅពេលធម្មតាទេ ។

- Cខ្ញុំបានទទួលសេចក្តីយោងទាំងនេះពី Thomaz១៩៩៣ : ៧១ n

*មកទល់នឹងសតវត្សរ៍ទី ១៧ ជាទូទៅទីក្រុងនៅអាស៊ីមានទំហំធំជាងទីក្រុងនៅអឺរ៉ុប ដោយក្នុងនោះ ទីក្រុងប៉េកាំង និងអេដូ (តូក្យូ) មានប្រជាជនមួយលាននាក់រស់នៅប្រហែលជាឆ្នាំ ១៦០០ ។ បើតាមស្គីននឺរ (១៩៧៧: ២៨-៣០) ដែលបង្ហាញពីប្រទេសចិន(ស្មីត – Smith ១៩៨៨: ១៧-១៨) ពីប្រទេសជប៉ុន និង (ហាប៊ី – Habib ១៩៨២: ១៦៧-៧១) និង(បេលី – Bayly១៩៨៣: ១១២-១៣) ពីប្រទេសឥណ្ឌា បានបង្ហាញឲ្យឃើញថា មានការថយចុះគួរឲ្យកត់សម្គាល់នូវចំនួនប្រជាជននៅតាមទីប្រជុំជនធំៗ នៅរវាង ស.វទី ១៧ និងទី ១៩ ។ ចំពោះតំបន់អាស៊ីអាគ្នេយ៍ដែលទទួលរងនូវអនុត្តរភាពវិស័យពាណិជ្ជកម្មពីពួកអឺរ៉ុបដោយផ្ទាល់ជាងនេះមុននោះ គេមិនមានការភ្ញាក់ផ្អើលទេដែលឃើញថា ទីក្រុងទាំងឡាយមានទំហំធំនៅឆ្នាំ ១៦០០ ជាងនៅឆ្នាំ ១៨៥០ ។*

*នៅមុនសម័យទំនើប គេមិនឃើញមានបញ្ជីជំរឿនប្រជាជនរស់នៅក្នុងទីក្រុងដែលអាចយកជាការបាននោះទេ លើកលែងបញ្ជីរបស់ជនជាតិអឺរ៉ុបតែប៉ុណ្ណោះ ។ ជារឿយៗ ការប៉ាន់ប្រមាណធ្វើឡើងដោយអ្នកទេសចរផ្អែកលើការរាប់ត្រួសៗនូវចំនួនផ្ទះ ឬក៏ការអះអាងរបស់អាជ្ញាធរមូលដ្ឋានអំពីទាហានដែលបានកេណ្ឌចេញពីទីក្រុង និងតំបន់ជាយក្រុង ។ បន្ថែមពីលើនេះទៀត យើងអាចសង្កេតអំពីវិសាលភាពផ្ទៃក្រឡាបវត្តរបស់ទីក្រុងនៅពេលដែលមានមនុស្សច្រើនបំផុត ទីក្រុងអាចផ្តល់នូវការគ្រប់គ្រងបានល្អចំពោះភាពអាចទុកចិត្តបានចំពោះការប៉ាន់ប្រមាណទាំងនោះ ។*

*ចំពោះការប៉ាន់ប្រមាណនូវចំនួនប្រជាជនក្នុងសតវត្សរ៍ទី ១៦ ដែលបង្ហាញក្នុងតារាងលេខ ៦ មានតែការលើកឡើងរបស់ភីនតូ (Pinto) ទេ ដែលគេមិនអាចជឿបានទាំងស្រុង ។ គេគួរតែយល់ថាគាត់បានអះអាងថា អយុធ្យា និងពេគូ គឺជាទីក្រុងដ៏ធំ ។ នៅកន្លែងទៀតនៃការរៀបរាប់របស់គាត់ភីនតូ (១៥៧៨: ២១៨) បានបង្ហាញនូវបញ្ជីរាជធានីធំៗ ចំនួន ១៨ នៅអាស៊ីដែលរាជធានីទាំងអស់នេះមានទំហំតូចជាងរាជធានីប៉េកាំង ។ ក្នុងនោះរាជធានីចំនួន ៨ ស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ មានដូចជា រាជធានី ដឹម៉ាក់ និងប៉ាស្សួន នៅប្រទេសជ្វា ពេគូ អាវ៉ា និងម៉ាតាបាននៅភូមា «យូសាង "Uzangue"» នៅវៀតណាម អយុធ្យា និងលួងប្រាបាង។ គេក៏មានការមន្ទិលសង្ស័យផងដែរ ចំពោះការប៉ាន់ប្រមាណចំពោះទំហំរបស់ប្រទេសប្រ៊ុយណេនៅក្នុងការធ្វើដំណើររបស់ Magellan ។ យើងអាចទទួលស្គាល់បានថា នៅមុនការចូលលុកលុយរបស់ពួកអេស្ប៉ាញនៅឆ្នាំ ១៥៧៩ ប្រ៊ុយណេមានទំហំធំជាងទ្រង់*

ទ្រាយរបស់ខ្លួននារយៈកាល ៣ សតវត្សរ៍ ក្រោយមកដោយសារថា នៅមុននោះវា គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្មរបស់ ប៉ីរ៉េណោអូ និងហ្វីលីពីន ប៉ុន្តែវិសាលភាពផ្ទៃក្របវ័ន្តរបស់ប្រ៊ុយណេហាក់ដូចជាមិនអាចបញ្ជាក់ឲ្យបានត្រឹមត្រូវថាប្រទេសនេះមានប្រជាជនលើសពី ៥ ម៉ឺននាក់នោះទេ ។ ផ្ទុយទៅវិញចំពោះទីក្រុងម៉ាឡាកា គេឃើញមានការប្រាននទោលការប៉ាន់ស្មានបន្ថែមជាច្រើនទៀតហើយយើងឃើញថា ទាំងពាណិជ្ជកម្ម ការនាំចូលអង្ករ និងវិសាលភាពផ្ទៃក្របវ័ន្តរបស់ម៉ាឡាកាបានបញ្ជាក់យ៉ាងច្បាស់ចំពោះចំណុចនេះ ។ បើតាមប្រវត្តិសាស្ត្រម៉ាឡេ គឺថាមានលំនៅស្ថានជាប់ៗគ្នានៅតាមបណ្តោយឆ្នេរពីខាងជើងម៉ាឡាកាហូតដល់ទន្លេមួរ ដែលមានប្រវែងប្រហែល ៤៥ គីឡូម៉ែត្រ ។ (Sejarah Melayu ១៦១២ : ១៨១, ១៨៣១ : ២៤៧) ។

ទោះបីជាគ្មាននូវការប៉ាន់ស្មានអំពីរាជធានីថាំងឡុង (ហាណូយ) នៃប្រទេសវៀតណាមនាសតវត្សរ៍ទី ១៦ ក៏ដោយ ក៏កស្តុតាងផ្ទៃក្របវ័ន្តរួម និងប្រពៃណីផងដែរ បានបង្ហាញពីការធ្លាក់ចុះបន្តិចម្តងៗនៃទីក្រុងនេះពីការរីកចម្រើនដល់កំពូលនាចុងសតវត្សរ៍ទី ១៥ ។ ដោយសារតែថាំងឡុងនៅតែមានទំហំដ៏ធំសតវត្សរ៍ទី ១៧ ទីក្រុងនេះក៏ប្រហែលជាទីក្រុងដែលធំជាងគេបង្អស់នៅអាស៊ីអាគ្នេយ៍នាសតវត្សរ៍ទី ១៦ ផងដែរដោយមានប្រជាជនប្រហែលជាជាង ១០០.០០០ នាក់ ។ យើងក៏អាចចាត់អយុធ្យា (មុនពេលដែលភូមាបានចូលមកលុកលុយបំផ្លិចបំផ្លាញក្នុងឆ្នាំ១៥៦៧) និង ពេគូ ចូលក្នុងចំណាត់ថ្នាក់រាជធានីដែលមានប្រជាជនចំនួន ១០០.០០០ នាក់ដែរ ហើយម៉ាឡាកាក៏ដូច្នេះផងដែរ នៅក្នុងដំណាក់ដ៏ខ្ទីមួយ (ប្រហែលពីឆ្នាំ ១៤៧០–១៥១១) នៅក្នុងកំលុងពេលដែលទីក្រុងនេះ គឺជាទីក្រុងកំពង់ផែដ៏មានអនុភាពជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ ។ ដឺម៉ាក់ ដែលនៅពេលនោះ ជាទីក្រុងកំពង់ផែដ៏សំខាន់របស់ជ្វាអាចមានប្រជាជនប្រហែលពី ៦០.០០០ នាក់ ទៅ ៨០.០០០ នាក់ រីឯ ប្រ៊ុយណេ ហ្គ្រីស៊ីក និងប៉ាសៃ វិញប្រហែលជាមានប្រជាជនប្រហែលជាពាក់កណ្តាលនៃប្រជាជននៅដឺម៉ាក់ តែប៉ុណ្ណោះ ។ ចំពោះទីក្រុងនៅឆ្ងាយពីមាត់សមុទ្រមួយចំនួនដូចជា អាវ៉ា លួងប្រាបាង្គ វៀងច័ន្ទ និងឈៀងម៉ៃ គេពិបាកក្នុងការធ្វើការប៉ាន់ប្រមាណនូវចំនួនប្រជាជនក្នុងកំលុងពេលនោះណាស់ ។

មិនមានអ្វីជាមន្ទិលទេដំណាក់កាលរីកចម្រើនពាណិជ្ជកម្មដល់កំពូលនៅចន្លោះឆ្នាំ ១៥៧០–១៦៣០ បាននាំឲ្យមាននូវការរីកចម្រើនផ្នែកនគរូបនីយកម្មច្រើនគួរសម ដោយគេឃើញមាននូវការរីកលូតលាស់នៃទីក្រុងដែលមានស្រាប់មួយចំនួន និងការកើតឡើងនូវទីក្រុងថ្មីៗផងដែរ (តារាងលេខ ៧) ។ គេអាចធ្វើការពិនិត្យពិច័យទៅលើការប៉ាន់ប្រមាណមិនមានលក្ខណៈច្បាស់លាស់ផ្សេងៗនាសតវត្សរ៍ទី ១៧ តាមរយៈវិសាលភាពផ្ទៃក្របវ័ន្តនៃទីក្រុងអស់ទាំងនេះ ដែលគេអាចសន្និដ្ឋានបានតាមរយៈការបរិយាយបច្ចុប្បន្ន និងការធ្វើកំណាយសម័យទំនើប (តារាងលេខ ៨) ។ ក្នុងករណីភាគច្រើន គេអាចមើលឃើញនូវបន្ទាយការពារព្រះរាជវាំងសាងសង់ឡើងយ៉ាងច្បាស់លាស់ ដែលព័ទ្ធជុំវិញដោយតំបន់ជាយក្រុងដែលមានទ្រង់ទ្រាយមិនច្បាស់លាស់ហើយនៅតាមតំបន់ជាយក្រុងទាំងនោះគេឃើញមានការតាំងលំនៅរបស់សហគមន៍ពាណិជ្ជករបរទេស និងប្រជាជនដែលរសាត់អណ្តែតមកពីតំបន់ជនបទ ហើយជារឿយៗ ក៏ជាបរិវេណរស់នៅរបស់បណ្តាពួកអភិជនជាន់ខ្ពស់ ។ នៅប្រទេសសៀម និងភូមា ប្រជាជនរស់នៅក្នុងទីក្រុងដែលមានកំពែងការពារប្រហែលជាមានចំនួនស្មើនឹងពាក់កណ្តាល ឬក៏ច្រើនជាងនេះនៃចំនួនប្រជាជនសរុបក្នុងទីក្រុងទាំងមូល ។ ផ្ទុយទៅវិញ នៅតាមប្រជុំកោះនានាជារឿយៗ គេមិនឃើញមានកំពែងការពារទេ លើកលែងតែនៅជុំវិញបន្ទាយការពារព្រះរាជវាំង (ក្រាតុង ឬគ្គូតា)តែប៉ុណ្ណោះ ។ ចំណែកឯនៅប្រទេសវៀតណាម និងឡាវវិញ គេឃើញមានទាំងបន្ទាយការពារព្រះរាជវាំងនៅខាងក្នុង និងទាំងកំពែងការ

ពារពីខាងក្រៅ ដែលក្តោបស្ទើរតែទាំងមូលនៃតំបន់ប្រជុំជន ។

បន្ទេរការប៉ាន់ស្មានចំនួនប្រជាជនពីកន្លែងដែលពួកគេរស់នៅ គឺមានការលំបាកដោយសារតែលក្ខណៈមិនទៀងទាត់នៃស្ថានភាពលំនៅដ្ឋានទាំងនេះ ។ ជារឿយៗ ផ្ទះដែលនៅក្បែរតំបន់ឆ្នេរ តំបន់កំពង់ផែ ទីផ្សារ និងវិហារសាសនាសំខាន់ៗ សង់ឡើងកៀកៗគ្នាណែនណាន់តាន់តាប់ រីឯនៅកន្លែងដទៃទៀត ប្រជាជនរស់នៅរាយប៉ាយនៅតាមភូមិដាច់ៗគ្នា ដាសដាងនៅតាមតំបន់ទីក្រុងដែលមានទ្រង់ទ្រាយកំណត់ច្បាស់លាស់ ។ តំបន់ដែលមានមនុស្សរស់នៅកកកុញច្រើន អាចមានផ្ទះប្រហែលជា ៣ ពាន់ខ្នង (ឬក៏ប្រជាជនប្រហែលពីរម៉ឺននាក់) ក្នុងមួយគីឡូម៉ែត្រការ៉េ ចំណែកឯតំបន់ក្នុងក្រុងទាំងមូល ប្រហែលជាមានដង់ស៊ីតេប្រជាជនមិនលើសពីពាក់កណ្តាលនៃចំនួនខាងលើនេះទេ[២] ។

**តារាងលេខ ៧.ការប៉ាន់ស្មានចំនួនប្រជាជនក្នុងទីក្រុងនាសតវត្សរ៍ទី ១៧**

| | | **ការប៉ាន់ស្មាន** | **ចំនួនប្រជាជនប្រហាក់ប្រហែល** |
|---|---|---|---|
| ថាំងឡុង | ១៦៤០<br>១៦៨៨ | «ច្រើនស្មើនឹងមួយលាននាក់» (Rhodes 1651: 26)<br>ផ្ទះ ២០,០០០ ខ្នង (Dampier 1699: 36) | ១,០០០,០០០<br>១៣០,០០០ |
| គឹមឡុង | ១៦៧៤ | ១៥០,០០០ (de Courtelin, in Nguyen 1970: 120) | ១៥០,០០០ |
| វ៉េ | ១៧៤៩ | ៦០,០០០ (Poivre 1750: 97) | ៦០,០០០ |
| ភ្នំពេញ | ១៦០៦ | ផ្ទះ ២០,០០០ ខ្នង (Jaque, in Groslier 1958: 152) | ១៣០,០០០ |
| ស្រីសន្ធ | ១៦០០ | «ច្រើនជាង ៥០,០០០» (San Antonio 1604: 95) | > ៥០,០០០ |
| អយុធ្យា | ១៦១៧<br>១៦៨១<br>១៦៨៦<br>១៦៨៧ | «ធំដូចទីក្រុងឡុងដ៍» (Anderson 1890: 69)<br>ក្មេង ១០,០០០ នាក់ ស្លាប់ក្នុងមួយឆ្នាំ (Noguettes 1685: 71)<br>២០០,០០០ (Tachard 1688: 190)<br>ទាហាន ៦០,០០០ នាក់ (Gervaise 1688: 47)<br>ជនបរទេស ១៦,០០០ នាក់ (La Loubère 1691: 112) | ២០០,០០០<br>> ២០០,០០០<br>២០០,០០០<br>២៤០,០០០<br>៣០,០០០ |
| អាវ៉ា | ១៦៨៨ | «ធំដូចទីក្រុងរ៉េម» (Goüye 1692: 73) | ៣០,០០០ |
| ស៊ីរៀម | ១៦៨៨ | «ធំដូចទីក្រុងម៉េតស៍» (ibid.: 73) | ២៥,០០០ |
| ព្រំ | ១៦៨៨ | «ធំដូចទីក្រុងស៊ីលៀម» (ibid.: 73) | ២៥,០០០ |
| ប៉ាហ្កូន | ១៦៨៨ | «ធំដូចទីក្រុងឌីចន» (ibid.: 73) | ៣០,០០០ |

| តារាងលេខ ៧. ការប៉ាន់ស្មានចំនួនប្រជាជនក្នុងទីក្រុងនាសតវត្សរ៍ទី ១៧ (ត) | | | |
|---|---|---|---|
| | | ការប៉ាន់ស្មាន | ចំនួនប្រជាជន ប្រហាក់ប្រហែល |
| ប៉ាតានី | ១៦០២ | ៤-៥០០០ នាក់ ក្នុងក្បួនជង្កែ (van Neck 1604: 226) | ២០,០០០ |
| | ១៦៩០ | ១០-២០,០០០ នាក់ (Tosen 1690 in Ishii ដែលបោះពុម្ពក្នុងពេលឆាប់ៗ) | ១៥,០០០ |
| ប៉ាហាំង | ១៦១៨ | ១១,០០០ នាក់ គេណ្ឌយកដោយអាចេះ (van den Broecke 1634 I: 177) | >១២,០០០ |
| ចូហរ | ១៦០៤ | ទាហាន ៤០០០ នាក់ (Mandelslo 1662: 108) | ១៦,០០០ |
| ប្រ៊ុយណេ | ១៦០៨ | ផ្ទះអណ្តែតទឹក ២-៣០០០ ខ្នង (van Noort 1601: 202) | ១៦,២០០ |
| អាចេះ | ១៦០២ | ផ្ទះផែះ ៧-៨០០ ខ្នង (Lancaster 1603: 133) | >១០,០០០ |
| | ១៦២១ | ទាហាន ៤០,០០០ នាក់ (Beaulieu 1666: 106) | ១៦០,០០០ |
| | ១៦៨៨ | ផ្ទះ ៧-៨០០០ ខ្នង (Dampier 1699: 90) | >៤៨,៧០០ |
| ប៉ាហ្គារូយ៉ុង | ១៦៨៤ | មនុស្ស ៨០០០ នាក់ បើគិតតែអ្នកនៅក្នុងព្រះរាជវាំង (Dias 1684: 355) | ៣២,០០០ |
| បង់តេន | ១៦៧២ | «ច្រើនជាង ១០០,០០០ នាក់» (Missions Etrangères 1680: 90) | >១០០,០០០ |
| | ១៦៧៣ | ទាហាន ៥៥,០០០ នាក់ (VOC, in Guillot 1989: 150) | ២២០,០០០ |
| | ១៦៧៤ | ទាហាន ២០០,០០០ នាក់ (Cortemünde 5: 122) | ៨០០,០០០ |
| | ១៦៨៤ | ៧០០,០០០ (Fryke 1692: 80) | ៧០០,០០០ |
| | ១៦៩៦ | «មនុស្ស ៣១,៨៤៨ នៅ Surasowan» (Pigeaud 1968: 64) | ១២៥,០០០ |
| ហ្សាកាតារ | ១៥៩៦ | ផ្ទះ ៣០០០ ខ្នង (Lodewycksz 1598: 163) | ២០,០០០ |
| | ១៦០៦ | ទាហាន ៤០០០ នាក់ (Matelief 1608: 53) | ១៦,០០០ |
| | ១៦១៨ | ទាហាន ៦-៧០០០ នាក់ (van den Broecke 1634 I: 187) | ២៦,០០០ |
| មាតារាម | ១៦២៤ | ទាហាន ២០០,០០០ នាក់ (de Haen 1623: 35) | ៨០០,០០០ |
| ស៊ីមាវាំង | ១៦៥៤ | ១០០,០០០ (van Goens 1656: 205) | ១០០,០០០ |
| ហ្សាប៉ារ៉ា | ១៦៥៤ | ១០០,០០០ (van Goens 1656: 268) | ១០០,០០០ |
| ទូបង់ | ១៦០០ | ទាហាន ៣២-៣៣,៥០០ នាក់ ("Tweede Boeck" 1601: 184) | ១៣០,០០០ |
| ស៊ូរ៉ាបាយ៉ា | ១៦២៥ | ៥០-៦០,០០០ (VOC, in Meilink-Roelofsz 1962: 270) | >៥០,០០០ |
| ម៉ាកាសារ | ១៦១៤ | ផ្ទះផែះ ១២៦០ ខ្នង (EIC, G/10/1:5) | >២០,០០០ |
| | ១៦១៥ | ទាហាន ១៦,០០០ នាក់ (EIC, G/10/1:9) | ៦៤,០០០ |
| | ១៦៣៦ | ៦០,០០០ នាក់ ស្លាប់ដោយសារអាសន្នរោគ (EIC, G/10/1: 73) | >១០០,០០០ |
| | ១៦៦០ | ទាហាន ១៦០,០០០ នាក់ (Gervaise 1701: 60) | ៦៤០,០០០ |

*នៅពេលដែលយើងច្របាញ់បញ្ចូលគ្នានូវសក្ខីភាពនៃទំហំប្រហាក់ប្រហែលនេះជាមួយ នឹងការប៉ាន់ប្រមាណបច្ចុប្បន្ននូវចំនួនប្រជាជន យើងអាចទាញនូវសេចក្ដីសន្និដ្ឋានយ៉ាងច្បាស់ថា ទីក្រុងដែលធំជាងគេបង្អស់ គឺទីក្រុងថាំងឡុង អយុធ្យា និង ម៉ាតារ៉ាមដែលនៅពាក់កណ្ដាល ស.វ ទី ១៧ មានចំនួនប្រជាជនប្រហែលចាប់ពី ១៥០.០០០ ទៅ ២០០.០០០ នាក់ (ដូចដែលក្រុងពេគូធ្លាប់មានមុនពេលទទួលរងនូវការបំផ្លិចបំផ្លាញក្នុងឆ្នាំ ១៥៩៧) ។ ទីក្រុងអាចេ ម៉ាកាសសារ បង់តេន និង រាជធានីគីមឡុងនៃដែនដីកូសាំងស៊ីនប្រហែលជាទីក្រុងស្ថិតក្នុងលំដាប់ថ្នាក់បន្ទាប់ពីទីក្រុងធំនៅក្នុងដំណាក់កាលដែលទីក្រុងទាំងនេះមានប្រជាជនច្រើនបំផុតនាពាក់កណ្ដាលសតវត្សរ៍ទី ១៧ ដោយមានប្រជាជនជិត ១០០.០០០ នាក់ ។ ទីក្រុងផ្សេងៗទៀតនៅតាមតំបន់មាត់សមុទ្រភាគខាងជើងនៃប្រទេសជ្វា មានការប្រែប្រួលឡើងចុះនូវជោគវាសនាយ៉ាងរហ័ស នៅក្នុងកំលុងពេលសតវត្សរ៍នេះ ប៉ុន្ដែចំពោះទុយបង់ និង ស៊ុរ៉ាបាយ៉ា វិញ នាពេលនោះប្រហែលជាមានប្រជាជនរហូតដល់ ៥០.០០០ នាក់ ។* Mrauk-u *(រាជធានីរបស់អារ៉ាកាន) ប៉ាតានី វៀងចន្ទ័ និងភ្នំពេញក៏ប្រហែលជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទីក្រុងដែលមានប្រជាជនរវាងពី ២០.០០០ទៅ ៥០.០០០ នាក់ ហើយ ប្រហែលជាក្បែរនឹង ៥០.០០០ នាក់ ។ ការប្ដូររាជធានីរបស់ភូមាទៅកាន់អាវ៉ា វិញនៅឆ្នាំ ១៦៣៤ បានបណ្ដាលឲ្យទីក្រុងនេះរីកចម្រើនជាលំដាប់ ហើយមកទល់នឹងឆ្នាំ ១៧០០ ទីក្រុងនេះប្រហែលជាមានប្រជាជនរហូតដល់ ៥០.០០០ នាក់ ។ ទីក្រុងដែលបានរៀបរាប់ទាំងប៉ុន្មាននេះ ប្រហែលជាទីក្រុងដំបូងដែលធំជាងគេបង្អស់លំដាប់ទី ១៣ ។*

*តំបន់ដែលគ្រប់គ្រងដោយជនជាតិអឺរ៉ុបមានបណ្ដាញពាណិជ្ជកម្មទូលំទូលាយ និងសំណង់អាគារធ្វើអំពីថ្មរឹងមាំជាច្រើន ក៏ប៉ុន្ដែតំបន់ទាំងនេះមិនមែនជាតំបន់ដែលមានទីក្រុងធំជាងគេបង្អស់នោះទេ ។ បរិវេណទីក្រុងបាតាវៀបានកើនចំនួនប្រជាជនរហូតដល់ប្រហែលជា ៣០.០០០ នាក់រស់នៅទាំងក្នុង និងក្រៅកំពែងនៅឆ្នាំ ១៦៣០ ហើយនៅក្នុងឆ្នាំ ១៦៧០ ចំនួនដដែលនេះ បានកើនឡើងដល់កំពូលរហូតដល់ ១៣០.០០០ នាក់* (Hageman *១៨៥៩ : ៣៦៤,* Blussé *១៩៨៦ : ៨៤-៨៥) ។ ទីក្រុងម៉ានីលមានប្រជាជនប្រហែល ៤០.០០០ នាក់នៅពេលទីក្រុងនេះមានការរីកចម្រើនដល់កំពូលនាឆ្នាំ ១៦៣០* (Phelan *១៩៥៩ : ១៧៨) ។ នៅមុនឆ្នាំ ១៦៤១ ពេលដែលទីក្រុងម៉ាឡាកានៅជាទីបញ្ជាការរបស់ព័រទុយហ្កាល់ ទីក្រុងនេះមានប្រជាជនប្រហែលជា ១២.០០០ នាក់* (Mandelslo *១៦៦២ : ១០៦) ហើយចំនួននេះនៅសល់តែ ៥.០០០ នាក់នៅពេលដែលស្ថិតនៅក្រោមការត្រួតត្រារបស់ហូឡង់ ក្រោយមកទៀត ។*

*ការកំណត់នូវចំនួនប្រជាជនសរុបក្នុងទីក្រុងទាំងនេះមានលក្ខណៈរឹតតែលំបាកជាងការប៉ាន់ស្មានទំហំទីក្រុងទាំងនេះ ព្រោះថាទីក្រុងទាំងនេះមានចំនួនប្រជាជនកើនឡើងច្រើនក្នុងដំណាក់កាលខុសៗគ្នា ហើយពេលខ្លះទីក្រុងខ្លះមានចំនួនប្រជាជនកើនឡើងច្រើននៅពេលដែលទីក្រុងខ្លះទៀតមានប្រជាជនតិច ។ ទោះជាយ៉ាងនេះក្ដី សូម្បីតែការគណនាបន្ថែមត្រួសៗក៏ដោយ យ៉ាងច្រើនអាចផ្ដល់ត្រឹមតែចំនួនប្រជាជនសរុបលើសពីមួយលាននាក់នៅក្នុងទីក្រុងណាដែលមានប្រជាជនលើសពី ៣០.០០០ នាក់ក្នុងកំលុងពាក់កណ្ដាលសតវត្សរ៍ទី ១៧ តែប៉ុណ្ណោះ ។ ដូច្នេះហើយប្រជាជនអាស៊ីអាគ្នេយ៍ប្រហែលជា ៥% នៃចំនួនប្រជាជនសរុបរស់នៅតាមទីក្រុងធំៗ ដែលជាសមាមាត្រមួយច្រើនជាងតំបន់អឺរ៉ុបខាងជើង* (de Vries *. ១៩៧៦ : ១៥៤) ទោះបីជាប្រហែលមិនច្រើនដូចមុះហ្គោលឥណ្ឌា ឬក៏ប្រទេសចិនក៏ដោយ* (Habib *១៩៨២ : ១៦៩; ស្គីននឺរ ១៩៧៧ : ២៨) ។*

| តារាងលេខ ៨. ទំហំប្រហាក់ប្រហែលនៃតំបន់ទីក្រុងនាសតវត្សរ៍ទី ១៧ | | | |
|---|---|---|---|
| | ផ្ទៃក្រឡាកំពែងព្រះរាជវាំង ឬតំបន់ដែលមានកំពែងការពារ (km$^2$) | ផ្ទៃក្រឡាប្រហាក់ប្រហែលនៃតំបន់ទីក្រុង (km$^2$) | ប្រភពព័ត៌មាន |
| ថាំងឡុង | 0.4 | 5.6×4 = 22 | Hanoi 1977: 40-46 nigEpnTI |
| វៀងច័ន្ទ | 0.3 | 4×0.8 = 3.2 | Lajonquière 1901: 100-01 |
| ឈៀងម៉ៃ | 3.8 | 5 | Wijeyewardene 1985: 86; 1986: 6 |
| អយុធ្យា | 3.6×2 = 7.2 | 15 | Sternstein 1965 |
| ពេគូ ស.វ ១៦ | 5.8a | 15 | Symes 1827 I: 214; Frederici 1581: 244-45 |
| ម្រោវ-អ៊ូ | 0.4 | 7 | Collis 1943: 174-75 |
| ប៉ាតានី | 0.1 | 5×0.4 = 2b | Welch and McNeill 1989: 38; Bougas 1988: 15-16 |
| អាចេ | 0.2 | 12 | ENI 1893-1905 II: 321 |
| បង់តេន | 1.0 | 5 | Scott 1606: 169; Guillot 1989 |
| មាតារ៉ាម | 0.4 | 7.5×5.5 = 41c | Van Goens 1656: 66, 212-15; Nurhadi and Armeini 1978: 17 |
| ម៉ាកាសារ | 0.8+0.8+0.2d | 10×0.6 = 6 | Reid 1983: 140-50; Bulbeck 1992: 351-72 |

កំណត់សម្គាល់ ៖

a នេះជាការប៉ាន់ស្មានរបស់ខ្ញុំចំពោះកំពែងការពារទីក្រុងថ្មីរបស់ស្តេច បាយីណងដែលជាមណ្ឌលរាជវាំងនៅរវាងឆ្នាំ ១៥៦៦-៩៩ ចំណែកឯទីក្រុងកំពែងចាស់របស់ទីក្រុងពេគូវិញទុកសំរាប់ការធ្វើពាណិជ្ជកម្ម ហើយវាមានតំបន់ជាយក្រុងយ៉ាងធំ ។

b. វើលច៍ និងម៉ាក់នេល បានកំណត់នូវតំបន់សម្បូរដោយបំណែកក្អមឆ្នាំងផ្សេងៗថាមានផ្ទៃក្រឡាតែ ៩០ ha ប៉ុណ្ណោះ ប៉ុន្តែបើតាមការរៀបរាប់របស់ពួកគេអំពីទីតាំងនោះ ក៏ដូចគ្នានឹងការរៀបរាប់របស់បូហ្គាស ផងដែរ បានបង្ហាញអោយឃើញថា វាជាតំបន់ដ៏ធំមួយលាតសន្ធឹង ៥ គីឡូម៉ែត្រតាមបណ្តោយឆ្នេរសមុទ្រ ។ ខ្ញុំបានសម្រេចចិត្តរើសយកការប៉ាន់ស្មានទំហំ ដោយសន្មត់ថាតំបន់តូចៗក្នុងបរិវេណតំបន់នេះទទួលរងការ

គ្រប់គ្រងក្នុងរយៈកាលដ៏យូរ ប៉ុន្តែតំបន់នៅតាមបណ្តោយឆ្នេរសមុទ្រទាំងមូលទទួលរងការគ្រប់គ្រងអស់រយៈកាលកន្លះសតវត្សរ៍បន្ទាប់ពីឆ្នាំ ១៥៩០ នៅពេលដែលទីក្រុងមានការរីកចម្រើន ដោយនៅពេលនោះហ៊ីកាយ៉ាត ប៉ាតានី (១១៣) បានធ្វើការកត់សម្គាល់ថា ឆ្មាអាចដើរឆ្លងកាត់តាមដំបូលផ្ទះនីមួយៗដោយមិនចាំបាច់ចុះលើដី ទេ ក្នុងចម្ងាយប្រហែល ២,៥ គីឡូម៉ែត្រ ហើយនៅពេលដែលវ៉ាន់ និក (១៦០៤ : ២២២) បានគិតថាទីក្រុងលាតសន្ធឹងតាមបណ្តោយឆ្នេរក្នុងចម្ងាយកន្លះម៉ាយអាល្លឺម៉ង់ ។

c. ផែនទីរបស់ Van Goen អំពីទីក្រុងម៉ាតារ៉ាមបានបង្ហាញអំពីទីក្រុងដែលមានទំហំលាតសន្ធឹងមិនធម្មតាសម្របទៅតាមបំលាស់ទីបន្តបន្ទាប់នៃ គរាតៀន(កំពែងការពារព្រះរាជវាំង) ពីកុតា ហេរ្សូរ ទៅ Kerta រហូតដល់ Plered ។

d. ទីក្រុងម៉ាកាសសារ គឺជាទីក្រុង និង រដ្ឋ ស្មុគ្រស្មាញមួយ ដោយមានមណ្ឌលរាជវាំងដ៏រឹងមាំ ៣ កន្លែង គឺនៅហ្គូវ៉ា តាលូ និងសំបៅភូ ។

*គេនៅតែមានការលំបាកក្នុងការកំណត់នូវចំនួនប្រជាជននៅតាមទីក្រុងតូចៗ និងតាមទីប្រជុំជននានានៅតាមតំបន់ផ្សេងៗទៀតនៅអាស៊ីអាគ្នេយ៍ ។ ដោយសំអាងទៅលើការប៉ាន់ស្មាននូវចំនួនប្រជាជនដែលយើងមាន និងតួនាទីសេដ្ឋកិច្ច និងនយោបាយរបស់ទីក្រុងទាំងឡាយដែលមិនទាន់មានការប៉ាន់ស្មានចំនួនប្រជាជន យើងមិនអាចនិយាយឲ្យបានច្រើនក្រៅអំពីថា ទីក្រុងដូចរៀបរាប់តទៅនេះប្រហែលជាមានប្រជាជនលើសពី ១០.០០០ នាក់ (សូមមើលផែនទីលេខ ៥)៖*

- *ប្រូម ប៉ាហ្គន ទួនហ្គូ ស៊ីរៀម (នៅក្បែរទីក្រុងរ៉ង់ហ្គូន) តាវូយ និងម៉ារ់តាបង់ ក្នុងប្រទេសភូមា*[៣]
- *តេណាស់សេរីម ឈៀងម៉ៃ លប់បូរី និងនគរស៊ីថាមម៉ារ៉ាត់ (លីហ្គ័រ) ក្នុងប្រទេសសៀម*
- *លួងប្រាបាង្គនៅភាគខាងជើងប្រទេសឡាវ*
- *រាជធានីលង្វែករបស់ប្រទេសកម្ពុជា*
- *កំពង់ផែហ័រអាន នៃតំបន់កូសាំងស៊ីន*
- *ចូហរ និងប៉ាហាង (រហូតដល់ការចូលមកលុកលុយដោយអាចេក្នុងឆ្នាំ ១៦១៨) នៅឧបទ្វីបម៉ាឡេ*
- *ប៉ាឡេមបាង ចមប៊ី និងរាជធានីមីណាងកាបាវនៅឯប៉ាហ្គារ៍រុយយ៉ុង នៅកោះស៊ូម៉ាត្រា*
- *បង់ចារ៍ម៉ាស៊ីន និងប្រ៊ុយណេ នៅកោះប៊ រណេអូ*
- *ចាប៉ារ៉ា សេម៉ារាំង និងបាឡាំបាន់ហ្គាន់នៅប្រទេសជ្វា*
- *រាជធានីបាលី នៅឯហ្គេលហ្គេលនិង*
- *រាជធានីម៉ាហ្គីនដាណាវរបស់ស៊ុលតង់ (គេនិយាយថា មានចំនួនមនុស្សប្រុស ៣៦.៥០០ នាក់ ជាប់កាតព្វកិច្ច (Laarhoven ១៩៨៩: ១១២) ។*

*ប្រសិនបើភាគរយនៃអ្នករស់នៅទីក្រុងមានកម្រិតខ្ពស់នៅក្នុងតំបន់ទាំងមូល វាក៏មានភាគរយខ្ពស់ជាងដែរនៅតាមតំបន់ទាំងឡាយដែលមានពាណិជ្ជកម្មខ្លាំងក្លានៅជុំវិញច្រកសមុទ្រម៉ាឡាក់កា (Malacca)។ នៅឧបទ្វីបម៉ាឡេទាំងមូលយើងមានការលំបាកក្នុងការរំពឹងទុកថាចំនួនប្រជាជនអាចមានចំនួនលើសពីកន្លះលាននាក់ណាស់ ព្រោះថាវាមិនអាចមានចំនួនច្រើនជាងចំនួនប្រជាជននៅដើមសតវត្សរ៍ទី ១៩ ទេ (Reid ១៩៨៧) ។ នេះមានន័យថា ទីក្រុងម៉ាឡាកាតែឯងដែលជាទីផ្សារពាណិជ្ជកម្មធំដែលមិនមានតំបន់កសិកម្មជាប់ស្រយាលមានប្រជាជនយ៉ាង*

ហោចណាស់ក៏ ២០% ដែរ នៃចំនួនប្រជាជនឧបទ្វីបសរុបនៅកំលុងឆ្នាំ ១៥០០ ។ ហើយចំណែកឯ ប៉ាតានី ប៉ាហាង ចូហរ និងម៉ាឡាកា ដែលត្រួតត្រាដោយពួកព័រទុយហ្គាល់រួមគ្នាទាំងអស់នៅឆ្នាំ ១៦០០ មានសមាមាត្រប្រជាជនស្រដៀងគ្នា និងម៉ាឡាកាដែរ ។ គេដាហ៍ (Kedah) ដែលបានក្លាយជាកំពង់ផែតូចសំខាន់មួយនៅដើមសតវត្សរ៍ទី ១៨ ត្រូវបានគេជឿថាមានប្រជាជនពី ៧.០០០ ទៅ ៨.០០០ នាក់ រស់នៅក្នុងទីក្រុងធៀបទៅនឹងប្រជាជនសរុបចំនួនតែ ២០.០០០ នាក់ប៉ុណ្ណោះ រស់នៅក្នុង ប្រទេសទាំងមូល (Taillandier ១៧១១ : ៤០៩) ។ ចំណែកទីក្រុងអាចេ តេន និងប្រ៊ុយណេវិញពេលដែលមានចំនួនប្រជាជនខ្ពស់បំផុត ប្រហែលជាមានប្រជាជនយ៉ាងហោចណាស់កំមួយភាគប្រាំនៃប្រជាជនសរុបដែរស្ថិតក្រោមការគ្រប់គ្រងរបស់ទីក្រុងទាំងនោះផ្ទាល់ ។

នគរូបនីយកម្មអាចមានការរីកចម្រើនខ្ពស់ប្រសើរបាននាពេលនោះ ក៏ដោយសារតែភាពប្រសើរនៃបរិស្ថាននៅអាស៊ីអាគ្នេយ៍ ផ្អែកលើមូលដ្ឋាន ៣ យ៉ាង ។ ទីមួយ (កត្តារួមរបស់បណ្តាប្រទេសនៅអាស៊ីដែលទទួលឥទ្ធិពលខ្យល់មូសុងទាំងអស់) ដោយសារតែបច្ចេកវិទ្យាសមស្រប វាមានលក្ខណៈងាយស្រួលក្នុងការផ្តល់នូវបរិមាណស្រូវដ៏ច្រើនលើសតម្រូវការទីផ្សារ ជាជាងការផ្តល់នូវស្រូវសាលី និងសាច់ ។ ទីពីរ គ្រប់តំបន់ទីក្រុងទាំងអស់ លើកលែងតែម៉ាតារ៉ាមចេញ (ដូចជាអាវ៉ា និងថាំងឡុង ស្ថិតនៅចំតំបន់បង្កបង្កើនទិន្នផលស្រូវបានខ្ពស់) មានលក្ខណៈអាចធ្វើឲ្យគេធ្វើដំណើរចេញចូលបានដោយងាយតាមរយៈផ្លូវទឹក ដែលជាមធ្យោបាយងាយស្រួលប្រសើរជាងផ្លូវរទេះនៅដែនដីគោកដ៏ធំល្ហល្ហេវនោះ ។ ហើយទីបី បើប្រៀបធៀបជាមួយវិស័យដទៃទៀត វិស័យជំនួញបានដើរតួនាទីដ៏ធំនៅក្នុងខឿនសេដ្ឋកិច្ចទាំងមូលរបស់តំបន់ភាគច្រើននៅអាស៊ីអាគ្នេយ៍ ។ ទីក្រុងកំពង់ផែទាំងនេះគឺមិនមែនជាបញ្ញើក្អែក ដែលត្រូវស្រូបយកផលិតផលលើសតម្រូវការពីតំបន់ឆ្ងាយៗនោះទេ ។ ទីក្រុងកំពង់ផែទាំងនោះបានបង្កើតទ្រព្យធនរបស់ខ្លួនភាគច្រើនពីវិស័យជំនួញ និងបានចំណាយសម្រាប់ម្ហូបអាហារផ្សេងៗនៅលើទីផ្សារបើកទូលាយ ។

យោងតាមការប៉ាន់ស្មាននាដើមសតវត្សរ៍ទី ១៧ ទីក្រុងប៉ាតានីបានពឹងផ្អែកលើការនាំចូលតាមផ្លូវសមុទ្រសម្រាប់ជាងពាក់កណ្តាលនៃតម្រូវការអង្ករបស់ខ្លួន ហើយបង់តេនពឹងផ្អែករហូតដល់ ៣ ភាគ ៤ នៃតម្រូវការអង្កររបស់ខ្លួន (Scott ១៦០៦ : ១៣៦, Terpstra១៩៣៨ : ១៦៣) ។ ចំណែកឯក្រុងម៉ាឡាកាវិញ មុនពេលការចូលមកកាន់កាប់របស់ពួកទុយហ្គាល់រឹតតែមានការពឹងផ្អែកជាងនេះទៅទៀត ។ ក្រុងម៉ាឡាកាត្រូវបានផ្គត់ផ្គង់ជារៀងរាល់ឆ្នាំដោយអង្ករប្រហែលជា ៤៥ នាវាពីប្រទេសភូមា ៣០ ពីប្រទេសសៀម និង ៥០ ទៅ ៦០ ពីប្រទេសជ្វាហើយរួមទាំងជាច្រើននាវាទៀតពី កូរ៉ូម៉ង់ដេល (Coromandel)(Araujo ១៥១០ : ២៨, Empoli ១៥១៤ : ១៥៥, Pires ១៥១៥ : ៩៨,១០៧) ។ ទោះបីនាវាទាំងនោះមានទំហំខុសប្លែកគ្នាខ្លាំងក៏ដោយ ក៏គេអាចប៉ាន់ស្មានបានថា នាវាមួយអាចផ្ទុកបានជាមធ្យមយ៉ាងហោចណាស់ក៏ ៥០ តោន ដោយសារគេឃើញមានការផ្គត់ផ្គង់នូវការនាំចូលអង្ករប្រហែល ៧.០០០ តោនក្នុងមួយឆ្នាំ តែពីតំបន់ផ្គត់ផ្គង់ស្ថិតនៅឆ្ងាយៗប៉ុណ្ណោះ ។ ចំនួននេះគឺល្មមគ្រប់គ្រាន់សម្រាប់ចិញ្ចឹមអ្នករស់នៅក្នុងទីក្រុងជាង ៥០.០០០ នាក់ទៅទៀត ។ បន្ទាប់ពីដំណាក់កាលរីកចម្រើនខ្លាំងរបស់ខ្លួនមក ក្រុងអាចេនៅក្នុងទសវត្សរ៍ឆ្នាំ ១៦៨០ នៅតែមាននាវា ១០ គ្រឿងដែលផ្ទុកទៅដោយអង្ករនាំចូលពីឥណ្ឌាដែរចតនៅក្នុងកំពង់ផែ ហើយអ្នកលក់រាយនូវអង្ករនាំចូលទាំងឡាយនៅតាមទីផ្សារ អាចរកចំណូលបានច្រើនរហូតដល់ ៨០ ស្ទៀលីង (Sterling) ក្នុងមួយថ្ងៃៗដែល (ស្មើនឹងការលក់អង្ករចំនួន ៣៥.០០០ គីឡូក្រាមឯណោះ ដាំពៃរ (Dampier) ១៦៩៩ : ៩៤) ។


Populations of Southeast Asian Cities at their 16th / 17th Century Height
1511 = Date of sacking and dramatic loss of population
About 100,000 or more
About 50, 000
10,000 or above
Ava
Pagan
Mrauk-u
Prome
Syriam
PEGU (1599)
Toungoo
Martaban
Chiengmai
Luang Prabang
Vientiane
THANG-LONG (HANOI)
KIM-LONG (HUE)
Hoi An (Faifo)
Lopburi
AYUTTHAYA (1569, 1767)
Mergui
Tenasserim
Lovek
Phnompenh (1658)
Nakhon Sithammarat
Patani (1674)
Pahang (1618)
MELAKA (1511,1641)
Johor
ACEH
Pasai (1524)
Pagarruyung
Jambi
Palembang (1659)
BANTEN (1682)
BATAVIA
Japara
Demak
Semarang
MATARAM (1677)
Tuban (1619)
Gresik (1623)
Surabaya (1624)
Gelgel
Balambangan
Banjarmasin
MAKASSAR (1669)
Brunei (1578)
Manila
Sinoay
SOUTH CHINA SEA
JAVA SEA
CELEBES SEA
FLORES SEA
BANDA SEA
PACIFIC OCEAN
INDIAN OCEAN
0
1000
kilometres

ផែនទីលេខ ៥

# រចនាសម្ព័ន្ធនៃទីក្រុងអាស៊ីអាគ្នេយ៍

ស៊ូណាន គុណនុង ហ្សាទី (Sunan Gunung Jati) បានបង្រៀនកូនប្រុសរបស់គាត់ឲ្យកសាងទីក្រុងនៅមាត់សមុទ្រ ហើយបានបង្ហាញប្រាប់កន្លែងណាខ្លះដែលគួរសាងសង់ព្រះរាជវាំង (ដាលមេ) ទីផ្សារ និងទីលានកណ្ដាល(alun-alun) ជាដើម ។ –Sadjarah Banten, segçbeday Djajadiningrat ១៩១៣ : ៣៤

*ដោយកកើតឡើងនៅសម័យកាលពាណិជ្ជកម្ម ក្រុងបន់តេន បានតំណាងឲ្យភាពផ្ទុយគ្នានៅក្នុងសម័យនោះ ។ដោយសារគេបានកសាងឡើងនៅក្បែរមាត់សមុទ្រ ដើម្បីទាញប្រយោជន៍ពីការដឹកជញ្ជូនតាមផ្លូវសមុទ្រទីក្រុងនេះមានការរីកចម្រើនយ៉ាងរហ័សក្លាយជាទីក្រុងដ៏ធំមួយ ដែលស្វាគមន៍ចំពោះឈ្មួញទាំងឡាយហើយក៏មានការកើតឡើងបរិវេណអាគារ ប្រលាយ ផ្លូវ និងទីផ្សារ យ៉ាងច្រើនណែនណាន់តាន់តាប់ឥតសណ្ដាប់ធ្នាប់ ។ ទោះជាយ៉ាងនេះក្ដី បន់តេន ជាទីក្រុងប្រកាន់នូវប្រពៃណីបណ្ដុំ (Indic) ដែលក្នុងនោះទំហំ និងទ្រង់ទ្រាយរបស់សំណង់អាគារសំខាន់ៗបានឆ្លុះបញ្ចាំងឲ្យឃើញនូវសេចក្ដីប៉ងប្រាថ្នាផ្នែកលោកធាតុរបស់ព្រះមហាក្សត្រ ។ ប្រ៊ូដែល (Braudel) (១៩៦៧:៣៨៤-៩៥) បានលើកឡើងនូវភាពចែកដាច់ពីគ្នារវាងទីក្រុងយកគំរូតាមក្ដារអុកនៃតំបន់អាស៊ីបូព៌ា និងខាងត្បូង និងភាពគ្មានសណ្ដាប់ធ្នាប់ណែនណាន់តាន់តាប់ ដែលគេឃើញមាននៅអឺរ៉ុបនាមជ្ឈិមសម័យ និងក្រុងអ៊ីស្លាមទាំងឡាយ «ចាប់ពីហ្គីប្រាល់តារ៍រហូតដល់ប្រជុំកោះស៊ុនដា» ។ ភាពផ្ទុយគ្នានេះបានជ្រួតជ្រាបពាសពេញតំបន់អាស៊ីអាគ្នេយ៍ទាំងមូល ។ នេះមិនមែនមានន័យថាទីក្រុងនៅតំបន់ដីគោក មានសណ្ដាប់ធ្នាប់ជាងទីក្រុងនៅតំបន់ឧបទ្វីបឬក៏រាជធានីអាណាចក្រផ្សេងៗដែលនៅឆ្ងាយពីមាត់សមុទ្រ មានសណ្ដាប់ធ្នាប់ជាងទីក្រុងកំពង់ផែដែលមានការរីកចម្រើននោះទេ ។ គ្រប់ទីក្រុងទាំងអស់សុទ្ធតែមាននូវកម្រិតសណ្ដាប់ធ្នាប់ខ្លះៗបែបលោកធាតុជាស្ថូលរបស់ខ្លួនដែលសណ្ដាប់ធ្នាប់នេះតែងតែទទួលរងនូវការគ្របដណ្ដប់ទាំងស្រុងដោយភាពរញ៉េរញ៉ៃនៃលំហូរចូលមនុស្សដ៏ច្រើនក្នុងដំណាក់កាលរីកចម្រើន ។*

*នៅក្នុងរាជាណាចក្រប្រកាន់នូវសាសនាព្រះពុទ្ធ ដែលប្រកាន់យកទស្សនៈថា ទីក្រុងគឺជាលំហដែលមានកំពែងការពារច្បាស់លាស់នោះ តំបន់កណ្ដាលដែលមានគម្រោងប្លង់ច្បាស់លាស់នោះអាចលាតសន្ធឹងពាសពេញបរិវេណទីក្រុងមានកំពែងការពារទាំងមូល ដែលមានផ្ទៃក្រឡាច្រើនគីឡូម៉ែត្រការ៉េ ។ នៅឯតំបន់ឧបទ្វីបវិញ គេឃើញមានតែបន្ទាយការពារព្រះរាជវាំង និងសំណង់អាគារសាធារណៈនៅក្បែរៗនោះប៉ុណ្ណោះ ដែលមានការរៀបចំប្លង់បានច្បាស់លាស់ ចំណែកឯលំនៅស្ថាននៅខាងក្រៅវិញ ស្ថិតនៅប្រមូលផ្ដុំយ៉ាងរញ៉េរញ៉ៃនៅជុំវិញទីផ្សារ ផ្លូវទឹក និងបរិវេណភូមិគ្រឹះរបស់ពួកមេកើយមានអំណាច ។ វៀតណាមមានរាជធានីតែមួយនៅតំបន់ហាណូយអស់រយៈកាលជិតមួយសហសវត្សរ៍ ហើយប្រជាជននៅរាជធានីនេះមានចំនួនច្រើនពេកដែលមិនអាចឲ្យគេអនុវត្តគម្រោងប្លង់ដំបូង (សូមមើលរូបភាពទី ១៣៧) តាមទស្សនៈលោកធាតុដែលគេប្រើនៅពេលកសាងទីក្រុងនេះដំបូងបាន÷ «ទីប្រជុំជននេះលាតសន្ធឹងយ៉ាងឆ្ងាយ ហើយមិនមានកំពែងការពារព័ទ្ធជុំវិញទេ...នៅគ្រប់កន្លែងទាំងអស់ គេឃើញមានមនុស្សម្នាយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលសូម្បីតែផ្លូវធ្វើដំណើរមានទំហំធំយ៉ាងណាក៏ដោយ ក៏គេមានការលំបាកយ៉ាងខ្លាំងក្នុងការធ្វើដំណើរឆ្លងកាត់នៅកន្លែងជាច្រើន» (Missions Etrangeres ១៦៧៤ : ១៧៦)។*




រូបភាព១៣ ក
ប្លង់ទីក្រុង ថាំងឡុង (ហាណូយ) មានកាលបរិច្ឆេទនៅឆ្នាំ ១៤៩០ ។

*ព្រះរាជាភូមាសំញែងពីអំណាចរបស់ព្រះអង្គតាមរយៈការកសាងនូវទីក្រុងថ្មីៗ ស្របទៅតាមទស្សនៈលោកធាតុ ហើយព្រះរាជាបៃយីនលាង* (Bayinnaung) *ដែលជាព្រះរាជាដ៏មានកិត្យានុភាពបំផុតរបស់ភូមាបានកសាងទីក្រុងដ៏គួរឲ្យស្ញប់ស្ញែងបំផុត ។ ដូចដែលពង្សាវតារភូមាបានកត់ត្រាថា៖ «នៅមុនចុងឆ្នាំ ៩២៨ (១៥៦៦) ព្រះអង្គបានកសាងរួចរាល់សូម្បីតែគោបុរៈ និងប៉មការពារនៅតាមកំពែងទាំងឡាយ ។ គេឃើញមានគោបុរៈចំនួន ២០ និង ប៉មការពារចំនួន១.០០៩ ហើយព្រះអង្គក៏បានកសាងផ្លូវធំសំខាន់ៗចំនួន ១០ ខ្សែ និងផ្លូវតូចៗដទៃទៀតជាច្រើនរួមទាំងគូទឹកមួយខ្សែផងដែរ ដែលព្រះអង្គបញ្ជាឲ្យគេជីកជុំវិញទីក្រុងដែលមានប្រវែង ២០ ព្យាម និងជម្រៅ ២០ ហត្ថគូ ។ ចំពោះគោបុរៈទាំង ២០ ដែលព្រះអង្គបានកសាងឡើង ព្រះអង្គបានប្រទានឈ្មោះគោបុរៈ ទាំងនោះតាមឈ្មោះរបស់ទីប្រជុំជន និង ភូមិទាំងឡាយ»* ("History of Syriam *១៩១៥ : ៦) ។ ក្នុងចំណោមផ្លូវធំទាំង ១០ ខ្សែ ដែលបានពោលខាងលើ ៥ ខ្សែ លាតសន្ធឹងពីជើងទៅត្បូង ដោយភ្ជាប់គោបុរៈ ៥ នៅកំពែងខាងជើង និងគោបុរៈ ៥ ទៀតនៅកំពែងខាងត្បូង ។ ចំណែកឯ ផ្លូវធំ ៥ ខ្សែផ្សេងទៀតលាតសន្ធឹងពីលិចទៅកើត ។ ដូច្នេះហើយ ទីក្រុងត្រូវបែងចែកជា ៣៦ ប្លុក ដែលក្នុងមួយប្លុកៗមានទំហំផ្ទៃក្រឡា ៦ x ៦ ដោយរក្សាទុកនូវទីធ្លាចំនួន ៤ ប្លុក នៅកណ្ដាលសម្រាប់ព្រះរាជវាំង ដែលក្លាយជាផ្ចិតរបស់ទីក្រុងដែលមានផ្លូវសំខាន់ៗទាំងអស់បុកឆ្ពោះមកចំ ។ ដូច្នេះបន្សល់ទុក ៣២ ប្លុកទៀតស្ថិតនៅក្រៅព្រះរាជវាំង ដែលគេមានបំណងយ៉ាងច្បាស់ចង់ឲ្យតំណាងខេត្តទាំង ៣២ ដែលព្រះរាជាបៃយីនលាង បានបែងចែកក្រោមការគ្រប់គ្រងរបស់រាជធានីប៉េគូ នោះ* (ibid *:៧) ។ ហេតុដូច្នេះហើយទាំងទីក្រុង និងប្រទេសរបស់ព្រះអង្គបានឆ្លុះបញ្ចាំងនូវឋានសួគ៌ក្នុងព្រះពុទ្ធសាសនា ដែលមានព្រះឥន្ទស្ថិតនៅចំកណ្ដាលហែហមព័ទ្ធជុំវិញដោយទេវតាចំនួន ៣២ អង្គផ្សេងទៀត* (Guillon 1989: 115) ។




រូបភាពទី ១៣ ខ
ក្រុង អមរបុរៈ ទីក្រុងភូមា ឆ្នាំ ១៧៩៥ ។

*អ្នកដំណើរជនជាតិអឺរ៉ុប ដែលបានមកដល់ទីក្រុងថ្មីនេះមានការភ្ញាក់ផ្អើលចំពោះទំហំដ៏ធំអស្ចារ្យរបស់ទីក្រុងនេះ ។ លោកសេសា ហ្វ្រេឌីរិកស៊ី* (Cesare Frederici) *បន្ទាប់ពីវាបានកសាងហើយរួចរាល់ភ្លាមៗបានធ្វើដំណើរទៅដល់ទី ក្រុងនេះ...ហើយការរៀបរាប់របស់គាត់មានភាពស្របគ្នា និងសេចក្ដីរៀបរាប់របស់ជនជាតិភូមា ដោយគាត់បានបរិយាយថា ÷*

នៅក្នុងទីក្រុងថ្មី មានព្រះរាជវាំងរបស់ព្រះមហាក្សត្រ និងទីស្នាក់អាស្រ័យរបស់ព្រះអង្គ រួមទាំងមន្ត្រីសព្វមុខទាំងឡាយ និងពួកអភិជនផ្សេងៗទៀត . . . វាជាទីក្រុងដ៏អស្ចារ្យមួយ ដែលមានផ្ទៃរាបស្មើ និងមានរាង

ជាការ៉េ ហើយថែមទាំងមានកំពែងការពារជុំវិញ រួមជាមួយ និងគូទឹកព័ទ្ធជុំវិញកំពែងដែលមានក្រ ក្រពើជាច្រើននៅក្នុងនោះទៀតផង ។ ទីក្រុងនេះមិនមាននូវស្ពានដែលគេអាចបញ្ឆាទាញឡើងចុះដើម្បីបិទបើនោះទេ តែវាមានគោបុរៈចំនួន ២០ ដោយគោបុរៈ ៥ ស្ថិតនៅតាមជ្រុងនីមួយៗនៃកំពែង ។ មានកន្លែងជាច្រើនទៀតសាងសង់ឡើងពីឈើស្រោបដោយទឹកមាសសម្រាប់ឆ្មាំក្នុងការការពារឃ្លាំ ។ ផ្លូវថ្នល់ធំៗ ក្នុងទីក្រុងនេះមានលក្ខណៈរលោងស្អាតដែលខ្ញុំពុំធ្លាប់ឃើញពីមុនមកផ្លូវទាំងនោះត្រង់ដូចបន្ទាត់ភ្ជាប់ពីគោបុរៈមួយទៅគោបុរៈមួយទៀត ឈរនៅគោបុរៈម្ខាងអ្នកអាចមើលឃើញម្ខាងទៀត ហើយវាធំទូលាយ មនុស្ស ១០ ឬ ១២ នាក់ធ្វើដំណើរដោយចក្រយាននៅលើទ្រូងថ្នល់ទាំងនោះបាន . . . ផ្លូវថ្នល់ទាំងនោះ . . . ត្រូវបានគេដាំដើមឈើអមសងខាងនៅតាមមុខផ្ទះនីមួយៗ ដែលមានដូចជាដើមសណ្តែកដីឥណ្ឌា ដែលផ្តល់ម្លប់ដ៏ត្រឈឹងត្រឈៃ ។ ផ្ទះទាំងនោះសង់ឡើងពីឈើប្រក់ក្បឿងម្យ៉ាងដែលមានរាងជាពែង . . . ព្រះរាជវាំងរបស់ព្រះមហាក្សត្រស្ថិតនៅចំកណ្តាលទីក្រុង ដែលសង់ឡើងក្នុងទម្រង់ជាប្រាសាទមានកំពែងការពារ ដោយមាន គូទឹកដែលមានទឹកពេញប្រៀបព័ទ្ធជុំវិញ រីឯលំនៅស្ថានផ្សេងៗនៅខាងក្នុងបរិវេណវិញ សុទ្ធតែសង់ឡើងពីឈើដោយមានដំបូលស្រួចយ៉ាងស្រស់ស្អាតទៀតផង ហើយសំណង់ដែលមានការចំណាយប្រាក់ច្រើន គឺស្រោបដោយមាសសន្លឹកជាច្រើនទៀតផង (Frederici ១៥៨១ : ២៤៥)។

រាជធានីរបស់ភូមាដទៃទៀត ដូចជាអាវ៉ា, អមរបុរៈ និងម៉ាន់ដាលេ ទាំងអស់សុទ្ធតែសាងសង់ឡើងដោយប្លង់ដាក់លាក់ស្រដៀងៗគ្នា ដោយមានព្រះរាជវាំងស្ថិតនៅចំកណ្តាលបន្ទាយការពារព្រះរាជវាំងរាងការ៉េដ៏ធំទូលាយដែលមានកំពែង និងគូទឹកព័ទ្ធជុំវិញ ដែលប្រសព្វគ្នាដោយផ្លូវត្រង់ភ្ជាប់ពីគោបុរៈមួយទៅគោបុរៈមួយទៀត (O'Connor ១៩០៧; fig ១៣b) ។ ក្រុងតែភាគខាងជើងមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងទម្រង់ជាប្រក្រតីរបស់ទីក្រុងភូមា ។ តាមដឹងមកថា ឈៀងម៉ៃដែលបានកសាងឡើងក្នុងរយៈពេល ៤ ខែសម្រាប់ព្រះមហាក្សត្រម៉ាន់ក្រៃ (Mangrai) នៅក្នុងឆ្នាំ ១២៩២ ដោយធ្វើទៅតាមក្បួនទំនាយផ្សេងៗក៏យកគំរូទៅតាមទស្សនៈលោកធាតុដែរ ដោយមានកំពែង និងគូទឹកព័ទ្ធជុំវិញ ហើយនឹងផ្លូវរាងចតុកោណទៀតផង (Chronique de Xieng Mai: ៥៦–៦១; Wijeyewardene១៩៨៦ : ៨) ។ ម្យ៉ាងវិញទៀត ប្រសិនបើក្រុងអយុធ្យាមានប្រភពស្រដៀងគ្នានោះ ម្ល៉ោះវានឹងរីកចម្រើនយ៉ាងឆាប់រហ័សជាងទីក្រុងទាំងអស់នោះមិនខាន ។ ផ្លូវទឹករបស់ទីក្រុងនេះផ្ទាល់ (ផែនទីលេខ ៦) ជាអ្នកកំណត់នូវទម្រង់រូបរាងមិនប្រក្រតីរបស់ក្រុងសៀមនេះ ហើយទោះបីជារាជធានីដែលស្ថិតនៅលើដីកោះដែលមានកំពែងការពារយ៉ាងមាំតែមួយចំហៀងនៅក្នុងទន្លេចៅផាយ៉ាមានផ្លូវថ្នល់ «ធំ ត្រង់ និងរាបស្មើ» ពីរបីខ្សែក៏ដោយក៏គមនាគមន៍ភាគច្រើនធ្វើឡើងតាមរយៈ «ផ្លូវចង្អៀតតូចៗប្រលាយ និងព្រែកតូចៗ ដែលមានទីតាំងខ្វាត់ខ្វែងគ្នា» (Schouten ១៦៣៦ : ១២៤)។




ផែនទីលេខ ៦ ទីក្រុងអយុធ្យា គ.ស. ១៦៨៧

ប្រសិនបើទីក្រុងកាន់ព្រះពុទ្ធសាសនាមានកំពែងការពារហ៊ុមព័ទ្ធទីក្រុងស្ទើរតែទាំងមូលនោះកំពែងការពារដូចគ្នានេះដែរនៅក្នុងប្រទេសវៀតណាម និងតំបន់តាមឧបទ្វីប គឺសម្រាប់តែព្រះមហាក្សត្រ ស្រីស្នំមីនំមីនាងរបស់ព្រះអង្គ និងមន្ត្រីបម្រើផ្ទាល់នៅក្នុងព្រះរាជវាំងតែប៉ុណ្ណោះ ។ នៅប៉ាហាំង (Pahang) គេឃើញមានតែ «នាយម៉ឺនមន្ត្រី» ប៉ុណ្ណោះ ដែលរស់នៅក្នុងបរិវេណកំពែងបន្ទាយការពារព្រះរាជវាំង ។ «គេឲ្យប្រជាជនសាមញ្ញរស់នៅខាងក្រៅកំពែងនៅតាមតំបន់ជាយក្រុង» (Matelief ១៦០៨ : ១២២) ។ ទស្សនៈទិ្វកនិយមនៃទីក្រុងម៉ាកាសសារ (Makassar) បានបង្កើតឲ្យមានកំពែងបន្ទាយការពារក្រុងសំខាន់ៗ ៣ ដែលក្នុងនោះកំពែងក្រុងសំខាន់ជាងគេបំផុត

គឺសមបាវពុយ (Sombaopu) ដែលមានតែក្រុមគ្រួសាររាជវង្ស និងអ្នកបម្រើ និងអ្នកការពារប៉ុណ្ណោះ ដែលរស់ក្នុងនោះ (ផែនទីលេខ ៧) ។ គេមានការលំបាកក្នុងការមើលឃើញច្បាស់នូវការរៀបចំតាមទស្សនៈលោកធាតុនូវលំពែង ផ្លូវថ្នល់ និងអាគារ នៅក្នុងស្ថានភាពមមាញឹកស្មុគស្មាញនៃទីក្រុងកំពង់ផែទាំងអស់នេះ ។ គេឃើញមានតែទីតាំងរាជវាំងនៅចំកណ្ដាលទីក្រុងប៉ុណ្ណោះ ដែលមានទម្រង់ច្បាស់លាស់ដោយព្រះរាជវាំងបែរមុខទៅរកទីធ្លាស្រឡះនៅទិសខាងជើង រីឯនៅទិសខាងលិចវិញ គឺជាវិហារសាសនាអ៊ីស្លាមដ៏ធំស្កឹមស្កៃមួយ ហើយចំណែកឯនៅទិសខាងកើត ឬទិសខាងជើងវិញគឺជាទីផ្សារ ។ ការបង្ហាញខាងលើនេះ គឺជាការបង្ហាញពីគំរូបែបផែនរបស់ក្រុងបង់តេន (ផែនទីលេខ ៨) ហើយនិងរបស់ក្រុងជ្វាភាគច្រើននាសម័យក្រោយៗទៀតដែលទីលានមុខព្រះរាជវាំង (paseban or alun-alun) គឺជាទីធ្លាសម្រាប់ប្រារព្ធពិធីបង្ហាញការសំដែង និងការប្រកួតផ្សេងៗ ដែលចាត់ចែង និងឧបត្ថម្ភដោយព្រះរាជវាំង ។ ទោះបីជាគេមិនឃើញមាននៅក្រុងម៉ាកាសសារក៏ដោយ គេឃើញមានការចម្លងគំរូបែបផែនដូចគ្នានេះ (រូបភាពទី ១៤) នៅក្រុងអាចេ និងប៉ាតានីផងដែរ ។

កំពែងបន្ទាយការពារព្រះរាជវាំងភាគច្រើនមានទីធ្លាបន្តបន្ទាប់គ្នាជាច្រើនជាន់ ដែលធ្វើឲ្យមានការលំបាកកាន់តែខ្លាំងឡើងៗក្នុងការឆ្លងកាត់ពីមួយដំណាក់ទៅមួយដំណាក់ទៀត ដោយព្រះរាជដំណាក់នៅផ្នែកខាងក្នុងបំផុតគឺរក្សាទុកជាពិសេសសម្រាប់តែព្រះមហាក្សត្រ និងស្រីស្នំរបស់ព្រះអង្គ ។ នៅអាចេ គេត្រូវធ្វើដំណើរឆ្លងកាត់ទ្វាចំនួន ៧ ជាន់ មុននឹងចូលទៅដល់ទីធ្លាខាងក្នុង (Warwijck ១៦០៤ : ១៥) ហើយមិនមានព្រះរាជវាំងណាដែលមានទ្វាតិចជាង ៣ ជាន់នោះទេ ។ រីឯទីធ្លាខាងក្រៅបំផុតវិញ មានដូចជា រោងដំរីរបស់ស្ដេចបន្ទប់សម្រាប់ទាហានយាមឃ្លាំងស្ដុកកាំភ្លើងធំ និងកន្លែងធ្វើបដិសណ្ឋារកិច្ចភ្ញៀវៗ ទីធ្លាផ្នែកខាងក្រៅព្រះរាជវាំងវិញ នៅអាចេមានទីលានទូលាយគួរសមដែលគេអាចរៀបចំពិធីប្រជល់ដំរីជាសាធារណៈបាន (Ito ១៩៨៤ : ២៣) ។ ចំណែកព្រះរាជដំណាក់នៅផ្នែកខាងក្នុងធ្វើអំពីឈើជាទូទៅមានតែមួយជាន់ ប៉ុន្តែមានសសរឈើខ្ពឹមធំៗជាទម្រ ។ ដំបូលវិមានដែលពោរពេញដោយក្បូរក្បាច់រចនា និងក្បាច់ចម្លាក់ដ៏វិចិត្រនៅតាមជញ្ជាំងព្រះរាជវាំង គឺជាទិដ្ឋភាពដ៏ទាក់ទាញក្រៃលែងចំពោះភ្ញៀវជនជាតិអឺរ៉ុបដែលមានអារម្មណ៍ធូរស្រាលរីករាយនៅពេលមកដល់វិមាននៅផ្នែកខាងក្នុងធ្វើអំពីឈើ បន្ទាប់ពីធ្វើដំណើរឆ្លងកាត់កំពែងហាមឃាត់ធ្វើអំពីថ្មនៅខាងក្រៅជាច្រើនជាន់មក (Warwijck ១៦០៤ : ១៥; Marini ១៦៦៦ : ១១៧; Baron១៦៨៥ : ៣; Tevernier ១៦៩២ II :៥៣២) ។

ជាទូទៅ ប្រមុខដឹកនាំមានកន្លែងសម្រាប់បួងសួងផ្ទាល់ខ្លួននៅក្នុងបរិវេណព្រះរាជវាំង ក៏ប៉ុន្តែវិហារអ៊ីស្លាមសំខាន់ គឺស្ថិតនៅតំបន់ក្បែរព្រះរាជវាំងដើម្បីបើកឲ្យមនុស្សម្នាអាចបានប្រើប្រាស់ផងដែរ ។ ជាធម្មតានៅក្នុងទីក្រុងអ៊ីស្លាម គេឃើញមានវិហារអ៊ីស្លាមធំតែមួយគត់បែរមុខទៅរកទីលានស្រឡះហើយជាទូទៅដំបូលច្រើនជាន់របស់វិហារនេះ គឺជាចំណុចចំណាំដ៏ខ្ពស់ជាងគេប្រចាំទីក្រុង ។ ទោះបីជាអ្នកខ្លះបាននិយាយថា ក្រុងអាចេមាន «វិហារអ៊ីស្លាមច្រើនអនេក» ក៏ដោយ (ដាំពែរ ១៦៩៩ : ៩០) ក៏តាមពិតទៅវិហារទាំងនោះជាសំណង់ធម្មតាដែលជារឿយៗមានទំនាក់ទំនង និងសាលារៀន ឬក៏ស្ថាប័នសាសនា ។ ផ្ទុយពីនេះ នៅរាជធានីកាន់ព្រះពុទ្ធសាសនាថេរវាទវិញ គេឃើញមានចេតិយ ឬក៏ព្រះវិហារកំពូលស្រួចពណ៌មាសច្រើនព្រាងព្រាតនៅស្ទើរតែគ្រប់ជ្រុងទាំងអស់របស់ទីក្រុង ។ គេល្បីថា ទីក្រុងអយុធ្យាមានព្រះវិហារចំនួនប្រហែលពី ៣០០ ទៅ ៥០០ ហើយវៀងច័ន្ទមាន ៦២ និង ចំណែកឯឈៀងម៉ៃវិញ មាន ៨៥ (Schouten ១៦៣៦ : ១២៥; Gervaise១៦៨៨ : ៤៧; Lunet de Jonquière ១៩០១ : ១០២; Wijeyewardene ១៩៨៥ : ៩១) ។ ដោយសារតែបំណងចង់សន្សំបុណ្យកុសលតាមរយៈការកសាង និង




ផែនទីលេខ ៧

ការផ្ទួសផុល និងការតុបតែងលម្អនូវសំណង់សាសនាផ្សេងៗ បណ្តាលឲ្យមាននូវចំនួនព្រះវិហារកាន់តែច្រើនឡើងៗ បើទោះបីជាមានតែព្រះវិហារមួយ ប៉ុកំពីរប៉ុណ្ណោះ ដែលដើរតួនាទីសំខាន់ជាកន្លែងផ្តោតសម្រាប់ធ្វើពិធីបុណ្យសាសនា ឬក៏ពិធីផ្សេងៗក៏ដោយ ។ រីឯនៅក្នុងប្រទេសកាន់សាសនាអ៊ីស្លាមវិញ គេឃើញមានតែផ្នូរអាចារ្យដឹកនាំសាសនាសំខាន់ៗ និងឥស្សរជនមានឥទ្ធិពលប៉ុណ្ណោះ ដែលអាចទាក់ទាញបានជាពិសេសនូវអ្នកគោរពបូជាដូចគ្នាទៅនឹងទីសក្ការៈដ៏សម្បូរបែបផ្សេងនៅក្នុងសាសនាព្រះពុទ្ធដែរ ។

ទីក្រុងសំខាន់ៗទាំងអស់ស្ថិតនៅក្បែរមាត់សមុទ្ររួមមានទីក្រុង (ម៉ាឡាកា បង់តេន ហ្សាកាតា-បាតាវៀ ហ្គ្រេស៊ីក ម៉ាកាសសារ តឺណាត ម៉ានីល) ឬក៏ស្ថិតនៅក្បែរទន្លេធំៗដែលអាចធ្វើនាវាចរណ៍បាន ។ តំបន់ស្នូលដែលមានកំពែងការពារ ក៏មានស្ទឹងមួយនៅក្បែរ ឬក៏ហូរកាត់ដែរ ដែលអាចផ្តល់ទឹកសម្រាប់ការបោកគក់សម្លៀកបំពាក់ និងការដាំស្ល្ររមទាំងអាចផ្តល់លទ្ធភាពឲ្យទូកតូចៗអាចធ្វើដំណើរចូលមកដល់បានដែរ ។ ជារឿយៗ ស្ពានរំលងស្ទឹងនេះដែលបុកឆ្ពោះទៅកាន់សំណង់អាគារកណ្តាលរបស់ព្រះរាជវាំង គឺជាកន្លែងដែលមានមនុស្សច្រើនកុះករដើរឆ្លងកាត់ ។ នៅម៉ាឡាកានៅតាមផ្លូវស្ពាននេះមានតូបលក់ដូរតូចៗជាច្រើនតម្រៀបជាជួរដែលក្លាយជាផ្នែកបន្ថែមនៃទីផ្សារ ។ ហួសពីនេះទៅស្ពានមានចំនួនតិចតួច និងចាស់ទ្រុឌទ្រោម ។ នៅអយុធ្យាមានតម្រូវការស្ពានយ៉ាងខ្លាំងសម្រាប់ឆ្លងព្រែកដ៏ច្រើននៅក្នុងទីក្រុងនេះ ÷ «ស្ពានដែលសង់នៅពីលើព្រែកដ៏កធំៗធ្វើពីថ្ម ប៉ុន្តែស្ពានទាំងនោះមានលក្ខណៈតូចចង្អៀត ដោយសារតែនៅតំបន់នេះគ្មាននូវរទេះកង់បួន ឬក៏រទេះផ្សេងៗទៀតធ្វើដំណើរឆ្លងកាត់ ។ ស្ពានទាំងនោះមានរាងកោងខ្ពស់នៅផ្នែកកណ្តាល និងមានប្រវែងបណ្តោយ ៨០ ជំហាន

*ប៉ុន្តែចំពោះស្ពានពីលើព្រែកតូចៗវិញ...ភាគច្រើនធ្វើឡើងពីឈើ»* (Kaempfer ១៧២៧ : ៤៤, cf. Gervaise ១៦៨៨ : ៤៧) ។



**ផែនទីលេខ ៨**
**ប្លង់ទីក្រុង ម៉ាកាសសានៃ សំបាពូ នៅឆ្នាំ ១៦៣៨ គូសដោយជាងគំនូរហូឡង់ ។**

*មធ្យោបាយធ្វើដំណើរងាយស្រួលបំផុតគឺតាមផ្លូវទឹក ចំណែកឯផ្លូវថ្នល់វិញមិនសូវមានការអភិវឌ្ឍប៉ុន្មានទេ ។ រាជធានីនីមួយៗនៅប្រទេសភូមា ថៃ និងវៀតណាម មានវិថីឈូសឆាយស្អាតតែពីរបីប៉ុណ្ណោះ ។ នៅក្រុងថាំងឡុង ផ្លូវធំៗសំខាន់ៗមិនមានការឈូសឆាយឲ្យបានស្អាតទេ ដោយសារគេទុកសម្រាប់ឲ្យសត្វពាហនៈធ្វើដំណើរ* (Richard ១៧៧៨I : ២៧) ។ *ចំណែកនៅតំបន់ឧបទ្វីប និងនៅកន្លែងណាដែលទីក្រុងកកើតឡើងដោយសារតម្រូវការផ្នែកពាណិជ្ជកម្មជាជាងដោយសារព្រះរាជបញ្ជារបស់ព្រះមហាក្សត្រវិញ គេឃើញផ្លូវថ្នល់សុទ្ធតែដីខ្សាច់ និងដី៖ «នៅទីក្រុង (បង់តេន) គេឃើញមានផ្លូវថ្នល់សមរម្យតែ ៣ ខ្សែប៉ុណ្ណោះដែលផ្លូវទាំងនោះបុកត្រោះទៅរកទីលានខាងមុខព្រះរាជវាំង ។ ផ្លូវទីមួយតផ្ទាប់ពីទីលានត្រោះទៅកាន់សមុទ្រផ្លូវទីពីរបុកត្រោះទៅរកច្រកដីគោក និងផ្លូវទីបីបុកត្រោះទៅរកច្រកភ្នំ ។ ដីក្នុងទីក្រុងក៏មិនមានការឈូសឆាយសម្អាត គឺមានសុទ្ធតែខ្សាច់ ។ទីក្រុងក៏ពោរពេញទៅដោយភក់ជ្រាំ និងជះក្លិនស្អុយផងដែរដោយសារតែអ្នករស់នៅបោកភក់នៅតាមទីសាធារណៈទាំងបុរស និងស្ត្រីដែលធ្វើឲ្យផុលដី និងល្អក់ទឹក» (លូដូវីស្គស៍ ១៥៩៨ : ១០៦) ។ ទោះបីជាមិនមានការឈូសឆាយសម្អាតក៏ដោយក៏មានវិថីមួយចំនួនដែលគួរឲ្យស្ញប់ស្ញែងដូចជាផ្លូវ ដែលណាវ៉ាររ៉េត* (Navarrete) *បានធ្វើដំណើរត្រោះទៅកំពែងការពារព្រះរាជវាំងសំបាវពូ នៅ ក្រុងម៉ាកាសសារ (ប្រហែលជាមកពីទិសខាងជើង*


Banten in the 1620s
(based on a Dutch map)
0
500
metres
JAVA SEA
Fishing Villages
Villages and Artisans etc
Great Market
Chinese
(and other foreign)
Quarter
wall of inner city
gate
a bulwark, defending a gate or strategic point
densely-settled urban area
A Royal Palace
B Great Mosque
C The small or city market
D The sheds for the king's principal war prahus
E The king's elephant house
F Magazine for the king's cannon ('14 guns, badly maintained')
G The paseban (or alun-alun) 'and trees where he normally holds counsel'
g Royal pavilion (balai)
H House of king's weigh-men
J The English Factory
Aristocratic compounds:
1 Court of the young king
2 The Temenggung
3 Kiai Kanga Pamman
4 'a great nobleman, close in blood to the king'
5 Ratu Bagus Panta, 'of the king's family'
6 Patra Sari, a former resident of Batavia
7 Kiai Wadon Adi, 'a principal noble'
8 Pangeran Aria Papati
9 Pangeran Sambang Loor, 'the king's nephew and counsellor'
10 Kiai Agus
11 Sim Suan,' formerly... one of the principal Chinese'

*សូមមើលផែនទីលេខ ៧ ខាងលើ) «ដោយមានដើមត្នោតជាជួរ មានសភាពដ៏ស្អាតប្រណិតជាងគេបំផុតនៅលើពិភពលោក ។ កាំរស្មីព្រះអាទិត្យមិនអាចប៉ុកទម្លុះដើមត្នោតទាំងនោះបានទេ ហើយជួរដើមត្នោតទាំងនោះមានប្រវែងលើសពី ២៥ គីឡូម៉ែត្រទៅទៀត...តើវាធ្វើឲ្យយើងស្ញប់ស្ញែងប៉ុណ្ណា»* (Navarrete ១៦៧៦I *: ១១៥;* cf. Gervaise *១៦៨៨ : ៤៧ អំពីអយុធ្យា) ។*

*ទីក្រុងទាំងឡាយដែលជោគជ័យខ្លាំងទាក់ទាញឈ្មួញបរទេសដែលមានទ្រព្យច្រើន ក៏ដូចជាបរិវារដែលជាចំនុះផងដែរ ។ អ្នកទាំងនោះមួយចំនួនបានធ្វើសមាហរណកម្មចូលទៅក្នុងក្រុមឈ្មួញធំៗដ៏មានឥទ្ធិពលនៅក្នុងទីក្រុងទាំងនោះ ហើយបង្កើតបានភាពចម្រុះ ដែលធ្វើឲ្យពាណិជ្ជកម្មមានដំណើរទៅបាន ។ ស្ថាបត្យកម្មនៅក្នុងទីក្រុងបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីលទ្ធភាពរីកដុះដាលនៃភាពចម្រុះទាំងនេះដោយធ្វើឲ្យធ្លាក់ចុះនូវមហិច្ឆតាមជ្ឈការនិយមរបស់ព្រះមហាក្សត្រ ។ ភូមិគ្រឹះរបស់ពួកអភិជនទាំងឡាយស្ថិតនៅតាមសង្កាត់ផ្សេងៗពីគ្នា ដែលសង្កាត់នីមួយៗមានអំណាចច្បាប់រៀងៗខ្លួន គ្របដណ្តប់ទៅលើតំបន់ក្បែរខាងនោះ ។ អភិជនដែលមានឥទ្ធិពលនិមួយៗរស់នៅក្នុងបរិវេណភូមិគ្រឹះដែលមានការយាមកាមការពារយ៉ាងហ្មត់ចត់ ដែលចម្លងតាមគំរូរបស់ព្រះរាជវាំង ប៉ុន្តែក្នុងទ្រង់ទ្រាយតូច ។ នៅក្រុងបង់តេន គំរូបែបថែវនេះបង្ហាញយ៉ាងច្បាស់តាមរយៈផែនទីរបស់ហូឡង់ (សូមមើលផែនទីលេខ ៨) និងកំណត់ត្រានេះ ៖*

> ទីក្រុងបែងចែកចេញជាច្រើនតំបន់ ហើយនៅតាមតំបន់នីមួយៗ គេដាក់ឲ្យមានអភិជនមួយរូបប្រចាំនៅទីនោះ ដើម្បីការពារតំបន់នោះនៅគ្រាដែលមានសង្គ្រាម អគ្គិភ័យ ឬក៏អ្វីផ្សេងទៀតជាយថាហេតុហើយអភិជនម្នាក់ៗមាននូវអំណាច និងតំបន់គ្រប់គ្រងផ្ទាល់ខ្លួនផ្សេងពីអ្នកដទៃទៀត. . . អភិជនម្នាក់ៗមានអ្នកការពារ ១០ ឬ ១២ នាក់សម្រាប់យាមកាមភូមិគ្រឹះរបស់ខ្លួនជារៀងរាល់យប់ ។ ពេលដែលអ្នកចូលទៅក្នុងភូមិគ្រឹះរបស់ពួកអភិជនទាំងនោះដំបូងបង្អស់អ្នកនឹងប្រទះភ្នែកឃើញទីធ្លាស្រឡះមួយ ដែលពួកគេហៅថា ផាសហោនដែលជាកន្លែងសម្រាប់ទទួលភ្ញៀវ និងក៏ជាកន្លែងដែលអ្នកការពារដែលបានពោលខាងលើឈរជើងផងដែរ . . . នៅឯជ្រុងម្ខាងនៃទីធ្លានេះគេមានវិហារអ៊ីស្លាមផ្ទាល់ខ្លួនសម្រាប់ធ្វើពិធីបួងសួងនៅពេលថ្ងៃត្រង់ ហើយនៅជាប់នោះដែរ គឺមានអណ្តូងទឹកមួយសម្រាប់ពួកគេលាងសម្អាតដៃជើង ។ ប្រសិនបើធ្វើដំណើរចូលជ្រៅទៅក្នុងបន្តិច គេនឹងទៅដល់ទ្វាមួយ ដែលមានច្រកតូចចង្អៀត ដោយសារតែមានតូប និងឃ្លាំទំនិញជាច្រើន ដែលទាសករភាគច្រើនរបស់ពួកអភិជនទាំងនោះរស់នៅ ដើម្បីការពារពួកគេ ។ ដូច្នេះហើយ ពួកគេមិនអាចរងការវាយប្រហារពីសំណាក់សត្រូវនៅពេលយប់បានឡើយ ព្រោះតែពួកគេក៏មិនទុកចិត្ត ឬក៏ស្មោះត្រង់ និងនរណាម្នាក់ឡើយ (លូដូវីស្គស៍ ១៥៩៨ : ១០៧-០៨)។

*គំរូបែបផែនបរិវេណភូមិគ្រឹះក្នុងក្រុងមានការការពារហ្មត់ចត់របស់អ្នកមានអំណាចដែលជុំវិញមានប្រពន្ធកូន ទាសករ និងបរិវាររស់នៅក្នុងលំនៅដោយឡែកៗជុំវិញគេហដ្ឋានរបស់ខ្លួនបែបនេះ ត្រូវបានគេចម្លងតាមនៅទីក្រុងដទៃទៀតរបស់ជ្វា និងកោះបាលី (រូបភាពទី ១៥) នៅម៉ាកាសសារ និងអាចេ និងនៅសៀមផងដែរ*(Pires *១៥១៥ : ១៩០;* Lintgens *១៥៩៧ : ៩៨–៩៩;* Van den Broecke *១៦៣៤*I *: ១៨៥, ២០៦;* La Loubère*១៦៩១ : ៣០)។ ពាក្យថា គាមផុនដែលប្រើសំដៅដល់ភូមិ ឬក៏ទីស្នាក់អាស្រ័យនៅក្នុងភាគម៉ាឡេសម័យទំនើបនេះ កាលពីសម័យពាណិជ្ជកម្ម គឺសំដៅបរិវេណភូមិគ្រឹះរបស់អ្នកមាន ដែលជាទូទៅស្ថិតនៅក្នុងទីក្រុង ។ នៅម៉ាឡាកា គេ*

ឃើញមានមានច្បាប់យ៉ាងលម្អិតផ្តល់ដោយព្រះមហាក្សត្រស្តីអំពីការលក់ដូរ កំដូចជាកិច្ចសន្យាដួលគុប៉ាង និង អំពី ការគ្រប់គ្រងបរិវារ (Undang-undang Melaka: ១០៦-០៩)។

ជាមូលដ្ឋាន «ទីក្រុង» អាស៊ីអាគ្នេយ៍ គឺជាបណ្តុំនៃបរិវេណភូមិគ្រឹះរបស់ពួកអភិជនដែលម្នាក់ៗមានចង្កោមលំនៅស្ថានរបស់អ្នកដែលពឹងពាក់លើខ្លួនរស់នៅព័ទ្ធជុំវិញ ។ ក្រៅពីទីក្រុងភូមា និងទីក្រុងតែខាងជើងគេឃើញមានតិចតួចណាស់នូវគំនិតអំពីទីធ្លាទីក្រុងដាក់លាក់ ដែលកំណត់ដោយកំពែងការពារ និង មានទ្រង់ទ្រាយខុសប្លែកពីតំបន់ជនបទជុំវិញ ។ នៅតាមតំបន់ឧបទ្វីបវិញពួកអឺរ៉ុបចាត់ទុកទីក្រុងថា «មិនមានអ្វីក្រៅតែពីបណ្តុំភូមិ» ទេ (Crawfurd ១៨២០ I : ១៦៨)ហើយជាទូទៅភាសាដើម មិនបានបែងចែកឲ្យច្បាស់រវាងពាក្យទីក្រុង និងរដ្ឋទេ ។ ពាក្យទាំងពីរនេះជាភាសាម៉ាឡេហៅថា negeri (cf. Pasaéffa nakhon) ដែលមានប្រភពមកពីភាសាសំស្ក្រឹតជាទីក្រុង តែនៅពេលចូលមកក្នុងភាសាឥណ្ឌូនេស៊ី និងម៉ាឡេ សម័យទំនើបពាក្យនេះមានន័យថារដ្ឋ ។ ពេលដែល Ma Huan (១៤៣៣ : ៨៦-៨៧) បានធ្វើដំណើរមកដល់ប្រទេសជ្វា មិនមានទីក្រុងជំនួញណាមួយដែលមានកំពែងការពារនោះទេ (យ៉ាងហោចណាស់នេះក៏ជាការយល់ឃើញរបស់ជនជាតិចិនដែរ) ។ ទីក្រុង ធំៗរបស់ម៉ាឡេដូចជាម៉ាឡាកា អាចេ ចូហរ និងប្រ៊ុយណេសុទ្ធតែមិនមានកំពែងការពារទីក្រុងទេ លើកលែងតែពេលដែលគេបោះរបងចម្រឹងបុស្សីឡើងសម្រាប់ការការពារបណ្តោះអាសន្នប៉ុណ្ណោះ ។ អ្នកកត់ត្រាពង្សាវតាអាចេម្នាក់ដោយយល់ច្បាស់ពីការផ្លើងធ្ងល់របស់ពួកអ្នដំណើរអារ៉ាប់ និងឥណ្ឌាភាពចម្លែកនៃការគ្មានអ្វីការពារទីក្រុងបានអះអាងថា «ទីក្រុងនេះគ្មានកំពែងការពារដូចទីក្រុងដទៃទៀតទេ ដោយសារតែវាមានដំរីចម្បាំងច្រើន» ដែលមានលទ្ធភាពអាចការពារទីក្រុងនេះបាន (Hikayat Aceh : ១៦៦)។

ដោយសារតែមានការរីកចម្រើនទីក្រុងយ៉ាងរហ័ស និងបំណងចង់ការពារទីក្រុងពីការឈ្លានពានរបស់ពួកទាហានជើងទឹកអឺរ៉ុប កំពែងការពារទីក្រុងបានការកកើតឡើងរីកសាយភាយជាច្រើននៅក្នុងសតវត្សរ៍ទី ១៦ និង ១៧ ។ ទីក្រុងអយុធ្យាបានកសាងកំពែងការពារទីក្រុងរបស់ខ្លួននៅក្នុងឆ្នាំ ១៥៥០ ហើយមកទល់នឹងឆ្នាំ ១៦០០ ទីក្រុងផ្សេងៗរបស់ជ្វាដូចជាបង់តេន ចាប៉ារ៉ា ទុយបាន ប៉ាទី និងស៊ុយរ៉ាបាយ៉ា ក៏បានកសាងកំពែងទីក្រុងដូចគ្នានេះដែរ ។ នៅក្នុងឆ្នាំ ១៦៣៤ ប្រជារាស្ត្រនៃក្រុងម៉ាកាសសារ បានសាងសង់កំពែងប្រវែងប្រហែល ១០ គីឡូម៉ែត្រដើម្បីការពារទីក្រុងពីការវាយប្រហារតាមផ្លូវសមុទ្ររបស់ពួកហូឡង់ (ទោះបីជាគេមិនឃើញមានព្រំប្រទល់ដែនដីរបស់ទីក្រុងក៏ដោយ) ហើយកំពែងនៅតាមមាត់សមុទ្រស្រដៀងគ្នានេះដែរគឺជារបាំងការពារដ៏មាំរបស់រាជធានីហ្គេលហ្គេលនៅកោះបាលី (Reid 1983A: 142; Lintgens 1597: 101-02) ។ ដោយសារតែមានការរីកចម្រើនបរិវេណក្រុងច្រើនពេកនៅខាងក្រៅកំពែង កំពែងទាំងនេះអាចការពារ បុកំការពារបានមួយផ្នែកនូវតំបន់ស្នូល ដែលជាគ្រឹះសំខាន់របស់ព្រះរាជវាំងតែប៉ុណ្ណោះ ។ ដោយសារជាទូទៅ គេមិនអនុញ្ញាតឲ្យជនបរទេសរស់នៅក្នុងបរិវេណរបស់កំពែងទាំងនោះ ធ្វើឲ្យលំហូរចូលមកឥតដាច់នៃឈ្មួញអន្តោប្រវេសន៍ និងជនអន្តោប្រវេសន៍ថ្មីៗ មកតាំងទីលំនៅបន្ថែមនូវលំនៅស្ថានប្រៀបដូចជាភូមិនៅខាងក្រៅកំពែង ។

សូម្បីតែតំបន់ដែលមានកំពែងការពារមើលទៅសុទ្ធតែព្រៃឈើពណ៌បៃតង និងលំនៅស្ថាននៅដាច់ៗពីគ្នាខុសពីទីក្រុងនៅអឺរ៉ុប និងប្រទេសចិន ។ នៅទីក្រុងប៉ាហាង កំពែងការពារក្រុងមាន «សុទ្ធតែដើមដូង និងរុក្ខជាតិដទៃទៀត ដូច្នេះវាមើលទៅមានទិដ្ឋភាពហាក់ដូចជាទីធ្លាជាយក្រុង និងសួនច្បារច្រើនជាងទីក្រុងមួយដែលមានមនុស្សរស់នៅច្រើន» (Matelief ១៦០៨ : ១២២) ។ នៅអយុធ្យា គេឃើញមានតែតំបន់ក្បែរកំពង់ផែប៉ុណ្ណោះ ដែល




រូបភាពលេខ ១៥
បរិវាណរស់នៅរបស់ជនជាតិថ្វាក្នុងទីក្រុងសូរ៉ាកាតា ។

មានប្រជាជនរស់នៅច្រើនកកកុញ ដែលតំបន់នោះគ្របដណ្តប់ប្រហែលមួយភាគប្រាំមួយនៃតំបន់ដែលមានកំពែងការពារ (La Loubère ១៦៩១ : ៦ សូមមើលផែនទីលេខ ៦ ខាងលើ) ។ នៅក្រៅកំពែងព្រះរាជវាំង ឬក្រៅតំបន់ដែលមានកំពែងការពារ តំបន់ប្រជុំជនក្រុងនៅជុំវិញទីផ្សារលាតសន្ធឹងទៅជាប់នៅជាប់ និងភូមិជិតខាងដោយមិនមានភាពខុសប្លែកគ្នានូវម៉ូដសំណង់អាគារឡើយ ។

ជនជាតិបរទេសដែលធ្វើដំណើរមកដល់ភូមិក្នុងក្រុងទាំងនេះយល់ថា ពួកគេកំពុងតែស្ថិតនៅក្នុងទីក្រុងមួយដែលមានភាពខុសស្រឡះពីទីក្រុងទាំងឡាយដែលពួកគេធ្លាប់បានស្គាល់នៅតំបន់ដំណើរខ្យល់មូសុងខាងលើ÷ «ទីក្រុងអាឈៀន (អាចេ) ប្រសិនបើគេហៅអ៊ីចឹង គឺជាទីក្រុងដែលមានទំហំធំទូលាយ និងកសាងឡើងនៅក្នុងព្រៃ

*ដូច្នេះហើយយើងមិនអាចមើលឃើញលំនៅស្ថាននៅក្នុងទីក្រុងនេះបានទេ លុះត្រាតែយើងទៅដល់តែម្តង។ ជាងនេះទៅទៀត យើងក៏មិនអាចចូលទៅកាន់កន្លែងណាមួយនោះដែរ ក្រៅតែអំពីប្រទះឃើញផ្ទះសម្បែង និងក្រុមមនុស្សជាច្រើនតែប៉ុណ្ណោះ ។ ដូច្នេះខ្ញុំគិតថា ទីប្រជុំជននេះលាតសន្ធឹងនៅលើផ្ទៃដីទាំងមូលតែម្តង»* (Davis *១៦០២:១៤៧)* ។ *សម្រាប់អ្នកទេសចរបស្ចិមប្រទេស ដែលធ្វើដំណើរមកដាន់ទឹកដីនេះមុនគេបង្អស់គេតែងតែមានការភ្ញាក់ផ្អើលជាខ្លាំងចំពោះភាពខៀវស្រងាត់របស់ទីក្រុងអាឆេ ។*

> បើយើងស្រមៃទៅដល់ព្រៃព្រឹក្សាដែលសម្បូរដោយដើមដូង ឫស្សី ដើមចេក ម្នាស់ នឹងមាននូវជងទន្លេដ៏គួរឲ្យគយគន់ មានទូកត្រៀបត្រាអណ្តែតលើផ្ទៃទឹកនៅចំកណ្តាលព្រៃព្រឹក្សានោះ ។ បើនៅក្នុងព្រៃនេះមានផ្ទះសម្បែងជាច្រើនខ្ពង់ធ្វើពីឈើផ្តៅ ត្រែង និងសំបកឈើក្រាស់ៗ ហើយតម្រៀបជួរបង្កើតបានជាផ្លូវថ្នល់ និងសង្កាត់ដាច់ដោយឡែកៗពីគ្នា ដែលខាន់ដាច់ពីគ្នាដោយវាលស្មៅ និងរុក្ខាលតាវល្លិ ដែលលាតសន្ធឹងពាសពេញផ្ទៃព្រៃព្រឹក្សានេះ ដូចទៅនឹងប្រជាជនច្រើនកកកុញដែលអ្នកឃើញនៅក្នុងទីប្រជុំជនរបស់អ្នកដូច្នេះដែរ ។ អ្នកប្រាកដបង្កើតបានរូបភាពទីក្រុងអាឆេនៅក្នុងគំនិតរបស់អ្នក ហើយអ្នកក៏នឹងប្រាកដជាយល់ស្របថាទីក្រុងប្រភេទថ្មីនេះអាចធ្វើឲ្យអ្នកដំណើរទាំងឡាយណាដែលបានឆ្លងកាត់ទីនេះមានភាពសប្បាយរីករាយបាន (Premare ១៦៩៩ : ៣៤៤-៤៥)។

*ប្រការនេះមិនមែនជាករណីដែលថាជនចំណាកស្រុកមកពីតំបន់ជនបទបន្តនូវទំនៀមទម្លាប់រស់នៅតាមបែបដើមរបស់ខ្លួននោះទេ ។ សង្កាត់ដំបូងៗរបស់ទីក្រុងមួយចំនួនដូចជា ម៉ាឡាកា ហ្សាកាតា និងម៉ាកាសសា រក្សាបាននូវព្រៃឈើ មាន់ទា និងផ្ទះសង់មានតែមួយជាន់របស់ខ្លួនជាយូរលង់រាប់សតវត្សរ៍មកហើយ ។ ជាការពិតទៅធាតុអាកាសគឺជាកត្តាមួយដែលធ្វើឲ្យទីក្រុងទាំងនេះមានលក្ខណៈដូច្នេះ ។ សង្កាត់ដែលគ្មានព្រៃឈើ និងមានមនុស្សអ៊ូអរណែនណាន់តាន់តាប់ ដែលជនជាតិចិន និងក្រោយមកទៀតជនជាតិអឺរ៉ុបបានកសាងឡើងពីឥដ្ឋ ឬថ្ម មានលក្ខណៈធុញថប់ ស្អុះស្អាប់ងាយបង្ករជំងឺ និងងាយទទួលរងទាំងកម្តៅព្រះអាទិត្យ និងទឹកជំនន់ ។ ក្រោយមក គំរូទីក្រុងខុសធម្មតានេះមានបញ្ហាកាន់តែធ្ងន់ធ្ងរឡើងៗ ហើយក៏ត្រូវគេបោះបង់ចោលទុកឲ្យអ្នកក្រីក្ររស់នៅ ។ សារៈសំខាន់នៃដើមដូង និងដើមឈើហូបផ្លែដទៃទៀត រល្លិម្ល និងរុក្ខជាតិក្លិនក្រអូបផ្សេងៗចំពោះសេដ្ឋកិច្ចគ្រួសារ គឺជាមូលហេតុមួយផ្សេងទៀតសម្រាប់ចំណូលចិត្តវប្បធម៌បែបនេះ ។ រុក្ខជាតិមិនមែនជាផ្ទះ ឬក៏ដីធ្លី គឺជាអចលនទ្រព្យឯកជនដ៏សំខាន់ ដែលមានចែងក្នុងច្បាប់* (Undang-undang Melaka: *១០៦–០៩)* ។ *ពេលដែលជនជាតិអង់គ្លេសសុំកាន់កាប់ដីមួយឡូដើម្បីសង់រោងចក្ររបស់ខ្លួននៅក្រុងម៉ាកាសសារនៅក្នុងឆ្នាំ ១៦១៣ ស្តេចស៊ុលតង់របស់ទីក្រុងនេះបានតម្រូវឲ្យពួកគេទូទាត់ប៉ះប៉ូវដល់អ្នកដែលរស់នៅទីនោះពីមុននូវសំណាងសម្រាប់តែដើមដូងប៉ុណ្ណោះ ។ ជាធម្មតា ម្ចាស់ផ្ទះអាចសែងផ្ទះរបស់ខ្លួនទៅកាន់ទីតាំងថ្មីបាន* (Jourdain *១៦១៧ : ២៩៣)* ។

*ទោះជាយ៉ាងនេះក្តី ចំណូលចិត្តក្នុងការដាំដំណាំគឺមិនមែនជាបំណកស្រាយតែមួយនោះទេ ។ អ្នកស្រុក* Naples *ឬក៏ខេត្តគង់តុង ក៏ទំនងជាពេញចិត្តនឹងរក្សាដើមឈើដែរ ប្រសិនបើពួកគេបើកសិទ្ធិឲ្យធ្វើដូច្នោះ ។កត្តាផ្សេងទៀតគឺថា កំពែងទីក្រុងដែលមានមិនអាចរារាំងការរីកធំរបស់ទីក្រុងបានទេ ។ ជាការពិត យុទ្ធសាស្ត្រចម្បងគឺមិនមែនដើម្បីការពារទីក្រុងជាអគ្គភាពមួយនោះទេ បើទោះបីជាគេអាចនឹកឃើញដល់អគ្គភាពនោះក៏ដោយ ។ ព្រះមហាក្សត្រការពារខ្លួនព្រះអង្គ និងក្រុមជិតស្និទ្ធនឹងព្រះអង្គនៅក្នុងបរិវេណកំពែងព្រះរាជវាំងរបស់ព្រះអង្គដើម្បី*

ការពារទប់ទល់ទៅនឹងមន្ត្រីដែលមានអំណាច និងឥទ្ធិពលខ្លាំងក្លាជ្រុល ក៏ដូចជាទប់ទល់នឹងមហាអំណាចបរទេស ប៉ុន្តែពួកបរទេសសាហាវយង់ឃ្នង ។ នៅពេលជួបប្រទះជាមួយនឹងសត្រូវខ្លាំងជាងខ្លួនយុទ្ធសាស្ត្ររបស់ប្រជារាស្ត្រទាំងអស់ ក៏ដូចជាមេដឹកនាំ គឺប្រមូលរបស់របរមានតម្លៃរបស់ពួកគេ និងគេចខ្លួនចូលទៅក្នុងព្រៃដែលនៅជិតខាង ។ ជាទូទៅការវាយប្រហាររបស់សត្រូវ គឺមានគោលបំណងដើម្បីកេណ្ឌយកតែប្រជាជន គឺមិនយកទ្រព្យសម្បត្តិ ប៉ុន្តែទឹកដីទេ ។ ប្រសិនបើប្រជាជនអាចរត់គេចខ្លួនបាន សត្រូវទាំងនោះមិនអាចធ្វើអ្វីបានច្រើនឡើយ ក្រៅតែអំពីការដុតផ្ទះ កាប់បំផ្លាញដើមឈើ និងលួចយកនូវរបស់របរមានតម្លៃទាំងប៉ុន្មានពីក្នុងព្រះរាជវាំង និងភូមិគ្រឹះរបស់ពួកអភិជន ។

នៅក្នុងប្រទេសហ្វីលីពីន ពួកអេស្ប៉ាញបានប្រទះឃើញថានៅពេលដែលទទួលរងការប្រហារ ប្រជាជនហ្វីលីពីន «ត្រៀមរួចជាស្រេចក្នុងការបោះបង់ចោលផ្ទះសម្បែង និងទីប្រជុំជនរបស់ពួកគេដើម្បីទៅរកកន្លែងផ្សេងទៀត ប៉ុន្តែរត់ខ្វាត់ខ្វាយយ៉ាងរហ័សទៅពួននៅតាមតំបន់ភ្នំ និងខ្ពង់រាបខ្ពស់ៗ» (Legazpi ១៥៦៩ : ៦០) ។ សូម្បីតែនៅទីក្រុងម៉ាឡាកាដ៏មហិមាក៏ដោយ ពេលដែលការប្រឆាំងតបតទៅនឹងការវាយប្រហាររបស់ពួកព័រទុយហ្កាល់ទទួលការបរាជ័យ ព្រះមហាក្សត្រ និងរាជវង្សានុវង្ស រួមទាំងក្រុមមនុស្សដែលរស់នៅក្នុងបរិវេណព្រះរាជវាំងទាំងអស់ បានដកថយទៅកាន់តំបន់ឆ្ងាយៗពីមាត់សមុទ្រ ដោយ «មាននូវគំនិតថា Afonso Dalboquerque ជាធម្មតាគ្រាន់តែមានន័យថា លួចប្លន់ទីក្រុង និងបន្ទាប់មកចេញនាវាទៅវិញដោយយកទៅជាមួយនូវរបស់របរមានតម្លៃជាច្រើន» (Albuquerque ១៥៥៧ : ១២៩) ។ ដោយសារសម្ភារៈសំណង់មានភាពស្រាលគេអាចកសាងទីក្រុងឡើងវិញតែក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ ហើយប្រសិនបើចាំបាច់ គឺកសាងឡើងវិញនៅទីតាំងថ្មីដែលមានសុវត្ថិភាពជាងមុន ។ នៅឆ្នាំ ១៦៣៤ ពួកអ្នកធ្វើដំណើរអង់គ្លេសមួយក្រុមបានចំណាយអស់រយៈពេល ២ ថ្ងៃ ក្នុងការស្វែងរកកំពង់ផែដែលធ្លាប់រុងរឿងឈ្មោះ អ៊ីនដ្រាហ្គីរី (ស៊ូម៉ាត្រា) រហូតដល់ពួកគេរកឃើញថា ទីប្រជុំជនទាំងមូលបានផ្លាស់ទីទៅតំបន់ខ្សែទឹកខាងលើដែលត្រូវធ្វើដំណើរបីថ្ងៃទើបដល់ជាការឆ្លើយតបទៅនឹងការវាយប្រហាររបស់ពួកអាចេះ (Reid ១៩៨០ : ២៤៤-៤៥)។

បើទោះបីជាសម្បូរដើមឈើ និងទីធ្លាទំនេរក៏ដោយលំហូរចូលនូវប្រជាជនថ្មីមកក្នុងសង្កាត់នានាដែលមានស្រាប់នៅក្បែរទីផ្សារ បានបង្កើតជាតំបន់ដែលមានផ្ទះឈើជាច្រើនខ្នងសង់នៅជាប់ៗគ្នា ។ នៅប៉ាតានី «ឆ្មាអាចដើរពីប៉ាយុងហ៊ុយជុង (Payung Hujung) ទៅ គួឡា អារុ (Kuala Aru)ដោយមិនចុះជាន់ដី» (Hikayat Patani: ១១៣) ។ នៅទីកន្លែងបែបហ្នឹង គ្រោះថ្នាក់បង្កឡើងដោយអគ្គិភ័យមានភាពខ្លាំងក្លាបំផុត ។ គេបានរាយការណ៍ថានៅអាចេះមានផ្ទះចំនួន ៨០០ ខ្នងត្រូវបានបំផ្លាញដោយអគ្គិភ័យក្នុងឆ្នាំ ១៦០២ នៅម៉ាកាសសារអស់ចំនួន ១២៦០ ក្នុងឆ្នាំ ១៦១៤ និងនៅអយុធ្យាចំនួន ១០,០០០ ខ្នង ក្នុងឆ្នាំ ១៥៤៥ ។ ទីក្រុងម៉ានីលមួយភាគធំត្រូវបានអគ្គិភ័យបំផ្លិចបំផ្លាញអស់នៅក្នុងឆ្នាំ ១៥៨៣ ហើយក្រុងប៉ាតានីមួយភាគធំផងក៏ទទួលរងផងដែរក្នុងការបះបោរពីសំណាក់ពួកទាសករនៅក្នុងឆ្នាំ ១៦១៣ ។ ពិសេសជាងនេះ នៅក្នុងទីក្រុងដែលមានជាតិសាសន៍ចម្រុះរស់នៅជាមួយគ្នា ពេលខ្លះគេប្រើភ្លើងដើម្បីដុតបំផ្លាញរបស់របរផ្សេងៗរបស់សត្រូវរបស់ខ្លួន ហើយដែលរឿងនេះគឺជាកង្វល់ដ៏ចម្បងសម្រាប់ឈ្មួញដែលមានឃ្លាំងទំនិញច្រើនដែលត្រូវការពារ ។ បន្ទាប់ពីបានឃើញផ្នែកខាងកើតនៅក្បែរទីផ្សារធំរបស់ទីក្រុងបង់តេនបានត្រូវគេដុតបំផ្លាញ ៥ ដងក្នុងរយៈពេលតែ ៣ ខែប៉ុណ្ណោះ អ្នកដើងសារជំនួញជនជាតិអង់គ្លេសម្នាក់បានសរសេរអំពីគ្រួញគ្នេរដូច្នេះថា ៖

> អូ ពាក្យថាភ្លើងនេះ! មានគេនិយាយពាក្យនេះនៅជិតៗខ្ញុំ ទាំងជាភាសាអង់គ្លេស ភាសាម៉ាឡេ ភាសាជ្វា ឬក៏ភាសា Chyna ទោះបីជាខ្ញុំមានអារម្មណ៍ហាក់ដូចជាចង់ងងុយដេកក៏ដោយ ក៏ខ្ញុំបានស្ទុះលោតចេញពីគ្រែរបស់ខ្ញុំដែរ ។ ពេលខ្លះ ខ្ញុំបានស្ទុះចេញពេលដែលលឺអ្នកយាមរបស់យើងខ្សឹបខ្សៀវគ្នារឿងភ្លើងពីរឿងភ្លើង . . . នេះជាភាពភ័យខ្លាចដែលយើងកំពុងតែរស់នៅជាមួយដោយគ្មានមូលហេតុអ្វីទាំងអស់ ។ ជាច្រើនដងហើយ ដែលខ្ញុំតាមដានមើលរហូតដល់ម៉ោង ១២ អធ្រាត ខ្ញុំភ្ញាក់ឡើងចំនួន ៣ ដង ក្នុងមួយយប់មុនពេលមេឃភ្លឺដោយសារតែការភ័យខ្លាចមានភ្លើងឆេះ។ ខ្ញុំបានត្អូញត្អែរចំពោះព្រះជាម្ចាស់ថា ខ្ញុំមិនបានដេកអស់ជាច្រើនយប់មកហើយដោយសារភាពភ័យខ្លាច again for the best ship's lading of pepper that ever came from thence (Scott ១៦០៦ : ៩៧-៩៩) ។

ឈរលើហេតុផលនេះយ៉ាងហោចណាស់ស្អុត ប្រហែលជាមានការសប្បាយចិត្តជាងចំពោះរាជធានីភូមាដែលមានច្បាប់ទម្លាប់ល្អជាង ។ នៅទីនោះប្រជាជនអាចចម្អិនម្ហូបអាហារនៅក្នុងចង្ក្រានដែលមានជម្រៅ និងម៉ោងតាមបទបញ្ញាត្រឹមត្រូវ ហើយនៅទីនោះផងដែរ អ្នកយាមកាមអគ្គិភ័យបានឆែកឆេរផ្ទះសម្បែងទាំងឡាយ ៥ ដងក្នុងមួយថ្ងៃ ដើម្បីឲ្យប្រាកដថាមិនមានអណ្តាតភ្លើងឆេះដោយគ្មានការអនុញ្ញាតនោះទេ (Than Tun ១៩៨៣: ៨៤–៨៥) ។

## ទីផ្សារ

> «ខ្ញុំថែមឲ្យមួយ មាស និងមួយគុប៉ាងទៀត»
>
> «មិនបានទេ ខ្ញុំប្រាកដជាខាត»
>
> «ខ្ញុំមិនមិនហ៊ានឲ្យថ្លៃជាងហ្នឹងទេ»
>
> «Bismillah អ៊ីចឹងទៅរកមើលកន្លែងផ្សេងទៀត ក្រែងលោអាចទិញបានថោកជាងនេះ ។ លោកមិនអាចរកទិញនៅកន្លែងណាដែលលក់ថោកជាងនេះទៀតទេ ។ ខ្ញុំលក់ក្នុងតម្លៃសមរម្យដូចអ្នកដទៃទៀតដែរនៅក្នុងទីក្រុងនេះ ។ ខ្ញុំចំណេញបានតែបន្តិចបន្តួចទេ ។ ខ្ញុំមកអង្គុយលក់នៅតូបរបស់ខ្ញុំនេះមិនមែនដើម្បីខាតដើមនោះទេ ។ ខ្ញុំរស់នៅពឹងផ្អែកលើការលក់ដូរនេះដែរ ។ អ្នកដឹងទេថារបស់របរឥឡូវថ្លៃណាស់ ។ របស់របរឡើងថ្លៃតាមគ្នា ។បើមិនហ៊ានឲ្យខ្ញុំ ៥ មាស នោះទេ ខ្ញុំមិនអាចលក់ឲ្យបានទេ ។ លោកកំណាញ់មែន » នេះជាផ្នែកនៃកិច្ចសន្ទនាជាភាសាម៉ាឡេដែលប្រើនៅទីផ្សារក្រុងអាឆេ ដកស្រង់ពី Houtman ១៦០៣ : ៦៥-៦៦

ទោះបីបើជាសកម្មភាពពាណិជ្ជកម្មមានការរីកចម្រើនមិនធម្មតានៅរវាងឆ្នាំ ១៤០០ និង ១៦០០ ក៏ដោយក៏ទីផ្សារនៅតែជាគ្រឹះស្ថានក្នុងការចាត់ចែងចរាចរទំនិញ ។ ទីផ្សារមានការរីកចម្រើនទាំងទំហំ និងចំនួនតូបលក់ដូរ ហើយកិច្ចការជំនួញធំៗទាំងឡាយ (ជាពិសេសរបស់ពួកអឺរ៉ុប) ប្រព្រឹត្តិទៅកាន់តែច្រើនឡើងៗដោយការចរចាជាលក្ខណៈបុគ្គលនៅក្រៅទីផ្សារ ប៉ុន្តែការដោះដូរទំនិញ និងលុយដោយផ្ទាល់តាមរយៈការតថ្លៃប្រដេងគ្នា នៅតែប្រព្រឹត្តិទៅតាមទីផ្សារដដែល ។

មានគោលការណ៍ខុសគ្នាពីរដែលទំនងជាត្រូវបានអនុវត្ត ។ នៅតាមទីក្រុងធំៗនៅតំបន់ឧបទ្វីបកិច្ចការជំនួញជាលក្ខណៈអន្តរជាតិភាគច្រើនប្រព្រឹត្តិទៅនៅលើទីផ្សារធំតែមួយប៉ុណ្ណោះ ហើយគេមិនឃើញមានទីក្រុងណាមួយដែលមានទីផ្សារលើសពី ៣ ដើម្បីបម្រើតម្រូវការជនបរទេសនោះទេ (ផ្ទុយពីចំនួន ទីផ្សារផ្លែឈើបន្លែដែលមាន

នៅគ្រប់តំបន់ទាំងអស់) ។ ទីផ្សារទាំងនេះគឺជាទីផ្សារសេរី ដែលនរណាៗក៏អាចធ្វើជាម្ចាស់កម្មសិទ្ធិតូបលក់ដូរបានដែរ ដោយគ្រាន់តែបង់ថ្លៃឈ្នួលជាប្រចាំឲ្យអាជ្ញាធរតែប៉ុណ្ណោះ ។ យោងទៅលើអាដាត់ អាចេ (Adat Aceh) នៅក្រុងអាចេ តម្លៃត្រូវបានបង្គាប់ឲ្យបង់គឺមួយកាក់មាសតូច (មាស)សម្រាប់តូបមួយក្នុងមួយខែ (Lombard ១៩៦៧ : ៤៦, cf. Chou Ta-Kuan ១២៩៧ : ២៧) ។ គំរូបែបនេះក៏ទំនងជាត្រូវគេអនុវត្តផងដែរ នៅតាមទីក្រុងរបស់ប្រទេសតៃដំបូងៗ ដូចជា សុខោទ័យជាដើម ។

ផ្ទុយទៅវិញ នៅក្រុងថាំងឡុង និងអយុធ្យា គេឃើញមានការត្រួតត្រាដោយព្រះរាជវាំងច្រើន ។ គឺវាមានទម្រង់ជាការកំណត់ឲ្យតំបន់មួយចំនួននូវសិទ្ធិផ្ដាច់មុខក្នុងការលក់ដូរផលិតផលណាមួយ ។«រាល់ទំនិញផ្សេងៗលក់នៅក្នុងទីក្រុងនេះ (ថាំងឡុង) ត្រូវបានដាក់លក់នៅតាមដងផ្លូវដែលគេកំណត់ឲ្យ ហើយតាមដងផ្លូវទាំងនេះទៀតសោត គេតម្រូវឲ្យអ្នកភូមិមកពីភូមិពីរបីប៉ុណ្ណោះ ដែលមានសិទ្ធិក្នុងការកាន់កាប់តូបលក់ដូរនៅតាមដងផ្លូវទាំងនោះបាន» (Baron ១៦៨៥ : ៣) ។ គេបានហៅឈ្មោះសង្កាត់ទៅតាមឈ្មោះទំនិញជំនាញដែលបានលក់ ឬផលិត នៅទីនោះដូចជា (Phuong) ដែលឈ្មោះនេះមួយចំនួននៅមានសេសសល់ប្រើនៅទីក្រុងហាណូយសម័យទំនើបនេះ ។ នៅអយុធ្យា គេក៏ឃើញមានទីផ្សារជាច្រើនលក់ផលិតផលដោយឡែកៗពីគ្នា ដែលមានចំនួនច្រើនរហូតដល់ទៅ ៩០ផ្សារ នៅសតវត្សរ៍ទី ១៨ ។ ទីផ្សារភាគច្រើនស្ថិតនៅក្នុង ឬក៏ក្បែរទីធ្លាព្រះវិហារដែលសម្បូរមនុស្សម្នាកកកុញច្រើន ។ មូលហេតុនៃភាពខុសគ្នានេះបណ្ដាលមកពីនិន្នាការរបស់ព្រះមហាក្សត្រវៀតណាម និងរបស់ព្រះមហាក្សត្រសៀមទៅរកការគ្រប់គ្រងផ្ដាច់មុខនូវមុខទំនិញជំនួញ និងជាច្រើនប្រភេទ ដែលចាត់ទុកជាពិសេសជាសួយសារអាករសម្រាប់ព្រះមហាក្សត្រ ដោយក្នុងមុខទំនិញនីមួយៗមានមន្ត្រីរាជវាំងមួយរូបជាអ្នកទទួលខុសត្រូវគ្រប់គ្រង និងចាត់ចែងឲ្យមានទីផ្សារ (O'Connor១៩៨៣ : ៥២-៥៣, Le ១៩៧១ : ២២២-២៣) ។

សូម្បីតែនៅតាមតំបន់ឧបទ្វីប ក៏ទំនិញទាំងអស់មិនមែនសុទ្ធតែតម្រូវឲ្យលក់តែក្នុងទីផ្សារធំនោះទេ ។ Pires បានសរសេរថា នៅម៉ាឡាកាមាន ស្ត្រីលក់ដូរអីវ៉ាន់ «នៅគ្រប់ដងផ្លូវទាំងអស់» ដោយបង់ថ្លៃឈ្នួលសម្រាប់សិទ្ធិលក់ដូរនេះទៅឲ្យអូរ៉ង់កាយ៉ា (Orangkaya)ដែលទទួលខុសត្រូវនៅតំបន់នោះ (Pires ១៥១៥ : ២៧៤) ។ ម៉ាទីន (១៦០៤: ៥៣) បានសង្កេតឃើញថា នៅទីក្រុងអាចេ ទីផ្សារផ្លែឈើ និងបន្លែភាគច្រើនបើកលក់នៅពេលព្រឹកចំណែកឯដាំពែរ (១៦៩៩ : ៩២) វិញបានកត់សម្គាល់ថា នៅក្រុងអាចេ អ្នកដូរលុយជាស្ត្រីមិនត្រឹមតែមាននៅតាមទីផ្សារប៉ុណ្ណោះទេ តែក៏មាននៅតាមកាច់ជ្រុងផ្លូវនីមួយៗផងដែរ ។ ក្រៅពីស្ត្រីក្នុងស្រុកទាំងនេះ គេក៏ឃើញមានក្រុមផ្សេងទៀតមួយក្រុម ដែលទទួលបានសិទ្ធិធ្វើអាជីវកម្មនៅខាងក្រៅទីផ្សារ ។ ឈ្មួញបរទេសធំៗមួយចំនួនជាពិសេសជនជាតិចិន អាស៊ីខាងលិច និង ជនជាតិអឺរ៉ុបបានទទួលការអនុញ្ញាតឲ្យលក់ទំនិញនៅឯគេហដ្ឋានរបស់ពួកគេតែម្ដងដែលស្ថិតនៅសង្កាត់ជនបរទេសរស់នៅខាងក្រៅមណ្ឌលក្រុង ។ នៅក្នុងទីក្រុងភាគច្រើន ក្នុងកំលុងរដូវដែលមាននាវាចិនចូលមកចតនៅកំពង់ផែ សង្កាត់ដែលមានជនជាតិចិនរស់នៅប្រៀបដូចជាកន្លែងពិព័រណ៍ពាណិជ្ជកម្មដូច្នេះដែរ ហើយប្រជាជននៅក្នុងក្រុងបានទៅទីនោះដើម្បីទិញប្រដាប់ប្រដារប្រើប្រាស់ និងផលិតផលតូចៗផ្សេងៗ និងដើម្បីទទួលទានអាហារ (Guillot ១៩៨៩ : ១៤២-៤៣, លូដូវីស្គស់ ១៥៩៨ : ១១៣, Borri ១៦៣៣: I; ដាំពែរ ១៦៩៩ : ៩៤-៩៥) ។ មិនមានអ្វីធ្ងល់ទេសិទ្ធិអត្តិភាពក្នុងការធ្វើអាជីវកម្មនៅក្រៅទីផ្សារដូច្នេះដាច់ខាតត្រូវតែមានការបង់ថ្លៃឈ្នួលមិនខាន ប៉ុន្តែសម្រាប់ឈ្មួញបរទេសធំៗវិញ ពួកគេអាចមានសិទ្ធិក្នុងការចរចាដើម្បីបានសិទ្ធិអត្តិភាពនោះបាន ។

ទោះជាយ៉ាងនេះក្តី គេឃើញមានតែនៅក្នុងទីផ្សារធំៗប៉ុណ្ណោះ ដែលមានការកំណត់តម្លៃបន្ទាប់ពីដំណើរការនៃការតថ្លៃមក ។ ហ្វ្រិឌ៊ីរិ ឌឺហ្វូត (១៦០៣ : ៤៤-៤៨, ៦០-៧១, ៨៦-៩៤) បានផ្តល់នូវឧទាហរណ៍យ៉ាងជាក់ច្បាស់អំពីការជជែកតវ៉ាដែលបន្តមានដើម្បីកំណត់តម្លៃទំនិញ និងសេវាកម្មទាំងឡាយ ដោយសារតែតម្លៃមានការប្រែប្រួលចុះឡើងអាស្រ័យទៅលើការធ្វើដំណើរមកដល់ និងចាកចេញទៅវិញរបស់នាវាទាំងឡាយ ។ដើម្បីពន្យល់ថាហេតុអ្វីបានជាពួកម៉ាឡេងកាន់ស៍ បាត់បង់ចំណូលចិត្តក្នុងការដាំផ្កាក្លាំពូបន្ទាប់ពីការមកដល់របស់ពួកហូឡង់នោះ ឡូរ៉េន រៀល (១៦១៨ : ៨៧) បានលើកឡើងចំណុចមួយក្នុងចំណុចជាច្រើនថា ករណីនេះ គឺបណ្តាលមកពីការបដិសេធរបស់ពួកហូឡង់ក្នុងការតថ្លៃ ដែល «ពួកគេនិយាយថា នៅកន្លែងហ្នឹង វាជាប្រពៃណីទៅហើយក្នុងចំណោមឈ្មួញទាំងឡាយក្នុងការជជែកតវ៉ា ដោយហេតុថាពួកគេត្រូវតែទទួលយកសាច់ក្រណាត់ពីពួកយើងក្នុងតម្លៃមួយដែលបានកំណត់ទុករួចជាស្រេច និងក្នុងឥរិយាបថមានការបង្ខិតបង្ខំខ្លះ»។ ប្រជាជនអាស៊ីអាគ្នេយ៍ប្រហែលជាមានការអាណិតអាសូរ (អ្នកខ្លះប្រាកដជាបានអាន) នូវរឿងគំរូរបស់ជនជាតិពែរសង់ និយាយអំពីឈ្មួញម្នាក់ដែលបានឈ្លោះប្រកែកពេញមួយថ្ងៃអំពីចំនួនទឹកប្រាក់ដែលបុរសអ្នកលក់ដូរជំពាក់បំណុលគាត់ ហើយបន្ទាប់មកពេលដែលគាត់បានទទួលលុយនោះមក គាត់បែរជាឲ្យលុយនោះទាំងអស់ទៅកូនជាងរបស់បុរសអ្នកលក់ដូរនោះទៅវិញ ។ គាត់បានពន្យល់ថា «ខ្ញុំគឺជាឈ្មួញ ហើយវាជាច្បាប់ពាណិជ្ជកម្មក្នុងកំលុងពេលទិញលក់ និងចរចារ ដែលថែងថាប្រសិនបើនរណាម្នាក់ត្រូវបានគេបោកប្រាស់សូម្បីតែប្រាក់មួយដិរហាមនោះ ក៏ដោយអ្នកនោះទំនងដូចជាត្រូវគេបោកប្រាស់អស់ពាក់កណ្តាលជីវិតអ៊ីចឹងដែរ ។ មួយទៅវិញ ពេលដែលនិយាយពីការមានសន្តានចិត្តវិញ ប្រសិនបើនរណាម្នាក់មានកំហុសដោយសារតែភាពកំណាញ់ វាដូចជាគេបាននិយាយថា ពូជអ្នកនោះមិនល្អដូច្នោះដែរ» (Qabus Nama ១០៨២: ១៥៩) ។ ទោះជាយ៉ាងនេះក្តីសម្រាប់ក្រុមហ៊ុនអឺរ៉ុបវិញ គេគិតថាដំណើរការតថ្លៃបែបនេះជារឿយៗ គឺជារឿងសាំញ៉ាំ និងមិនចាំបាច់ទេ ។

កំណត់ត្រាលម្អិតអំពីទីផ្សារធំនៃទីក្រុងបង់តេន ដែលស្ថិតនៅខាងក្រៅកំពែងក្រុងខាងកើតជាប់នឹងមាត់សមុទ្រ (សូមមើលផែនទីលេខ ៨ ខាងលើ) ។ ប្រហែលជាឆ្នាំ ១៦០០ នៅលើទីផ្សារនេះ គេឃើញមានទាំងការលក់ទំនិញបោះដុំជាមួយ និងទំនិញលក់រាយមានទាំងជនបរទេស និងប្រជាជនក្នុងស្រុក ទាំងបុរស និងស្ត្រី និងថែមទាំងម្ហូបអាហារប្រចាំថ្ងៃគ្រប់ប្រភេទ នៅដាក់លក់ជាមួយរបស់របរដែលនាំមកពីតំបន់ឆ្ងាយៗផងដែរ ។ «នៅទីនោះរាល់ព្រឹក អ្នកឃើញមានឈ្មួញមកពីគ្រប់ប្រទេស ដូចជាជនជាតិព័រទុយហ្គាល់ អារ៉ាប់ ទួគី ចិន ក្លីង អ្នកពេគូ ម៉ាឡេ បង់ហ្គាល ម៉ាឡាបារី ហ្គូចារ៉ាទី អាប់ប៊ីសស៊ីនៀន និងមកពីគ្រប់តំបន់ ដើម្បីធ្វើចរាចរទំនិញរបស់ពួកគេ» (Lodewycks ១៥៩៨ : ១១០) ។ ស្ត្រីក្នុងស្រុកលក់ម្រេច និងបន្លែបន្ការ ត្រីសាច់ផ្សេងៗឲ្យអ្នកទិញជាជនបរទេស រីឯក្រុមឈ្មួញបរទេសនីមួយៗវិញមាននូវកន្លែងសម្រាប់លក់ទំនិញផ្ទាល់ខ្លួនរបស់ពួកគេ ។ នេះគឺជាទីផ្សារប្រចាំថ្ងៃលក់ក្នុងពេលជាមួយគ្នានូវម្ហូបអាហារផ្សេងៗ ដូចជាអង្ករ បន្លែបន្លា ផ្លែឈើ ស្ករ ត្រី និងសាច់ និងជាកន្លែងសម្រាប់លក់ បសុសត្វ សាច់កំណាត់ ម្រេច ផ្កាក្លាំពូ និងចន្ទន៍ក្រឹស្នា អាវុធ ប្រដាប់ប្រដាប្រើប្រាស់ផ្សេងៗ និងដែកស្ថិត (សូមមើលរូបភាពទី ១៦) ។ ស៊ីយ៉ាបាន់ដា ជាអ្នករៀបចំចាត់ចែងសណ្តាប់ធ្នាប់ទីផ្សារឲ្យមានរបៀបរៀបរយ និងជាអ្នករៀបចំជាប្រចាំឲ្យសវនាការដោះស្រាយទំនាស់ពាណិជ្ជកម្មផ្សេងៗ ( លូដូវីស្គស៍ ១៥៩៨: ១១០-១៣; Coen ១៦២៣ : ៧៧៤; Missions Etrangères ១៦៨០ : ៩៣) ។

ការលក់ដូរទំនិញនៅលើទីផ្សារក្នុងស្រុកនៅតាមតំបន់ជនបទនៅអាស៊ីអាគ្នេយ៍ គឺស្ទើរតែទាំងអស់ជាកិច្ចការ

របស់ស្ត្រី ។ រីឯបុរសវិញគ្រាន់តែដើរមើលត្រួសៗ ដើរវ៉ៃញ៉ ដើរខ្សឹបខ្សៀវនាយអាយ និងដើរលេងនៅលើទីផ្សារតែប៉ុណ្ណោះ ដោយពួកគេជាទូទៅមិនមានបំណងចង់ទិញដូរអ្វីនោះទេ លើកលែងតែក្នុងករណីត្រូវការបំផុត ។ ករណីលើកលែងនេះគឺជាការចរាចរទំនិញពីបរិមុខដែលជាទូទៅផលិតដោយបុរស និងជាកិច្ចការមានការទាក់ទងផ្ទាល់ជាមួយនឹងបុរស ដោយក្នុងចំណោមនោះសំខាន់ជាងគេគឺ អាវុធធ្វើពីលោហៈ និងឧបករណ៍ប្រើប្រាស់ផ្សេងៗ (Reid ១៩៨៨: ១៦២-៦៥) ។ ទោះជាយ៉ាងនេះក្តី នៅក្នុងទីក្រុងវិញជាទូទៅគេឃើញមានបុរសបរទេសជាច្រើនលក់ដូរនៅលើទីផ្សារ ។ «(នៅអាចេ) មានតូបលក់ដូរជាច្រើនជាកម្មសិទ្ធិរបស់ឈ្មួញដែលស្លៀកពាក់ដូចជាជនជាតិទួគី ដែលមកពីរដ្ឋតូចៗនៅអាស៊ី ដូចជាណាហ្គាប៉ាត់ទីណាំ (Nagapattinam) ហ្គូចារ៉ាត់ (Gujarat) កាពេ (Cape) ករម៉ូរីន (Cormorin) កាលីកាត់ (Calicut) កោះសីឡូន (Seylon) សៀម (Siam) បេនហ្កាល់ (Bengal) និង កន្លែងផ្សេងៗទៀត ។ ពួកគេមកទីនេះប្រហែលជា ៦ ខែ ដើម្បីលក់ទំនិញរបស់ខ្លួន ដូចជា សម្លៀកបំពាក់ធ្វើពីក្រណាត់កូតុងដ៏មានគុណភាពល្អ...សូត្រអំបោះកូតុង កាដន់ធ្វើពីព័រស៊ីឡែនគ្រប់ប្រភេទ និងឱសថ គ្រឿងទេស និងត្បូងដ៏មានតម្លៃផ្សេងៗ» (Martin ១៦០៤ : ៥៧)។ តាមពិតឈ្មួញជាបុរសដែលធ្វើដំណើរមកពីតំបន់នៅជំណើរខ្យល់មូសុងខ្លាំងលើទាំងនេះក៏ដូចជាជនជាតិអាស៊ីបូព៌ាផងដែរថ្មើកទៅនឹងការធ្វើអាជីវកម្មនៅលើទីផ្សារនៅក្នុងប្រទេសកំណើតរបស់ខ្លួនរួចទៅហើយ ។ ជាងនេះទៅទៀត នាវិកសំពៅ និងឈ្មួញតូចតាច ជនជាតិអាស៊ីអាគ្នេយ៍ ដែលបានដឹកជញ្ជូនទំនិញបន្តិចបន្តួចធ្វើដំណើរមក មិនមានជម្រើសអ្វីច្រើនក្រៅពីការលក់ទំនិញឲ្យគ្នាទៅវិញទៅមកនៅលើទីផ្សារពេលដែលពួកគេធ្វើដំណើរមកដល់លើកលែងតែពួកគេស្នាក់នៅរយៈពេលយូរគួរសមអាចរកបានប្រពន្ធបណ្តោះអាសន្នម្នាក់មកជួយលក់ដូរឲ្យពួកគេ ។ សរុបសេចក្តីមកនៅទីក្រុងបង់តេន ជាឧទាហរណ៍គេឃើញមានទីផ្សារលក់សាច់កំណាត់ផ្សេងគ្នា ដែលទីផ្សារមួយមានអ្នកលក់ជាបុរស (ជនបរទេសលក់សាច់កំណាត់ឥណ្ឌា ចិន) និងទីផ្សារមួយទៀតមានអ្នកលក់ជាស្ត្រី (អ្នកក្នុងស្រុកលក់សាច់កំណាត់ក្នុងស្រុក) ។

## ការចោះប្រាក់ និងពាណិជ្ជនីយកម្ម (ភាពជោគជ័យរបស់ប្រាក់)

ការកើនឡើងនៃផលិតកម្មសម្រាប់ទីផ្សារពិតពលោកប្រាកដជាមិនអាចទៅរួចទេ ប្រសិនបើគ្មាននូវការកើនឡើងនៃការផ្គត់ផ្គង់សាច់ប្រាក់នោះ ។ ជាការពិត កិច្ចការជំនួញមួយចំនួនធ្វើឡើងតាមរយៈការផ្លោះប្តូរទំនិញសំខាន់ៗទៅវិញទៅមក ឧទាហរណ៍ដូចជា ការដោះដូរសម្លៀកបំពាក់ជាមួយនឹងម្រេច ឬក៏ផ្កាក្លាំពូ ជាដើម ។ ក៏ប៉ុន្តែចំនួនផលិតករ និងអ្នកចែកចាយ ទាំងតូចទាំងធំរាប់សែននាក់ដែលជួយឲ្យមានលំហូរនៃទំនិញមិនអាចធ្វើការទូទាត់គ្នាតាមបែបនេះបានទេ ។ យុគសម័យពាណិជ្ជកម្មបានបង្ហាញនូវតម្រូវការជាប្រចាំឲ្យមានការបោះប្រាក់ដែលអាចប្រើប្រាស់បាន ។ ក្រៅពីសម្លៀកបំពាក់ឥណ្ឌា រូបិយវត្ថុដែលមានទម្រង់ជាប្រាក់ ស្ពាន់ និងសំណគឺជាមុខទំនិញដ៏មានសារៈសំខាន់ជាងគេបំផុតដែលហូរចូលមកក្នុងតំបន់ ។ ការដែល ជារឿយៗពាផ្គត់ផ្គង់មិនគ្រប់ទោះបីជាមានការហូរចូលដូចនេះក៏ដោយ គឺជាកត្តាដបង្ហាញទាំងពាណិជ្ជនីយកម្មដ៏ឆាប់រហ័សក្នុងចំណោមជីវភាពប្រចាំថ្ងៃរបស់ជនជាតិអាស៊ីអាគ្នេយ៍ និងទាំងភាពខ្វះខាតនៃការផ្គត់ផ្គង់រូបិយវត្ថុក្នុងស្រុកដើម្បីបំពេញតម្រូវការនៃការដោះដូរទំនិញ ។ នៅមុនសតវត្សរ៍ទី ១៥ នៅតំបន់អាស៊ីអាគ្នេយ៍ដីគោកទំនងជាមិនបានបង្កើតប្រាក់កាក់សម្រាប់ជួយសម្រួលដល់ពាណិជ្ជកម្មនោះទេ ។ ប្រាក់កាក់បានត្រូវគេផលិតឡើងនៅវាងសតវត្សរ៍ទី ៥ និង ទី ១០ តែដោយសារតែមានការចែកចាយក្នុងស្រុកតឹងតែងពេក គេបានប្រើប្រាស់កាក់ទាំងនោះសម្រាប់គោលបំណងតែសម្រាប់

ការផាកពិន័យ និងបង់ពន្ធតែប៉ុណ្ណោះ (Wicks ១៩៨៣ : ៦៧-៦៨) ។ ចក្រភពបាហ្កន និងអង្គរបុរាណ មិនបានផលិតកាក់ទេ ។ ការផលិតកាក់សម្រាប់ការធ្វើអាជីវកម្មនៅក្នុងសតវត្សរ៍ទី ១៥ គឺជាគំនិតថ្មីមួយដែលជំរុញដោយសារតម្រូវការផ្នែកពាណិជ្ជកម្ម បំណងរបស់មេដឹកនាំក្នុងការយកពន្ធ និងគំរូរបស់រដ្ឋអ៊ីស្លាម ។ មិនយូរប៉ុន្មានបន្ទាប់ពីឆ្នាំ ១៤៣០ អារ៉ាកាន (Arakan)បានដាក់ឲ្យប្រើប្រាស់នូវកាក់ប្រាក់ប្រភេទរបស់ពួកអ៊ីស្លាមបេនហ្កាលី ហើយមិនយូរប៉ុន្មានដែរ សៀមក៏បានបោះជំហានទៅរកការធ្វើឲ្យមានស្តង់ដានូវទម្ងន់ប្រាក់របស់ខ្លួន រីឯពេគូ និងតេណាស់សេរីមវិញ ក៏បានដាក់ឲ្យប្រើប្រាស់កាក់ប្រាក់ និងសំណ នៅក្នុងទសវត្សរ៍ឆ្នាំ ១៥៣០ ដែរ (ibid : ៦៨-៦៩, ១១៦-២០)។

នៅតាមតំបន់នៅឧបទ្វីបវិញ គេឃើញមានការទទួលនូវឥទ្ធិពលពីសំណាក់ឈ្មួញបរទេស និងកាក់ដែលពួកគេប្រើប្រាស់យូរលង់ជាងនៅតំបន់ដីគោក តែគេក៏ឃើញមានការបោះលុយកាក់ក្នុងស្រុក ជាពិសេសកាក់ដែលធ្វើពីមាសច្រើនដែរ ។ វ៉ារធីម៉ា (Varthema ១៥១០ : ២៣៩) បានអះអាងថាបានឃើញនៅភិដ្ឋិ (ស៊ូម៉ាត្រាភាគខាងជើង) មានអ្នកដូរលុយប្រហែល ៥០០ នាក់ ដោយសារតែមានឈ្មួញចម្រុះជាតិសាសន៍ផ្សេងៗធ្វើដំណើរមកកាន់កំពង់ផែនេះជាញឹកញាប់ ។ រាជាណាចក្រមួយចំនួននៅប្រទេសជ្វា ស៊ូម៉ាត្រា និងលូហ្សុន បានបោះលុយកាក់នៅរវាងសតវត្សរ៍ទី ៩ និងទី ១៣ តែក្រោយមកក៏មានការបើកផ្លូវឲ្យនាំចូលនូវលុយស្ពាន់ពីប្រទេសចិន (Wicks១៩៨៣ : ២៤៤-៥៦)។នៅមុនយុគសម័យពាណិជ្ជកម្ម គេវាយតម្លៃមាស និងប្រាក់ជាចម្បងតាមរយៈការថ្លឹងទម្ងន់ដោយភាគច្រើន គេវាយតម្លៃមាសនៅតាមតំបន់ឧបទ្វីប និងប្រាក់នៅតាមតំបន់ដីគោក ។ មាសគឺជារង្វាស់តម្លៃ តែវាក៏មានសារៈសំខាន់ដូចគ្នាដែរសម្រាប់ជាមធ្យោបាយក្នុងការសន្សំទុក និងសញ្ញាសម្គាល់ពីឋានៈរបស់ព្រះមហាក្សត្រ និងព្រះពុទ្ធ ។ យើងដឹងមិនសូវច្រើនប៉ុន្មានទេ ពីការប្រើប្រាស់លុយជាមូលដ្ឋាននៅសម័យដើម ទោះបីជាក្នុងចំណោមនោះយើងដឹងថាមានការប្រើសំបកខ្យង និងដុំកំណាត់ក្នុងចំណោមនោះក៏ដោយ ។ សំបកខ្យងនៅមានប្រើនៅក្នុងប្រទេសសៀម និងដុំកំណាត់នៅមានប្រើនៅក្នុងប្រទេសឥណ្ឌូនេស៊ីភាគខាងកើត និងមីនដាណាវរហូតដល់សតវត្សរ៍ទី ១៨ ។

បន្ទាប់ពីឆ្នាំ ១៤០០ មក លុយស្ពាន់របស់ចិន និងលុយកាក់ក្នុងស្រុកដែលមានឆ្លាក់រូបពីលើ គឺជាកត្តាលីករដ៏សំខាន់សម្រាប់ដំណើរការពាណិជ្ជកម្មដែលកាន់តែកើនច្រើនឡើងៗនៅក្នុងតំបន់ ។ ពាក្យថា «ក្រដាសប្រាក់» មានប្រភពមកពីភាសាសំស្ក្រឹត[០៥] តែពួកព័រទុយហ្កាល់បានហៅថា (caixa)ទៅវិញ ជាពិសេសសម្រាប់សម្គាល់ទៅលើលុយកាក់ដែលនាំចូលមកពីស្រុកចិន និងក្រោយមកទៀតពួកអឺរ៉ុបក៏បានហៅតាមដូច្នេះដែរ ។ ជាទូទៅ ប្រជាជនដែលរស់នៅជុំវិញសមុទ្រជ្វាទាំងប៉ុន្មានហៅលុយកាក់ទាំងនោះដោយពាក្យជ្វាថា «ពីស៊ីស» ។ លុយកាក់រាងមូលតូចៗទាំងនេះមានប្រហោងបួនជ្រុងរាងការេនៅចំកណ្តាលដើម្បីងាយស្រួលក្នុងការចងចូលគ្នាជាចង្កោមស្មើនឹងមួយពាន់កាក់ (ទោះបីជារឿយៗ ចំនួន ៦០០ ឬចំនួនផ្សេងៗខ្លះទៀតក៏អាចចងបានដែរ) ។ លុយកាក់ទាំងនេះមានប្រើនៅក្នុងប្រទេសវៀតណាមដែលគ្រប់គ្រងដោយចិនក្នុងកំលុងរាជវង្សថាំង ហើយគេក៏រកឃើញនៅតាមស្ថានីយកំណាយមួយចំនួននៅតំបន់ច្រកសមុទ្រដែលមានអាយុកាលតាំងពីសតវត្សរ៍ទី ១០ មកម៉្លេះ (Crawfurd១៨៥៦ : ២៨៦ ។

នៅក្នុងប្រទេសជ្វា គេមិនឃើញមានសិលាចារឹកណាមួយមាននិយាយពីទម្ងន់ ឬក៏លុយកាក់ជ្វាទេប្រហែលក្រោយឆ្នាំ ១៣០០ មក មាននិយាយគ្រាន់តែចំពោះ ពីស៊ីសប៉ុណ្ណោះដែលជាលុយស្ពាន់របស់ចិននោះ (Wicks ១៩៨៣ : ២៤៦-៥២) ។ គួរឲ្យចាប់អារម្មណ៍ពិសេសជាងនេះទៅទៀត គឺថាសស្ពាន់របស់អ្នកគីឌីរី ដែលប្រហែល

*ជាមានកំណើតនៅឆ្នាំ ១៣៥០ មកម្ល៉េះ បានចារនូវសក្ខីភាពរបស់ម្ចាស់ទឹកដីដែលមានវិវាទថា៖«វាជាទ្រព្យសម្បត្តិដែលផ្តល់ឲ្យមានភាពគ្រប់គ្រាន់ដោយបុព្វបុរសរបស់ខ្ញុំរាប់តំណមកហើយសម្រាប់ផ្លាស់តម្លៃមួយកន្ទះប្រាក់ នៅពេលដែលទឹកដីផ្កានេះមិនទាន់មានពីស៊ីស យកមកប្រើជាមធ្យាបាយនៅឡើយទេ»* (Pigeaud*១៩៦០-៦៣* III: *១៥៧) ។ ចំណុចនេះបង្ហាញថាការឈ្មានពានរបស់ពួកម៉ុងហ្គោលទៅលើទឹកដីផ្កាភាគខាងកើត ដែលនាំមកនូវទាហានចិនពីរម៉ឺននាក់កាន់ទឹកដីនេះនៅក្នុងឆ្នាំ ១២៩៣ គឺជាសន្ទុះដំបូងដ៏ខ្លាំងដែលជំរុញឲ្យមានការបោះលុយកាក់ប្រភេទថ្មី ក៏ដូចជាបំលាស់ប្តូរផ្សេងទៀតជាច្រើននៅក្នុងប្រទេសជ្វាផងដែរ* (Wicks*១៩៨៦ : ៥៩-៦៣*, Reid *១៩៩២ : ១៨១-៨៧) ។ លុយកាក់ស្ពាន់ចិនទំនងជារីកសាយភាយទៅដល់ប្រទេសហ្វីលីពីនប្រហែលជាក្នុងកំលុងពេលដូចគ្នាដែរ ប៉ុន្តែគេឃើញមានឯកសារបញ្ជាក់ច្បាស់លាស់ថាវាបានក្លាយជាលុយកាក់ គោលសំខាន់នៅអាស៊ីអាគ្នេយ៍ត្រឹមសតវត្សរ៍ទី ១៥ មកប៉ុណ្ណោះ ។*

*នៅប្រទេសវៀតណាមក្នុងរាជកាលឡេ បន្ទាប់ពីរំដោះខ្លួនពីការត្រួតត្រារយៈពេលខ្លីរបស់រាជវង្សម៉េងមក បានចាប់ផ្តើមបោះលុយកាក់ស្ពាន់ផ្ទាល់ខ្លួនដែលមានរូបរាងស្រដៀងទៅនឹងលុយកាក់ចិនដែរនៅក្នុងឆ្នាំប្រមាណជា ១៤៣០ ។ គេឃើញមានការបោះលុយកាក់ស្ពាន់នៅតំបន់ខ្ពង់រាបខាងជើងកាន់តែមានភាពខ្លាំងក្លាឡើងៗ ហើយមកទល់នឹងពាក់កណ្តាលសតវត្សរ៍ទី១៥ គេអាចបង់លុយឲ្យមន្ត្រីជាលុយកាក់នេះ និងជាដីធ្លី ។ ទោះជាយ៉ាងនេះក្តី ការផ្គត់ផ្គង់ក្នុងស្រុកនៅតែមានភាពខ្វះខាត ហើយនៅក្នុងសតវត្សរ៍ទី ១៧ គេឃើញមានការចរាចរឲ្យប្រើប្រាស់នូវលុយកាក់ស្ពាន់ពីរប្រភេទ ដែលកាក់ប្រភេទធំនាំចូលពីប្រទេសចិន ឬជប៉ុន រីឯកាក់តូចរបស់វៀតណាមវិញមានចរាចរគោគច្រើនតែនៅតំបន់ក្បែររាជធានីតែប៉ុណ្ណោះ* (Whitmore*១៩៨៣ : ៣៦៥-៦៩*, Le *១៩៧១ : ២២៣*, Rhodes *១៦៥១ : ៥៧) ។ មេដឹកនាំរដ្ឋកាលង្វៀនភាគខាងត្បូងវិញមានការខ្វះខាតនូវការផ្គត់ផ្គង់លុយកាក់ស្ពាន់ដោយខ្លួនឯង ដូច្នេះពួកគេត្រូវការនូវការផ្គត់ផ្គង់ស្រដៀងគ្នានេះដែរនូវប្រភេទលុយកាក់ស្ពាន់ ។ ជារួមមកការនាំចូលនូវស្ពាន់ និង លុយកាក់ស្ពាន់មកពីប្រទេសចិន ជប៉ុន ឬក៏វៀតណាមខាងជើង គឺជាបញ្ហាសំខាន់មួយក្នុងចំណោមបញ្ហាសំខាន់ៗផ្សេងទៀតរបស់របបនេះ ។*



រូបភាពទី ១៦

រូបគំនូររបស់ជនជាតិហូឡង់ ដោយពឹងផ្អែកលើការពិពណ៌នាសម័យបច្ចុប្បន្ន ពីទីផ្សារដ៏ធំនៅ បានតង់ (Banten) ។

ប្រហែលជាដោយសារតែកងនាវាដ៏អស្ចារ្យរបស់រដ្ឋកាលម៉េង ក្រោមការដឹកនាំរបស់ជឹងហ៊ី (ZhengHe) ដែលធ្វើឲ្យគេស្គាល់លុយកាក់ចិននៅតាមកំពង់ផែនៅតំបន់ឧបទ្វីបមួយចំនួនដូចជា ម៉ាឡាកា និងប៉ាសែជាដើម នៅដើមសតវត្សរ៍ទី ១៥ ។ ទោះជាយ៉ាងនេះក្តី គេបានប្រើសំណប៉ាហាំង ជាងការប្រើស្ពាន់អស់រយៈកាលជាយូរមកហើយ នៅតំបន់ច្រកសមុទ្រម៉ាឡាក់កា ហើយបណ្តារដ្ឋផ្សេងៗ នៅទីនោះក៏បានចាប់ផ្តើមយកសំណប៉ាហាំងមកធ្វើជាកាក់ផងដែរ ។ យោងតាមពួកព័រទុយហ្កាល់ នៅឆ្នាំ ១៤១៤ ពេលដែលក្សត្រ មេហ្កាត់ អ៊ីកាន់ដា ធ្វើដំណើរទៅកាន់រាជធានីប្រទេសចិនដើម្បីទទួលបាននូវការឯកភាពពីអធិរាជឲ្យព្រះអង្គបានឡើងសោយរាជ្យ ព្រះអង្គក៏បានទទួលនូវព្រះរាជអនុញ្ញាតឲ្យបោះលុយកាក់ផ្ទាល់ខ្លួនព្រះអង្គដែលមាន «រាងតូច និងធ្វើពីសំណលាយជាមួយនឹងសំណប៉ាហាំង ដែលព្រះអង្គហៅថា ចាសហ» (Albuquerque ១៥៥៧ : ៧៧, cf. Pires ១៥១៥ : ២៤៣, Wang ១៩៦៨ : ១០៤-០៥) ។ គំរូលុយកាក់សំណប៉ាហាំងរបស់ម៉ាឡាកាដែលនៅសេសសល់គង់វង្សមានឆ្លាក់ងាររបស់មេដឹកនាំសម័យមុនៗរហូតទៅដល់សម័យស្តេច មុហ្សាហ្វា (Muzaffar) ឯណោះ (១៤៤៦-៥៩) ។ នាពេលនោះដែរ រាជាណាចក្រស៊ូម៉ាត្រាខាងជើង ក៏បានបោះលុយកាក់តូចៗដែលមានកម្រាស់ក្រាស់ៗជាច្រើន ដោយមានឆ្លាក់ឈ្មោះរបស់មេដឹកនាំរបស់ពួកគេនៅលើនោះផងដែរ (Wicks ១៩៨៣ : ២៧៣; Ma Huan ១៤៣៣ : ១២០, Dakers ១៩៣៩, Pires ១៥១៥ : ១៤៤ Varthema ១៥១០ : ២៣១)។

ការរៀបរាប់របស់ជនជាតិអឺរ៉ុបលើកដំបូងអំពីប្រ៊ុយណេ ស៊ុមបាវ៉ា ម៉ាលុគុ ចំប៉ា និងជ្វាបានបង្ហាញថាលុយកាក់ចិនធ្វើអំពីស្ពាន់ គឺជាលុយកាក់ផ្លូវការប្រើប្រាស់នៅក្នុងតំបន់ទាំងអស់នេះ (Pires ១៥១៥ : ១១៤, ១៧០, ១៨១, ២០៣, ២០៦-០៧, ពីហ្កាហ្វេតា (Pigafetta) ១៥២៤ : ៥៩-៦០, Galvão ១៥៤៤ : ១៣៨-៣៩) ។ ក៏ប៉ុន្តែមិនមែនលុយកាក់ទាំងអស់សុទ្ធតែនាំចូលមកពីប្រទេសចិននោះទេ ។ ដោយសារតែទំនាក់ទំនងផ្ទាល់ជាមួយចិនមានការធ្លាក់ចុះនៅប្រហែលឆ្នាំ ១៥០០ ជាងកាលពីសម័យយ៉ុងហ្គិល (Yongle) នៅក្នុងប្រទេសជ្វា និងកន្លែងដទៃទៀតគេទំនងជាចម្លងលុយកាក់ «ចិន» ហើយផលិតនៅក្នុងស្រុកវិញដើម្បីឲ្យមានការផ្គត់ផ្គង់គ្រប់គ្រាន់ ។ ពីហ្កាហ្វេតា (១៥២៤ : ៦០) បានរៀបរាប់តាមភាពជាក់ស្តែងថា លុយកាក់ចិនដែលគាត់ប្រទះឃើញនៅប្រ៊ុយណេគឺជា «លុយកាក់ដែលផលិតដោយពួកមូស្លីមនៅក្នុងតំបន់ទាំងនោះ» ។ មកទល់នឹងឆ្នាំ ១៥០០ មិនថាស្ថានការណ៍ណាទេ ទាំងលុយកាក់ចិនធ្វើពីស្ពាន់លុយកាក់ស្ពាន់ក្នុងស្រុក ក៏ដូចជាលុយកាក់សំណប៉ាហាំងដែលយកគំរូតាមលុយកាក់ចិនបានត្រូវគេប្រើប្រាស់ជាលុយផ្លូវការនៅអាស៊ីអាគ្នេយ៍ទាំងអស់ ។ នៅឆ្នាំ ១៥៣៧ ពេលដែលពួកព័រទុយហ្កាល់ប៉ុនប៉ងឲ្យសម្ព័ន្ធមិត្តរបស់ខ្លួននៅម៉ាលុគុទទួលស្គាល់នូវលុយកាក់ព័រទុយហ្កាល់ដែលធ្វើពីស្ពាន់សុទ្ធជាងលុយកាក់ស្ពាន់ចិន សម្ព័ន្ធមិត្តរបស់ពួកគេបានប្រាប់ថា ពួកគេអាចទទួលយកបានប្រសិនបើគេធ្វើប្រហោងនៅចំកណ្តាលលុយកាក់នោះដើម្បីងាយស្រួលក្នុងការចងចូលគ្នា (Galvão ១៥៤៤ : ២៧០-៧៣)។

មកទល់នឹងឆ្នាំ ១៥០០ គេឃើញមានតែនៅក្នុងប្រទេសសៀម អារ៉ាកាន (Arakan) កំពង់ផែម៉ារតាបាន (Martaban) នៃប្រទេសភូមា និងកេដាហ៍ (Kedah) ប៉ុណ្ណោះ ដែលនៅតែប្រើសំបកខ្យងសម្រាប់កិច្ចការជំនួញដូរទ្រព្យទ្រាយតូចនៅឡើយ ។ ទោះបីជាគេរំពឹងទុកថាទំនាក់ទំនងស្លួយសារអាករដ៏ល្អប្រសើររបស់ប្រទេសសៀមជាមួយប្រទេសចិនអាចនាំចូលនូវលុយកាក់បានដោយស្រួលក៏ដោយ ក៏គេនៅឃើញមានការនាំចូលនូវសំបកខ្យងសមុទ្រពីប្រជុំកោះម៉ាល់ឌីវ បរណៃវ ម៉ាលុគុ និងហ្វីលីពីន (Pires ១៥១៥ : ១០០, Gervaise ១៧១០ : ១២០) ។ នៅតាមតំបន់ភាគច្រើននៃប្រទេសភូមា និងអារ៉ាកាន លុយកាក់ប្រើជាទូទៅ គឺផានសាធ្វើពីលោហធាតុសំខាន់ៗជា

ពិសេសគឺផ្សំពីស្ពាន់ និងសំណប៉ាហាំង តែជារឿយៗគឺផ្សំឡើងពីសំណដែលអាចធ្វើផ្លាស់ខ្នាតបានដោយសារការថ្លឹងទម្ងន់ ។ «វាមិនមែនជាលុយកាក់របស់ព្រះមហាក្សត្រនោះទេ តែមនុស្សគ្រប់រូបអាចឲ្យតម្លៃវាទៅតាមគំនិតនេះផងដែរ ព្រោះថាលុយកកាក់នេះមាននូវចំណែក ឬតម្លៃដ៏ត្រឹមត្រូវរបស់ព្រះអង្គ» (Frederici ១៥៨១ : ២៥៤,cf. Pires ១៥១៥ : ៩៩, ៩៦-៩៧)។

ការបញ្ឈប់នូវការហាមប្រាមរបស់អធិរាជចំពោះការធ្វើជំនួញចិនទៅកាន់តំបន់ភាគខាងត្បូងនៅក្នុងឆ្នាំ ១៥៦៧ បាននាំឲ្យមានលំហូរចូលយ៉ាងគំហុកនូវលុយកាក់ចិនធ្វើពីស្ពាន់នៅតំបន់នោះ ។ កងនាវាហូឡង់ដែលបានធ្វើដំណើរមកដល់ប្រទេសជ្វាលើកដំបូងក្នុងឆ្នាំ ១៥៩៦ បានស្វែងយល់ថា លុយកាក់អស់ទាំងនេះ «មានប្រើយ៉ាងច្រើនសន្ធឹកសន្ធាប់នៅពាសពេញដីកោះទាំងនេះ» នាដំណាក់កាលនោះ ដោយបានធ្វើឲ្យមន្ត្រីចិនមានការព្រួយបារម្ភ ដោយបានចាត់ទុកលំហូរចេញនៃលុយកាក់អស់ទាំងនេះ ជាការរីងស្ងួតទៅៗចំពោះធនធានកម្មរបស់ប្រទេស ។ ជាលទ្ធផលនៅប្រមាណឆ្នាំ ១៥៩០ គេបានបោះលុយកាក់ថ្មីផ្សំពីល្បាយសំណ ដែលមានគុណភាពអន់នៅខេត្តគ័ងតុង និងហ្វូជៀន ដើម្បីឲ្យធ្វើចរាចរជាពិសេសនៅតំបន់ណានយ៉ាង (Blussé ១៩៨៦ : ៣៦-៣៨, លូដូវីស្គស៍ ១៥៩៨ : ១២២-២៣) ។ ជនជាតិអឺរ៉ុបមានការត្អូញត្អែរទៅចំពោះលុយកាក់ប្រភេទនេះណាស់ ÷ «ដោយសារតែលោហធាតុនេះហើយ ដែលគេប្រើវាសុទ្ធតែក្នុងរយៈ ៣ ឬ ៤ឆ្នាំ» (van Neck១៥៩៩ : ៨៧), cf. លូដូវីស្គស៍ ១៥៩៨ : ១២២) ។ មកទល់នឹងឆ្នាំ ១៥៩៦ លុយកាក់ពីស៊ីស ដែលមានគុណភាពមិនសូវល្អទាំងនេះត្រូវគេប្រើប្រាស់រហូតទៅដល់តំបន់ឆ្ងាយៗរបស់ប្រទេសជ្វាផងដែរ ។ ឈ្មួញកណ្តាលចិនបាននាំកាក់ទាំងនោះទៅកាន់តំបន់ខ្ពង់រាបហ្វូសពីទីក្រុងបង់តែន ដើម្បីទិញម្រេចពីអ្នកដាំក្នុងតម្លៃមួយភាគបួននៃតម្លៃដែលលក់នៅលើទីផ្សារក្រុងបង់តែន (Blussé ១៩៨៦ : ៤០)។

ជារឿយៗ មានការនិយាយពីកង្វះខាតពីស៊ីសនៅលើទីផ្សារក្រុងបង់តេន ក្នុងកំលុងពេល ៣ ទសវត្សរ៍បន្តបន្ទាប់គ្នា ។ សៀន បានអះអាងថា បើប្រៀបនឹងប្រាក់តម្លៃរបស់ពីស៊ីស មានការកើនឡើងមួយជាបួនទៅចន្លោះឆ្នាំ ១៦១៣ និង ១៦១៨ ព្រោះដោយសារតែភាពមិនសូវសម្បូរ (ពី ៣០.០០០ មក ៨.០០០ ក្នុងមួយរៀល) ហើយចំណែកឯនៅហ្សាំប៊ី (Jambi) វិញ តម្លៃពីស៊ីស ក៏បន្តកើនឡើងផងដែរ ដែលកើនរហូតដល់ ៦,៩០០ ក្នុងមួយរៀល នៅក្នុងឆ្នាំ ១៦៣៦ (Blussé ១៩៨៦ : ៤១-៤២, Andaya. ១៩៩៣ : ១០៥)[៥] ។ លំហូរចូលនៃប្រាក់ជាច្រើនដើម្បីបំពេញតម្រូវការក្នុងការដួញដូរម្រេចនៅតាមកំពង់ផែទាំងនេះ ជាអ្នកធ្វើឲ្យតម្លៃ ពីស៊ីស កើនឡើង ទោះបីជាការផ្គត់ផ្គង់ ពីស៊ីស នៅមានលំនឹងក៏ដោយ ។

លុយកាក់ផ្សំពីល្បាយសំណទាំងនេះមានគុណភាពទាបដូចនេះ ហើយគេអាចចម្លងដោយងាយ ។ កង្វះខាតសំណ គឺជាឧបសគ្គចម្បងសម្រាប់ផលិតកម្មលុយកាក់ក្នុងស្រុក រហូតដល់ពួកអង់គ្លេស និងហូឡង់រកឃើញថា សំណគឺជារបស់មួយក្នុងចំណោមរបស់ពីរបីប្រភេទនៅអឺរ៉ុប ដែលមានទីផ្សារនៅអាស៊ីអាគ្នេយ៍ ។ ពួកអង់គ្លេសនៅក្រុងបង់តេន បានបង្កើនការនាំចូលសំណចាប់ពី ២០ តោន នៅឆ្នាំ ១៦០៨ រហូតដល់ ៥០-៦០ តោន នៅឆ្នាំ ១៦១៥ និង ១០០-១៥០ តោន នៅឆ្នាំ ១៦៣៦ ។ ក្នុងចំណោមសំណទាំងនេះ សំណខ្លះបានប្រើសម្រាប់ការផលិតគ្រាប់កាំភ្លើងនៅក្នុងសម័យសង្គ្រាម តែសំណភាគច្រើន គឺប្រើសម្រាប់ការផលិតលុយកាក់ដើម្បីផ្គត់ផ្គង់ទីក្រុងបានចារម៉ាស៊ីន (Banjarmasin) និងប៉ាឡេមបាំង (Palembang) ក៏ដូចជា បង់តេន ផងដែរ (LREIC I: ២១-22; III : ២៧៧-៧៨, Willoughby ១៦៣៦ : ១៥៣) ។ ពួកហូឡង់មានការប្រយ័ត្នប្រយែងក្នុងការលក់សំណ ព្រោះខ្លាចក្រែងសត្រូវរបស់

ខ្លួនយកវាទៅប្រើសម្រាប់គោលបំណងធ្វើសង្គ្រាម ។ លើកលែងតែនៅក្នុងឆ្នាំ ១៦៣៣ នៅពេលដែលពួកគេចាប់ផ្តើមលក់ឲ្យជនជាតិចិន នៅប៉ាតាវៀ ទើបពួកគេរកឃើញថាមានឧស្សាហកម្មផលិតពីស៊ីស «ចិន» រួចជាស្រេចទៅហើយ នៅប្រទេសជ្វា ជាពិសេសនៅទីក្រុងបង់តេន ស៊ីរ៉េបុន (Cirebon) និងហ្សាប៉ារ៉ា (Japara) ។ ពួកគេទាញយកប្រយោជន៍ដោយការលក់សំណទាំងនេះ ក្នុងលក្ខណៈផ្តាច់មុខឲ្យទៅជនជាតិចិនសំខាន់ៗដែលរស់នៅក្នុងតំបន់ត្រួតត្រាដោយពួកហូឡង់ប៉ុណ្ណោះ ។ ការពិសោធបែបនេះ ត្រូវពួកគេបោះបង់ចោលនៅឆ្នាំ ១៦៤០ ពេលដែលពួកអង់គ្លេសប្រជែងកាត់មុខការរកស៊ីផ្តាច់មុខរបស់ហូឡង់ ដោយការផ្គត់ផ្គង់នូវសំណដែលមានតម្លៃថោកជាងទៅឲ្យរោងចក្រផលិតពីស៊ីស ដែលជាគូប្រជែងនៅក្នុងទីក្រុងបង់តេន ហ្សាប៉ារ៉ា ហ្សាំប៊ី ប៉ាឡេមបាំង ម៉ាកាស-សារ និងម៉ារតាពូរ៉ា (ប៊ីណេអូ) ។ ហូឡង់ បានប្តូរទៅផលិតលុយកាក់ស្ពាន់វិញ ដើម្បីជាមធ្យោបាយចម្បងក្នុងការបញ្ជ្រាបចូលទៅក្នុងសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ ។ ទោះជាយ៉ាងនេះក្តី ប្លូសេ (Blussé ១៩៨៦ : ៤៦-៤៨) បានបង្ហាញថា រយៈកាលប្រើប្រាស់លុយកាក់ដែលពួកហូឡង់បានជំរុញ គឺមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការកសាងក្រុងបាតាវៀក្លាយជាកំពង់ផែដ៏ទាក់ទាញមួយសម្រាប់អ្នកដឹកជញ្ជូនតាមនាវាជនជាតិឥណ្ឌូនេស៊ី ដែលអន្ទះសាចង់បានឲ្យលុយកាក់ ពី-ស៊ីស និងទំនិញចិន ។

បណ្តារដ្ឋនៅអាស៊ីអាគ្នេយ៍នៅតែបន្តបោះលុយកាក់ធ្វើពីសំណ ឬសំណលាយនឹងសំណប៉ាហាំង ទោះបីជាការខូចខាតយ៉ាងឆាប់រហ័សរបស់កាក់ទាំងនេះបានបន្សល់នៅតែលុយកាក់ពីរបី ដែលគេមានការលំបាកក្នុងការកំណត់អត្តសញ្ញាណរបស់លុយកាក់ទាំងនេះនៅក្នុងការប្រមែប្រមូលបាននាសម័យទំនើបក៏ដោយ ។ គេបានរកឃើញលុយកាក់ដែលធ្វើពីសំណសុទ្ធ និងមានការឆ្លាក់រចនានូវហាមសារមានលក្ខណៈដូចរូបទា នៅទីក្រុងពេគូ និងកាក់រាប់រយទៀតនៅក្នុងបរិវេណកំពែងទីក្រុងដែលបានកសាងឡើងនៅក្នុងទសវត្សរ៍ឆ្នាំ ១៥៦០ ។ ចំណុចនេះបង្ហាញថា ភាពរុងរឿងខ្លាំងរបស់ទីក្រុងពេគូ ប្រហែលជាត្រូវការឲ្យមាននូវរូបិយវត្ថុផ្លូវការនៅក្នុងសតវត្សរ៍ទី ១៦ ទោះបីជាអ្នកទេសចរនាពេលនោះមិនបានលើកឡើងក៏ដោយ (Robinson ១៩៨៦ : ២៥-២៧,៣៤, Wicks ១៩៨៣ : ៩៤-៩៥) ។ នៅក្នុងសតវត្សរ៍ទី ១៧ ទីក្រុងតេណាស់ស៊ីរីម (Tenasserim) ឬទីក្រុងតាវ៉ូយ (Tavoy)បានបោះលុយកាក់ធំៗធ្វើពីសំណប៉ាហាំង និងសំណ ហើយប្រហែលជាធ្វើចរាចរប្រើប្រាស់រហូតដល់ទីក្រុងគេដាហ៍ និងពេរ៉ាក់ ទៀតផង (Robinson ១៩៨៦ : ៦៧-៧០, Gervaise ១៧០១ : ១២០)។ ឧទាហរណ៍ជាក់ស្តែងអំពីលុយកាក់ធ្វើពីសំណប៉ាហាំងលាយនឹងសំណដែលនៅសេសសល់ (ហើយក៏មានធ្វើពីទង់ដែងផងដែរនៅទីក្រុងបង់តេន) បានបង្ហាញថា យ៉ាងហោចណាស់ក៏មានទីក្រុងអាចេ បង់តេន ស៊ីរ៉េបុន ប្រ៊ុយណេ និងប្រហែលជា ចូហរ ផងដែរ ដែលបានបោះលុយកាក់ផ្លូវការ ដែលមានចារឈ្មោះ ឬគោរមងាររមេដឹកនាំ នៅក្នុងសតវត្សរ៍ទី ១៦ និង ១៧ (Beaulieu ១៦៦៦ : ៥៨, ដាំពៃរ ១៦៩៩ : ៩២, Davidson ១៩៧៧ : ៤៨, Netscher and van der Chijs១៨៦៤ : ១៤៩-៥៣, Wicks ១៩៨៣ : ២៧៣-៧៦, ៣១៩-២៣, ៤០៨-២៨)។ យោងទៅលើឯកសារមួយរបស់អេស្ប៉ាញ(Dasmariňas១៥៩០ : ១៣) ប្រទេសប្រ៊ុយណេបានយល់ថា លុយកាក់ធ្វើពីប្រាក់ សុទ្ធរបស់ខ្លួនមានប្រជាប្រិយខ្លាំងក្នុងចំណោមឈ្មួញបរទេស ដែលបានយកលុយកាក់ទាំងនោះទៅជាមួយ ដូច្នេះហើយបានជានៅពាក់កណ្តាលទីពីរនៃសតវត្សរ៍ទី ១៦ មេដឹកនាំបានសម្រេចចិត្តផលិតនូវកាក់មួយប្រភេទដែល «មានទំហំស្មើនឹងកាក់កន្ទះរៀល និងធ្វើពីសំណប៉ាហាំង ឬក៏សំណ ជំនួសវិញ ដែលពួកគេហៅថា ពីតីស »។

រយៈកាលនៃកិច្ចប្រឹងប្រែងរបស់ក្រុមហ៊ុនហូឡង់ ដើម្បីរកស៊ីផ្តាច់មុខ បានបង្ហាញពីបរិមាណខ្វះនៃតម្រូវ

ការលុយកាក់ពីស៊ីសនាពេលនោះ ។ ក្រុមហ៊ុនបានផ្គត់ផ្គង់សំណចំនួន ១៣៣ តោន នៅឆ្នាំ ១៦៣៧ និង ១៥៣ តោន នៅឆ្នាំ ១៦៣៨ ឲ្យរោងចក្រផលិតពីស៊ីស របស់ខ្លួន (Blussé ១៩៨៦ : ៤៧) ។ ហើយពួកអង់គ្លេសផ្គត់ផ្គង់សំណក្នុងចំនួនស្រដៀងគ្នាហើយ ពួកចិននៅតែនាំចូលមកនូវលុយកាក់របស់ពួកគេ ហើយក្រុមហ៊ុន ហូឡង់ ផ្ទាល់សង្ឃឹមថាទទួលបាននូវចំណែកមួយភាគធំនៅលើទីផ្សារ ដែលមានចំនួនរហូតដល់ ២៤០ តោន នោះយើងអាចប៉ាន់ស្មានបានថា នៅពេលនោះ គេត្រូវការសំណប្រហែល ៣៥០ តោន ក្នុងមួយឆ្នាំៗ ដើម្បីផលិតលុយកាក់ពីស៊ីស សម្រាប់ផ្គត់ផ្គត់តំបន់ឧបទ្វីបតណ្ឌូនេស៊ីទាំងមូល ។ ប្រសិនបើពីស៊ីសមួយមានទម្ងន់ជាមធ្យមប្រហែលជា ២ ក្រាម (ឧទាហរណ៍នៃកាក់ដែលមាននៅសេសល់មានទម្ងន់ខុសៗគ្នា ដោយភាគច្រើនមានទម្ងន់តិចជាងមួយក្រាម រីឯផ្សេងទៀតមានទម្ងន់រហូតដល់ ៥ ក្រាម (Wicks ១៩៨៣ : ២៧៥–៧៦, ២៧៩, ៤១០–១៣, Museum Nasional ១៩៨០ : ២៦៧, ១៩៨៤–៨៥ : ០៧–០៨) ដូច្នេះ កាក់ប្រហែលជាចំនួន ១៧០ លាន ត្រូវគេផលិតក្នុងមួយឆ្នាំ ។ ដោយសារតែកាក់ទាំងនោះអាចសឹករិចរិលក្នុងកំលុងពេល ៥ ឆ្នាំ យើងអាចគណនាត្រួសៗឃើញថា កាក់លើសពី ៨០០ លានប្រហែលជាបានចរាចរនៅតាមតំបន់នៃឧបទ្វីបតណ្ឌូនេស៊ី ។ កាក់ទាំងនេះនៅតែមានតម្លៃមិនគ្រប់គ្រាន់សម្រាប់ប្រជាជនប្រហែល ១០ លាននាក់ តែវាមានចំនួនសមល្មមក្នុងការសម្រួលឲ្យចរន្តសាច់ប្រាក់មានដំណើរការស្រួលនៅក្នុងសង្គម ។

កំណត់ត្រារបស់ក្រុមហ៊ុនហូឡង់ ក៏បានបញ្ជាក់អំពីកម្រិតនៃការផ្គត់ផ្គង់លុយកាក់នៅរោងចក្រផ្សៀននៃដែនដីកូសាំងស៊ីន នាដំណាក់កាលនោះផងដែរ ។ នៅក្នុងកំលុងពេល ៥ ឆ្នាំ ពីឆ្នាំ ១៦៣៣ ដល់ ១៦៣៧ ក្រុមហ៊ុន ហូឡង់ បាននាំចូលខ្សែនីឡុងចំនួន ១០៥.៨៣៤ ខ្សែ ដែលក្នុងមួយខ្សែៗ មានកាក់ស្ពាន់ជប៉ុនចំនួន ៩៦០ កាក់ ដើម្បីប្រើជារូបិយវត្ថុផ្លូវការនៅតំបន់កូសាំងស៊ីន (van Aelst១៩៨៧) ។ ដូច្នេះការនាំចូលដោយពួកហូឡង់តែឯងដូចនេះប្រហែលជាស្មើនឹងការនាំចូលកាក់ចំនួន ២០ លាន ក្នុងមួយឆ្នាំៗ ។ រីឯឈ្មួញចិន និងជប៉ុនវិញក៏បាននាំចូលកាក់ក្នុងបរិមាណច្រើនដែរ ។ នៅឆ្នាំ ១៦៣៥ ពេលដែលជំនួញផ្លូវឆ្ងាយជប៉ុនត្រូវហាមឃាត់ អ្នកផ្គត់ផ្គត់ធំរបស់ជប៉ុនបានបង្វែរស្តុកកាក់ស្ពាន់របស់ខ្លួនចំនួន ២០០ តោន សម្រាប់តំបន់កូសាំងស៊ីន ទៅឲ្យពួកហូឡង់វិញ (Klein ១៩៨៦ : ១៦១) ។ ដូច្នេះជារួមមក ការនាំចូលសរុបប្រចាំឆ្នាំមិនអាចមានចំនួនតិចជាង ៤០ លាន កាក់នោះទេ ។ កាក់ធ្វើពីស្ពាន់មានគុណភាពស្ថិតស្ថេរយូរជាងកាក់ពីស៊ីស ធ្វើពីសំណដែលមានគុណភាពអន់ជាង តែគេក៏ចូលចិត្តយកវាទៅរំលាយធ្វើជាគ្រឿងប្រដាប់ប្រដាផ្ទះបាយផងដែរ ។ តែទោះជាយ៉ាងនេះក្តី វាមានការពិបាកក្នុងការមើលឃើញថា ចំនួនកាក់សរុបដែលធ្វើចរាចរនៅតំបន់កូសាំងស៊ីនអាចមានចំនួនតិចជាង ២០០ លាន ណាស់ ដែលកាក់ទាំងនេះ សម្រាប់ប្រជាជនតែប្រហែលជា ២ លាននាក់ មានន័យថា កម្រិតនៃរូបិយវត្ថុនីយកម្មនៅទីនេះមានកម្រិតខ្ពស់ជាងនៅតំបន់ឧបទ្វីបតណ្ឌូណេស៊ីបន្តិច ។

ចំពោះលុយកាក់ដែលមានតម្លៃខ្ពស់ ជាធម្មតាគេនិយមមាសដោយវាជាសញ្ញាសម្រាប់សម្គាល់នូវទ្រព្យសម្បត្តិឋានៈ សន្តិសុខ និងសម្ភស្ស ដូចគ្នាអ្នកសម្របសម្រួលក្នុងកិច្ចការពាណិជ្ជកម្ម ។ ទោះបីជាកាក់មាស ឬមេដាយមាសត្រូវគេស្គាល់នៅក្នុងប្រទេសថ្ងៃសម័យបុរាណក៏ដោយ ក៏ការបោះកាក់មាសក្នុងតម្លៃដាក់លាក់ក្រោមឈ្មោះរបស់មេដឹកនាំ ត្រូវគេដាក់ឲ្យប្រើប្រាស់នៅតំបន់អាស៊ីអាគ្នេយ៍ដំណាលគ្នា និងសាសនាអ៊ីស្លាម ។ លុយកាក់មាសចាស់ជាងគេបំផុត គឺកាក់របស់ទីក្រុងប៉ាសៃ ដែលជារដ្ឋអ៊ីស្លាមល្បីល្បាញដំបូងគេស្ថិតនៅតំបន់ក្រោមដំណើរខ្យល់មូសុងៗ គេឃើញកាក់មាសទាំងនេះនៅមានសេសសល់ពីមេដឹកនាំល្បីល្បាញ ៨ រូបរបស់ប៉ាសៃ ដែលមានតាំងពី

ស៊ុលតង់ មហាម៉ាត់ (Sultan Muhammad)(១២៩៧–១៣២៦) រហូតដល់ អាប់ដាល់ឡាហ៍ ម៉ាលីក អាហ្ស ហ្សាហ៊ីរ (Abdallah Malik az-Zahir) (១៥០១–១៣) (Alfian ១៩៧៩ : ១៥–២៧, Wicks ១៩៨៣ : ២៦៣–៦៨) ។ ការឲ្យតម្លៃរបស់អ៊ីស្លាមចំពោះលុយកាក់ដ៏បិតថេរនេះ សបញ្ជាក់យ៉ាងច្បាស់តាមរយៈមិនត្រឹមតែគោរមងាររបស់ពួកអារ៉ាប់ឆ្លាក់ជាប់នៅលើកាក់នោះទេ តែថែមទាំងតាមរយៈពាក្យអារ៉ាប់ ឌីរ៉ាម (ភាសាអាចេហៅថា ដីរីហាម) ដែលគេស្គាល់ទូទាំងក្នុងប្រទេសអារ៉ាប់ទៀតផង ។ ពាក្យនេះ នៅម៉ាកាសសារ គេហៅថា dinaraដែលមានប្រភពមកពីពាក្យអារ៉ាប់ ឌីណារ៉ា ។ ចំពោះពាក្យម៉ាឡេ មាស(ដែលជាពាក្យសំដៅមាសជាទូទៅ) វិញ គឺជាពាក្យទទួលស្គាល់ជាអន្តរជាតិសម្រាប់សម្គាល់លើកាក់មាសក្នុងស្រុកទាំងអស់ ។ កាក់តូចដែលមានអង្កត់ផ្ចិតប្រវែងពី ១០ទៅ១៤ មីលីម៉ែត្រ នេះនៅតែមានបន្តបោះដោយមេដឹកនាំស៊ូម៉ាត្រាខាងជើងអស់រយៈពេលយ៉ាងហោចណាស់ក៏ ៤ សតវត្សរ៍ដែរ ដោយមានភាពជាក់លាក់ គឺភាពសុទ្ធ ១៧ ការ៉ាត់ និងមានទម្ងន់ ០,៦ ក្រាម (fig ១៧a)។

នៅសតវត្សរ៍ទី ១៧ លុយកាក់ មាសរបស់អាចេជាផ្នែកមួយនៃប្រព័ន្ធតម្លៃដ៏បិតថេរ ដែលក្នុងនោះ ១ តាហិល (គិតតាមទម្ងន់ប្រាក់) ស្មើនឹង ១៦ មាសហើយ ១ មាសស្មើនឹង ៤គុប៉ាង ដែលស្មើទៅនឹង ១៦០០ ចាសហ (Lombard ១៩៦៧ : ១០៦–០៧; LREIC III: ៣១៤) ។ ដោយសារតែតម្លៃរបស់លុយមាស និងប្រាក់មានការប្រែប្រួល ជាពិសេសជាមួយនឹងលំហូរចូលនៃប្រាក់ថ្មីនោះ គេពិតជាមានការលំបាកក្នុងការរក្សាតម្លៃពាក់ព័ន្ធទាំងនោះឲ្យនៅដដែលណាស់ក្នុងស្ថានភាពជាក់ស្តែង ។ ទំនងជាមានការខ្វះខាត ចាសហនៅអាចេក៏ដូចជានៅបន់តេនផងដែរ ដោយហេតុថា ចាសហចំនួន ២១០០ អាចដូរបានតែមួយ មាសប៉ុណ្ណោះនៅក្នុងឆ្នាំ ១៦០២ (Martin ១៦០៤ : ៥៥–៥៦, Lancaster ១៦០៣ : ១៣៦) ហើយនៅទសវត្សរ៍ឆ្នាំ ១៦៣០ ចាសហចំនួនពី ៦០០ ទៅ ១.០០០ ស្មើនឹងមួយ មាស (Mundy, quoted Lombard ១៩៦៧ : ១០៧n) តែបន្ទាប់ពីពេលនោះមកគេឃើញមានតុល្យភាពក្នុងការដោះដូរខ្វះរិលទៅរកភាពដើមខ្លះ ។ គិតទល់ និងអត្រាប្រាក់ លុយកាក់ មាសរបស់អាចេក៏បានបង្កើនតម្លៃរបស់ខ្លួនដែរ ពីព្រោះវាមានតម្លៃស្មើនឹងមួយភាគប្រាំមួយនៃលុយកាក់ real របស់អេស្ប៉ាញនៅក្នុងឆ្នាំ ១៦០២ និងស្មើនឹងមួយភាគប្រាំនៅក្នុងឆ្នាំ ១៦១៣ ហើយថែមទាំងស្មើនឹង ៩ កាក់ផេនសរបស់អង់គ្លេស នៅដើមសតវត្សនោះ និង ១៥ កាក់ផេនសសម្រាប់ដាំពែរ នៅឆ្នាំ ១៦៨៨ ទៀងផង (Lancaster ១៦០៣ : ១៣៦, LREIC III : ៣១៤n)។



រូបភាព ១៧ ក និង ១៧ ខ
កាក់ដែលប្រើប្រាស់នៅអាឆេនាសតវត្សទី ១៧

*ទោះបីជាគុប៉ាង របស់អាឆេ ត្រូវគេចាត់ទុកគ្រាន់តែជាឯកតាគណនាតែមួយគត់ក៏ដោយ ក៏រដ្ឋដទៃទៀតបានបោះទាំងមាស និងគុប៉ាង ដែលធ្វើពីមាស ដោយមាសមានតម្លៃស្មើនឹង ៤ ដងនៃតម្លៃគុប៉ាង ។ ទីក្រុងចូហរ និងគេដាហ៍ បានផលិតកាក់រាងប្រាំបីជ្រុងនៅចុងសតវត្សរ៍ទី ១៧ ។ លុយកាក់មាសរបស់ចូហរ មានទម្ងន់ធ្ងន់ជាងលុយកាក់មាសរបស់ទីក្រុងអាឆេ ៤ ដង តែវាជាធម្មតាផ្សំពីល្បាយលោហ:* (Hamilton ១៧២៧ II : ១៧២,Wicks ១៩៨៣ : ៣០៧-១៨, Taillandier ១៧១១ : ៤១១) ។ *គេក៏ឃើញមានការប្រើប្រាស់កាក់មាសរាងមូលរបស់អាឆេផងដែរនៅប៉ាតានី ដែលមួយចំហៀងមានរូបគោឈ្មោល និងមួយចំហៀងទៀតមានរូបម៉ាលីក-អាល់-អាឌីល ក៏ប៉ុន្តែគេមិនអាចកំណត់ឲ្យច្បាស់ថាវាជារបស់មេដឹកនាំមួយណា ឬកន្ទៃងមួយណានោះទេ* (Wicks១៩៨៣ : ៣៦០-៦៨) ។

*លុយកាក់ដែលមានឯកសារបញ្ជាក់ច្បាស់លាស់ គឺកាក់មាសបង្កើតឡើងដោយទីក្រុងម៉ាកាសសារ ជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងដ៏ក្លៀវក្លារបស់ខ្លួនដើម្បីឲ្យក្លាយទៅជាកំពង់ផែជំនួញអន្តរជាតិដ៏ធំមួយនៅតំបន់ឧបទ្វីបភាគខាងកើត ។ ដូចដែលពង្សាវតារបានបង្ហាញ វាគឺជាស្នាដៃស្ថាបត្យកម្មដំផ្តើមនៃម៉ាកាសារ ការរៀង ម៉ាតោយ៉ា នៃតំបន់* Tallo *ដែលធ្វើជាឧត្តមមន្ត្រីចាប់ពីឆ្នាំ ១៥៩៣ ដល់ ១៦៣៧ ។ គាត់គឺជា «មនុស្សដំបូងបង្អស់ក្នុងការបោះ*

កាក់ (មាស) ដែលហៅថា ឌីណារ៉ា និង ក្នុងការបោះកាក់សំណប៉ាហាំង» (Sejarah Kerajaan Tallo' : ១៨)។ ទោះបីជាកាក់មាសរបស់ម៉ាកាសសារនេះមានរូបរាងស្រដៀងទៅនឹងកាក់របស់ទីក្រុងអាចេក៏ដោយ ក៏វាមានទំហំធំជាង ៤ដងដែរ គឺមានទម្ងន់រហូតដល់ ២,៤ ក្រាម ។ កាក់មាស គុប៉ាង ដែលមានទំហំមួយភាគបួននៃប្រាក់នេះបានបោះយ៉ាងហោចណាស់ក៏នៅឆ្នាំ ១៦៥៧ ដែរ (បោះនៅរាជចក្រមាកាសសារក្នុងឆ្នាំ ១៦៥៨, Bassett១៩៥៨ : ២៦-២៧, Netscher and van der Chijs ១៨៦៤ : ១៨៥) ។

មេដឹកនាំដទៃទៀតនៅក្នុងពិភពម៉ាឡេប្រហែលជាធ្លាប់បានបោះលុយកាក់ មាសធ្វើពីមាសដែរ តែគេមិនអាចសិក្សារកឃើញបានទេ ។ លុយកាក់នេះប្រាកដជាបានក្លាយជារង្វាស់តម្លៃ ដែលជ្រួតជ្រាបនៅក្នុងគំនិតរបស់ជនជាតិម៉ាឡេចាប់ពីសម័យម៉ាឡាការហូតមក ។ ការផាកពិន័យចំពោះបទល្មើសផ្សេងៗ ដែលចែងនៅក្នុងច្បាប់ម៉ាឡេ ក៏មានបញ្ជាក់ដោយផ្អែកលើលុយកាក់មាសដែរ ទោះបីជាលុយកាក់នេះមានន័យខុសប្លែកគ្នាពីរដ្ឋមួយទៅរដ្ឋមួយក៏ដោយ ។ សូម្បីតែនៅក្នុងប្រទេសសៀម និងទឹកដីកូសាំងស៊ីនក៏ដោយ ជនបរទេសសំដៅទៅលើឯកតាលុយ ១៦ តាហិល ស្មើនឹងមួយ មាស ដែរ (ភាសាថៃហៅថា សាលុង (Salung)ឯភាសាវៀតណាមវិញ ហៅថាធៀន (tiên)) (Smith ១៩៧៤ : ៣១៧, Chen ១៩៧៤ : ២៤) ។

ព្រះរាជពង្សាវតារប្រទេសកម្ពុជាបានបញ្ជាក់ថា ស្តេចជ្រែករាជ្យមួយអង្គព្រះនាម កន ជាជនជាតិខ្មែរដែរ (ប្រហែលជាឈ្មួញ) បានកសាងរាជធានីថ្មីនៅឯស្រាលាប់ (Sralap) នៅឆ្នាំ ១៥១៦ ដែលមានជនជាតិខ្មែរ និងបរទេសធ្វើដំណើរទៅមកយ៉ាងច្រើន ។ «ព្រះរាជាបានត្រាស់បង្គាប់ឲ្យគេបោះលុយកាក់ ដែលធ្វើពីសន្លឹកប្រាក់ និងសន្លឹកមាស និងមានឆ្លាក់រូបនាគ សម្រាប់ចរាចរក្នុងជំនួញដូរ» (Chroniques Cambodge ១៩៨៨ : ២១) ។ បើទោះបីជា ១០ ឆ្នាំក្រោយមក ព្រះរាជាអង្គនេះបានអស់ព្រះជន្មដោយគេដោតព្រះកេសរបស់ទ្រង់នៅលើបង្គោលឈើក៏ដោយ ក៏គេទទួលស្គាល់ថា នៅប្រហែលឆ្នាំ ១៦០០ ប្រទេសកម្ពុជាបានបោះលុយកាក់ប្រាក់ និងមាសរបស់ខ្លួន ដែលមានរចនានូវរូប «មាន់គោក ពស់ ឬក៏បេះដូង» (ប្រហែលជារូបហង្សនាគ និងផ្កាឈូក (San Antonio ១៦០៤ : ៩) ។ កាក់ធំបំផុត ដែលមានតម្លៃជិតមួយរៀលគឺគេហៅថា មាិបដែលទំនងជាទទួលឥទ្ធិពលរបស់ម៉ាឡាយូ-មូស្លីម ឬអាចមកពីពួកអេស្ប៉ាញបានសិក្សាស្វែងយល់ពីប្រទេសកម្ពុជាតាមរយៈការបញ្ច្រះភាសាម៉ាឡេ ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៦៣០មានឈ្មួញចិនក្នុងស្រុកម្នាក់ដែលបានចុះកិច្ចសន្យាក្នុងការបោះលុយកាក់ខ្មែរ ដោយសារគាត់បានស្វែងរកទិញប្រាក់ពីពួកហូឡង់ដើម្បីយកមកបោះកាក់នេះ (Gaelen ១៦៣៦ : ៧៤, ១១២)។

គេប្រាកដជាមើលឃើញថា កិច្ចប្រឹងប្រែងក្នុងកំណែទម្រង់រូបិយវត្ថុតាមរយៈការបោះកាក់មាសទាំងនេះគឺជាការតទល់ទៅ និងលំហូររបស់ប្រាក់ដ៏ច្រើនអនេកមកមកក្នុងតំបន់ក្រោយឆ្នាំ ១៥៧០។ លទ្ធផលក្លាមៗនៃវិធីថ្មីក្នុងការទាញយកបារតចេញពីរ៉ែប្រាក់ នៅតាមតំបន់និយាយភាសាអេស្ប៉ាញ នៅទ្វីបអាមេរិក និងប្រទេសជប៉ុនយ៉ាងហោចណាស់ក៏បានបង្កើននូវលំហូរប្រាក់ចូលមកក្នុងតំបន់អាស៊ីខាងកើត មួយជាបួនដែរ ដូចមានបង្ហាញប្រាប់ត្រួសៗខាងលើស្រាប់ (តារាងលេខ ៣) ។ ទោះបីជាចិន និងឥណ្ឌា បានស្រូបយកភាគច្រើននៃប្រាក់ដែលហូរចូលមកនេះក្តី ក៏នៅមានភាគច្រើនទៀតបានហូរចូលឆ្លងកាត់តំបន់អាស៊ីអាគ្នេយ៍ ហើយមួយចំនួនស្ថិតនៅតំបន់នេះមិនរសាត់ទៅណាទេ។ តុងកឹងគឺជាចំណុចដឹកជញ្ជូនឆ្លងកាត់ ក៏ប៉ុន្តែការដឹកជញ្ជូនរបស់ក្រុមហ៊ុន VOC នូវប្រាក់របស់ជប៉ុននៅទីនោះជាមធ្យមមានចំនួន ២.៥ តោនក្នុងមួយឆ្នាំៗ នៅក្នុងកំលុងឆ្នាំ ១៦៤០-៥៤ ហើយការនាំចូលប្រាក់របស់រដ្ឋមិនសូវមានសកម្មភាពពាណិជ្ជកម្មនៅអាស៊ីអាគ្នេយ៍មួយនេះជាសរុបមានចំនួនប្រហែល ១០ តោន

ក្នុងមួយឆ្នាំ (Klein១៩៨៨ : ១៦៦-៦៩, Baron ១៦៨៥ : ៧) ។

គេបានធ្វើការគណនាឃើញថា ការផ្គត់ផ្គង់រូបិយវត្ថុពីធ្វើពីប្រាក់ឲ្យមានចរាចរនៅក្នុងប្រទេសឥណ្ឌាបានកើនឡើងលើសបីដងនៅចន្លោះឆ្នាំ ១៥៩១ និង ១៦៣៩ (Habib ១៩៨២ A : ៣៦៣-៦៥)។ នៅអាស៊ីអាគ្នេយ៍ក៏មានការការកើនឡើងមិនតិចជាងនៅក្នុងប្រទេសឥណ្ឌាដែរ ដោយសារតែនៅទីនេះគេបានប្រដែងគ្នាយ៉ាងខ្លាំងក្លាបំផុតក្នុងការទិញផលិតផលអាស៊ី ។ មិនមានមន្ទិលទេ ប្រាក់បានតំណាងឲ្យការផ្គត់ផ្គង់លុយកាក់ទាំងដុំក្នុងចំនួនយ៉ាងច្រើននៅតាមទីក្រុងក្នុងតំបន់នេះ ។ ភាពសម្បូរហូរហៀរបស់ប្រាក់នេះហើយ គឺជាការពន្យល់យ៉ាងច្បាស់អំពីការធ្លាក់ចុះនៃតម្លៃរបស់វាទល់នឹង លុយ និងមាស ។ គេប្រហែលរំពឹងថារដ្ឋអាស៊ីអាគ្នេយ៍ទាំងឡាយគួរតែអាចក្តាប់ឱកាសនៃការទទួលយក និងជំរុញនូវរូបិយវត្ថុប្រាក់របស់ខ្លួនឲ្យក្លាយជាមធ្យោបាយមួយដើម្បីគ្រប់គ្រងសេដ្ឋកិច្ចផ្ទៃក្នុងរបស់ខ្លួន ដូចដែលប្រទេសឥណ្ឌានៅសម័យមុហ្គោល និងបណ្តាប្រទេសអឺរ៉ុបជាច្រើនទៀតធ្លាប់បានអនុវត្តកន្លងមកអ៊ីចឹងដែរ ។

ទោះបីជាពួក ភានងរោននៅទីក្រុងបង់តេនបានស្នើសុំពួកហូឡង់នៅឆ្នាំ ១៦១៨ ឲ្យជួយបោះកាក់ប្រាក់តូចៗហើយក្រុងគេដាហ៍បានផលិតកាក់ប្រាក់មួយចំនួនតូចដើម្បីជាមធ្យោបាយបញ្ឈប់នូវចរាចរកាក់មាសក៏ដោយ (Netscher and van der Chijs ១៨៦៤ : ១៤៩-៥១, Wicks ១៩៨៣ : ៣៨៧) ក៏កិច្ចខិតខំប្រឹងប្រែងច្បាស់លាស់ដើម្បីបោះលុយកាក់ប្រាក់ គឺមាននៅក្នុងប្រទេសកាន់សាសនាព្រះពុទ្ធប៉ុណ្ណោះ ។ រដ្ឋទាំងនេះមិនសូវផ្តោតទៅលើមាសទេដោយសារតែខ្លួនធ្លាប់ប្រើប្រាស់ប្រាក់ធ្វើជារង្វាស់តម្លៃអស់រយៈកាលយូរមកហើយ ។ កាក់ប្រាក់សុទ្ធដំបូងគេបង្អស់ ដែលគេស្គាល់ថាបានបោះក្រោមឈ្មោះរបស់មេដឹកនាំនៅបណ្តារដ្ឋស្ថិតនៅតំបន់ក្រោមដំណើរខ្យល់មូសុង គឺជាកាក់របស់រដ្ឋអារ៉ាកាន ។ មេដឹកនាំកាន់ព្រះពុទ្ធសាសនារបស់រដ្ឋនេះបានចម្លងគំរូកាក់របស់បេហ្គាល់ នៅក្នុងសតវត្សរ៍ទី ១៥ និង ១៦ ដោយមានបំពេញងារជាភាសាអារ៉ាប់ ។ គេឃើញមានតែចាប់ពីទសវត្សរ៍ឆ្នាំ ១៥៣០ មកទេ ដែលកាក់ទាំងនេះមានឆ្លាក់នូវអក្សរអារ៉ាកាន ដោយនៅពេលនោះវាច្បាស់ណាស់ថា កាក់ទាំងនោះបានបោះនៅក្នុងស្រុកប៉ុណ្ណោះ មិនមែននៅបេនហ្គាល់ទេ ។ មកទល់នឹងសតវត្សរ៍ទី ១៧ កន្លែងបោះលុយកាក់នៅអារ៉ាកានបានប្តូរមកបោះឡើងវិញនូវប្រាក់ដែលនាំចូល និងកាក់បរទេសទាំងអស់ឲ្យទៅជាកាក់ក្នុងស្រុកដែលទង្វើនេះធ្វើឲ្យអារ៉ាកានមានលក្ខណៈពិសេសអាចតទល់ទៅនឹងលុយ real ដ៏មានឥទ្ធិពលខ្លាំងក្លានោះបាន (Wicks ១៩៨៣ : ៧៤-៩១) ។ ទោះជាយ៉ាងនេះក្តី ជនជាតិតែមានប្រវត្តិយូរយារជាងក្នុងការប្រកាន់នូវទម្ងន់របស់ប្រាក់ឲ្យមានទំហំស្តង់ដារ ។

អ្នកនិយាយភាសាតៃ ស្គាល់នូវទម្ងន់កាក់ប្រាក់ពីរប្រភេទសំខាន់ៗ ។ កាក់ដែលមានរាងពកដូចក្រលៀន ឬក៏ដូចគ្រាប់កាំភ្លើង គឺជាលក្ខណៈកាក់របស់ក្រុងអយុធ្យា (រូបភាពទី ១៧ b) និងកាក់បន្ទះដែលមានរាងដូចក្រចកជើងសេះ ឬក៏ដូចកងដៃ គឺជាលក្ខណៈកាក់របស់ក្រុងឈៀងម៉ៃ និងតំបន់នៅភាគខាងជើង (រូបភាពលេខ ១៨) ។ ប្រពៃណីប្រជាប្រិយចំពោះការបង្កើតកាក់រាងដូចគ្រាប់កាំភ្លើង (ដូចកាក់ផ្សេងៗជាច្រើនទៀត) មានជាប់ទាក់ទងស្តេចរ៉ាមកំហែង នៅសុខោទ័យ (១២៧៥-១៣១៧) និង កាក់រាងដូចកងដៃជាមួយ និងស្តេចម៉ាងរ៉ៃ នៅឈៀងម៉ៃនាសម័យកាលជាមួយគ្នានោះ (១២៥៩-១៣១៧) ប៉ុន្តែដោយសារតែសញ្ញានៅលើទម្ងន់កាក់ទាំងនេះមិនមែនសម្រាប់តែព្រះរាជាអង្គណានោះ គេពិតជាពិបាកនឹងស្វែងយល់ពីការពិតនូវភាពចំណាស់នៃប្រព័ន្ធនេះណាស់ ។ Le May (១៩៣២ : ១៩-២២, ៤៤-៤៥) បានផ្តល់ជាសម្មតិកម្មថា កាក់រាងដូចកងដៃជាកាក់ដែលមានអាយុកាលចំណាស់ជាង ហើយក្រុងតៃខាងជើងបានបោះកាក់នេះដោយយកលំនាំតាមកាក់រាងជាអឌ្ឍចន្ទរបស់ Pyu ដែលមានសរសេរ

នៅក្នុងឯកសារចិនក្នុងរជ្ជកាលថាំង ។ កាក់រាងដូចកងដៃនេះមានលក្ខណៈងាយស្រួលក្នុងការយួរដើរដោយចងចូលគ្នាជាចង្កោម ប៉ុន្តែអាចបណ្តាលមកពីកាក់ដែលមានរាងពកមានលក្ខណៈងាយស្រួលជាងសម្រាប់ការធ្វើដំណើរតាមផ្លូវទឹក ឬក៏អាចបណ្តាលមកពីគោលបំណងក្នុងការជំនួសលុយសំបកខ្យងដែលកំពុងតែចរាចរដោយប្រាក់នោះដែលធ្វើឲ្យកាក់រាងដូចគ្រាប់កាំភ្លើងបានវិវត្តជាបន្តបន្ទាប់នៅសម័យសុខោទ័យ ឬក៏នៅដើមសម័យអយុធ្យា ។

គេនៅតែមានការស្រពិចស្រពិលអំពីពេលវេលាដែលលុយកាក់ទម្ងន់នេះក្លាយជាលុយកាក់ផ្លូវការនោះ ទោះបីជាគេប៉ាន់ស្មានថាប្រហែលជាក្នុងកំលុងរជ្ជកាលព្រះបាទឆៃរ៉ាចា (Chairaja) (១៥៣៤–៣៦) ដែលពង្សាវតារដំបូងៗបានបញ្ជាក់ថា «ព្រះអង្គបានលប់បំបាត់នូវការអនុវត្តការថ្លឹងទម្ងន់ ក៏ដូចជារង្វាស់រង្វាល់ដែលមានការកេងបន្ទំពីទឹកដីរបស់ព្រះអង្គ» ក៏ដោយ (van Vliet ១៦៤០ : ៧១) [៦] ។ យ៉ាងហោចណាស់ គេអាចធ្វើការសន្និដ្ឋានបានថា នៅពេលណាមួយ ក្នុងកំលុងសតវត្សរ៍ទី ១៦ ទម្ងន់ និងរូបរាងរបស់កាក់ប្រាក់របស់សៀមដែលមានរាងដូចគ្រាប់កាំភ្លើងចាប់ផ្តើមមានមាត្រដ្ឋានត្រឹមត្រូវ ។ មកទល់នឹងឆ្នាំ ១៦១៤ សម្រាប់ពួកអង់គ្លេស កាក់ តិកាល ធ្វើពីប្រាក់ (ភាសាថៃហៅថាបាត) នេះតំណាងឲ្យ «Kings coyne of Syam» (Best ១៦១៤ : ៥៣) ។ កាក់នេះមានទម្ងន់ថេរប្រហែល ១៤,៦ ក្រាម ក្នុងកំលុងសតវត្សរ៍ទី ១៧ (Wicks ១៩៨៣ : ១៦៩–៧០) ហើយបានរក្សាតម្លៃជាលក្ខណៈអន្តរជាតិរបស់ខ្លួនឲ្យនៅថេរ ដែលមានតម្លៃបីភាគប្រាំនៃតម្លៃកាក់ real ឬក៏ ៣០ ផេនសលុយអង់គ្លេស ។ គេធ្វើកាក់ទម្រង់រាងដូចក្រលៀនបានដោយការរំលាយទៅក្នុងពុម្ពរាងមូលទ្រវែង ហើយបន្ទាប់មកគេកាត់ជ្រុងសំប៉ែតដើម្បីងាយស្រួលក្នុងការកាច់ជ្រុងសងខាងឲ្យកោងចូលគ្នា ។ បន្ទាប់មកទៀត គេឆ្លាក់នៅលើផ្នែកទាំងសងខាងរបស់កាក់នូវរូបសត្វ សំបកខ្យង ផ្កាឈូក ឬក៏រូបកង់រទេះជាដើម (Le May១៩៣២ : ៦៣–៦៥) ។

ទោះបីជានៅភាគខាងជើងប្រទេសភូមាសម្បូរធនធានប្រាក់ច្រើនក៏ដោយ ក៏ទីក្រុងពេគូមិនមានរូបិយវត្ថុទេនៅក្នុងសតវត្សរ៍ទី ១៦ គ្រាន់តែមានការប្រើកាក់ gansa ដែលមានលក្ខណៈរញ៉េរញ៉ៃ ។ Pires (១៥១៥ : ១០០) បានបន្ថែមនូវព័ត៌មានគួរឲ្យចាប់អារម្មណ៍ថា ប្រាក់ក៏មានប្រើផងដែរនៅលើទីផ្សារក្រុងពេគូ «កាក់ទាំងអស់នោះមាននិមិត្តសញ្ញារបស់សៀម ដោយសារកាក់ទាំងនោះមានប្រភពមកពីសៀម» ។ មកទល់នឹងពីរបីទសវត្សរ៍ដំបូងនៃសតវត្សរ៍ទី ១៧ ប្រទេសភូមាបានជ្រើសយកប្រព័ន្ធលុយកាក់ប្រាក់របស់ថៃផ្តោតលើទម្ងន់មកអនុវត្តយ៉ាងមានប្រសិទ្ធិភាព ដោយបានផ្តល់សិទ្ធិឲ្យឈ្មួញកណ្តាលក្នុងការធានាឲ្យដំណើរការនេះមាននិរន្តរភាពបាន ។ ទិកាលជាពាក្យហៅដោយពួកបរទេសសំដៅទៅលើទម្ងន់ផ្លូវការរបស់ប្រាក់នៅក្នុងប្រទេសទាំងពីរ ប៉ុន្តែពាក្យដើមរបស់វាគឺពាក្យ បាត (baht) និងក្យាត (kyat)ដែលពាក្យទាំងនេះនៅមានប្រើសំដៅលើឯកតានៃរូបិយវត្ថុនៅក្នុងប្រទេសថៃ និងភូមាមកទល់សព្វថ្ងៃ ដោយពាក្យ បាតប្រើនៅក្នុងប្រទេសថៃពាក្យ ក្យាតប្រើនៅក្នុងប្រទេសភូមា ។ នៅក្នុងប្រទេសភូមាវាទម្ងន់មួយភាគមួយរយនៃមួយ វិសស ស្មើនឹងប្រហែល ២៤ ក្រាម ។

ប្រព័ន្ធលុយកាក់នេះក៏មានរួមបញ្ចូលទាំងរូបិយវត្ថុដទៃទៀត ដូចជាកាក់រៀល ដែលគេនិយមប្រើប្រាស់ផងដែរ ប៉ុន្តែប្រព័ន្ធនេះជាការឆ្លើយតបដ៏មានប្រសិទ្ធភាពចំពោះបដិវត្តន៍ប្រាក់ ។ ចម្ងល់គឺថាហេតុអ្វីបានជារដ្ឋដទៃទៀតមិនជ្រើសយកមាត្រដ្ឋានកាក់ប្រាក់មកប្រើប្រាស់ ។ ចម្លើយមួយ គឺថាមាសមានភាពសម្បូរហូរហៀរនៅតាមតំបន់នៅឧបទ្វីបជាងនៅតាមតំបន់ផ្សេងៗទៀតនៅទ្វីបអាស៊ី ហើយវាមានតម្លៃថោកជាងប្រាក់ជាងនៅក្នុងប្រទេសឥណ្ឌា ប្រទេសចិន ឬជប៉ុនទៅទៀត ។ នៅមុនឆ្នាំ ១៦២០ វាមានអត្រាប្រហែល ១ : ៧ នៅអាស៊ីអាគ្នេយ៍ និង ១ : ១០ នៅប្រទេសឥណ្ឌា ហើយមកទល់នឹងពាក់កណ្តាលទីពីរនៃសតវត្សរ៍ទី ១៧ វិញអត្រាបានកើនឡើងរហូត



រូបភាព ១៨
ប្រភេទកងដៃប្រាក់របស់ជនជាតិតៃភាគខាងជើង

*ដល់ ១:១២ នៅអាស៊ីអាគ្នេយ៍ និង ១ : ១៥ នៅប្រទេសឥណ្ឌា* (SP I *៦២៥២–២៩ : ៣៧១*, LREIC III: *១៥៦, ឡាលូប៊ែរ* (La Loubere) *១៦៩១ : ៧២*, Habib *១៩៨២*A *: ៣៦៧) ។ គេនិយាយថា នៅក្នុងទសវត្សរ៍ឆ្នាំ ១៦២០ បើសិនជានាំប្រាក់ពីប្រទេសជប៉ុនចូលមកទីក្រុងពេគូដើម្បីផ្តោះប្តូរនឹងមាស នោះគេអាចរកចំណេញបានជិត ១០០%* (Robinson and

Shaw ១៩៨០ : ២៣-២៤) ហើយកោះស៊ូម៉ាត្រា និងប្រទេសហ្វីលីពីនបានបន្តនាំចេញមាសទៅក្រៅប្រទេសនៅសតវត្សរ៍ទី ១៧ ។ ជាងនេះទៅទៀត ការយកចិត្តទុកដាក់ជាប្រពៃណីចំពោះមាសជានិមិត្តរូបនៃអំណាច និងកិត្យានុភាព បានធ្វើឲ្យវាជាវត្ថុដ៏សក្តិសមសម្រាប់ឆ្លាក់ព្រះនាមរបស់ព្រះមហាក្សត្រ ។

សំខាន់ជាងនេះទៅទៀត អាស៊ីអាគ្នេយ៍មានការបែងចែកផ្នែកនយោបាយ ជាងប្រទេសឥណ្ឌា ឬក៏ប្រទេសចិនទៅទៀត ហើយមិនត្រឹមតែប៉ុណ្ណោះ ទំហំរវាងទីផ្សារអន្តរជាតិ និងទីផ្សារក្នុងស្រុកមានលក្ខណៈខុសគ្នាខ្លាំង ។ ឈ្មួញហ្វ្រង់ស៊ីស្កូ ឌឺ បូស៊ីញ (Francesco del Bocchier) ដែលជាជនជាតិស៊ីហ្វារឌីក ជ្វីស Sephardic Jewish(១៥១៨ : ១៩៨) បានពន្យល់ថា ទីក្រុងម៉ាឡាការបស់ម៉ាឡេមិនមានប្រើកាក់ធ្វើពីមាស ឬក៏ ប្រាក់ទេដោយសារតែ «ឈ្មួញនៅទីនោះយល់ច្បាស់ពីទំនិញ ហើយទូទាត់ជាទម្ងន់មាស» តែហេតុផលស៊ីជម្រៅជាងនេះទៅទៀតគឺថា ឈ្មួញអន្តរជាតិទាំងឡាយដែលមកទីក្រុងដូចនេះមានផលប្រយោជន៍ទៅលើរដ្ឋទាំងនោះ ។ មកទល់នឹងសតវត្សរ៍ទី ១៧ គេមិនឃើញមានកាក់ក្នុងស្រុកណាមួយអាចប្រកួតប្រជែងជាមួយនឹងកាក់រៀល របស់អេស្ប៉ាញ ដើម្បីក្លាយជារូបិយវត្ថុអន្តរជាតិនោះបានទេ ។ កាក់រៀលបានក្លាយជារូបិយវត្ថុ និងឯកតាគណនាយ៉ាងរហ័ស សម្រាប់កិច្ចការជំនួញអន្តរជាតិផ្សេងៗ ដែលគ្របដណ្តប់លើកិច្ចការជំនួញទាំងអស់នៅលើទីផ្សារធំៗក្នុងទីក្រុង ។ តម្រូវការប្រាក់ជប៉ុន និងអាមេរិក ដោយឈ្មួញចិន និងឥណ្ឌាដើម្បីយកទៅកាន់ប្រទេសរបស់គេ បណ្តាលឲ្យមានសម្ពាធយ៉ាងធំចំពោះការបោះប្រាក់ក្នុងស្រុក ។ មេដឹកនាំដែលជាអ្នកបោះកាក់ទាំងនេះកំពុងជាប់ពាក់ព័ន្ធនឹងអ្វីដែលបង្ហាញថាជាសមរភូមិបរាជ័យ ដើម្បីរក្សានូវអាណាចក្រខាងក្នុងប្រទេស ដែលពួកគេមានអធិបតេយ្យភាពសេដ្ឋកិច្ចខុសអំពីទីផ្សារអន្តរជាតិដែលពួកគេរស់នៅនោះ ។

កាក់មាសធំៗដែលបានបោះដោយទីក្រុងម៉ាកាសសារ និងចូហរ ដែលមានទម្ងន់ធ្ងន់ជាងកាក់ មាសរបស់អាចេចំនួន ៤ ដង ដែលទំនងក្លាយជាគំរូបានបង្ហាញឲ្យឃើញពីការប្រើងប្រែងបោះជាកាក់មាសដោយចម្លងតាមកាក់ប្រាក់រៀល ដែលឈ្មួញបរទេសបាននាំចូល ។ នៅទសវត្សរ៍ឆ្នាំ ១៦៣០ និង ១៦៤០ កាក់ មាសរបស់ម៉ាកាសសារមានតម្លៃថេរគួរឲ្យកត់សម្គាល់នៅលើទីផ្សារដោយស្មើនឹងប្រមាណបួនភាគប្រាំនៃកាក់ប្រាក់រៀល ហើយគេមានការសង្ស័យថាការប្រមូលចំណូលក្នុងស្រុកខ្វះមានតម្លៃស្មើគ្នា ។ ស្តេចហាសាន់នុឌិន (Hasanuddin) ចាប់ផ្តើមស្គាល់នូវបញ្ហាលំបាកផ្នែកសេដ្ឋកិច្ច ហើយនៅក្នុងឆ្នាំ ១៦៥៥ ព្រះអង្គបានព្យាយាមអនុត្តន៍ដោយបង្ខំឲ្យមានភាពស្មើគ្នារវាងកាក់ មាសថ្មីដែលមិនសូវមានឥទ្ធិពល និង កាក់ចាស់ៗ ទីផ្សារចំពោះកាក់នេះក៏ចាប់ផ្តើមមាន ក៏ប៉ុន្តែប្រជាជនទាំងអស់ចូលចិត្តដោះដូរជាកាក់រៀល ឬមាសដែលមិនមែនជាកាក់ហើយកាក់ថ្មីដែលមិនមានប្រជាប្រិយនោះត្រូវគេដកចេញពីទីផ្សារក្នុងរយៈពេល ៣ ឆ្នាំ ក្រោយមក (Macassar Factory ១៦៥៨ : ១៤៨, Bassett១៩៥៨ : ២៧)។

ស្តេចអ៊ីស្កាន់ដា មុដា (Iskandar Muda) (១៦០៧-៣៦) ដែលជាស្តេចអាចេដ៏ខ្លាំងក្លាជាងគេបំផុត និងជាស្តេចដែលប្រឈមមុខផ្ទាល់ទៅនឹងលំហូរចូលនៃប្រាក់ដ៏ហូរហារនោះ ស្ទើតែវិលក្បាលជាមួយនឹងការប្តេជ្ញាព្រះទ័យរបស់ទ្រង់ចំពោះការឲ្យមានចរាចរមាសនៅលើទីផ្សារ ។ រាល់ព្រះសារលិខិតរបស់ទ្រង់ទាំងប៉ុន្មានបានបង្ហាញថា ព្រះអង្គមានមោទនភាពយ៉ាងខ្លាំងចំពោះកម្មសិទ្ធិរបស់ទ្រង់លើអ្វីៗដែលធ្វើពីមាសដូចជា គ្រឿងតុបតែងលម្អផ្សេងៗ កាជន៍ស្វេតឆត្រ និងសូម្បីតែផ្ទះព្រះអង្គផ្ទាល់ ក៏គេធ្វើឡើងពីមាសរៀបចំទុករួចជាស្រេច ។ គេតម្រូវឲ្យឈ្មួញមូស្លីមទាំងឡាយបង់ពន្ធនាំចូលចំនួន ១០% ជាមាសទៅឲ្យព្រះអង្គ (Beaulieu ១៦៦ : ១១០) ។ មេទ័ពជើងទឹកបារាំងឈ្មោះអុហ្គីស្ទីន ឌឺ បូលីយ៍ ដែលធ្វើដំណើរមកទីក្រុងអាចេ ដោយមិនបានយកអ្វីមកជាប់ខ្លួនក្រៅតែអំពីកាក់ប្រាក់

real នោះ ត្រូវព្រះអង្គធ្វើឲ្យគាត់ជួបការលំបាកស្មុគស្មាញយ៉ាងខ្លាំង ដោយព្រះអង្គមិនត្រឹមតែបដិសេធចំពោះការជួញដូរជាប្រាក់នោះទេ តែថែមទាំងអាចរារាំងប្រជានុរាស្ត្ររបស់ទ្រង់មិនឲ្យធ្វើដូច្នេះទៀតផង ។ «ព្រះអង្គបានប្រាប់ខ្ញុំថា...ប្រាក់...គ្មានប្រយោជន៍ទេសម្រាប់ព្រះអង្គ ហើយព្រះអង្គមិនមានការខ្វល់ខ្វាយចំពោះប្រាក់ជាជាងការខ្វល់ខ្វាយចំពោះទឹកដីរបស់ទ្រង់នោះទេ ÷ ដូច្នេះហើយ ប្រសិនបើខ្ញុំបានយកមាសមកវិញ ព្រះអង្គប្រាកដជាលក់ម្រេចរបស់ទ្រង់ក្នុងតម្លៃមួយស្មើនឹងតម្លៃកំពុងតែចរាចរនៅក្នុងទីប្រជុំជននេះ» (cited Lombard ១៩៦៧ : ១០៧) ។ ទោះជាយ៉ាងនេះក្ដី ការសម្រេចព្រះទ័យរបស់ទ្រង់ក្នុងការរក្សានូវកម្រិតមាត្រដ្ឋានរបស់មាសឲ្យស្ថិតស្ថេរនៅពេលដែលមានលំហូរចូលនៃប្រាក់យ៉ាងហូរហៀរ បានធ្វើឲ្យព្រះអង្គជួបប្រទះនូវបញ្ហាលំបាកជាច្រើន ។ នៅប្រមាណឆ្នាំ ១៦២០ ព្រះអង្គបានយកគំរូតាមទីក្រុងម៉ាកាសសារ ដោយបោះកាក់មាសថ្មីដែលកំណត់ឲ្យមានតម្លៃស្មើនឹង ៤ ដងនៃតម្លៃរបស់កាក់ចាស់ ហើយប្រហែលជាទ្រង់ក៏មានបំណងចង់ឲ្យកាក់មាស នេះប្រដេង និងជំនួសនូវកាក់រៀលផងដែរ ។ តែកាក់ថ្មីនេះគឺធ្វើឡើងពីល្បាយលោហៈដែលមានគុណភាពអន់ជាងមុន ហេតុដូច្នេះហើយបានជាគេមិនទទួលយកកាក់នេះទេនៅតាមទីផ្សារ ទោះបីជាតម្លៃរបស់វាមានតម្លៃស្មើនឹង ៤ ដងតម្លៃកាក់មាសចាស់ក៏ដោយ គេយកតែកាក់រៀលមួយប៉ុណ្ណោះ ។ «ទោះបីជាស្ដេចចេញព្រះរាជបញ្ជាឲ្យកាត់ដៃកាត់ជើងនរណាដែលបដិសេធមិនទទួលកាក់ថ្មីនេះក៏ដោយ ក៏ឈ្មួញទាំងឡាយនៅតែចង់ឃើញជាមុនសិនថា គេចំណាយលុយប្រភេទណាឲ្យទៅខ្លួន» (Beaulieu ១៦៦៦ : ៦៥, also Lombard ១៩៦៧ : ១០៨-០៩) ។ ការព្យាយាមរបស់ស្ដេច Iskandar Muda ក្នុងការគ្រប់គ្រងទីផ្សារតាមវិធីនេះបានទទួលបរាជ័យ ។ នៅក្រោមការគ្រប់គ្រងរបស់ស្ដេចគ្រងរាជ្យបន្តមក គេមិនឃើញមានការប្រើប្រាស់កាក់ មាសធំៗរបស់ទ្រង់ទៀតទេ ហើយកាក់តូចសម័យមុនគេប្រើជាចម្បងសម្រាប់ការធ្វើពិធីបុណ្យ និងសម្រាប់ប្រព័ន្ធច្បាប់ចំណែកទីផ្សារក៏ដំណើរការផ្អែកលើការប្រើកាក់រៀល និងមាសដោយថ្លឹងទម្ងន់ ។

មកទល់នឹងប្រហែលឆ្នាំ ១៦៣០ មិនថាយ៉ាងណាទេ ប្រាក់បានជ្រាបចូលយ៉ាងខ្លាំងក្លាក្លាយជារូបិយវត្ថុអន្តរជាតិដ៏ជោគជ័យនៅអាស៊ីអាគ្នេយ៍ មិនថាជាកាក់រៀល ដូចមាននៅតាមតំបន់ដីគោក ឬជាការថ្លឹងទម្ងន់ទេ ។ ទោះបីជាកាក់មាសរបស់ស្ដេចមានកិត្តិសព្ទយ៉ាងណាក៏ដោយ ក៏ស្ដេចទាំងនេះចាប់ផ្ដើមរំពឹងចង់យកពន្ធ ក៏ដូចជាការផាកពិន័យផ្សេងៗជាប្រាក់ ។ មិនមានអ្វីឆ្ងល់ទេ ដោតជ័យរបស់ប្រាក់បានជំរុញបន្ថែមទៀតការធ្វើសមាហរណកម្មអាស៊ីអាគ្នេយ៍ទៅក្នុងសេដ្ឋកិច្ចពិភពលោក ។ ដោយការផ្លោះប្ដូរប្រាក់យកលុយកាក់ជូវការធ្វើពីស្ពាន់ ឬសំណដែលកំពុងមានភាពអន់ខ្សោយនេះ ជនជាតិវៀតណាម និងជ្វា ប្រហែលជាមិនបានបំពេញកិច្ចការនេះសម្រាប់ខ្លួនពួកគេផ្ទាល់ឲ្យបានល្អនោះទេ ដូចដែលពួកអឺរ៉ុបបានចង្អុលបង្ហាញយ៉ាងឆាប់រហ័ស (van Neck ១៥៩៩ : ៨៧, Baron ១៦៨៥ : ៧) ។ បញ្ហាសំខាន់គឺថា ជនបរទេសគ្រប់គ្រងការផ្គត់ផ្គង់លុយកាក់ ហើយតាមរយៈនេះជនបរទេសទាំងនោះអាចមានលទ្ធភាពចូលទៅទិញផលដំណាំសម្រាប់លក់ដោយផ្ទាល់ពីអ្នកដាំ ។ Blussé (១៩៨៦) បានហៅកាក់បរទេសថា «ជនបង្កប់» សម្រាប់បណ្ដារដ្ឋនៅអាស៊ីអាគ្នេយ៍ ។ កាក់នេះជាអាវុធដ៏ចម្បងនៅក្នុងការតស៊ូដ៏មោះមុតដើម្បីការគ្រប់គ្រងសេដ្ឋកិច្ចរបស់តំបន់នាសតវត្សរ៍ទី ១៧ ។

## ការចាត់ចែងផ្នែកហិរញ្ញវត្ថុ

ជាទូទៅ សកម្មភាពធ្វើជំនួញនៅតាមកំពង់ផែ (អាឆេ) មានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីកន្លែងដទៃទៀត បើមិនធ្លាប់មានបទពិសោធនៅទីនោះទេ គេប្រាកដជាមិនអាចជឿទេ ។ អ្នកទិញទំនិញក្នុងបរិមាណច្រើនគឺមានតែគ្រួសារ

> របស់ពួកពន្ធដារប៉ុណ្ណោះ លើកលែងតែពួក Dagon ៤ នាក់ ប៉ុណ្ណោះ ដែលទិញតែពួកគេមិនហ៊ានចេញមុខតថ្លៃទេលើកលែងតែអ្នកផ្សេងបដិសេធមិនទិញទំនិញទាំងនោះ ។ ពួកគេមិនប្រគល់លុយឲ្យរួចរាល់ឡើយ ហើយអ្នកដែលចង់បានលុយត្រូវលក់ទៅឲ្យម្ចាស់ហាងដែលហ៊ានទិញត្រឹមតែ (កំណាត់ ២០ ដុំ) ឬ ១០ ដុំប៉ុណ្ណោះ ដូច្នេះគេអាចលក់ចេញទៅវិញក្នុងថ្ងៃតែមួយនៅទីផ្សារ . . . ឈ្មួញទាំងនេះនឹងមិនមានបំណងស្តុកទំនិញណាមួយនោះទេ លើកលែងតែ វត្ថុមួយចំនួនដែលមិនអាចរងការខូចខាតពេលកប់ក្នុងដី ដូចជា សំណប៉ាហាំង និងស្ពាន់ធ័រ ជាដើម ។ល។ ប្រសិនបើអ្នកលក់អ្នកត្រូវតែចេញវិក្កយបត្រឲ្យពួកគេឲ្យបង់ក្នុងប៉ុន្មានខែក្រោយ ដោយក្នុងនោះមានមនុស្សតិចតួចណាស់ ឬសឹងតែគ្មានតែម្តង ដែលមិនបានបង់ការប្រាក់ទាន់ពេលកំណត់ ។ ប្រសិនបើនាវាទាំងនោះចាកចេញទៅបាត់ហួសពីការស្មានព្រោះព្រះមហាក្សត្រិយានី ឬពួកអូរ៉ង់កាយ៉ាសំខាន់ៗមានភាពតឹងរ៉ឹងបំផុត ក្នុងការអនុវត្តយុត្តិធម៌ចំពោះចំណុចនេះ ។ ជលោរក្សសំបុត្រពីអាឆេ ១៧ ធ្នូ ១៦៤៣, IOLE/៣,១៨ : f.២៨២-៨៣

*អ្នកធ្វើដំណើរជនជាតិអឺរ៉ុប និងចិនចាប់តាំងពី ចូវ ជូ គ័រ (១២៥០ : ១៦០) នៅស.វទី ១៣ រហូតដល់មន្ត្រីអាណានិគម និងពួកសហគ្រិននៅដើមស.វទី ២០ សម្លឹងឃើញនៅក្នុងក្រសែភ្នែករបស់ពួកគេថាតំបន់អាស៊ីអាគ្នេយ៍ជាទូទៅមិនសូវសម្បូរមូលធនប៉ុន្មានទេ ។ គេកម្រឃើញមានឈ្មួញធំៗដែលមានស្តុកទំនិញច្រើនៗ សម្រាប់ដាក់លក់ណាស់ ឬក៏មានលុយច្រើនសម្រាប់ទិញទំនិញផ្សេងៗនោះទេ ។ «ពួកគេទាំងនេះទិញសម្លៀកបំពាក់តណ្លៃតិចតួចប៉ុណ្ណោះហើយនៅពេលដែលពួកគេលក់អស់ ពួកគេក៏មកទិញម្តងទៀត ហើយគ្មានឈ្មួញណាម្នាក់ហ៊ានដោះដូរទំនិញគិតជាលុយស្មើនឹង ១០០ តាហិលនោះទេ» (សម្បុរតមកពីអាឆេ ១២ កុម្ភៈ ១៦១៩, IOC E, ៣,៦: f ២១៣)។ មិនថាតែសម្រាប់ដំណាំសម្រាប់លក់ដូរដូចជាម្រេច ឬក៏ទំនិញផលិតកម្មផ្សេងៗដូចជា ឆ្នាំងដីរបស់វៀតណាមនោះទេ ឈ្មួញគិតថាពួកគេត្រូវតែដោះដូរទំនិញក្នុងទ្រង់ទ្រាយតូចប៉ុណ្ណោះ បើមិនអ៊ីចឹងទេ គឺតាមវិធី «ទុកចិត្ត» ដោយបង្កើនមូលធនសម្រាប់ការចែកចាយទំនិញទៅថ្ងៃអនាគត ។*

*ទោះជាយ៉ាងនេះក្តី បញ្ញត្តិនៃពាក្យឥណទាន ការប្រាក់ និងកាតព្វកិច្ច មានឫសគល់យ៉ាងជ្រៅនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ។ ទោះបីជាគេបានខ្ចីពាក្យហិរញ្ញវត្ថុជាច្រើនពីភាសាតាមីល អារ៉ាប់ ចិន ឬក៏ហូឡង់នៅក្នុងសម័យពាណិជ្ជកម្មក៏ដោយ ក៏ពាក្យជាទូទៅដែលគេប្រើសំដៅលើការប្រាក់ចំពោះមូលធន មានប្រភពដើមយូរយារមកហើយដោយផ្អែកលើពាក្យធៀបជាមួយនឹងផ្កា (ភាសាម៉ាឡេថា ប៊ុនហ្គា (bunga) រីឯភាសាថៃថា ដក (dòk)) នៃរុក្ខជាតិ ឬដើមឈើ ។ នៅក្នុងភាសាថៃសម័យទំនើបពាក្យដកបៀ (dòk-bia) ដែលមានន័យថាការរីករបស់សំបកខ្យងនៅតែប្រើសំដៅលើការប្រាក់ ដែលទំនងជាប្រើតាំងពីសតវត្សរ៍ទី ១៤ នាសម័យសុខោទ័យមកម៉្លេះ ចំណែកឯពាក្យ កុ ដែលមានន័យថាខ្ចីមានការប្រាក់ក៏អ៊ីចឹងដែរ ។ ជាងនេះទៅទៀត ឈ្មួញបរទេសដែលបង្កើនមូលធនទៅលើផលិតកម្មនាថ្ងៃអនាគត ឬក៏ទៅលើជំនួញដឹកជញ្ជូនទំនិញក្នុងស្រុក មិនសូវខ្វល់ជាមួយនឹងកិច្ចសន្យា ដូចដែលពួកគេធ្លាប់នៅក្នុងប្រទេសរបស់ខ្លួននោះទេ ។ «ច្បាប់ស្តីពីបំណុលរបស់ពួកគេមានលក្ខណៈតឹងតែងបំផុត រហូតដល់អ្នកដែលឲ្យខ្ចីប្រាក់មានសិទ្ធិរឹបអូសយកប្រពន្ធ កូន ក៏ដូចជា ទាសករទាំងឡាយ ហើយនិងអ្វីៗទាំងអស់ដែលកូនបំណុលមានយកមកលក់ដើម្បីកាត់បំណុល» (Scott ១៦០៦ : ១៧៣) ។ ច្បាប់នេះគឺជាគ្រិស្តរបស់រចនាសម្ព័ន្ធសង្គមអាស៊ីអាគ្នេយ៍ដែលបំណុលមានន័យថាជាកាតព្វកិច្ច ហើយជាពិសេសគឺកាតព្វកិច្ចទៅលើកម្លាំងពលកម្ម ។ ទាំងនៅក្នុងទីក្រុង និងតំបន់ខ្ពង់រាបផ្សេងៗ ក៏ដូចជារដ្ឋដែលមានឥទ្ធិពល និងសង្គមកុលសម្ព័ន្ធទាំងឡាយ កូនបំណុលត្រូវជាប់ជំពាក់ម្ចាស់បំណុលរបស់ខ្លួនហើយត្រូវបំពេញកាតព្វកិច្ចបម្រើម្ចាស់រហូតដល់សងបំណុលដែលបានខ្ចីនោះ*

*រួចអស់* (Reid ១៩៨៨ : ១២៩-៣៦, ១៩៨៣ : ៨-១២) ។ គោលបំណងរបស់ម្ចាស់បំណុលនៅក្នុងប្រព័ន្ធបែបនេះ គឺមិនមែនចង់បង្កើននូវមូលធនរបស់ខ្លួនដោយការចំណេញការប្រាក់ឲ្យបានច្រើនជាងការចង់បង្កើននូវកិត្តិស័ព្ទ និងអំណាចរបស់ខ្លួនតាមរយៈការមានបរិវារច្រើននោះទេ ។

ការកើនឡើងនូវឱកាសពាណិជ្ជកម្ម និងការចរាចរលុយកាក់ក្នុងកំលុងសម័យពាណិជ្ជកម្មបាននាំឲ្យមានបម្រែបម្រួលយ៉ាងខ្លាំងចំពោះទម្រង់បែបនេះ ប៉ុន្តែវាមិនបានកម្ទេចទម្រង់បែបនេះទេ ។ ទោះបីជាមានលំហូរប្រាក់ និងលុយកាក់ស្ពាន់ចូលមកយ៉ាងច្រើនក៏ដោយ ក៏គេនៅតែពុការត្អូញត្អែរអំពីកង្វះមូលធនដ៏ធ្ងន់ធ្ងរដដែល ៗ ជាក់ស្តែង វាមិនមែនបណ្តាលមកពីការខ្វះថវិកានោះទេ តែមកពីកង្វះប្រព័ន្ធមួយដើម្បីយកថវិការទាំងនេះទៅប្រើប្រាស់ក្នុងការវិនិយោគ ។ នៅម៉ាលុគុ មានគេនិយាយថា ប្រាក់ចំណូលដែលបានមកពីការលក់ផ្កាក្លាំពូជាធម្មតាត្រូវគេកប់ទុកក្នុងដី ÷ «ពួកគេរក្សា (លុយកាក់ស្ពាន់) ទាំងនេះក៏ដូចជា គ្រឿងអលង្ការផ្សេងៗវត្ថុធ្វើពីមាស កងថ្លាកំណាត់សូត្រ និងកំណាត់កូតុងដ៏ម៉ត់ល្អជាច្រើន... ពួកគេរក្សារបស់អស់ទាំងនោះទុកនៅក្នុងភាជន៍ធ្វើពីដី ហើយលាក់ទុកនៅតាមភ្នំដោយកប់នៅក្នុងដី ដូច្នេះគ្មាននរណាអាចដឹងបានទេលើកលែងតែទាសករពីរបីនាក់ដែលយករបស់អស់ទាំងនេះទៅកប់នៅពេលយប់ប៉ុណ្ណោះ» (Galvão ១៥៤៤ : ១៤០-៤១) ។ ក្រោយមកអ្នកដើងសារជំនួញជាតិអង់គ្លេសបានស្នើឲ្យបញ្ជូនកំណាត់ឥណ្ឌាជាសជាងកាក់ប្រាក់ real ទៅកាន់តំបន់ដីកោះផ្សេងៗ ដោយសារតែជនជាតិឥណ្ឌូនេស៊ីមិនសូវខ្វល់ពីកាក់ប៉ុន្មានទេ ដោយគាត់បាននិយាយថា÷ «សន្សំបន្តិចបន្តួចសម្រាប់គ្រឿងអលង្ការផ្សេងៗ ដោយកប់នៅក្នុងដីពីជំនាន់មួយទៅជំនាន់មួយ» (SP ១៦២៥-២៩ : ៣៧១)[៧] ។

បរិបទនយោបាយបានធ្វើឲ្យអ្នកតូចតាចមានភាពខ្វាចរអាក្នុងការបង្ហាញនូវទ្រព្យធនរបស់ខ្លួនដរាបណាអ្នកនោះមានបរិវាគ្រប់គ្រាន់ដើម្បីការពារ និងរក្សាភាពស្របច្បាប់របស់ថាទ្រព្យសម្បត្តិនេះ ។ ដូច្នេះ ហើយគេប្រើមូលធនមុនគេបង្អស់ គឺដើម្បីទាក់ទាញយកមនុស្សជាមុន តាមរយៈការទិញទាសករ ការឲ្យគេខ្ចី ការចងមេត្រីភាពរៀបអាពាហ៍ពិពាហ៍ និងសម្ព័ន្ធភាពយោធា និងរួមទាំងពិធីជប់លៀងផ្សេងៗផងដែរ ។ អ្នកដែលឲ្យខ្ចីលុយជាអាជីពប្រហែលជា ក៏ក្នាក់ងារធនាគារ ដែលផ្តល់នូវប្រាក់កម្ចីដើម្បីផលចំណេញ ជាជាងដើម្បីតែការគាំទ្រ គឺមួយផ្នែកជាមេដឹកនាំ និងឥស្សរជនដែលមានអំណាច ហើយមួយផ្នែកទៀត គឺជាជនបរទេស។

ខាលូ ស៊ីប៉ូឡា (Carlo Cipolla) បានអះអាងថា «បដិវត្តន៍សេដ្ឋកិច្ចដ៏ពិតប្រាកដ» នាដើមសម័យទំនើបនៅទ្វីបអឺរ៉ុបគឺជាការធ្លាក់ចុះយ៉ាងខ្លាំងនៃអត្រាការប្រាក់ (cited Jones ១៩៨១ : ៤១) ។ ការឈានមុខក្នុងពិភពលោករបស់ទីក្រុងអាំស្ទែដាំ នៅក្នុងសតវត្សរ៍ទី ១៧ អាចវាស់បានដោយការផ្គត់ផ្គង់នូវមូលធនយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងកម្រិតការប្រាក់ទាបបំផុតនៅលើពិភពលោករវាងពី ២,៥ ទៅ ៥ % ក្នុងមួយឆ្នាំ (Israel១៩៨៩ : ៧៨) ។ ទោះជាយ៉ាងនេះក្តីក្រុងអឺរ៉ុបភាគច្រើនមិនទទួលបានការផ្គត់ផ្គង់បានប្រសើរជាងទីក្រុងអាស៊ី ដែលមានការចាត់ចែងបានល្អនោះទេ ។ ជាឧទាហរណ៍ ទីក្រុងទាំងឡាយនៅឥណ្ឌាភាគខាងជើងមានអត្រាការប្រាក់រវាងពី ៦% ទៅ ១២ % នៅពាក់កណ្តាលដំបូងនៃសតវត្សរ៍ទី ១៧ (Habib ១៩៦៣ : ៤០១-០៤) ។ យោងទៅលើការប្រៀបធៀបអំពីការរីកលូតលាស់ទៅរកមូលធននិយមនេះ យើងឃើញថាបណ្តាទីក្រុងនៅអាស៊ីអាគ្នេយ៍ស្ថិតនៅពីក្រោយការរីកលូតលាស់នេះឆ្ងាយ ។ ក្រៅពីករណីពិសេសនៅអាចេ ក្រោមការដឹកនាំរបស់ព្រះរាជា Iskandar Muda អត្រាការប្រាក់ល្អបំផុតគឺ ២ ភាគរយក្នុងមួយខែ ហើយវាអាចឡើងលើសពីនេះបីដង ។ អត្រានេះអាចប្រៀបធៀបបានជាមួយ និងឥណ្ឌាភាគខាងត្បូង និងជាមួយបណ្តាប្រទេសភាគច្រើននៅអឺរ៉ុបកាលពីមួយសតវត្សរ៍មុន ក៏ប៉ុន្តែវានៅមានគម្លាតខ្លាំង

ពីមជ្ឈមណ្ឌលហិរញ្ញវត្ថុធំៗ ។

អត្រាការប្រាក់ទាបបំផុតដែលស្រង់យកមកនេះមិនមែនមានន័យថាវាជាអត្រាដែលគេប្រើជាទូទៅនោះទេ សូម្បីតែនៅស៊ូរ៉ាត់ (Surat) ដែលអ៊ីហ្វាន ហាប៊ីច បានបង្ហាញពីអត្រាដ៏សមរម្យបំផុតក៏ដោយ ក៏ពួកអង់គ្លេសនៅគ្រាដំបូងបានត្អូញត្អែរថា ពួកគេមិនអាចរកខ្ចីលុយក្នុងអត្រាការប្រាក់តិចជាង ៣% ក្នុងមួយខែបានទេ ។ លើកលែងតែពេលដែលគេទុកចិត្តអ្នកទាំងនោះ ទើបពួកគេអាចខ្ចីក្នុងអត្រាការប្រាក់ទាបបំផុតបាន ។ នៅក្នុងប្រទេសទំនើបដំបូងភាគច្រើន ក៏ដូចជានៅតាមតំបន់ជនបទនៃបណ្ដាប្រទេសតតិយលោកនាសម័យទំនើបភាគច្រើន ជីវិតរស់នៅក្នុងស្ថានភាពដែលការខ្ចីលុយមានភាពមិនច្បាស់លាស់ ច្បាប់គ្រប់គ្រងមិនមានប្រសិទ្ធភាព ហើយការសងលុយវិញ ក៏មិនមានភាពច្បាស់លាស់ផងដែរ ។ អត្រាការប្រាក់ទាបបំផុតគឺសម្រាប់តែអតិថិជនណាដែលគេទុកចិត្តថានឹងសងវិញតែប៉ុណ្ណោះ ដែលជាទូទៅគ្រប់គ្រងដោយរដ្ឋាភិបាល ។ នៅអាស៊ីអាគ្នេយ៍នាសតវត្សរ៍ទី ១៧ អ្នកទាំងនេះរួមមានដូចជា ក្រុមហ៊ុនអឺរ៉ុប មេដឹកនាំដ៏មានឥទ្ធិពល និងសម្បូរធនធាន ឈ្មួញធំៗ និងសមាជិកនៅក្នុងវណ្ណៈ ឬខ្សែស្រលាយរបស់ខ្លួនតែប៉ុណ្ណោះ ។ ក្រៅពីក្រុមដែលស្ថិតក្នុងរង្វង់អត្តិភាពទាំងនេះ អ្នកផ្សេងទៀតត្រូវខ្ចីក្នុងការប្រាក់ខ្ពស់ខុសធម្មតា ។ វចនានុក្រមតាកាឡុកអេស្ប៉ាញ ដំបូងគេបង្អស់បានផ្ដល់នូវពាក្យបីយ៉ាងសម្រាប់ប្រាក់កម្ចីដែលមានការប្រាក់អាស្រ័យទៅលើថាការប្រាក់នោះ ២០% ក្នុងមួយខែ ១០០% ក្នុងមួយឆ្នាំ ឬ ១៥០% ក្នុងមួយឆ្នាំ (Scott ១៩៨២ : ៥៣៤)។ នៅឆ្នាំ ១៦៤៣ អ្នកជំនួញជើងសារជាតិអង់គ្លេសមួយរូបដែលត្រូវការជាចាំបាច់នូវថវិការមកផ្គត់ផ្គង់ការទិញដូររបស់គាត់នៅអាចេ ត្រូវបង្ខំចិត្តខ្ចីលុយក្នុងកម្រិតការប្រាក់ ៤០០% ក្នុងមួយឆ្នាំ (IOL O.C. E/៣,១៨ : ២៨៥) ។ នៅក្នុងទីក្រុងដដែលនេះកាលពី ១៦ ឆ្នាំមុន មានគេនិយាយថា អ្នកជំនួញជើងសារជាតិអង់គ្លេសសំខាន់មួយរូបបានបន្លំក្រុមហ៊ុនដោយការផ្ដល់នូវប្រាក់របស់ក្រុមហ៊ុនឲ្យជនជាតិចិនខ្ចីក្នុងអត្រាការប្រាក់ ៦% ក្នុងមួយខែ (SP ១៦២៥–២៩ : ៤១៤) ។

ផ្ទុយពីអ្វីដែលបានលើកឡើងខាងលើ អ្វីដែលសំខាន់គឺថាទីផ្សារប្រាក់ដែលមានស្ថេរភាពជាងនេះបានវិវឌ្ឍសម្រាប់អតិថិជនដែលមានការអនុគ្រោះនៅតាមទីក្រុងសំខាន់ៗនៅអាស៊ីអាគ្នេយ៍ ។ ជារឿយៗអត្រាការប្រាក់ ២% ក្នុងមួយខែ មានផ្ដល់ឲ្យគួរសមនៅសៀម បង់តេន ហ្សំប៊ី និងប៉ាតានី ដើម្បីបង្ហាញថាប្រព័ន្ធដូចនេះមានដំណើរការបាននៅពាក់កណ្ដាលសតវត្សរ៍ទី ១៧ (Coolhaas III: ៣២២, ៣៩៩; Smith១៩៧៤ : ២៦៦–៦៧, Schrieke ១៩៤២ : ៣៨៦–៨៧) ។ នៅប៉ាតានីនាឆ្នាំ ១៦១៧ យោងទៅលើបែបបទលម្អិតក្នុងការរៀបចំឲ្យមានអត្រាការប្រាក់ផ្សេងៗគ្នាសម្រាប់ប្រាក់កម្ចីរយៈពេលវែង ដោយមានការប្រាក់ ២០% ក្នុងមួយឆ្នាំនោះ ព្រះមហាក្សត្រីបានប្រទានកំចីប្រាក់ទៅឲ្យឈ្មួញធំៗទាំងឡាយក្នុងអត្រាការប្រាក់ ២% ក្នុងមួយខែ (LREIC II: ៨០–៨១, ៨៧) ។

សាសនាអ៊ីស្លាមមានឥទ្ធិពលគួរឲ្យកត់សម្គាល់ទៅលើនិតិវិធីពាណិជ្ជកម្ម ។ ផ្នែកនៃកំរងច្បាប់ម៉ាឡេដែលនិយាយទាក់ទង និងពាណិជ្ជកម្មគឺមួយភាគធំខ្ចីមកពីច្បាប់អ៊ីស្លាម និងពាក្យសម្រាប់សម្គាល់បញ្ញត្តិនីមួយៗដូចជាពាក្យថា ការក្ស័យធន (muflis)ជាដើម ត្រូវគេខ្ចីមកពីភាសាអារ៉ាប់បញ្ចូលទៅក្នុងភាសាម៉ាឡេ ។ ច្បាប់នេះមិនបានថែងឲ្យបានច្បាស់ពីការប្រាក់នោះទេ ពីព្រោះពាក្យរីបា (riba) ដែលជាពាក្យអារ៉ាប់សំដៅលើការចងការប្រាក់ក្នុងចំនួនការប្រាក់ច្រើន ត្រូវបានហាមឃាត់ក្នុងសាសនាអ៊ីស្លាម ។ ជំនួសមកវិញ វាបានថែងអំពីការចែករំលែកប្រាក់ចំណេញដោយមានការព្រមព្រៀងគ្នា (laba)÷[៨] «អ្នកផ្ដល់មូលធននិយាយទៅកាន់ភ្នាក់ងាររបស់ខ្លួនថា ÷ «យកលុយកាក់មាស ឬប្រាក់នេះ ហើយប្រើវាសម្រាប់ធ្វើជំនួញទៅ ។ ប្រាក់ចំណេញ (laba) ពីការធ្វើជំនួញនេះ

ទាំងសម្រាប់ខ្ញុំ ក៏ដូចជាសម្រាប់អ្នក ត្រូវតែបែងចែកទុកជាមុន» ប្រសិនបើមូលធននេះខាតបង់មួយផ្នែក ឬទាំងអស់ (ក្នាក់ងារ) មិនចាំបាច់ត្រូវទូទាត់សងសម្រាប់ការធ្វើជំនួញនេះ ឬក៏ការខាតបង់នូវមូលធននោះទេ ប្រសិនបើវាមិនមែនបណ្ដាលមកពីការធ្វេសប្រហែល» (Undang-undang Melaka : ១៨៦) ។ យើងបានឃើញថាកំណត់ត្រារបស់ពួកព័រទុយហ្កាល់បានបញ្ជាក់ថា គេជំរុញមូលធនឲ្យកើនឡើងតាមវិធីនេះទៅលើការធ្វើជំនួញតាមផ្លូវសមុទ្រ ដោយអាចទទួលប្រាក់ចំណេញមកវិញ ខ្ពស់រហូតដល់ ៥០% ។ គេមើលឃើញថាប្រព័ន្ធបែបនេះខុសពីកម្ចីប្រាក់ជាលក្ខណៈបុគ្គលត្រង់ថា អ្នកផ្ដល់ប្រាក់កម្ចីទទួលយកនូវភាពប្រថុយប្រថាននៃការខាតបង់ ហើយអ្នកខ្ចីវិញមិនជួបនូវភាពប្រថុយប្រថានក្នុងការត្រូវគេបង្ខំឲ្យធ្វើជាទាសករនោះទេ ដែលនេះគឺជាជោគវាសនាល្អរបស់អ្នកខ្ចី ។

ការមិនឯកភាពក្នុងសាសនាអ៊ីស្លាមចំពោះការប្រាក់ (riba) ទំនងជាមិនមានឥទ្ធិពលទៀតទេ ទៅលើទីផ្សារប្រាក់នៅអាស៊ីអាគ្នេយ៍ជាងនៅមុហ្គោល ឥណ្ឌា (Habib ១៩៦៣ : ៤១៣–១៩) ទេ ដែលយ៉ាងហោចណាស់ ឈ្មួញក៏មិនបានត្អូញត្អែរចំពោះបញ្ហានេះដែរ ។ មានការប្រើងប្រែងពីរក្នុងការធ្វើឲ្យពាក្យនេះបញ្ចូលទៅក្នុងច្បាប់ ។ នៅក្នុងឆ្នាំ ១៦៣១ មេដឹកនាំនៅម៉ាកាសសារបានចេញបម្រាមថា «បំណុលគួរតែមានការប្រាក់» ( Lontara’ Bilang Gowa :៩១) ទោះបីជាពួកអឺរ៉ុបមិនបានចាត់ទុកបញ្ហានេះថាជាឧបសគ្គក៏ដោយ ។ នៅអាចេ ក្រោមការដឹកនាំរបស់ព្រះរាជា អ៊ីស្កានដា មុដា ,(បូលីយ៉ឺ ១៦៦០ : ១០០–០១) បានសន្និដ្ឋានថា «ប្រាក់កម្ចីដែលមានការប្រាក់ច្រើនត្រូវបានហាមឃាត់» ។ គាត់បានអះអាងថា ការប្រាក់មិនមានលើសពី ១% ក្នុងមួយខែទេ ចំណែកឯនៅក្នុងទីក្រុងបង់តេនដែលជា (គូប្រជែងរបស់ទីក្រុងអាចេ) វិញ អ្នកខ្ចីត្រូវបង់ការប្រាក់ ៥% ។ បូលីយ៉ឺ មានទំនងជិតស្និទ្ធមិនធម្មតាជាមួយនឹងស្ដេច ហើយគាត់បានបង្ហាញចំណាប់អារម្មណ៍បែបនេះដោយយោងពីជំពូកមួយនិយាយពីច្បាប់រៀបអាពាហ៍ពិពាហ៍របស់សាសនាអ៊ីស្លាម ដូច្នេះព័ត៌មានរបស់គាត់ប្រហែលជាមានប្រភពមកពីស្ដេច ឬក៏កាដិ (ចៅក្រមអ៊ីស្លាម) ដែលមិនមែនមានប្រភពមកពីសហគមន៍ឈ្មួញនោះទេ ។ ស្ដេច អ៊ីស្កានដា មុដា បានក្ដោបក្ដាប់សេដ្ឋកិច្ចក្នុងស្រុកនៅក្នុងព្រះហស្ដរបស់ទ្រង់យ៉ាងណែន ហើយប្រហែលជាបានចេញសេចក្ដីបង្គាប់បែបនេះប្រហែលជាដើម្បីផ្ដល់ផលប្រយោជន៍ដល់កម្ចីផ្ទាល់របស់ព្រះអង្គ ។ ការណ៍នេះអាចពន្យល់បានថាហេតុអ្វីបានជានៅក្នុងទីផ្សារសេរីនៅទីក្រុងអាចេអត្រាការប្រាក់ខ្ពស់ខ្លាំងមិនធម្មតាដែលពួកអង់គ្លេសសម្អាង(ខាងលើ)នេះកើតមានឡើង ។

ទម្រង់នេះសរបញ្ជាក់យ៉ាងច្បាស់ថា អាស៊ីអាគ្នេយ៍មិនអាចឈានទៅដល់ការបង្កើតស្ថាប័នសាជីវកម្មដូចជាធនាគារ និងទីផ្សារភាគហ៊ុន ដែលរីកដុះដាលនៅបណ្ដាទីក្រុងនៅអឺរ៉ុបនាសតវត្សរ៍ទី ១៧ នោះទេ ។ ទោះបីជាយ៉ាងនេះក្ដី ទម្រង់បែបផែនដែលបានអនុវត្តកាលពីមួយសតវត្សរ៍ ឬពីរសតវត្សរ៍មុននៅអឺរ៉ុប ដែលក្នុងនោះអ្នកផ្ដល់ប្រាក់កម្ចីសំខាន់ៗ គឺពួកអ្នកឲ្យខ្ចីលុយជនជាតិជ្វីស និងស្ថាប័នសាសនាមួយចំនួនដូចជា មុន ទី ឌី (monti di pietá) របស់អ៊ីតាលីជាដើម ពិតជាមានលក្ខណៈស្រដៀងគ្នាខ្លះនៅតាមតំបន់ស្ថិតនៅពីក្រោមដំណើរខ្យល់មូសុងដែរ ។ នៅតាមបណ្ដាកំពង់ផែនៃមហាសមុទ្រឥណ្ឌា ពួកវណ្ណៈអ្នកពាណិជ្ជកម្មសាសនាហិណ្ឌូ ដូចជាហ្គូចារ៉ាទី សារ៉ាម និងចេទីយ៉ាស នៅឥណ្ឌាភាគខាងត្បូងបានដើរតួយ៉ាងសំខាន់ជាក្រុមជនជាតិភាគតិចអន្តរជាតិដែលមានការរៀបចំចាត់ចែងបានល្អដែលពួកគេប្រកបរបរចិញ្ចឹមជីវិតតាមរយៈការធ្វើចរាចរចរន្តសាច់ប្រាក់ ។ ពួកគេរស់នៅតាមទីក្រុងម៉ាឡាកាប៉ាសែ និងពេគូ នៅពេលដែលពួកព័រទុយហ្កាល់បានធ្វើដំណើរមកដល់នៅដើមសតវត្សរ៍ទី ១៦ ហើយក្រោយមកពួកគេបានបែករស់រីកសាយទៅដល់តំបន់កំពង់ផែផ្សេងៗទៀត ។ ស្ថាប័នសាជីវកម្មសំខាន់ដែលសហគមន៍វណ្ណៈចេទីយ៉ាស បានបង្កើតឡើងក្នុងគោលដៅជាធនាគារ គឺជាមូលនិធិរបស់ព្រះវិហារ ដែលធានា

ដោយការយល់ព្រមបែបសាសនាដ៏មានឥទ្ធិពល ដែលក្នុងនោះមនុស្សគ្រប់គ្នាត្រូវឲ្យរួមវិភាគទាននូវថវិកា ហើយគេក៏អាចខ្ចីថវិកានេះទៅវិញបានផងដែរ (Evers ១៩៨៨: ២០៤) ។ បើតាមនិយមន័យ ទោះបីជាសហគមន៍ភាគច្រើនមិនអាចធ្វើតាមគំរូរបស់ធនាគារសម័យមុននេះក៏ដោយ ក៏ពាណិជ្ជដែរដែលសហគមន៍ទាំងនោះបានស្គាល់ពីគំរូនេះ ដូចដែលវគ្គសំខាន់មួយនៅក្នុងវីរកថាម៉ាឡេដ៏មានប្រជាប្រិយបំផុតបានលើកឡើងដូច្នេះដែរ ។ វីរបុរសម៉ាឡេមួយរូបបានធ្វើដំណើរទៅដល់ព្រះវិហារមួយនៅឥណ្ឌាខាងត្បូង៖ «ពេលដែលមានទំនិញច្រើនសន្ធឹក ឬឈ្មួញខ្វះនូវដើមទុន គាត់បានទៅរកព្រះចៅអធិការព្រះវិហារ ហើយខ្ចីមាសរបស់រូបបដិមា បន្ទាប់មកព្រះចៅអធិការដែលថែរក្សារូបបដិមានេះបានប្រគល់ឲ្យមួយ ឬពីរ បាហារទៅឈ្មួញនោះ ។ ប្រសិនបើឈ្មួញមានបំណងធ្វើឲ្យខកខានមិនបានសងមាសរបស់រូបបដិមានោះ ទោះបីជាឈ្មួញនោះទៅដល់ទីណាក៏ដោយ ក៏ឈ្មួញនោះប្រាកដជារលាយខាតបង់តែម្តង ។ ប្រសិនបើឈ្មួញនោះគោរពស្មោះត្រង់ចំពោះរូបបដិមានោះ ទោះគាត់ទៅដល់ទីណាក៏ដោយ ក៏ទំនិញរបស់គាត់មានសុវត្ថិភាពជានិច្ចដែរ ។ ប្រសិនបើគាត់ខ្ចី (មាស) ២០ កាទី (kati)គាត់ត្រូវថ្វាយកាទីមួយដល់រូបបដិមានោះ» (Hikayat Hang Tuah: ៣៦២)[៩] ។

ពួកវណ្ណៈអភិជនសាសនាហិណ្ឌូដែលគិតតែពីផលចំណេញទាំងនេះ គឺស្ថិតនៅក្នុងក្រុមអ្នកដូរលុយក្លាមៗ តែពួកគេក៏ប្រតិបត្តិធ្វើជាធនាគាររីក និងឈ្មួញកណ្តាលសម្រាប់ឈ្មួញដទៃទៀតផងដែរ ។ ពួកគេមាននូវប្រព័ន្ធសៀវភៅធនាគារ (hundi)ដ៏ជឿនលឿនមួយ ដែលគេអាចចេញឲ្យនៅក្នុងទីក្រុងមួយ ហើយដកសាច់ប្រាក់នៅក្នុងទីក្រុងមួយទៀតបាន មិនត្រឹមតែនៅក្នុងប្រទេសឥណ្ឌាប៉ុណ្ណោះទេ តែថែមទាំងពង្រីកទៅដល់បណ្តាកំពង់ផែផ្សេងៗទៀតនៅតាមតំបន់ស្ថិតនៅក្រោមដំណើរខ្យល់មូសុងដែលពួកឥណ្ឌាឧស្សាហ៍ធ្វើដំណើរទៅមក ដូចជាម៉ាឡាកា ពេគូ បង់តេន ឬអាចេ (Habib ១៩៦៣: ៤០១; Tavernier ១៦៩២ II: ១៨, ២៥)។ នៅសម័យដែលពួកព័រទុយហ្គាល់ដណ្តើមកាន់កាប់ឈ្មួញដែលមានជាងគេពីររូបនៅទីក្រុងម៉ាឡាកា ឈ្មោះសុរ៉ាដេវ៉ាណា និងណៃណា ឆាតុ គឺជាអ្នកកាន់សាសនាហិណ្ឌូមកពីឥណ្ឌាភាគខាងត្បូង ហើយប្រហែលជាមកពីវណ្ណៈចេទីយ៉ាស ដែលបានឈានឡើងហួសពីមុខរបរដើមជាអ្នកផ្តល់ប្រាក់កម្ចី ។ នៅក្នុងការរៀបរាប់ពីឈ្មួញនៅម៉ាឡាកា ប៉ាបូសា បានសំដៅជាពិសេសទៅលើ «ចេទីយ៉ាសនៃកូរ៉ូម៉ង់ដែល (Coromandel) ដែលមានរាងជាត់ដុះក្បាលពោះស្អុយ ហើយពួកគេលែងខ្លួនទទេចាប់ពីត្រឹមចង្កេះឡើងទៅលើ» (១៥១៨ II: ១៧៧) ។ កាស្តង់ហេដា (Castanheda ១៥៥២ II: ៤៥៨) បានបង្ហាញអត្តសញ្ញាណរបស់ពួកឈ្មួញទាំងនោះទៅនឹងពូលីកា (Pulicat) ដែលនៅគ្រានោះគឺជាកំពង់ផែ កូរ៉ូម៉ង់ដែល ដ៏សំខាន់ និងច្រកចេញចូលសម្រាប់វិជ័យាណាហ្គា (Vijayanagar) ។ គាត់បានពិពណ៌នា ពួកគេថាជាឈ្មួញដែលមានជាងគេ ហើយមានបណ្តាញជំនួញច្រើនជាងគេនៅលើពិភពលោក ។ ពួកគេចាត់ចែងការធ្វើដំណើរតាមផ្លូវសមុទ្រទៅកាន់ក្រុងម៉ាលុគុ ជ្វា កោះស៊ូម៉ាត្រា ក្រុងពេគូ និងប្រទេសចិន ដែលជាទូទៅប្រើនាវិកជាជនជាតិម៉ាឡេ ជ្វា និងមន (ពេគូ) (Thomaz ១៩៨៨: ៣៧) ។ ស៊ីចារ៉ា ម៉ឺឡាយុ (Sejarah Melayu ១៦១២: ១៨៥) បានចាត់ទុកសុរ៉ាដេវ៉ាណា ថាជា «ឈ្មួញធំជាងគេបង្អស់នៅក្នុងទីក្រុង» ដែលមានសមត្ថភាពក្នុងការព្យាយាមសូកប៉ាន់ប៉ង់ដាហា (Bendahara) ដោយឲ្យ ១ បាហារ ដើម្បីមានឥទ្ធិពលទៅលើជម្លោះពាណិជ្ជកម្មជាមួយនឹងគូប្រជែងរបស់ខ្លួន[១០]។ គាត់បានសហការជាមួយនឹងមេដឹកនាំជ្វានៅទីក្រុងហ្គ្រេស៊ីក ដើម្បីមានឥទ្ធិពលគ្របដណ្តប់ទៅលើជំនួញនៅទីក្រុងម៉ាឡាកា និងម៉ាលុគុ ដោយជ្វាបញ្ជូនសំពៅ ៨ គ្រឿងចេញទៅក្នុងមួយឆ្នាំៗ ។ រួមជាមួយ និងឈ្មួញវណ្ណៈចេទីយ៉ាស មានៗដទៃទៀតនៅពេគូ និងប៉ាសៃឈ្មួញ ណៃណា ទីរីវ៉ាន់ហ្គា (Naina Tirivanga) និងណៃណា កុណាប៉ង់

(Naina kuna pan) សុទ្ធតែជាសម្ព័ន្ធមិត្តដំបូងៗរបស់ពួកព័រទុយហ្គាល់ដែប្រឆាំងនឹងពួកមូស្លីម ហើយពួកគេបាន បរិច្ចាកដើមទុន និង ជំនាញទៅឲ្យក្រុមហ៊ុនពាណិជ្ជកម្មដំបូងៗរបស់ពួកព័រទុយហ្គាល់នៅតាមឈូងសមុទ្របេងហ្គាល់ (Bouchon ១៩៧៩:១៤១; Alves ១៩៨៩) ។

ទោះជាយ៉ាងនេះក្តី អ្នកប្រកបរបរជាឈ្មួញកណ្តាលផ្នែកពាណិជ្ជកម្មដែលមានចំនួនច្រើនជាងនេះទៀតគឺ ជាជនជាតិម៉ូស្លីម ហ្គូចារ៉ាទី ដែលមានសមត្ថភាពប្រសើរជាងក្នុងការដំណើរការជំនួញនៅក្នុងបរិយាកាសសម្បូរ ទៅដោយពួកកាន់សាសនាអ៊ីស្លាមច្រើនឡើងៗនៅតាមកំពង់ផែមួយចំនួន ដូចជា អាចេ និងបង់តេន ជាដើម ។ ឈ្មួញហ្វ័រង់ទីន ដំបូងបង្អស់ដែលធ្វើដំណើរមកដល់ម៉ាឡាកា បានទទួលស្គាល់ថា ពួកហ្គូចារ៉ាទី នៅទីនោះជា «ឈ្មួញប៉ិនប្រសប់ និងវៃឆ្លាត គ្រប់សកម្មភាពពាណិជ្ជកម្មទាំងអស់ដូចជាពួកយើងផងដែរ ។ បញ្ជីរកត់ត្រាទំនិញ ចេញចូល និងបញ្ជីរទំនិញបរិមាណច្រើនរបស់ពួកគេ ដែលបានយកចូល និងបញ្ជូនចេញគឺមានលក្ខណៈល្អឥតខ្ចោះ ទាំងអស់» (Florentine Letter ១៥១៣ : ៣៧៥-៧៧) ។ ឈ្មួញជាតិព័រទុយហ្គាល់ ហ្វ័រង់ទីន នៅឥណ្ឌាម្នាក់ទៀតក៏ ប្រហែលជាសំដៅទៅលើពួក ហ្គូចារ៉ាទីស ទាំងនេះដែរ ពេលដែលឈ្មួញនោះនិយាយថា «អ្នកនៅទីនេះទាំងប៉ុន្មាន មានប្រៀបជាងពួកយើងគ្រប់ផ្នែកទាំងអស់ ។ ហើយមានឈ្មួញជនជាតិមួរដែលមានទ្រព្យសម្បត្តិពី ៤០០.០០០ ទៅ ៥០០.០០០ ducats ។ ហើយពួកគេថែមទាំងអាចគិតលុយដោយប្រើខួរក្បាលបានល្អជាងការដែលយើងគិតដោយ ប្រើប៊ិចទៅទៀត» (cited Subrahmanyam ១៩៩០: ៧) ។ ទោះបីជាឈ្មួញអឺរ៉ុបជាគូប្រជែងដ៏ខ្លាំងក្លារបស់ពួកហ្គូចារ៉ាទី ក៏ដោយ ក៏ពួកគេត្រូវតែជួលពួកនោះឲ្យធ្វើការឲ្យនៅតាមកំពង់ផែម៉ូស្លីមដែលពួកគេមិនស្គាល់ច្បាស់ដែរ ដើម្បី ការពារកុំឲ្យមានការបោកប្រាស់ផ្សេងៗ ។ ជនជាតិអាចេមានការទម្រើសជាមួយនឹងលុយកាក់ណាស់ ហើយពួក គេនឹងចាប់ជនបរទេសណាដែលធ្វើឲ្យមានបំណែកខូចខាតដែលមិនអាចទទួលយកបានចំពោះកាក់នេះ ។ «ប៉ុន្តែ ប្រសិនបើឈ្មួញកណ្តាលព្រមទទួលយកលុយកាក់កខ្វក់ណាមួយនោះ វាគឺជាការខាតបង់ផ្ទាល់ខ្លួនរបស់អ្នកនោះ ។ ជាទូទៅ ឈ្មួញប្រភេទនេះគឺពួកហ្គូស ស៊ុរ៉ាតស៍ (Guzurats) ហើយសម្រាប់ឈ្មួញដែលធ្វើដំណើរឆ្ពោះមកទីនេះជា ពិសេសបើសិនអ្នកនោះជាជនចំណូលថ្មី ចាំបាច់ត្រូវតែមាននូវឈ្មួញកណ្តាលនេះម្នាក់ដើម្បីបង្ការកុំឲ្យទទួលយកប៉ះ លុយកខ្វក់ ឬលុយសើប» (ដាំពែរ ១៦៩៩:៩៤-៩៥, cf. LREIC I:២៧០-71; IV.: 9៤) ។ វាជាការមិនគួរឲ្យភ្ញាក់ ផ្អើលទេ ដែលថាពាក្យម៉ាឡេដែលសំដៅលើដើមទុន (modal) និង ឈ្មួញបរទេស (baniaga) មានប្រភពមកពីភាសា ឥណ្ឌានោះ ។

មិនថាតាមវិធីណាទេរាល់ឈ្មួញកណ្តាលទាំងអស់ដែលធ្វើការទាក់ទងនឹងលុយកាក់គឺសុទ្ធតែជាជនជាតិឥណ្ឌា ទេ សូម្បីតែឈ្មួញកណ្តាលក្នុងស្រុកមួយចំនួនក៏មានឈាមជ័រជាឥណ្ឌាដែរ ។ ប្រទេសភូមាមានប្រភេទឈ្មួញកណ្តាល ពាក់កណ្តាលផ្លូវការ ដែលគេតម្រូវឲ្យពួកបរទេសដែលធ្វើជំនួញនៅតាមទីផ្សារប្រើប្រាស់ពួកនេះ ។ ដើមកំណើត ជាឥណ្ឌារបស់ពួកនេះបញ្ជាក់ដោយពាក្យ« តារ៉េហ្គា- tarega » ដែលសម្រាប់សម្គាល់ពួកនេះ (មានប្រភពមកពី ពាក្យតារ៉េហ្គានៅក្នុងភាសា Telugu—Yule and Burnell ១៩០៣ : ៩០១) ប៉ុន្តែអ្នកទាំងនេះទំនងជាជាតិសាសន៍មន នៅសតវត្សរ៍ទី ១៦ពេលដែលយើងបានឮគេនិយាយពីពួកនេះថា÷ «នៅពេគូមានឈ្មួញកណ្តាល ៨ នាក់ ដែលគេ ហៅពួកនេះថា Tareghe ដែលកម្រិតឲ្យលក់ទំនិញរបស់អ្នកក្នុងតម្លៃដែលត្រឹមត្រូវសម និងលក់ហើយអ្នកផ្តល់ ប្រាក់កម្រៃចំពោះកម្លាំងពលកម្មរបស់ពួកគេ ២% ដោយក្នុងនោះពួកគេអាចជួយធ្វើឲ្យប្រាក់កម្ចីរបស់អ្នកមានផល ចំណេញច្រើនព្រោះអ្នកអាចលក់ទំនិញរបស់អ្នកបានអាស្រ័យលើវោហារសព្ទរបស់ពួកគេតែប៉ុណ្ណោះ ។ បើឈ្មួញ

*កណ្តាលមិនបានបង់លុយឲ្យអ្នក នៅថ្ងៃគាត់សន្យានោះទេ អ្នកអាចយកឈ្មួញនោះទៅឃុំនៅក្នុងផ្ទះរបស់អ្នកបាន»* (Fitch ១៥៩១ : ៣០៤) ។ *ព្រះរាជាគួមាទំនងជាអ្នកដែលបានដាក់ព្រះរាជបញ្ជាឲ្យអនុវត្តប្រព័ន្ធដែលមានតែមួយបែបនេះដើម្បីធានាឲ្យមានការគោរពទទួលស្គាល់នូវភាពផ្តាច់មុខរបស់ព្រះរាជាក្នុងការនាំចេញនូវទំនិញផ្សេងៗ ។ ទោះជាយ៉ាងនេះក្តី តួនាទីរបស់* tarega *បានទទួលការស្ងើចសរសើរពីសំណាក់ជនបរទេសជាច្រើន (ទោះបីជាក្រុមហ៊ុនភាគច្រើនមិនសូវទទួលស្គាល់ក៏ដោយ) ពីព្រោះតែបញ្ហាដដែលៗក្នុងការដោះស្រាយជាមួយនឹងរូបិយវត្ថុដែលគេមិនស្គាល់ដែលក្នុងករណីនេះ គឺរូបិយវត្ថុ* gansa (Hall ១៩២៨ : ៩១)។

*វាក៏បង្ហាញយ៉ាងច្បាស់ផងដែរថា ទម្លាប់ប្រយ័ត្នប្រយែងរបស់ពួកឥណ្ឌាក្នុងការកត់ត្រាកិច្ចសន្យាពាណិជ្ជកម្មជាលាយលក្ខណ៍អក្សរ ក៏មានពួកជ្វា ម៉ាឡេ និងមនចម្លងធ្វើតាមផងដែរ យ៉ាងហោចណាស់ក៏មកត្រឹមនឹងសតវត្សរ៍ទី ១៧ ដែរ ។ លូដូវីស្គស់ (១៥៩៨ : ១២០) បានពន្យល់អំពីរបៀបដែលគេសរសេរកិច្ចសន្យាជាភាសាជ្វានៅលើស្លឹកត្នោត ឬក៏ក្រដាសរបស់ចិនអំពីការប្រគល់ដើមទុនទៅឲ្យឈ្មួញរកស៊ីតាមផ្លូវសមុទ្រដោយឈ្មួញនៅទីក្រុងបង់តេន ។ ឈ្មួញព័រទុយហ្គាល់ប្រចាំនៅទីក្រុងហ្គ្រេស៊ីកនៅចុងស.វទី ១៦ ក៏ដូចជាអ្នកប្រចាំនៅក្រុងម៉ាឡាកានាសម័យកកើតម៉ាឡាកាផងដែរ ផ្អែកជាសំខាន់ទៅលើប្រព័ន្ធកិច្ចសន្យាអាស៊ីដែលមានស្រាប់ដើម្បីធានានូវការវិនិយោគរបស់ពួកគេ ។ នៅពេលដែលអ្នកធ្វើដំណើរជាតិហូឡង់ម្នាក់សួរពួកព័រទុយហ្គាល់ថា ៖ «តើពួកគេអាចយល់អំពីអ្វីដែលរៀបរាប់ជាភាសាម៉ាឡេបានយ៉ាងដូចម្តេច» ហើយចម្លើយគឺថាពួកគេមិនអាចយល់បានទេ តែពួកគេឲ្យជនជាតិជ្វាជាច្រើនអ្នកអានដើម្បីធានាថាកិច្ចសន្យានោះមានភាពត្រឹមត្រូវ* (Heemskerck ១៦០០ : ៥៥១)។

*ជាការពិត ជនជាតិអាស៊ីអាគ្នេយ៍គឺស្ថិតនៅក្នុងចំណោមពួកឈ្មួញរកស៊ីក្នុងក្រុងទាំងឡាយដែលបង្កើនដើមទុនបានច្រើនក្រាស់ក្រែល ហើយវិនិយោគនៅក្នុងដំណើរធ្វើជំនួញតាមផ្លូវសមុទ្រ ។ ចំនួនរបស់ពួកគេហើយនិងបរិមាណដើមទុន ដែលពួកគេបានដាក់ទៅក្នុងរបរជំនួញទាំងនេះមានការកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងសម័យពាណិជ្ជកម្ម ប៉ុន្តែមានការយឺតយ៉ាវជាងដែលគេរំពឹងទុកពីចំណូលនៃការនាំចេញ ។ មូលហេតុគឺមិនមែនបណ្តាលមកពីកង្វះបច្ចេកទេសពាណិជ្ជកម្ម ឬរូបិយវត្ថុនោះទេ ។ ជនបរទេសដែលធ្វើដំណើរមកពីតំបន់នៅខាងលើដំណើរខ្យល់មូសុង ដូចជាពួកព័រទុយហ្គាល់ដែលមកដាលក្ខណៈឯកជនជាដើម* [១១] *ទោះបីជាពួកគេមានកង្វះខាតទាំងផ្នែកបច្ចេកទេសពាណិជ្ជកម្ម និងរូបិយវត្ថុក៏ដោយ ក៏ពួកគេអាចរកប្រាក់បានច្រើនប្រកាន់យកតួនាទីជំនួញរបៀបហ្នឹងដែរ ។ គេក៏ឃើញមានឧបសគ្គដទៃផ្សេងទៀតចំពោះការរីកវឌ្ឍនៃវណ្ណៈឈ្មួញក្នុងស្រុកផងដែរ ។*

## អូរ៉ង់កាយ៉ា (Orangkaya) — ឈ្មួញលំដាប់ខ្ពស់

ខ្ញុំច្រៀងចម្រៀងនេះសំដៅដល់ភាពអស្ចារ្យរបស់ឈ្មួញ និងធនធានសម្បូរហូរហៀររបស់គាត់ ។ ទំនិញសព្វសារពើ និង មាសពេជ្រកែវកងផ្សេងៗមានចំនួនយ៉ាងច្រើនអនេកមិនអាចរាប់អស់ ហើយមានសុភមង្គល និងសេចក្តីសប្បាយឥតសៅហ្មង ។ នៅក្នុងទីក្រុងឥន្ទ្រះបុរៈ ទាំងមូលគ្មាននរណាម្នាក់មានព្រេងសំណាងស្មើ និងគាត់ទេ ។ គាត់មានទាសករមួយពាន់នាក់ ទាំងក្មេងទាំងចាស់ មកពីប្រទេសជ្វា និងតំបន់ផ្សេងៗទៀត ។ ឋានៈរបស់ឈ្មួញនេះខ្ពស់ជាងឋានៈរបស់ ប៊ុន ហ្គាវ៉ា ទៅទៀត ។ គាត់ក៏មានប្រពន្ធច្រើននាក់ផងដែរ ។

—Sya’ir Bidasari: 7

ជាធម្មតា ពាក្យដែលគេប្រើសំដៅដល់ឈ្មួញនៅក្នុងភាសាអាស៊ីអាគ្នេយ៍មានប្រភពមកពីភាសាបរទេស ដូចជាពាក្យជាភាសាម៉ាឡេ សូដាហ្គា (Saudagar) មានប្រភពមកពីភាសាអ៊ីរ៉ង់ ពាក្យ ប៉ានៀហ្គា (baniaga) មានប្រភពមកពីភាសាសំស្ក្រឹត (គេឃើញពាក្យនេះមានប្រើនៅក្នុងសិលាចារឹកដូនាសតវត្សរ៍ទី ១១.—Hall ១៩៨៥ : ១៨) ។ ពាក្យថា «សេទី ceti » នៅក្នុងភាសាម៉ាឡេពាក្យថា «សេដ្ឋី (សេដ្ឋី) setthi » នៅក្នុងភាសាភូមា និងពាក្យថា sethi នៅក្នុងភាសាថៃសុទ្ធតែមានប្រភពមកពីភាសាសំស្ក្រឹតដែលឆ្លងចូលមកតាមរយៈភាសាបាលី និងភាសាតណ្ឌាខាងត្បូង រីឯពាក្យថា «ធួង ម៉ៃ – thuong mai »នៅក្នុងភាសាវៀតណាមវិញ មានប្រភពមកពីភាសាចិន ។ ពាក្យផ្សេងៗទៀតដូចជាពាក្យម៉ាឡេ orang dagang និងពាក្យធៀបរបស់វា ដែលគេឃើញមានប្រើនៅគ្រប់ភាសាអូស្ត្រូនេស៊ី អាចមានន័យថាឈ្មួញ ឬជនបរទេស ដែលជាអ្នកធ្វើដំណើរមកពីខាងក្រៅតំបន់ និងស្ទើរតែទាំងអស់ជាឈ្មួញធ្វើដំណើរ ។ មានពាក្យមួយដែលទំនងជាពាក្យដើមក្នុងស្រុកសុទ្ធសាធតែម្តង គឺពាក្យថា អូរ៉ង់កាយ៉ា ។ នៅក្នុងភាសាម៉ាឡេ និងឥណ្ឌូនេស៊ីសម័យទំនើប ជាធម្មតា ពាក្យនេះមានន័យថាអ្នកមាន (ដូចជានិយមន័យរបស់ពាក្យ សេដ្ឋី នៅក្នុងភាសាថៃ និងភូមាសម័យទំនើបដែរ) ។ នៅតាមបណ្តារដ្ឋភាគច្រើននៅតំបន់ឧបទ្វីប ពាក្យនេះសំដៅទៅលើងាររបស់ពួកអភិជន (ប្រទេសប្រ៊ុយណេក៏នៅប្រើពាក្យនេះដែរ) ។ ទោះជាយ៉ាងនេះក្តី ពាក្យថា កាយាគឺជាពាក្យភាសាអូស្ត្រូនេស៊ី ដែលមានឫសគល់យូយារមកហើយចំណែកឯន័យដើមរបស់វាទាំងនៅក្នុងភាសាជ្វា ភាសាតាកាឡុក ក៏ដូចជាភាសាម៉ាឡេ សំដៅទៅលើអំណាចបុណ្យសក្តិច្រើនជាងសំដៅទៅលើទ្រព្យសម្បត្តិ ។

ចំណុចសំខាន់គឺថា ក្នុងភាសាអាស៊ីអាគ្នេយ៍ ពាក្យថាអំណាច និងទ្រព្យសម្បត្តិមិនសូវខុសគ្នាប៉ុន្មានទេ ។ នៅក្នុងទស្សនៈនៃកម្លាំងខាងក្នុង និងទំនាក់ទំនងជិតស្និទ្ធជាមួយនឹងពិភពព្រលឹង ទ្រព្យសម្បត្តិអាចទទួលបានតាមរយៈតែអំណាចប៉ុណ្ណោះ (Acciaioli ១៩៨៩; Milner ១៩៨២) ។ ប៉ុន្តែ ដោយសារទ្រព្យសម្បត្តិអាចសម្តែងឡើងជាចម្បងតាមរយៈមានបរិវារ ដូច្នេះអ្នកដែលមានទ្រព្យសម្បត្តិច្រើនដាច់ខាតត្រូវតែមានអំណាច ហើយអាចមានការគំរាមកំហែងប្រកបដោយសក្តានុពលដល់មេដឹកនាំបាន ។ សម្រាប់ជនបរទេស និងស្ត្រីវិញ សមភាពរវាងទ្រព្យសម្បត្តិ និងអំណាច មិនសូវច្បាស់ប៉ុន្មានទេ ដូច្នេះចំណុចនេះអាចផ្តល់ឱកាសច្រើនឲ្យមេដឹកនាំដែលមានចិត្តច្រណែនបំបៅងទ្រព្យសម្បត្តិបុណ្យសក្តិរបស់ខ្លួនបាន ។ ទោះជាយ៉ាងនេះក្តី ក៏គេនៅតែឃើញមានបញ្ហាកើតឡើងចំពោះពួកគេផងដែរ ។

ពាក្យ អូរ៉ង់កាយ៉ា បានបញ្ជាក់ពីភាពផ្ទុយគ្នាបែបនេះសម្រាប់ពិភពម៉ាឡេ ។ បើជាប្រភេទមនុស្សវិញពាក្យនេះអាចបកប្រែថាជា «ពួកអភិជនដែលមានទ្រពស្តុកស្តម» ឬ «ក្រុមឈ្មួញជាន់ខ្ពស់» ។ បើជាងារវិញ ពាក្យនេះសម្រាប់មន្ត្រីជាន់ខ្ពស់នៃព្រះរាជវាំង ប៉ុន្តែពាក្យនេះក៏អាចផ្តល់ឲ្យផងដែរដល់ឈ្មួញបរទេស ដែលព្រះរាជាមានបំណងចង់ជ្រើសតាំងឲ្យចូលមកបម្រើព្រះអង្គ និងបង្គាប់ឲ្យគោរពតាមពិធីការរបស់ព្រះរាជវាំង ។ បុរសជនជាតិអង់គ្លេសម្នាក់ឈ្មោះ ថូម៉ាស់ បេស (Thomas Best) បានទទួលងារយ៉ាងវិសេសវិសាលជាអូរ៉ង់កាយ៉ាង ពូទីហ៍ (Orangkaya putih)(ឧបរាជដែលមានចិត្តជ្រះថ្លា) ពីព្រះរាជាអ៊ីស្កាន់ មុដា របស់អាចេ ដោយសារតែគាត់បានបំពេញព្រះហឫទ័យព្រះរាជាដោយការប្រគល់នូវសំពៅរបស់ពួកព័រទុយហ្កាល់ដែលគាត់រឹបអូសបាន (Best ១៦១៤ : ៥៦, ១៦១៣ : ២៥៦) ។ ពាក្យនេះក៏សំដៅទៅលើគ្រួសារគ្រប់គ្រងអំណាចជាច្រើនដែលមានដើមកំណើតជាអ្នកធ្វើជំនួញផងដែរ រួមទាំងគ្រួសារនៅហ្សាប៊ី, ប៉ង់ដា និង អាំបុន ផងដែរ ។ ទោះជាយ៉ាងនេះក្តី នៅទីណាមាននូវទម្រង់រាជាធិបតេយ្យខ្លាំង គេបានមើលឃើញថា អូរ៉ង់កាយ៉ាដែលជាសមូហភាពរួមមានលក្ខណៈប្រឆាំង និងទម្រង់បែបនេះ ។

ពួកគេគឺស្ថិតនៅក្នុងវណ្ណៈអភិជនដែលសម្បូរធនធានតាមរយៈការធ្វើជំនួញ (រូបភាពទី ១៩៧)។

សម្រាប់គោលបំណងវិភាគផ្សេងៗ វាពិតជាសំខាន់ណាស់ក្នុងការបែងចែកអូរ៉ង់កាយ៉ាជាបីប្រភេទ ទោះបីជាយើងមានការពិបាកក្នុងការកំណត់ព្រំដែនឲ្យដាច់ស្រឡះរវាងប្រភេទទាំងបីនេះក៏ដោយ ។ ប្រភទទីមួយ គឺជាឈ្មួញបរទេស ដែលធ្វើដំណើរមកកាន់កំពង់ផែដោយសារឱកាសធ្វើជំនួញ ហើយពួកគេក៏អាចធ្វើដំណើរចាកចេញទៅវិញបានដែរ ។ ប្រភេទទីពីរ គឺជាឈ្មួញបរទេស ឬឈ្មួញដែលមានឈាមជ័រជាបរទេស ដែលមួយផ្នែកគឺពាក់កណ្ដាលឈ្មួញ ពាក់កណ្ដាលមន្ត្រី ដោយពួកគេជាអ្នកធ្វើការសម្រុះសម្រួលរវាងព្រះរាជវាំង និងឈ្មួញ ។ ហើយប្រភេទទីបី គឺជាពួកវណ្ណៈអភិជននៅក្នុងស្រុកដែលពួកគេចូលប្រឡូកក្នុងកិច្ចការជំនួញតាមរយៈអំណាច និងទ្រព្យសម្បត្តិបុណ្យសក្តិរបស់ពួកគេ ។

សមាសភាពនៃប្រភេទទីមួយមានការប្រែប្រួលទៅតាមពេលវេលា ដោយនៅសតវត្សរ៍ទី ១៧ ឈ្មួញក៏ដូចជាឈ្មួញហេរញ្ញិកឯករាជ្យ មានបំណងចង់បើកឱកាសឲ្យអ្នកតំណាងរដ្ឋបរទេសផ្សេងៗនៅក្នុងស្រុក ។ នៅប្រមាណឆ្នាំ ១៥០០ ឈ្មួញធំៗនៅក្រុងម៉ាឡាកា គឺពួកតាមីលកាន់សាសនាហិណ្ឌូ (រួមទាំងពួកចាទីយ៉ាស អ្នកមានសម្បូរហូរហារដែលបាននិយាយពីខាងលើផងដែរ) និងពួកមូស្លីមហ្គុចារ៉ាទី, ជ្វា និងតាហ្គាលុក(Luzon) ។ មិនសូវមានពត៌មានច្រើននិយាយពីជនជាតិហ្គុចារ៉ាទីម្នាក់ៗទេ ដោយសារពួកនោះភាគច្រើនបានធ្វើដំណើរចាកចេញទាំងកំហឹងពេលដែលពួកព័រទុយហ្គាល់ចូលមកដណ្តើមកាន់កាប់ ។ ឈ្មួញតាហ្គាលុក ឈានមុខជាងគេ គឺ «កុលៀឌីរ៉ាចា – Curedera ja» (Kuriadiraja?) ដែលបានបញ្ជូនសំពៅទៅកាន់ប្រទេសចិនជារៀងរាល់ឆ្នាំ និង «អារ៉ីហ្គឹមុត រ៉ាចា – Aregemute Raja» ដែលបានតែងតាំងឲ្យធ្វើជាមេដឹកនាំពួកមូស្លីមដែលនៅសេសសល់នៅម៉ាឡាកាដោយពួកព័រទុយហ្គាល់ ដែលជាអ្នកបញ្ជូនសំពៅទៅកាន់ប្រទេសចិន សៀម បរណៃវ ស៊ុនដា និងប៉ាឡេមបាំង នៅក្នុងឆ្នាំ១៥១៣ (Thomaz១៩៧៩: ១១៤-១៦) ។ ពួកជ្វាគ្រប់គ្រងជំនួញអង្ករមកពីប្រទេសជ្វា ហើយគេអាចសម្គាល់ពួកនេះបានជាពិសេសតាមរយៈការមានធនធានកម្លាំងមនុស្សច្រើន ។ ហត្ថករ និងពលករភាគច្រើននៅម៉ាឡាកាជាជនជាតិជ្វា ហើយមាន «ទាសករ» ប៉ុន្មានពាន់នាក់ទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេដឹកនាំដ៏មានឥទ្ធិពលបំផុតរបស់ពួកគេ គឺ «អុទីមុទីរ៉ាចា– Utimutiraja» (Utamadiraja)។




រូបភាព ទី១៩ក
អូរ៉ង់ការយ៉ានៃអាឆេ គូសពីជីវិតក្នុងអំឡុងឆ្នាំ ១៦៤០

*ក្នុងអំឡុងសតវត្សរ៍ទី ១៦ ឈ្មួញជនជាតិចិន «ទួគី» ព័រទុយហ្គាល់ឯកជន និង ជនជាតិអេស្ប៉ាញបានចូលរួមទៅក្នុងក្រុមឈ្មួញពាណិជ្ជកម្មជាន់ខ្ពស់អន្តរជាតិនេះ រីឯឈ្មួញកាន់សាសនាហិណ្ឌូ និងតាកាឡុកវិញបានត្រូវគេបញ្ចូល ប៉ុឈប់មានសារៈសំខាន់ទៀតហើយ ។ បើយោងទៅលើការរៀបរាប់របស់ពីនតូ* (Pinto *១៥៧៨ : ៦១) អ្នកតំណាងរដ្ឋក៏បានចាប់ផ្តើមមានឥទ្ធិពលផងដែរ ដែលរួមមានមិនត្រឹមតែអ្នកបម្រើឲ្យអេស្តូ* (Estado da India) *ដែលជាជនជាតិព័រទុយហ្គាល់ប៉ុណ្ណោះទេ តែថែមទាំងឥស្សរជនមួយចំនួនទៀតដូចជា ខូចា ហ្សេណាល់ដែលជា «អ្នកមានទ្រព្យសម្បត្តិហូរហៀរមួយរូប» ដែលជាអ្នកតំណាងឲ្យស្តេចស៊ុលតង់ប្រ៊ុយណេនៅតំបន់ប៉ាហាងអស់រយៈកាល ៣ ឬ ៤ ឆ្នាំ នៅក្នុងទសវត្សរ៍ឆ្នាំ ១៥៤០ មុនពេលគាត់សម្លាប់មេដឹកនាំនៅប៉ាហាងដែលមានទំនាក់ទំនងស្នេហាជាមួយប្រពន្ធរបស់គាត់ ។* Drake *(១៥៨០ : ៧០) បានធ្វើដំណើរទៅកាន់ទៃណោត ពេលដែលវាមានការរីកចម្រើនរុងរឿងបំផុត ក្នុងឋានៈជាតំបន់មូស្លីម និងជាអ្នកមានឥទ្ធិពលប្រឆាំងទៅនឹងពួកព័រទុយហ្គាល់ ហើយបានប្រទះឃើញមាន «ជនជាតិរ៉ូម៉ាំង» ៤ នាក់ ស្លៀកសម្លៀកបំពាក់ដូចទៅនឹងពួកទួរគី ជនជាតិទួរគី ២ នាក់ និងជនជាតិអ៊ីតាលីម្នាក់ ដែលអ្នកទាំងអស់គ្នាដើរតួជាភ្នាក់ងារអេចិន្ត្រៃយ៍សម្រាប់ទិញផ្កាក្លាំពូ ។ នៅប្រមាណឆ្នាំ ១៦០០ ឈ្មួញនៅទីក្រុងអាឆេមានតាំងពីឈ្មួញមកពី «ប្រទេសចិន បេនហ្គាឡា ពេគូ កូរ៉ូម៉ង់ដែល ហ្គុយស៊ីរ៉ាត់* (Guserate)*អារ៉ាប៊ី* (Arabia) *និង រូម៉ូស* (Rumos)*(ទួរគី)»* (Davis *១៦០០: ១៥១) ចំណែកឯឈ្មួញនៅទីក្រុងបង់តេនវិញ មានឈ្មួញជនជាតិ*




រូបភាពទី ១៩ខ
គំនូសរបស់ហូឡង់ ពីវណ្ណៈសង្គមនៅប៉ង់ដា នាឆ្នាំ ១៦០០

ដូចខាងលើ និងរួមទាំងឈ្មួញព័រទុយហ្គាល់ អេស្ប៉ាញ និងម៉ាឡេផងដែរ ។

ឈ្មួញមួយរូបក្នុងចំណោមឈ្មួញធំៗនៅទីក្រុងប៉ង់តេន ដែលពួកហូឡង់ និងអង់គ្លេស ជំបូងបង្អស់ធ្វើជំនួញតាមនាវាជាមួយ នោះគឺឈ្មោះចេទី ម៉ាលុគុ ប៉ុសាន់ឆូ ដែលសន្មត់ថាមានដើមកំណើតនៅទីក្រុងម៉ាលុគុ ដោយមានឪពុកជាជនជាតិអេស្ប៉ាញ ដែលឪពុករបស់គាត់ធ្លាប់បានកាន់កាប់នូវបរិវេណមួយផ្នែកធំនៃទីក្រុងប៉ង់តេនហើយបានបញ្ជូនសំពៅទៅកាន់ទីក្រុងហ្គ្រេស៊ីក និងម៉ាលុគុ និងមានលទ្ធភាពផ្គត់ផ្គង់ជនជាតិហូឡង់នូវម្រេចចំនួន ២០០តោន ភ្លាមៗ (លូដូវីស្គស៍ ១៥៩៨ : ៨៨, ១០៤–៥, True Report ១៥៩៩:៣៣, Meilink-Roelofsz ១៩៦២ : ២៤១) ។ ឈ្មួញមួយរូបទៀតក្នុងចំណោមនោះដែរ គឺជាឈ្មួញ «ជនជាតិទួរគី» (ប្រហែលជាមកពីទីក្រុងខេរ៉ូ) ឈ្មោះ Kojah Rayoanដែលចេះនិយាយភាសាអ៊ីតាលី និងធ្លាប់ធ្វើដំណើរទៅទីក្រុងវីយែន ។ គាត់បានជួយជ្រោមជ្រែងជនជាតិហូឡង់នៅប៉ង់តេន និងបន្ទាប់មកនៅប៉ង់ដា ដែលនៅទីនោះគេនិយាយថា មានប្រជាជនគោរពគាត់ច្រើន ("Tweede Boeck ១៦០១ : ៦៨, ៧៧, van Leur ១៩៣៤ : ១៦២, ប៊ិង ១៩៧) ។ ឈ្មួញជនជាតិចិនមានចំនួនច្រើនណាស់ ប៉ុន្តែមានតែពីរបីនាក់ប៉ុណ្ណោះ ដែលមានទ្រព្យសម្បត្តិច្រើនលេចធ្លោ ។ អ្នកជំនិតរបស់ពួកអង់គ្លេស ដែលពួកគេហៅថា «Kewee» គឺជា «ជនដែលមានទ្រព្យច្រើនជាងគេបំផុតនៅក្នុងទីក្រុង» និងសំខាន់មានប្រាក់កម្ចីច្រើនអាចឲ្យពួកអង់គ្លេសខ្ចីនៅឆ្នាំ ១៦១៥ នូវលុយចំនួន ២.០០០ រៀល និងម្រេចចំនួន ៣៩០ តោន (LREIC III: ២៧៤–៧៥) ។ មនុស្សជំនិតរបស់ពួកហូឡង់ ដែលហៅថា «ស៊ីម សួន –Sim Suan» ក៏បានផ្តល់នូវកម្ចីដ៏ច្រើនឲ្យពួកហូឡង់ផងដែរ ដោយ

សារតែគាត់មានសំពៅផ្ទាល់ខ្លួននៅទីក្រុងបង់តេន និងផ្ទះធំល្មមមួយដែលអាចស្តុកនូវទំនិញរបស់ហូឡង់មួយចំនួនបាន (Meilink-Roelofsz ១៩៦២ : ២៥០–៥១) ។

មកទល់នឹងពាក់កណ្តាលសតវត្សរ៍ទី ១៧ ពេលដែលសម្ពាធពីសិទ្ធផ្តាច់មុខរបស់ពួកហូឡង់បានបង្កឲ្យមានបរិយាកាសកាន់តែយ៉ាប់យ៉ឺនខ្លាំងជាងមុនចំពោះឈ្មួញឯករាជ្យជនជាតិអាស៊ីផ្សេងៗ នោះយើងសម្គាល់ឃើញថាឈ្មួញលេចមុខមាត់ជាងគេក្នុងចំណោមនោះច្រើនជាជនជាតិម៉ូស្លីមមកពីឥណ្ឌាខាងជើង ដែលជារឿយៗ ពួកទទួលការការពារបានតាមរយៈចំណងទាក់ទងរបស់ពួកគេជាមួយនឹងព្រះអង្គម្ចាស់សំខាន់ៗរបស់ឥណ្ឌា ។ ការច្បាំងដណ្តើមកាន់កាប់បាន អុញ្ញារាតដោយពួកមុហ្គោល បានធ្វើឲ្យស៊ុរ៉ាត ក្លាយជាកំពង់ផែដ៏សំខាន់របស់ចក្រភពមុហ្គោល ហើយរាល់ឈ្មួញដែលមានទីតាំងនៅស៊ុរ៉ាត ដែលពីមុនគេហៅថាអ្នកគូចារ៉ាត់នោះ ឥឡូវនេះត្រូវគេចាត់ទុកជាមនុស្សរបស់អាណាចក្រមុហ្គោលមុហ្គោល ឬហៅថា «ម័រស៍ – Moors» ។ នៅអាចេនាឆ្នាំ ១៦៤២ ឈ្មួញឯកជនម្នាក់ក្នុងចំណោមឈ្មួញធំៗជាងគេ គឺជានិយោជិករបស់បុត្រាម្នាក់របស់អធិរាជចាហាន់ – ណាក់ខូនដា (Jahan—a Nakhoda) ដែលគេហៅថា «ម៉ារសាលី – Marsaly »ដែលជា «អ្នកមានសួនផ្កាដ៏ស្រស់ស្អាតមួយ» នៅក្នុងបរិវេណផ្ទះរបស់គាត់នាទីក្រុងបង់ដានៅអាចេ ។ តែទោះជាយ៉ាងនេះក្តី ប្រសិនបើគាត់មិនមានអ្នកមានឥទ្ធិពលខ្លាំងការពារគាត់ទេ នោះគាត់ប្រហែលជាត្រូវគេកាត់ប្រអប់ដៃមួយចំហៀងបាត់ទៅហើយ បើយោងទៅលើច្បាប់ដ៏តឹងរ៉ឹងរបស់អាចេ ដោយហេតុថាគាត់បានធ្វើឲ្យមនុស្សជាច្រើនរងរបួសពេលដែលគាត់ស្រវឹងមានចេវចាវនៅក្នុងទីផ្សារ (Sourij ១៦៤២: f ៥៨២ v-៥៨៣ v) ។ នៅក្នុងទីក្រុងបង់តេនមានពួក«ម័រស៍» ដែលមានទ្រព្យស្តុកស្តម្ភ និងកិត្តិសព្ទល្បីរន្ទឺ មួយចំនួន រួមមានឈ្មួញម្នាក់ដែលបានផ្តល់រង្វាន់ដល់គ្រូពេទ្យវះកាត់ជនជាតិអាល្លឺម៉ង់នូវទឹកប្រាក់ស្មើនឹងលុយកាក់ចំនួន ៣០០រៀល ដើម្បីជាសំណងទៅនឹងការដែលគាត់ជួយព្យាបាលជើងបាក់ជូនធូរឲ្យកូនប្រុសរបស់គាត់ (Fryke ១៦៩២ : ១៣២–៣៣, សូមមើលលេខ ២០) ។ សេដ្ឋីនៅហ្គោល ខូន បានបញ្ជូនតំណាងរបស់ខ្លួន (ជាធម្មតាជាជនជាតិពែរស៊ិន) តាមនាវាជំនួញតាមផ្លូវសមុទ្រទៅកាន់អាចេ ភូមា បង់តេន និង ម៉ាកាសសារ ។ នៅក្នុងប្រទេសសៀម ពួកម៉ូស្លីមឥណ្ឌា និងពែរស៊ិនមានឥទ្ធិពលឡើងដល់កំពូលនៅក្នុងទសវត្សរ៍ឆ្នាំ ១៦៧០ ។ អគ្គរាជទូតបារាំងមានការស្ញើចសរសើរយ៉ាងខ្លាំងចំពោះភាពល្អធើតឆាយរបស់គេហដ្ឋានមួយខ្នងក្នុងចំណោមគេហដ្ឋានជាច្រើនរបស់ពួកគេ ហើយដែលគេបានប្រគល់ឲ្យគាត់ស្នាក់នៅ នៅឆ្នាំ ១៦៨៥ បន្ទាប់ពីអ្នកទាំងនោះមានរឿងអាម៉ាស់ជាច្រើនមក (Aubin ១៩៨០ : ១២៤) ។

គេឃើញមានពត៌មានលម្អិតបន្ថែមទៀតអំពីការធ្វើពាណិជ្ជកម្មរបស់ឈ្មួញឯកជនធំជាងគេពីររូបនៅទីក្រុងម៉ាកាសសារនាពាក់កណ្តាលសតវត្សរ៍ទី ១៧ ។ ម្នាក់គឺជាជនជាតិព័រទុយហ្គាល់ឈ្មោះ ហ្វ្រង់ស៊ីស្កូ វីរ៉ា ឌឺ ហ្វីហ្ស៊ីរ៉េដូ (Francisco Vieira de Figueredo ១៦២៤–៦៧) និងម្នាក់ទៀតជាជនជាតិម៉ូស្លីមឥណ្ឌាឈ្មោះហៅស៊ីននេណា ខូចា (Howsenena Khoja) ដែលគេហៅថា «ម៉ាពូល – Mapule » ឬ (ចំពោះពួកអង់គ្លេស) ហៅ «ម៉ប់ ភ្លី – Mopley» (d ១៦៧៥) ។ វីរ៉ា បានបញ្ចូលនូវវិស័យការទូត និងជំនួញជាមួយគ្នាយ៉ាងប៉ិនប្រសប ដែលជាបែបបទនាសម័យកាលនោះ ហើយគាត់ដើរតួជាអគ្គរាជទូតនៅក្នុងដំណាក់កាលផ្សេងៗគ្នាជាច្រើន តាំងពីធ្វើជាតំណាងព្រះមហាក្សត្រព័រទុយហ្គាល់ និង អេស្ប៉ាញ អ្នកតំណាងព្រះមហាក្សត្រនៅម៉ាកាសសារ និងកម្ពុជា និងធ្វើអ្នកតំណាងឲ្យសេដ្ឋីនៅ Golconda ឈ្មោះមៀ ហ្សាំឡា ។ ក្នុងអំឡុងពេលនៃឆាកជីវិតរបស់គាត់គាត់បានរកស៊ីមានចំណេញ និងខាតបង់ជាច្រើនដោយជាទូទៅតាមរយៈការដាក់ហ៊ុនវិនិយោគផ្ទាល់របស់គាត់ទៅក្នុងជំនួញតាមផ្លូវសមុទ្រជាមួយរង្វង់

មេដឹកនាំនៅម៉ាកាសសារ ប៉ុន្តែក៏រង្គផ្សេងៗមួយចំនួនទៀត ។ ទង្វើនេះបានជួយការពារទំនិញរបស់គាត់ឲ្យរួចផុតពីការរឹបអូសយកពីសំណាក់ពួកហូឡង់ ឬសត្រូវផ្សេងៗទៀត (Boxer ១៩៦៧)។

ម៉ប់ ភ្វី ក៏ប្រហែលជាបានមកម៉ាកាសសារដំបូងក្នុងនាទីជាភ្នាក់ងាររបស់ មៀ ហ្សាំឡា តែមកទល់នឹងចុងទសវត្សរ៍ឆ្នាំ ១៦៥០ គាត់គឺជាដៃគូជំនួញដ៏សំខាន់របស់ពួកអង់គ្លេសនៅទីនោះ ដោយការទិញក្រណាត់ឥណ្ឌាពីពួកអង់គ្លេស និងលក់ទៅវិញនូវផ្កាក្លាំពូ និងស្នូកអណ្តើក (IOLG, ១០/១ : 14១,១៤៦-៤៨,១៧៧-៧៨) ។ គាត់ក៏មានសំពៅផ្ទាល់ខ្លួនដែលធ្វើដំណើរទទួលបានផលចំណេញជាច្រើនជារៀងរាល់ឆ្នាំពីម៉ាកាសសារទៅម៉ានីល ដោយចុះបញ្ជីក្នុងនាមរបស់ព្រះមហាក្សត្រដើម្បីឲ្យត្រូវទៅនឹងតម្រូវការរបស់ពួកអេស្ប៉ាញ ។ ពួកហូឡង់បានប៉ាន់ប្រមាណថា ទំនិញនៅក្នុងសំពៅនោះអាចមានតម្លៃរហូតដល់ ១០០.០០០ រៀល ឯណោះ (ស្មើនឹងប្រាក់ ២,៥ តោន) ដែលភាគច្រើនជាក្រណាត់ឥណ្ឌា ហើយពួកគេក៏បានប៉ាន់ប្រមាណដែរថា «ពួកម៉ាឡេបានបង់លុយឲ្យគាត់ដើម្បីបានដាក់ទំនិញរបស់ពួកគេនៅក្នុងសំពៅនោះផងដែរ ដូច្នេះហើយមនុស្សម្នានៅក្រុងម៉ាកាសាទាំងមូលមានការចាប់អារម្មណ៍ទៅលើសំពៅនេះ អ្នកខ្លះចាប់អារម្មណ៍ខ្លាំងហើយ អ្នកខ្លះចាប់អារម្មណ៍តិច ចំពោះប្រាក់ចំណេញដែលគេចំណេញបាននាពេលថ្មីៗនេះ ដែលលើសពី ៥០ ទៅ ៦០% ហើយពេលខ្លះចំណេញលើសពីនេះទៅទៀត» (Speelman ១៦៧០ A :១០៧) ។ នាពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៦៦០ នៅខណៈដែលពួកហូឡង់ធ្វើការរឹតបន្តឹងនៅជុំវិញក្រុងម៉ាកាសសារម៉ប់ ភ្វី ផ្លាស់ប្តូរគោលស្មោះត្រង់របស់គាត់យ៉ាងប៉ិនប្រសប់ ហើយប្រហែលជាធ្វើដំណើរតាមនាវាទៅកាន់ក្រុងម៉ានីលនៅក្នុងកំណត់ហេតុរបស់ពួកហូឡង់បាត់ទៅហើយ ប្រសិនបើគាត់មិនទាន់ស្លាប់នៅក្នុងឆ្នាំ ១៦៧៥ ទេនោះ (Coolhaas ១៩៦៨ : ៧៥៥; Gaastra ១៩៨២ : ៣០៧) ។

ឈ្មួញបរទេសអស់ទាំងនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងពួកមេដឹកនាំ ហើយពួកគេលេងល្បែងនយោបាយយ៉ាងប្រុងប្រយត្ន បើមិនដូច្នេះទេ ពួកគេមិនអាចធ្វើជំនួញបានយូរនោះទេ ។ ឈ្មួញខ្លះកម្រនឹងដើរតួឲ្យខុសពីឈ្មួញស្ថិតនៅក្នុងប្រភេទទីពីរណាស់ ដែលឈ្មួញប្រភេទទីពីរនេះគឺជាឈ្មួញពាក់កណ្តាលឈ្មួញ ពាក់កណ្តាលមន្ត្រី ដែលធ្វើការសម្របសម្រួលរវាងព្រះរាជវាំងនិងទីផ្សារ ។ តួនាទីខ្ពស់របស់ឈ្មួញប្រភេទនេះគឺតួនាទីរបស់ ស៊ីយ៉ាបាន់ដា (មកពីភាសាពែរស៊ែន សំដៅលើមេគ្រប់គ្រងកំពង់ផែ) ដែលជាតំណែងដែលមេដឹកនាំម៉ាឡេតែងតាំងជាពិសេសដល់ឈ្មួញបរទេសឈានមុខគេ ដើម្បីធានាថាមានការប្រតិបត្តិតាមពិធីការ ហើយឈ្មួញបរទេសទាំងឡាយដែលធ្វើដំណើរមកដល់កំពង់ផែតាមផ្លូវសមុទ្រត្រូវតែបង់ពន្ធ ។ ក្នុងអំឡុងពេលដែលទីក្រុងម៉ាឡាការីកចម្រើនជឿនលឿនដល់កំពូលគេឃើញមានស៊ីយ៉ាបាន់ដា ៤ នាក់ ។ ស៊ីយ៉ាបាន់ដា ម្នាក់តំណាងឲ្យឈ្មួញហ្គុចារ៉ាទី ម្នាក់ទៀតតំណាងឲ្យឈ្មួញទាំងអស់ដែលធ្វើដំណើរមកពីទិសខាងលិច (មកពីឥណ្ឌា តែក៏មានខ្លះមកពីទីក្រុងពេគូ និងប៉ាស៊ែផងដែរ) ម្នាក់ទីបីតំណាងឲ្យឈ្មួញនិយាយភាសាម៉ាឡេទាំងឡាយណាដែលធ្វើដំណើរមកពីទិសខាងកើត (រួមមានជ្វា ទីក្រុងម៉ាលុគុ ស៊ូម៉ាត្រាខាងត្បូង ប៊ីណេអូ និងហ្វីលីពីន) រីឯម្នាក់ចុងក្រោយតំណាងឲ្យឈ្មួញជនជាតិអាស៊ីខាងកើត (ចិន និងរីយុក្យុ) ។



រូបភាពទី ២០
រូបអ្នកដឹកនាំ បាតង់គូរដោយអ្នកជំនួញហូឡង់ឆ្នាំ ១៦៧៣

*គំរូនៅទីក្រុងម៉ាឡាកាបែបនេះក៏បានជះឥទ្ធិពលទៅដល់កន្លែងផ្សេងៗផងដែរ ៗ ទោះបីជាកំពង់ផែដទៃទៀតត្រូវការតែស៊ីយ៉ាបង់ដាម្នាក់ បុពីរនាក់ក៏ដោយ ក៏ប្រទេសកម្ពុជានៅដើមសតវត្សរ៍ទី ១៧ មានស៊ីយ៉ាបង់ដាដល់ទៅ៥នាក់ឯណោះ ដោយក្នុងនោះពីរនាក់តំណាងឲ្យឈ្មួញចិនម្នាក់តំណាងឲ្យឈ្មួញព័រទុយហ្គាល់ម្នាក់ទៀតតំណាងឲ្យឈ្មួញជប៉ុន និងម្នាក់ផ្សេងទៀតតំណាងឲ្យឈ្មួញនិយាយភាសាម៉ាឡេ* (Gaelen ១៦៣៦ : ៦៣)ៗ *នៅប្រមាណឆ្នាំ១៥១២ជនជាតិចាទីយ៉ា ហិណ្ឌូគឺជាស៊ីយ៉ាបាន់ដា នៅទីក្រុងប៉ាសៃ* (Barros ១៥៦៣ III, i: ២៧២)*ហើយមួយសតវត្សរ៍ក្រោយមកជនជាតិឥណ្ឌាខាងត្បូងម្នាក់ក៏បានកាន់តំណែងនេះនៅទីក្រុងបង់តេនជនជាតិមូស្លីមចិនម្នាក់ក៏បានប្ដូរមករកតួនាទីនេះនៅហ្សំប៊ី ហ្សាប៉ា៉ា និងហ្សាក់តាន់ ហើយជនជាតិអុញ្ញាពាតិម្នាក់ក៏ធ្វើដូច្នេះដែរនៅហ៊ីតុ ក្នុងក្រុងអាំបុន* (Jourdain ១៦១៧:២៥៣; Scott ១៦០៦ : ១៧៤; Meilink-Roelofsz ១៩៦២ : ២៤០, ២៨៣,២៨៦,២៨៩) ៗ តំណែង

របស់ស៊ីយ៉ាបង់ដា គឺជាមុខងារបែបយុទ្ធសាស្ត្រ ដែលម្យ៉ាងគេផ្តល់ឲ្យសម្រាប់ភាពជាដៃគូរដែលអាចផ្តល់ផលចំណេញច្រើនជាមួយនឹងមេដឹកនាំ ហើយម្យ៉ាងទៀត គឺសម្រាប់ជនបរទេសទាំងឡាយណា ដែលត្រូវការការគាំទ្រជាផ្លូវការ ។ ពង្សាវតាររបស់ម៉ាឡេបានលើកសរសើរអំពីធនធានរបស់ស៊ីយ៉ាបង់ដា ជាតិឥណ្ឌាខាងត្បូងម្នាក់ឈ្មោះរ៉ាចា មិនដាលៀថា៖ «មានទ្រព្យសម្បត្តិសម្បូរហូរហៀរក្រៃលែង ដែលនៅគ្រានោះគ្មាននរណាម្នាក់មានទ្រព្យសម្បត្តិស្មើគាត់ទេនៅក្នុងក្រុងម៉ាឡាកា» (Sejarah Melayu ១៦១២ : ១៨៣)។ ពួកហូឡង់បាននិយាយថា ស៊ីយ៉ាបង់ដាជាតិឥណ្ឌានៅទីក្រុងបង់តេនកាលធ្វើដំណើរមកដល់ទីក្រុងនេះដំបូង «គ្មានអ្វីទាល់តែសោះ ហេតុដូចនេះហើយ គាត់ប្រកបការងាររកំប៉ិកកំប៉ុកផ្សេងៗដើម្បីរស់» តែនៅទីបំផុត គាត់បានក្លាយទៅជាអ្នកមានអស្ចារ្យមួយរូប (លូដូវីស្គស៍ ១៥៩៨ : ៧៥) ។

មុខងារខ្ពស់ៗជាងនេះ មានដូចជាតំណែងអភិបាលកំពង់ផែ ដែលមិនមែនជារាជធានី ជារឿយៗបានទៅឈ្មួញសហគ្រាសផងដែរ ។ ជនជាតិអុញ្ញាពាតិម្នាក់បានគ្រប់គ្រងកំពង់ផែហ្សាប៉ារ៉ា ឲ្យទីក្រុងម៉ាតារ៉ាម នៅដើមសតវត្សរ៍ទី ១៧ រីឯជនជាតិមូស្លីមឥណ្ឌា និងសូម្បីតែជនជាតិអង់គ្លេសម្នាក់បានគ្រប់គ្រងកំពង់ផែតេណាស់សឺរីមឲ្យប្រទេសសៀម ។ នៅក្នុងប្រទេសសៀមផ្ទាល់ មុខតំណែងពីរទាក់ទងទៅនឹងជំនួញបរទេស គឺ ក្រាឡាហោម និងម៉ាហាថៃ គឺស្ថិតនៅក្រោមការគ្រប់គ្រងដំបូងឡើយដោយជនជាតិមូស្លីមបរទេស ហើយក្រោយមកដោយជនជាតិអ៊ីរ៉ុបនៅក្នុងរជ្ជកាលស្តេចប្រាសាទ ថង (Prasat Thong) និងណារ៉ៃ (Wyatt ១៩៨២:១០៨-០៩) ។ នៅប៉ាតានី ជនជាតិម៉ាឡេដែលមានដើមកំណើតចិនម្នាក់ឈ្មោះដាតុ ស៊ីរីណារ៉ា មានឥទ្ធិពលដ៏អស្ចារ្យទៅលើកិច្ចការពាណិជ្ជកម្មរបស់រដ្ឋស៊ុលតង់មួយនេះ (Warwijck ១៦០៤ : ៤៣) ។ ការរីកចម្រើនយ៉ាងរហ័សខុសប្លែកពីធម្មតានៃបណ្តាទីក្រុងនៅក្នុងតំបន់ បានផ្តល់ឱកាសឥតព្រំដែនដល់ជនបរទេសដែលមានជំនាញសហគ្រាស និងសម្បូរធនធាន ដែលបណ្តោយវាសនារបស់ខ្លួនទៅជាមួយក្រុមវណ្ណៈកាន់អំណាច និងបានសម្របខ្លួនរស់នៅជាមួយពួកគេយ៉ាងស្រួល ។ មេដឹកនាំជាច្រើនរូបអាចស្វែងរកដានដើមកំណើតរបស់ខ្លួនផ្ទាល់ត្រលប់ទៅតែប៉ុន្មានជំនាន់មុនប៉ុណ្ណោះ ជាពិសេសគឺទៅ និងឈ្មួញចិនដែលបានអភិវឌ្ឍរដ្ឋកំពង់ផែមួយចំនួន ដូចជា ប៉ាឡេមបាំង ដេម៉ាក់ និងហ្គ្រេស៊ីក ជាដើម កាលពីដើមសតវត្សរ៍ទី ១៥ ។ តំបន់គ្រប់គ្រងក្នុងរយៈពេលខ្លីមួយរបស់អ្នកផ្សងព្រេងជាតិព័រទុយហ្គាល់ឈ្មោះ ហ្វីលីប ឌឺប្រ៊ីតូ នៅឯកំពង់ផែស៊ីរៀមនៃប្រទេសភូមានារវាងឆ្នាំ ១៦០០-១៤ អាចត្រូវគេចាត់ទុកថាជាករណីបន្ថែមមួយទៀតរបស់អ្នកមកពីខាងក្រៅដែលមានចិត្តក្លាហានមុះមុតដែលបានយកការរីកចម្រើនពាណិជ្ជកម្មជាឈ្នាន់ឈានទៅរកអំណាចនាដំណាក់កាលបើកចំហមិនធម្មតាមួយ ។

ឈ្មួញដែលមានដើមកំណើតបរទេសបានបន្តឈានឡើងរហូតដល់តំណែងថ្នាក់ខ្ពស់ៗបំផុត សូម្បីតែនៅក្នុងរដ្ឋដែលបង្កើតយូរយារហើយក៏ដោយ ។ ជាឧទាហរណ៍ ស្តេចស៊ុលតង់ដ៏អស្ចារ្យជាងគេរបស់ម៉ាឡាកាឈ្មោះ Mansur (១៤៥៩-៧៧) បានបន្តរឹងចំណងទំនាក់ទំនងរបស់បុព្វបុរសរបស់ខ្លួនជាមួយនឹងប្រទេសចិន និងជ្វា យ៉ាងជិតស្និទ្ធធ្វើឲ្យមានទាំងរាជាភិសេក និងលំហូរចូលនៃជនជាតិចិន និងជ្វាដែលមានឥទ្ធិពល (Sejarah Melayu ១៦១២ : ១០៤-១០, ១១៧-១៩) ។ គាត់ក៏បានតែងតាំង «ជនជាតិក្លីងម្នាក់ដែលមិនមានជំនឿទៅលើសាសនាអ្វីទាំងអស់» ដែលប្រហែលជាជនហេរញ្ញិក ចាទីយ៉ា មួយរូបទៀត ឲ្យជួយរៀបចំចាត់ចែងហិរញ្ញវត្ថុផ្ទាល់របស់គាត់ ។ យោងទៅលើការរៀបរាប់របស់ពួកព័រទុយហ្គាល់បន្ទាប់ពីបានក្លាយជាជនមូស្លីមមក ជនជាតិឥណ្ឌារូបនេះបានក្លាយទៅជាបុព្វបុរសនៃរជ្ជកាលបង់ដាហារ៉ា (Bendahara) ដ៏អស្ចារ្យ ដែលបានផ្តល់ឲ្យមានប្រធានរតនាគារជាបន្តបន្ទាប់នៅក្រុង

ម៉ាឡាកា (Pires ១៥១៥: ២៤៩) ។ ទំនោរផ្នែកពាណិជ្ជកម្មរបស់ក្រុមគ្រួសារនេះបានបន្តកាន់តំណែង ហើយចៅប្រុសរបស់ជនជាតិហិណ្ឌូរូបនេះ គឺជាវីរបុរសរបស់ស៊ីចារ៉ា មិឡេយុ (Sejarah Melayu) ដែលមានព្រះនាមថា បន់ដាហារ៉ា ស្រ៊ី ម៉ាហារ៉ាចា (Bendahara Sri Maharaja) ។ ព្រះអង្គមិនត្រឹមតែជាអ្នកអភិបាលម្នាក់ដ៏អស្ចារ្យទទួលខុសត្រូវចំពោះការរីកចម្រើនរបស់ទីក្រុងម៉ាឡាកាប៉ុណ្ណោះទេតែថែមទាំងជាមនុស្សម្នាក់ដែល«ប្រកាន់នូវយុត្តិធម៌ និងមានសេចក្តីមេត្តាករុណាខ្ពស់ និងឈ្លាសវៃនៅក្នុងការគ្រប់គ្រងឈ្នួញបរទេសទៀតផង» ។ ជាងនេះទៅទៀត ព្រះអង្គជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងសម្បូរមាសជាច្រើនសន្ធឹកសន្ធាប់រហូតដល់ព្រះអង្គអនុញ្ញាតឲ្យបុត្ររបស់ទ្រង់លេងមាសទាំងនេះ៖«បន់ដាហារ៉ា ស្រ៊ី ម៉ាហារ៉ាចា តែងតែគិតរកប្រាក់ចំណេញ ហើយមិនដែលបរាជ័យម្តងណាទោះទេ» (Sejarah Melayu ១៦១២: ១៥៩-៦០, ១៨៤)។

ស្តេចមែនសួរ ក៏បានលើកតម្កើងទាសករមិនមែនជាជនមូស្លីមរបស់ព្រះអង្គម្នាក់ មកពីប៉ាឡេមបាំងហើយក្រោយមកទាសកររូបនេះមានអំណាចឥទ្ធិពលយ៉ាងខ្លាំងក្លារហូតដល់គាត់បានបង្កើតរាជវង្សដ៏អស្ចារ្យមួយទៀតនៅម៉ាឡាកាផ្សេងទៀត គឺរាជវង្សឡាក់ សាម៉ាណា (Laksamana) (Pires ១៥១៥: ២៤៩) ។ ទោះបីជារដ្ឋម៉ាឡេដូចជាម៉ាឡាកាជាដើម ជារដ្ឋដែលមានមនុស្សម្នារួមរស់នៅឡូកឡំគ្នាយ៉ាងស្រួល ដែលអ្នកមកពីស្រុកក្រៅអាចកសាងអំណាចឥទ្ធិពលយ៉ាងឆាប់រហ័សក៏ដោយ ក៏គេឃើញមានបាតុភូតស្រដៀងគ្នានេះកើតឡើងនៅតាមគ្រប់បណ្តារដ្ឋដែលពឹងផ្អែកលើជំនួញផងដែរ ។ សូម្បីតែនៅក្នុងប្រទេសសៀម (David Wyatt ១៩៨៦) បានបង្ហាញឲ្យឃើញថា ចាប់ពីប្រហែលឆ្នាំ ១៦១០ រហូតដល់ការដួលរលំក្រុងអយុធ្យា ក្រុមគ្រួសារមន្ត្រីមានអំណាចជាងគេចំនួន ៤ សុទ្ធតែមានដើមកំណើតមកពីជនបរទេសដែលមានសមត្ថភាពដែលត្រូវគេបញ្ចូលទៅក្នុងវិស័យពាណិជ្ជកម្មរបស់រដ្ឋាភិបាលនាសតវត្សរ៍ទី ១៧ ។ ក្រុមគ្រួសារទាំងនោះរួមមានចេញមកពីជនជាតិ ពែរស៊ិន ព្រាហ្មណ៍ ចិន និងអ្នកមានដើមកំណើតជនជាតិមន ។

គាពសម្លៀមបែបក្រអឺតក្រទមរបស់វណ្ណៈអភិជនក្នុងស្រុកអាចធ្វើឲ្យពួកអភិជនទាំងនោះមានចំណាប់អារម្មណ៍ និង ដឹងពីឋានៈរបស់ខ្លួនយ៉ាងច្បាស់ ដែលធ្វើឲ្យអ្នកមកពីខាងក្រៅមិនមានលទ្ធភាពចូលមកបាន ។ នៅអាចេ និងចូហូរ ក្រុមពួកអភិជនបានធ្វើឲ្យខ្លួនពួកគេខុសពីប្រជាជនសាមញ្ញតាមរយៈការបណ្តុះក្រចកមេដៃ និងកូនដៃឲ្យវែងខុសប្លែកពីធម្មតា ដើម្បី «បង្ហាញថាពួកគេមិនដែលប្រើដៃរបស់ខ្លួនទៅប្រឡូកប្រឡាក់ជាមួយនឹងការងារនោះទេ» (Martin ១៦០៤: ៤០, cf. Nieuhoff ១៦៨២: ១៨១) ។ ដូចគ្នានេះដែរ ការពិតបញ្ជាក់ថា ពួកអភិជននៅម៉ាកាសសារបានកាត់ក្រចកដៃរបស់ខ្លួនយ៉ាងស្អាត «ពីព្រោះតែពួកគេគិតថាខ្មោចព្រាយបិសាចអាចលាក់ខ្លួននៅក្នុងក្រចកដៃទាំងនោះពេលដែលក្រចកដុះវែង» (Gervaise ១៧០១: ១៥៥)ហើយការណ៍នេះបានបង្ហាញថា ទស្សនៈសីលធម៌អ៊ីស្លាមថ្មីបានប្រឆាំងយ៉ាងដាច់អហង្កាចំពោះគំនិតចាស់នេះ ។ ពួកឥស្សរជនថៃ ម៉ាឡេ ជ្វា និងម៉ាកាសសារធ្វើឲ្យពួកបស្ចិមប្រទេសមានការភ្ញាក់ផ្អើលចំពោះបរិវារហែហមជាច្រើនដែលពួកគេដួលមក ចំពោះអារម្មណ៍អួតអាងអំពីមុខងារខ្ពង់ខ្ពស់របស់ពួកគេ និងចំពោះការបដិសេធមិនធ្វើការងារប្រើកម្លាំងរបស់ពួកគេ (du Jarric ១៦០៨: ៦៣០) ។ «នៅទីក្រុងម៉ាកាសសារ ពួកវណ្ណៈអភិជនមានភាពអំនួតជាងនៅកន្លែងណាៗទាំងអស់នៅលើផែនដីនេះ» (Gervaise ១៧០១: ៨៧, cf. Barros ១៥៦3 II, ii: ២៤; Scott ១៦០៦: ១៧០-៧១) ។

ប៉ុន្តែផ្ទុយពីនេះវិញ ការផ្តោតខ្លាំងទៅលើឋានៈនេះស្របគ្នាទៅនឹងការប្រមូលផ្តុំនៃវណ្ណៈអភិជនក្នុងកម្រិតដ៏ខ្ពស់នៅក្នុងជួរនៃឋានៈ ។ បើនិយាយឲ្យចំទៅ ដោយសារតែមិនមានការបែងចែកវណ្ណៈតឹងរឹង និងដោយសារ

*តែពួកអភិជនភាគច្រើនមានដើមកំណើតជាអ្នកជំនួញនោះ បានជាគេសំញែងឋានៈឡើងជាសាធារណៈជារៀង រហូតមកនោះ ។ ការអធិប្បាយជាច្រើនអំពីដំណើរការរបស់ឋានានុក្រមសង្គមនៅក្នុងទីក្រុងម៉ាកាសសារ និងអាចេ បានបង្ហាញឲ្យឃើញថាអ្នកដែលស្ថិតនៅលំដាប់ដាន់ក្រោមបានខំប្រឹងស្វះស្វែងដើម្បីអាចទិញបានទាសករ និងទទួល បាននូវឋានៈជាអភិជន ដែលធ្វើឲ្យពួកគេមិនចាំបាច់ធ្វើការងារប្រើកម្លាំងទៀត* (Gervaise *១៧០១ : ៧១–៧២,* Reid *១៩៨៣ : ១៦៦–៦៧) ។ ជនបរទេស (ប្រហែលជាពិសេសជាងគេផងក៏មិនដឹង) ក៏ខំប្រឹងប្រែងឆ្លងកាត់នូវឧបសគ្គនេះ ដែរ ។ ជនជាតិចិននៅទីក្រុងបង់តេនប្រឹងប្រែងធ្វើការងារគ្រប់ប្រភេទទាំងអស់ដើម្បីរកលុយ តែពេលដែលពួក គេ «ក្លាយជាជ្វា» ដោយការកាន់សាសនាអ៊ីស្លាម ការកាត់សក់ និងការប្តូរនូវសម្លៀកបំពាក់របស់ពួកគេចេញពួកគេ «មានអំនួត និងភាពក្រអឺតក្រទមដូចទៅនឹងជនជាតិជ្វាដែរ»* (Scott *១៦០៦ : ១៧៤) ។*

*ទោះបីជាអ្នកកត់ត្រាព្រះរាជពង្សាវតារអាស៊ីអាគ្នេយ៍មានការឈឺចាប់ក្នុងការបង្ហាញអំពីភាពក្រអឺតក្រទមនៃ បណ្តាមេដឹកនាំដែលមានអំណាចក៏ដោយ ក៏នេះគ្រាន់តែឆ្លុះបញ្ចាំងពីមនោគមវិជ្ជាតែប៉ុណ្ណោះ មិនមែនពីសង្គមវិជ្ជា នោះទេ ហើយភាគច្រើនវាបង្ហាញឲ្យឃើញពីមនោគមវិជ្ជានាសម័យបន្ទាប់ ពេលដែលគេសរសេរពង្សាវតារដែល មាននៅសេសសល់ ។ ជនជាតិព័រទុយហ្គាល់ម្នាក់ ដែលបានសរសេរនៅដំណាក់កាលក្រោយៗទៀត និងសម័យដើម ដំបូងនៃពូជពង្សមេដឹកនាំនៅប្រទេសជ្វា បានបង្ហាញថាគេដឹងថាមេដឹកនាំភាគច្រើនមានប្រភពចេញមកពីអ្នកឋានៈ ទាប ឬក៏អ្នកជំនួញ ។ នាពេលនោះការមានខ្សែស្រឡាយដូនតាជនជាតិចិនគឺមិនមែនជាអ្វីដែលវរជនជ្វាព្យាយាម លាក់លាមនោះទេ* (Barros*១៥៦៣* II, ix*:៣៥២;* Reid *១៩៩២:១៩៦–៩៧) ។ ថមមេ ពីរេស៍ បានផ្តល់នូវឧទាហរណ៍អំពី ការរីកឡូតឿនលឿនយ៉ាងរហ័សនៅប្រទេសជ្វាក៏ដូចជានៅម៉ាឡាកាផងដែរ នៅសម័យគាត់ ទោះបីជាគាត់អះអាង ថាភាពក្រអឺតក្រទមរបស់ជនជាតិជ្វាមានលក្ខណៈលេចធ្លោជាងគេក៏ដោយ ។ ក្នុងនោះ គឺជាមេដឹកនាំនៅ ហ្សាប៉ារ៉ា ឈ្មោះប៉ាទី យូដុស៖*

> ជនជាតិជ្វានិយាយអំពី ខុនណាង ព្រោះពួកគេនិយាយថាគាត់គឺជាអ្នកចំបាំងដ៏ខ្លាំងពូកែនៅប្រទេសជ្វា និងជាមនុស្ស មានការប្រុងប្រយត្ននខ្ជាប់ជានិច្ច. . . ជីតារបស់គាត់គឺជាកម្មករធ្វើការនៅលើកោះ ឡូវេ (ភាគខាងលិចកោះ ប៊ីណេអូ) ហើយគាត់បានធ្វើដំណើរទៅកាន់ទីក្រុងម៉ាឡាកាក្នុងឋានៈតូចទាប និងទ្រព្យសម្បត្តិតិចតួចប៉ុណ្ណោះ ។ គាត់បានរៀបការនៅម៉ាឡាកា និងមានកូនប្រុសម្នាក់ដែលជាឪពុករបស់ប៉ាតេ អូនុ ។ ហើយនៅម៉ាឡាកានេះគាត់ ក៏បានបន្តរកលុយ និងធ្វើជំនួញនៅប្រទេសជ្វា ហើយកាលពីប្រហែល ៤០ ទៅ ៤៥ ឆ្នាំមុន គាត់បានប្រើឧបាយកល សម្លាប់ ផាតិហរបស់ក្រុងហ្សាប៉ារ៉ា ដែលជាទីក្រុងទន់ខ្សោយមួយ និងមិនមានធនធានច្រើនទេ. . .បន្ទាប់ពីនោះមក និងដោយសារតែឧបាយកលវ័យឆ្លាតរបស់គាត់គាត់បានធ្វើឲ្យទីក្រុងនេះមានមនុស្សជាច្រើនរស់នៅ. . .គាត់គឺជា បុរសដ៏អង់អាចក្លាហានបំផុតដែលអាចវាយដណ្តើមយកកោះប៉ង់កា ឲ្យស្ថិតនៅក្រោមអជ្ញារបស់គាត់ និងបានយក កោះតង់ហ្យុងពុរ៉ា និងកោះឡូវេ(ភាគខាងលិចកោះប៊ីណេអូ) ហើយរួមទាំងកោះផ្សេងៗទៀតផង (Pires ១៥១៥ : ១៨៧) ។

*តម្រូវការដើម្បីបង្ហាញសញ្ញាសម្គាល់នៃឋានៈខ្ពស់ខ្ពង់ដូចមានរៀបរាប់ជាហូហែរខាងក្រោមនេះ គឺជាលក្ខណៈ ដែលមានរួចមកហើយរបស់អាស៊ីអាគ្នេយ៍នៅក្នុងសម័យពាណិជ្ជកម្ម តែក្រោយមកគេច្នៃលក្ខណៈទាំងនេះ ក្នុងគោលបំណងដើម្បីឲ្យវាលុបបំបាត់ ឬលាក់កំបាំងនូវប្រភពដើមដែលជារឿយៗជាឋានៈទាប ។ វណ្ណៈអភិជននៅ*

អាស៊ីអាគ្នេយ៍មិនបានក្លាយជាវណ្ណៈពិសេសផ្ដាច់មុខតែឯងនោះទេរហូតដល់សម័យអាណានិគម នៅពេលនោះពូជពង្សខ្ពង់ខ្ពស់គឺជាសន្ទឹកបៀរដែលអាស៊ីអាគ្នេយ៍នៅសេសសល់តែមួយគត់ដើម្បីលេង ។

ហើយវាក៏មិនមែនជាការងាយស្រួលដែរក្នុងការគូសនូវបន្ទាត់កំណត់រវាងវណ្ណៈអភិជនក្នុងស្រុកដែលមានលក្ខណៈអសកម្ម និងក្រុមអូរ៉ង់កាយ៉ាអន្តរជាតិដែលមានលក្ខណៈសកម្មខាងពាណិជ្ជកម្ម ។ ជាការពិតនៅក្នុងអំឡុងសតវត្សរ៍ទី ១៧ គេឃើញព្រះរាជារាំងភាគច្រើនចាត់ទុកពាណិជ្ជកម្មថាគ្មានប្រយោជន៍អ្វីទាំងអស់ លើកលែងតែសម្រាប់ប្រភពចំណូលនៃការធ្វើអំណោយ ក៏ដូចជា បង់ពន្ធតែប៉ុណ្ណោះ ។ មេដឹកនាំវៀតណាមខាងជើងដែលប្រកាន់យកមនោគមវិជ្ជាខុងជឺ ជារឿយៗ មានចំណាប់អារម្មណ៍បែបនេះដូចដែលព្រះរាជាភូមានៅអាវ៉ាធ្លាប់មានដែរ ។ ដោយហេតុនេះហើយ បានជាពួកគេមានលក្ខណៈស៊ាំទៅនឹងអ្នកដែលមានឈាមជ័រថ្មីធ្វើជំនួញនៅក្នុងព្រះរាជវាំង ។ ផ្ទុយមកវិញ ដោយសារតែឱកាស និងការដាក់សម្ពាធនាសម័យកាលនោះក្រុមមេដឹកនាំខ្លះដែលបន្តនូវកេរដំណែលប្រពៃណីពួកអភិជន ខាងចំបាំង និងការប្រកបរបរកសិកម្មបានផ្លាស់ប្ដូរទៅរកវិស័យពាណិជ្ជកម្ម ។ ពួកវណ្ណៈអភិជនជាច្រើននៅក្រុងម៉ាកាសសារ និងបង់តេន បានប្ដូរមកបែបនេះនៅពាក់កណ្ដាលដំបូងនៃសតវត្សរ៍ទី ១៧ ដោយបានដើរតួនាទីកាន់តែសកម្មជាងមុននៅក្នុងការវិនិយោគផ្នែកពាណិជ្ជកម្ម ការស្ដាបនានាវា និងសូម្បីតែនៅក្នុងការធ្វើជំនួញតាមផ្លូវសមុទ្រ ។ នៅមុនពេលដែលក្រុងទុយបាន (Tuban)ដ៏រុងរឿងអស្ចារ្យរងបំផ្លិចបំផ្លាញពីសំណាក់ស្ដេចអាហ្គុង (Agung) នាឆ្នាំ ១៦១៩ កំណត់ប្រវត្តិរបស់ពួកហូឡង់អំពីទីក្រុងនេះបានបញ្ជាក់យ៉ាងច្បាស់ថា ពួកអភិជនជ្វាក្នុងស្រុកផ្ទាល់ដែលជាអ្នកបានបញ្ជូនសំពៅរបស់ពួកគេទៅកាន់ទីក្រុងបង់ដា តឺរណាត់ និងប្រទេសហ្វីលីពីន ពួកគេគឺជាក្រុមតែមួយដែលពាក់ព័ន្ធនឹងការប្រកួតកីឡាផ្សេងៗប្រចាំសប្ដាហ៍ និង មិនដែលធ្វើដំណើរចេញក្រៅដោយមិនមានបរិវារបួនដប់នាក់ហែហមតាមជាមួយទេ (Tweede Boeck ១៦០១ : ៣៦-៣៧) ។ឈ្មួញល្បីល្បាញម្នាក់នៅទីផ្សារធំនាក្រុងប៉ាតានី ដែលកប៉ាល់គាត់ត្រូវពួកហូឡង់នៅក្រុងម៉ាឡាការឹបអូសយកនោះមានឈ្មោះថាវ៉ាចា គេឡាន់តង់ ដែលជាមេដឹកនាំនៃសាមន្តរដ្ឋក្បែរៗនោះ (Warwijck ១៦០៤ : ៨២; Jansz ១៦១៦:២១៧) ។

ក្នុងការវាយតម្លៃទៅលើតួនាទីរបស់អូរ៉ង់កាយ៉ា គេដាច់ខាតត្រូវតែយកចិត្តទុកដាក់ចំពោះភាពក្លៀវក្លាដ៏សម្បើមនាសម័យកាលនោះ ។ ជារឿយៗ ឈ្មួញបរទេសបានចូលរួមជាមួយវណ្ណៈអភិជនក្នុងស្រុក ។ រីឯរាជវង្សានុវង្សដើមក្នុងស្រុកមានចំណាប់អារម្មណ៍ធ្វើដំណើរទៅកាន់ទីក្រុងកំពង់ផែធំៗ ឬក៏ ត្រូវបានព្រះរាជាដែលមានព្រះហឫទ័យប្រណែនបង្ខំឲ្យទៅទីនោះ ហើយនៅទីនោះ ពួកគេបានប្រឡូកក្នុងវិស័យពាណិជ្ជកម្ម ។ ហើយសម្ព័ន្ធភាពរវាងទ្រព្យសម្បត្តិ និងអំណាចបុណ្យសក្តិក៏ត្រូវគេបង្កើតឡើងជាហូរហែ ។ នៅពេលដែលវិស័យពាណិជ្ជកម្មបានចាប់ផ្ដើមថមថយឥទ្ធិពលរបស់ខ្លួននៅពាក់កណ្ដាលទីពីរនៃសតវត្សរ៍ទី ១៧ មកអូរ៉ង់កាយ៉ាដែលធ្លាប់មានរឹសគល់ក្នុងវិស័យពាណិជ្ជកម្ម ជារឿយៗបានក្លាយជាពួកអភិជនដែលមានសិទ្ធិកាន់កាប់ដីធ្លី និងមនុស្ស (សូមមើលជំពូកទី ៥) ។ នៅក្នុងការផ្លាស់ប្ដូរបែបនេះ ជាទូទៅតុល្យភាពរវាងមេដឹកនាំ និងពួកអូរ៉ង់កាយ៉ាជាក្រុម គឺតែងតែមានលក្ខណៈធ្ងន់ ។ ជាធម្មតា ដំណាក់កាលនៃការរីកចម្រើនផ្នែកពាណិជ្ជកម្មយ៉ាងរហ័សកើតឡើងស្របគ្នានឹងការគ្រប់គ្រងដោយពួកអូរ៉ង់កាយ៉ាមួយក្ដាប់តូចដែលមានដើមកំណើតមួយផ្នែកជាជនបរទេស តែក្រុមបែបនេះមិនបានទទួលការសប់ព្រះហឫទ័យពីព្រះរាជាមានអំណាច ដែលអាចការពារអ្នកទាំងនោះនៅក្នុងពិភពដែលមានភាពសាហាវបាន ។ កម្ចាំងបដិបផ្សេងៗក៏បានកើតឡើងដោយសារស្ថានការណ៍នាសម័យកាលនោះ ហើយគេមិនឃើញមានជំណោះស្រាយជម្លោះសមរម្យណាមួយរវាងកម្លាំងបដិបទាំងនោះទេ ។ យើងនឹងធ្វើការពិភាក្សាចំណុចនេះលម្អិត

*បន្ថែមទៀតនៅក្នុងជំពូកទី ៤ ។*

## ក្រុមភាគតិចនៅក្នុងវិស័យពាណិជ្ជកម្ម និងជាតិពន្ធ

*ដូចដែលមេលីង រ៉ូលូហស់ (Meilink-Roelofsz – ១៩៦២ : ៩) ក៏ដូចជាអ្នកដទៃទៀតផងដែរ ដែលបានលើកឡើង យើងមិនគួរលើកសារៈសំខាន់របស់ឈ្មួញបរទេសធ្វើជំនួញនៅតាមរាល់កំពង់ផែនៅអាស៊ីអាគ្នេយ៍មកបកស្រាយថាមានន័យថាគ្មានវត្តមានរបស់ «ក្រុមមនុស្សថ្នាក់កណ្ដាលក្នុងស្រុកដែលប្រកបរបរជំនួញផ្ទាល់ខ្លួននោះទេ» ។ ដូចដែលយើងបានឃើញរួចមកហើយ ទំនិញជុំរបស់អាស៊ីអាគ្នេយ៍ គឺដឹកដោយនាវាអាស៊ីអាគ្នេយ៍ និងប្រើប្រាស់នូវធនធាននៅអាស៊ីអាគ្នេយ៍ផ្ទាល់ ។ បរិមាណប្រជាជនដ៏ច្រើនបានប្រកបរបររកស៊ីតាមធ្វើជាអ្នកដឹកជញ្ជូនទំនិញតាមនាវា នាវិក និងអ្នកទិញលក់ដំណាំពាណិជ្ជកម្ម និងក្រុណាត់បរទេស ។ គេអាចចាត់ទុកពួកអូរ៉ង់កាយ៉ាថាជាវណ្ណៈដ៏មានអំណាចដែលមានមូលដ្ឋានដ៏រឹងមាំក្នុងវិស័យជំនួញ និងមានផលប្រយោជន៍ប៉ះពាល់ជាមួយ និងផលប្រយោជន៍របស់ស្ដេច ។ ប្រសិនបើពួកគេមិនបានបង្កើតជា «វណ្ណៈគហបតីដ៏ពិតប្រាកដ» មួយ ដែលមានឯករាជភាពពីក្រុមមេដឹកនាំទេនោះ ម៉្លោះបណ្ដាមេដឹកនាំនៅបណ្ដាប្រទេសនៅអឺរ៉ុបជាច្រើននាពេលនោះ ក៏ប្រហែលជាត្រូវគេបដិសេធដែរនោះដែរហើយ (ក្រុមឈ្មួញឥណ្ឌា និងជប៉ុន មានសិទ្ធិប្រសើរជាងក្នុងការអះអាងពីស្វ័យភាពរបស់ខ្លួន) ។ តម្រូវការដំបូងគឺត្រូវវិភាគរកក្រុមមនុស្សប្រភេទណាដែលធ្វើជំនួញកម្រិតខ្ពស់ និងពួកគេមានឋានៈអ្វីនៅក្នុងសង្គម ។*

*«ភាពជាបរទេស» គឺជាគុណសម្បត្តិដ៏ជាក់លាក់ នៅក្នុងវិស័យពាណិជ្ជកម្ម ជាពិសេសពេលដែលវាពាក់ព័ន្ធនឹងទំនាក់ទំនងអន្តរជាតិ ។ ជនបរទេសមិនត្រឹមតែមិនត្រូវបានគេចាត់ចូលទៅក្នុងវិស័យកសិកម្ម និង រដ្ឋបាលទេ តែថែមទាំងត្រូវបានមេដឹកនាំចាត់ទុកពួកគេថាជាទ្រព្យសម្បត្តិមួយដ៏មានប្រយោជន៍ ជាជាងជាការគំរាមកំហែង ។ ទោះជាយ៉ាងនេះក្ដី នៅក្នុងតំបន់ពហុនយោបាយ (ដូចច្រើនទៅ និងអឺរ៉ុប ឬឥណ្ឌាខាងត្បូង ជាងនៅអាណាចក្រដេលី និងប៉េកាំង) មានកម្រិតផ្សេងៗនៃភាពជាបទេស ។ ឈ្មួញបរទេសមួយចំនួនដែលបានចូលសាសនា និងចេះនិយាយភាសារបស់តំបន់នោះ អាចឈានចូលទៅក្នុងវណ្ណៈអភិជនក្នុងស្រុកបានយ៉ាងរហ័ស ហើយឈ្មួញទាំងអស់អាចធ្វើដូច្នេះបានតែក្នុងមួយជំនាន់របស់ពួកគេប៉ុណ្ណោះ ប្រសិនបើពួកគេតាំងចិត្តទទួលយកនូវសាសនា និងវប្បធម៌របស់អ្នកស្រុក ។ នៅក្នុងចលនាផ្លាស់ប្ដូរឋានៈសង្គមបែបនេះ អាស៊ីអាគ្នេយ៍មានភាពដាច់ដោយឡែកពីប្រទេសឥណ្ឌា និងជប៉ុន ដែលនៅទីនោះដោយសារតែឧបសគ្គនៃវណ្ណៈ ឬឋានៈ ឈ្មួញមិនអាចឈានចូលទៅក្នុងវណ្ណៈនៃក្រុមមេដឹកនាំបានទេ ។ ជាការពិត ដោយសារតែរឿងរ៉ាវជោគជ័យផ្នែកពាណិជ្ជកម្មអាចមានលទ្ធភាពឈានទៅរកអំណាចបាន គេកាន់តែមានការលំបាកជាងមុនក្នុងការកំណត់ឲ្យបានច្បាស់នូវក្រុមមនុស្សថ្នាក់កណ្ដាលដ៏រឹងមាំ ឬ «វណ្ណៈគហបតី» ។*

*ទោះជាយ៉ាងនេះក្ដី គេឃើញមានក្រុមមនុស្សនៅអាស៊ីអាគ្នេយ៍មួយចំនួនដែលដាក់ចិត្តដាក់កាយទាំងស្រុងទៅក្នុងវិស័យពាណិជ្ជកម្ម ដោយមាននូវដើមទុនរបស់ខ្លួនផ្ទាល់ និងបង្កើតនូវទស្សនៈរួមផ្នែកពាណិជ្ជកម្មខុសពីអ្វីដែលជារបស់ក្រុមដឹកនាំ ។ ក្រុមដំបូងនៃក្រុមទាំងនេះបានបង្កើតឡើងដោយស្ត្រី ។ ពួកគេមិនត្រឹមតែមានប្រៀបនៅលើទីផ្សារប៉ុណ្ណោះទេ តែក៏មានមួយចំនួនធំបានក្លាយជាឈ្មួញ និងឈ្មួញរូបិយវត្ថុក្នុងទ្រង់ទ្រាយធំផងដែរ (Reid ១៩៨៨ : ១៦៣–៦៦) ។ វាមិនមែនជាការងាយស្រួលទេក្នុងការស្វែងរកនូវអំណះអំណាងអំពីមនោគមវិជ្ជាធ្វើជំនួញ*

របស់ស្ត្រីផ្សេងពីនេះនោះ តែជាការពិតដែលថាស្ត្រីមិនសូវខ្វល់ខ្វាយពីឋានៈ និងអំណាចដូចពួកពាណិជ្ជករបុរសទេ ។

ក្រុមទីពីរដែលគេចាប់អារម្មណ៍នោះគឺឈ្មួញត្រាច់ចរដែលគេហៅថា«គីវី – kiwi» និងមេដឹកនាំរបស់គេគឺគេហៅថា «ណាខូនដា – nakhodas» ។ ដោយមានឋានៈទាបជាងក្រុមស៊ីយ៉ាបាន់ដា បន្តិច អ្នកទាំងនេះមានវត្តមានជាជនបរទេសនៅគ្រប់ទីកន្លែង ។ សូម្បីតែនៅតាមកំពង់ផែដែលពួកគេចាត់ទុកថាជាផ្ទះរបស់ខ្លួន ក៏ពួកគេប្រហែលជារស់នៅតាមតំបន់ជាតិពន្ធុមួយដែលធ្វើទំនាក់ទំនងជាសំខាន់ជាមួយនឹងអគ្គាធរស៊ីយ៉ាបាន់ដានៃក្រុមរបស់ពួកគេ ។ នៅក្នុងគំនិតរបស់ពួកអឺរ៉ុប គេកំណត់ឈ្មួញប្រភេទនេះដោយតួនាទី និងជាតិពន្ធុជាជាងដោយវណ្ណៈ ។ ដូចដែល Pires បានបង្ហាញពីប៉ាទីយុនុ (Patih Yunus) ជាឧទាហរណ៍ ណាខូនដាដែលពូកែអាចក្លាយជា ស៊ីយ៉ាបាន់ដា ឬជាមេដឹកនាំដោយងាយស្រួល ។ ទោះជាយ៉ាងនេះក្តី ដោយសារពួកគេជាឈ្មួញដែលធ្វើដំណើរតាមផ្លូវសមុទ្រ ពួកគេមាននូវទស្សនៈមួយដែលផ្សេងពីគេ ។

ច្បាប់ដែលនិយាយពីសិទ្ធិ និងតួនាទីរបស់ក្រុមនេះគឺក្រុមច្បាប់ម៉ាឡេនៅក្នុងផ្នែកដែលចែងពីច្បាប់លើផ្ទៃសមុទ្រដែលគេហៅថាអ៊ុនដាង–អ៊ុងដាង លូត (Undang-undang Laut) ។ ច្បាប់នេះផ្តល់តួនាទីខ្ពស់ដល់ ណាខូនដាដែលមានអំណាចអាចកំណត់ពីជោគវាសនាស្លាប់រស់នៅលើនាវា ក៏ដូចជាមានសិទ្ធិលើសគេលើសឯងនៅគ្រប់សកម្មភាពពាណិជ្ជកម្មទាំងអស់ រួមទាំងសិទ្ធិក្នុងការលក់ទំនិញរបស់ខ្លួនមុនគេបន្ទាប់ពីធ្វើដំណើរមកដល់កំពង់ផែមុនពេលដែលឈ្មួញដទៃទៀតដែលធ្វើដំណើរមកជាមួយធ្វើការបញ្ចុះតម្លៃ។ អំណាចបែបនេះគឺមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ព្រោះបើយោងទៅលើកស្តុតាងផ្នែកក្នុង ច្បាប់នេះសរសេរឡើងដោយណាខូនដា ៥ នាក់ នៅម៉ាឡាកា នៅទសវត្សរ៍ដំបូងនៃសតវត្សរ៍ទី ១៦ ។ ក្នុងចំណោមអ្នកទាំង ៥ នាក់នោះ បើមើលតាមឈ្មោះវិញ គឺយ៉ាងហោចណាស់ក៏មាន ៣នាក់មានដើមកំណើតជាជនជាតិជ្វា ។ បន្ទាប់មក នាកហៀដាទាំង ៥ រូបពិភាក្សាច្បាប់នេះជាមួយនឹងណាខូនដាទាំងអស់ ។ ពេលដែលច្បាប់នេះទទួលបានការព្រមព្រៀងនាដំណាក់កាលនេះ ពួកគេបញ្ជូនវាឆ្លងទៅប៉ង់ដាហា ហើយពីប៉ង់ដាហា ក៏ធ្វើដំណើរជាមួយនឹងណាខូនដាទាំង ៥ នាក់នោះទៅជួបជាមួយនឹងស្តេចស៊ុលតង់ម៉ាមុដ ។ ស្តេចស៊ុលតង់បានប្រកាសឲ្យប្រើច្បាប់នេះដោយមានពាក្យពេចន៍ថា ÷ «អ្វីក៏ដោយដែលអ្នកធ្វើការសម្រេចនៅឯសមុទ្រ គឺជាច្បាប់សមុទ្រ ឯនៅលើដីគោក គឺកំណត់ដោយច្បាប់ដីគោក ។ ចំពោះអ្នកទាំងអស់ដែលជា ណាខូនដាគឺប្រៀបដូចជាស្តេចនៅលើនាវារៀងៗខ្លួនរបស់អ្នក» (Undang-undang Laut : ៤៥–៤៦) ។ ណាខូនដា ក៏ជាបុគ្គលដែលគេស្គាល់ច្រើននៅក្នុងអក្សរសិល្ប៍ម៉ាឡេនាសម័យកាលនោះ ។ ស្វ័យជីវប្រវត្តិម៉ាឡេ–ពិតប្រាកដដំបូងគេបង្អស់សរសេរឡើងដោយណាខូនដាម្នាក់ទោះបីជាការសរសេរនេះធ្វើឡើងនៅសតវត្សរ៍ទី ១៨ ហើយដោយមានការជំរុញពីពួកអឺរ៉ុបក៏ដោយ (La-uddin ១៧៨៨) ។ ដោយសារតែមានចំណេះវិជ្ជា និងដឹងហេតុការណ៍ច្រើនណាខូនដា តែងតែទទួលបានការស្វាគមន៍ជានិច្ចនៅក្នុងទីក្រុង ដោយសារតែគាត់បានពាំនាំយកមកមិនត្រឹមតែទំនិញប៉ុណ្ណោះទេ តែថែមទាំងដំណឹងមកពីគ្រប់ទិសទីក្នុងតំបន់ទៀតផង ។ ដោយសារមូលហេតុនេះហើយណាខូនដាដែលគ្រាន់បើជាងគេទទួលបាននូវការស្វាគមន៍នៅក្នុងព្រះរាជវាំង (Houtman ១៦០៣ : ១៤–៣២) ។ ភាពល្អឥតខ្ចោះនៃពត៌មានពីអាស៊ីអាគ្នេយ៍របស់ពួកហូឡង់ គឺភាគច្រើនបានមកពីការរាយការណ៍របស់ពួកនេះ ។

ទស្សនៈរួមនេះមានការពាក់ព័ន្ធជាមួយនឹងក្រុមជាតិពន្ធុមួយចំនួនច្រើនជាងក្រុមជាតិពន្ធុដទៃទៀត ។ គេឃើញមានកស្តុតាងតិចតួចណាស់អំពីក្រុមជាតិពន្ធុភូមា ថៃ ខ្មែរ វៀតណាម ឬបាលីដែលធ្វើជំនួញតាមផ្លូវសមុទ្រ

នៅក្រៅតំបន់របស់ពួកគេ ។ រ៉ូដស៍ (Rhodes ១៦៥១ : ៥៦) បានបង្ហាញពីឧបសគ្គបីដែលរារាំងដល់ពួកវៀតណាមខាងជើង គឺកង្វះខាតនូវបច្ចេកទេសធ្វើនាវាចរណ៍ កង្វះខាតនាវាធ្វើដំណើរតាមផ្លូវសមុទ្រ និងបំរាមរបស់ស្តេចខ្លួនដែលខ្លាចបាត់បង់អ្នកបង់ពន្ធសំខាន់ៗ ។ ទោះបីជាអយុធ្យាជារដ្ឋមហាអំណាចចម្បងនៅឈូងសមុទ្រថៃក៏ដោយក៏វាមិនមាននូវនាវាធ្វើដំណើរតាមផ្លូវសមុទ្រផ្ទាល់ខ្លួននោះទេលើកលែងតែមកដល់រជ្ជកាលព្រះបាទប្រាសាទ ថង (១៦២៩-៥៦) (រូបភាពទី ២១) ។ ចំណុចនេះនៅជាបញ្ហានៅឡើយនៅពេលដែលវាធ្វើការវាយប្រហារទៅលើទីក្រុងប៉ាតានីនៅក្នុងឆ្នាំ ១៦៣៤ ដែលញុំាងឲ្យមាននូវការសង្កេតនៅក្នុងពង្សាវតាររបស់ទីក្រុងប៉ាតានីដូច្នេះថា ÷ «ជនជាតិសៀមមិនទាន់ដឹងច្បាស់នៅឡើយពីវិធីធ្វើដំណើរតាមសំពៅនៅលើសមុទ្រ ដូច្នេះទោះបីពួកគេត្រូវធ្វើដំនើរចម្ងាយឆ្ងាយប៉ុណ្ណាក៏ដោយ ក៏ពួកគេនៅតែធ្វើដំណើរតាមផ្លូវគោក» (Hikayat Patani : ១៨២) ។ កងនាវារបស់ព្រះរាជា ដែលបានបង្កើតក្រោយមកប្រើមនុស្សដែលភាគច្រើនជាជនជាតិចិន ពួកមូស្លីម និងជនជាតិអឺរ៉ុបដោយសារ «ពួកសៀមជំនាញតែខាងធ្វើដំណើរតាមទន្លេរបស់ខ្លួនតែប៉ុណ្ណោះ» (Choisy ១៦៨៧ : ២៤៤) ។

ប្រសិនបើអ្នកដែលមកពីរដ្ឋដីគោកអស់ទាំងនេះ ប៉ុកំអ្នកដែលមកពីតំបន់ខ្ពង់រាបធ្វើជំនួញនៅក្រៅតំបន់របស់ពួកគេ ពួកគេប្រាកដជាសម្របខ្លួនចូលទៅក្នុងក្រុមមួយក្នុងចំណោមក្រុមដទៃទៀតជាច្រើនដែលពូកែខាងពាណិជ្ជកម្ម ជាពិសេសគឺក្រុមជនជាតិម៉ាឡេ និងចិនតែឈានមកដល់ប្រមាណឆ្នាំ ១៦០០ ក៏មានចូលទៅក្នុងក្រុមជនជាតិចាម មន (មកពីទីក្រុងពេគូ) លូស្សន់ (មកពីទីក្រុងម៉ានីល និងប្រ៊ុយណេ) ជ្វា និងក្រុមពួកបង់ដាផងដែរ ។ ភាគច្រើននៃក្រុមទាំងប៉ុន្មានរៀបរាប់ខាងក្រោយនេះ ដែលនៅបន្តធ្វើជាឈ្មួញសកម្មនោះ ប្រហែលជាសម្របខ្លួនធ្វើជាជនជាតិម៉ាឡេនៅពេលដែលទឹកដីកំណើតរបស់ពួកគេត្រូវបានឈ្លានពានដណ្តើមកាន់កាប់ដោយក្រុមកម្លាំងទ័ពដែលមិនមានក្តីមេត្តាចំពោះពាណិជ្ជកម្មរបស់ពួកគេ ។ ក្នុងនោះ ទឹកដីចម្ប៉ាត្រូវពួកវៀតណាមដណ្តើមយក ពេគូត្រូវពួកភូមាដណ្តើមយក ម៉ានីលត្រូវពួកអេស្ប៉ាញដណ្តើមយក រីឯតំបន់ឆ្នេរសមុទ្រជ្វា ត្រូវពួកម៉ាតារ៉ាមដណ្តើមយក ។ នាសតវត្សរ៍ទី ១៧ ពួកម៉ាកាសារ និងពួកប៊ូគីសបានចាប់ផ្តើមលេចចេញជាក្រុមឈ្មួញធ្វើជំនួញតាមផ្លូវសមុទ្រមួយក្រុមផ្សេងទៀត ។ ពួកព័រទុយហ្កាល់បានមកបង្កើតក្រុមភាគតិចធ្វើពាណិជ្ជកម្មមួយផ្សេងទៀត ហើយជនជាតិអាស៊ីកាន់សាសនាគ្រិស្តដែលមានទំនោរទៅរកផ្នែកពាណិជ្ជកម្ម មានបំណងចង់សម្របខ្លួនចូលជ្រកពីក្រោមផ្លាករបស់ពួកព័រទុយហ្កាល់ ។ ក្រុមទាំងអស់នេះនិយាយភាសាម៉ាឡេជាភាសាទីពីរ ប្រសិនបើមិនមែនជាភាសាទីមួយរបស់ពួកគេទេនោះ ។ ពេលដែលពួកគេនៅតាមកំពង់ផែ ពួកគេរស់នៅតាមតំបន់ក្រុមរបស់ពួកគេរៀងៗខ្លួនក្នុងទីក្រុងប្រសិនបើពួកគេអាចមានលទ្ធភាពបង្កើតតំបន់ក្រុមរបស់ខ្លួនបាន តែបើមិនបានទេ ពួកគេរស់នៅតាមក្រុមដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែលនឹងពួកគេ ។ អម្បូរជាតិសាសន៍ គឺប្រហែលជាលទ្ធផលនៃឋានៈភាគតិចខាងផ្នែកពាណិជ្ជកម្មច្រើនដូច និងបុព្វហេតុរបស់វា ។

ភាពពហុជាតិសាសន៍ដែលជាលក្ខណៈពិសេសគួរឲ្យកត់សម្គាល់មួយនៅសតវត្សរ៍ទី ១៦ បានធ្លាក់ចុះយ៉ាងរហ័សនៅសតវត្សរ៍ទី ១៧ រីឯមូលហេតុដែលនាំឲ្យដូច្នេះ យើងនឹងធ្វើការបកស្រាយលម្អិតបន្ថែមទៀតនៅក្នុងជំពូកទី ៤ និងទី ៥ ។ ការទិញផ្តាច់មុខរបស់ពួកអឺរ៉ុប និងសម្ពាធផ្សេងៗទៀត បានញុំាងឲ្យពួកមេដឹកនាំប្រមូលក្តោបក្តាប់ជំនួញកាន់តែច្រើនឡើងៗនៅក្នុងកណ្តាប់ដៃរបស់ខ្លួនហើយជួយធ្វើឲ្យអំណាចស្ថិតនៅកណ្តាលចំពោះរដ្ឋទាំងឡាយដែលមានទំនោរទៅរកវិស័យពាណិជ្ជកម្ម ។ ក្រុមជាតិសាសន៍ភាគតិចផ្នែកពាណិជ្ជកម្មដែលជាម្ចាស់ស្រុកនៅក្នុងតំបន់បានបង្រួមមកនៅត្រឹមតែក្រុមជនជាតិម៉ាឡេ និងចិនប៉ុណ្ណោះហើយនៅក្នុងសតវត្សរ៍ទី ១៧ ជន

ជាតិចិនកាន់តែមិនមានបំណងចង់ធ្វើជាម្ចាស់ស្រុក និងសម្របខ្លួនចូលជាមួយនឹងម្ចាស់ស្រុក ។

អន្តរអន្តោប្រវេសន៍របស់ជនជាតិម៉ាឡេបានទាក់ទាញការចាប់អារម្មណ៍ពិសេសជាក្រុមជាតិសាសន៍ភាគតិចផ្នែកពាណិជ្ជកម្មអាស៊ីអាគ្នេយ៍ដ៏សំខាន់ដោយមាននូវស្វ័យភាពខ្លះផងដែរ ។ នៅដំណាក់កាលរីកចម្រើនដល់កំពូលរបស់ក្រុងម៉ាឡាកា វរជន «ម្ចាស់ស្រុក» និយាយភាសាម៉ាឡេរបស់ទីក្រុងនេះត្រូវគេដឹងថាមានដើមកំណើតមកពីប្រភពផ្សេងៗដែលក្នុងនោះភាគច្រើនមានដើមកំណើតមកពីជនជាតិជ្វា ប៉ុន្តែ ចិនកាត់ជ្វា (Barbosa ១៥១8 II :១៧៦) ។ អន្តរអន្តោប្រវេសន៍បានចាប់ផ្តើមនៅពេលដែលពួកព័រទុយហ្កាល់ច្បាំងដណ្តើមយកទីក្រុងម៉ាឡាកាបាន ដោយទង្វើនេះបានបណ្តេញពួកឈ្មួញមូស្លីមដែលរស់នៅទីនោះចាកចេញពីទីក្រុង ។ មិនថាពួកអន្តោប្រវេសន៍មានដើមកំណើតមកពីណាក៏ដោយ គឺចាប់ពីពេលនោះមក គេបានចាត់ទុកអន្តរអន្តោប្រវេសន៍នៅម៉ាឡាកាថាជាម៉ាឡាយូ ឬម៉ាឡេល្អដាច់គេ ។ សម្រាប់អ្នកនិយាយភាសាម៉ាឡេនៅប៊្រុយណេ និងម៉ាលុគុ «គំរូរបស់ម៉ាឡេ» គឺមានន័យថាបែបបទរបៀបរបបរបស់ទីក្រុងម៉ាឡាកា (Pigafetta ១៥២៤ : ៨៨) ។ ដំបូងឈ្មួញទាំងនេះតាំងទីនៅប៉ាហាំង ប៉ាតានីចូហរ និងអាចេ ហើយក្រោយមកនៅតាមទីក្រុងកំពុងផែថ្មីៗនៅបង់តេន ម៉ាកាសសារ អយុធ្យានិងកម្ពុជា ។ នាឆ្នាំ ១៥៩៦ សហគមន៍ម៉ាឡេនៅទីក្រុងបង់តេនត្រូវគេស្គាល់ថាជាសហគមន៍មួយក្នុងចំណោមសហគមន៍ដែលធូរធារជាងគេ ដែលដូចទៅនឹងជនជាតិគណ្ឋាខាងត្បូងដែរ ។ សហគមន៍នេះ «បានផ្តល់កម្ចីដោយមានការប្រាក់ និងផ្តល់កម្ចីសម្រាប់ការធ្វើដំណើរតាមផ្លូវសមុទ្រ និងដល់ម្ចាស់នាវាដែលដាក់នាវាបញ្ចាំផងដែរ» (លូដូវីស្គស៍ ១៥៩៨ : ១២១) ។ នៅក្នុងប្រទេសកម្ពុជា ពួកម៉ាឡេចាប់ផ្តើមមានឥទ្ធិពលខ្លាំងគួរសមនៅក្នុងទសវត្សរ៍ឆ្នាំ ១៦៤០ ដែលធ្វើឲ្យព្រះរាជាសម្រេចព្រះហឫទ័យផ្គត់ផ្គង់ ឬក៏សហការជាមួយពួកនោះ និងជាមួយនឹងសាសនាអ៊ីស្លាម (សូមមើលខាងក្រោម) ។

នៅភាគខាងកើតឥណ្ឌូនេស៊ី គេមិនសូវឃើញមានជនជាតិចិនប៉ុន្មានទេ ហើយជនជាតិម៉ាឡេវិញទទួលបានឋានៈពិសេសជាក្រុមជនជាតិភាគតិចផ្នែកពាណិជ្ជកម្មដ៏អស្ចារ្យតែមួយគត់ ។ ព្រះរាជពង្សាវតាររបស់ទីក្រុងម៉ាកាសសារបានកត់ត្រានូវកិច្ចសន្យាសន្តមដែលចូលរួមដោយព្រះរាជាទុនី ប៉ាឡាងហ្គា (១៥៤៨-៦៦) ដែលកំណត់ថាអ្នករស់នៅម៉ាកាសសារយល់ព្រមមិនចេញចូលទៅក្នុងលំនៅស្ថានរបស់ពួកម៉ាឡេដែលសេចក្តីសម្រេចនេះជាការផ្តល់ឲ្យពួកម៉ាឡេនូវសិទ្ធអំណាចគ្រប់គ្រងតំបន់ខាងក្នុងរបស់ខ្លួន ។ នាពេលនោះអ្នកតំណាងរបស់ពួកគេគឺណាខូដាម៉ងណាង តែព្រះរាជវាំងម៉ាកាសសារបានតែងតាំងឥស្សរជននាំមុខមួយរូបរបស់ខ្លួនជាស៊ីយ៉ាបាន់ដា ដើម្បីមើលការខុសត្រូវពួកគេ ក៏ដូចជាឈ្មួញដទៃទៀតផងដែរ ។ គេក៏ឃើញមានការបង្កើតនូវតំណែងជាស្មៀនថ្មីៗផងដែរ ដែលមួយសម្រាប់អ្នកបកប្រែភាសាម៉ាឡេ និងមួយទៀតសម្រាប់អ្នកសរសេររដ្ឋបាលហិរញ្ញវត្ថុជំនួញ (Sejarah Goa :២៦-២៨; Cense ១៩៧៨ : ៤២២) ។

ពង្សាវតាររបស់ ពិមា បានកត់ត្រាពីការចុះហត្ថលេខានៅលើកិច្ចសន្យាស្រដៀងគ្នានេះដែរ ពេលដែលមេដឹកនាំមូស្លីមដំបូងបង្អស់របស់ ពិមាចង់ប្រគល់ផ្ទះនៅទីតាំងមួយជូនដល់ពួកម៉ាឡេក្នុងការ ដែលពួកគេជួយផ្សព្វផ្សាយសាសនាអ៊ីស្លាម ។ មេដឹកនាំនោះបានផ្តល់ដីឲ្យពួកម៉ាឡេធ្វើស្រែ តែពួកគេបានប្រកែកមិនព្រមទទួលយកដោយនិយាយថា ពួកគេជា «អ្នកធ្វើដំណើរតាមនាវា និងជាឈ្មួញ មិនមែនជាកសិករទេ» ហើយជាការប្តូរនឹងផ្ទះនៅបែបនេះពួកគេបានសុំឲ្យលើកលែងពន្ធនាំចូល និងនាំចេញទំនិញវិញ ។ ហើយពួកគេក៏ទទួលបាននូវការធានានូវសិទ្ធិសេរីភាពក្នុងការរស់នៅក្នុងរាជធានីនោះផងដែរ (Syamsuddin ១៩៨២ : ២៩៦-៩៧) ។

ដូចទៅនឹងក្រុមជនជាតិភាគតិចផ្សេងទៀតដែរ អានុភាពរបស់ពួកម៉ាឡេអាស្រ័យយ៉ាងខ្លាំងទៅនឹងទំនាក់ទំនងអន្តរជាតិ និងចលភាព ។ គេឃើញមានសហគមន៍និយាយភាសាម៉ាឡេនៅគ្រប់មជ្ឈមណ្ឌលពាណិជ្ជកម្មនៅអាស៊ីអាគ្នេយ៍ ប៉ុន្តែរូបភាពពិតជាក់ស្តែងបំផុតរបស់សហគមន៍នេះគឺនៅទីក្រុងម៉ាកាសសារ ។ ក្រុមដែលទទួលបានសម្បទានដំបូងគេបង្អស់នៅទីនោះនៅសតវត្សរ៍ទី ១៦ គឺមកពីចូហរ ប៉ាតានី ប៉ាហាំង មីណង់កាបាវ និងចម្ប៉ា (Sejarah Goa :២៨; cf. Paiva ១៥៤៤ : ២៩៥)។ ចាប់ពីប្រហែលឆ្នាំ ១៦២០ ក្រុមនេះមានសមាជិកក៏ដូចជាធនធានកាន់តែច្រើនឡើងៗគឺនៅពេលដែលទីក្រុងម៉ាកាសសារបានក្លាយជាទីកន្លែងជ្រកកោនសម្រាប់អ្នកដែលចង់គេចចេញពីការប៉ុនប៉ងរបស់ពួកហូឡង់នៅក្នុងការផ្តាច់មុខនូវផ្កាក្លាំពូ និង ចន្ទន៍ក្រស្នា ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៦២០ គេឃើញមានឈ្មួញជនជាតិម៉ាឡេរាប់ពាន់នាក់នៅក្នុងទីក្រុងនេះ ហើយក្នុងនោះឈ្មួញម៉ាឡេប្រាំមួយរយនាក់បានចូលរួមទៅក្នុងកងនាវាដែលបង្កើតឡើងសម្រាប់ការធ្វើដំណើរទៅកាន់ទីក្រុងម៉ាលុគុដើម្បីប្រមូលទិញនូវគ្រឿងទេសផ្សេងៗនាឆ្នាំ១៦២៤ (Dagh-Register ១៦២៤–២៩ : ៧៨, ១២៥) ។ នៅកំលុងឆ្នាំនេះដែរ សមាជិកផ្តាច់ខ្លួននៃរាជវង្សានុវង្សរបស់ព្រះមហាក្សត្រនៅប៉ាតានីបានធ្វើដំណើរមកដល់ដែលជួយបន្ថែមឋានៈទៅដល់សហគមន៍នេះបន្ថែមទៀត ហើយក្នុងចំណោមសមាជិកផ្តាច់ខ្លួនទាំងនោះមានម្នាក់ព្រះនាមដាទុ មហារាជាឡេឡា (Datu Maharajalela) ដែលត្រូវជាព្រះប៉េតុលារបស់ព្រះមហាក្សត្រិយ យ៉ានីប៉ាតានី ត្រូវបានព្រះរាជជាចាត់តាំងឲ្យធ្វើជាមេដឹកនាំសហគមន៍នោះ ។ ទោះបីជាប្រជាជនរស់នៅក្រុងម៉ាកាសសារភាគច្រើនបន្តប្រើប្រាស់នូវភាសាផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់គោលបំណងខាងអក្សរសាស្ត្រក៏ដោយ ក៏ក្រុងម៉ាកាសសារបានក្លាយជាមណ្ឌលដ៏សំខាន់មួយសម្រាប់អក្សរសាស្ត្រម៉ាឡេដែលភាគច្រើនធ្វើឡើងតាមរយៈសកម្មភាពរបស់ក្រុមអ្នកធ្វើជំនួញភាគតិចនេះ (ស្តីននីរ ១៩៦៣ : ២៥–២៧) ។

ពួកម៉ាឡេបានប្រយុទ្ធយ៉ាងស្វិតស្វាញបំផុតជាមួយនឹងពួកហូឡង់ដើម្បីការពារក្រុងម៉ាកាសសារ ហើយនៅពេលដែលទីក្រុងនេះដួលរលំនៅក្នុងឆ្នាំ ១៦៦៩ មក ពួកគេបានរត់បែកខ្ញែកគ្នាអស់ ។ អ្នកដើងសារជំនួញជាតិអង់គ្លេសមួយរូបបានកត់សម្គាល់ឃើញថាពួកព័រទុយហ្កាល់ និងពួកម៉ាឡេ ដែលជា «សរសេរស្តីអំពីនៅក្នុងវិស័យជំនួញ» ប្រហែលជាបានចាកចេញពីក្រុងម៉ាកាសសារទៅកាន់ប្រទេសសៀម (cited Bassett ១៩៥៨ : ៣០) ។ នៅទីបំផុត សហគមន៍ម៉ាឡេតូចមួយបានវិលត្រឡប់ទៅទទួលយកនូវការការពាររបស់ពួកហូឡង់ ហើយនៅតែជាសហគមន៍មួយក្នុងចំណោមសហគមន៍ផ្នែកពាណិជ្ជកម្មឈានមុខគេនៅក្នុងទីក្រុងអាណានិគមនេះ ។ ពួកមូស្លីមឥណ្ឌាដែលដឹកនាំដោយឈ្មួញដ៏អស្ចារ្យ «ម៉បក្វី» នៅទីបំផុតបានសម្របខ្លួនចូលទៅក្នុងសហគមន៍នេះ (Cense ១៩៧៨ : ៤២៤–២៦) ។ នៅក្នុងក្រុងបាតាវៀដែលគ្រប់គ្រងដោយពួកហូឡង់ គេក៏ឃើញមានក្រុមភាគតិចម៉ាឡេសំខាន់មួយផងដែរដែលមេដឹកនាំដំបូងរបស់ក្រុមនោះ គឺជាមនុស្សម្នាក់ផ្សេងទៀតមកពីប៉ាតានីឈ្មោះ Entji Amat ដែល «រកស៊ីមានបានតាមរយៈការលក់ទៀនតាមនាវា» និងបានធ្វើជាអ្នកនិពន្ធ អ្នកបកប្រែភាសា អ្នកការទូត និងមន្ត្រីពិធីការឲ្យក្រុមហ៊ុន VOC (de Haan ១៩២២I :៤៨៣) ។




រូបភាព ២១
អ្នកជំនួញជនជាតិបរទេសនៅតាមផ្លូវសមុទ្រ
រូបបង្ហាញក្នុងសំពៅថៃ ឆ្នាំ ១៧៧៦

## នគរូបនីយកម្មនិយម និង មូលធននិយម

ក្នុងការវាយតម្លៃការផ្លាស់ប្ដូរចំពោះរបៀបរបបសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ក្នុងអំឡុងសម័យពាណិជ្ជកម្ម យើងអាចចាប់ផ្ដើមជាមួយនឹងលក្ខណៈទាំងប៉ុន្មានដែលអាស៊ីអាគ្នេយ៍មានដូចគ្នានឹងប្រទេសឈានមុខដទៃទៀតនៅក្នុងការពង្រីកពាណិជ្ជកម្មសកលលោក ។ ដំណាក់កាលពីឆ្នាំ១៤០០-១៦៣០ ទាំងមូល គឺជាដំណាក់កាលនៃការរីកចម្រើនផ្នែករូបិយវត្ថុនីយកម្ម និងពាណិជ្ជនីយកម្មរបស់សេដ្ឋកិច្ចយ៉ាងរហ័ស ដែលការរីកចម្រើនខ្លាំងក្លាបំផុត គឺនៅចន្លោះរវាងឆ្នាំ១៥៧០-១៦៣០ ។ បើគិតសម័យកាលនោះ ប្រជាជនជាច្រើនត្រូវបានអូសទាញទៅក្នុងវិស័យផលិតកម្ម និងទីផ្សាររបស់សេដ្ឋកិច្ចពិភពលោក ហើយបានពឹងផ្អែកលើការនាំចូលពីតំបន់ឆ្ងាយៗនូវរបស់របរប្រើប្រាស់ប្រចាំថ្ងៃដូចជា ក្រណាត់ កុលាលភាជន៍ ប្រដាប់ប្រដាផ្ទះបាយ និងលុយកាក់ៗ(បើគិតតាមបទដ្ឋានអន្តរជាតិ) វិស័យជំនួញបានរួមចំណែកខ្ពស់សម្រាប់ចំណូលជាតិរបស់អាស៊ីអាគ្នេយ៍ ហើយវាក៏បានបង្កឲ្យមានការរីកចម្រើនផ្នែកនគរូបនីយកម្មដែលប្រហែលជាបានប្រសើរជាងការរីកចម្រើនដដែលនេះម្ដងទៀតនៅមុនសតវត្សរ៍ទី ២០ ផងដែរ ។ នៅក្នុងទីក្រុងអស់ទាំងនេះ គេឃើញមានសហគមន៍ផ្សេងៗដែលដាក់ចិត្តដាក់កាយទាំងស្រុងទៅក្នុងជំនួញ និងពាណិជ្ជកម្ម ហើយគេក៏ឃើញមានការបង្កើតឲ្យមាននូវស្ថាប័នមួយចំនួនទៀតផងដែរដូចជា ស្ថាប័នបញ្ចាំនាវ ស្ថាប័នចែករំលែកផលចំណេញ និងស្ថាប័នកម្ចីមានការប្រាក់ជាដើម ។

ទោះជាយ៉ាងនេះក្ដី នៅក្នុងវិស័យសំខាន់ៗមួយចំនួនប្រទេសចិន ឥណ្ឌា និងជប៉ុន មានការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចខ្ពស់ជាងតំបន់អាស៊ីអាគ្នេយ៍ ទោះបីជាអ្នករស់នៅទីក្រុងជាច្រើននៅអាស៊ីអាគ្នេយ៍ចេះនូវបច្ចេកទេសនេះក៏ដោយ ។ បច្ចេកទេសនេះរួមមាន ធនាគារដែលទើបបង្កើតឡើងថ្មីៗដែលនៅអាស៊ីអាគ្នេយ៍ ដំណើរការវាប្រព្រឹត្តទៅជាលក្ខណៈបុគ្គលដោយពួកជាងមាស និងពួកផ្ដល់ប្រាក់កម្ចី ។ ដោយសារតែយើងមានទំនុកចិត្តជាង យើងអាចឯកភាពជាមួយនឹងទស្សនៈរបស់មេលីង រូលូហ្វស៍ ដោយបដិសេធទៅនឹងទស្សនៈរបស់ វ៉ាន់ ឡឺ (Van Leur) ថាបណ្ដាទីក្រុងនាំមុខនៅអឺរ៉ុបបានបង្កើតនូវស្ថាប័នសាធារណៈដើម្បីចែករំលែក និងមើលថែរក្សាមូលធនផ្សេងៗដែលស្ថាប័នបែបនេះ គេមិនឃើញមាននៅអាស៊ីអាគ្នេយ៍ទេ ។ ទីផ្សារភាគហ៊ុន ធនាគារ និងក្រុមហ៊ុនដាក់ឲ្យដួលផ្សេងៗនៅទីក្រុងអាំស្ទែដាម អានវែបឡុងដ៍ និងប៉ារីសបានបង្កលទ្ធភាពដល់ចល័តនីយកម្មសម្រាប់គោលបំណងទទួលបានផលចំណេញពីការសន្សំផ្សេងៗ ដែលមិនត្រឹមតែសម្រាប់ព្រះអង្គម្ចាស់ និងក្រុមភាគតិចដែលប្រកបរបរជាឈ្មួញទេ តែថែមទាំងសម្រាប់អ្នករស់នៅក្នុងទីក្រុងគ្រប់ស្រទាប់ជាន់ថ្នាក់ និងក្រុមពួកអ្នកមាននៅតាមតំបន់ជនបទផងដែរ ។

នៅពីក្រោយចម្ងល់អំពីបច្ចេកវិជ្ជាមូលធននេះគឺមានបង្កប់នូវបញ្ហានយោបាយយ៉ាងជ្រាលជ្រៅ ដែលមានដូចជា សន្តិសុខរបស់មនុស្ស និងទ្រព្យសម្បត្តិជាដើមដូចដែលមេលីង រូលូហ្វស៍ បានលើកឡើងថា ÷ «ជាការប្រឆាំងទៅនឹងគំនិតរំលោភបំពានតាមអំពើចិត្តរបស់មេដឹកនាំ» (១៩៦២ : ៨) ។ នេះមិនមែនជាអ្វីដែលអាចវាស់វែងបានតាមរយៈរង្វាស់ម៉ែត្រណាមួយបានទេ តែវាគឺជាភាពខុសគ្នាខ្លាំងបំផុតរវាងអាស៊ីអាគ្នេយ៍ និងអឺរ៉ុប នាដំណាក់កាលនោះ ។ អ្នកធ្វើដំណើរដំបូងគេបង្អស់ទៅកាន់អឺរ៉ុប មានការភ្ញាក់ផ្អើលខ្លាំងជាងគេចំពោះការបង្កើតឡើងនូវសិទ្ធិរបស់បុគ្គល និងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិដែលមាននៅទីនោះ ។ អ្នករស់នៅទីក្រុងបង់តេនម្នាក់ដែលជាទាសករមានដើមកំណើតជាជនជាតិចិន និងដែលត្រូវគេនាំទៅកាន់ប្រទេសហូឡង់ដំបូងគេបង្អស់បានរាយការណ៍មកឲ្យព្រះរាជវាំងបង់តេនថា ÷ «មនុស្សគ្រប់គ្នានៅទីនោះគឺជាម្ចាស់លើខ្លួនឯងហើយមិនមានទាសករ

បុកឹ្អកជាប់ឃុំម្នាក់សោះឡើយនៅលើទឹកដីទាំងមូលនោះ» (True Report ១៥៩៩ : ៣៦-៣៧)។ ពួកអភិជនដែលបានបង្កើតស្ថានទូតបង់តេននៅក្នុងក្រុងឡុងដ៍នាឆ្នាំ ១៦៨២ គឺ «មានការភ្ញាក់ផ្អើលក្នុងការស្វែងយល់ឃើញថាច្បាប់របស់យើងបានផ្ដល់ឲ្យយើងនូវសិទ្ធិគ្រប់គ្រងត្រឹមត្រូវចំពោះទឹកដីរបស់យើង ហើយដូច្នេះហើយពួកគេគិតថាយើងទាំងអស់គ្នាសុទ្ធតែជាស្ដេចដោយសារតែពួកគេមិនអាចយល់បានថាតើបរិវាអាចមានកម្មសិទ្ធិយ៉ាងម៉េចកើតក្រៅតែអំពីការបម្រើឲ្យសេចក្ដីសប្បាយរបស់ព្រះអង្គម្ចាស់របស់ផងខ្លួនតែប៉ុណ្ណោះ» (Evelyn ១៩៥៥ : ២៨៦)។ ជាការអនុវត្តជាក់ស្ដែង អំណាចត្រូវបែងចែកទៅតាមវិធីផ្សេងៗ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ប្រព័ន្ធច្បាប់និងមនោគមវិជ្ជាបានដាក់កំហិតតែបន្តិចបន្តួចប៉ុណ្ណោះទៅលើវា ។

ចម្ងល់នេះបានធ្វើឲ្យយើងត្រឡប់ទៅមើលទីក្រុងវិញ ។ សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិអាចបង្កើតឡើងនៅចុងមជ្ឈិមសម័យនាទ្វីបអឺរ៉ុបបានមួយផ្នែកដោយសារតែសម័យសក្តិភូមិអឺរ៉ុបបានបង្កើតនូវចន្លោះមួយសម្រាប់ទីក្រុងស្វយ័ត។ មួយផ្នែកផ្សេងទៀត ប្រទេសនៅអាស៊ីបូព៌ាដែលកាន់សាសនាខុងជឺក៏បានបង្កើតនូវទីក្រុងស្វយ័តដែលមានកំពែងការពារទៅតាមសិទ្ធិ និងតម្រូវការផ្សេងៗដែលជាការទទួលស្គាល់របស់ពួកគេផងដែរ ហើយសម្រាប់ករណីរបស់ទីក្រុងតូគីហ្គាវ៉ានៃប្រទេសជប៉ុនវិញ លក្ខណៈនេះមានសារៈសំខាន់ចំពោះការប្រមែប្រមូលបាននូវដើមទុន និងរបៀបរបបរស់នៅបែបជំនួញ ។ ផ្ទុយមកវិញ នៅអាស៊ីអាគ្នេយ៍ ទីក្រុង និងរដ្ឋ មានព្រំប្រទល់ដែនស្ទើរតែរួមជាមួយគ្នា។ ទីក្រុងនីមួយៗមានមេដឹកនាំ ក៏ដូចជាអភិបាលមួយរូប ហើយឋានានុក្រមរបស់មេដឹកនាំទាំងនេះដូចទៅនឹងឋានានុក្រមរបស់ទីក្រុងផងដែរ ។ ស្ត្រី និងក្រុមជាតិសាសន៍ភាគតិចមួយចំនួនអាចនឹងបង្កើតនូវប្រព័ន្ធតម្លៃឯករាជ្យមួយដែលអំណោយផលដល់ផ្នែកពាណិជ្ជកម្ម ប៉ុន្តែសម្រាប់ទីក្រុងទាំងមូលក្នុងនាមជាអង្គភាពមួយពិតជាមានការលំបាកណាស់ក្នុងការធ្វើដូច្នេះ ។

ទោះជាយ៉ាងណាក៏ដោយ ទីក្រុងអោបក្រសោបទាំងទីផ្សារ ក៏ដូចជាព្រះរាជវាំង ហើយកន្លែងនីមួយៗមាននូវតម្លៃរៀងៗខ្លួន ។ នាពេលនោះ ពេលដែលការរីកចម្រើនផ្នែកពាណិជ្ជកម្មកាន់តែលឿនពិសេសថែមទៀតនោះយើងអាចឃើញថាទីផ្សារអាចទាញយកផលប្រយោជន៍សំខាន់ៗជាច្រើនប្រជែងនឹងព្រះរាជវាំង ។ ការលើកឡើងរបស់ ចិន អំពីរឿង «ហីកាយ៉ាត បាយាន ពុឌីម៉ែ -Hikayat Bayan Budiman » នាសតវត្សរ៍ទី ១៦ ដែលនិយាយពីឈ្មួញម្នាក់ដែលធ្វើដំណើរចាកចេញទៅធ្វើជំនួញផ្លូវឆ្ងាយដោយទុកនូវសត្វសេកមួយក្បាលដើម្បីឲ្យឃ្លាំមើលប្រពន្ធរបស់គាត់ក្រែងលួចមានសាហាយនោះ ប្រហែលជាលទ្ធផលរបស់ទស្សនៈរួមស្ដីពីភាពអត្តានិយម និងការគិតតែពីផលចំណេញដែលទើបលេចឡើងនៅក្នុងក្រុងម៉ាឡាកា ដែលមិនអាចទៅរួចដោយងាយនោះទេ (Johns ១៩៧៩ : ២១២, cf. Day ១៩៨៣ :១៤៨-៤៩) ។ នាពេលថ្មីៗនេះ Lombard (១៩៩0 II : ១៥៥-៦២) បានបន្ថែមនូវករណីសំខាន់ជាងនេះមួយទៀតក្នុងការបកស្រាយនូវទស្សនៈអំពីទំនួលខុសត្រូវរបស់បុគ្គលម្នាក់ៗនៅក្នុងស្នាដៃរបស់ ហាំហ្សា ហ្វាំស៊ូរី (Hamzah Fansuri) និង Bukhari នៅទីក្រុងចូហរនៅប្រហែលឆ្នាំ ១៦០០ ដែលគេពិបាករកអត្ថបទណាដែលបរិយាយឲ្យបានល្អដូចនេះណាស់ទាំងអត្ថបទពីមុនៗ ក៏ដូចជាអត្ថបទក្រោយៗដែរ ។ ម្ដងហើយម្ដងទៀតហាំហ្សា បានប្រដូចអ្នកអានរបស់គាត់ទៅនឹងឈ្មួញត្រាច់ចរ ដែលធ្វើដំណើរឆ្លងកាត់មហាសាគរក្នុងការស្វែងរកចំណេះដឹង ហើយគាត់ក៏បានជំរុញឲ្យអ្នកអានរបស់គាត់ «ដឹងអំពីខ្លួនឯង» ផងដែរ (កំណាព្យ ៧២, ៨០, ១១២, ១១៦; Sharabu'l Ashiqin: ៣០៥, ៣០៨-០៩) ។ អត្ថបទផ្សេងៗជាច្រើនទៀតនាសម័យកាលនោះបានឆ្លុះបញ្ចាំងឲ្យឃើញពីសហគមន៍ឈ្មួញចល័តដែលស្គាល់ច្បាស់អំពីតម្លៃឥរិយាបថ និងទំនួលខុសត្រូវសីលធម៌របស់ខ្លួន ។

*ក្រមច្បាប់ម៉ាឡាកា ច្បាប់ផ្លូវសមុទ្ររបស់ម៉ាឡេ កំណាព្យស្តីពីសង្គ្រាមនៅទីក្រុងម៉ាកាសសាររបស់ អ៊ិនហ្សិ អាមីន* (Entji Amin) *និង «ក្រមសីលធម៌មូស្លីម» របស់ជ្វា គឺជាឧទាហរណ៍ដ៏ជាក់ស្តែង ។ ច្បាប់ចុងក្រោយគេនេះសង្កត់ធ្ងន់ទៅលើភាពឧស្សាហ៍ព្យាយាមភាពពេញចិត្តនឹងជីវិតរស់នៅសាមញ្ញ និងការធ្វើទានហើយក៏ទំនងជារំពឹងថាមនុស្សគ្រប់រូបនឹងគិតថាអ្នកផ្លាស់សាសនាទៅជាជនមូស្លីមនឹងមានការកាន់តែកំណាញ់ជាងកាលដែលពួកគេជាអ្នកបាហ្កានទៅទៀត* (Drewes*១៩៧៨ : ២៨-៣៧*) *។ ដើម្បីបង្ហាញឲ្យឃើញថាតើទស្សនៈទៅលើជាតិសាសន៍មានការប្រែប្រួលទៅតាមពេលវេលាប៉ុណ្ណា យើងគ្រាន់តែលើកយកសម្រង់សេចក្តីរបស់មន្ត្រីហូឡង់ម្នាក់ (ប្រជាជនទូទៅ) ដែលបានរិះគន់ថា ÷ «ជនជាតិជ្វាអាចលក់ឪពុកបង្កើតរបស់ខ្លួនដើម្បីប្តូរនឹងការរកស៊ីបន្តិចបន្តួចតែប៉ុណ្ណោះ» គឺជាការគ្រប់គ្រាន់ស្រេចទៅហើយ*(Heemskerck *១៦០០ : ៤៥១*)*។*

*បន្ថែមទៅលើកម្លាំងរបស់ទីផ្សារ គេក៏ឃើញមាននូវកម្លាំងរបស់ក្រុមមនុស្សអានាធិបតេយ្យនៅក្នុងទីក្រុងផងដែរ ដែលជាកត្តាម្តងម្កាលនៅតាមបណ្តាទីក្រុងធំៗ ។ នៅទីក្រុងប៉ាតានី «ការបះបោររបស់ពួកទាសករ» ជនជាតិជ្វានាឆ្នាំ ១៦១៣ បានវាយកម្ទេចទីក្រុង ហើយបណ្តេញពួកអ្នកមានឥទ្ធិពលទាំងឡាយឲ្យចេញពីគេហដ្ឋានរបស់ខ្លួន* (Floris *១៦១៥ : ៩៤–៩៥*) *។ នៅទីក្រុងអាចេនាពាក់កណ្តាលសតវត្សរ៍ទី ១៧ ប្រជាជនរស់នៅក្នុងទីក្រុងបានប្រមូលផ្តុំគ្នាតវ៉ានៅតាមដងផ្លូវជាច្រើនលើកក្នុងពេលមានព្រឹត្តិការណ៍តឹងតែងនីមួយៗ ។ ប្រជាជនសាមញ្ញប្រហែលជាបានសម្លាប់ អ៊ុឡាម៉ា រ៉ានីរី* (Ulama Raniri) *ដែលកាន់សាសនាតឹងរឹងដែលគ្មានប្រជាប្រិយ៍បាត់ទៅហើយប្រសិនបើគាត់មិនបានគេចចេញពីទីក្រុងនៅចុងឆ្នាំ ១៦៤៣ ទេនោះ* (Ito *១៩៧៨*) *។ ជម្លោះជាតិសាសន៍ និងសាសនាជារឿយៗកើតឡើងជាការប្រយុទ្ធគ្នានៅតាមដងផ្លូវនានា ។ ព្រឹត្តិការណ៍ថ្មីៗនេះគឺជាព្រឹត្តិការណ៍ទីក្រុងហើយអាចបង្កជាឧបសគ្គដល់ការគ្រប់គ្រងរបស់ស្តេច ក៏ប៉ុន្តែពួកគេមានការលំបាកក្នុងការធ្វើស្ថាប័ននីយកម្មនូវអំណាចរបស់ខ្លួន ។ ការបរិយាយលម្អិតអំពីទំនាស់រវាងលទ្ធិផ្តាច់ការ និងលទ្ធិពហុនិយម និងមានបកស្រាយនៅជំពូកទី ៤ ។*

# ជំពូកទី ៣

# បម្រែបម្រួលលំហទីក្រុង ការធ្វើនគរូបនីយកម្មអាស៊ីអាគ្នេយ៍ ក្នុងយុគសម័យសកលភាវូបនីយកម្មដ៏ងាយនឹងប្រែប្រួល

*ដោយ ផាល អេហ្វ ឃេយ៍*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* Changing Spaces: Southeast Asian Urbanization in an Era of Volatile Globalization ។

*អត្ថបទនេះ ដកស្រង់ចេញពីសៀវភៅ ៖អាស៊ីអាគ្នេយ៍ក្នុងការប្រែប្រួល : ការផ្លាស់ប្តូរភូមិសាស្ត្រ។ រក្សាសិទ្ធិ គ.ស. ២០០០ ដោយគ្រឹះស្ថានបោះពុម្ព វិទ្យាស្ថានសិក្សាតំបន់អាស៊ីអាគ្នេយ៍*

## CHAPTER 3 :

Changing Spaces: Southeast Asian Urbanization in an Era of Volatile Globalization

Kelly, Philip F. & McGee, T.G.

(*Southeast Asia Transformed: A Geography of Change*)

**Copyright © 2000 by Institute of Southeast Asian Studies**

បកប្រែដោយ លោក ឈ៊ាត ស្រ៊ាង

# ជំពូកទី ៣
# បម្រែបម្រួលលំហាធីក្រុង ការធ្វើនគរូបនីយកម្មអាស៊ីអាគ្នេយ៍ ក្នុងយុគសម័យសកលភាវូបនីយកម្មដ៏ងាយនឹងប្រែប្រួល

## សេចក្ដីផ្ដើម

ការសិក្សាអំពីតំបន់អាស៊ីអាគ្នេយ៍ពីសម័យបុរាណ និងបច្ចុប្បន្ននេះបានបង្ហាញនូវភាពដូចគ្នាគួរឲ្យចាប់អារម្មណ៍មួយចំនួន ។ ចំណុចសំខាន់បំផុតនៃការសិក្សាដំបូងរបស់ពួកបស្ចិមប្រទេសទៅលើតំបន់អាស៊ីអាគ្នេយ៍ គឺផ្ដោតសំខាន់ទៅលើភាពងាយរងឥទ្ធិពលពីខាងក្រៅ ។ ការស្រាវជ្រាវមួយភាគធំផ្ដោតលើភាពខុសគ្នាខាងភូមិសាស្ត្ររួមមានបទពិសោធប្រវត្តិសាស្ត្រ វប្បធម៌ និងបរិដ្ឋានរូបវន្តនៅក្នុងតំបន់នោះ ។ អ្នកនិពន្ធមួយចំនួនយល់ថា «ភាពខុសគ្នា» គឺជាប្រកពសំខាន់បំផុតនៃអត្តសញ្ញាណតាមតំបន់ ដែលពាក្យថា «រួមគ្នានៅក្នុងភាពខុសគ្នា» មានប្រើដំបូងបង្អស់នៅក្នុងឯកសាររបស់លោក ប្រូក (Broeck គ.ស.១៩៤៤) ។ គំនិតបង្កប់នៅក្នុងន័យនៃភាពខុសគ្នានេះគឺភាពងាយទទួលឥទ្ធិពល ភាពផុយស្រួយ និងភាពងាយរងគ្រោះខាងផ្នែកភូមិសាស្ត្រនយោបាយ ។ ឆាយ ហ្វីសឺរ (Charles Fisher) បានពណ៌នាតំបន់អាស៊ីអាគ្នេយ៍ថាជា «បន្ទាត់ព្រំដែន» រវាងមហាវប្បធម៌ធំពីរក្នុងលោក ដែលមានអាស៊ីខាងត្បូង និងចិន ។ ហើយព្រំដែននេះជាព្រំដែនចំហដែលអាចឲ្យកម្លាំងមកពីក្រៅហូរចូលមកបាន និងធ្វើឲ្យវប្បធម៌អាស៊ីអាគ្នេយ៍ដែលគេគិតថាជាវប្បធម៌ខ្សោយនោះក្លាយទៅជាវប្បធម៌រណប (ហ្វីសឺ គ.ស.១៩៦៤) ។

បច្ចុប្បន្ននេះអ្នកប្រាជ្ញភាគច្រើននឹងប្រានចោលពេញទំហឹងនូវការរិះគន់ពុំសមហេតុផល ទៅលើលក្ខណៈពិសេស និងបូរណភាពខាងវប្បធម៌របស់អាស៊ីអាគ្នេយ៍ ។ [១] ប៉ុន្តែគំនិតដែលថាអាស៊ីអាគ្នេយ៍ជាតំបន់ដែលងាយទទួលរងគ្រោះនោះ នៅតែជាលក្ខណសម្បត្តិរបស់តំបន់នេះដដែល ។ ជាពិសេស ការពិពណ៌នាទាំងនេះមាននៅក្នុងការពិពណ៌នាទូទៅ និងការពិពណ៌នាខាងផ្នែកនយោបាយនៃតំបន់នៅក្នុងបរិបទសេដ្ឋកិច្ចសកលលោក ។ ខណៈដែលបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍បានធ្វើសមាហរណកម្មសេដ្ឋកិច្ចជាតិរបស់ខ្លួនយ៉ាងលឿនទៅក្នុងលំហូរទុន ជំនួញ អន្តោប្រវេសន៍នៅលើសកលលោកជាដើមនោះ គំនិតដែលថាអាស៊ីអាគ្នេយ៍ គឺជា «តំបន់នៅក្រោមខ្យល់» នៃពាណិជ្ជកម្មសកលលោកបានលេចឡើងជាថ្មីម្ដងទៀត ។ តាមពិតទៅការគិតបែបនេះ គឺជាផ្នែកមួយនៃអ្វីដែលយើងហៅថា បរិបទនៃសកលភាវូបនីយកម្មដែលមានប្រើនៅក្នុងប្រទេសមួយចំនួនដើម្បីធ្វើឲ្យគោលនយោបាយសេដ្ឋកិច្ច និងសង្គមមានលក្ខណៈស្របច្បាប់ (ExlII Kelly គ.ស.១៩៩៧) ។ ទោះបីជាដូច្នេះក៏ដោយ ការចូលរួម និងភាពងាយរងឥទ្ធិពលរបស់តំបន់នេះបញ្ជាក់យ៉ាងច្បាស់ថាមានឥទ្ធិពលខាងផ្នែកសម្ភារៈយ៉ាងធ្ងន់ដូចដែលការធ្លាក់ចុះផ្នែកហិរញ្ញវត្ថុនៃគ.ស.១៩៩៧ បានបង្ហាញយ៉ាងដូច្នេះដែរ។

ដំណើរការនគរូបនីយកម្ម គឺជាកត្តាសំខាន់នៃការប្រសព្វរវាងសេដ្ឋកិច្ចជាតិ និង «រូបវន្តនៃលំហូរ» ថ្នាក់សកលលោក ។ ការចូលរួមរបស់តំបន់អាស៊ីអាគ្នេយ៍ទៅក្នុងសេដ្ឋកិច្ចសកលលោកមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការផ្លាស់ប្ដូរផ្នែករចនាសម្ព័ន្ធដែលតែងជំរុញឲ្យមានការធ្វើនគរូបនីយកម្មនៅក្នុងតំបន់កាន់តែខ្លាំងឡើង ។ ទោះជាយ៉ាងដូច្នេះក៏ដោយ យើងសូមធ្វើការអះអាងថា គេពុំត្រូវយល់ឃើញថា ដំណើរការនគរូបនីយកម្មគ្រាន់តែជាមូលធនថ្នាក់សកលលោក ដែលកំណត់ច្បាស់ក្នុងបរិដ្ឋានដែលគេបង្កើតឡើងណាមួយនោះទេ ។ ផ្ទុយទៅវិញ

គេត្រូវបកស្រាយថា ដំណើរការនគរូបនីយកម្ម គឺជាដំណើរការមួយដែលកើតមានឡើងក្នុងកម្រិតច្រើន ដែលអាចធ្វើការវិភាគបាន ។ ដំណើរការនេះរួមមានសេដ្ឋកិច្ច នយោបាយ និងវប្បធម៌ថ្នាក់ជាតិ ការកេពប្រសព្វកម្រិតតំបន់ជាមួយតំបន់ខ្ពង់រាបដែលប្រកបរបរកសិកម្ម និងបណ្តាទ្រង់ទ្រាយផ្សេងៗទៀតរបស់ទីក្រុង ។

ដោយហេតុនេះហើយ យើងត្រូវយកចិត្តទុកដាក់ទៅលើបទពិសោធខាងវប្បធម៌ និងប្រវត្តិសាស្ត្រ និងការរៀបចំផ្នែកស្ថាប័នរបស់សង្គមផ្សេងៗគ្នា ។ ដូចមានបង្ហាញនៅក្នុងតារាង ៧.១ ខាងក្រោមនេះ បរិបទថ្នាក់ជាតិរបស់ប្រទេសភូមា ឡាវ កម្ពុជា និងវៀតណាមបានបង្កើតឲ្យមាននគរូបនីយកម្មកម្រិតទាប ដែលបង្ហាញឲ្យឃើញនូវភាពយឺតយ៉ាវរបស់បណ្តារដ្ឋទាំងនេះក្នុងការចូលរួមក្នុងសកលភាវូបនីយកម្ម និងដែលបង្ហាញឲ្យឃើញនូវកង្វះខាតខាងទីតាំងដែលអាចទាក់ទាញឲ្យមានវិនិយោគទុនថ្នាក់សកលលោកបាន ។ ម្យ៉ាងវិញទៀត ក្នុងផ្នែកសេដ្ឋកិច្ចទីផ្សាររបស់តំបន់អាស៊ីអាគ្នេយ៍ រដ្ឋបានជួយសម្របសម្រួលឲ្យមានការវិនិយោគជាសកលលោក ។

**តារាង៧.១ ៖ កម្រិតនៃការកើនគរូបនីយកម្មនៅអាស៊ីអាគ្នេយ៍ ១៩៥០-២០១០**

| ប្រទេស | ១៩៥០ | ១៩៦០ | ១៩៧០ | ១៩៨០ | ១៩៩០ | ២០០០ | ២០១០ |
|---|---|---|---|---|---|---|---|
| ប្រ៊ុយនេ | ៤៣.៤ | ៤២.៨ | ៤៤.០ | ៤៩.៧ | អត់មាន | អត់មាន | អត់មាន |
| កម្ពុជា | ៧.៨ | ១០.១ | ១១.៧ | ១២.៤ | ១៧.៦ | ២៤.១ | ៣១.៦ |
| ឥណ្ឌូនេស៊ី | ១២.២ | ១៤.៩ | ១៧.១ | ២២.២ | ៣០.៦ | ៤០.៣ | ៤៩.៧ |
| ឡាវ | ៦.៥ | ៨.៥ | ៩.៦ | ១៣.៤ | ១៨.៦ | ២៥.១ | ៣២.៦ |
| ម៉ាឡេស៊ី | ២៤.៥ | ៣០.០ | ៣៣.៥ | ៤២.០ | ៤៩.៨ | ៥៧.៥ | ៦៤.៤ |
| ភូមា | ១២.៩ | ១៤.៣ | ២២.៨ | ២៤.០ | ២៤.៨ | ២៨.៤ | ៣៥.៤ |
| ហ្វីលីពីន | ១៩.៨ | ២១.៤ | ៣៣.០ | ៣៧.៥ | ៤៨.៨ | ៥៩.០ | ៦៦.៦ |
| សិង្ហបុរី | ១០០.០ | ១០០.០ | ១០០.០ | ១០០.០ | ១០០.០ | ១០០.០ | ១០០.០ |
| ថៃ | ១០.០ | ១១.៤ | ២០.៨ | ២៤.៥ | ៣២.០ | ៤០.០ | អត់មាន |
| វៀតណាម | អត់មាន | អត់មាន | ១៨.៣ | ១៩.២ | ១៩.៩ | ២២.៣ | ២៧.៤ |
| អាស៊ីអាគ្នេយ៍ | ១៣.៦ | ១៦.៦ | ២០.៤ | ២៤.៣ | ៣០.២ | ៣៧.៣ | ៤៤.៨ |

ប្រភព ៖ ម៉ាកហ្គី (McGee គ.ស. ១៩៦៧ ១៩៧៩) ចូនស៍ (Jones គ.ស. ១៩៩៧) និងអ៊ីអេសស៊ីអេភី ( ESAP គ.ស. ១៩៩២)

ទំនាក់ទំនងនេះបានបង្កើតឲ្យមានការរៀបចំតំបន់សេដ្ឋកិច្ចសារជាថ្មី ដោយមានកម្លាំងពលកម្មមិនមែនកសិកម្មកើនឡើងយ៉ាងគំហុក និងធ្វើឲ្យមានការចូលរួមពីខាងផ្នែកដទៃដែលមិនមែនកសិកម្មដទៃទៀត ទៅផលិតផលសរុបក្នុងស្រុក (GDP) ។ ដូច្នេះ បណ្តារដ្ឋនៅអាស៊ីអាគ្នេយ៍ដីគោកដែលធ្វើសមាហរណកម្មយ៉ាងយឺត រួម

មានវៀតណាម ភូមា ឡាវ និងកម្ពុជា) និងបណ្តារដ្ឋដែលធ្វើសមាហរណកម្មលឿន (រួមមានសិង្ហបុរី ម៉ាឡេ ថៃ ហ្វីលីពីន និងប្រ៊ុយនេ) ។ រីឯប្រទេសឥណ្ឌូនេស៊ីស្ថិតនៅចន្លោះក្រុមប្រទេសទាំងពីរនេះ ។ ក្នុងនាមជាប្រទេសធំជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ ការធ្វើនគរូបនីយកម្មនៅឥណ្ឌូនេស៊ីមានកម្រិតខុសគ្នាខ្លាំងរវាងតំបន់មួយ និងតំបន់មួយ ដោយនៅកោះជ្វាកំពុងខិតទៅរកកម្រិតនៃការធ្វើសមាហរណកម្មលឿននៅខណៈពេលដែលបណ្តាតំបន់ឆ្ងាយៗនៃប្រទេសនេះមានកម្រិតនគរូបនីយកម្មទាបក្រៃលែង ។ ដូច្នេះខណៈដែលកម្រិតថ្នាក់ជាតិមានសារសំខាន់សម្រាប់ឲ្យយើងយល់ពីដំណើរការនគរូបនីយកម្ម ក្នុងដំណើរការនៅកម្រិតថ្នាក់តំបន់ ក៏មានដំណើរការសង្គមដែលធ្វើការសម្របសម្រួល និងកែប្រែផលប៉ះពាល់នៃលំហូរសកលលោកមកលើប្រព័ន្ធទីក្រុងដែរ ។

នៅក្នុងជំពូកនេះយើងសូមលើកឡើងការវិភាគវែកញែករបស់យើងតាមលំដាប់ដូចខាងក្រោម ។ ពីរផ្នែកខាងដើមពិភាក្សាអំពីការពិពណ៌នាសង្ខេបនៃការវិវឌ្ឍជាប្រវត្តិសាស្ត្រនៃដំណើរនគរូបនីយកម្មនៅនៅអាស៊ីអាគ្នេយ៍តាំងពីសម័យមុនអាណានិគម និងសម័យក្រោយសង្គ្រាមពីចន្លោះឆ្នាំ ១៩៤៥ និង ១៩៩០ ។ ជាពិសេសយើងនឹងបង្ហាញអំពីដំណើរការនៃការធ្វើសមាហរណកម្មរបស់តំបន់ទៅក្នុងសកលលោកដែលមានសន្ទុះខ្លាំងចាប់ពីទសវត្សឆ្នាំ ១៩៦០ មក[២] ។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការនគរូបនីយកម្មមានទំនាក់ទំនងយ៉ាងច្បាស់ជាមួយនឹងការធ្វើសកលភាវូបនីយកម្មផ្នែកសកម្មភាពសេដ្ឋកិច្ចតាំងពីសតវត្សឆ្នាំ ១៩៩០ ។ នៅផ្នែកបន្ទាប់ទៀតនៅក្នុងជំពូកនេះ យើងនឹងបង្ហាញអំពីទ្រង់ទ្រាយភូមិសាស្ត្រមួយចំនួនដែលដំណើរការនេះបានបង្កើតឡើង ។ ប៉ុន្តែ ដើម្បីឲ្យយលបានថាដំណើរការនគរូបនីយកម្មនាពេលបច្ចុប្បន្ន ជាលទ្ធផលនៃសកលភាវូបនីយកម្មនោះគេត្រូវមើលទៅលើការសន្និដ្ឋានលក្ខណៈជាទ្រឹស្តី និងលទ្ធផលគោលនយោបាយមួយចំនួនជាក់លាក់ ។ នៅក្នុងផ្នែកទី ៥ យើងនឹងធ្វើការបង្ហាញពី «ទីក្រុងដែលកំពុងតែធ្វើសកលភាវូបនីយកម្ម» ក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលរួមមាន (១) ក្រុងលំដាប់ពិភពលោក (២) ទីក្រុងរីកលូតលាស់បែបពហុកោណ និង (៣) ទីក្រុងរណប និងរបៀង ។ ខណៈដែលវិធីសាស្ត្រទាំងនេះផ្តល់ជាចំណេះដឹងល្អៗឲ្យយល់ពីដំណើរការនគរូបនីយកម្មនោះ យើងនឹងបកស្រាយនៅក្នុងផ្នែកទីបន្ទាប់មកទៀតថា យើងត្រូវយល់ថាដំណើរការនគរូបនីយកម្មមិនមែនគ្រាន់តែជាការប្រព្រឹត្តឡើងនៅក្នុងតំបន់ជាកម្រិតសកលនោះទេ ។ ផ្ទុយទៅវិញ គេត្រូវយល់ថាដំណើរការនគរូបនីយកម្មជាអន្តរកម្មដែលមានលក្ខណៈស្មុគស្មាញនៃបណ្តាដំណើរការសង្គមក្នុងកម្រិតជាច្រើន ។ ដូច្នេះយើងនឹងដាក់ចេញនូវទស្សនវិស័យខ្លះៗសម្រាប់ការធ្វើនគរូបនីយកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជម្រើសផ្នែកគោលនយោបាយដែលគួរទទួលយកសម្រាប់អនាគត ។

## ការវិវឌ្ឍជាប្រវត្តិសាស្ត្រនៃដំណើរការនគរូបនីយកម្មនៅអាស៊ីអាគ្នេយ៍[៣]

តំបន់អាស៊ីអាគ្នេយ៍តែងមានប្រពៃណីខ្ពង់ខ្ពស់ខាងនគរូបនីយកម្ម ។ មុនពេលមានទំនាក់ទំនងជាមួយពួកលោកខាងលិច ទីក្រុងពីរសណ្ឋានបានរីកលូតលាស់ឡើង ។ ការរីកលូតលាស់នេះទំនងជាកើតឡើងដោយសារឥទ្ធិពលរបស់ចិន និងឥណ្ឌាក្នុងការគ្រប់គ្រងនយោបាយដែលរីកសាយភាយមកក្នុងតំបន់តាំងពីសតវត្សទី ១ នៃគ្រិស្តសករាជ ។ ទីក្រុងពីរប្រភេទបានលេចចេញជារូបរាងឡើង ។ ទីក្រុងប្រភេទទី ១ គឺជាទីក្រុងជំនួញមានដូចជាក្រុងមេឡាកា និងប៉ាឡឹមបាង (Palembang) ដែលពឹងផ្អែកលើជំនួញអន្តរតំបន់រវាងបណ្តាអាណាចក្រក្នុងតំបន់ និងមហាអរិយធម៌ពីរនៅអាស៊ីរួមមានឥណ្ឌា និងចិន ។ ទីក្រុងប្រភេទទី ២ ជាទីក្រុងសក្ការៈដែលស្ថាបនាឡើងសម្រាប់

ជា «និមិត្តរូបខ្ពង់ខ្ពស់របស់រដ្ឋតាមបែបសកលសាស្ត្រដែលភ្ជាប់ទំនាក់ទំនងរវាងភពផែនដី និងឋានទេវតា» ហើយការធ្វើកសិកម្ម គឺជាមូលដ្ឋានសេដ្ឋកិច្ចសំខាន់បំផុតរបស់ទីក្រុងប្រភេទទីពីរនេះ ។ ទីក្រុងសក្ការៈទាំងនេះមានជាអាទិ៍ក្រុងអង្គរធំរបស់ខ្មែរ ដែលជាក្រុងសាងឡើងសម្រាប់ព្រះអាទិទេព ដែលភាគច្រើនសាងឡើងនៅសតវត្សទី ១២ ។

ទោះជាយ៉ាងនេះក៏ដោយ គឺពួកមហាអំណាចអឺរ៉ុបនោះទេ ដែលជាអ្នកលើកកម្ពស់ការស្ថាបនាបណ្តាញមូលដ្ឋាននៅទីក្រុងចាប់ពីសតវត្សទី ១៦ រហូតមក ។ ក្នុងចន្លោះឆ្នាំ ១៥០០-១៨០០ មហាអំណាចអឺរ៉ុបជាទូទៅចាប់អារម្មណ៍តែទៅលើការដណ្តើមគ្រប់គ្រងផ្នែកជំនួញក្នុងស្រុកតែប៉ុណ្ណោះ ហើយពុំមានការយកចិត្តទុកដាក់ច្រើនលើការពង្រីកអំណាចក្នុងការកាន់កាប់ដីធ្លីនោះទេ លើកលែងតែពួកអេស្ប៉ាញនៅហ្វីលីពីននិងពួកហូឡង់នៅជ្វាដែលបានកសាងបណ្តាញទីក្រុងយ៉ាងច្រើន ។ គោលបំណងចម្បងរបស់មហាអំណាចអាណានិគមគឺដណ្តើមគ្រប់គ្រងលើផ្លូវសមុទ្រ និងចាប់អារម្មណ៍ច្រើនលើការស្ថាបនាកំពង់ផែដូចជាផែនៅមេឡាកា បាតាវីយ៉ា (Batavia) និងម៉ានីល (Manila) សម្រាប់ធ្វើជាមូលដ្ឋាន និងធ្វើជាផែផ្លាស់ប្តូរទំនិញសម្រាប់សកម្មភាពជំនួញរបស់គេ ។

នៅចុងសតវត្សទី ១៨ ស្ថានភាពបានចាប់ផ្តើមប្រែប្រួល ។ បដិវត្តន៍ឧស្សាហកម្មនៅអឺរ៉ុបខាងលិចដែលជំរុញឲ្យមានតម្រូវការខាងទីផ្សារ និងវត្ថុធាតុដើមបាននាំឲ្យមានការផ្លាស់ប្តូរពីការគ្រប់គ្រងផ្លូវសមុទ្រទៅការគ្រប់គ្រងដីគោកវិញ ។ ការផ្លាស់ប្តូរនេះជំរុញឲ្យមានការពង្រីកបណ្តាញនៃការតាំងលំនៅកាន់តែធំទូលាយជាងមុន ។ កំពង់ផែ ប្រព័ន្ធដឹកជញ្ជូន និងមជ្ឈមណ្ឌលរដ្ឋបាលថ្មីៗបង្កើតបានជាបណ្តាញរបស់រចនាសម្ព័ន្ធក្រុមក្រុងថ្មីៗ ។ ជាទូទៅការតាំងលំនៅក្នុងទ្រង់ទ្រាយភ្ជោះ (រួម) បានកើតឡើង ហើយការតាំងលំនៅមានឥទ្ធិពលលើសគេបង្អស់គឺក្រុងកំពង់ផែដែលមានមុខងារច្រើន ដូចជា ក្រុងកំពុងផែសិង្ហបុរី បាតាវីយ៉ា (សព្វថ្ងៃជា ចាកាតា) ក្រុងម៉ានីល រ៉ង់ហ្គូន(សព្វថ្ងៃជា យ៉ាងហ្គូន) សាយហ្គន-ចូឡុន (ក្រុងហូជីមិញសព្វថ្ងៃ) និងក្រុងបាងកក ។ មកដល់ដើមទសវត្សឆ្នាំ ១៩៤០ក្រុងទាំងអស់នេះបានចាប់ផ្តើមដើរតួនាទីយ៉ាងសំខាន់ក្នុងរចនាសម្ព័ន្ធទីក្រុងនៅតាមតំបន់របស់ពួកគេ ។ ការតាំងទីលំនៅលំដាប់ទី ២ រួមមានមជ្ឈមណ្ឌលតូចៗខាងផ្នែករដ្ឋបាល តំបន់រុករករ៉ែ និងផ្នែកសេវាកម្មដែលមាននៅក្នុងប្រទេសភាគច្រើន ប៉ុន្តែចំនួនប្រជាជន និងមុខងាររបស់កន្លែងតាំងលំនៅទាំងនេះមានចំនួនតិចតួចជាងក្រុងធំៗខាងលើឆ្ងាយណាស់ ។ លើសពីនេះទៀត ទោះតំបន់តាំងលំនៅទាំងនេះមានតួនាទីសំខាន់ក្នុងទំនាក់ទំនងជាមួយតំបន់ដាច់ស្រយាលតាមជនបទក៏ដោយ ក៏តំបន់ទាំងនេះមិនសំខាន់ដូចមជ្ឈមណ្ឌលក្រុងធំៗនោះដែរ ។

ក្រុងធំៗទាំងនេះមានចំនួនប្រជាជនរស់នៅច្រើន និងមានទំហំដីធំជាង ២ ទៅ ៣ ដងនៃក្រុងធំលំដាប់បន្ទាប់នេះទៀតផង ។ មកដល់ដើមទសវត្សឆ្នាំ១៩៤០ ក្រុងរ៉ង់ហ្គោន មានទំហំធំជាងក្រុង ម៉ាន់ដាឡាយ ៣ ដង ហើយនៅឥណ្ឌូចិន សាយហ្គន-ជូឡុង បានក្លាយទៅជាក្រុងដ៏ធំមានប្រជាជនច្រើនជាងក្រុងហាន់ណូយទៅទៀត ។ ប្រទេសហ្វីលីពីនក៏មានលំនាំដូចគ្នានេះដែរ ដោយក្រុងម៉ានីលធំជាងជិត ៥ ដងនៃក្រុងសេប៊ូ ។ នៅឧបទ្វីបម៉ាឡេ វិញក្រុងសិង្ហបុរី (ដែលជាក្រុងធំបំផុតនៅដែនអាណានិគមម៉ាឡេរបស់អង់គ្លេស) មានប្រជាជនច្រើនជាងក្រុងគួឡាឡាំពួដ៏សម្បើម ។ មានតែនៅប្រទេសឥណ្ឌូនេស៊ីមួយទេដែលមិនមានទ្រង់ទ្រាយការលូតលាស់ក្រុងបែបនេះ ដោយហេតុថាក្រុងហ្សាការតាមានប្រជាជនប្រហាក់ប្រហែលនឹងក្រុងធំៗនៅជ្វាដែរ ដូចជាក្រុងស៊ុរ៉ាបាយ៉ា និងយោគយ៉ាការតាជាដើម ។

រចនាសម្ព័ន្ធក្រុងពិសេសរបស់តំបន់ គឺជាក្រុងដ៏ធំមួយមានប្រជាជនរស់នៅជាង ១ លាននាក់ និងមានការ

*តាំងលំនៅរាងតូចៗដែលមិនមានមុខងារច្រើន ។ សកម្មភាពក្នុងក្រុងទាំងនេះរួមមានសកម្មភាពធំៗខាងរដ្ឋបាល សេដ្ឋកិច្ច និងសង្គមរបស់មហាអំណាចអាណានិគម ។ ជំនួញមាននៅពាសពេញក្នុងទីក្រុងទាំងនេះ ដែលដើរតួនាទីជាកន្លែងសម្របសម្រួលការនាំទំនិញចេញចូល ។ ដោយសារតែឧស្សាហកម្មទ្រង់ទ្រាយធំមានតិចតួច រចនាសម្ព័ន្ធការងារនៅទីក្រុងទាំងនេះបានបង្ហាញតាមរយៈប្រជាជនភាគច្រើនពិសេសពួកអន្តោប្រវេសន្ត និងចិនដែលធ្វើការខាងផ្នែកសេវាកម្ម ។ ដូច្នេះ គេបានប៉ាន់ស្មានថា មកដល់ចុងទសវត្សឆ្នាំ ១៩៣០ ជនជាតិចិន នៅសិង្ហបុរីមាន ៧៧% នៅបាងកកមានជាង ៥០% នៅសាយហ្គន-ចូឡុនមាន ៣០% និងនៅម៉ានីល និងហ្សាការតាមានពី ៥-១០% ។ នៅក្រុងរ៉ង់ហ្គូនមានជនជាតិឥណ្ឌាជាង ៧០% (សូមអានឯកសាររបស់ហ្វ្រាយអឺ Fryer គ.ស. ១៩៧៩) ។ ស្ថានភាពនេះបានបង្កើតឲ្យមានជាសង្គមទីក្រុងបែបពហុនិយម និងមានជនជាតិភាគតិចខុសៗគ្នាយ៉ាងច្រើន (យោងតាមឯកសាររបស់ ហ៊ឺនីវ៉លធុរ គ.ស. ១៩៤៨) ។ ដូច្នេះ ប្រជាជនដែលជាអ្នកស្រុកអាយភាគច្រើនរស់នៅតាមទីជនបទ និងពុំបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅទីក្រុងដែលមានប្រាក់ចំណូលច្រើននោះទេ ។ទោះជាយ៉ាងនេះក៏ដោយ ប្រជាជនស្រុកអាយនេះហើយដែលមានអំណាចខាងនយោបាយ ។*

*រចនាសម្ព័ន្ធសង្គមក្នុងទីក្រុងដែលកើតចេញពីលំនាំនយោបាយ និងសេដ្ឋកិច្ចខាងលើនេះ គឺជាការចម្លងតាមរចនាសម្ព័ន្ធអំណាចរបស់ពួកអាណានិគម ។ ជនមួយក្រុមតូចដែលរួមមានអ្នកគ្រប់គ្រងពាណិជ្ជកម្ម និងអ្នករដ្ឋបាលជនជាតិអឺរ៉ុប និងជនអន្តោប្រវេសន្តរួមមានឈ្មួញកណ្តាលចិន ពួកអ្នកជំនាញជាតិជ្វីស អារ៉ាប់ និងឥណ្ឌា និងពួកអភិជនស្រុកអាយមកពីត្រកូលខ្ពង់ខ្ពស់ពីរបីអ្នក គឺជាពួកមានវណ្ណៈជាន់ខ្ពស់ស្ថិតនៅក្នុងលំដាប់ខ្ពស់បំផុតនៃរចនាសម្ព័ន្ធសង្គមនេះ ។ មនុស្សមួយភាគធំដែលស្ថិតក្នុងវណ្ណៈកណ្តាល គឺជាអ្នកទីក្រុងជាជនបរទេស ។ ក្រៅពីនេះ មានប្រជាជនអ្នកស្រុកអាយដែលធ្វើការក្នុងជួរកងទ័ព រដ្ឋាភិបាល និងការងារដែលមិនត្រូវការជំនាញ ។*

## នគរូបនីយកម្មនៅអាស៊ីអាគ្នេយ៍សម័យក្រោយសង្គ្រាម ១៩៤៥–១៩៩០

*ការបន្សល់ទុកពីសម័យអាណានិគមឲ្យដល់នគរូបនីយកម្មអាស៊ីអាគ្នេយ៍ មានឥទ្ធិពលយ៉ាងសំខាន់លើទ្រង់ទ្រាយដែលកើតឡើងក្រោយសង្គ្រាមលោកលើកទី ២ ។ តែទោះជាយ៉ាងណា ការបន្សល់ទុកនេះមិនមែនជាឥទ្ធិពលប្រវត្តិសាស្ត្រតែមួយនោះទេ ព្រោះថាដំណើរការវិវឌ្ឍផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គមក្រោយពីបណ្តាប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ទទួលបានឯករាជ្យ ក៏មានឥទ្ធិពលមកលើការកំណត់ទ្រង់ទ្រាយនៃការធ្វើនគរូប-នីយកម្មនោះផងដែរ ។ ការវិវឌ្ឍផ្នែកនគរូបនីយកម្មអាចយកមកពិភាក្សាជាពីរដំណាក់កាល (សូមអានឯកសាររបស់ មែកហ្គី* (McGee *គ.ស. ១៩៩៧)* ។

### ដំណាក់កាលទី១ ៖ នគរូបនីយកម្មនិងជាតិនិយមថ្មីនៅអាស៊ីអាគ្នេយ៍ ១៩៤៥_៦០

*ដំណាក់កាលទី ១ នេះជាដំណាក់កាលនៃការរើខ្លួនឲ្យរួចផុតពីអាណានិគមខាងនយោបាយដោយក្នុងដំណាក់កាលនេះប្រជាជាតិមួយភាគធំយកចិត្តទុកដាក់លើការទាមទារឯករាជ្យពីអតីតមហាអំណាចអាណានិគម និងស្ថាបនាជាតិខ្លួនឲ្យទៅជាប្រជាជាតិស្របច្បាប់ ។ ចំណែកគោលបំណងខាងផ្នែកសេដ្ឋកិច្ចជាទូទៅ គឺជាការចាប់អារម្មណ៍បន្ទាប់បន្សំប៉ុណ្ណោះ ។*

*មកដល់ឆ្នាំ ១៩៦០ (សូមមើលតារាង ៧.១) មានតែប្រទេសសិង្ហបុរី និងប្រ៊ុយណេ ប៉ុណ្ណោះដែលមានកម្រិត*

នៃការធ្វើនគរូបនីយកម្មប្រហាក់ប្រហែលទៅនឹងបណ្ដាប្រទេសអភិវឌ្ឍទាំងឡាយ ។ ប្រទេសទាំងពីរ គឺជារដ្ឋតូចដោយក្នុងនោះសិង្ហបុរី ជារដ្ឋដែលទទួលបានចំណូលពីការងារខាងផែដោះដូរទំនិញឧស្សាហកម្ម និងទេសចរណ៍ ចំណែកឯប្រ៊ុយណេវិញ គឺជាប្រទេសសម្បូរប្រេងហើយមានប្រជាជនប្រមូលផ្ដុំគ្នាច្រើននៅតំបន់បានដារសេរីបេហ្កាវ៉ាន Bandar Seri Begawan ។ មានតែឧបទ្វីបម៉ាឡេមួយគត់ដែលខិតទៅជិតប្រទេសពីរទៀតដែលនៅសម័យក្រោយសង្គ្រាមដោយមានកម្រិតការធ្វើនគរូបនីយកម្មកើនឡើងលឿនដល់ទៅជិត ៣០% មកដល់ឆ្នាំ ១៩៦០ ។ ជាផ្នែកមួយស្ថានភាពនេះបង្ហាញពីការរីកចម្រើននៅចុងទសវត្សឆ្នាំ ១៩៤០ និងដើមទសវត្សឆ្នាំ ១៩៥០ នៅពេលដែលប្រជាជនជាង ១ លាននាក់បានតាំងលំនៅតាមភូមិថ្មីៗ ដែលគេចាត់ទុកថាជាទីក្រុង ។ ដូច្នេះនៅឧបទ្វីបម៉ាឡេស៊ីចំនួននៃតំបន់តាំងលំនៅដែលមានប្រជាជនចាប់ពី ១ ពាន់នាក់ឡើងទៅកើនឡើងពី ១៦៣ ក្នុងឆ្នាំ ១៨៤៧ ដល់ ៤០១ ក្នុងឆ្នាំ ១៩៥៧ ។ ប្រទេសដទៃទៀតមានការធ្វើនគរូបនីយកម្មក្នុងកម្រិតទាបណាស់ជាក់ស្ដែងដូចនៅវៀតណាមខាងជើង និងខាងត្បូង និងប្រទេសហ្វីលីពីន ដែលមានប្រជាជនប្រមាណ១ ភាគ ៤ នៃចំនួនប្រជាជនសរុប ។ ចំណែកប្រទេសដទៃទៀតមានប្រជាជនរស់នៅទីក្រុងមិនដល់ ១ ភាគ ៥ ផង ។ច្បាស់ណាស់ថា ប្រទេសឥណ្ឌូនេស៊ី ដែលមានប្រជាជនសឹងពាក់កណ្ដាលនៃប្រជាជនសរុបនៃតំបន់ទាំងមូល គឺជាមូលហេតុចម្បងដែលធ្វើឲ្យកម្រិតនៃការធ្វើនគរូបនីយកម្មទូទៅក្នុងថ្នាក់តំបន់ធ្លាក់ចុះ ។ ដូច្នេះទោះជាអាស៊ីអាគ្នេយ៍មានការធ្វើនគរូបនីយកម្មកម្រិតទាបក៏ពិតមែន ក៏ក្នុងដំណាក់កាលនេះប្រទេសទាំងអស់មានលក្ខណៈខុសៗគ្នាច្រើន ។

មកដល់នឹងឆ្នាំ ១៩៦០កត្តាទាំងឡាយដែលនាំឲ្យមានការកើនឡើងនៃចំនួនប្រជាជនក្នុងទីក្រុងនៅក្នុងតំបន់ទាំងមូលមានលក្ខណៈដូចគ្នាច្រើន ។ កំណើនដោយធម្មជាតិ និងការពង្រីកព្រំប្រទល់ក្រុងមានតួនាទីយ៉ាងសំខាន់ ។ ប៉ុន្តែកត្តាសំខាន់បំផុតដែលនាំឲ្យមានកំណើនបែបនេះ គឺការធ្វើអន្តោប្រវេសន៍ក្នុងស្រុកមកពីតំបន់ជនបទ ។ ទោះជាយ៉ាងនេះក៏ដោយ ការធ្វើអន្តោប្រវេសន៍ពីជនបទមកទីក្រុងនេះមានមូលហេតុច្រើនណាស់ ហើយមូលហេតុទាំងនេះខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតផង ហើយអ្នកនិពន្ធភាគច្រើនទំនងជាសង្កត់ធ្ងន់ទៅលើមូលហេតុចម្បងនៃការផ្លាស់ប្ដូរលំនៅមកពីជនបទ ថាបណ្ដាលមកពីកង្វះខាតផ្នែកសេដ្ឋកិច្ច ។ ប៉ុន្តែ អសន្តិសុខនៅតាមជនបទនោះវិញទេ ដែលជាកត្តាសំខាន់មួយដែលជំរុញឲ្យប្រជាជនធ្វើដំណើរមកទីក្រុងដើម្បីស្វែងរកសន្តិសុខក៏ដូចជាមកស្វែងរកការងារធ្វើផងដែរ ។ នៅប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ភូមា និងឥណ្ឌូចិន កត្តាអសន្តិសុខនេះគឺជាកត្តាចម្បងយ៉ាងជាក់ច្បាស់ ។ លើសពីនេះទៀត គេឃើញមានកំណើនចំនួនប្រជាជនជនជាតិដើមមកកាន់ទីក្រុងកាន់តែច្រើនដើម្បីធ្វើការនៅក្នុងជួរកងទ័ព ធ្វើជាឈ្មួញ និងមន្ត្រីរាជការដែលគេបានពង្រីកកាន់តែធំឡើងក្នុងរយៈពេលយ៉ាងឆាប់រហ័ស ។

រហូតមកដល់ដើមទសវត្សឆ្នាំ ១៩៦០ រចនាសម្ព័ន្ធសេដ្ឋកិច្ចនៅតាមទីក្រុងធំៗពុំសូវខុសគ្នាពីសម័យអាណានិគមប៉ុន្មាននោះទេ ។ ដំណាក់កាលដំបូងនៃសម័យឯករាជ្យបង្កើតឲ្យមានឥរិយាបថថ្មីទៅលើការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចដោយពេលនោះគេផ្ដោតជាសំខាន់លើការអភិវឌ្ឍផ្នែកឧស្សាហកម្មតាមរយៈគោលនយោបាយមួយចំនួនដូចជាបង្កើនការនាំចេញ ការបង្កើតតំបន់សេដ្ឋកិច្ចថ្មីៗ និងជំរុញឲ្យមានកំណើនខាងផ្នែកឧស្សាហកម្មនៅតាមទីក្រុង។ទោះបីជាមកដល់ឆ្នាំ ១៩៦០ ការធ្វើបែបនេះជាទូទៅមិនមានដំណើរការបានច្រើនក៏ដោយ ។ តំបន់ឧស្សាហកម្មថ្មីៗដូចជាប៉េតាលីងជ្វា (Petaling Java) នៅក្រៅក្រុងគូឡាឡាំពួរ (Kuala Lumpur) ត្រូវបានគេបង្កើតឡើងប៉ុន្តែការរីកលូតលាស់វិស័យឧស្សាហកម្មពិតជាពុំអាចផ្ដល់ការងារគ្រប់គ្រាន់ដល់ប្រជាជន នៅតាមទីក្រុងដែលកំពុងតែ

*កើនឡើងយ៉ាងរហ័សនោះទេ ។ ហេតុដូច្នេះហើយ អ្នករស់នៅទីក្រុងយ៉ាងច្រើនត្រូវបង្ខំចិត្តធ្វើការងារក្នុងផ្នែកសេវាកម្មដែលមានអតិផរណាខ្ពស់បំផុត ។ ការងារទាំងនោះរួមមានដូចជាការធ្វើជំនួញ និងពាណិជ្ជកម្មតូចៗ ការដឹកជញ្ជូន និងការងារដែលមានប្រាក់ចំណូលទាបផ្សេងទៀត ។ នៅក្នុងផ្នែកការងារប្រភេទនេះយ៉ាងហោចណាស់ក៏បានផ្តល់ការងារធ្វើសម្រាប់មនុស្សមួយចំនួនដែរ ទោះជាអត្រាផ្តល់ការងារទាបពិតមែននោះចំណែកការងារផ្នែកស៊ីប្រាក់ខែវិញមានអ្នកអត់ការងារធ្វើច្រើនណាស់ ។ មកដល់ពាក់កណ្តាលទសវត្សឆ្នាំ ១៩៥០ អត្រាអ្នកអត់ការងារធ្វើ និងអ្នកទទួលបានប្រាក់ចំណូលតិចជ្រុលមានកម្រិតខ្ពស់ណាស់ ។ ជាក់ស្តែងនៅទីក្រុងម៉ានីលក្នុងឆ្នាំ ១៩៥៥ មនុស្សស្រី ១៤,៦% និងមនុស្សប្រុស ១៤,១% អត់ការងារធ្វើ ហើយនៅទីក្រុងដទៃទៀតដូចជាក្រុងហ្សាការតា និងបាងកកក៏មានស្ថានភាពដូចគ្នាដែរ។*

*បញ្ហាដែលបណ្តាលមកពីការរីកចម្រើនលឿនក្នុងទីក្រុងធំៗក្នុងរយៈពេល ១៥ ឆ្នាំដំបូងរាប់ចាប់ពីឆ្នាំ ១៩៤៥ មកមានកើតឡើងច្រើននៅក្នុងទីក្រុងតែម្តង ។ ហេដ្ឋារចនាសម្ព័ន្ធខាងផ្នែកលំនៅស្ថាន ផ្លូវថ្នល់ ការផ្គត់ផ្គង់ទឹក និងអគ្គិសនីក្នុងក្រុងមានកំណត់ដែលសម័យអាណានិគមបានបន្សល់ទុកឲ្យនោះពុំគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់របស់ប្រជាជនដែលមានចំនួនកើនឡើងខ្ពស់បានទេ ។ កំណើនប្រជាជនខ្ពស់បានបណ្តាលឲ្យមានការតាំងទីលំនៅអាណាធិបតេយ្យនៅតាមក្រវាត់ក្រុង ឬកន្លែងទំនេរនៅទីក្រុង ឬកន្លែងដែលមានប្រជាជនកកកុញស្រាប់ទៅហើយក្នុងក្រុងតែម្តង ។ ការផ្គត់ផ្គង់តម្រូវការផ្នែករូបវន្តចាំបាច់ដូចជាការផ្គត់ផ្គង់ទឹក និងប្រព័ន្ធកាកសំណល់ និងប្រព័ន្ធដឹកជញ្ជូនសាធារណៈមានការខ្វះខាតយ៉ាងខ្លាំង ។ ក្នុងដំណាក់កាលដំបូងនៃសម័យឯករាជ្យ ការទាមទារឲ្យរដ្ឋាភិបាលថ្មីចែករំលែកធនធានកម្រមានច្រើនលើសលុប ។ ប៉ុន្តែតម្រូវការខាងផ្នែករូបវន្តក្នុងទីក្រុងហាក់មានសារសំខាន់មិនដល់តម្រូវការរួមដែលចង់ឲ្យមានសន្តិសុខក្នុងប្រទេសនោះទេ ។ ដូច្នេះទីក្រុងបានដើរតួនាទីខាងផ្នែកនយោបាយខណៈដែលរដ្ឋាភិបាលជាតិថ្មីៗមួយចំនួនបានបង្កើតឲ្យមានជារបៀបវិនិយោគខាងជាតិនិយម (ដូចអ្នកនិពន្ធម្នាក់បានពិពណ៌នាដែរ) ។ តាមរូបភាពខ្លះទីក្រុងបានក្លាយជាការរំលឹកនូវក្រុងសក្តិសិទ្ធិពីអតីតកាលដោយមានតាំងជាវិមាន និងនិមិត្តសញ្ញាដែលសាងអំពីថ្មរឹកស្កុសស្កាយសំដៅជួយឲ្យទីក្រុងដើរតួនាទីជាបេះដូងរបស់បជាជាតិថ្មី ។*

*មកដល់ទសវត្សឆ្នាំ ១៩៦០ គេបានបន្ថែមធាតុថ្មីៗដល់បណ្តាទីក្រុងនៅក្នុងតំបន់ ។ ក្នុងករណីខ្លះទីប្រជុំជនថ្មីៗបានកើតឡើងនៅតំបន់ជាយក្រុងដូចជាម៉ាកាទី (Makati) នៅជាយក្រុងម៉ានីល និងប៉េតាលីងជ្វា នៅជាប់ក្រុងគូឡាឡាំពួរ ។ លើសពីនេះទៅទៀត ការតាំងទីលំនៅអនាធិបតេយ្យ ក៏រីកសាយភាយគ្រប់ទីកន្លែងដែរ ។ ប៉ុន្តែក្រៅពីធាតុទាំងពីរនេះដំណើរការនៃការស្ថាបនាក្រុងនៅក្នុងដំណាក់កាលនេះយ៉ាងហោចណាស់ក្នុងចំណោមរាជធានីនៅអាស៊ី (ក្រុងបាងកកប្រហែលជាករណីលើកលែង) បានបង្កើតបានទ្រង់ទ្រាយមួយដែលរួមផ្សំដោយធាតុតូចៗដូចកាលនៅសម័យអាណានិគមដែរ ។*

## ដំណាក់កាលទី ២ ៖ សមាហរណកម្មសាកលលោក និងនគរូបនីយកម្ម ១៩៦០_៩០

*ពីឆ្នាំ ១៩៦០ ដល់ទសវត្សឆ្នាំ ១៩៨០ ទ្រង់ទ្រាយនៃការអភិវឌ្ឍទីក្រុងនៅអាស៊ីអាគ្នេយ៍កាន់តែមានលក្ខណៈដោយឡែកៗពីគ្នាដោយសារមូលហេតុច្រើនយ៉ាង ។ មូលហេតុទី ១ គឺដោយសារលក្ខខណ្ឌភូមិសាស្ត្រនយោបាយរបស់តំបន់អាស៊ីអាគ្នេយ៍ដែលកាន់តែមានសភាពខុសគ្នាជាងមុន ។ ការលេចចេញរបស់ប្រទេសចិនទៅជាមហាអំណាច*

*សង្គមនិយមធំមួយ និងសភាពតានតឹងនៃសង្គ្រាមត្រជាក់នៅអាស៊ីជាពិសេសជាមួយសង្គ្រាមវៀតណាម បានបែងចែកបណ្តារដ្ឋសង្គមនិយមនៅក្នុងតំបន់ (ដូចជាវៀតណាម កម្ពុជា និងឡាវ) ដែលមានសេដ្ឋកិច្ចដែលបានគ្រាងឲ្យដាច់ចេញពីបណ្តារដ្ឋដទៃទៀតដែលមានសេដ្ឋកិច្ចបែបមូលធននិយម (ដូចជា ប្រទេសភូមា ជាប្រទេសដែលមានលក្ខណៈដោយឡែកពីគេ) ។ នៅក្នុងសេដ្ឋកិច្ចបែបសង្គមនិយម ការផុតរលុតទៅនៃសង្គ្រាមតម្រូវឲ្យមានការស្តាបនាឡើងវិញ ។ ហើយនេះមានន័យថា កម្រិតនៃការធ្វើនគរូបនីយកម្មក្រោយឆ្នាំ ១៩៧៥ នៅមានកម្រិតទាបនៅឡើយ ។ នៅតាមប្រទេសដែលមានសេដ្ឋកិច្ចបែបមូលធននិយមវិញដែលមានទំនាក់ទំនងជាមួយបណ្តាប្រទេសមូលធននិយមរីកចម្រើនជាមួយការវិនិយោគទុនបរទេសកើនឡើងពិសេសក្នុងផ្នែកផលិតការទាញយកវត្ថុធាតុដើម និងកសិ–ពាណិជ្ជកម្ម បាននាំឲ្យមានការបង្កើនការងារខាងផ្នែកមិនមែនកសិកម្ម និងការកើនឡើងខ្លាំងខាងផ្នែកនគរូបនីយកម្ម ។ នៅតាមបណ្តាប្រទេសទាំងនេះ ជាក់ស្តែងនៅក្នុងប្រទេសម៉ាឡេស៊ី កម្រិតនៃកំណើនទីក្រុងកើនឡើងសឹងទ្វេដងបើប្រៀបនឹងកំណើនប្រជាជនសរុប ។*

*មូលហេតុទី ២ គឺថាបណ្តារដ្ឋក្នុងតំបន់ចាប់ផ្តើមអនុវត្តវិធីឧស្សាហូបនីយកម្មដែលមានការពេញនិយមសម្រាប់ការរៀបចំឡើងវិញ នៅតាមប្រទេសនានាដូចជាប្រទេសជប៉ុន សហរដ្ឋអាមេរិក និងអឺរ៉ុប ។ ប្រទេសសិង្ហបុរី និងក្រោយមកប្រទេសម៉ាឡេស៊ី ថៃ និងឥណ្ឌូនេស៊ីបានក្លាយជាមូលដ្ឋានសំខាន់ក្នុងការទាក់ទាញវិនិយោគទុនបរទេសក្នុងផ្នែកឧស្សាហកម្មមិនថាសម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬក៏សម្រាប់ការនាំចេញនោះទេ ។ ដំណើរការនេះបានបង្កើតឲ្យមានជាតំបន់ឧស្សាហកម្ម តំបន់នាំចេញសេរី ព្រលានយន្តហោះ និងឃ្លាំងផ្ទុកទំនិញ និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀតនៅតាមក្រុងធំៗ ។ ជាក់ស្តែង មកដល់ឆ្នាំ ១៩៨៥ ការផលិតក្រៅពីប្រេងជិត ៦០% នៅឥណ្ឌូនេស៊ីមានមូលដ្ឋាននៅតំបន់ចាបូតាបេក* (Jabotabek) *។ មកដល់ឆ្នាំ ១៩៩០ ប្រទេសម៉ាឡេស៊ីបានបង្កើតតំបន់ឧស្សាហកម្មប្រមាណ ៩០ ដែលបង្កើតជាការងារជិត ៤០% នៃការងារនៅវាលៀងក្រុង គួឡាឡាំពួរ–កេឡាង ។ មកដល់ឆ្នាំ ១៩៨៩ ឧស្សាហកម្មនៅតាមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចបែបមូលធនទាំង ៦ ក្នុងតំបន់បានចូលរួមចំណែក* GDP *ច្រើនជាងផ្នែកកសិកម្ម (សូមអានឯកសាររបស់ ម៉ាកហ្គី គ.ស. ១៩៩៥ខ) ។*

*មូលហេតុទី ៣ គឺមកពីកំណើនទេសចរណ៍ក្នុងតំបន់ ។ នៅដើមទសវត្សឆ្នាំ ១៩៦០ ទីក្រុងភាគច្រើនក្នុងតំបន់ទទួលបានអ្នកទេសចរប្រចាំឆ្នាំមិនដល់ ១០០.០០០ នាក់ទេ ប៉ុន្តែមកដល់ទសវត្សឆ្នាំ ១៩៨០ ក្រុងជាច្រើនមានអ្នកទេសចរលើសពី ១ លាននាក់ទៅទៀត ។ ឥទ្ធិពលលើទីក្រុងដែលមានការហូរចូលខាងទេសចរណ៍នេះមានលក្ខណៈធំធេងណាស់ គឺធ្វើឲ្យមានកំណើនខ្ពស់ខាងសណ្ឋាគារ ទីផ្សារធំៗ សម្រាប់ភ្ញៀវទេសចរណ៍ និងឱកាសការងារច្រើន ។*

*ផលប៉ះពាល់នៃបម្រែបម្រួលទាំងនេះគឺបង្កើតឲ្យមានទម្រង់នគរូបនីយកម្មមួយបែបនៅអាស៊ីអាគ្នេយ៍មកដល់ទសវត្សឆ្នាំ ១៩៨០ ។ ទី ១÷ សិង្ហបុរីបានពង្រឹងតួនាទីរបស់ខ្លួនឲ្យក្លាយជាបេះដូង របស់តំបន់តាមរយៈការពង្រីកតួនាទីជាមជ្ឈមណ្ឌលហិរញ្ញវត្ថុ ការដឹកជញ្ជូន ព័ត៌មាន និងការគ្រប់គ្រងរបស់តំបន់ ។ រដ្ឋាភិបាលសិង្ហបុរីបានអនុវត្តនូវកម្មវិធីបច្ចេកវិទ្យាកម្រិតខ្ពស់ធំៗជាច្រើន ដែលស្ថាបនាឡើងសំដៅធ្វើឲ្យប្រទេសនេះក្លាយជាទីក្រុងទំនើបក្រោយសម័យឧស្សាហកម្មទី ១ នៅក្នុងតំបន់ ។ ខណៈដែលសិង្ហបុរីរៀបចំរចនាសម្ព័ន្ធឡើងវិញ ឧស្សាហកម្មដែលទាមទារកម្លាំងពលកម្មច្រើនកាន់តែច្រើនឡើងបានដូរទៅតាំងនៅជរហោរ* (Johor –*ម៉ាឡេស៊ី) និងតំបន់រីយ៉ូ* (Riau- *ឥណ្ឌូនេស៊ី) ដែលជាផ្នែកមួយនៃគម្រោងដែលស្ថាបនាឡើងដើម្បីបង្កើតឲ្យមានជាត្រីកោណរីកចម្រើនក្នុង*

*តំបន់ដោយយកចំណេញពីកត្តាចម្រុះនៃផលិតកម្ម (សូមមើលម៉ាកលីអូត Macleod និងម៉ាកហ្គី គ.ស.១៩៩៦)។ គម្លាតខាងផ្នែកសេដ្ឋកិច្ចសង្គមនៅមានក្នុងប្រទេសសិង្ហបុរីនៅឡើយ ប៉ុន្តែកម្មវិធីរបស់រដ្ឋាភិបាលក្នុងការសាងសង់ផ្ទះសម្រាប់អ្នកមានចំណូលទាប និងសេវាសង្គមដែលផ្តល់ជូនក្នុងក្របខណ្ឌ «លទ្ធិប្រជាធិបតេយ្យផ្ទាល់»បណ្តាលឲ្យរដ្ឋនេះមាន «ស្ថិរភាព» និងអាចទាក់ទាញការវិនិយោគបរទេស ។*

*បណ្តាប្រទេសក្រុមទី ២ អនុវត្តការធ្វើនគរូបនីយកម្មនៅក្នុងលក្ខខណ្ឌសង្គម និងនយោបាយដែលមានសភាពមិនទៀងទាត់ដាងនេះឆ្ងាយណាស់ ។ ប្រទេសម៉ាឡេស៊ីនៅរក្សាមរតកពីសម័យអាណានិគមក្នុងនាមជាសង្គមពហុសាសន៍ដែលរួមមានម៉ាឡេ ចិន និងឥណ្ឌានៅឡើយ ។ អំណាចនយោបាយស្ថិតនៅក្នុងដៃជនជាតិម៉ាឡេដែលភាគច្រើនរស់នៅជនបទ ចំណែកអំណាចសេដ្ឋកិច្ចស្ថិតក្នុងដៃជនជាតិចិននៅតាមទីក្រុង ។ ចលាចលផ្នែកពូជសាសន៍ក្នុងឆ្នាំ ១៩៦៩ បានធ្វើឲ្យរដ្ឋាភិបាលប្តូរការយកចិត្តទុកដាក់ពីផ្នែកកសិកម្មទៅរកការអភិវឌ្ឍផ្នែកឧស្សាហកម្មតាមទីក្រុង និងគោលនយោបាយសេដ្ឋកិច្ចថ្មីដែលបង្កើតឡើងក្នុងបំណងឲ្យជនជាតិម៉ាឡេនៅតាមទីក្រុងមានសេដ្ឋកិច្ចប្រសើរជាងមុន ។ មកដល់ដើមទសវត្សឆ្នាំ ១៩៩០ គោលនយោបាយទាំងនេះទទួលបានជោគជ័យខ្លះដោយចំនួនជនជាតិម៉ាឡេនៅតាមទីក្រុងបានកើនឡើងយ៉ាងខ្លាំង ។ នៅប្រទេសហ្វីលីពីន និងថៃការប្រែប្រួលផ្នែកនយោបាយដូចគ្នាបានកើតឡើង ហើយខណៈដែលកំណើនទីក្រុងនៅតែបន្ត បញ្ហាចំពោះមុខគឺត្រូវបង្កើតឲ្យបាននូវរបបនយោបាយសមស្របមួយសំដៅអភិវឌ្ឍប្រទេសប្រកបដោយប្រសិទ្ធភាព ។*

*ទ្រង់ទ្រាយបែបទី ៣ នោះគឺ លំនាំដោយឡែ ១ បានរីកលូតលាស់នៅឥណ្ឌូនេស៊ីពិសេសនៅកោះជ្វា ។ទោះជាកោះជ្វាមានការរីកចម្រើនខាងសេដ្ឋកិច្ចលឿន និងការងារក្នុងវិស័យឧស្សាហកម្មមានកំនើនក៏ដោយ ក៏ការ-ងារដែលមានប្រាក់បៀវត្សមិនសមរម្យនៅតែជាបញ្ហាតាមតំបន់ទីក្រុង ។ ការធ្វើចំណាកស្រុកពីតំបន់ជនបទក៏មានទំហំធំដែរ ដែលស្ថានភាពនេះលោកហ៊ុយហ្គុំ (Hugo គ.ស.១៩៧៥) ទទួលស្គាល់មុនគេ ។ ការសិក្សារបស់ហ៊ុយហ្គូបានឲ្យដឹងថាជនចំណាកស្រុកដល់ទៅ ២០% ដែលធ្វើការនៅក្រុងហ្សាការតាតែងត្រលប់ទៅស្រុកកំណើតយ៉ាងហោចណាស់ ៣ ទៅ ៤ ដងក្នុងមួយខែ ។ ពួកគេបានចែករំលែកប្រាក់ចំណូលដែលគេរកបាននៅទីក្រុងសម្រាប់ផ្គត់ផ្គង់គ្រួសារនៅជនបទ (សូមអានជំពូកទី ៦ របស់រីហ្គ (Rigg) នៅក្នុងសៀវភៅនេះ) ។ លំនាំនៃការធ្វើនគរូបនីយកម្មនៅជ្វានេះប្រហាក់ប្រហែលនឹងប្រព័ន្ធទ្វេនិយមដែលនៅមានអត្ថិភាពតាមបណ្តារដ្ឋនៅអាមេរិកឡាទីនដូចជាប្រទេសប្រេស៊ីលជាដើម (សូមអានឯកសាររបស់ហ្គីលប៊ែត៍ (Gilbert) គ.ស.១៩៩៧) ។ ទីក្រុងម៉ានីលក៏មានលក្ខណៈដូចគ្នាខ្លះៗដែរ ។*

*ទ្រង់ទ្រាយបែបចុងក្រោយនេះ គឺចាប់ពីទសវត្សឆ្នាំ ១៩៧០ មកបណ្តារដ្ឋសង្គមនិយមមានឡាវ វៀតណាម និងកម្ពុជាបានចេញផុតពីសង្គ្រាមវៀតណាម ។ ក្រោយពីទទួលយកនូវគោលនយោបាយដើម្បីការពារមិនឲ្យមានកំនើនលឿននៅតាមតំបន់ក្រុង ប្រទេសទាំងនេះចាប់ផ្តើមបើកចំហសេដ្ឋកិច្ចរបស់ខ្លួនជាបណ្តើរៗ ឲ្យមានការវិនិយោគមកពីក្រៅ ។ គោលការណ៍នេះមានជោគជ័យគួរកត់សម្គាល់នៅប្រទេសវៀតណាមក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយ ហើយបាននាំឲ្យមានការធ្វើនគរូបនីយកម្មលឿននៅរដ្ឋធានីហាណូយ និងក្រុងហូជីមិញ (សូមអានឯកសាររបស់ម៉ាកហ្គី គ.ស.១៩៩៥ a និង ហ្វបស៍ (Forbes) គ.ស.១៩៩៦ b) ។*

*មកដល់ចុងទសវត្សឆ្នាំ ១៩៨០ ទីក្រុងនៅអាស៊ីអាគ្នេយ៍មានការប្រែប្រួលយ៉ាងសម្បើមដោយមរតកពីសម័យអាណានិគមត្រូវបានគេធ្វើឲ្យរង្គោះរង្គើ គេកែច្នៃ បំផ្លាញ និងសាងសង់ឡើងវិញ ។ ដោយមានការគាំទ្រ និងគប់គិត*

*ពីរដ្ឋាភិបាលជាតិ ក្រុមហ៊ុនអភិវឌ្ឍន៍ដីធ្លី និងពួកមូលធននិយមក្នុងស្រុកចាប់ផ្ដើមកែប្រែក្រុងទាំងនេះឲ្យមានជាសង្កាត់ពាណិជ្ជកម្មកណ្ដាល តំបន់ឧស្សាហកម្ម និងតំបន់រស់នៅតាមជាយក្រុង ។ ការកែប្រែច្បាស់ជាងគេមាននៅសិង្ហបុរីដែលជាទីក្រុងលំដាប់ពិភពលោកធំជាងគេនៅអាស៊ីអាគ្នេយ៍ ។ ចន្លោះទសវត្សឆ្នាំ ១៩៦០ និងទសវត្សឆ្នាំ ១៩៨០ សិង្ហបុរីបានធ្វើការកែប្រែទាំងស្រុងនូវបរិដ្ឋានដែលស្ថាបនាពីមុនសម្រាប់សង់ផ្ទះទាបៗនៅតាមតំបន់ជាតិសាសន៍នានាឲ្យទៅជាទិដ្ឋភាពមួយដែលមានសំណង់អាគារខ្ពស់ៗហ៊ុមព័ទ្ធដោយពណ៌ខៀវស្រងាត់ (សូមអានឯកសាររបស់ ដឺ ខូនីនយ៍* (De Koninck) *គ.ស. ១៩៩២ និងហូ* (Ho) *គ.ស. ១៩៩៧) ។ ទោះជាយ៉ាងនេះក៏ដោយការអភិវឌ្ឍទាំងនេះបានទទួលនូវប្រតិកម្មពីសំណាក់ក្រុមមនុស្សក្នុងស្រុកមួយចំនួនដែលប្រឹងប្រែងឲ្យមានការធ្វើអភិរក្សកេរ្តិ៍ដំណែលទាំងនោះតាមរយៈកម្មវិធីថែរក្សា ឬពង្រីកបន្ថែមលើអ្វីដែលមានស្រាប់ ។ ក្រុងមួយចំនួននៅអាស៊ីអាគ្នេយ៍នៅមានកិច្ចខិតខំប្រឹងប្រែងមួយចំនួនក្នុងការរក្សាឲ្យបាននូវផ្នែកចាស់ៗក្នុងទីក្រុងដូចជាសង្កាត់បាពាំងនៅក្រុងហាណូយ ក្លូដុក*(Glodok) *នៅហ្សាការតា និងអិនត្រាមូរូស៊ីន* (tramuros) *នៅក្រុងម៉ានីល (សូមអានឯកសាររបស់ អាស្ក្លូ* (Askew) *និងឡូហ្គែន*(Logan) *គ.ស. ១៩៩៤)។*

*វិធីគិតអំពីដំណើរការទាំងអស់ដែលលេចឡើងក្នុងចន្លោះឆ្នាំ ១៩៥០ និង ១៩៩០ គឺត្រូវផ្ដោតលើរបៀបដែល «សេដ្ឋកិច្ចនយោបាយនៃលំហ» បង្កើតជាទម្រង់ស្ថាបត្យកម្ម និងរូបរាងទីក្រុងសម្រាប់ការប្រើប្រាស់ និងសោភណភាព ។ ដូច្នេះតំបន់ទីក្រុងទទួលនូវការរីកចម្រើនយ៉ាងលឿនខាងផ្នែកសណ្ឋាគារ តំបន់ទេសចរណ៍ សំណង់ផ្ទះសម្រាប់អ្នកមានប្រាក់ចំណូលខ្ពស់ និងមធ្យម និងមជ្ឈមណ្ឌលពាណិជ្ជកម្មជាច្រើនទៀត ។ តំបន់ទាំងនេះជាប់គ្នាពី ១ ទៅ ១ តាមរយៈប្រព័ន្ធដឹកជញ្ជូនជាច្រើនដែលមានប្រសិទ្ធភាពខុសៗគ្នា ។ ជាលទ្ធផលការអភិវឌ្ឍទាំងនេះបង្កើតបានជាបរិដ្ឋានថ្មីមួយដែលនៅទីនេះអត្តសញ្ញាណរបស់ក្រុង ត្រូវគ្របដណ្ដប់ដោយរូបភាពអន្តរ-ជាតិ ។ រូបភាពនេះបានមកដោយការបំផ្លាញ និងបិទបាំងមរតកវប្បធម៌សម្បូរបែបក្នុងស្រុក ។ ការឆ្លើយតបនៅតាមក្រុងជាច្រើននៅអាស៊ីអាគ្នេយ៍ចំពោះការរីកចម្រើនទាំងនេះមានសកាពមានសភាពប្រែប្រួលខ្លាំងណាស់ លើកលែងតែករណីមួយចំនួនដូចជាសិង្ហបុរី ព្រោះថាសិង្ហបុរីបានបិទបាំងនូវសហគមន៍អ្នកក្រីក្រធំៗដែលពុំមានសេវាកម្មគ្រប់គ្រាន់ និងពុំមានផ្ទះសំបែងសមរម្យក្រោមរូបភាពអភិវឌ្ឍដូចគ្នា ។*

## នគរូបនីយកម្មក្នុងទសវត្សឆ្នាំ ១៩៩០៖ សកលភាវូបនីយកម្មពុំទៀងទាត់និងទីក្រុងនៅអាស៊ីអាគ្នេយ៍

*ដំណើរការដែលបានពិពណ៌នាខាងលើភាគច្រើននៅបន្ត និងកាន់តែមានលក្ខណៈខ្លាំងក្លានៅទសវត្សឆ្នាំ ១៩៩០ ។ ប៉ុន្តែទសវត្សចុងក្រោយ ក៏មានសមាហរណកម្មអាស៊ីអាគ្នេយ៍ និងទីក្រុងទៅក្នុងប្រព័ន្ធពិភពលោកកាន់តែខ្លាំងក្លាជាងមុនដែរ ។ ដំណើរការសមាហរណកម្មនេះមិនមែនអាស្រ័យតែលើទំនាក់ទំនងសេដ្ឋកិច្ចមួយមុខនោះទេ ។ តំបន់ទាំងមូលពិសេសបណ្ដាទីក្រុងទាំងអស់សុទ្ធតែធ្លាប់មានបទពិសោធចូលរួមទៅក្នុងបណ្ដាអគ្គការធំជាងថ្នាក់ជាតិ លំហូរជនចំណាកស្រុក អ្នកទេសចរ និងជនស្វែងរកការជ្រកកោន និងការផ្សព្វផ្សាយព័ត៌មានអន្តរជាតិជាក្រដាស និងដោយគ្រឿងម៉ាស៊ីនយ៉ាងទូលំទូលាយ ។ ទោះជាយ៉ាងនេះក៏ដោយ ក្នុងមួយទសវត្សចុងក្រោយនេះការវិនិយោគទុកបរទេសក្នុងផ្នែកផលិត និងសេវាកម្មក៏ជាចំណែកសំខាន់យ៉ាងខ្លាំងមួយនៃលំហូរទាំងនេះដែរ ។*

*ការបង្កើតជាទ្រឹស្ដីអំពីដំណើរការបញ្ចូលទីក្រុងទៅក្នុងសេដ្ឋកិច្ចពិភពលោកមានតាំងពីយូរមកហើយ ។ អ្នក*

និពន្ធប្រកាន់ទ្រឹស្តីទំនាក់ទំនងកេងប្រវ័ញ្ចនិយមបានអះអាងថារាល់បណ្តាមជ្ឈមណ្ឌលធំៗ តាមទីក្រុងតែងបង្កើតជាទំនាក់ទំនងរវាងទីក្រុងនឹងជនបទដែលមានលក្ខណៈកេងប្រវ័ញ្ចយ៉ាងច្រើនដោយក្នុងនោះរាជធានីតែងស្រូបយកនូវមូលធនពីទីជនបទដាច់ស្រយាល ។ នេះបើនិយាយពីទំនាក់ទំនងនៅក្នុងប្រទេសក្រីក្រ ។ ប៉ុន្តែប្រទេសក្រីក្រត្រូវបានប្រទេសមានឧស្សាហកម្មរីកចម្រើនកេងប្រវ័ញ្ចតាមរយៈទីក្រុងរបស់គេ ។ មកដល់ទសវត្សឆ្នាំ ១៩៧០ ហើយពិសេសនៅទសវត្សឆ្នាំ ១៩៨០ ទំនាក់ទំនាក់ទំនងរវាងប្រទេសអ្នកមាននឹងអ្នកក្រពុំមែនជាមធ្យោបាយគ្រប់គ្រាន់សម្រាប់និយាយបំព្រួញអំពីតួនាទីរបស់ទីក្រុងអាស៊ីអាគ្នេយ៍ក្នុងសេដ្ឋកិច្ចពិភពលោកឡើយ ។ ការវិនិយោគមូលធនបានហូរចូលទៅក្នុងសេដ្ឋកិច្ចទីផ្សារក្នុងតំបន់ស្របនឹងការរីកចម្រើនសេដ្ឋកិច្ចដើរទន្ទឹមគ្នាដែរ ។ នៅទសវត្សឆ្នាំ ១៩៩០ ការរីកចម្រើននេះបានកើនឡើងគួរកត់សម្គាល់ និងបានពង្រីកដល់បណ្តាសេដ្ឋកិច្ចអន្តរកាលនៅតណ្ឌចិនទៀតផង ។ ទិន្នន័យដែលលោក ទ្រូម៉ាន (Truman) កត់ត្រានៅក្នុងព្រឹត្តិបត្រមូលធនបំរុងរបស់សហព័ន្ធ (Federal Reserve Bulletin) បានបង្ហាញថា មូលធនសរុបទាំងអស់ដែលហូរចូលទៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍបានកើនឡើងពី ៥៤,១ កោដិលានដុល្លារអាមេរិកនៅចន្លោះឆ្នាំ ១៩៧៣–៨៩ ដល់ ១០៨,៤ កោដិលានដុល្លារនៅឆ្នាំ១៩៩០–៩៤ ។ ៥០% នៃមូលធនទាំងនេះបានមកប្រទេសនៅអាស៊ី ហើយ ៣០% បានមកអាស៊ីអាគ្នេយ៍ ។ ដូច្នេះនៅក្នុងសេដ្ឋកិច្ចពិភពលោកទាំងមូល ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ ១៩៨០ មក ការហូរចូលនូវមូលធនមានចំនួនលើសការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ចជាតិច្រើនណាស់ ។ យោងតាមការប្រើប្រាស់ពាក្យរបស់ មីសែស ស្តូបភើ (Michael Stoper គ.ស. ១៩៩៧) «សេដ្ឋកិច្ចលំហូរមូលធន» ចាប់ផ្តើមធ្វើឲ្យ «សេដ្ឋកិច្ចដែនដី» ពុំសូវមានសារៈសំខាន់ ។ នៅអាស៊ីអាគ្នេយ៍ការហូរចូលទាំងនេះផ្តោតសំខាន់លើផ្នែកទីផ្សារភាគហ៊ុន ស្ថាប័នហិរញ្ញវត្ថុឧស្សាហកម្មកែច្នៃ និងទ្រព្យនៅតាមតំបន់ក្រុងធំៗនៅអាស៊ីអាគ្នេយ៍ ។

ម៉ាញូអែល ខាស្ត្រែលស៍ (Manuel Castells គ.ស. ១៩៩៦ និង គ.ស. ១៩៩៧) ប្រហែលជាបង្កើតនូវបញ្ញត្តិកម្មថ្មីៗល្អជាងគេស្តីអំពីលំហរសេដ្ឋកិច្ចពិភពលោកដែលជំរុញឡើងដោយបរិដ្ឋានខ្វាត់ខ្វែងទាំងនេះ ។ លោកបានពិព័ណនាអំពីសង្គមបណ្តាញដែលក្នុងនោះគេបង្កើតឲ្យមានជា «ទំនាក់ទំនងថ្មី» រវាង «ផលិតកម្ម ការប្រើប្រាស់ ការគ្រប់ពលកម្មនិងមូលធន និងព័ត៌មាន» (ខាស្ត្រែលស៍ ១៩៨៩ ទំ. ៣៤៨) ។ ក្នុងកាលៈទេសៈនេះ ទីតាំងមានសារៈសំខាន់តិចជាងតួនាទីនៅក្នុងបណ្តាញ ។ និយាយម្យ៉ាងទៀត «លំហរនៃលំហូរមូលធន» ក្នុងពិភពលោកមានសារៈសំខាន់ជាង «លំហរនៃទីតាំង» ។ ដូច្នេះហើយទើបមានលេចឡើងនូវការយល់ឃើញថ្មីមួយអំពីលំហរសេដ្ឋកិច្ចពិភពលោក និងតួនាទីនៃទីតាំងរាប់បញ្ចូលទាំងទីក្រុងនៅក្នុងនោះផង ។ ក្នុងន័យប្រៀបធៀប លំហរនៃលំហូរមានន័យថាទីតាំងត្រូវដើរស្របទៅនឹងទំនាក់ទំនងរវាង ឬបណ្តាញនៃការវិនិយោគ ផលិតកម្ម និងឱកាសក្នុងទីផ្សារ ។ ដូច្នេះន័យធៀបនៃបណ្តាញជំនួសឲ្យន័យធៀបនៃទីតាំងខ្វាត់ខ្វែងក្នុងដែនដីនៃប្រទេសណាមួយ (សូមអានឯកសាររបស់ ស្រ៊ីវត៍ (Thrift) និង អូលដ្ស៍ (Olds) គ.ស. ១៩៩៦) ។ ន័យធៀបនៃពាក្យលំហរដូច្នេះបានផ្តល់នូវអ្វីដែលឡឺហ្វែបវ្រ៍(Lefebvre) ហៅថា «ការបង្ហាញអំពីលំហរ» ដែលមានន័យថា ជារបៀបដែលយើងបង្កើតនូវការយល់ដឹងអំពីទំនាក់ទំនងរូបធាតុនិយមឆ្លងកាត់លំហរ ។ លើសពីនេះទៀត ការកើតឡើងនូវការយល់ដឹងថ្មីៗអំពីលំហរសេដ្ឋកិច្ចពិភពលោកមានបង្ហាញនៅក្នុងប្រវត្តិនៃការធ្វើនគរូបនីយកម្មនៅអាស៊ីអាគ្នេយ៍ (ហ្វូបស៍ (Forbes) គ.ស. ១៩៩៧ និង ខែលលី (Kelly) គ.ស. ១៩៩៧) ។ ក្នុងកម្រិតគោលនយោបាយ ស្ថានភាពដែលជាលទ្ធផលនៃការយល់ដឹងអំពីសេដ្ឋកិច្ចពិភពលោកដូច្នេះគឺការធ្វើម៉ាឃីតធីងអំពីទីក្រុង និងតំបន់ដែលជាគោលដៅសម្រាប់

លំហូរផ្នែកមូលធន និងលំហូរផ្នែកដទៃទៀត[៤]។ ទោះជាយ៉ាងណា ចំណុចសំខាន់គឺថា បច្ចុប្បន្នគេយល់ថាសេដ្ឋកិច្ចពិភពលោក គឺជាបន្ទាត់មេត្រចំបាច់សម្រាប់វាស់នូវដំណើរការនៃការធ្វើនគរូបនីយកម្ម និងការអភិវឌ្ឍក្នុងតំបន់ ។

ដូចដែលយើងបានកត់សម្គាល់រួចមកហើយ ការបកស្រាយសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ជាមួយលំហូរសកលលោក ដូចជាការបញ្ចូលសេដ្ឋកិច្ចរបស់តំបន់នេះទៅក្នុងបណ្ដាញសកលលោក គឺធ្វើឡើងតាមរយៈទីក្រុងធំៗក្នុងតំបន់ ។ តាមរយៈការហូរចូលមូលធនយើងអាចមើលឃើញចំណុចនេះកាន់តែច្បាស់ ។ ពេលយើងសិក្សាលើតួលេខនៃការហូរចូលនៃការវិនិយោគបរទេសដែលជាកត្តានាំឲ្យមានសន្ទុះខ្លាំងសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅប្រទេសជាច្រើនក្នុងតំបន់ យើងឃើញថាការវិនិយោគប្រមូលផ្ដុំនៅតំបន់ប្រជុំជនធំៗ ។ ប្រភពទិន្នន័យខុសគ្នានិងការកំណត់ភូមិសាស្ត្រខុសគ្នាធ្វើឲ្យការប្រៀបធៀបរវាងប្រទេសមួយនឹងប្រទេសមួយផ្ទាល់មានការលំបាក ប៉ុន្តែស្ថិតិថ្នាក់ជាតិខ្លះពិតជាបានបញ្ជាក់ថាមានការប្រមូលផ្ដុំតាមតំបន់ពិតប្រាកដមែន ។ ឌីខេអាយហ្សាការតាមានប្រជាជន ៤,៦% នៃប្រជាជនឥណ្ឌូនេស៊ី ប៉ុន្តែក្នុងចន្លោះឆ្នាំ ១៩៦៧–១៩៩១ ទទួលតម្លៃវិនិយោគបរទេសបានត្រឹមតែ ១៧,២% ប៉ុណ្ណោះ(សូជីចូកូ (Soegijoko) គ.ស. ១៩៩៦) ។ ប្រសិនបើគេបន្ថែមផ្លាខាងលិចទៀត (រួមបញ្ចូលទាំងតំបន់ហ្សាបូតាបែក និងប្រជុំជនជិតៗដែលស្ថិតក្នុងក្រវាត់ក្រុងហ្សាការតា) ទីក្រុងទាំងមូលទទួលបានតម្លៃវិនិយោគដល់ទៅ ៤៤,៨% នៃវិនិយោគជាតិសរុប ។ ចំនួននេះមានន័យថាបានបង្កើតការងារជាង ៥០% នៃការងារដែលបង្កើតឡើងដោយការវិនិយោគក្នុងអំឡុងពេលដូចគ្នានេះ។ មែតឌី (Medhi) (គ.ស. ១៩៩៦) បានផ្ដល់នូវទិន្នន័យអំពីចំនួនគម្រោងវិនិយោគបរទេសដែលក្រុមប្រឹក្សាវិនិយោគថៃបានអនុម័តក្នុងចន្លោះឆ្នាំ ១៩៧៩–៩០ ។ គម្រោងនៅទីក្រុងបាងកកមានចំនួនស្មើ ១៥,៧% នៃចំនួនសរុបរបស់ជាតិ ប៉ុន្តែពេលគេបញ្ចូលខេត្តជុំវិញ ៥ ទៀតដើម្បីបង្កើតជាតំបន់មហាក្រុងបាងកក ចំនួននេះកើនឡើងដល់ ៦៧,៨% ។ សេដ្ឋកិច្ចអន្តរកាលរបស់វៀតណាមដែលទាក់ទាញមូលធនបរទេសខ្លាំងក្នុងពេលថ្មីៗនេះ (ក្រោយប្រទេសដែលមានសេដ្ឋកិច្ចទីផ្សារ) បង្ហាញនូវលំនាំស្រដៀងគ្នាដែរ ។ ណេស្ត (១៩៩៧) បង្ហាញថាសម្រាប់រយៈពេល ១៩៨៨–៩៣ ក្រុងហូជីមិញទទួលបានការវិនិយោគសហពាណិជ្ជបរទេស ៤៥,៩% ចំណែកក្រុងហាណូយបាន ២១,១% ។

សម្រាប់ប្រទេសហ្វីលីពីនគេមានទិន្នន័យពិស្ដារថ្មីៗជាង(សូមអានឯកសាររបស់ ខេលលី គ.ស ១៩៩៧) ។ បើយកការបង្កើតការងារដែលជាការវាស់វែងនូវកម្រិតនៃការវិនិយោគ តារាង ៧.២ បង្ហាញអំពីការចូលរួមចំណែករបស់តំបន់ទីក្រុងជាតិ (រួមមានបណ្ដាក្រុងនៅរដ្ឋធានីម៉ានីល) និងតំបន់រដ្ឋបាលជាប់គ្នាពីរមានលូសុនកណ្ដាល និងតាកាឡូកខាងត្បូង ។ លំនាំនៃការវិនិយោគនៅប្រទេសហ្វីលីពីនមានលេចចេញចំណុចសំខាន់ពីរ ។ ទី ១ ការវិនិយោគប្រមូលផ្ដុំច្រើននៅតំបន់សំខាន់របស់ជាតិ (រួមមានតំបន់ទាំងបីនេះ) ដូចប្រទេសដទៃទៀតដែរ ។ តំបន់ទាំងបីនេះរួមគ្នាបង្កើតការងារពីរវាង ៥០% ទៅ ៩០% នៃការងារបង្កើតក្នុងរយៈពេល ១០ ឆ្នាំមានក្នុងតារាង ។ទោះជាយ៉ាងណា បម្រែបម្រួលទី ២ នៅក្នុងតារាង ៧.២ គឺជាការធ្លាក់ចុះនូវសារៈសំខាន់របស់រដ្ឋធានីខ្លួនឯង ហើយនិងការកើនឡើងនូវកម្រិតការងារបង្កើតនៅតាមបណ្ដាខេត្តជុំវិញ ។ លំនាំនេះបង្ហាញឲ្យឃើញនូវដំណើរការនៃការពង្រីករដ្ឋធានីដែលក្នុងនោះការធ្វើនគរូបនីយកម្មប្រព្រឹត្តទៅតាមតំបន់ណាមួយមិនមែនតែនៅទីក្រុងទេ ។

**តារាង ៧.២ ៖ ការងារដែលបង្កើតឡើងដោយការវិនិយោគនៅប្រទេសហ្វីលីពីន ១៩៨៦-៩៦**

| ឆ្នាំ | ហ្វីលីពីន (សរុប) | % នៃចំនួនសរុបនៅក្រុងម៉ានីល | % នៃចំនួនសរុបនៅក្រៅក្រុងម៉ានីល (លូសុនកណ្ដាល និងតាកាឡូកខាងត្បូង) | % នៃចំនួនសរុបនៅតំបន់សំខាន់ជាតិ (ម៉ានីល លូសុនកណ្ដាល និងតាកាឡូកខាងត្បូង) |
|---|---|---|---|---|
| ១៩៨៦ | ២៦,២៨៧ | ៧៣,៥ | ១២,២ | ៨៥,៧ |
| ១៩៨៧ | ៨២,១០១ | ៦៦,៤ | ២០,២ | ៨៦,៦ |
| ១៩៨៨ | ១២៨,០៥២ | ៥០,៥ | ២៦,០ | ៧៦,៥ |
| ១៩៨៩ | ១៥៣,៤៩០ | ៤៨,៥ | ៣៤,៦ | ៨៣,១ |
| ១៩៩០ | ១១៣,២៩០ | ៤០,៦ | ៣៩,៧ | ៨០,៤ |
| ១៩៩១ | ៦០,០៦៨ | ២០,២ | ៤៩,៤ | ៦៩,៦ |
| ១៩៩២ | ៤៩,៤៨៣ | ១៦,៧ | ៤៥,៤ | ៦២,១ |
| ១៩៩៣ | ៥៩,១០៦ | ២១,០ | ៤២,៧ | ៦៣,៧ |
| ១៩៩៤ | ១៤៨,៦៣០ | ១៦,៩ | ៤៥,៣ | ៦២,២ |
| ១៩៩៥ | ៨០,៤០១ | ១១,៦ | ៤០,៨ | ៥២,៤ |
| ១៩៩៦* | ៥៨,៧៦៤ | ២៦,៩ | ៣០,៣ | ៥៧,២ |

***មករា-កញ្ញា**

ប្រភព ៖ ទិន្នន័យដែលមិនទាន់បោះពុម្ពស្ដីពីកម្មវិធីអនុម័តស្របតាមច្បាប់ស្ដីពីការលើកទឹកចិត្តវិនិយោគផ្សេងៗ ក្រុមប្រឹក្សាវិនិយោគ ម៉ានីល ១៩៩៦ ។

*ដូច្នេះការដាក់បញ្ចូលសេដ្ឋកិច្ចជាតិទៅក្នុងលំហូរសកលលោកតែងធ្វើឡើងតាមរយៈតំបន់ក្រុងសំខាន់នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ។ ការប្រមូលផ្ដុំនៅតាមតំបន់នេះប្រហែលជាមានឫសគល់នៅក្នុងប្រព័ន្ធទីក្រុងពីសម័យអាណានិគម ប៉ុន្តែគេកត់សម្គាល់ឃើញថាការប្រមូលផ្ដុំនៅក្នុងលំនាំបច្ចុប្បន្ននៃការធ្វើនគរូបនីយកម្ម គឺអាស្រ័យលើមូលហេតុមួយចំនួន ។ មិនថាគេសាងសង់រោងចក្រសម្រាប់ផលិតទំនិញនាំចេញ ឬសម្រាប់បម្រើទីផ្សារនៅ*

ក្នុងស្រុកទេ តំបន់ទីក្រុងថ្នាក់ជាតិមានការទាក់ទាញប្រកបដោយកម្លាំងខ្លាំងណាស់ ។ ក្នុងការអង្កេតលើក្រុមហ៊ុនចំនួន ១០០ នៅប្រទេសហ្វីលីពីន ហែរីន (Herrin) និងពែនៀ (Pernia) (គ.ស.១៩៨៦) បានរកឃើញថា តម្រូវការលើផ្នែកទីតាំងសំខាន់បំផុត គឺនៅជិតកន្លែងដឹកជញ្ជូន (ផែសមុទ្រ បញ្ជើតាមយន្តហោះ និងមហាវិថី) ការផ្គត់ផ្គង់អគ្គិសនីល្អ បណ្ដាញទំនាក់ទំនង និងមានដីទំនេរច្រើន និងសម្ភារពេងចក្រ ។ ពែនៀ និងប៉ាដេរ៉ាងហ្គា (Paderanga) (គ.ស.១៩៨៣) ក៏បានសង្កត់ធ្ងន់លើភាពចាំបាច់នៃទីតាំងដែលនៅជិតការិយាល័យរដ្ឋាភិបាល ធនាគារធំៗ និងសេវាកម្មអាជីពផ្សេងៗដែរ ។ ដោយសារតែហេដ្ឋារចនាសម្ព័ន្ធទាំងនេះរួមទាំងតម្រូវការទីផ្សារផងប្រមូលផ្ដុំនៅទីក្រុងម៉ានីល តំបន់ស្នូលនេះមានភាពទាក់ទាញយ៉ាងខ្លាំង ។ កត្តាទាំងនេះមានសារៈសំខាន់ច្រើនជាងការផ្ដល់នូវការអនុគ្រោះផ្នែកសារពើពន្ធដែលគេផ្ដល់ដល់អ្នកវិនិយោគបរទេសដែលតាំងនៅតំបន់ឆ្ងាយៗ (ហ្វុចន៍ (Fuchs) និងពែនៀ គ.ស.១៩៨៩) ។ ពែនវែល (Parnwell) និងវង្សសុផាសាវត្ត (Wongsuphasawat) (គ.ស.១៩៩៧) ក៏បានឲ្យដឹងថា រោងចក្រនៅតំបន់ពង្រីករាជធានីបាងកកក៏មានតម្រូវការលើផ្នែកទីតាំងនិងដំណើរការរត់ឯកសារដូចគ្នាដែរ ។

យើងគួរបន្ថែមទៀតថា ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅតំបន់ស្នូលរបស់ប្រទេសមិនគ្រាន់តែជាមរតកនៃការឲ្យតម្លៃលើទីក្រុងប៉ុណ្ណោះទេ ។ គោលនយោបាយបែបនេះក៏បង្ហាញឲ្យឃើញពីការវិនិយោគរបស់រដ្ឋាភិបាលក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលផ្ដោតសំខាន់លើតំបន់នេះដែរ ។ បើយកប្រព័ន្ធដឹកជញ្ជូនមកធ្វើជាឧទាហរណ៍ យើងឃើញថា គម្រោងអភិវឌ្ឍរបស់ហ្វីលីពីនសម្រាប់រយៈពេលមធ្យម (១៩៩៣-៩៨) បានកំណត់យកគម្រោងដឹកជញ្ជូនធំៗចំនួន ១១ ក្រោមគម្រោងធំ ១ ដែលមានឈ្មោះថា «កសាង-ដំណើរការ-ផ្ទាស់ប្ដូរ» ដែលគេប៉ាន់ស្មានថានឹងត្រូវការទឹកប្រាក់សរុប ៨២,១ គោដិប៉េសូ(ប្រហែល ៤,១ លានដុល្លាអាមេរិកបើគិតតាមអត្រាប្ដូរប្រាក់ឆ្នាំ ១៩៩៥) (នេដា ១៩៩៥) ។ គម្រោងទាំង ១១ ស្ថិតនៅទីក្រុងម៉ានីលឬនៅតំបន់ជាប់ក្រុង ។ គម្រោងទាំងនោះរួមមានបណ្ដាញរថភ្លើងដឹកជញ្ជូនធនស្រាល ផ្លូវក្រវាត់ក្រុងម៉ានីល និងផ្លូវលើក្នុងក្រុងម៉ានីល ។ វិសមភាពខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការផ្ដល់សេវាកម្មតាមតំបន់នេះបង្ហាញឲ្យឃើញពីចេតនាឆ្លើយតបនឹងតម្រូវការនៃមូលធនបរទេស ដែលជាហេតុធ្វើឲ្យមានការវិនិយោគសាធារណប្រមូលផ្ដុំនៅក្នុងតំបន់ស្នូលនេះយ៉ាងលើសលុប ។

## ការបង្ហាញអំពីទីក្រុងដែលកំពុងធ្វើសកលភាវូបនីយកម្មនៅអាស៊ីអាគ្នេយ៍

តួនាទីនៃមូលធនអន្តរជាតិនៅក្នុងដំណើរការនគរូបនីយកម្ម និងភាពសមស្របនៃការធ្វើទីផ្សារតំបន់ណាមួយមានន័យថា មនុស្សកាន់ច្រើនមានការចាប់អារម្មណ៍គិតថាទីក្រុង គឺជាខ្នែងនៅក្នុង «លំហរនៃលំហូរ» ។ ដូច្នេះ យើងគួរធ្វើការសិក្សាលើវិធីសាស្ត្រមួយចំនួនដែលធ្វើឲ្យគេយក «ការបង្ហាញអំពីលំហរ» នេះមកអនុវត្តនៅអាស៊ីអាគ្នេយ៍ ។ ដើម្បីយល់ឲ្យបានអំពីការដាក់បញ្ចូលទីក្រុង និងតំបន់មួយចំនួននៅអាស៊ីអាគ្នេយ៍ទៅក្នុងសេដ្ឋកិច្ចពិភពលោកគេបានប្រើប្រាស់នូវពហុក្របខណ្ឌ ប៉ុន្តែគេបានកំណត់ថាការអភិវឌ្ឍទីក្រុង និងតាមតំបន់នៅអាស៊ីអាគ្នេយ៍បច្ចុប្បន្នត្រូវបានស្ថាបនាឡើងតាមទម្រង់ធំៗ ៣ ដែលរួមមាន ÷ ទីក្រុងលំដាប់ពិភពលោក ទីក្រុងរីកលូតលាស់តាមបែបពហុកោណ និងទីក្រុងលូតលាស់តាមការពង្រីកព្រំដែន និងរបៀងក្រុង (សូមមើល ហ្វបស៍ ១៩៩៧ និងយ៉ឹង ១៩៩៥) ។ ទោះបីជាការស្ថាបនានេះមានប្រភពមកពីការជជែកវែកញែកក្នុងថ្នាក់ស្រាវជ្រាវជាន់ខ្ពស់ក៏ដោយ ក៏ការស្ថាបនានីមួយៗសុទ្ធតែមានផលវិបាកសំខាន់លើការធ្វើគោលនយោបាយសម្រាប់ការធ្វើគម្រោង និងការគ្រប់

គ្រងទីក្រុង និងតំបន់មួយចំនួននៅអាស៊ីអាគ្នេយ៍ ។

## ទីក្រុងលំដាប់ពិភពលោក

ពាក្យទីក្រុងលំដាប់ពិភពលោកមានប្រភពនៅក្នុងស្នាដៃរបស់លោកចន ហ្វ្រាយម៉ង់ (John Friedmann) និងអ្នកសិក្សាមួយចំនួនទៀតដែលអះអាងថា គេអាចកំណត់តំបន់ទីក្រុងថាស្ថិតនៅក្នុងឋានានុក្រមលំដាប់ពិភពលោកដោយសំអាងលើការប្រៀបធៀបអំណាចសេដ្ឋកិច្ច (ហ្វ្រាយម៉ង់ (Friedmann) និងវ៉ូល្វ (Wolfe) ១៩៨២ ហ្វ្រាយម៉ង់ គ.ស.១៩៨៦សាស្សែន (Sassen) គ.ស.១៩៩១-១៩៩៤) ។ និយាយម្យ៉ាងវិញទៀត ទីក្រុងមានតួនាទីមួយចំនួនដូចគ្នានឹងតួនាទីនៃតំបន់ប្រជុំជនក្រុង និងកន្លែងដទៃទៀតដែលមានតួនាទីលំដាប់ខ្ពស់ដូចជាបណ្ដាញដឹកជញ្ជូនតាមអាកាស និងឡានសណ្ដាងវែងៗ តួនាទីផ្នែកហិរញ្ញវត្ថុសាកលលោក ផ្នែកច្បាប់ និងផ្នែកគ្រប់គ្រង និងលំដាប់សារសំខាន់ផ្នែកនយោបាយអន្តរជាតិនៅលំដាប់ខ្ពស់ជាងគេក្នុងឋានានុក្រម ។ ឋានៈជាទីក្រុងលំដាប់ពិភពលោកមិនចាំបាច់មានប្រជាជនច្រើននោះទេ ជាក់ស្ដែងសិង្ហបុរីមានចំនួនប្រជាជនតិចជាងទីក្រុងម៉ានីល ឬទីក្រុងហ្សាការតាឆ្ងាយណាស់ប៉ុន្តែក្រុង នេះស្ថិតនៅលំដាប់ខ្ពស់នៅក្នុងឋានានុក្រមទីក្រុងលំដាប់ពិភពលោក ។ តាមលោកហ្វ្រីមែនន៍ (១៩៨៦)សិង្ហបុរីមាននាទីជាទីក្រុងធំលំដាប់ទី ១ ក្នុងប្រទេសអភិវឌ្ឍថ្នាក់កណ្ដាល ចំណែកក្រុងបាងកក និងម៉ានីលជាទីក្រុងធំលំដាប់ទី ២ ។ មកដល់ឆ្នាំ ១៩៩៧ ហ្វ្រីមែនន៍បានកំណត់ប្រទេសសិង្ហបុរីជា «ចំណុចទាក់ទងប្រទេសចំរុះ»(ដែលជាប្រភេទលំដាប់ថ្នាក់ទី ២ របស់លោក) ប៉ុន្តែពុំមានទីក្រុងនៅអាស៊ីអាគ្នេយ៍ណាផ្សេងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ដាក់បញ្ចូលទៅក្នុងឋានានុក្រមរបស់លោកទៀតឡើយ ។

ការសិក្សាមុនៗលើទីក្រុងលំដាប់ពិភពលោកតែងតែពុំយកចិត្តទុកដាក់អំពីតួនាទីរបស់ទីក្រុងនៅក្នុងបរិបទជាតិឬតំបន់ទេ ។ ណក់ស៍បានយល់ឃើញដូច្នេះហើយ បានបង្ហាញពីភាពផ្ទុយគ្នារវាង «ពិភពយឺតយ៉ាវ» នៃជីវិតពិតប្រចាំថ្ងៃនឹង «ពិភពលឿន» នៃការភ្ជាប់ទំនាក់ទំនងកម្រិតពិភពលោក ៖

> បង្កប់នៅក្នុងទីក្រុងលំដាប់ពិភពលោកមានចំណុចខ្ទែងរបស់ «ពិភពលឿន» ជាច្រើននៃប្រព័ន្ធផលិតកម្មបត់បែននិងលំនាំប្រើប្រាស់លំដាប់ខ្ពស់ ។ ពិភពលឿនសព្វថ្ងៃនេះពង្រីកខ្លួនពីតំបន់ស្នូលផ្នែកសេដ្ឋកិច្ចបីរបស់ពិភពលោកទៅដល់តំបន់ក្រីក្រក្រៅៗដែលកំពុងអភិវឌ្ឍនៅក្នុងរាជធានីនៃបណ្ដាប្រទេសកំពុងអភិវឌ្ឍកម្រិតកណ្ដាលនិងប្រទេសក្រីក្រជាងគេ ។ ស្ថានភាពនេះបង្កើតបានជា «ពិភពយឺត» នៅតាមតំបន់ដាច់ស្រយាលដែលមិនងាយប្រែប្រួល តំបន់រោងចក្រសម្រាប់ផលិតមានការធ្លាក់ចុះហើយ និងមានការតាំងលំនៅមិនស្របច្បាប់ច្រើន ។ ទាំងអស់នេះកាន់តែឃ្លាតចាកឆ្ងាយពីវប្បធម៌និងរបៀបរបបរស់នៅរបស់ទីក្រុងលំដាប់ពិភពលោក(ណក់ស៍ (Knox) ១៩៩៥ ទំ. ២៣២-៣៣) ។

ដូច្នេះទស្សនៈបែបទីក្រុងលំដាប់ពិភពលោកសុំឲ្យមានការបែងចែកឲ្យដាច់គ្នារវាងតួនាទីលំដាប់ពិភពលោករបស់ទីក្រុង និងជីវិតពិតរបស់ប្រជាជនក្នុងក្រុង ។ ទស្សនៈបែបនេះមានន័យថា ការធ្វើគោលនយោបាយសង្កត់ធ្ងន់លើការភ្ជាប់ទំនាក់ទំនងរបស់ទីក្រុងជាមួយសាកលលោកជាជាងផ្ដោតលើតួនាទីរបស់ទីក្រុងក្នុងលំដាប់មូលដ្ឋានលំដាប់តំបន់ និងលំដាប់ជាតិ ។ ស្ថានភាពដូច្នេះជំរុញឲ្យមានជាកម្មវិធីធំៗក្នុងការធ្វើនគរូបនីយកម្មខ្នាតធំក្នុងបំណងសំដៅជំរុញទីក្រុងឲ្យឡើងទៅលំដាប់ខ្ពស់នៅក្នុងឋានានុក្រមទីក្រុងលំដាប់ពិភពលោក ។ អាគារភ្លោះ (តួប៉ម ប៉េត្រូណាស់) រាជធានីរដ្ឋបាលពុទ្រាជ័យ និងអាកាសយានដ្ឋានអន្តរជាតិកូឡាឡាំពួរថ្មី គឺជាឧទាហរណ៍ជាក់ស្ដែង ។

*ប៉ុន្តែគេ ក៏អាចលើកយកប្រទេសសិង្ហបុរីដែលមានការិយាល័យកណ្តាលក្រុមហ៊ុនពហុជាតិជាច្រើន (ពែរី ១៩៩២ ១៩៩៥) និងប្រទេសហ្វីលីពីនដែលមានការអភិវឌ្ឍឡើងវិញនូវហ្វតបូនីហ្វាស្សូខ្នាតធំមកធ្វើជាឧទាហរណ៍ អំពីយុទ្ធសាស្ត្រនៃការធ្វើគម្រោង និងការគ្រប់គ្រងទីក្រុងដែលផ្អែកលើទស្សនៈបែបទីក្រុងលំដាប់ពិភពលោកដែរ ។*

## ទីក្រុងរីកលូតលាស់តាមបែបពហុកោណ

*ទស្សនៈទី ២ នៃការបកស្រាយទីក្រុងនៅអាស៊ីអាគ្នេយ៍ជាមួយសេដ្ឋកិច្ចពិភពលោក និងដែលជាទស្សនៈមួយពេញនិយមច្រើននៅក្នុងរង្វង់អ្នកធ្វើគោលនយោបាយ គឺការកំណត់ឲ្យឃើញនូវទីក្រុងរីកលូតលាស់តាមបែបពហុកោណ។ ការរីកចម្រើនបែបពហុកោណនេះបង្កើតឲ្យមានជាការចងគ្នារវាងតំបន់ក្រុង ឬរវាងតំបន់ក្រុងធំមួយជាមួយនឹងតំបន់ដាច់ស្រយាលនៅជិត ដែលភាគច្រើនឆ្លងកាត់ព្រំដែននយោបាយរបស់ប្រទេស ។ យឿង (Yeung ១៩៩៥) បានលើកឡើងថាទាំងនេះ គឺជាបាតុភូតពិសេសមួយរបស់ប្រទេសនៅអាស៊ីជាឧទាហរណ៍តំបន់អភិវឌ្ឍត្រីកោណរវាងសិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី (សូមមើលផ្នែកទី ១០ ក្នុងជំពូកនេះ) ដែលភ្ជាប់ក្រុងសិង្ហបុរីនឹងរដ្ឋចូហ៊ររបស់ម៉ាឡេស៊ីដែលនៅជាប់គ្នា និងប្រជុំកោះរៀវរបស់ឥណ្ឌូនេស៊ី ។ ឧទាហរណ៍ផ្សេងពីនេះរួមមានតំបន់ពហុកោណមាសរវាងភូមា ឡាវ ថៃ និងចិន និងតំបន់អភិវឌ្ឍអាស៊ីខាងកើតជាមួយនឹងហ្វីលីពីន (មីនដាណាវ) ប្រ៊ុយនេ ម៉ាឡេស៊ី (សាបា និងសារ៉ាវ៉ាក់) និងប្រទេសឥណ្ឌូនេស៊ី (ស៊ុលឡាវេស៊ី) ។ ក្នុងករណីនីមួយៗ គោលបំណងយុទ្ធសាស្ត្រ គឺដើម្បីបង្ហាញ ឬមិនដូច្នេះទេដើម្បីបង្កើតជាតំបន់ក្រុងមួយដែលអាចដំណើរការបាន និងអាចពឹងផ្អែកលើគ្នាបាន ។ ទោះជាយ៉ាងនេះក៏ដោយ បើនិយាយពីបញ្ហាគោលនយោបាយវិញ ការចងក្រងថ្នាក់តំបន់ដូច្នេះតែងមានគោលបំណងលើកស្ទួយការវិនិយោគជាចម្បងជាជាងគម្រោងទីក្រុង ឬគម្រោងតាមតំបន់ ។*

## តំបន់ទីក្រុងពង្រីក និងក្រុងរបៀង

*ទស្សនៈទី ៣ ដើម្បីឲ្យយល់អំពីទីក្រុងនៅអាស៊ីអាគ្នេយ៍នៅក្នុងសេដ្ឋកិច្ចពិភពលោកគឺតាមរយៈការវិភាគលើទីក្រុងរីកលូតលាស់តាមការពង្រីកទីក្រុងធំ ឬរបៀងក្រុង ។ លក្ខណៈពិសេសសំខាន់មួយនៃការអភិវឌ្ឍទីក្រុងធំៗនៅអាស៊ីអាគ្នេយ៍ក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ គឺការលេចឡើងនូវទម្រង់ទីក្រុងដែលបានមកពីការពង្រីកក្រុងធំ ។ ការរីកចម្រើននេះឃ្លាតចាកឆ្ងាយពីលំនាំនៃការធ្វើនគរូបនីយកម្មក្នុងតំបន់កាលពីមុន និងឃ្លាតឆ្ងាយពីគំរូអន្តរកាលជនបទ–ទីក្រុងរបស់លោកខាងលិចដែរ (លីនឡិន ១៩៩៤) ។ លោកម៉ាកហ្គី (១៩៨៩) បានហៅទីក្រុងរីកលូតលាស់តាមការពង្រីកក្រុងធំនេះថា «ដេសាកូតា (desakota)» ដោយលោកផ្សំពាក្យភូមិ (ដេសា) ក្នុងភាសាឥណ្ឌូនេស៊ី និងពាក្យប្រជុំជន (កូតា) ដើម្បីបង្ហាញនូវសមាហរណកម្មរវាងតំបន់ទាំងពីរទាំងក្នុងផ្នែកតួនាទីទាំងទិដ្ឋភាព និងដើម្បីបញ្ជាក់អំពីសារៈសំខាន់នៃការប្រើបច្ចេកសព្ទជាភាសាអ្នកស្រុកអាយជាជាងបំណែងចែករបស់លោកខាងលិចក្នុងការស្វែងយល់អំពីការធ្វើនគរូបនីយកម្មនៅអាស៊ី (ម៉ាកហ្គី ១៩៩១ សូមអានឯកសាររបស់ហ្វបស៍ធៀបសេគ.ស.១៩៩៧ ផងដែរ) ។ យោងតាមម៉ាកហ្គី តំបន់ដេសាកូតាគឺជា*

> តំបន់ពិសេសដែលមានសកម្មភាពខាងកសិកម្មនិងមិនមែនកសិកម្ម. . ..កើតឡើងដោយនៅជាប់ ឬនៅចន្លោះតំបន់ទីក្រុងស្នូល ។ តំបន់នេះកើតឡើងដោយសារតែលក្ខខណ្ឌដែលមានពីមុនមក កាលទេសៈ ការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា និងការផ្លាស់ប្តូរខាងកម្លាំងពលកម្មដែលកើតឡើងតាមលក្ខណៈ

ខុសៗគ្នា ផ្សំនឹងចលនានៃកត្តាទាំងអស់នេះនៅក្នុងបណ្តាប្រទេសឧស្សាហកម្មលោកខាងលិចនៅសតវត្សទី ១៩ និងដើមសតវត្សទី ២០ (ម៉ាកហ្គី ១៩៩១ : ៤)។

ដូច្នេះលំនាំនៃការធ្វើនគរូបនីយកម្មតាមបែបដេសាកូតា គឺជាការបង្កើតជាតំបន់ពិសេសមួយដែលមិនគ្រាន់តែពាក់ព័ន្ធនឹងសម្ពាធប្រជាជននៅតំបន់ក្រុងស្នូល ឬការរីកចម្រើនដាយក្រុងមកក្រៅនោះទេ ប៉ុន្តែដេសាកូតាជាលំនាំនៃការធ្វើនគរូបនីយកម្មតាមតំបន់ដើម្បីបង្កើតជាតំបន់ក្រុងធំ ។ នៅតំបន់ខ្លះមិនគ្រាន់តែមានការផ្លាស់ប្តូរលើការប្រើប្រាស់ដីធ្លី និងរចនាសម្ព័ន្ធសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែក៏មានការផ្លាស់ប្តូរច្រើនលើរចនាសម្ព័ន្ធគ្រួសារ ជីវិតសង្គម និងគ្រួសារ នយោបាយនៅមូលដ្ឋាន និងទំនាក់ទំនងអំណាចព្រមទាំងបរិដ្ឋានហេដ្ឋារចនាសម្ព័ន្ធ (សម្រាប់បាងកកសូមមើលសែតថែល ១៩៩៥ រ៉ូស និងពួងសមលី ១៩៩៥) ។ ឧទាហរណ៍គំរូអំពីទម្រង់ទីក្រុងធំៗទាំងនេះមាននៅទីក្រុងបាងកក ហ្សាការតា និងម៉ានីល ប៉ុន្តែសូម្បីទីក្រុងលំដាប់ទី ២ ដូចជាបាន់ឌុង ហ្សុកថោន និងឈាងម៉ៃក៏ធ្លាប់ទទួលនូវការពង្រីកតាមលំនាំប្រហាក់ប្រហែលគ្នានេះដែរ ហើយក្នុងករណីខ្លះបានបង្កើតជាផ្នែកមួយនៃការពង្រីករបៀងនៃការធ្វើនគរូបនីយកម្មមានផ្លូវដឹកជញ្ជូនធំៗច្រើនទៀតផង ។

កត្តាស្ថានភាព និងកត្តាប្រវត្តិសាស្ត្របានធ្វើឲ្យការធ្វើនគរូបនីយកម្មក្នុងទម្រង់នេះខុសពីបទពិសោធន៍នៅលោកខាងលិច ។ កត្តាទី ១ គឺទីតាំងទីក្រុងធំៗនៅអាស៊ីអាគ្នេយ៍ស្ថិតនៅក្នុងតំបន់ដែលមានតុងស៊ីតេប្រជាជនខ្ពស់ និងដែលពឹងផ្អែកលើកម្លាំងពលកម្មដាំដុះស្រូវ ។ ទំនាក់ទំនងនេះមានន័យថា សក្តានុពលកម្លាំងពលកម្មយ៉ាងច្រើន (និងទីផ្សារ) សម្រាប់វិស័យឧស្សាហកម្ម និងសេវាកម្មមាននៅហួសពីព្រំដែនផ្លូវច្បាប់របស់ទីក្រុងដែលជាហេតុធ្វើឲ្យការប្រមូលផ្តុំជាទីប្រជុំជនមាននៅតែជុំវិញតំបន់ទាំងនេះ ។ កត្តាទី ២ ដែលភាគច្រើនមានប្រភពចេញពីដុងស៊ីតេប្រជាជនខ្ពស់គឺ «ស្ថានភាពទាក់ទងនឹងការដោះដូរ» ធូន់ធ្ងរនៅតាមតំបន់កសិកម្មដែលប្រើប្រាស់នូវមធ្យោបាយដឹកជញ្ជូនច្រើនបែបតែថោកៗ ដូចជារម៉កកង់បី បេកាក ស៊ីក្លូ រថយន្តដឹកជញ្ជូនតូចៗ ឡានឈ្នួលតូចៗ និងកាណូត ។ ចំណុចទាំងនេះបានធ្វើឲ្យចរាចរណ៍ទំនិញ មូលធន និងពិសេសការធ្វើដំណើររបស់មនុស្សមានការងាយស្រួលដែលជាហេតុធ្វើឲ្យការប្រមូលផ្តុំបង្កើតជាទីក្រុងមិនមានការចាំបាច់ ។

អ្វីដែលធ្វើឲ្យការធ្វើនគរូបនីយកម្មនៅអាស៊ីអាគ្នេយ៍បច្ចុប្បន្ន ខុសពីបទពិសោធន៍ពីមុននៅក្នុងតំបន់គឺថាកម្លាំងរុញច្រានសំខាន់បំផុតនៅពីក្រោយការពង្រីកទីក្រុង គឺការកើនឡើងនូវឧស្សាហូបនីយកម្មដែលបានមកពីតម្រូវការសម្រាប់នាំចេញ និងវិនិយោគបរទេសនៅតាមតំបន់ស្នូលរបស់ជាតិដែលបានពង្រីកនាខាងដើមរួចហើយ។ ខណៈដែលទីក្រុងភាគច្រើន នៅក្នុងតំបន់ជាការបន្តមរតកពីមូលធនអាណានិគម លំហូរនៃការវិនិយោគបច្ចុប្បន្នផ្តល់ជាការរីកចម្រើនច្រើនជាងការកេងប្រវញ្ចផ្ទាល់ៗ ។

ដូច្នេះគេអាចបង្ហាញបានថា ការរីកលូតលាស់តាមបែបពង្រីកទីក្រុង គឺជាស្ថានភាពខាងភូមិសាស្ត្រមួយដែលជាលទ្ធផលនៃការហូរចូលនូវមូលធនពិភពលោក មកក្នុងបរិដ្ឋានដែលមានស្រាប់រួមនឹងកត្តាស្ថានភាព និងប្រវត្តិសាស្ត្រដែលបង្កើតតំបន់ពង្រីកពិសេសមួយលើតំបន់កសិកម្មឲ្យក្លាយជាទីក្រុងនៅក្នុងតំបន់ស្នូលរបស់ជាតិ ។ ផលវិបាកលើផ្នែកគោលនយោបាយនៃទស្សនៈនេះភាគច្រើនមានទំនោរទៅលើការគ្រប់គ្រង និងការធ្វើគម្រោងសម្រាប់ទីក្រុង ៖ ទី ១ ដោះស្រាយជាមួយតំបន់ពង្រីកទីក្រុងតាមរយៈការផ្តល់សេវាកម្មឲ្យប្រសើរជាងមុនដែលមានជាអាទិ៍ខាងផ្នែកសំណល់រឹង និងការធ្វើគម្រោងខាងផ្នែកគមនាគមន៍ ។ ទី ២ សំដៅសម្រួលនូវសម្ពាធសម្រាប់ការរីកចម្រើនតាមរយៈយុទ្ធសាស្ត្រដែលមានគោលបំណងចែករំលែកនូវមូលធនសម្រាប់ការវិនិយោគ

លើផ្នែកហេដ្ឋារចនាសម្ព័ន្ធទីក្រុងទៅឲ្យតំបន់ជិតខាង (យើងនឹងពិភាក្សាពីបញ្ហានេះខាងក្រោមទៀត) ។

## នគរូបនីយកម្ម និងឧស្សាហកម្មពហុកម្រិត

ទោះជាទស្សនៈការបង្ហាញអំពីទីក្រុង និងផលប៉ះពាល់លើផ្នែកគោលនយោបាយ បកស្រាយខាងលើខុសគ្នាពីមួយទៅមួយទាំងក៏ដោយ ក៏ទស្សនៈទាំងអស់បានយល់ស្របគ្នាក្នុងកម្រិតមួយថានគរូបនីយកមកើតឡើងដោយដំណើរការក្នុងកម្រិតលំហរសេដ្ឋកិច្ចពិភពលោក ។ ការសិក្សាជាច្រើនពុំសូវបង្ហាញថាទីក្រុងជាស្ថាប័ន សង្គមរឹងមាំដែលមាននៅក្នុងប្រពៃណីក្នុងតំបន់ទេ ។ ប៉ុន្តែគេច្រើនបង្ហាញថាទីក្រុងគឺជាខ្នងនៅក្នុងទំនាក់ទំនងនៃលំហូរមូលធនពិភពលោក ។ យើងអះអាងថា ទោះជាកម្លាំងសេដ្ឋកិច្ចពិភពលោក គឺជាកត្តារុញច្រានសំខាន់បំផុតនៅពីក្រោយដំណើរការនគរូបនីយកម្មក៏ពិតមែន ក៏ដំណើរការនេះកើតឡើងក្នុងកម្រិតច្រើនហើយការផ្តោតការវិភាគជាអាទិភាពទៅលើសេដ្ឋកិច្ចសាកលលោកបានបិទបាំងនូវដំណើរការសាំញ៉ាំជាច្រើនដែលកើតឡើងនៅក្នុងផ្នែកដទៃទៀតនៃជីវិតសង្គម និងដែលអាចកើតឡើងតាមការវិភាគក្នុងកម្រិតផ្សេងទៀត ។ ការអះអាងនេះមិនមានន័យថា «ស្រុកអាយ» មានដំណើរការសង្គមដាច់ដោយឡែកពី «ពិភពលោក» នោះទេ ។ ប៉ុន្តែការអះអាងនេះគ្រាន់តែជាការអះអាងសុំឲ្យមានការទទួលស្គាល់ថា ដំណើរការនៃការផ្លាស់ប្តូរសេដ្ឋកិច្ចនិងសង្គមកើតឡើងក្នុងកម្រិតច្រើនក្នុងពេលស្របគ្នា ។ លោកហូបស៍បានលើកឡើងថ្មីៗនេះថា ÷

> នៅក្នុងការបង្ហាញខ្នាតធំៗទាំងនេះ មានកន្លែងតូចចង្អៀតណាស់សម្រាប់ភាពដោយឡែកៗ និងកត្តាផ្សេងៗ ។ ការសន្និដ្ឋានខាងសេដ្ឋកិច្ចនយោបាយរាប់បញ្ចូលដោយអចេតនានូវយន្តកម្មខាងក្នុង ឬការអភិវឌ្ឍទីក្រុង ភាពតូចល្អិតនៃនយោបាយក្នុងប្រទេស សារៈសំខាន់នៃលំនាំជីវិតបែបទីក្រុង ភាពតានតឹងនៅក្នុងរចនាសម្ព័ន្ធសង្គមដែលប្រេះស្រាំ វប្បធម៌ទំនើបនិយមច្រើនផ្នែក និងការប្រឆាំងនឹងបម្លាស់ប្តូរ (ហូបស៍ ១៩៩៧ : ៤៦២)[៥] ។

យើងយល់ស្របជាមួយលោកហូបស៍ដែលថា ផ្នែកនៃជីវិតនៅទីក្រុងដែលលោករៀបរាប់ខាងលើមិនត្រូវបានគេយកមកបកស្រាយនោះទេ និងថាការស្វែងរកនូវវិធីបកស្រាយដទៃទៀតអាចផ្តល់ជាទស្សនៈផ្សេងៗអំពីដំណើរការ និងបទពិសោធក្នុងការធ្វើនគរូបនីយកម្មនៅអាស៊ីអាគ្នេយ៍ពិតជាមានសារៈសំខាន់ ។ ប៉ុន្តែយើងនឹងអះអាងថា វិធីសាស្ត្របែប «សេដ្ឋកិច្ចនយោបាយ» មិនចាំបាច់កើតមុនសម្រាប់វិធីសាស្ត្រផ្សេងៗទៀតទេ ផ្ទុយទៅវិញដែលចាំបាច់នោះ គឺសេដ្ឋកិច្ចនយោបាយមួយនៃការធ្វើនគរូបនីយកម្មដែលមានច្រើនកម្រិត និងទាក់ទងទៅនឹងកត្តាស្ថានភាព និងប្រវត្តិសាស្ត្រផ្សេងៗនៃជីវិតនៅទីក្រុង ។

នៅក្នុងការសិក្សាអំពីនគរូបនីយកម្មអ្នកនិពន្ធជាច្រើនពិសេសភូមិវិទ្យាវិទូបានយកចិត្តទុកដាក់លើសារសំខាន់ក្នុងការចៀសវាងមិនផ្តល់ការចាប់អារម្មណ៍ច្រើនពេកលើដំណើរការកម្រិតធំ[៦] ។ ក្នុងករណីតំបន់លូតលាស់តាមការពង្រីកទីក្រុងនៅម៉ានីល លោកខែលី (១៩៩៨-១៩៩៩) បានបង្ហាញអំពីការចូលរួមចំណែកនៃការធ្វើសាកលភាវូបនីយកម្មសេដ្ឋកិច្ចហ្វីលីពីន នៅក្នុងការពង្រីកទីក្រុង ប៉ុន្តែការចូលរួមនេះកើតមានក្នុងដំណើរការសង្គមតាមកម្រិតជាច្រើន ។ ក្នុងកម្រិតថ្នាក់ជាតិ គេមានក្របខណ្ឌគោលនយោបាយច្បាស់លាស់សម្រាប់គ្រប់គ្រងការប្រើប្រាស់ និងផ្លាស់ប្តូរដី ប៉ុន្តែជាញឹកញាប់គោលនយោបាយទាំងនេះគេមិនយកមកអនុវត្ត និងត្រូវបំផ្លាញដោយយុទ្ធសាស្ត្រអភិវឌ្ឍដែលសំដៅទៅរកការធ្វើឧស្សាហូបនីយកម្មជាជាងការធ្វើទំនើបកម្មខាងផ្នែកកសិកម្ម ។

ក្នុងកម្រិតរដ្ឋាភិបាលថ្នាក់ក្រុងនៅក្នុងខេត្តកាវីត (Cavite) ដែលនៅជាប់ទីក្រុងម៉ានីល ច្បាប់អនុញ្ញាតិឲ្យមានភាពបត់បែនក្នុងការបកស្រាយច្បាប់ស្តីពីការបែងចែកជាតំបន់ និងក្នុងការកំណត់លើការប្រើប្រាស់ដី ។ សំខាន់ជាងនេះទៀត ភាពបត់បែននេះត្រូវបានគេយកមកអនុវត្តនៅក្នុងបរិបទមួយដែលពុំមានព្រំដែនច្បាស់លាស់រវាងតួនាទីសាធារណៈ និងតួនាទីឯកជន និងរវាងការទទួលខុសត្រូវខាងការគោរពតែងច្បាប់ និងផលប្រយោជន៍ឯកជន ។ ចំណែកនៅកម្រិតបុគ្គលនៃទំនាក់ទំនងរវាងម្ចាស់ដី អ្នកជួលដី និងអ្នកមានឥទ្ធិពលខាងនយោបាយនៅមូលដ្ឋានវិញ កសិករជួលដីគេមានការលំបាកសូម្បីតែក្នុងការទាមទារសិទ្ធិស្របច្បាប់ឲ្យមានជាសំណងគ្រប់គ្រាន់ ឬជាការផ្តល់ដីតាមរយៈកំណែទម្រង់ដីធ្លី ។ កត្តាស្ថានភាពទាំងអស់នេះបង្កើតបានជាដំណើរការសង្គមសាំញ៉ាំយ៉ាងច្រើនដែលពិតជាបានជំរុញឲ្យមានដំណើរការនគរូបនីយកម្មនៅម៉ានីល (ការបំព្រួញកត្តាទាំងអស់មកជាការផ្តួផ្គង ក្នុងកម្រិតខ្ពស់នៃមូលធនសាកលលោកឲ្យត្រូវនឹងបរិដ្ឋានក្រុង គឺធ្វើឲ្យយើងភ្លេចគិតនូវចំណុចជាច្រើន) ។

ដំណើរការដូចគ្នានេះត្រូវបានគេរកឃើញនៅក្នុងការសិក្សាជាច្រើនអំពីទីក្រុងហ្សាការតា និងការពង្រីកក្រុងនេះទៅក្នុងតំបន់ហ្សាបូតាបែក និងឆ្ពោះទៅតំបន់ដេសាកូតា នៅជុំវិញបាន់ឌុងតម្រង់ទៅទិសខាងកើត (ហ្វឺមែន១៩៩៥ -១៩៩៦) ។ លីហ្វ (១៩៩៤–១៩៩៦)សិក្សាលើកម្លាំងវប្បធម៌ ឬមនោគមវិជ្ជា និងកត្តាសេដ្ឋកិច្ចដែលរុញច្រានឲ្យមានការអភិវឌ្ឍនៅហ្សាបូតាបែក ។ លោកបានអះអាងថា ក្នុងនាមជានិមិត្តរូបខាងមនោគមនវិជ្ជា ការពង្រីកតំបន់ជាយក្រុងទៅក្នុងតំបន់ដេសាកូតាបង្ហាញនូវទំនើបកម្ម និងការអភិវឌ្ឍដែលផ្តល់នូវធម្មានុរូបភាពដល់គោលនយោបាយសេដ្ឋកិច្ចរបស់ស៊ូហាតូ ។ ជាមួយគ្នានេះកម្លាំងសេដ្ឋកិច្ចនៅពីក្រោយដេសាកូតា គឺពួកវណ្ណៈកណ្តាលនៅផ្លូវនេស៊ីដែលមានចំនួនកាន់តែច្រើន និងឧស្សាហកម្មខាងការអភិវឌ្ឍទ្រព្យសម្បត្តិដែលមាននិរន្តរភាពបានដោយសារចំណងនយោបាយ និងបរិដ្ឋានគោលនយោបាយអនុគ្រោះ (សូមមើលឌូក្លាស ១៩៨៩ និងហិនដឺសុន ល. ១៩៩៦) ។ ស្នាដៃនេះធ្វើឲ្យយើងមានសំណួរសំខាន់ៗជាច្រើនអំពីតួនាទីនៃកត្តាសង្គម នយោបាយ និងស្ថាប័ននៃដំណើរការកសាងទីក្រុង នៅក្នុងក្រុង និងនៅតាមតំបន់ ។ យើងមើលឃើញថា ដំណើរការនៃការភ្ជាប់ទំនាក់ទំនងទៅនឹងលំហូររបស់សកលលោកនៅតាមតំបន់ក្រុងមួយចំនួន (និងក្រុមសង្គម) និងការផ្តាច់ទំនាក់ទំនងនៅតាមតំបន់ក្រុងដទៃទៀត មិនមែនគ្រាន់តែជាការបង្ហាញអំពីដាននៃ «មូលធនសាកលលោក» ដូចដែលទស្សនៈមួយចំនួនអះអាងនោះទេ ។ ពេលដែលតំបន់ទីក្រុងធំៗនៅអាស៊ីអាគ្នេយ៍រីកចម្រើន លម្ហទីក្រុងត្រូវផ្លាស់ប្តូររូបរាងទៅជាបណ្តាញទំនាក់ទំនងរវាងអ្នកទីក្រុងវណ្ណៈថ្នាក់ខ្ពស់ និងថ្នាក់កណ្តាល ប៉ុន្តែក៏បានធ្វើឲ្យ «លម្ហជាច្រើនដែលនៅជាយខាងមិនអាចចូលរួមនៅក្នុងបណ្តាញនេះបានដែរ ពីព្រោះបណ្តាញទាំងនេះឆ្លងកាត់លម្ហដោយពុំអនុញ្ញាតឲ្យអ្នកមូលដ្ឋានចូលដល់បាន» (Rkaham ១៩៩៧ : ១១២) ។

## ទិសដៅនៅអនាគត៖ នគរូបនីយកម្ម និងសាកលភាវូបនីយកម្មដែលងាយនឹងប្រែប្រួល

ដូច្នេះ តើដំណើរការគ្រប់កម្រិតនៃការអភិវឌ្ឍបែបមូលធននិយមនិងនគរូបនីយកម្មនឹងកើតឡើងយ៉ាងណានៅថ្ងៃអនាគត? តើគេត្រូវគ្រប់គ្រង ឬសម្របសម្រួលដំណើរការទាំងនេះយ៉ាងណាដើម្បីបង្កើតជាបរិដ្ឋានទីក្រុងដែលអាចរស់នៅបាននៅអាស៊ីអាគ្នេយ៍? វិបត្តិសេដ្ឋកិច្ចដែលចាប់ផ្តើមនៅឆ្នាំ ១៩៩៧ និងការធ្លាក់ចុះនៅអាស៊ីអាគ្នេយ៍បង្ហាញនូវការផ្លាស់ប្តូរនូវតួនាទីរបស់ប្រព័ន្ធទីក្រុងមួយចំនួន ។ យើងនឹងបង្ហាញនូវទិសដៅចំនួន ៥ សម្រាប់ការ

ធ្វើនគរូបនីយកម្មធ្វើដំណើរទៅនៅក្នុងបរិបទសម័យសាកលភាវូបនីយកម្មដ៏ផុយស្រួយ ។

ទី ១ ៖ ការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ពិតជាបានធ្វើឲ្យគម្រោងបង្កើតទីក្រុងធំៗនៅក្នុងតំបន់ឲ្យក្លាយជាក្រុងលំដាប់ពិភពលោកលែងសូវមានសារៈសំខាន់ ។ ជាក់ស្តែង គេឃើញមានការលុបចោលនូវគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធធំៗនៅទូទាំងតំបន់ទាំងមូល ។ ខណៈដែលកិច្ចខិតខំប្រឹងប្រែងដូចជាអាកាសយានដ្ឋានអន្តរជាតិគួឡាឡាំពួរ និងរបៀងផ្សារទំនើបនៅម៉ាឡេស៊ីបន្តដំណើរការ គម្រោងចំណាយផ្សេងទៀតរួមមានបណ្តាញផ្លូវដែកថ្មីមួយទៅអាកាសយានដ្ឋានអន្តរជាតិនិងទៅអាកាសយានដ្ឋានមួយផ្សេងទៀតនៅរដ្ឋភាគខាងជើងគឺរដ្ឋកេដាហ៍ត្រូវផ្អាក[៧] ។ ជាមួយគ្នានោះ ប្រព័ន្ធផ្លូវជាន់លើនៅបាងកក និងកោះដូវត្រូវបានគាំង ។ បូករួមនឹងការគាំងស្ទះខាងការវិនិយោគក្នុងផ្នែកឯកជន សម្គាល់ឲ្យមានការពង្រីកក្រុងត្រូវស្រាកស្រាន្ត ។

ទី ២ ៖ ការធ្លាក់ចុះខាងផ្នែកសេដ្ឋកិច្ចបានធ្វើឲ្យវិស័យអចលនទ្រព្យគាំង ។ ការធ្លាក់ចុះទីផ្សារអចលនទ្រព្យដែលមានអតិផរណាហួសហេតុ គឺជាបុព្វហេតុចម្បងមួយដែលនាំឲ្យមានការធ្លាក់ចុះតម្លៃលុយបាតថៃនៅពាក់កណ្តាលឆ្នាំ ១៩៩៧ ហើយវិស័យអចលនទ្រព្យនៅក្នុងតំបន់ទាំងមូលត្រូវទទួលរងគ្រោះយ៉ាងខ្លាំង ។ ដោយសារការធ្លាក់ចុះនៅទីផ្សារ និងការប្រុងប្រយត្នរបស់ធនាគារក្នុងការពាក់ព័ន្ធនឹងការវិនិយោគខាងអចលនទ្រព្យអាចមានន័យថា សម្គាល់ឲ្យមាននគរូបនីយកម្មនៅតំបន់ពង្រីកក្រុងត្រូវថយចុះជាពុំខាន ។ ការផ្លាស់ប្តូរការប្រើប្រាស់ដីកសិកម្មនៅតាមតំបន់ពង្រីកក្រុងនៅអាស៊ីអាគ្នេយ៍ទាំងនេះក៏ថមថយដែរ ។

ទី ៣ ៖ បម្រែបម្រួលពីប្រឆាំងគ្នាអាចលេចចេញជារូបរាងនៅក្នុងការវិវឌ្ឍនៃប្រព័ន្ធទីក្រុង និងការអភិវឌ្ឍតំបន់នៅអាស៊ីអាគ្នេយ៍ ។ ទោះជាមានលំនាំប្រមូលផ្តុំនៃការអភិវឌ្ឍឧស្សាហកម្មហើយទីក្រុងបន្តមានសារសំខាន់ជាងគេក៏ដោយ ក៏មានសញ្ញាខ្លះបង្ហាញអំពីការងាកទៅរកការធ្វើវិមជ្ឈការដែរ ។ ដូចដែលបានពិពណ៌នាមកពីខាងលើទិដ្ឋភាពចម្បងនៃការរីកចម្រើនបែបទីក្រុងនៅតំបន់ទីក្រុងពង្រីកនៅអាស៊ីអាគ្នេយ៍ គឺការកសាងនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងគមនាគមន៍ដែលផ្តល់នូវបរិដ្ឋានងាយស្រួលដល់សេដ្ឋកិច្ចបែបទីក្រុង ។ ទោះជាយ៉ាងនេះក៏ដោយ ខណៈដែលដំណើរការសាកលភាវូបនីយកម្មនៅបន្ត លម្ហសេដ្ឋកិច្ចនៅតែបន្តប្រែប្រួលដែរ ។ ប្រការនេះបានធ្វើឲ្យទស្សនៈមួយដែលនិយាយថា «មានតែតំបន់ពិសេសប៉ុណ្ណោះដែលមានសារៈសំខាន់ខ្លាំងជាងគេខាងផ្នែកសេដ្ឋកិច្ចជាតិ» អាចឈប់ពេញនិយមទៀតហើយ ។ ការរៀបចំសេដ្ឋកិច្ចនៅកម្រិតផ្សេងទៀតកាន់តែមានសារសំខាន់ខ្លាំងឡើងៗ ហើយឋានានុក្រមទីក្រុងថ្នាក់ជាតិអាចនឹងឈប់ជាលំនាំនៃសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ទៀតហើយ ។ នៅពេលអនាគត តំបន់តូចៗនៅអាស៊ីអាគ្នេយ៍ក៏អាចនឹងភ្ជាប់ខ្លួនទៅនឹងសេដ្ឋកិច្ចសាកលលោកបានល្អដូចគ្នាដែរ (ឌូក្លាស ១៩៩៨) ។ ជាក់ស្តែងនៅប្រទេសហ្វីលីពីន ចំនួនការងារនៅរដ្ឋធានីមានការថយចុះនៅទសវត្សឆ្នាំ ១៩៩០ ដូចមានបង្ហាញនៅក្នុងតារាង ៧.២ ។ ទិន្នន័យដទៃទៀតក៏គាំទ្រចំពោះបម្រែបម្រួលនេះដែរ ។ នៅខែមិថុនាឆ្នាំ ១៩៩២ ក្នុងចំណោមក្រុមហ៊ុនឧស្សាហកម្មចំនួន ៣២ ក្រុមហ៊ុន ២៨ ដំណើរការនៅរដ្ឋធានី ។ មកដល់ខែមករា ឆ្នាំ ១៩៩៨ក្នុងចំណោមតំបន់សេដ្ឋកិច្ចចំនួន ៨០ មានតែ ៤៦ទេដែលដំណើរការនៅទីក្រុងម៉ានីល និងតំបន់ក្បែរៗក្រុង ។ ដូច្នេះ គេសង្កេតឃើញថា សារសំខាន់អាចត្រូវរីកសាយភាយទៅតាមតំបន់ដទៃហើយឋានុក្រមទីក្រុងអាចនឹងត្រូវលុបបំបាត់ដោយសារក្រុងដូចជាចចថោន ប្កបាត់ចឹវ៉ស បាតាយ៉ា និងសេប៊ូកាន់តែមានសារៈសំខាន់ច្រើនឡើងៗ ។

នៅពេលជាមួយគ្នានេះការធ្លាក់ចុះផ្នែកសេដ្ឋកិច្ច ក៏បានបង្កើតនូវនិន្នាការអភិវឌ្ឍបញ្ច្រាសវិញខ្លះដែរ ។

ឧទាហរណ៍ នៅប្រទេសថៃកម្មសិទ្ធិសម្រាប់ក្រុមហ៊ុនបរទេសនៅទីក្រុងបាងកក និងតំបន់ជុំវិញក្រុងមានតែសម្រាប់ឧស្សាហកម្មមួយចំនួនប៉ុណ្ណោះ ប៉ុន្តែនៅតំបន់ឆ្ងាយៗច្បាប់ស្តីពីកម្មសិទ្ធិមានលក្ខណៈសេរីជាងនេះ ។ ទោះជាយ៉ាងនេះក៏ដោយនៅឆ្នាំ ១៩៩៨ ដើម្បីឆ្លើយតបនឹងការធ្លាក់ចុះនៃការវិនិយោគ និងតម្រូវការបន្ទាន់ខាងមូលធនថ្មីទៀត រដ្ឋាភិបាលថៃបានអនុញ្ញាតឲ្យមានកម្មសិទ្ធិពេញលេញសូម្បីតែនៅក្នុងរាជធានី ។ ដូច្នេះផ្ទុយនឹងបម្រែបម្រួលដែលបង្ហាញពីខាងលើ គោលនយោបាយនេះអាចនាំឲ្យមានសម្ពាធជាថ្មីលើការអភិវឌ្ឍនៅក្នុងតំបន់ទីក្រុងពង្រីក និងការធ្លាក់ចុះនូវការចាប់អារម្មណ៍លើការអភិវឌ្ឍនៅតំបន់ឆ្ងាយៗ(៨) ។ និយាយម្យ៉ាងទៀត វិបត្តិសេដ្ឋកិច្ចអាចនាំឲ្យមានការយកចិត្តទុកដាក់ច្រើនជាថ្មីម្តងទៀតលើទីក្រុង ដោយសារតែភ្នាក់ងាររៀបចំគម្រោងសេដ្ឋកិច្ចព្យាយាមទាក់ទាញការវិនិយោគថ្មីៗដោយយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះលើការអភិវឌ្ឍនៅតំបន់ដទៃ ។

ទី ៤÷ ពេលដែលសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍រីកចម្រើនខ្លាំង ទីក្រុងបានក្លាយជាមជ្ឈមណ្ឌលដែលមានកម្លាំងទិញខ្ពស់ និងការសាយភាយខាងផ្នែកវប្បធម៌ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ខណៈដែលការធ្លាក់ចុះខាងផ្នែកសេដ្ឋកិច្ចបានធ្វើឲ្យវណ្ណៈកណ្តាលរងគ្រោះ ទីក្រុងមួយចំនួននៅក្នុងតំបន់បានក្លាយជាចំណុចស្នូលនៃចលាចលសង្គម និងជម្លោះជាតិសាសន៍ ។ ការលំបាកដែលកាន់តែកើនឡើង និងការមិនពេញចិត្តជាប់រហូតមកបានបណ្តាលឲ្យមានភាពជាសត្រូវនឹងគ្នានៅតាមតំបន់ទីក្រុងនៅទូទាំងប្រទេសឥណ្ឌូនេស៊ី និងក្នុងចំណោមអ្នកទីក្រុងនៅក្នុងរាជ-ធានីបាងកក ។ នៅប្រទេសថៃ រដ្ឋាភិបាលថ្មីមួយបានកើតឡើងនៅខែកញ្ញា ឆ្នាំ ១៩៩៧ ហើយនៅប្រទេសឥណ្ឌូនេស៊ីប្រជាជនខឹងសម្បានឹងលោកស៊ូហាតូ និងជនជាតិឥណ្ឌូនេស៊ីអំបូរចិនដែលជាគោលដៅនៃអរិភាពក្នុងប្រវត្តិសាស្ត្រ ។ ការតវ៉ាប្រឆាំងនៅតាមទីក្រុងនៅទូទាំងប្រជុំកោះបាននាំទៅរកជម្លោះហិង្សា ។ ប្រភពមួយចំនួនបានប៉ាន់ស្មានថា មានមនុស្សជាង ១០០០ នាក់បានស្លាប់នៅក្នុងពេលធ្វើការតវ៉ា ការធ្វើកូដកម្ម និងការលួចប្លន់នៅក្នុងខែមេសា និងឧសភា ឆ្នាំ១៩៩៨ ។ ការតវ៉ាប្រឆាំងទាំងនេះដឹកនាំដោយក្រុមនិស្សិតមកពីតាមមហាវិទ្យាល័យក្នុងក្រុង និងមានការចូលរួមពីវណ្ណៈកណ្តាលក្នុងក្រុង ហើយបានជំរុញឲ្យស៊ូហារតូចុះចេញពីតំណែងនៅថ្ងៃទី ២១ ឧសភាឆ្នាំ ១៩៩៨ ។ ដូចព្រឹត្តិការណ៍នៅហ្វីលីពីនកាលពីឆ្នាំ ១៩៩៨ ដែរ អ្នកទីក្រុង (មិនមែនអ្នកនៅតាមទីជនបទដែលមានចំនួនច្រើនទេ) នឹងបន្តជំរុញឲ្យមានការផ្លាស់ប្តូរខាងផ្នែកសង្គម និងនយោបាយនៅអាស៊ី-អាគ្នេយ៍ ។

ទី ៥÷ វិបត្តិសេដ្ឋកិច្ចនៅឆ្នាំ ១៩៩៧-៩៨ បាននាំមកនូវការផ្លាស់ប្តូរសំខាន់ៗដល់ទស្សនៈលើលម្ហទីក្រុងនិងសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ ។ នៅក្នុងកំលុងពេលនៃការធ្លាក់ចុះ ការប្រគួតប្រជែងសម្រាប់ការវិនិយោគខាងមូលធននៅក្នុងតំបន់កាន់តែមានលក្ខណៈស្រួចស្រាវ ។ ជាមួយគ្នានេះ គេក៏កាន់តែមើលឃើញនូវភាពខុសគ្នារវាងលម្ហសេដ្ឋកិច្ចជាតិរបស់ប្រទេសមួយនឹងប្រទេសមួយទៀត ។ ឧទាហរណ៍ លោកនាយករដ្ឋមន្ត្រីសិង្ហបុរី ហ្គូចុកតុងបានធ្វើការកត់សម្គាល់ថា «ទីផ្សារដែលកំពុងកើតឡើងចាំបាច់ត្រូវតែចែកឲ្យដាច់ពីប្រទេសមួយទៅប្រទេសមួយ» ។ ការកត់សម្គាល់នេះបានបង្ហាញថា ពេលគេសិក្សាពីឱកាសវិនិយោគគេលែងគិតថា អាស៊ីអាគ្នេយ៍ជាករណីរួមទៀតហើយ ។ និយាយម្យ៉ាងទៀតការចងជាក្រុមដូចជា «សេដ្ឋកិច្ចអាស៊ី» និង «បញ្ហារបស់អាស៊ី» (ដែលជាការអនុវត្តនាំឲ្យមានការរីកសាយភាយនូវគ្រោះថ្នាក់ខាងផ្នែកហិរញ្ញវត្ថុ) បច្ចុប្បន្នកំពុងតែបើកច្រកឲ្យមានការបែងចែកឲ្យដាច់ពីគ្នាក្នុងផ្នែកលម្ហសេដ្ឋកិច្ច និងអាចបណ្តាលឲ្យមានការប្រគួតប្រជែងកាន់តែខ្លាំងរវាងទីក្រុងទាំងអស់នៅក្នុងតំបន់ ។ ការតាមដានលើឥទ្ធិពលនៃដំណើរការនេះលើផ្នែក «ការរីកចម្រើនបែបពហុកោណ» ដែល

*ពិពណ៌នាមកពីខាងលើដែលកើតឡើងពីការយល់ថា ការរីកចម្រើនដែលបានមកពីការសហការគ្នាអាចកើតឡើងបានពីតំបន់សេដ្ឋកិច្ចអន្តរប្រទេសជាការអន្តេតគួរឲ្យចាប់អារម្មណ៍ណាស់ ។ យើងប្រហែលជានឹងឃើញនូវដំណើរការនៃការបំបែកជាបំណែកតូចៗ (ដំណើរការរួមគ្នារវាងសាកលភាវូបនីយកម្ម និងមូលដ្ឋាននីយកម្ម)នៅក្នុងលម្ហសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ដោយសារមូលធនបរទេស មើលឃើញកាន់តែច្បាស់អំពីភាពខុសគ្នារវាងក្របខ័ណ្ឌច្បាប់ជាតិរបស់ប្រទេសនីមួយៗ ហើយតំបន់ក្រុងលំដាប់ទី ២ របស់ជាតិនីមួយៗកាន់តែត្រូវប្រកួតប្រជែងកាន់តែខ្លាំងសម្រាប់មូលធនកម្រ ។*

## សេចក្តីសន្និដ្ឋាន៖ ឥទ្ធិពលលើគោលនយោបាយ

*ការងើបឡើងវិញខាងផ្នែកសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍នឹងបណ្តាលឲ្យមានការផ្លាស់ប្តូរខាងផ្នែកស្ថាប័ន ។ ចនហ្វ្រីតមែន (១៩៩៧ក) បានកំណត់នូវឧបសគ្គចំនួនបីដែលមានចំពោះការគ្រប់គ្រងអន្តរកាលនៅទីក្រុង÷ ទី១គឺភាពចាំបាច់ក្នុងការបង្កើតឲ្យមានជាប្រព័ន្ធអភិបាលកិច្ចប្រកប ដោយប្រសិទ្ធភាពសម្រាប់តំបន់ទីក្រុងដែលកាន់តែរីកចម្រើន និងដែលអាចផ្តល់ខាងផ្នែកច្បាប់ សារពើពន្ធ និងបច្ចេកទេសដល់ក្របខណ្ឌស្ថាប័នដើម្បីគ្រប់គ្រងអន្តរកាលទីក្រុង ។ ទី ២គឺភាពចាំបាច់ក្នុងការយកចិត្តទុកដាក់លើនិរន្តរភាពក្នុងការគ្រប់គ្រងអន្តរកាលនេះ និងទី ៣ គឺថា«ការធ្វើគម្រោងគួរតែឲ្យក្លាយជាដំណើរការមួយដែលមានលក្ខណៈបើកចំហ និងប្រកបដោយការចូលរួមច្រើនជាងបច្ចុប្បន្ន និងមានលទ្ធភាពគ្របដណ្តប់លើកម្លាំងរបស់ក្រុមសង្គមស៊ីវិលពិសេសក្រុមមនុស្សដែលគេមិនយកចិត្តទុកដាក់....»( ហ្វ្រីតមែន ១៩៩៧ ក:៤) ។*

*ក្នុងចំណោមឧបសគ្គទាំងបីនេះការគិតគូរពីបញ្ហាអភិបាលកិច្ចទីក្រុងនៅក្នុងបរិបទតំបន់អាស៊ីអាគ្នេយ៍ គឺជាកិច្ចការសាំញ៉ាំជាងគេបំផុតក្នុងរូបភាពច្រើនយ៉ាង ។ ទី ១ដោយសារបញ្ហានេះមានកប់យ៉ាងជ្រៅនៅក្នុងសេដ្ឋកិច្ចនយោបាយរបស់បណ្តាប្រទេសនៅអាស៊ីជាច្រើន ។ និយាយឲ្យពិតទៅបញ្ហានេះ ក៏ត្រូវបានគេធ្វើសមាហរណកម្មយ៉ាងជ្រៅទៅក្នុងដំណើរការសាកលភាវូបនីយកម្មដែលយើងបានពិពណ៌នាពីខាងដើមមក ។ ទំនាក់ទំនងនេះកើតឡើងក៏ដោយសារវេជនខាងនយោបាយមានទស្សនវិស័យថាទីក្រុង គឺជាតំបន់ប្រជុំជនដែលមានលក្ខណៈប្រកួតប្រជែងកម្រិតពិភពលោក ។ ការស្រាវជ្រាវលើបញ្ហាអភិបាលកិច្ចនៅតាមប្រទេសជឿនលឿនផ្តោតសំខាន់លើការកើតឡើងរាជធានីធំៗដែលជាទម្រង់ទីក្រុងមានឧត្តមភាពជាងគេនៅចុងសតវត្សទី ២០ប៉ុន្តែនៅតាមប្រទេសកំពុងអភិវឌ្ឍភាគច្រើនអំណាចនយោបាយស្ថិតនៅកម្រិតជាតិ និងខេត្តនៅឡើយហើយបញ្ហាអភិបាល-កិច្ចតាមរាជធានីធំៗនៅពុំទាន់ជាអាទិភាពនៅអាស៊ីនៅឡើយទេ ។ វរជនខាងនយោបាយមានការចាប់អារម្មណ៍លើការរក្សាទាំងអំណាចនយោបាយទាំងអំណាចសេដ្ឋកិច្ច និងចាប់អារម្មណ៍លើការជំរុញឲ្យមានយុទ្ធសាស្ត្រ«អភិវឌ្ឍ» ដែលបង្កើតឡើងដើម្បីធ្វើឲ្យទីក្រុងកាន់តែមានលក្ខណៈប្រកួតប្រជែងនៅក្នុងតំបន់ប៉ុណ្ណោះ ។ ទោះជាយ៉ាងណា ដោយសារការធ្លាក់ចុះផ្នែកសេដ្ឋកិច ការដាក់សម្ពាធជំរុញឲ្យមានការធ្វើវិមជ្ឈការអំណាចនេះមានកាន់តែច្រើនឡើងៗ ។*

*បញ្ហានៃការធ្វើវិមជ្ឈការអំណាចនេះពិតជាកត្តាសំខាន់ក្នុងការកំណត់នូវជោគជ័យក្នុងអភិបាលកិច្ចទីក្រុង ព្រោះថា ជោគជ័យនេះអាស្រ័យទាំងស្រុងលើសុច្ឆន្ទៈរបស់រដ្ឋាភិបាលជាតិក្នុងការអនុញ្ញាតឲ្យរដ្ឋាភិបាលទីក្រុងទទួលបាននូវការទទួលខុសត្រូវកាន់តែច្រើនជាងមុនលើការយកពន្ធ ការគ្រប់គ្រងដីធ្លី ហេដ្ឋារចនាសម្ព័ន្ធទីក្រុង*

និងការដឹកជញ្ជូន ។ ទីនេះមានបដិមតិព្រោះថា ខណៈពេលដែលរដ្ឋាភិបាលជាតិចង់ក្តោបអំណាចនយោបាយលើទីក្រុងធំៗ ក្របខណ្ឌគោលនយោបាយបច្ចុប្បន្នក្នុងការកាត់បន្ថយច្បាប់ ឯកជនភាវូបនីយកម្ម និងការកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលដែលជាផ្នែកមួយនៃគម្រោងអភិវឌ្ឍ (ដែលគាំទ្រដោយទីភ្នាក់ងារហិរញ្ញវត្ថុអន្តរជាតិដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ) តម្រូវឲ្យរដ្ឋាភិបាលជាតិផ្តល់អំណាចនេះដល់ភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ និងភ្នាក់ងារឯកជនថ្នាក់ក្រុង ។ នៅក្នុងបរិបទតំបន់អាស៊ីអាគ្នេយ៍ ល្បឿននៃការផ្តល់អំណាចនេះមានភាពពុំទៀតទាត់ខ្លាំងណាស់ ។

ឧបសគ្គទី ២ ដែលការរីកចម្រើននៃតំបន់ទីក្រុងធំៗបង្កើតឡើង គឺការធ្វើឲ្យទីក្រុងមានការរស់នៅកាន់តែស្រួល ។ ការនិយាយបែបនេះអាចទទួលយកបានច្រើនជាងការប្រើពាក្យ «និរន្តរភាព» ព្រោះថា តំបន់ទីក្រុងពឹងផ្អែកលើធនធានមកពីខាងក្រៅតិចបំផុត ។ ជាទូទៅបញ្ហានិរន្តរភាពដែលផ្តោតសំខាន់លើការវិចរិលផ្នែកបរិដ្ឋាននៅក្នុងតំបន់ទាំងនេះ[៩] ការបំពុលបរិយាកាស និងបំពុលទឹក បញ្ហាសម្អាតកាកសំណល់ និងសម្អាតដីត្រូវបានគេយល់ថាជាបញ្ហាចំពោះនិរន្តរភាពទីក្រុងធំៗ ។ ជារឿយៗបញ្ហាបរិដ្ឋានទាំងនេះត្រូវបានគេយល់ថាជាលទ្ធផលនៃការរីកលូតលាស់របស់ទីក្រុងជាជាងដោយសារបរាជ័យក្នុងការគ្រប់គ្រង ។ យើងយល់ស្របជាមួយចនហ្វ្រីមែនថាវិធីសាស្ត្រក្នុងការធ្វើឲ្យមាននិរន្តរភាពនេះពុំទាន់គ្រប់គ្រាន់នៅឡើយទេ ហើយថាគេគួរយកចិត្តទុកដាក់ឲ្យកាន់តែច្រើនជាងមុនលើការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព ។ ជាចុងក្រោយ ការបង្កើតឲ្យមានបរិដ្ឋានមួយប្រកបដោយនិរន្តរភាពមិនអាស្រ័យតែលើការកំណត់ខាងបច្ចេកវិទ្យានោះទេ ប៉ុន្តែអាស្រ័យលើការសម្រេចយកគោលនយោបាយស្តីពីការអភិវឌ្ឍធនធានមនុស្ស ។ គោលការណ៍គ្រឹះបច្ចុប្បន្នក្នុងការសិក្សាពីការអភិវឌ្ឍដើម្បីដាក់បញ្ចូលបញ្ញត្តិ «មូលធនសង្គម» ជាធាតុមួយសំខាន់ចាំបាច់សម្រាប់ការអភិវឌ្ឍបានទទួលយល់ស្របថាមូលធនខាងមនុស្ស និងខាងស្ថាប័នគឺជាតម្រូវការស្នូលសម្រាប់ការអភិវឌ្ឍ ។ និយាយអំពីតំបន់ទីក្រុងធំៗវិញ គេអះអាងថាតំបន់ទាំងនេះជាទូទៅមាន «មូលធនសង្គម» ក្នុងកម្រិតខ្ពស់ជាងជាតិទាំងមូលទៀតពិសេសខាងផ្នែកធនធានមនុស្ស ។ទោះជាយ៉ាងណាក៏ដោយ តម្រូវការចាំបាច់បំផុតគឺត្រូវអភិវឌ្ឍធនធានស្ថាប័នដែលអាចជំរុញឲ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើតំបន់ទីក្រុងធំៗ ។

តម្រូវការនេះមួយផ្នែក គឺជាឧបសគ្គទី ៣ ដែលលោកចនហ្វ្រីតមែនដាក់ចេញដើម្បីធ្វើឲ្យប្រព័ន្ធអភិបាលកិច្ចទីក្រុងកាន់តែអាចឆ្លើយតបទៅនឹងតម្រូវការ និងការចង់បានរបស់ប្រជាពលរដ្ឋៗ នៅក្នុងបរិបទខ្លះ គេហៅយុទ្ធិសាស្ត្រនេះថាជា «យុទ្ធិសាស្ត្រផ្តល់អំណាច» ដែលធ្វើឲ្យប្រជាជននៅក្នុងមូលដ្ឋានកាន់តែមានការចូលរួមច្រើននៅក្នុងការធ្វើគម្រោងសម្រាប់មូលដ្ឋានរបស់ខ្លួន ។ យុទ្ធសាស្ត្រផ្តល់អំណាចនេះអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែគេផ្តល់អំណាចដល់សហគមន៍ខាងផ្នែកសារពើពន្ធជាដើមដើម្បីធានាឲ្យបានថាសេចក្តីសម្រេចចិត្តរបស់ប្រជាជនមូលដ្ឋានត្រូវបានគេយកទៅអនុវត្ត (ហ្វ្រីតមែន ១៩៩២ ឌូក្លាស និងហ្វ្រីតមែន ១៩៩៨) ។

យើងអាចធ្វើសេចក្តីសន្និដ្ឋានបានតាមរយៈការដកស្រង់ពីស្នាដៃរបស់លោកឌិនស៍ ហ្វូបស៍ដែលនិយាយថា «ចំណុចដែលជាឧបសគ្គគឺថា យើងត្រូវរុករកបន្ថែមទៀតលើដំណើរការដែលបង្កើតជាទម្រង់ទីក្រុងថ្មីៗដោយផ្តោតជាពិសេសលើការប្រគួតប្រជែងខាងវប្បធម៌ដែលជាអ្នកកំណត់នូវការស្រមើលស្រមៃទាំងនេះ និងផ្តោតលើដំណើរការ និងយន្តកម្មខាងនគរូបនីយកម្មក្នុងប្រទេសនីមួយៗដែលទទួលយក ឬប្រឆាំងនឹងបម្លាស់ប្តូរចំពោះជីវិតរបស់អ្នកទីក្រុង» (ហ្វូបស៍ ១៩៩៧ : ៤៦៦) ។ ដូច្នេះកតព្វកិច្ចបន្តទៅទៀតគឺយើងត្រូវទទួលស្គាល់ថាការ

ស្រមើលស្រមៃបង្កើតជាដំណើរការនគរូបនីយកម្មដែលគេធ្វើឡើង គេជំរុញឲ្យមានហើយគេអនុវត្តនៅក្នុងកម្រិតច្រើន និងត្រូវបានថាលម្អទីក្រុងថ្មីនៅអាស៊ីអាគ្នេយ៍នឹងកាន់តែផ្តល់ភាពងាយស្រួលដល់ការរស់នៅ ៕

# ជំពូកទី ៤

# ឥទ្ធិពលប្រជាសាស្ត្រក្នុងការកំណត់ចំនួនយុវជន នៅក្នុងបណ្តាទីក្រុងនៅអាស៊ី

*ដោយ ភីតធឺ ស៊ីនុស*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* "Demographic Forces Shaping Youth Populations in Asian Cities" ។

*អត្ថបទនេះ ដកស្រង់ចេញពីសៀវភៅ ៖ យុវជន ភាពក្រីក្រ ហើយនិងជម្លោះក្នុងទីក្រុងអាស៊ីអាគ្នេយ៍ ។*

*រក្សាសិទ្ធិ គ.ស. ២០០៤ ដោយគ្រឹះស្ថានបោះពុម្ព វូតត្រូ វីលសុន ។*

## CHAPTER 4:

Demographic Forces Shaping Youth Populations in Asian Cities
Xenos, Peter
Youth, Poverty and Conflict in Southeast Asian Cities

**Copyright © 2004, Woodrow Wilson Center Press.**

បកប្រែដោយ សាយ ពុទ្ធី

# ជំពូកទី ៤
# ឥទ្ធិពលប្រជាសាស្ត្រក្នុងការកំណត់ចំនួនយុវជននៅក្នុងបណ្ដាទីក្រុងនៅអាស៊ី

មានកត្តាដ៏សំខាន់មួយស្ថិតនៅពីក្រោយហេតុការណ៍នានារបស់យុវជនអាស៊ីនាសម័យទំនើបនៅតាមបណ្ដាទីក្រុងនៅអាស៊ី ដែលកត្តានោះស្ដីអំពីប្រជាសាស្ត្រមូលដ្ឋាន[១]ៗ ជំពូកនេះមានបំណងធ្វើការពណ៌នា និងពន្យល់អំពីកត្តាប្រជាសាស្ត្រនេះ និងឥទ្ធិពលរបស់កត្តានេះខ្លះៗចំពោះចំនួនយុវជននៅតំបន់ទីក្រុងនាពេលសម័យទំនើបទូទាំងអាស៊ី ។ ការពិភាក្សានេះគ្របដណ្ដប់លើតំបន់អាស៊ីទាំងមូល ប៉ុន្តែខ្ញុំផ្ដោតសំខាន់ទៅលើ ប្រទេសចំនួនបួនគឺប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន កូរ៉េខាងត្បូង និងថៃ ដែលជាកន្លែងអាចប្រមូលបាននូវទិន្នន័យលម្អិតដើម្បីយកមកបង្ហាញអំពីផ្នែកសំខាន់ៗរបស់កត្តាប្រជាសាស្ត្រនេះៗ

ចំណុចសំខាន់សម្រាប់តំបន់ទាំងនេះទាំងមូល គឺចំនួនកើនឡើងនៃយុវជនដែលបង្កើតបានជា «កំណើនដ៏មហិមានៃយុវជន» សព្វថ្ងៃនេះ ឬយើងហៅថាជា «បំទុះឡើងនៃចំនួនយុវជន» ។ ពាក្យគន្លឹះទាំងនេះពីរសំដៅទៅលើ÷ ១) ការកើនឡើងនៃបមាណភាគរបស់ចំនួនយុវជននៃចំនួនប្រជាជនសរុបនិង ២) អត្រាកំណើតចំនួនប្រជាជនជាយុវជនច្រើនជាងយ៉ាងខ្លាំងពីអត្រាកំណើនសម្រាប់ចំនួនប្រជាជនសរុបទាំងអស់ ។ នៅទូទាំងអាស៊ីអត្រាកំណើតយុវជនមានពេលខ្លះកើនដល់ ៦% ក្នុងមួយឆ្នាំដែលជាកម្រិតមធ្យមសម្រាប់មួយទសវត្ស ។ ហើយបមាណភាគចំនួនយុវជននៃចំនួនប្រជាជនសរុបមានពេលខ្លះកើនស្ទើរតែនឹងដល់ ២៤%ៗ ការវិភាគលើកំណើនយ៉ាងមហិមានៃចំនួនយុវជនអាស៊ីនេះផ្អែកលើបរិបទប្រជាសាស្ត្រទូលំទូលាយជាភស្តុតាង ។

ទោះបីជាមានកំណើនយ៉ាងឆាប់រហ័សនៃចំនួនយុវជនទាំងអស់នៅទូទាំងអាស៊ីក៏ពិតមែន ការវិភាគបង្ហាញថាកំណើនដ៏មហិមានៃចំនួនយុវជនជាទូទៅ គឺជាបាតុភូតបណ្ដោះអាសន្នតែប៉ុណ្ណោះ ហើយលើសពីនេះទៀតកំណើននេះ គឺជាបាតុភូតដែលកើតចេញពីកត្តាពីរបន្ថែមទៀតនៃកត្តាប្រជាសាស្ត្រទាំងមូល ។ កត្តាទាំងពីរនេះគឺ÷ ១) ការផ្លាស់ទីមានលក្ខណៈជាប្រព័ន្ធពីជនបទទៅទីក្រុងរបស់យុវជន និងភាពខុសគ្នាយ៉ាងខ្លាំងរវាងអត្រាកំណើនយុវជន និងបមាណភាគយុវជននៅតំបន់ជនបទ-ទីក្រុង ហើយនិង ២) បម្រែបម្រួលដ៏សំខាន់នៅក្នុងសង្គមក្នុងចំណោមយុវជន ដែលក៏កំពុងតែកើតឡើងផងដែរនោះ ។

ជាញឹកញាប់ ដូចបានបង្ហាញនៅក្នុងទិន្នន័យដែលខ្ញុំបានពិនិត្យនោះ បម្រែបម្រួលសង្គមនៃយុវជនទាំងនេះកំពុងតែកើតឡើងទន្ទឹមគ្នាជាមួយ និងការផ្ទុះឡើងនៃចំនួនយុវជន និងការផ្លាស់លំនៅ ឬចំណាកស្រុកទៅកាន់តំបន់ទីក្រុង ។

ការវិភាគលើកឡើងនៅពេលនេះសង្កត់ធ្ងន់ទៅលើកម្លាំងសរុបរួមនៃកត្តាទាំងបី ÷ ១) ការកើន ឡើងនៃចំនួនយុវជន ២) បម្រែបម្រួលសង្គមដ៏លម្អិត និង ៣) ការផ្ដោតសំខាន់នៃចំណុចពីរខាងលើនៅក្នុងបណ្ដាតំបន់ទីក្រុងៗ កំណើនយុវជនជាតិនីមួយៗភាគច្រើន គឺជាបាតុភូតតំបន់ទីក្រុង ដែលឆ្លុះបញ្ចាំងអំពីការហូរចូលយ៉ាងសន្ធឹកសន្ធាប់គ្រប់ទីកន្លែងនៃយុវជនមកកាន់ទីក្រុងជាពិសេសបណ្ដាទីក្រុងធំៗ ។ ម្យ៉ាងវិញទៀត យុវជនទីក្រុងពាក់ព័ន្ធយ៉ាងសំខាន់ទៅនឹងបម្រែបម្រួលសង្គមសំខាន់ៗដែលកំពុងតែបង្កើតឲ្យមាននូវសមាមាត្រច្រើនឡើងទៀតនៃចំនួន

យុវជននៅលើវសមាមាត្រកើនឡើងនៃចំនួនយុវជនចុះឈ្មោះចូលរៀន និងសមាមាត្រធ្លាក់ចុះនៃចំនួនយុវជននៅក្នុងកម្លាំងការងារ ។ ខ្ញុំសូមធ្វើការពិនិត្យទៅលើវិធានការដែលអាចមាននៃបម្រែបម្រួលទាំងនេះ និងធ្វើការបង្ហាញថាមានតំបន់ទីក្រុង និងសូម្បីតែទីក្រុងធំៗ សម្រាប់ការប្រែប្រួលទាំងនោះ ។

ជាទូទៅកស្តុតាងសម្រាប់កំណើនយុវជនបានធ្វើឲ្យមានការចាប់អារម្មណ៍គួរឲ្យកត់សម្គាល់ ដោយមានវិធានវាស់ស្ទង់កំណើនយុវជនធ្វើជាសូចនាករនៃបញ្ហា ។ តាមគំនិតរបស់ ហាន់ទីងទុង Hun-tington (គ.ស.១៩៩៦) ស្តីអំពី «ការប៉ះទង្គិចគ្នានៃអរិយធម៌» ដែលត្រូវបានពិភាក្សាវែកញែកយ៉ាងទូលំទូលាយនោះ ការផ្ទុះឡើងនៃចំនួនយុវជនមានតួនាទីយ៉ាងសំខាន់មួយ ជាពិសេសនៅក្នុងតំបន់មជ្ឈឹមបូព៌ា (ហាន់ទីងទុង ជំពូកទី ៥ ជាពិសេសតារាងលេខ ២ បោះពុម្ព នៅគ.ស. ១៩៩៦)[២]។ ដូចអ្នកនិពន្ធដទៃទៀតដែរ ហាន់ទីងទុង យកបមាណភាគយុវជន ២០% ឬច្រើនជាងនេះជាសូចនាករនៃករណីឧក្រិដ្ឋកម្ម ការរំខានផ្នែកសង្គមស៊ីវិល និងសូម្បីតែភាពតានតឹងខាងនយោបាយដ៏ជ្រាលជ្រៅ ។ ហាន់ទីងទុង ចាត់ទុក «ការបូកបញ្ចូលគ្នារវាងទំហំចំនួនយុវជន និងចល័តភាពសង្គម»ហើយយល់ថាយុវជនជា «គាំទ្រការប្រឆាំងតវ៉ា អស្ថិរភាព កំណែទម្រង់ និងបដិវត្តន៍» (យោងតាមឯកសារដដែលទំ. ទី ១១៧) ។

ការវាយតម្លៃថ្មីៗផ្សេងៗទៀតស្របទៅនឹងការព្រួយបារម្ភទូទៅរបស់ ហាន់ទីងទុង ដែរ ថ្វីបើមិនមែនស្របតាមន័យវិនាសកម្មរបស់គាត់ក៏ដោយ ។ នៅដើមគ.ស. ១៩៨៩ គណៈកម្មការដោះស្រាយវិបត្តិចំនួនប្រជាជនបានសិក្សាអំពីការទាក់ទងគ្នារវាងកំណើនយុវជន និងអស្ថិរភាពសង្គម[៣]។ ថ្មីៗនេះទៀត ទីទែប្បូម Teitelbaum (គ.ស.២០០០) បានធ្វើការពណ៌នាពីបុរសនៅលីវដែលមានអាយុពី ១៥ ដល់ ២៥ ឆ្នាំ ថាជាមនុស្សមានសក្តានុពល «ដ៏គ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សង្គម» ។ លោកបានសួរដែរថា តើការកើនឡើងនៃចំនួនយុវជនអាចបង្កើតឲ្យមានសភាពទន់ខ្សោយយ៉ាងលើសលុបបានដែរឬទេ? គាត់និយាយថាកត្តានេះអាចកើតឡើងនៅពេលដែលចំនួនយុវជនបុរសៗ «មិនមានការងារធ្វើ មិនបានទទួលការអប់រំពីសាលារៀន ឬទាហ៊ាន ឬក៏មិនស្ថិតក្រោមការគ្រប់គ្រងរបស់អាណាព្យាបាល ឬសហគមន៍» ។ ថ្មីៗនេះ យើងមានទីភ្នាក់ងារព័ត៌មានកណ្តាលរបស់សហរដ្ឋអាមេរិក (Central Intelligence Agency) (២០០១) ដែលផ្តល់ការវាយតម្លៃលើនិនាការ ឬទំនោរប្រជាសាស្ត្រពិភពលោកប្រើរយៈពេលវែងមួយ ដែលសរុបសេចក្តីមកដូចគ្នានេះដែរ ។ សូម្បីតែនៅពេលថ្មីៗជាងនេះទៅទៀតនោះវិទ្យាស្ថានវិទ្យាសាស្ត្រជាតិរបស់ សហរដ្ឋអាមេរិក (U.S. National Academy of Science) បានផ្តល់ការវិភាគមួយដើម្បីឆ្លើយតបទៅនឹងព្រឹត្តិការណ៍ថ្ងៃទី ១១ ខែកញ្ញា គ.ស. ២០០១ ដែលជាថ្ងៃវាយប្រហាររបស់ភាវរករ (ស្មែលសឺ (Smelser និងHuntington Mitchell គ.ស.២០០២) ។ ផ្នែកមួយនៃការវិភាគនេះមានចំណងជើងថា «ការពិចារណាឡើងវិញទៅលើផ្នែកសេដ្ឋកិច្ច និងប្រជាសាស្ត្រ» ហើយនិងមានសេចក្តីបន្ថែមស្តីអំពីប្រជាសាស្ត្រដ៏វែងអន្លាយមួយទៀតផងដែរ (ហាម៉ែល (Hammel) និងស្មិត្ស (Smith) គ.ស.២០០២) ។ របាយការណ៍ចម្បងនោះធ្វើការពិភាក្សាទៅលើ «អនុបាតនៃភាពពឹងផ្អែករបស់យុវជន» ថាជាកត្តាមួយដែលដាក់ «សម្ពាធដ៏ធ្ងន់ទៅលើប្រព័ន្ធអប់រំរបស់សង្គមទាំងនោះហើយក៏ជាកត្តាដែលធ្វើឲ្យសមាមាត្រប្រជាជនជាយុវជនមានអត្រាខ្ពស់ខាងផ្នែកសេដ្ឋកិច្ចផលិត» (យោងតាមឯកសារដដែល ទំ. ទី ២៩) ។

អ្នកស្រាវជ្រាវភាគច្រើនទាំងនេះចេះគិតគូរបានគ្រប់គ្រាន់ក្នុងការពិចារណាទៅលើកន្សោមកត្តាជាច្រើនដែលអាចជំរុញឲ្យមានអស្ថិរភាពសង្គម ហើយពួកអ្នកស្រាវជ្រាវទាំងនោះធ្វើការពិនិត្យយ៉ាងល្អិតល្អន់ទៅលើលក្ខខណ្ឌជាក់លាក់ដើម្បីឲ្យកំណើនចំនួនយុវជនមួយអាចឲ្យគេចាត់ទុកថា មានសារៈសំខាន់ ។ ខាល (Kahl គ.ស.

២000) មិនយល់ឃើញថាសម្ពាធខាងប្រជាសាស្ត្រជាលក្ខខណ្ឌសំខាន់ ឬគ្រប់គ្រាន់សម្រាប់ការតស៊ូរបស់ប្រជាជនស៊ីវិលឡើយ ដូចដែលរិងហ្គិន្ស (Wriggins គ.ស.១៩៨៨ និងគ.ស. ១៩៨៩) បានលើកឡើងពីយូរមកហើយថាចំនួនយុវជនគឺជា «ការផ្តល់ឲ្យនូវគាពហិនហោច» ដែលជាបញ្ហាមួយអាចត្រូវបានគេដោះស្រាយយ៉ាងប្រសើរ ឬមិននោះ គឺអាស្រ័យទៅលើថាតើមានកំណើនយុវជនច្រើនឬក៏អត់? ការវិភាគរបស់គីហ្វិទ្ស (Keyfitz គ.ស.១៩៧១ គ.ស.១៩៧៣ និងគ.ស.១៩៨៦) ក៏បានបង្ហាញ ពីនិន្នាការដូចគ្នានេះដែរ ។ កងកម្លាំងពិសេសដោះស្រាយភាពបរាជ័យរបស់រដ្ឋ (របស់អេស្ទី (Esty et al) និងអ្នកស្រាវជ្រាវឯទៃទៀត គ.ស.១៩៩៥) ដែលគាំទ្រដោយភ្នាក់ងារពត៌មានកណ្តាលរបស់សហរដ្ឋអាមេរិក បានធ្វើការសន្និដ្ឋានថាកំណើនយុវជនច្រើនគ្រាន់តែជាសូចនាករដ៏ខ្សោយមួយប៉ុណ្ណោះក្នុងការប៉ាន់ស្មានពីភាពបរាជ័យរបស់រដ្ឋ ។ ការសន្និដ្ឋាននេះធ្វើឡើងដោយផ្អែកទៅលើកម្រងទិន្នន័យបានពីទូទាំងពិភពលោកដ៏ធំមួយ និងដោយផ្អែកលើខ្នាតទម្រង់សម្រាប់ការវាស់ស្ទង់ទំនាក់ទំនងពហុកត្តា ។

គួរឲ្យចាប់អារម្មណ៍ផងដែរថា ក្រុមភ្នាក់ងារពត៌មានកណ្តាលបានបង្ហាញពីការព្រួយបារម្ភលើ «ឱនភាពរបស់យុវជន» ដែលជាបញ្ហាមួយប្រភេទផ្សេងទៀតដែលអាចក្លាយជាកត្តាមួយនៅពេលដែល បមាណភាគរបស់យុវជនធ្លាក់ចុះមកក្រោម ១៥% បន្តបន្ទាប់ (ភ្នាក់ងារពត៌មានកណ្តាលរបស់សហរដ្ឋអាមេរិក គ.ស.១៩៩០) ។ បញ្ហាមួយនេះក៏បង្កើតឲ្យមានអ្នកចូលរួមក្នុងកម្លាំងពលកម្មមិនគ្រប់គ្រាន់ ។ នៅក្នុងការបង្ហាញខាងក្រោមនេះ យើងអាចធ្វើការប្រៀបធៀបសុចនករនៃកំណើនយុវជននៅអាស៊ីសម្រាប់ឱនភាពយុវជន និងការកើនឡើងដ៏មហិមានៃចំនួនយុវជនដោយប្រើកម្រិត ឃ្នាត ១៥% និង២០% ។

ដោយសង្កេតមើលឲ្យស៊ីជម្រៅទៅលើចំនួនសរុបទាំងនេះ ឃើញមានការចាប់អារម្មណ៍ទៅលើគោលនយោបាយ និងកម្មវិធីនៅក្នុងក្រុមដាក់លាក់មួយចំនួនរបស់យុវជន ។ ក្រុមទាំងនោះត្រូវបានគេ គិតថាមានឱកាសច្រើនក្នុងការជួបប្រទះនឹងបញ្ហា ហើយនិងពាក់ព័ន្ធទៅនឹងសកម្មភាពហិង្សា ឬក៏សកម្មភាពរំខាន ។ ជាតួយ៉ាងក្រុមយុវជនជនជាតិភាគតិចសិងហ្គាលីស (Singalese) និងតាមិល (Tamil) នៅប្រទេសស្រីលង្កា ត្រូវបានធ្វើការសិក្សាស្រាវជ្រាវដោយ ហ្វូលី (Fuller គ.ស.១៩៩៥) ។ រីឯ ប្រីនាន់ ហ្គាលវិន (Brennan-Galvin គ.ស.២00២) បានធ្វើការពិចារណាទៅលើអត្រាអំពើហិង្សាឡើងខ្ពស់នៅក្នុងចំណោមយុវជន ហើយជាពិសេសក្នុងចំណោមយុវជននៅលីវក្មេងៗ ។ហើយ ហ្គោលស្តូន (Goldstone គ.ស. ១៩៩១ និងគ.ស.២00២ ទំ. ទី១០) រកឃើញបញ្ហាជាច្រើននៅក្នុង «ការកើនឡើងយ៉ាងរហ័សនៃចំនួនយុវជនដែលមានការអប់រំខ្ពស់ ដែលស្ថិតនៅក្នុងសង្គមដែលមានរចនាសម្ព័ន្ធដ៏មានកម្រិតមួយរបស់ក្រុមវរជន»។

ការវិភាគខាងលើនេះគួសបញ្ជាក់អំពីផ្នែកខ្លះៗនៃចំនួនប្រជាជនដែលអាចមានគេចាប់អារម្មណ៍ ។ ផ្នែកទាំងនេះរួមមាន៖ ក្រុមយុវជនបុរសមិនទាន់រៀបការ ក្រុមយុវជនចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សា និងក្រុមយុវជនទាំងពីរភេទដែលនៅលីវប៉ុន្តែមិនចូលសាលារៀន ។ ជាតួយ៉ាង យើងនឹងឃើញថាក្នុងចំណោមយុវជនបុរសនៅក្នុងប្រទេសឥណ្ឌូនេស៊ីក្នុងកំលុងទសវត្ស ៧០ មានអត្រាកើនឡើងរួមមាន៖ ២៣% សម្រាប់ចំនួនប្រជាជនសរុប ៣៦% សម្រាប់បុរសវ័យក្មេងអាយុចាប់ពី ១៥ ដល់ ១៩ ឆ្នាំ ៥៤% សម្រាប់បុរសក្មេងទាំង នោះដែលរស់នៅទីក្រុងយ៉ាកាតា (Jakarta) ដែលជាទីក្រុងធំមួយមានប្រជាជនរស់នៅច្រើន ៥៦% សម្រាប់បុរសនៅលីវក្មេងៗនៅក្នុងទីក្រុងយ៉ាកាតា និង ១២១% សម្រាប់បុរសនៅទីក្រុង យ៉ាកាតា ដែលនៅលីវក្មេងៗបានចុះឈ្មោះចូលរៀន ។

ផ្នែកឯទៀតនៅក្នុងជំពូកនេះនឹងរៀបរាប់អំពីចំណុចដូចខាងក្រោម ÷ ១) ខ្ញុំនឹងធ្វើការសិក្សាពីលំដាប់

លំដោយថ្នាក់ជាតិនៃការផ្លាស់ប្តូរប្រជាសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ ។ ការផ្លាស់ប្តូរនេះ គឺជាការបញ្ចូលគ្នាខាងប្រជាសាស្ត្រដ៏សំខាន់នៅទូទាំងអាស៊ី ក្នុងកំលុងពេលចុងក្រោយសតវត្សទី ២០ (មជ្ឈមណ្ឌលបស្ចឹមបូព៌ា (East-West Center) គ.ស.២០០២ ជុំវិញបន្ទាត់ ១៥) ។ ទ្រង់ទ្រាយសំខាន់ៗថ្នាក់ជាតិនៃភាពដូចគ្នានិងខុសគ្នា កើតចេញពីពេលវេលានៃការផ្លាស់ប្តូរប្រជាសាស្ត្រផ្សេងៗគ្នានៅគ្រប់ទីកន្លែងនៅអាស៊ី ហើយបញ្ហានេះមានឥទ្ធិពលទៅលើពេលវេលានៃរលកអាយុកំពុងកើតមាន រួមមានរលកអាយុដែលយើងហៅថាការផ្ទុះឡើងនៃចំនួនយុវជន (Tulca Bulkar Tulja ផុលការកំពុងបោះពុម្ពផ្សាយ)[៤]។

បន្ទាប់មកយើងនឹងធ្វើការសិក្សាទៅលើការបំបែកចេញនូវចំនួនយុវជនតាមជនបទ និងចំនួនយុវជននៅទីក្រុង ហើយនិងការបំបែកចេញនូវផ្នែកដែលមានប្រជាជនរស់នៅច្រើននៃចំនួនយុវជននៅទីក្រុង ។ ការបំបែកចេញនេះនឹងផ្តល់ឲ្យនូវទម្រង់ថ្នាក់ជាតិជាក់លាក់នៃកំណើនយុវជន និងអត្រាកំណើន យុវជន ក៏ដូចជាការផ្តល់ឲ្យនូវចំណុចសំខាន់តាមតំបន់ដែលជាគស្តុតាង ។ ដូចនេះយើងអាចធ្វើការប្រៀបធៀបរវាងកម្លាំងប្រជាសាស្ត្រនៃការផ្លាស់ប្តូរប្រជាសាស្ត្រជាតិមួយ ទៅនឹងដំណើរការចំណាកស្រុកពីជនបទទៅកាន់ទីក្រុង នៅតាមបណ្តាប្រទេសនីមួយៗ ។ យើងក៏អាចធ្វើការប្រៀបធៀបរវាងទំហំ និងសារៈសំខាន់របស់កត្តាទាំងពីរនេះក្នុងការកំណត់បមាណ-ភាគយុវជននិងអត្រាកំណើនយុវជនដែល ជាសូចនាករបឋមពីចំពោះការកើនឡើងនៃចំនួនយុវជន ។

ដោយបានពិនិត្យទៅលើប្រជាសាស្ត្រសំខាន់ដែលជាមូលដ្ឋាននៃការកើនឡើងនៃយុវជនទីក្រុងនេះរួចមក យើងនឹងធ្វើការពិនិត្យឡើងវិញទៅលើប្រជាសាស្ត្រសង្គមដែលមានការផ្លាស់ប្តូរចំពោះយុវជននៅអាស៊ី ។ ហើយយើងក៏ពិនិត្យយ៉ាងជាក់លាក់ទៅលើនិនាការចម្បងពីរ៖ ១) ការផ្លាស់ប្តូរពីការរៀបការ ពេលមានអាយុក្មេង ទៅការរៀបការពេលមានអាយុច្រើនវិញ និងចំនួន%របស់យុវជននៅលីវ ដែលកើនឡើងខ្ពស់ពេលដែលគ្នានេះដែរ ។ ២) ការផ្លាស់ប្តូរទៅរកការចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សា នៅក្នុងចំណោមយុវជន ។ និនាការទាំងពីរនេះក៏បានគេចងក្រងជាឯកសារសម្រាប់គ្រប់ប្រទេស នៅតំបន់អាស៊ីនេះ ហើយក៏ជាឯកសារសម្រាប់យុវជនទាំងពីរភេទនៅក្នុងប្រទេសនីមួយៗផងដែរ ។

**(យោងតាម តារាង ១: សូចនាករនៃបម្រែបម្រួលទីក្រុងនៅតាមប្រទេសអាស៊ីមួយចំនួន ពី គ.ស.១៩៥០-២០០០ (%)**

| ប្រទេស | ១៩៥៥ | ១៩៦០ | ១៩៧០ | ១៩៨០ | ១៩៩០ | ២០០០ |
|---|---|---|---|---|---|---|
| ថៃ | | | | | | |
| តំបន់ទីក្រុង | ១០,៥ | ១២,៥ | ១៣,៣ | ១៧,០ | ១៨,៧ | ២១,៦ |
| អត្រាកំណើនតាមតំបន់ | | | | | | |
| តំបន់ទីក្រុង | ៤,៤ | ៣,៥ | ៥,៥ | ២,៨ | ២,៣ | ២,៧ |
| តំបន់ជនបទ | ២,៤ | ២,៩ | ២,៥ | ១,៦ | ០,៨ | ០,៣ |
| សមាមាត្រនៃចំនួនប្រជាជនទីក្រុងថ្នាក់ជាតិនៃចំនួនសរុប ៧៥០.០០០ ឬក៏ច្រើនជាងនេះ | ៦៤,៩ | ៦៥,១ | ៦៥,៥ | ៥៩,៣ | ៥៦,៧ | ៥៤,៩ |

| ប្រទេស | ១៩៩៥ | ១៩៦០ | ១៩៧០ | ១៩៨០ | ១៩៩០ | ២០០០ |
|---|---|---|---|---|---|---|
| **ឥណ្ឌូនេស៊ី** | | | | | | |
| តំបន់ទីក្រុង | ១២,៤ | ១៤,៦ | ១៧,១ | ២២,២ | ៣០,៦ | ៤០,៩ |
| អត្រាកំណើនតាមតំបន់ | | | | | | |
| តំបន់ទីក្រុង | ៣,៣ | ៣,៧ | ៤,៩ | ៥,៣ | ៤,៦ | ៣,៦ |
| តំបន់ជនបទ | ១,៤ | ១,៨ | ១,៨ | ១,០ | ០,០៤ | -០,៦ |
| សមាមាត្រនៃចំនួនប្រជាជនទីក្រុងថ្នាក់ជាតិ នៃចំនួនសរុប ៧៥០.០០០ ឬក៏ច្រើនជាងនេះ | ១៤,៧ | ១៩,១ | ១៩,១ | ១៧,៩ | ១៣,៧ | ១២,៧ |
| **ប្រទេស** | **១៩៩៥** | **១៩៦០** | **១៩៧០** | **១៩៨០** | **១៩៩០** | **២០០០** |
| **ហ្វីលីពីន** | | | | | | |
| តំបន់ទីក្រុង | ២៧,១ | ៣០,៣ | ៣៣,០ | ៣៧,៥ | ៤៨,៨ | ៥៨,៦ |
| អត្រាកំណើនតាមតំបន់ | | | | | | |
| តំបន់ទីក្រុង | ៣,៧ | ៣,៨ | ៤,២ | ៥,២ | ៤,៤ | ៣,១ |
| តំបន់ជនបទ | ២,២ | ២,៦ | ១,៩ | ០,៦ | ០,២ | -០,០៦ |
| សមាមាត្រនៃចំនួនប្រជាជនទីក្រុងថ្នាក់ជាតិ នៃចំនួនសរុប ៧៥០.០០០ ឬក៏ច្រើនជាងនេះ | ២៧,១ | ២៧,២ | ២៨,៦ | ៣៣,០ | ២៦,៩ | ២៤,៤ |
| **ប្រទេស** | **១៩៩៥** | **១៩៦០** | **១៩៧០** | **១៩៨០** | **១៩៩០** | **២០០០** |
| **កូរ៉េខាងត្បូង** | | | | | | |
| តំបន់ទីក្រុង | ២១,៤ | ២៧,២ | ៤០,៧ | ៥៦,៩ | ៧៣,៨ | ៨១,៩ |
| អត្រាកំណើនតាមតំបន់ | | | | | | |
| តំបន់ទីក្រុង | ៣,៧ | ៥,៧ | ៥,៣ | ៤,០ | ២,១ | ១,៤ |
| តំបន់ជនបទ | ០,២ | ១,៣ | -០,៦ | -២,៨ | -២,៧ | -២,៦ |
| សមាមាត្រនៃចំនួនប្រជាជនទីក្រុងថ្នាក់ជាតិ នៃចំនួនសរុប ៧៥០.០០០ ឬក៏ច្រើនជាងនេះ | ២៣,៥ | ៣៤,១ | ៤០,៩ | ៣៨,២ | ៣៣,៣ | ២៥,៨ |

សម្គាល់: (b) និង (c) ជាអត្រាប្រចាំឆ្នាំក្នុងកំលុង ៥ ឆ្នាំដំបូងនៃកំលុងពេលដែលបានបង្ហាញ, (d) ការកំណត់ទំហំរបស់ទីកន្លែងគឺធ្វើឡើងនៅក្នុង គ.ស. ១៩៩៥ យោង:

(a) អង្គការសហប្រជាជាតិ (គ.ស. ២០០១) តារាង A.២,

(b) អង្គការសហប្រជាជាតិ (គ.ស. ២001) តារាង A.៦

(c) អង្គការសហប្រជាជាតិ (គ.ស. ២001) តារាង A.១៥,

(d) អង្គការសហប្រជាជាតិ (គ.ស. ២001) តារាង A.១៥

*ឯកសាររបស់ហ្សិណូស៍ និងកាបាម៉ាឡាន (Kabamalan គ.ស.១៩៩៨a និងគ.ស.១៩៩៨b) ។ កម្លាំងរួមរបស់និន្នាការទាំងពីរនេះ ដែលមានតួនាទីក្នុងការកំណត់ទ្រង់ទ្រាយសង្គមយុវជន ត្រូវបានលើកយក មកបង្ហាញនៅក្នុងជំពូកនេះសម្រាប់ប្រទេសសំខាន់ៗទាំងបួន ។ នៅពេលដែលកត្តាទាំងនេះកើតឡើងដំណាលគ្នា ការរួមបញ្ចូលគ្នារវាងកំណើនយុវជន និងការផ្លាស់ប្តូរសង្គមអាចមានលក្ខណៈយ៉ាងពិសេសដែល ថាចំនួនមានការកើនឡើងជាបន្តបន្ទាប់ ប្រៀបដូចជាពាក្យដែលថា រលកក្រោយច្រានរលកមុខ ។ ជាថ្មីម្តងទៀត យើងឃើញថានិន្នាការនីមួយៗមានភាពសម្បើមណាស់ ហើយអាចរួមបញ្ចូលគ្នាយ៉ាងខ្លាំងក្លាបំផុត នៅក្នុងតំបន់ទីក្រុង និងតំបន់ដែលមានប្រជាជនរស់នៅច្រើន ។ ប៉ុន្តែជាដំបូងនេះ យើងត្រូវតែធ្វើការរំលឹកឡើងវិញនូវវិស័យពីរនៃការផ្លាស់ប្តូរប្រជាសាស្ត្រនៅអាស៊ី ។ វិស័យទាំងពីរនេះរួមមាន៖ ១) នគរូបនីយកម្មយ៉ាងរហ័ស និង ២) ចំណាកស្រុករបស់យុវជនសំដៅទៅទីក្រុង ។*

# បម្រែបម្រួលតំបន់ទីក្រុង និងយុវជននៅអាស៊ី

*ស្ទើរតែនៅជុំវិញទ្វីបអាស៊ី ចំនួនប្រជាជននៅតាមបណ្តាទីក្រុងទូទៅ និងជាពិសេសនៅតាមទីក្រុងធំៗ មានការកើនឡើងយ៉ាងខ្លាំង (អង្គការសហប្រជាជាតិ គ.ស. ២00១ និងរបស់មជ្ឈមណ្ឌលដើម្បីការតាំងលំនៅរបស់មនុស្សជាតិរបស់អង្គការសហប្រជាជាតិ គ.ស.១៩៩៦) ។ បដិវត្តន៍នៃចំនួនប្រជាជននៅតាមតំបន់ទីក្រុងបានកើតឡើងនៅក្នុងរយៈពេលដ៏ខ្លីនៅក្នុងកំលុងវគ្គពាក់កណ្តាលទីពីរ នៃសតវត្សទី ២0 ដូចដែលបានបង្ហាញដោយសូចនាករនៅក្នុងតារាង ១ ចំពោះប្រទេសទាំងបួនដែលយើង កំពុងធ្វើការពិនិត្យមើលនៅទីនេះ[៥]។ នៅក្នុងប្រទេសថៃ និងប្រទេសហ្វីលីពីនកម្រិតនគរូបនីយកម្មបានឡើងទ្វេដងក្នុងកំលុងពេល ៥0 ឆ្នាំនេះ ដោយចាប់ផ្តើមពីកម្រិតទាបមួយនៅក្នុងប្រទេសថៃ និងកម្រិតខ្ពស់មួយនៅក្នុងប្រទេសហ្វីលីពីន ដូចដែលបានបង្ហាញរួចមកហើយនោះ ។ ហើយកម្រិតទាំងនោះបានកើនដល់ទៅ ២២% នៅតំបន់ទីក្រុងក្នុងប្រទេសថៃ និង ៥៩% នៅប្រទេសហ្វីលីពីន ។ កម្រិតនគរូប-នីយកម្មនៅប្រទេសឥណ្ឌូនេស៊ីក៏មានកម្រិតទាបដែរនៅគ.ស.១៩៥0 ប៉ុន្តែកម្រិតនេះបានកើនឡើងបីដងមុនគ.ស. ២000 ។ នគរូបនីយកម្មពិសេសនៅប្រទេសកូរ៉េខាងត្បូងបានចតុគុណដល់ទៅ ៨២% មុនគ.ស.២000 ។*

*ចំនួនជាភាគរយនៃនគរូបនីយកម្មដែលកើនឡើងជាក់ស្តែងណាស់ ឆ្លុះបញ្ចាំងអំពីអត្រាកំណើន ចំនួនប្រជាជននៅតាមតំបន់ទីក្រុងមានលក្ខណៈច្រើនជាងតំបន់ជនបទ ។ ជាការប្រសើរមួយដែលយើងគួតែកត់សម្គាល់អំពីទ្រង់ទ្រាយទំហំទាំងនេះ ព្រោះយើងអាចនឹងធ្វើការប្រៀបធៀបអត្រាកំណើនជាក្រុមរបស់យុវជនទីក្រុងនៅពេលក្រោយទៀត ។ នៅទីខ្នែង និងរយៈកាលដែលខ្ញុំកំពុងធ្វើការពិពណ៌នានេះអត្រានៅជនបទតែងតែទាបជាងអត្រានៅទីក្រុង ហើយអត្រាទាំងនោះឡើង ឬធ្លាក់ចុះទៅតាមការផ្លាស់ប្តូរប្រជាសាស្ត្រជាតិ ។ ជាតួយ៉ាង អត្រាកំណើនតាមជនបទនៅប្រទេសថៃ បានកើនឡើងដល់ចំណុចខ្ពស់បំផុតនៅ ទសវត្សទី ៦0 ក្នុងកម្រិត ២,៩% ក្នុងមួយឆ្នាំ ហើយមានការធ្លាក់ចុះមកវិញនៅពេលអត្រាកំណើតជាតិធ្លាក់ ចុះ(ណូដែល* (Knodel *ចាមរ៉ាត់រិទ្ធិរ៉ុង* (Chamrathrithi-rong) *និងដេបាវាលីយ៉ា* (Debavalya) *គ.ស. ១៩៨៧ និងឯកសាររបស់ ចូន និងអ្នកនិពន្ធឯទៃទៀត* (Jones et al)

គ.ស.១៩៩៧) ។ អ្វី ដែលគួឲ្យចាប់អារម្មណ៍នោះ គឺអត្រាកំណើនតាមជនបទ សុទ្ធតែបានកើនឡើងដល់កម្រិតខ្ពស់បំផុតនៅតាមបណ្តាប្រទេសទាំងមូលនេះនៅក្នុងសតវត្សតែមួយ ។ ប៉ុន្តែកម្រិតនេះមានលក្ខណៈទាបច្រើននៅប្រទេសឥណ្ឌូនេស៊ី និងកូរ៉េខាងត្បូង ជាងនៅប្រទេសថៃ និងហ្វីលីពីន ។

**តារាងទី ២: សូចនាករនៃកំណើនទីក្រុង និងតួនាទីចំណាកស្រុកនៅតាមបណ្តាទីក្រុងមួយចំនួននៅអាស៊ី គ.ស. ១៩៥០-២០០០**

| **ទីក្រុង និងសូចនាករ** | **១៩៥០** | **១៩៦០** | **១៩៧០** | **១៩៨០** | **១៩៩០** | **២០០០** |
|---|---|---|---|---|---|---|
| ទីក្រុងបាងកក | | | | | | |
| (តួលេខ) សរុបយុវជន | (a) ១.៣៦០<br>(b) | ២.១៥១ | ៣.១១០<br>៥១៦ | ៤.៧២៣<br>១.២៩៣ | ៥.៩០១<br>១.២៩៣ | ៧.២៨១ |
| **អត្រាកំណើន(ភាគរយប្រចាំឆ្នាំ)** | | | | | | |
| សរុបយុវជន | (c)<br>(d) | | | | | |
| ចំណាកស្រុកគិតជាភាគរយនៃកំណើន | | | | | | |
| ទីក្រុងទាំងអស់ | (e) | ៥០១ | ៥៩២ | | | |
| បាងកក | (f) | ៤២៩ | ៥០៨ | | | |
| ទីក្រុងដទៃទៀត | (g) | ៥០១ | ៤៥៨ | | | |
| ភាគរយនៃចំនួនប្រជាជនដែលធ្វើចំណាកស្រុក | (h) | ២០៣ | ២០៧ | | | |
| **ទីក្រុងយ៉ាកាតា** | | | | | | |
| (តួលេខ) សរុបយុវជន | (a)១.៤៥២<br>(b) | ២.៦៧៩ | ៣.៩១៦<br>៩៤៦ | ៥.៩៨៥<br>១.៥៦០ | ៧.៦៥០<br>២.០៣៥ | ១១.០១៨ |
| **អត្រាកំណើន(ភាគរយប្រចាំឆ្នាំ)** | | | | | | |
| សរុបយុវជន | (c)<br>(d) | | | | | |
| ចំណាកស្រុកគិតជាភាគរយនៃកំណើន | (e) | | | | | |
| ទីក្រុងទាំងអស់ | (f) | ៣៥.៤ | | | | |
| បាងកក | (g) | ៣១.២ | | | | |
| ទីក្រុងដទៃទៀត | (h) | | | | | |

យោង : (a) ១៩៥០-១៩៨០ ឯកសារពីអង្គការសហប្រជាជាតិ(១៩៨៥) តារាងទី១ ឬបានពីរបាយការណ៍ជំរឿន, (b) យកពីរបាយការណ៍ជំរឿន, (c).និង (d) បានមកពីការធ្វើតួលេខពី (a) និង (b), (e) ១៩៦០-១៩៧០ និង ១៩៧០-១៩៨០ បានពីESCAP (១៩៨៨), (f) និង (g) ១៩៦០-១៩៧០ បានពី ESCAP (១៩៨៨) តារាង១៧, (h) បានពី ESCAP (១៩៨៨) តារាង ២

សម្គាល់: (e), (f) និង (g) មានការប្រែប្រួលតាមការកំណត់សាជាថ្មី

*គោលបំណងរបស់យើងគឺយើងចាប់អារម្មណ៍ថាអត្រាកំណើននៅតំបន់ទីក្រុងបានឡើងដល់ចំនុចខ្ពស់បំផុតនៅក្នុងទសវត្សទី ៦០ (នៅប្រទេសកូរ៉េខាងត្បូង) នៅក្នុងទសវត្សទី ៧០ (នៅប្រទេសថៃ) និងនៅក្នុងទសវត្សទី ៨០ (នៅប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន) ។ អត្រាកំណើននេះអាចឆ្លុះបញ្ចាំងអំពីការធ្លាក់ចុះនៃអត្រាផ្លាស់លំនៅនៅទីក្រុងសរុប ដូចដែលនឹងលើកយកមកបង្ហាញនៅផ្នែកខាងក្រោយទៀតក្នុងជំពូកនេះ ។ ប៉ុន្តែអត្រាកំណើននេះពិតជាឆ្លុះបញ្ចាំងជាចម្បងអំពីការអន់ថយនៃអត្រាកំណើតជាតិទាំងមូល ។ យោងតាមការពណ៌នា អត្រាកំណើននៅក្នុងទសវត្សទី ៧០ និងនៅកំលុងពេលមុននោះ ព្រេស្តុន (Preston គ.ស. ១៩៧៩) បានកត់សម្គាល់ថាកំណើនចំនួនប្រជាជនទូទៅ គឺជាកត្តាចម្បងទាក់ទងទៅនឹងកំណើនទីក្រុង ហើយនិនាការដែលត្រូវបានបង្ហាញជាបន្តបន្ទាប់ពិតជាគាំទ្រការកំណត់ដោយព្រេស្តុន នេះមែន ។ ជាចុងបញ្ចប់ យើងកត់សម្គាល់ថាអត្រាកំណើននៅទីក្រុងប្រចាំឆ្នាំខ្ពស់បំផុតកើនឡើងច្រើនជាង ៥% ហើយនៅប្រទេសថៃ និងប្រទេសកូរ៉េខាងត្បូង អត្រាកំណើននេះកើនដល់ ឬលើស ៥,៥% ។ លក្ខណៈរបស់តំបន់ទីក្រុងទាំងនេះមានភាពខុសប្លែកពីគ្នាយ៉ាងគួរឲ្យកត់សម្គាល់ ។ ប្រមាណជា ពី ១ ភាគ ៨ ដល់ ១ ភាគ ៣ នៃអ្នករស់នៅទីក្រុង គឺរស់នៅក្នុងទីក្រុងធំៗដែលមានចំនួនប្រជាជន៧៥០.០០០ ឬច្រើនជាងនេះ សូមមើលតារាង ១ ជួរ(d) ។ ករណីលើកលែងគឺចំពោះតំបន់ទីក្រុងធំៗនៃប្រទេសថៃ ដែលឆ្លុះបញ្ចាំងពីឥទ្ធិពលដ៏ខ្លាំងក្លារបស់ក្រុងបាងកក តាំងពីបុរាណ និងនាពេលបច្ចុប្បន្ន (យោងតាមឯកសាររបស់ស្ទើន-ស្តាញ (Sternstein) គ.ស. ១៩៨២ និងរបស់អាស្គ៍គូ (Askew) គ.ស. ២០០២) ហើយនិងឆ្លុះបញ្ចាំងអំពីចំនួនប្រមាណ ៤០% នៃការរៀបចំទីក្រុងធំៗរបស់នគរូបនីយកម្មកូរ៉េខាងត្បូង ដែលអត្រានេះកើនឡើងនៅក្នុងគ.ស. ១៩៧០ ។ សម្រាប់ប្រទេសទាំងនេះ ហើយក៏សម្រាប់ប្រទេសភាគច្រើននៅអាស៊ីដែរ កំណត់សម្គាល់ដ៏សំខាន់មួយ គឺការកើនឡើងខ្លាំងរួចហើយធ្លាក់ចុះមកវិញនៃបមាណភាគនគរូបនីយកម្មនៅទីក្រុងធំៗ ដោយសារការឈានទៅមុខនៃសតវត្សទី២០*[៦] ។

***តារាង ៣ : ផលធៀបរវាងអត្រាចំណាកស្រុកពីជនបទទៅទីក្រុងជាមួយ និងក្រុមអាយុជាក់លាក់ នៅតាមបណ្តាអាស៊ីមួយចំនួន និងនៅតាមរយៈកាល និងភេទ***

| ប្រទេស, រយៈកាល និងភេទ | ៥-៩ | ១០-១៤ | ១៥-១៩ | ២០-២៤ | ២៥-២៩ | ៣០-៣៤ | ៣៥-៣៩ | ៤០-៤៤ |
|---|---|---|---|---|---|---|---|---|
| ឥណ្ឌូនេស៊ី | | | | | | | | |
| ១៩៦១-១៩៧០ | | | | | | | | |
| ប្រុស | ២.៩ | ៩.៥ | ៧.៥ | ០.៥ | -២.៣ | | ១.១ | ០.៥ |
| ស្រី | ៤.២ | ១០.៨ | ៣.៤ | -១.៣ | | ១.៤ | | |
| ១៩៧០-១៩៨០ | | | | | | | | |
| ប្រុស | | ១៣.៦ | ១៥.២ | ៧.៣ | | | | |
| ស្រី | ៧.០ | ១៦.២ | ១០.៨ | ៤.១ | | ៦.១ | ៥.០ | ៤.៧ |
| **កូរ៉េខាងត្បូង** | | | | | | | | |
| ១៩៦០-១៩៧០ | ៣០.៣ | ៣៣.១ | ២៩.៩ | ៣៩.៩ | | | | |
| ១៩៧០-១៩៨០ | ៣៤.៣ | ៤៣.៥ | ៣១.៨ | ៣១.៨ | | | | |
| **ហ្វីលីពីន** | | | | | | | | |
| ១៩៧០-១៩៨០ | | ១៦.៤ | ១៣.៥ | | | | | |
| ប្រុស | | | | | | | | |
| ស្រី | ២០.៤ | ២៣.១ | ៩.៤ | | | | | |
| **ថៃ** | | | | | | | | |
| ១៩៧០-១៩៨០ | | | | | | | | |
| ប្រុស | | ៧.៨ | ១០.៦ | ៧.៤ | | | | |
| ស្រី | | ៩.៩ | ១១ | ៨.២ | | | | |

យោង : តាមឯកសាររបស់ សិងហ្គែលមែន (Singelman គ.ស. ១៩៩៣) តារាង ១០

សម្គាល់ : តារាងនេះបង្ហាញតែអត្រាសម្រាប់ក្រុមអាយុ ១៥-១៩ និង ២០-២៤ ប៉ុណ្ណោះ ហើយនិងសម្រាប់ក្រុមផ្សេងទៀតដែលអត្រាស្មើ ឬច្រើនជាងក្រុមទាំងពីរនេះ ។ ទាំងនេះ គឺជាការប៉ាន់ស្មានដោយប្រើវិធីសាស្ត្រជំរឿនធៀបអ្នកនៅរស់មានជីវិត ។

*អត្រាជាក់ស្តែងនៃការប្រែប្រួលចំនួនប្រជាជននៅតំបន់ទីក្រុងក្នុងកំលុងពេលដែលបានបង្ហាញមកនេះមិនកម្រិតស្មើនឹងកំណើនចំនួនប្រជាជននៅទីក្រុងដែលបានបង្ហាញមកនោះ (យោងតាមឯកសាររបស់អង្គការសហប្រជាជាតិ គ.ស.១៩៨០ និងយោងតាមការពិភាក្សានៅក្នុងឯកសាររបស់ ប្រូកឃើហូវ* (Brockerhoff) *គ.ស.២០០០ តារាង១)*[៧] *។ មូលហេតុសម្រាប់ភាពមិនស្មើគ្នានេះរួមមាន÷ ១) ដំណើរដើរថយក្រោយនៃម៉ាក្រូសេដ្ឋកិច្ច ទៅកាន់កំណើនឧស្សាហកម្មតាមតំបម់ទីក្រុង ២)ការផ្លាស់ប្តូរលក្ខន្តិកៈដែលមានភាពប្រសើរសម្រាប់វិស័យកសិកម្ម និង ៣) ការថយចុះនៃអត្រាកំណើនចំនួនប្រជាជនថ្នាក់ជាតិ ដែលជាកត្តាមួយដ៏សំខាន់ក្នុងកំណើនតំបន់ទីក្រុងមុនគ.ស. ១៩៨០ ។ ប៉ុន្តែការពន្យល់ខាងប្រជាសាស្ត្រដ៏សាមញ្ញមួយផ្សេងទៀតអាចមានលក្ខណៈគ្រប់គ្រាន់ ។ នៅពេលដែលចំនួនប្រជាជននៅតាមជនបទមានច្រើនប្រហាក់ប្រហែលទៅនឹងទីក្រុងដែរនោះ សូម្បីតែអត្រាចំណាកស្រុកពីជនបទទៅទីក្រុងដ៏តូចមួយ ក៏អាចធ្វើឲ្យមានសមាមាត្រធំទៅលើចំនួនប្រជាជននៅតាមទីក្រុងដែរ ។ ប៉ុន្តែនៅពេលដែរបមាណភាគ ទីក្រុងកើនឡើង អត្រាចំណាកស្រុកទៅកាន់ទីក្រុងដដែលនេះ បង្កើតឲ្យមានឥទ្ធិពលស្ទួចស្តើងទៅលើចំនួនតំបន់ទីក្រុង ។*

*ដំណាក់កាលចុងក្រោយនៃដំណើរការនេះគឺកម្រិតថេរនៃចំនួនប្រជាជននៅតាមជនបទ សូម្បីតែការចាប់ផ្តើមនៃការធ្លាក់ចុះនៅតាមតំបន់ជនបទក្តី ។ ក្នុងចំណោមប្រទេសដែលយើងធ្វើការផ្តោតសំខាន់នោះមានចំណុចរបត់ជាប្រវត្តិសាស្ត្រមួយដែលជាការធ្លាក់ចុះយ៉ាងខ្លាំងនៃចំនួនប្រជាជននៅតាមតំបន់ជនបទ ចាប់ផ្តើមនៅក្នុងកំលុង គ.ស.១៩៦៥-១៩៧០ នៅកូរ៉េខាងត្បូង និងគ.ស.១៩៩៥-២០០០នៅឥណ្ឌូនេស៊ី ហើយចំណុចរបត់នេះត្រូវបានបង្ហាញថានឹងកើតឡើងនៅ គ.ស. ២០០០-២០០៥ នៅប្រទេសហ្វីលីពីន និងគ.ស.២០១០-២០១៥ នៅប្រទេសថៃ*[៨]*។*

## យុវជននៅក្នុងប្រព័ន្ធអន្តោប្រវេសន៍ជាតិ

*ឥឡូវនេះយើងសូវបង្វែរមកចំណុចដែលមានការចាប់អារម្មណ៍គឺលើតំបន់ចំនួនបួនដែលមានប្រជាជនច្រើនវិញ ។ តំបន់បួនធំៗនោះ÷ ១)ក្រុងបាងកក ២)ក្រុងយ៉ាកាតា ៣)ក្រុងម៉ានីល និង៤)ក្រុងសេអ៊ូល ។ តំបន់នីមួយៗសុទ្ធតែជាកន្លែងសំខាន់ជាតិនៅក្នុងបណ្តាទីក្រុងទាំងនេះ ហើយរហូតដល់ពេលថ្មីៗនេះតំបន់នីមួយៗបានរួមចំនែកដោយមានលក្ខណៈមិនស្មើ នៅក្នុងការរីកលូតលាស់តំបន់ទីក្រុង ដូចដែលទើបបានរៀបរាប់មកនេះ ។ ជាការសំខាន់ណាស់ដែលត្រូវសម្គាល់កត្តាពីររបស់ប្រវត្តិសាស្ត្រទីក្រុង ទាំងនេះរួមមាន÷ ១)កត្តាអន្តោប្រវេសន៍ដ៏សំខាន់ដែលនាំឲ្យមានកំណើននៅទីក្រុងទាំងនោះ និង ២) ការផ្តល់ឲ្យនូវក្រុមអាយុយុវជនដ៏សំខាន់ដល់ទៅកត្តាអន្តោប្រវេសន៍នេះ ។ ទិន្នន័យពាក់ព័ន្ធត្រូវបានគេបញ្ចូលរួមគ្នានៅក្នុងតារាង ២ និង ៣។*

*ចំនួនប្រជាជននៅទីក្រុងត្រូវបានបង្ហាញនៅក្នុងតារាង ២ ជួរ*(a) *ហើយអត្រាកំណើនសរុបដែលពាក់ព័ន្ធត្រូវគេបង្ហាញនៅក្នុងជួរ*(c) *។ ទាំងនេះគឺជាអត្រាកំណើននៅទីក្រុងយ៉ាងរហ័សដែលជាទូទៅ (ទោះមិនមែនជានិច្ចកាលក៏ដោយ) ខ្ពស់ជាងកម្រិតនៅតំបន់ទីក្រុងក្នុងប្រទេសទាំងនោះ ។ ជួរ*(b) *និង*(d) *បង្ហាញពី និន្នាការនៃចំនួនយុវជននៅក្នុងទីក្រុងទាំងនេះ ហើយនិងអត្រាកំណើននៃចំនួនយុវជនដែលពាក់ព័ន្ធ ។ ទិន្នន័យទាំងនោះទទួលបានពីរបាយការណ៍ជំរឿនសម្រាប់កាលបរិច្ឆេទមួយចំនួន ។ នៅក្នុងកាលនីមួយៗ ចំនួនប្រជាជនជាយុវជននៅទីក្រុងធំៗមានកំណើនយ៉ាងឆាប់រហ័ស ប្រៀបទៅនឹងចំនួនប្រជាជនសរុបនៅក្នុងទីក្រុងធំៗទាំងនោះ ដែលចាប់តាំងពីពេលនោះមកបានចុះទាបទៅហើយ ។ នៅក្រុងបាងកក និងយ៉ាកាតា ហេតុការណ៍នេះកើតឡើងនៅក្នុងកំលុង*

ទសវត្សទី ៧០ នៅពេលដែលកំណើនចំនួនប្រជាជនសរុបនៅទីក្រុង ស្ថិតនៅចំណុចខ្ពស់បំផុតដែរនោះ ។ នៅក្រុងម៉ានីល ហេតុការណ៍នេះកើតឡើងនៅក្នុងកំលុងទសវត្សទី ៦០ មុនពេលដែលកំនើនប្រជាជនសរុបនៅក្រុងបានកើនឡើងដល់កម្រិតខ្ពស់បំផុត ។ នៅក្រុងសេអ៊ូល ហេតុការណ៍បែបនេះមិនអាចឲ្យគេមើលយល់យ៉ាងច្បាស់នោះទេ បើយោងតាមទិន្នន័យ ដែលមាននោះ ពីព្រោះថាភាគច្រើននៃហេតុការណ៍នេះអាចកើតឡើង (រួចមកហើយ) មុនពេលដែលកំរងទិន្នន័យត្រូវបានគេប្រមូលយកមក ។

ការចូលរួមរបស់ចំណាកស្រុកទៅលើការប្រែប្រួលចំនួនប្រជាជនបែបនេះអាចឲ្យគេធ្វើការពណ៌នាបានតែនៅក្នុងន័យទូលំទូលាយតែប៉ុណ្ណោះ ដូច្នេះបានដោយសារតែការប៉ាន់ស្មានតែប៉ុណ្ណោះ ។ ការវាស់ស្ទង់សំណាកស្រុក និងការបង្ហាញពីចំណាកស្រុកជាលក្ខណៈជាប្រព័ន្ធរបស់ប្រជាសាស្ត្រជាតិ គឺមិន មានខ្នាត (ស្តង់ដារ) ដូចការវាស់ស្ទង់អត្រាកើត និងអត្រាស្លាប់នៃការផ្លាស់ប្តូរប្រជាសាស្ត្រនោះឡើយ ពីព្រោះថាភាគច្រើនចំណាកស្រុកគឺជាបាតុភូតដែលមានភាពស្មុគស្មាញច្រើនជាងដែលអាចឲ្យគេបកស្រាយបានដោយផ្អែកតែលើការយល់ឃើញចាំបាច់មានកម្រិតតែប៉ុណ្ណោះ[៥] ។ លទ្ធផលមួយនៃភាពស្មុគស្មាញទាំងនេះ គឺជាចំណាកស្រុកដែលត្រូវបានគេវាស់ស្ទង់ដោយវិធីសាស្ត្រផ្ទាល់ និងប្រយោលជាច្រើន ។ យើងមានការខ្វះខាតនូវវិធីវាស់ស្ទង់ដែលមានលក្ខណៈស្របគ្នាសម្រាប់បណ្តាប្រទេសទាំងឡាយ ។ តារាង ២ បង្ហាញពីកស្តុតាងដែលភាគច្រើនសម្រាប់ទីក្រុងទាំងបួនដែលយើងធ្វើការសិក្សា ។

បំណកស្រាយលម្អិតជាងនេះអាចរកបានតែចំពោះផ្នែកតំបន់ទីក្រុងជាជាងទីក្រុងជាក់លាក់ ដោយការបកស្រាយនេះប្រើតាមវិធីសាស្ត្រប្រយោល ដូចជាវិធីសាស្ត្រសមាមាត្រអ្នកនៅរស់ដែលបានពីការធ្វើជំរឿន ។ វិធីសាស្ត្រនេះទាមទារឲ្យមានទិន្នន័យល្អអំពីចំនួនប្រជាជន និងប្រព័ន្ធដ៏ត្រឹមត្រូវសម្រាប់វាស់ស្ទង់សមាមាត្រអត្រាអ្នកស្លាប់ប៉ុន្តែមិនមានព័ត៌មានផ្ទាល់អ្វីទេស្តីអំពីចំណាកស្រុក ។ ការប៉ាន់ស្មានមួយក្នុងចំណោមភាពស្មុគស្មាញនៃការប៉ាន់ស្មានទាំងនេះ ត្រូវបានផ្តល់ឲ្យដោយ សិងហ្គែលមែន (Singel-man គ.ស. ១៩៩៣) ។ ការប៉ាន់ស្មានរបស់គាត់សម្រាប់តំបន់ទីក្រុងនៃប្រទេសទាំងបួនរបស់យើងត្រូវបានបង្ហាញនៅក្នុងតារាង ៣ ។ ទោះបីជាទិន្នន័យប៉ាន់ស្មានទាំងនេះសម្រាប់តំបន់ទីក្រុងទាំងមូលជាជាងទីក្រុងជាក់លាក់ដែលយើងធ្វើការសិក្សានោះក៏ដោយ ក៏ខ្ញុំយកទិន្នន័យទាំងនេះមកបង្ហាញដែរ ព្រោះថាទិន្នន័យទាំងនេះបង្ហាញយ៉ាងច្បាស់នូវការសំរាំងកត្តាអាយុ និងភេទ ដែលជាកត្តាគ្រឹះនៃចំណាកស្រុកឆ្ពោះទៅកាន់ទីក្រុង ។ ទិន្នន័យប៉ាន់ស្មានពីកត្តាក្រុមអាយុ និងភេទនេះអាចរកបាន ប៉ុន្តែសម្រាប់គោលបំណងនៅពេលនេះ ខ្ញុំ សូមបង្ហាញតែពីអត្រាក្រុមអាយុពី១៥-១៩ និង ២០-២៤ សម្រាប់ភេទនីមួយៗតែប៉ុណ្ណោះ ។ ខ្ញុំក៏បង្ហាញផងដែរនូវអត្រាអាយុ និងភេទឯទៃទៀតដែលក្រៅពីក្រុម១៥-១៩ ឬ ២០-២៤ ។

តារាង ៣ បង្ហាញយ៉ាងច្បាស់ថាប្រទេសកូរ៉េខាងត្បូង ហ្វីលីពីន និងប្រទេសឥណ្ឌូនេស៊ី មានការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះអ្នកផ្លាស់លំនៅមកកាន់ទីក្រុង ឬក៏យ៉ាងហោចណាស់ក៏ចំពោះផលប៉ះពាល់រួមដែលបានពីចំណាកស្រុកមកកាន់តំបន់ទីក្រុងរបស់ក្រុមអាយុ ១៥-១៩ និង ២០-២៤ ដែរ ។ អត្រាចំណាកស្រុកដទៃផ្សេងៗជាច្រើនទៀតមានលក្ខណៈល្អ ប៉ុន្តែមិនមានអត្រាមួយណាទៅដល់កម្រិតសម្រាប់ក្រុមអាយុទាំងនេះទេ លើកលែងតែអត្រាក្រុម ១០-១៤ នៅប្រទេសថៃ និងកូរ៉េខាងត្បូង ហើយនិងអត្រាក្រុម ២០-២៤ នៅប្រទេសកូរ៉េខាងត្បូង ។ នៅឥណ្ឌូនេស៊ី ក៏មានការយកចិត្តទុកដាក់ខ្ពស់ ទៅលើបញ្ហាចំណាកស្រុកមកកាន់ទីក្រុងក្នុងចំណោមយុវជនដែរ ប៉ុន្តែដោយមានការចូលរួមយ៉ាងសកម្មពីបណ្តាក្រុមអាយុផ្សេងទៀត ។ ក្រុមចំណាកស្រុកមកកាន់ទីក្រុងនៅ

ប្រទេសឥណ្ឌូនេស៊ីមានអាយុក្មេងជាងក្រុមចំណាកស្រុកនៅប្រទេសឯទៃទៀត ។ យើងក៏សូមធ្វើការកត់សម្គាល់ផងដែរថា អត្រានៅប្រទេសកូរ៉េខាងត្បូងមានកម្រិតខ្ពស់ខ្លាំងនៅក្នុងគម្លាតអាយុពី ១០ ទៅ ២៩ ។ គួរកត់សំគាល់ផងដែរថា ទិន្នន័យប៉ាន់ស្មានទាំងនេះមានភាពមិនគ្រប់គ្រាន់សម្រាប់កំលុងពេលពីជំរឿនមួយជំរឿនមួយបន្ទាប់ពី គ.ស.១៩៨០[១០]។ យើងនឹងត្រឡប់មកបកស្រាយពីទីក្រុងទាំងបួនរបស់យើងវិញ ហើយនិងរៀបរាប់អំពីកស្តុតាងបន្ថែមខ្លះៗ នៃចំណាកស្រុករបស់យុវជន ប៉ុន្តែជាបឋមយើងសូមធ្វើការបរិយាយលម្អិតជាងនេះអំពីបរិបទប្រជាសាស្ត្រ នៃកំណើនយ៉ាងឆាប់រហ័យនៃចំនួនយុវជនអាស៊ី ។

## ដំណើរប្រែប្រួលប្រជាសាស្ត្រ និងការផ្ទុះឡើងនៃចំនួនយុវជន

នៅតាមបណ្តាប្រទេសជាច្រើន ការផ្លាស់ប្តូរប្រជាសាស្ត្រមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងនៅក្នុងដំណើរបម្រែបម្រួលប្រជាសាស្ត្រ ប៉ុន្តែនៅពេលដែលប្រទេសនៅអាស៊ីបានជួបប្រទះនឹងដំណើរប្រែប្រួលប្រជាសាស្ត្រមានលក្ខណៈស្រដៀងគ្នា ប្រទេសទាំងនោះមានព្រឹត្តិការណ៍ទាំងនោះនៅពេលខុសៗគ្នា ។ ដូច្នេះ ហើយបទពិសោធនៃដំណើរការប្រែប្រួលប្រជាសាស្ត្ររបស់បណ្តាប្រទេសនានាបង្ហាញអំពីទំហំនៃភាព ខុសគ្នាដ៏ធំមួយនៅក្នុងប្រជាសាស្ត្រយុវជន ។ ដំណើរប្រែប្រួលប្រជាសាស្ត្រកើតឡើងនៅពេលអត្រាកើត និងអត្រាស្លាប់ទាំងពីរនេះធ្លាក់ចុះពីកម្រិតខ្ពស់តាមល្បឿនខុសៗគ្នា ហើយនិងនៅពេលដែលការធ្លាក់ចុះនេះសំដៅទៅរកកម្រិតទាបយ៉ាងលឿន ។ ផលប៉ះពាល់នៃដំណើរប្រែប្រួលប្រជាសាស្ត្រមានច្រើន ហើយផលប៉ះ ពាល់ខ្លាំងជាងគេនោះ÷ ១)លំដាប់នៃការផ្លាស់ប្តូរក្រុមអាយុបណ្តោះអាសន្នដែលមានលក្ខណៈដូចជារទេះភ្លើង និងការប្រែប្រួលក្រុមអាយុទៅជារចនាសម្ព័ន្ធក្រុមអាយុអចិន្ត្រៃយ៍ច្រើន ។ ២)ផលប៉ះពាល់ទី ២ នេះត្រូវបានគេទទួលស្គាល់ថាជាក្រុមប្រជាជនសក់ស្កូវ ឬក្រុមប្រជាជនវ័យចំណាស់ ។ រីឯផលប៉ះពាល់ទី ១ វិញ លេក ក្រុមអាយុប្រែប្រួលអាចឲ្យគេធ្វើការប៉ាន់ស្មានយ៉ាងជាក់លាក់ដោយប្រើវិធីសាស្ត្រប្រជាសាស្ត្រ ប៉ុន្តែបានទទួលការចាប់អារម្មណ៍តិចតួចណាស់ (ប៉ុន្តែសូមមើលសឯកសាររបស់ ទិលច្យាពុលការ (Tuljapulkar) ដែលកំពុងបោះពុម្ពផ្សាយ) ។

រលកយុវជនអាស៊ីឬកំណើនចំនួនយុវជនអាស៊ី គឺជាបាតុភូតមួយនៅក្នុងរយៈពេលបីទសវត្សកន្លង ទៅនេះ នៅក្នុងសតវត្សទី ២០ និងនៅក្នុងត្រីមាសដំបូងនៃសតវត្សទី ២១។ យុវជនអាស៊ីមានចំនួន ២៣៩ លាននាក់នៅ គ.ស.១៩៥០ ប៉ុន្តែបានកើនឡើង ២,៤ដង ស្មើនឹង ៥៧២ លាននាក់ នៅគ.ស.១៩៩០ ។ អត្រាកំណើនប្រចាំឆ្នាំជាមូលដ្ឋាននេះ (២,១៨%) ស្របទៅនឹងកំណើនប្រចាំឆ្នាំនៃកំណើនប្រជាជនសរុប (២,០៣%) នៅក្នុងកំលុងពេលដូចគ្នា ។ ប៉ុន្តែរវាងគ.ស. ១៩៩០ និងគ.ស. ២០២៥ ចំនួនប្រជាជនអាស៊ីសរុបនឹងកើន ។

### តារាង ៤: សូចនាករនៃប្រជាសាស្ត្រយុវជនក្នុងកំលុងពេលដំណើរការផ្លាស់ប្តូរប្រជាសាស្ត្រនៅតាមបណ្តាសង្គម

| តំបន់សង្គម | ឆ្នាំនៃការធ្លាក់ចុះអត្រាកំណើត (កាលបរិច្ឆេទ) | រយៈពេលនៃបម្រែបម្រួលប្រជាសាស្ត្រ (ចំនួនឆ្នាំ) | អត្រាកំណើនយុវជនដល់ចំណុចខ្ពស់បំផុត (គ.ស.) | បមាណភាគនៃយុវជនដល់ចំណុចខ្ពស់បំផុតនៃចំនួនប្រជាជនសរុប (គ.ស.) | ចំនួនប្រជាជនជាយុវជនដល់ចំណុចខ្ពស់បំផុត (គ.ស.) | ភាគរយនៃកំណើនប្រជាជនជាយុវនក្នុងកំលុងពេលបម្រែបម្រួលប្រជាសាស្ត្រ |
|---|---|---|---|---|---|---|
| សាំងហ្គាពួរ | ១៩៥៩ | ១៦ | ១៩៦៩ | ១៩៧៨ | ១៩៨០ | ១១២ |
| ហុងកុង | ១៩៦០ | ២០ | ១៩៧០ | ១៩៥០ | ១៩៨០ | ២២០ |
| កូរ៉េខាងត្បូង | ១៩៦២ | ២៣ | ១៩៧៤ | ១៩៨០ | ១៩៨១ | ៨៣ |
| ស្រីលង្កា | ១៩៦២ | ៤៣ | ១៩៧៥ | ១៩៨០ | ២០០២ | ៩០ |
| ភីលីពីន | ១៩៦៣ | ៦៦ | ១៩៧៤ | ១៩៧៧ | ២០២១ | ២៥៩ |
| ព្រុយណេ | ១៩៦៥ | ៥៥ | ១៩៧០ | ១៩៨០ | ២០១២ | ៤៤៣ |
| តៃវ៉ាន់ | ១៩៦៥ | ១៨ | ១៩៦០ | ១៩៨០ | ១៩៨០ | ៥៤ |
| ម៉ាឡេស៊ី | ១៩៦៦ | ៤៩ | ១៩៧០ | ១៩៨០ | ២០១៥ | ១៩៤ |
| ថៃឡង់ | ១៩៦៨ | ៣២ | ១៩៧៣ | ១៩៨៦ | ១៩៩២ | ១០៩ |
| ចិន | ១៩៦៩ | ២១ | ១៩៨៤ | ១៩៨៧ | ១៩៨៩ | ៩៧ |
| ឥណ្ឌា | ១៩៧៣ | ៤៧ | ១៩៧៧ | ១៩៨៤ | ២០១៤ | ១០៦ |
| ភូមា | ១៩៧៦ | ៤៩ | ១៩៨៥ | ១៩៩៤ | ២០០១ | ១១៧ |
| បង់ក្លាដេស | ១៩៨១ | ៣៤ | ១៩៩៥ | ២០០២ | ២០០៤ | ៧៨ |
| ណេប៉ាល់ | ១៩៨៨ | ៤២ | ២០០១ | ២០០៧ | ២០៣២ | ១២៧ |
| ប៉ាគីស្ថាន | ១៩៩០ | ៤០ | ២០០៥ | ២០១០ | ២០៣៣ | ១០០ |

យោង : តាមឯកសាររបស់ សិងហ្គែលមែន (Singelman គ.ស. ១៩៩៣) តារាង ១០

សម្គាល់ : តារាងនេះបង្ហាញតែអត្រាសម្រាប់ក្រុមអាយុ ១៥-១៩ និង ២០-២៤ ប៉ុណ្ណោះ ហើយនិងសម្រាប់ក្រុមផ្សេងទៀតដែលអត្រាស្មើ ឬច្រើនជាងក្រុមទាំងពីរនេះ ។ ទាំងនេះគឺជាការប៉ាន់ស្មានដោយប្រើវិធីសាស្ត្រជំរឿនធៀបអ្នកនៅរស់មានជីវិត ។

ឡើងដល់ ៣៨៩៧ លាននាក់ ស្មើនឹង ៣៩% នេះបើយោងតាមការសិក្សារបស់អង្គការសហប្រជាជាតិ ។ ទន្ទឹម ពេលនេះដែរ ចំនួនយុវជនអាស៊ីនឹងកើនត្រឹមតែ ២៥% ប៉ុណ្ណោះ ។ បមាណភាគយុវជននៃចំនួនប្រជាជន សរុបគឺ ១៨,៩% នៅគ.ស. ១៩៥០ និង ២០,៥% នៅគ.ស. ១៩៩០ ប៉ុន្តែនឹងថយចុះដល់ ១៤,៩% នៅមុនគ.ស. ២០២៥ ។ នៅក្នុងន័យដាក់លាក់បំផុតចំនួនប្រជាជនជាយុវជននៅអាស៊ីនឹងកើនឡើងដល់ចំណុចខ្ពស់បំផុតរវាង គ.ស. ២០១០ និងគ.ស. ២០២០ ហើយនឹងធ្លាក់ចុះវិញបន្ទាប់ពីនោះមក ។

លំដាប់នៃបទពិសោធសម្រាប់ក្រុមសង្គមដាក់លាក់ទាំងឡាយមិនមានភាពច្បាស់លាស់ទេនៅក្នុងអត្ថបទ សង្ខេបតាមតំបន់នេះ ។ ក្រុមវ័យអាយុត្រូវបានកំណត់ដោយការប្រែប្រួលនៃអត្រាកើត និងអត្រាស្លាប់ភ្លាមៗ ហើយបទពិសោធនៃការប្រែប្រួលទាំងនេះមានភាពខុសគ្នានៅបណ្ដាប្រទេសនៅអាស៊ី ។ នៅក្នុងចំណោមសង្គម ទាំង ១៦ ដែលការធ្លាក់ចុះដំបូងនៃអត្រាកើតត្រូវបានកំណត់ដោយមានកាលបរិច្ឆេទ ច្បាស់លាស់នោះ(១១) មាន ចំនួន ១១ ដែលមានលក្ខណៈស្មើគ្នាក្នុងកំលុងពេលពីគ.ស. ១៩៥៩ (នៅប្រទេសសិង្ហបុរី) រហូតដល់គ.ស. ១៩៧០ (នៅប្រទេសឥណ្ឌូនេស៊ី) ។ ហើយយើងមានកាលបរិច្ឆេទដំបូងពីរនៅក្នុងទសវត្សឆ្នាំ ៧០ (នៅប្រទេសឥណ្ឌា និង មីយ៉ាន់ម៉ា ឬភូមា) ពីរនៅក្នុងទសវត្សឆ្នាំ ៨០ (នៅប្រទេសបង់ក្លាដេស និងនេប៉ាល់) និងមួយនៅក្នុងទសវត្សឆ្នាំ ៩០ (នៅប្រទេសបង់ក្លាដេស) ។ ការជះឥទ្ធិពលរបស់បម្រែបម្រួលប្រជាសាស្ត្រមកលើការបង្កើតក្រុមវ័យអាយុ ផ្អែកទៅលើថាតើអត្រាកើតធ្លាក់ចុះខ្លាំងយ៉ាងណា (សំខាន់នោះ គឺផ្អែកទៅលើកម្រិតដំបូងរបស់អត្រាកើតនោះ) និងថាតើអត្រាកើតធ្លាក់ចុះលឿនយ៉ាងណា ។ នៅទូទាំង អាស៊ីអត្រាកើតធ្លាក់ចុះពីកម្រិតផ្ដើមដំបូងខ្ពស់ ។ សង្គម អាស៊ីមានភាពខុសគ្នានៅក្នុងដំណើរការនៃភាពប្រែប្រួលទាំងនោះ មានជាតួយ៉ាងពីការប្រែប្រួលយ៉ាងលឿន នៅតាមតំបន់ (ដំបូងឡើយនៅប្រទេសកូរ៉េខាងត្បូង ប្រទេសសិង្ហបុរី ទីក្រុងហុងកុង និងកោះតៃវ៉ាន់ ហើយនិង ថ្មីៗនេះនៅ ប្រទេសថៃ និងប្រទេសចិន) រហូតដល់ការប្រែប្រួលយឺតៗនៅប្រទេសឥណ្ឌា ប្រទេសម៉ាឡេស៊ី និង ប្រទេសហ្វីលីពីន ។ តាមការប៉ាន់ស្មានទាំងនេះកំលុងពេលនៃអត្រាកើតរបស់ភាពប្រែប្រួលប្រជាសាស្ត្រនេះមាន ពី ១៦ ទៅ៦៦ ឆ្នាំ (ដោយប្រៀបធៀបប្រទេសសិង្ហបុរី ជាមួយនឹងប្រទេសហ្វីលីពីន)។

**Figure 1. The Youth Explosion Phase of Demographic Transition: Four Countries of Asia**




គំនូស ១ : ដំណាក់កាលនៃការកើនឡើងនៃយុវជនក្នុងបម្រែបម្រួលប្រជាសាស្ត្រនៅតាមប្រទេសចំនួនបួននៅអាស៊ី

*កំណើនយុវជនធ្វើឲ្យមានទំហំដ៏ធំជាងគេនៅពេលដែលការប្រែប្រួលដែលទើបតែធ្វើការពណ៌នានេះមានភាពរហ័ស និងសំខាន់ ។ ហើយបន្ថែមលើនេះទៀត ឥទ្ធិពលរបស់កំណើននេះជាក់ស្តែងបំផុតនៅពេលដែលកម្លាំងពលកម្មធ្វើសកម្មភាព ។ បទសង្ខេបស្តីពីបទពិសោធបន្ថែមទៀត មាននៅក្នុងតារាង ៤ ដែលពណ៌នាពីប្រទេសសំខាន់បួនរបស់យើងនៅក្នុងគំនូស ១ ។ នៅក្នុងចំណោមប្រទេសទាំងបួន ប្រទេសកូរ៉េខាងត្បូងបង្ហាញយ៉ាងល្អប្រសើរជាងគេនូវបម្រែបម្រួលប្រជាសាស្ត្រយ៉ាងឆាប់រហ័សដែលបណ្តាលមកពីកម្រិតអត្រាកំណើតខ្ពស់ ដែលនាំឲ្យមានកំនើនយុវជនគួរឲ្យកត់សម្គាល់ដែលកំណត់ដោយសូចនាករចំនួនពីររួមមានអត្រាកំណើនយុវជនកើនឡើង និងបមាណភាគយុវជននៃចំនួនប្រជាជនសរុប ហើយនិងកំណត់ដោយព្រឹត្តិការណ៍ជាខ្នាតគំរូចំនួនបី ។*

ព្រឹត្តិការណ៍ខ្នាតតូចទាំងបីនេះរួមមាន÷ ១) ការដល់ចំណុចខ្ពស់បំផុតនៃអត្រាកំណើនយុវជន (នៅគ.ស.១៩៧៤) ២) ការឡើងដល់ចំណុចខ្ពស់បំផុតនៃបមាណភាគយុវជននៃចំនួនប្រជាជនសរុប (នៅគ.ស.១៩៨០) និង ៣) ការឡើងដល់ចំណុចខ្ពស់បំផុតនៃចំនួនបរិប្ដូររបស់យុវជន (នៅគ.ស.១៩៨១) ។ តាមទស្សនៈនយោបាយ មានការសម្រុះសម្រួលដំរដិបរដប់មួយនៅក្នុងតួលេខទាំងនេះ ពីព្រោះការប្រែប្រួលយ៉ាងរហ័សទាំងនេះមានការចំណាយទៅលើសង្គម និងហេដ្ឋារចនាសម្ព័ន្ធ (មានជាតួយ៉ាងដូចជា ការកើនឡើងរួចធ្លាក់ចុះវិញនូវតម្រូវការនៃការសាងសង់សាលារៀន) ប៉ុន្តែពិតជារក្សាបាននូវចំនួនយុវជនឲ្យនៅក្នុងកំណត់មួយ ។ ដូចនេះហើយចំនួនប្រជាជនជាយុវជននៅ ប្រទេសកូរ៉េខាងត្បូងកើនឡើងត្រឹមតែ ៨៣% ប៉ុណ្ណោះនៅក្នុងកំលុងពេលប្រែប្រួលប្រជាសាស្ត្ររបស់ ប្រទេសនេះ ។

បទពិសោធផ្ទុយពីនេះនៃបម្រែបម្រួលយឺតៗត្រូវបានបង្ហាញឲ្យឃើញនៅតាមបណ្ដាប្រទេស ដូចជាប្រទេសម៉ាឡេស៊ី និងប្រទេសនេប៉ាល់ ហើយនិងនៅក្នុងចំណោមបណ្ដាប្រទេសទាំងបួនរបស់យើងគឺបង្ហាញតាមរយៈប្រទេសហ្វីលីពីន ។ ប្រទេសហ្វីលីពីនចាប់ផ្ដើមមានបម្រែបម្រួលអត្រាកំណើតរបស់ខ្លួនដំបូង តាំងពីយូរមកម្ល៉េះ នេះបើយោងតាមការប៉ាន់ស្មានដែលមានការទទួលស្គាល់យ៉ាងទូលំទូលាយដែលខ្ញុំកំពុងតែយកមកធ្វើជាអំណះអំណាង ប៉ុន្តែចំនួននៃយុវជនដែលមានកម្រិតខ្ពស់បំផុតនោះនឹងមិនមាននោះទេ ។ ជាតួយ៉ាងនៅក្នុងកំលុងពេលទាំងមូលនៃការប្រែប្រួលនេះ ចំនួនយុវជននៅប្រទេសហ្វីលីពីន នឹងកើនឡើងដល់ទៅ ២៥៩% ។

នេះគឺជាកំណើនយុវជនតាមមាត្រដ្ឋានថ្នាក់ជាតិនៅទូទាំងអាស៊ី ។ ដួនកាលអត្រាកំណើននៃយុវជនកើនដល់កម្រិតដ៏ខ្ពស់ ដែលអាចចាត់ទុកថាខ្ពស់ជាងអត្រាកំណើននៃចំនួនយុវជនទាំងមូល ។ ម្យ៉ាងវិញទៀត បមាណភាគយុវជនដែលបានបង្ហាញឲ្យឃើញនៅក្នុងគំនូស ១ ជាទូទៅស្ថិតនៅកម្រិតខ្ពស់ជាង បមាណភាគយុវជននៅទូទាំងមជ្ឈិមបូព៌ា ដែលបានទទួលការចាប់អារម្មណ៍យ៉ាងច្រើន ។ តារាងស្ដីអំពីបមាណភាគយុវជនសម្រាប់បណ្ដាប្រទេសនៅមជ្ឈិមបូព៌ារបស់ ហាន់ទីងទន់ បង្ហាញអំពីកម្រិតខ្ពស់បំផុតដែលស្ថិតនៅលើបន្ទាត់ ២០% យ៉ាងពិបាក (សូមធ្វើការប្រៀបធៀបឯកសាររបស់ ហាន់ទីងទន់ គ.ស.១៩៩៦ គំនូស ៥ ពីទំ.ទី១-៥) ។ ប៉ុន្តែព្រឹត្តិការណ៍នៃកំណើនយុវជនទាំងនេះបានចប់ ឬក៏ស្ទើរតែចប់សព្វគ្រប់ហើយ នៅតាមបណ្ដាប្រទេសភាគច្រើននៅអាស៊ីនាពេលបច្ចុប្បន្ននេះ ។ សារៈសំខាន់ជាប្រវត្តិសាស្ត្ររបស់ព្រឹត្តិការណ៍ទាំងនេះ ត្រូវបានភ្ជាប់ជាមួយការប្រែប្រួលប្រជាសាស្ត្រដទៃទៀត ។ ដោយមានលំនាំប្រជាជាតិជាសំអាងនៅពេលនេះ យើងអាចងាកទៅបកស្រាយអំពីប្រជាសាស្ត្រយុវជននៅតាមទីក្រុងធំៗ តាមតំបន់ទីក្រុង និងតាមតំបន់ជនបទ ដែលតំបន់ទាំងនេះទទួលឥទ្ធិពលពីនិន្នាការប្រជាសាស្ត្រជាតិផង និងពីការហូរចូលជាប្រវត្តិសាស្ត្ររបស់យុវជនមកកាន់តំបន់ទីក្រុងផង ។

## ការហូរចូលរបស់យុវជនមកកាន់តំបន់ទីក្រុង

នៅខាងដើមនៃជំពូកនេះ យើងបានបកស្រាយពីបម្រែបម្រួលតំបន់ទីក្រុងជាតិនៅអាស៊ី ដែលបម្រែបម្រួលទាំង នោះចំពោះប្រទេសភាគច្រើន កើតឡើងនៅពេលដំណាលគ្នា ជាមួយនឹងបម្រែបម្រួលប្រជាសាស្ត្រជាតិ ហើយនិងបានទទួលឥទ្ធិពលពីដំណាក់កាលកំណើនដ៏ឆាប់រហ័សរបស់ដំណើរការបម្រែបម្រួលទាំងនោះ ។ យើងក៏បានបង្ហាញដែរថាបណ្ដាតំបន់ទីក្រុងជាទូទៅជួបប្រទះអត្រាអន្តោប្រវេសន៍ក្នុងស្រុកខ្ពស់ជាងគេបង្អស់ យ៉ាងជាក់លាក់នោះគឺចំពោះគម្លាតអាយុយុវជន ។ ជាផ្នែកមួយនៃប្រជាសាស្ត្ររបស់យុវជនទីក្រុង យើងមានបំណងលើងបង្ហាញអំពីឥទ្ធិពលប្រជាសាស្ត្រខ្លះៗនៃការហូរចូលតំបន់ទីក្រុងរបស់យុវជន ។ ជំហានដំបូងគឺ ត្រូវមើលទៅលើផ្នែកតូចៗនៃ

*តំបន់ជនបទ តំបន់ទីក្រុង និងតំបន់ទីក្រុងធំៗ ដើម្បីធ្វើជាសូចនាករនៃកំណើនយុវជន ។ ទិន្នន័យដែលមានអាចឲ្យគេបំបែកវិធានការទាំងនេះជាផ្នែកតូចៗសម្រាប់ ប្រទេសសំខាន់ទាំងបួនរបស់យើងនៅក្នុងកំលុងពេលពី គ.ស. ១៩៧០ រហូតដល់គ.ស.១៩៩០ ឬ ១៩៩៥ និងសម្រាប់ប្រទេសកូរ៉េខាងត្បូង និងប្រទេសហ្វីលីពីនមុនគ.ស.១៩៧០ ។ សូចនាករទាំងនោះមាននៅក្នុងតារាង ៥ ។*

*មានទ្រង់ទ្រាយជាទូទៅខ្លះៗនៅក្នុងតារាង ៥ នេះក៏ដូចជាមានលទ្ធផលពិសេសខ្លះៗផងដែរ ។ ជាទូទៅ សូចនាករចម្បងនៃកំណើនយុវជនទាំងពីរនេះស្ថិតនៅកម្រិតខ្ពស់ជាងនៅតំបន់ទីក្រុង ហើយកម្រិតខ្ពស់ ទាំងនោះគឺនៅក្នុងតំបន់ទីក្រុងធំៗ ។ និយាយរួមទាំងតំបន់ទីក្រុងធំៗ និងទាំងតំបន់ទីក្រុង គឺសុទ្ធតែបង្ហាញពីកស្តុតាងនៃកំណើនយុវជនខណៈពេលដែលនៅតាមតំបន់ជនបទកំណើននេះស្ថិតនៅកម្រិតទាបថ្វីបើមាន ក៏ដោយ ។ គួរកត់សម្គាល់ថាមានតែម្តងគត់ (គឺនៅប្រទេសថៃ គ.ស. ១៩៨០) ដែលបមាណភាគយុវជននៅជនបទមានច្រើនជាង ២០% ខណៈពេលដែលបមាណភាគយុវជនតែងតែលើ ២០% នៅតំបន់ទីក្រុងធំៗ និងតំបន់ទីក្រុងឯទៃទៀត ហើយនិងជាធម្មតាលើ ២៣% នៅតាមតំបន់ទីក្រុងធំៗ (ដោយមានករណីលើកលែងមួយ គឺនៅប្រទេសកូរ៉េខាងត្បូង នៅ គ.ស.១៩៩៥ ដែលនៅពេលនោះចំនួនយុវជនមានសភាពរាយប៉ាយប្រហាក់ប្រហែលគ្នាគ្រប់ទីកន្លែង) ។ នៅក្នុងតារាង ៥ មិនមានកន្លែងណាដែលបង្ហាញថាបមាណភាគយុវជនស្ថិតនៅក្រោមកម្រិត «ឱនភាព» ១៥% នោះឡើយ ។ យើងគួរកត់សម្គាល់ថាកម្រិតដែលនៅក្រោម ១៥% ត្រូវបានគេប៉ាន់ស្មានចេញពីខ្នាតគំរូប្រជាសាស្ត្រថាជាសភាពធម្មតានៃរចនាសម្ព័ន្ធអាយុ ទាំងមុន និងក្រោយពេលប្រែប្រួលប្រជាសាស្ត្រ ។ តាមការពិនិត្យពិច័យឲ្យហ្មត់ចត់ទៅ រាល់បមាណភាគយុវជនទាំងអស់ដែលបង្ហាញនៅក្នុងតារាង ៥ មានការកើនឡើងខ្ពស់ ។*

*បមាណភាគយុវជននៅតាមតំបន់ទីក្រុងធំៗជាមធ្យមគឺ ២៨% ខ្ពស់ជាងនៅតាមតំបន់ជនបទ នៅទូទាំងប្រទេសទាំងបួនដែលយើងធ្វើការសិក្សា ។ នេះឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីការផ្លាស់ប្តូរមកការហូរចូល ។*

**តារាង ៥: សូចនាករនៃការកើនឡើងចំនួនយុវជននៅក្នុងតំបន់ទីក្រុងធំ តំបន់ទីក្រុងឯទៀត និងតំបន់ជនបទ នៅប្រទេសចំនួនបួននៅអាស៊ី តាមគ.ស. ដែលមានទិន្នន័យ និងពីគ.ស.១៩២៥-១៩៩៥**

| ប្រទេស និងគ្រិស្តរាជ | បមាណភាគយុវជននៃចំនួនប្រជាជន | | | | អត្រាកំណើននៃចំនួនប្រជាជនជាយុវជន | | | |
|---|---|---|---|---|---|---|---|---|
| | ទូទាំងប្រទេស | តំបន់ទីក្រុងធំ | តំបន់ទីក្រុងឯទៀត | តំបន់ជនបទ | ទូទាំងប្រទេស | តំបន់ទីក្រុងធំ | តំបន់ទីក្រុងឯទៀត | តំបន់ជនបទ |
| **កូរ៉េ** | | | | | | | | |
| ១៩២៥ | ០,១៧៦ | ០,២១៣ | NA | NA | ២,០៧ | ៤,៤៩ | NA | NA |
| ១៩៣០ | ០,១៨៣ | ០,២៣៥ | NA | NA | ១,០០ | ២,៣៦ | NA | NA |
| ១៩៣៥ | ០,១៧៨ | ០,២៣៧ | NA | NA | -០,២៣ | ១៧,៧៣ | NA | NA |
| ១៩៤០ | ០,១៥៩ | ០,២៣២ | NA | NA | ១,៤៣ | ១,១៣ | NA | NA |
| ១៩៤៥ | ០,១៦៩ | ០,២២៧ | NA | NA | ៦,៣១ | ១០,៨៥ | NA | NA |
| ១៩៥០ | ០,១៦៨ | ០,២២៨ | NA | NA | ២,០៤ | ១,៧៨ | NA | NA |
| ១៩៥៥ | ០,១៩៣ | ០,២២៥ | ០,២០៩ | ០,១៨៦ | ១,៨៨ | ៧,៩៨ | ១,៦៨ | ២,៣៣ |
| ១៩៦០ | ០,១៨២ | ០,២១៨ | ០,១៩៥ | ០,១៧៤ | ១,៨៨ | ៨,៤៣ | ៥,៧២ | NA |
| ១៩៦៥ | ០,១៧២ | ០,២១៤ | NA | NA | ២,២៨ | ៩,១២ | ៥,៩៩ | NA |
| ១៩៧០ | ០,១៧៨ | ០,២៣២ | ០,២១៥ | ០,១៤៨ | ៥,១៨ | ៥,៣៣ | ៧,៩៥ | -០,៦៦ |
| ១៩៧៥ | ០,២១០ | ០,២៤៣ | ០,២៤០ | ០,១៨០ | ២,៦៤ | ៣,៥៣ | ៥,៩២ | -២,២៥ |
| ១៩៨០ | ០,២២២ | ០,២៣៩ | ០,២៤៤ | ០,១៩៤ | ០,៦៤ | ១,៣៤ | ៣,២១ | -២,៦៦ |
| ១៩៨៥ | ០,២១២ | ០,២២២ | ០,២២៣ | ០,១៩១ | ០,៦៥ | ០,៩៥ | ៣,៣៦ | -៤,៦៤ |
| ១៩៩០ | ០,២០៤ | ០,២១១ | ០,២០៤ | ០,១៩៦ | -១,៥៩ | -១,៩៨ | ០,៦០ | -២,៩៨ |
| ១៩៩៥ | ០,១៨៣ | ០,១៩៩ | ០,១៨៤ | ០,១៦៥ | NA | NA | NA | NA |
| **ឥណ្ឌូនេស៊ី** | | | | | | | | |
| ១៩៧១ | ០,១៦៤ | ០,២០៩ | ០,២០២ | ០,១៥៥ | ៤,២៣ | ៥,៥២ | ៧,០៤ | ១,៦៨ |
| ១៩៨០ | ០,១៩៣ | ០,២៤១ | ០,២៣០ | ០,១៨២ | ២,១៣ | ២,៦៦ | ៥,៧៦ | ០,៨៣ |
| ១៩៩០ | ០,១៩៦ | ០,២៤៧ | ០,២២៩ | ០,១៨០ | NA | NA | NA | NA |

| ប្រទេស និងត្រីស្តរាជ | បមាណភាគយុវជននៃចំនួនប្រជាជន | | | | អត្រាកំណើននៃចំនួនប្រជាជនជាយុវជន | | | |
|---|---|---|---|---|---|---|---|---|
| | ទូទាំងប្រទេស | តំបន់ទីក្រុងធំៗ | តំបន់ទីក្រុងឯទៀត | តំបន់ជនបទ | ទូទាំងប្រទេស | តំបន់ទីក្រុងធំៗ | តំបន់ទីក្រុងឯទៀត | តំបន់ជនបទ |
| **ហ្វីលីពិន** | | | | | | | | |
| ១៩០៣ | ០,១៨០ | ០,២៤៩ | NA | NA | ២,៤៧ | ១,៨០ | NA | NA |
| ១៩១៨ | ០,១៩២ | ០,២៥២ | NA | NA | ២,៦៦ | ៣,៤៨ | NA | NA |
| ១៩៣៩ | ០,១៩៩ | ០,២៣៩ | NA | NA | ២,០៧ | ៥,៩២ | NA | NA |
| ១៩៤៨ | ០,១៩៩ | ០ ៣៥៨ | NA | NA | ២,៦៦ | ១,១៨ | NA | NA |
| ១៩៦០ | ០,១៩៥ | ០,២៥៧ | NA | NA | ៣,១៦ | ១២,៥៦ | NA | NA |
| ១៩៧០ | ០,១៩៧ | ០,២៦០ | ០,២០៦ | ០,១៨៤ | ៣,៩០ | ៤,១២ | ២,៩២ | ២,៨០ |
| ១៩៧៥ | ០,២០៩ | ០,២៥៤ | ០,២២១ | ០,១៩៨ | ២,២៧ | ២,៩៨ | ៦,៥៥ | ០,៩៤ |
| ១៩៨០ | ០,២០៥ | ០,២៤៧ | ០,២១៣ | ០,១៩៣ | ២,៣២ | ១,៨៨ | ៥,៦៨ | ០,៣១ |
| ១៩៩០ | ០,២០៥ | ០,២២៤ | ០,២១០ | ០,១៩៧ | ២,០៣ | ៣,៤១ | NA | NA |
| ១៩៩៥ | ០,២០០ | ០,២២២ | NA | NA | NA | NA | NA | NA |
| **ថៃឡង់** | | | | | | | | |
| ១៩៧០ | ០,១៨២ | ០,២៣៩ | ០,២១២ | ០,១៨០ | ៤,៣៩ | ៩,១៩ | ៣,៥៨ | ២,២០ |
| ១៩៨០ | ០,២២២ | ០,២៧៥ | ០,២៤៨ | ០,២១៣ | ១,២៣ | ១,១៥ | ២,២៨ | ១,៧៦ |
| ១៩៩០ | ០,២០៦ | ០,២៤៧ | ០,២១១ | ០,២០០ | NA | NA | NA | NA |

សម្គាល់៖ ចំពោះព័ត៌មានសម្រាប់គ.ស. ១៩២៥-១៩៤៥ សំដៅទៅលើតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាតិជប៉ុន ដូច្នេះហើយសំដៅទៅលើឧបទ្វីបកូរ៉េទាំងមូល ។ នាមានន័យថា មិនមានទិន្នន័យ ។
យោង ៖ ការគណនាទាំងនេះយោងតាមជំរឿនដែលបានចេញផ្សាយ ។

ក្នុងតំបន់ទីក្រុងពីសំណាក់យុវជន ។ បមាណភាគយុវជនច្រើនជាងគេ គឺនៅទីក្រុងបាងកក នៅគ.ស.១៩៨០ (០,២៧២) ដែលមាន ៦២% ចំណុចពេញច្រើនជាងតំបន់ជនបទគ្រប់ពេល ។

អត្រាកំណើនយុវជនមានទ្រង់ទ្រាយប្រហាក់ប្រហែលគ្នាទាំងអស់ ទោះបីជាទ្រង់ទ្រាយទាំងនោះមិនមានសភាពទៀងទាត់ក្នុងការផ្លាស់ប្តូររបស់ពួកគេក៏ដោយ ។ ដោយយោងតាមលំដាប់ដំណើរនៃការប្រែប្រួលយុវជន

ដែលបានពណ៌នាពីខាងលើមក យើងដឹងថាអត្រាកំណើនយុវជនខ្ពស់បំផុតកើតឡើងនៅមុនពេលដែលមានបមាណភាគយុវជនខ្ពស់បំផុត ។ ជាតួយ៉ាង បមាណភាគយុវជនខ្ពស់បំផុតនៃ ០,២២២ នៅតំបន់ទីក្រុងធំៗនៅកូរ៉េខាងត្បូងមាននៅគ.ស.១៩៨០ ។ ប្រមាណពី ១០ ទៅ ១៥ ឆ្នាំមុននោះ គេឃើញមានអត្រាកំណើននៃចំនួនប្រជាជនជាយុវជនប្រចាំឆ្នាំរបស់ប្រទេសនេះស្ថិតនៅចន្លោះពី ៨% ទៅ ៩% ដែលជាកម្រិតគួរឲ្យគត់សម្គាល់ណាស់ ។ អត្រាកំណើនយុវជនស្រដៀងនេះមួយដែរមាននៅក្រុង បាងកកក្នុងកំលុងទសវត្សទី ៧០ មុនពេលដែលបមាណភាគយុវជនខ្ពស់បំផុតកើតឡើងនៅគ.ស.១៩៨០ ។

មានភាពខុសៗគ្នាគួរឲ្យចាប់អារម្មណ៍ខ្លះដែរ ក្នុងចំណោមប្រទេសទាំងបួននេះ ។ ជាតួយ៉ាង នៅប្រទេសកូរ៉េខាងត្បូងដែលកំណើនយុវជនកើតឡើងនៅក្នុងទសវត្សទី ៧០ ហើយសូចនាករមានលក្ខណៈខ្ពស់សម្រាប់ចំនួនយុវជនរួមនៅតំបន់ទីក្រុងក្រៅពីទីក្រុងសេអ៊ូល ។ នៅក្នុងប្រទេសកូរ៉េ ទាំងបមាណភាគយុវជន និងទាំងអត្រាកំណើនយុវជន សុទ្ធតែមានកម្រិតខ្ពស់នៅតាមតំបន់ទីក្រុងដែលមិនមានមនុស្សច្រើន[១២]។




គំនូស ២ ៖ សូចនាករនៃកំណើនយុវជនសម្រាប់តំបន់រស់នៅ ដោយមានព័ត៌មានលម្អិតនៅកូរ៉េខាងត្បូង ពីគ.ស. ១៩៧០-១៩៩០

គំនូស ២បង្ហាញអំពីទស្សនវិស័យមួយលើកម្លាំងប្រជាសាស្ត្រនៃបម្រែបម្រួលប្រជាសាស្ត្រជាតិដែលប្រឆាំងនឹងដំណើរការផ្លាស់ប្ដូរពីជនបទទៅកាន់ទីក្រុងនៅក្នុងបណ្ដាប្រទេសនានា ។ ផ្នែកខាងលើ នៃគំនូស ២ នេះបង្ហាញឲ្យយើងឃើញពីចន្លោះមួយរវាងទិសពីរដែលកំណត់ដោយសន្ទុស្សន៍កំណើនយុវជនទាំងពីរជាមួយ និងព័ត៌មានបង្ហាញពីតំបន់នីមួយៗនៃប្រទេសនីមួយៗ ក្នុងគម្លាតពី គ.ស.១៩៧០-៧១ រហូតដល់ គ.ស.១៩៩០ ។ នេះជាការជាក់ស្ដែងណាស់ដែលកម្រិតនៅតំបន់ទីក្រុងធំៗនៅលើសន្ទុស្សន៍ទាំងពីរខ្ពស់ជាងកម្រិតនៅតាមតំបន់ជនបទយ៉ាងខ្លាំងដោយកម្រិតតំបន់ទីក្រុងឯទៀតស្ថិតនៅចន្លោះកណ្ដាល ហើយមិនមានលក្ខណៈខុសពីតំបន់ទីក្រុងធំៗប៉ុន្មាននោះទេ ។ តំបន់នីមួយៗនៅប្រទេសនីមួយៗដើរតាមគន្លងដូចគ្នានេះដែរ ប៉ុន្តែតំបន់នៅកូរ៉េខាងត្បូង (ដូចដែលបានបង្ហាញនៅផ្នែកខាងក្រោមនៃរូប គំនូស២) ផ្ដល់ព័ត៌មានគួរឲ្យចាប់អារម្មណ៍ជាងគេនៅក្នុងចំណោមប្រទេសទាំងបួននេះ ពីព្រោះថាបម្រែបម្រួលប្រជាសាស្ត្រទាំងមូលរបស់តំបន់នេះត្រូវបានឆ្លុះបញ្ចាំងទន្ទឹមនឹងទ្រង់ទ្រាយទាំងមូលនៃប្រជាសាស្ត្រយុវជនដែរ ដោយរួមទាំងទ្រង់ទ្រាយតំបន់នៃកំណើនប្រជាជនជាយុវជន ។ សញ្ញាព្រួញទាំងនោះបង្ហាញអំពីគន្លងនៃតំបន់នីមួយៗនៃតំបន់ទាំងបី ។ បមាណភាគយុវជននៅជនបទមានកម្រិតទាបដូចគ្នា ហើយអត្រាកំណើនយុវជននៅជនបទធ្លាក់ចុះនៅក្នុងកំលុងពេលពី គ.ស.១៩៥៥-១៩៩០ (សូមធ្វើការប្រៀបធៀបតារាង ៥សម្រាប់កាលបរិច្ឆេទដំបូងគេបង្អស់) ។ ហើយអត្រាកំណើនទាំងនេះមិនមានសភាពល្អនោះទេពីគ.ស. ១៩៧០ មក ។ ទាំងតំបន់ទីក្រុង និងទីក្រុងធំៗ មានអត្រាកំណើនយុវជនកើតឡើងរួចហើយធ្លាក់ចុះវិញ ដែលអត្រាទាំងនោះកើនដល់ចំណុចខ្ពស់បំផុតប្រហាក់ប្រហែលគ្នា ទោះជាកើតឡើងនៅពេលខុសៗគ្នាក៏ដោយ ។ ហើយអត្រាទាំងនោះធ្លាក់ចុះយ៉ាងទាប ប្រយ៉ាងអាក្រក់នៅពេលថ្មីៗនេះ ។ បមាណភាគយុវជននៅតំបន់ទីក្រុងក៏កើនឡើងហើយធ្លាក់ចុះវិញដែរ (ចំណុចខ្ពស់បំផុតរបស់អត្រាឡើង-ចុះទាំងពីរនេះសុទ្ធតែកើតឡើងនៅជុំវិញគ.ស. ១៩៨០) ។ សម្រាប់ប្រទេសបីទៀត ដំណើរព្រឹត្តិការណ៍នេះមិនទាន់អាចធ្វើការបកស្រាយឲ្យបានពេញលេញនោះទេ បើយោងតាមទិន្នន័យដែលមានស្រាប់ទាំងនេះ ប៉ុន្តែយើងអាចប៉ានស្មានថាទ្រង់ទ្រាយដំណើរការប្រហាក់ប្រហែលនេះនឹងកើតឡើងចំពោះប្រទេសទាំងបីនេះ ។

## ទម្រង់បែបបទសង្គមមួយនៃយុវជនទីក្រុង

នៅផ្នែកខាងដើមនៃជំពូកនេះ យើងបានកត់សម្គាល់ពីនិន្នាការសង្គមចំនួនពីរដែលមានសារៈសំខាន់នៅក្នុងប្រជាសាស្ត្រនៃយុវជនអាស៊ី ។ និន្នាការទាំងពីរនោះរួមមាន៖ ការផ្លាស់ប្ដូរទំនោរទៅរកការរៀបអាពាហ៍ពិពាហ៍ពេលមានអាយុច្រើន ដែលទំនោរនេះធ្វើឲ្យមានភាគរយកាន់តែច្រើនទៅលើចំនួនយុវជននៅលីវ ។ ទំនោរមួយទៀតគឺការផ្លាស់ប្ដូរទៅរកការចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សាក្នុងចំណោមយុវជន ។ ការស្រាវជ្រាវមុនៗមកបានកត់ត្រាពីនិន្នាការទាំងពីរនេះតាំងពី គ.ស.១៩៥០ រហូតដល់គ.ស.១៩៩០ សម្រាប់ប្រទេសទាំងអស់ក្នុងតំបន់នេះ ហើយក៏សម្រាប់ភេទទាំងពីរនៅក្នុងនិន្នាការនីមួយៗដែរ (យោងតាមឯកសាររបស់ ស៊្មិកណូស និងកាបាម៉ាឡាន (Kabamalan)គ.ស.១៩៩៨ និងឯកសារដែលកំពុងបោះពុម្ពផ្សាយរបស់អ្នកទាំងពីរនេះ និងឯកសាររបស់ ស្មិកណូស និងហ្គុលទីយ៉ាណូ (Gultiano) គ.ស.២០០២) ។ នៅក្នុងផ្នែកនេះ យើងសូមធ្វើការពិចារណាទៅលើនិន្នាការបម្រែបម្រួលសង្គមជាតិទាំងពីរនេះ ទន្ទឹមនឹងកម្រិតនៃការចូលរួមកម្លាំងការងារ ដែលកត្តានីមួយៗត្រូវបែងចែកសម្រាប់តំបន់ទីក្រុងធំៗ ទីក្រុង និងតំបន់ជនបទ ដើម្បីបកស្រាយ ។ តាមទិន្នន័យដែលយើងមានអាចឲ្យយើងធ្វើការសិក្សា

*បែបនេះទៅលើប្រទេសសំខាន់ទាំងបួនរបស់យើង ។ សូមមើលឧបសម្ព័ន្ធ A។*

| ចំនួនប្រជាជនតាមផ្នែក | ឥណ្ឌូនេស៊ី | ថៃឡង់ | |
|---|---|---|---|
| | ១៥-១៩ ឆ្នាំ | ១៥-១៩ឆ្នាំ | ២០-២៤ឆ្នាំ |
| ចំនួនប្រជាជនសរុប | ២៥,០ | ៣០,៤ | ៣០,៤ |
| ចំនួនប្រជាជនជាយុវជន | ៣៦,០ | ៤៧,២ | ៦៩,៥ |
| តំបន់ទីក្រុងធំៗ | ៥៤,០ | ១១៨,៦ | ១៧៩,៩ |
| នៅលីវ | ៥៥,៧ | ១១៤,៣ | ១៧៣,៦ |
| នៅក្រៅសាលារៀន | ៩,៤ | ៦០,៥ | ១៣៥,៨ |
| ចុះឈ្មោះចូលរៀន | ១២១,៣ | ១៧១,០ | ៣២៧,៣ |

**តារាង ៦ ÷ ភាគរយបម្រែបម្រួលចំនួនប្រជាជនក្នុងរយៈពេល ១០ ឆ្នាំ ពីគ.ស. ១៩៧០-៨០ នៅតាមផ្នែកដោយមានកត្តាបុរសកំណត់ប្រទេស និងក្រុមអាយុ**

យោង៖ ការគណនាស្ថិតិទាំងនេះផ្អែកលើជំរឿនដែលចេញផ្សាយ

*ផ្នែកនេះមិនមែនសម្រាប់ពិភាក្សាឲ្យលម្អិតលើព័ត៌មានដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ A នោះទេ ។ ចំណុចមួយចំនួនខាងក្រោមនេះទាក់ទងទៅនឹងគោលបំណងរបស់យើងនៅក្នុងផ្នែកនេះ ។ មានភាពខុសគ្នាមួយចំនួនដែលយើងបានរំពឹងទុកនៅក្នុងចំណោមក្រុមអាយុ និងរវាងក្រុមបុរស និងស្ត្រី ។ អត្រាចុះឈ្មោះចូលរៀន និងភាគរយនៅលីវមានកម្រិតខ្ពស់សម្រាប់បុរសច្រើនជាងស្ត្រី ហើយអត្រាទាំងនេះធ្លាក់ចុះនៅពេលដែលពួកគេមានអាយុច្រើន ។ អត្រាចូលរួមក្នុងកម្លាំងការងារជាទូទៅខ្ពស់ជាងសម្រាប់បុរសជាងសម្រាប់ស្ត្រី ហើយខ្ពស់ជាងពេលមានអាយុកាន់តែច្រើន ។ ភាគរយនៅលីវ និងអត្រាចុះឈ្មោះចូលរៀនកើនឡើងជាមួយនឹងពេលវេលា ខណៈពេលដែលអត្រាចូលរួមខាងកម្លាំងការងារដើរតាមគន្លងខុសៗគ្នា ទៅតាមប្រទេសនីមួយៗតាម ទៅតាមក្រុមអាយុនីមួយៗ និងទៅតាមក្រុមភេទនីមួយៗ ។*

*ទ្រង់ទ្រាយនៅក្នុងការរស់សួង់ទាំងនេះដែលជាប់ទាក់ទិនជាមួយកម្រិតនៃការអភិវឌ្ឍ នឹងអាចឲ្យគេរកឃើញតាមរយៈភាពខុសគ្នា តាមតំបន់ និងតាមពេលវេលា ។ នៅក្នុងចំណោមការរស់ស្ទួង់ទ្រង់ទ្រាយសង្គមទាំងបីនេះ ការចុះឈ្មោះចូលរៀនហាក់ដូចជាមានទ្រង់ទ្រាយមួយដែលធ្វើឲ្យយើងមើលឃើញពីការវិវឌ្ឍប្រែប្រួលជាសកល ដោយគ្រប់កត្តាទាំងអស់មានកម្រិតកើនឡើងទៅតាមកម្រិតនគរូបនីយកម្ម និងទៅតាមពេលវេលា ទោះបីជាពេលវេលានោះខុសៗគ្នាក៏ដោយ ។ ភាគរយនៅលីវក៏បង្ហាញពីទ្រង់ទ្រាយដូចគ្នានេះខ្លះៗដែរ ប៉ុន្តែក៏ឆ្លុះបញ្ចាំងអំពីនិន្នាការរៀបអាពាហ៍ពិពាហ៍ពេលមានអាយុច្រើន ជាទូទៅនៅតាមបណ្តាប្រទេសទាំងនោះ ។ អ្វីដែលគួរឲ្យកត់សម្គាល់ខ្លាំងបំផុតនោះគឺ នៅមានភាគរយនៅលីវទាបនៅតាមតំបន់ជនបទខ្លះៗ និងជាពិសេសនៅក្នុងចំណោមនារីជនបទ ។យោងតាមការបូករួមបញ្ចូលគ្នារវាងបញ្ហារស់ស្ទួង់ និងការយល់ឃើញការពន្យល់បកស្រាយ អំពី*

ការចូលរួមនៃកម្លាំងការងារ មានសភាពលំបាកណាស់ ជាពិសេសការប្រៀបធៀបជាអន្តរជាតិ ឬការប្រៀបធៀបរវាងក្រុមបុរស និងក្រុមនារី ។ នៅក្នុងបណ្តាប្រទេសក និងក្រុមគេទ ការប្រៀបធៀបអាចឲ្យជឿទុកចិត្តបានច្រើន ។ ផ្ទុយទៅវិញ អត្រាចូលរួមកម្លាំងការងារដែលត្រូវបានផ្តល់ឲ្យនៅក្នុងឧបសម្ព័ន្ធ A នោះបង្ហាញអំពីនិន្នាការយ៉ាងពិបាកស្មុគស្មាញសម្រាប់ប្រទេសនីមួយៗ ។ ជាអាទិ៍ អត្រាទាំងនោះកើនឡើងជារៀងរាល់ពេលចំពោះនារីនៅតំបន់ទីក្រុងធំៗ ដែលមានអាយុពី ១៥ ទៅ ១៩ ឆ្នាំនៅប្រទេសឥណ្ឌូនេស៊ី ខណៈពេលដែលមានការធ្លាក់ចុះចំពោះបុរស (ដែលជាទ្រង់ទ្រាយមួយត្រូវបានគិតទុកជាមុន នេះបើយោងតាមឯកសាររបស់ ឌុរ៉ង់ (Durand) គ.ស. ១៩៧៥) ប៉ុន្តែអត្រាទាំងនោះផ្ទុយពីអត្រានៅប្រទេសហ្វីលីពីន ។ ចំពោះករណីមួយណាក៏ដោយ ផ្នែកនេះធ្វើការពិភាក្សាផ្តោតទៅលើសូចនាកររបស់កត្តារៀបអាពាហ៍ពិពាហ៍ និងកត្តាការចុះឈ្មោះចូលរួម ។

ការរួមបញ្ចូលគ្នារវាងកំណើនយុវជន ការផ្លាស់ទីមកទីក្រុងធំ និងបម្រែបម្រួលសង្គម អាចត្រូវបានគេលើកយកមកបង្ហាញបានខ្លះដែរ ។ តារាង ៦ ពណ៌នាអំពីយុវជនប្រុសៗ ហើយនិងរយៈពេលនៃការធ្វើអន្តរជំរឿនក្នុងកំលុងគ.ស. ១៩៧០ ទៅគ.ស. ១៩៨០ តែប៉ុណ្ណោះ ។ ព័ត៌មានស្តីអំពីយុវជនវ័យក្មេងជាបុរសជនជាតិឥណ្ឌូណេស៊ីបង្ហាញពីកំណើន ២៥% ក្នុងមួយទសវត្ស សម្រាប់គ្រប់បុរសទាំងអស់ ប៉ុន្តែមាន ៣៦% ក្នុងចំណោមយុវជនបុរសនៅតំបន់ទីក្រុងធំៗ ដែលមានអាយុពី ១៥ ទៅ ១៩ ឆ្នាំ ។ ក្នុងចំណោមបុរសនៅលីវមានអាយុពី ១៥ ទៅ ១៩ ឆ្នាំ ដែលនៅក្នុងតំបន់ទីក្រុងធំៗ កំណើនដែលបានចុះបញ្ជីជាផ្លូវការមានកម្រិតដូចគ្នា ដែលនេះឆ្លុះបញ្ចាំងពីការពិតមួយថា បុរសវ័យក្មេងទាំងអស់នេះសុទ្ធតែនៅលីវតាំងពីដើម គ.ស. ១៩៧០ មកម្ល៉េះ ។ អាចមានការប្រែប្រួលបន្ថែមទៀតខ្លះៗដែរ ។ ចំនួនបុរសវ័យក្មេងទាំងនេះដែលនៅក្រៅសាលាបានកើនឡើងត្រឹមតែ ៩,៤% ប៉ុណ្ណោះ ដែលនេះឆ្លុះបញ្ចាំងពីការពិតមួយថា សមាមាត្រអ្នកចុះឈ្មោះចូលរៀនកើនពី ៤០% ទៅ ៥៧% ហើយអត្រាកំណើននេះភាគច្រើនគឺបានពីបុរសនៅលីវដែលមានអាយុពី ១៥ ទៅ ១៩ ឆ្នាំ ។ ចំនួនបុរសវ័យក្មេងនៅលីវដែលបានចុះឈ្មោះចូលរៀនបានកើនដល់ ១២១% ដែលកំណើនខ្ពស់នេះ បានមកពីការរួមបញ្ចូលគ្នានូវលទ្ធផលរបស់កម្លាំងចលករទាំងអស់នៅក្នុងកំលុងពេលមួយទសវត្ស ដែលយើងកំពុងធ្វើការសិក្សានេះ ។

ទិន្នន័យសម្រាប់ក្រុមប្រជាជនដូចគ្នានេះនៅក្នុងប្រទេសថៃមានទម្រង់ផ្សេង ។ នៅទីនោះ កំណើនចំនួនបុរសសរុបមានកម្រិតច្រើនជាង ហើយកំណើនយុវជនដ៏មហិមា និងបម្រែបម្រួលទៅកាន់ទីក្រុង មានសារៈសំខាន់ជាង ។ ចំនួនយុវជនបុរសវ័យក្មេងនៅទីក្រុងធំៗបានកើនឡើងដល់ ១១៩% ។ ចំនួនអ្នកដែលនៅលីវនៅក្នុងក្រុមនេះកើនតិចជាងនេះបន្តិច នៅពេលដែលភាគរយនៅលីវធ្លាក់ចុះបន្តិចដែរនោះ ។ ដោយមានការកើនឡើងជាលំដាប់ទៅលើភាគរយអ្នកដែលចុះឈ្មោះចូលរៀន ចំនួនអ្នកដែលចុះឈ្មោះចូលរៀនកើនឡើងយ៉ាងគួរឲ្យកត់សម្គាល់ដល់ ១៧១% ។ នៅក្នុងគូឡោនចុងក្រោយក្នុងតារាង ៦ មានការពណ៌នាពីយុវជនបុរសជនជាតិថៃមានអាយុពី ២០ ទៅ ២៤ ឆ្នាំ ។ នៅទីនោះ ឥទ្ធិពលនៃចំណាកស្រុកមកកាន់តំបន់ទីក្រុងមានរឹតតែខ្លាំងជាងនេះទៅទៀត ដោយមានកំណើនយុវជននៅទីក្រុងធំៗដែលមានអាយុពី ២០ ទៅ ២៤ ឆ្នាំ កើនដល់ទៅ ១៨០% ។ ទីតាំងប្រជាសាស្ត្រនេះមិនមានការប្រែប្រួលទៅលើភាគរយអ្នកនៅលីវទេ ប៉ុន្តែមានការកើនឡើងនៃចំនួនអ្នកចុះឈ្មោះចូលរៀន (ពី ១៦% ទៅ ២៥%) ។ ជាលទ្ធផល ចំនួនអ្នកនៅក្រៅសាលានៅក្នុងក្រុមនេះមានតិចជាងមុន (ដែលមាន ១៣៦%) ដោយមានកំណើនដ៏មហិមាមួយនៃចំនួនអ្នកចុះឈ្មោះចូលរៀន (គឺ ៣២៧%) ។ ចំពោះក្រុមអាយុ ២០-២៤ កំណើនដ៏មហិមានេះឆ្លុះបញ្ចាំងអំពីការអប់រំថ្នាក់ឧត្តមសិក្សា ដែលនៅពេលនោះបានបើកឱកាសយ៉ាងទូលំទូលាយ

ដល់ក្រុមយុវជនវ័យក្មេងជនជាតិថៃ ។ ព្រឹត្តិការណ៍នេះអាចជាអព្ភូតហេតុមួយ ប៉ុន្តែកំណើនចំនួនប្រជាជននៅក្នុងផ្នែកមួយនេះ គឺជាការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងសកម្មភាពនយោបាយនៅក្នុងប្រទេសថៃ តាំងពីខែតុលា គ.ស. ១៩៧១ មកម្ល៉េះ ។

# សេចក្តីសន្និដ្ឋាន

យើងបានធ្វើការបកស្រាយអំពីកំណើនដ៏មហិមារបស់យុវជននៅទូទាំងអាស៊ី ដោយមើលទៅលើទំហំរបស់កំណើននោះ ឥទ្ធិពលក្រុមអាយុនៅក្នុងបម្រែបម្រួលប្រជាសាស្ត្រជាតិ និងទំនាក់ទំនងដ៏សំខាន់របស់កំណើននេះជាមួយកត្តាប្រជាសាស្ត្រពីរទៀត រួមមាន៖ ១)ការហូរចូលមកកាន់តំបន់ទីក្រុងរបស់យុវជន និង២)ដំណើរបម្រែបម្រួលក្នុងចំណោមយុវជន ដែលដំណើរនេះបង្កើតឲ្យមានទ្រង់ទ្រាយសង្គមថ្មីមួយ ។ ខ្ញុំបានធ្វើការបកស្រាយតាំងពីដើមជំពូកនេះហើយថាកំណើនដ៏មហិមានៃចំនួនយុវជនអាស៊ីមានភាពអស្ចារ្យដោយសារកំណើននេះមានទំនាក់ទំនងជាមួយកត្តាបម្រែបម្រួលសង្គមទាំងពីរនេះ ។ កំណើនដ៏មហិមានៃចំនួន យុវជននៅតាមប្រជាជាតិមួយៗរឹតតែមានលក្ខណៈសំខាន់ជាងនេះទៅទៀត ព្រោះថាព្រឹត្តិការណ៍ទាំងនេះសុទ្ធតែបានកើតឡើងនៅពេលជាមួយគ្នា ដោយមានចលនាចំណាកស្រុករបស់យុវជនទៅកាន់តំបន់ទីក្រុង និងដោយមានបម្រែបម្រួលសង្គមសំខាន់ៗខ្លះរបស់យុវជន ។ អត្រាកំណើនយុវជនដែលមើលទៅហាក់ដូចជាកើនឡើងខ្ពស់ មានលក្ខណៈគួរឲ្យចាប់អារម្មណ៍ជាងនៅពេលដែលយើងពិចារណាទៅលើចំនួនប្រជាជនជាយុវជននៅតាមតំបន់ទីក្រុង ។ ហើយនៅពេលដែលយើងមើលទៅលើកត្តាជាក់លាក់នៃយុវជននៅទីក្រុងវិញ យើងជារឿយៗឃើញថាមានអត្រាកំណើនដ៏អស្ចារ្យណាស់ ។ បមាណភាគយុវជន (នៅក្នុងចំណោមប្រទេសទាំងបួនដែលយើងសិក្សាទៅលើ) ដែលមិនដែលលើសពី ២០% នៅកម្រិតថ្នាក់ជាតិនោះ តែងតែកើនលើសពីកម្រិត ២០% នោះ នៅក្នុងបណ្តាទីក្រុងធំៗចំនួនបួន ។ ហើយនៅក្នុងអត្រាកំណើនយុវជននៅតាមទីក្រុងធំៗទាំងនេះ មានក្រុមជាក់លាក់ខ្លះជួបប្រទះអត្រាកំណើនដ៏អស្ចារ្យ ៕

ឧបសម្ព័ន្ធ A៖ សុចនករនៃធាតុផ្សំប្រែប្រួលរបស់ចំនួនប្រជាជនជាយុវជន កំណត់ដោយប្រទេស ក្រុម-អាយុ តំបន់ និងភេទ នៅតាមប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន កូរ៉េខាងត្បូង និងថៃឡង់ ពីគ.ស. ១៩៧០-៩០

| ប្រទេស ក្រុមអាយុ និងតំបន់ | បុរស | | | នារី | | |
|---|---|---|---|---|---|---|
| | ១៩៧០a | ១៩៨០ | ១៩៩០ | ១៩៧១ | ១៩៨០ | ១៩៩០ |
| | ភាគរយដែលបានចុះឈ្មោះ | | | | | |
| **ឥណ្ឌូនេស៊ី (អាយុពី ១៥-១៩ឆ្នាំ)** | | | | | | |
| តំបន់ទីក្រុងធំៗ | ៣៩,៧ | ៥៧,១ | ៦២,០ | ២៥,៣ | ៣៦,០ | ៤៨,៥ |
| តំបន់ទីក្រុងឯទៃទៀត | ៥៣,១ | ៦២,៧ | ៦៣,០ | ៣៦,៩ | ៤៥,៩ | ៥៤,០ |
| តំបន់ជនបទ | ២៤,១ | ៣៣,៦ | ៣៤,៥ | ១២,៤ | ២០,៤ | ២៨,១ |
| **អាយុពី ២០-២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ១៧,៩ | ១៤,៦ | ១៧,០ | ៧,២ | ៧,០ | ១១,០ |
| តំបន់ទីក្រុងឯទៃទៀត | ២៤,២ | ២២,០ | ២៣,២ | ១០,៨ | ៩,៦ | ១៥,៥ |
| តំបន់ជនបទ | ៥,៧ | ៥,៥ | ៥,៧ | ១,២ | ២,៣ | ២,៨ |
| **ហ្វីលីពីនអាយុពី ១៥-១៩ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៦៧,៨ | n.a | n.a | ៥៧,៤ | n.a | n.a |
| តំបន់ទីក្រុងឯទៃទៀត | ៥៤,៩ | n.a | n.a | ៤៨,៦ | n.a | n.a |
| តំបន់ជនបទ | ៣២,៤ | n.a | n.a | ៣២,៦ | n.a | n.a |
| **អាយុពី ២០-២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៣៣,៥ | n.a | n.a | ២៧,២ | n.a | n.a |
| តំបន់ទីក្រុងឯទៃទៀត | ២២,៩ | n.a | n.a | ១៩,២ | n.a | n.a |
| តំបន់ជនបទ | ៩,៨ | n.a | n.a | ៩,២ | n.a | n.a |

| ប្រទេស ក្រុមអាយុ និងតំបន់ | បុរស | | | នារី | | |
|---|---|---|---|---|---|---|
| | ១៩៧០a | ១៩៨០ | ១៩៩០ | ១៩៧១ | ១៩៨០ | ១៩៩០ |
| | ភាគរយដែលបានចុះឈ្មោះ | | | | | |
| **កូរ៉េខាងត្បូង (អាយុពី ១៥–១៩ឆ្នាំ)** | | | | | | |
| តំបន់ទីក្រុងធំៗ | ៤៦,១ | n.a | ៧៦,០ | ៣៤,០ | n.a | ៨៤,៦ |
| តំបន់ទីក្រុងឯទៃទៀត | ៤៩,៥ | ១០,២ | ៧៧,០ | ៣៥,៦ | ៨៦,២ | ៧១,៦ |
| តំបន់ជនបទ | ៣១,៣ | ៦១,៤ | ៧១,៤ | ១៧,៥ | ៥៥,២ | ៧៣,៩ |
| **អាយុពី ២០–២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ១៨,០ | n.a | ២៦,៨ | ៧,០ | n.a | ៦៧,០ |
| តំបន់ទីក្រុងឯទៃទៀត | ១១,៨ | ២,៩ | ២៥,១ | ៣,៤ | ១២,៦ | ៩,២ |
| តំបន់ជនបទ | ៣,១ | ៤,៧ | ៩,២ | ០,៤ | ១,៨ | ៦,៤ |
| **ថៃឡង់ (អាយុពី ១៥–១៩ឆ្នាំ)** | | | | | | |
| តំបន់ទីក្រុងធំៗ | ៤៧,៣ | ៥៨,៧ | ៥៥,២ | ៣៦,៨ | ៥១,១ | ៤៩,០ |
| តំបន់ទីក្រុងឯទៃទៀត | n.a | ៥៤,១ | ៥៦,០ | n.a | ៤៩,៨ | ៥២,៧ |
| តំបន់ជនបទ | n.a | ៣,៦ | ២១,៦ | n.a | ១៨,៦ | ២០,២ |
| **អាយុពី ២០–២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ១៦,២ | ២៤,៧ | ២២,០ | ១២,៧ | ២០,៧ | ២០,៦ |
| តំបន់ទីក្រុងឯទៃទៀត | n.a | ១៦,១ | ១៩,៧ | n.a | ១៤,០ | ១៨,៨ |
| តំបន់ជនបទ | n.a | ០,៩ | ៤,០ | n.a | ៣,៩ | ៤,០ |

| ប្រទេស ក្រុមអាយុ និងតំបន់ | បុរស | | | នារី | | |
|---|---|---|---|---|---|---|
| | ១៩៧០a | ១៩៨០ | ១៩៩០ | ១៩៧១ | ១៩៨០ | ១៩៩០ |
| | ភាគរយដែលនៅលីវ | | | | | |
| **ឥណ្ឌូនេស៊ី (អាយុពី ១៥-១៩ឆ្នាំ)** | | | | | | |
| តំបន់ទីក្រុងធំៗ | ៩៦,១ | ៩៧,១ | ៩៨,៧ | ៦៨,៥ | ៧៨,៩ | ៩១,៦ |
| តំបន់ទីក្រុងឯទៃទៀត | ៩៧,៥ | ៩៧,៨ | ៩៨,៥ | ៧៩,០ | ៨២,៨ | ៩០,៨ |
| តំបន់ជនបទ | ៩៤,៣ | ៩៥,៨ | ៩៧,០ | ៥៨,៩ | ៦៥,៦ | ៧៦,៥ |
| **អាយុពី ២០-២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៧០,៧ | ៩១,៥ | ៨៣,៨ | ២៦,១ | ៣៥,៧ | ៥៥,៧ |
| តំបន់ទីក្រុងឯទៃទៀត | ៧៥,៧ | ៧៥,០ | ៨២,៣ | ៣៦,៣ | ៣៧,០ | ៥២,៩ |
| តំបន់ជនបទ | ៥៣,៥ | ៥៣,៥ | ៦៤,៧ | ១៤,៥ | ១៧,២ | ២៥,៣ |
| **ហ្វីលីពីនអាយុពី ១៥-១៩ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៩៧,៦ | ៩៦,៥ | ៩៦,៦ | ៩៣,៣ | ៩០,០ | ៩១,៨ |
| តំបន់ទីក្រុងឯទៃទៀត | ៩៧,៩ | ៩៧,២ | n.a | ៩២,៥ | ៩០,០ | n.a |
| តំបន់ជនបទ | ៩៧,៣ | ៩៥,៨ | n.a | ៨៧,០ | ៨២,៨ | n.a |
| **អាយុពី ២០-២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៧៧,៦ | ៦៨,៥ | ៧៦,៥ | ៦៨,១ | ៥៨,១ | ៦៥,៩ |
| តំបន់ទីក្រុងឯទៃទៀត | ៧៤,១ | ៦៨,៤ | n.a | ៦០,៧ | ៥៣,១ | n.a |
| តំបន់ជនបទ | ៦៦,១ | ៥៩,៨ | n.a | ៤២,៨ | ៣៧,៩ | n.a |

| ប្រទេស ក្រុមអាយុ និងតំបន់ | បុរស | | | នារី | | |
|---|---|---|---|---|---|---|
| | ១៩៧០[a] | ១៩៨០ | ១៩៩០ | ១៩៧១ | ១៩៨០ | ១៩៩០ |
| | ភាគរយដែលនៅលីវ | | | | | |
| **កូរ៉េខាងត្បូង (អាយុពី ១៥–១៩ឆ្នាំ)** | | | | | | |
| តំបន់ទីក្រុងធំៗ | ១០០,០ | ៩៩,៨ | ៩៩,៩ | ៩៨,០ | ៩៨,៩ | ៩៩,៦ |
| តំបន់ទីក្រុងឯទៀត | ៩៤,០ | ៩៩,៨ | ៩៩,៩ | ៩៨,០ | ៩៨,៤ | ៩៩,៤ |
| តំបន់ជនបទ | ៩៩,៦ | ៩៩,៧ | ៩៩,៩ | ៩៦,១ | ៩៧,៦ | ៩៩,៤ |
| **អាយុពី ២០–២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៩៣,៧ | ៩៤,៣ | ៩៧,០ | ៦៥,៣ | ៧៣,៣ | ៨៤,៨ |
| តំបន់ទីក្រុងឯទៀត | ៩៣,៤ | ៩២,៥ | ៩៥,៧ | ៦០,១ | ៦៥,៣ | ៧៨,៨ |
| តំបន់ជនបទ | ៩១,៧ | ៩២,៨ | ៩៧,២ | ៥០,៨ | ៦០,៤ | ៧៨,៧ |
| **ថៃឡង់ (អាយុពី ១៥–១៩ឆ្នាំ)** | | | | | | |
| តំបន់ទីក្រុងធំៗ | ៩៧,១ | ៩៥,២ | ៩៥,៨ | ៩០,៣ | ៨៩,៨ | ៩២,៥ |
| តំបន់ទីក្រុងឯទៀត | ៩៣,៧ | ៩២,៩ | ៩៣,៣ | ៨៧,៧ | ៨៧,៥ | ៩០,៨ |
| តំបន់ជនបទ | ៩២,៧ | ៩២,៦ | ៩៣,៨ | ៧៩,៣ | ៨១,០ | ៨២,៩ |
| **អាយុពី ២០–២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៨១,៩ | ៨០,០ | ៨២,៥ | ៦៣,៣ | ៦៥,៨ | ៧២,២ |
| តំបន់ទីក្រុងឯទៀត | ៧៥,០ | ៧៣,២ | ៧៦,៦ | ៥៤,៨ | ៥៥,៧ | ៦២,៩ |
| តំបន់ជនបទ | ៥៧,៩ | ៥៩,៧ | ៦៥,៣ | ៣៣,៦ | ៣៧,៧ | ៤១,៦ |

| ប្រទេស ក្រុមអាយុ និងតំបន់ | ប្រុស | | | នារី | | |
|---|---|---|---|---|---|---|
| | ១៩៧០a | ១៩៨០ | ១៩៩០ | ១៩៧១ | ១៩៨០ | ១៩៩០ |
| | ភាគរយដែលនៅក្នុងកម្លាំងពលកម្ម | | | | | |
| **ឥណ្ឌូនេស៊ី (អាយុពី ១៥-១៩ឆ្នាំ)** | | | | | | |
| តំបន់ទីក្រុងធំៗ | ៤០,០ | ៥៤,៥ | ២៨,៨ | ២០,៩ | ២៦,៩ | ៣៥,១ |
| តំបន់ទីក្រុងឯទៀត | ៣១,២ | ២០,៩ | ២៨,៦ | ១៨,៨ | ២១,១ | ២៦,០ |
| តំបន់ជនបទ | ៥៨,២ | ៥៤,៨ | ៥៧,៥ | ៣៣,៨ | ៣៤,៤ | ៣៧,២ |
| **អាយុពី ២០-២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៧៣,៤ | ៧០,៨ | ៧៣,៥ | ២១,៩ | ២៨,៤ | ៤៦,៦ |
| តំបន់ទីក្រុងឯទៀត | ៦៥,០ | ៦៦,៦ | ៦៧,៧ | ២៥,០ | ២៦,៦ | ៣៩,៩ |
| តំបន់ជនបទ | ៨៣,០ | ៨៤,២ | ៨៧,៣ | ៣៥,៨ | ៣៥,៤ | ៤៤,៩ |
| **ហ្វីលីពីនអាយុពី ១៥-១៩ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ២៤,៣ | n.a | ៤១,៩ | ៩៣,៣ | n.a | ៤៦,០ |
| តំបន់ទីក្រុងឯទៀត | ៣១,៣ | n.a | ៣២,៤ | ៣០,៩ | n.a | ២៦,៥ |
| តំបន់ជនបទ | ៥៣,២ | n.a | ៤៨,៩ | ២៨,៣ | n.a | ៣១,០ |
| **អាយុពី ២០-២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៦៣,៧ | n.a | ៧១,៤ | ៦៨,១ | n.a | ៦១,៤ |
| តំបន់ទីក្រុងឯទៀត | ៦៨,០ | n.a | ៦៤,៤ | ៤១,៣ | n.a | ៤១,១ |
| តំបន់ជនបទ | ៨៤,៥ | n.a | ៧៤,១ | ៤៥,៥ | n.a | ៣៦,៥ |

| ប្រទេស ក្រុមអាយុ និងតំបន់ | បុរស | | | នារី | | |
|---|---|---|---|---|---|---|
| | ១៩៧០a | ១៩៨០ | ១៩៩០ | ១៩៧១ | ១៩៨០ | ១៩៩០ |
| | ភាគរយដែលនៅក្នុងកម្លាំងពលកម្ម | | | | | |
| **កូរ៉េខាងត្បូង (អាយុពី ១៥–១៩ឆ្នាំ)** | | | | | | |
| តំបន់ទីក្រុងធំៗ | ៣១,០ | ៤,៤ | ៦,៧ | ៣៩,៥ | ៣៤,៨ | ១៤,៤ |
| តំបន់ទីក្រុងឯទៀត | ៣១,៨ | ២៣,៦ | ៧,៥ | ៣៤,៦ | ៣៧,៥ | ១៦,៩ |
| តំបន់ជនបទ | ៥៤,២ | ២៨,៩ | ៦,៦ | ៤១,១ | ២៩,៨ | ១០,៨ |
| **អាយុពី ២០–២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៤១,២ | ៤៧,១ | ២៩,១ | ៣៨,០ | ៥៣,៦ | ៥០,៧ |
| តំបន់ទីក្រុងឯទៀត | ៤៣,១ | ៥០,៨ | ២៩,៩ | ៣៦,៤ | ៤៩,៦ | ៤៩,៦ |
| តំបន់ជនបទ | ៥១,៥ | ៥៣,០ | ២២,៤ | ៤៩,២ | ៥៦,៧ | ៤០,៥ |
| **ថៃឡង់ (អាយុពី ១៥–១៩ឆ្នាំ)** | | | | | | |
| តំបន់ទីក្រុងធំៗ | ៤៣,២ | ៣៦,៩ | ៣៨,៩ | ៤០,១ | ៣៨,០ | ៤៣,៤ |
| តំបន់ទីក្រុងឯទៀត | ៤២,៤ | ៣៦,២ | ៣៤,៩ | ៣៦,៣ | ៣៤,៧ | ៣៨,៧ |
| តំបន់ជនបទ | ៨៣,៧ | ៧០,៦ | ៧២,៤ | ៨៤,៥ | ៦៨,៤ | ៦៧,៦ |
| **អាយុពី ២០–២៤ឆ្នាំ** | | | | | | |
| តំបន់ទីក្រុងធំៗ | ៧៥,២ | ៦៩,៩ | ៧១,៩ | ៥២,២ | ៥៧,៧ | ៦៤,៦ |
| តំបន់ទីក្រុងឯទៀត | ៧៥,៩ | ៧២,៥ | ៧៦,៤ | ៥០,៣ | ៥៨,២ | ៦៤,៥ |
| តំបន់ជនបទ | ៩៥,៧ | ៨៧,៥ | ៩០,១ | ៨៤,៦ | ៧៤,៣ | ៧៧,៨ |

ចំណាំ៖ n.a. មានន័យថាមិនមានទិន្នន័យ។ a ចំពោះប្រទេសឥណ្ឌូនេស៊ី កាលបរិច្ឆេតគឺគ.ស. ១៩៧១។

យោង៖ ដកស្រង់ចេញពីរបាយការណ៍ជំរឿនជាតិ ដែលមានពេលខ្លះត្រូវការធ្វើការគណនាបន្ថែម។

# កំណត់សម្គាល់

## ជំពូកទី ២

១- នាឆ្នាំ ១៩៦០ បន្ទាប់ពីមានការភៀសខ្លួនជាច្រើនមកកាន់ទីក្រុងក្នុងកំឡុងពេលមានចលាចលនាទសវត្សរ៍ឆ្នាំ ១៩៤០ ប្រជាជនរស់នៅតាមទីក្រុងនៅអាស៊ីអគ្នេយ៍នៅមានចំនួន ១៧,៦ % នៅឡើយបើប្រៀបទៅនឹង ប្រជាជនដែលរស់នៅក្នុងទីក្រុងចំនួន ២១,៥ % នៅតំបន់អាស៊ីទាំងមូល និង ៦០ % នៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ (ស្ថិតិរបស់មជ្ឈមណ្ឌលអង្គការសហប្រជាជាតិស្តីអំពីការតាំងទីលំនៅ បោះពុម្ពឆ្នាំ ១៩៨៧ ទំព័រ ៥៣)។

២- បើយោងតាមសៀវភៅរបស់គាត់បោះពុម្ពឆ្នាំ ១៦១៧ ទំព័រ ២៩៣ Jourdain ទទួលបាននូវផ្ទះមួយប្លុក នៅតំបន់ឆ្នេរសមុទ្រ «ប្រវែង ៤០ ព្យាម បួនជ្រុង» ដោយមានផ្ទះចំនួន ២០ ខ្នងនៅទីនោះ នៅទីក្រុងម៉ាកាសសារដែលផ្ទះនីមួយៗមានទំហំដី ២៦៧ ម៉ែត្រការ៉េ ឬក៏ ៣.៧៥០ ផ្ទះក្នុងមួយគីឡូម៉ែត្រការ៉េ ។ ផ្ទុយមកវិញការធ្វើជំរឿននាសម័យទំនើប (ទាក់ទងទៅនឹងបំណែងចែករដ្ឋបាល មិនទាក់ទងទៅនឹងតំបន់សម្បូរសំណង់អគារនោះទេ) បានបង្ហាញអំពីដង់ស៊ីតេប្រជាជនរស់នៅក្នុងទីក្រុងពី ៥.០០០ ទៅ ១០.០០០ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ។ យោងទៅលើជំរឿនរបស់ពួកហូឡង់នៅឥណ្ឌានាឆ្នាំ ១៩៣០ បានបង្ហាញអោយឃើញថា ទីក្រុង «ឥណ្ឌូនេស៊ី» ភាគច្រើនដូចជាទីក្រុង Yogyakartaនិង Surakarta ជាដើម  មានដង់ស៊ីតេផ្ទះប្រហែល ៦.៣០០ ខ្នង ក្នុងមួយគីឡូម៉ែត្រការ៉េ ។

៣- ប្រទេសភូមានាសតវត្សរ៍ទី ១៧ មានទីប្រជុំជនដែលមានកម្រិតខ្ពស់ជាងថ្នាក់ភូមិចំនួន ៤ ប្រភេទ ។ ក្នុងចំណោមនោះ  ទីប្រជុំជនដែលតូចជាងគេប្រហែលជាបានបញ្ជូនមនុស្សប្រុសពី ១០០ ទៅ ១០០០ នាក់ទៅធ្វើសង្គ្រាម និងបានត្រួតត្រានូវតំបន់ដែលមានរង្វាស់អង្កត់ផ្ចិត ១០ គីឡូម៉ែត្រ ។ ទីក្រុងដែលមានបង្ហាញនៅទីនេះទាំងប៉ុន្មានចាត់ចូលទៅក្នុងប្រភេទទីក្រុងធំៗដែលជាទីក្រុងរបស់ទីរួមខេត្តទាំងឡាយ  ហើយគេអាចប៉ាន់ស្មានបានថា ទីក្រុងនីមួយៗមានផ្ទៃដីដែលមានប្រវែងអង្កត់ផ្ចិត ១០០ taing(c ៣២០ គីឡូម៉ែត្រ) (Than Tun ១៩៨៣ : ៧២-៧៣) ។

៤- ពាក្យនេះប្រហែលជាទាក់ទងទៅនឹងពាក្យGaeq.keu'eh ដែលនៅបន្តទទួលស្គាល់ក្នុងស្រុក (Kreemer ១៩២២ II: ៥៣-៥៤)។

៥- នៅក្នុងសៀវភៅបោះពុម្ពឆ្នាំ ១៩៨៦ ទំព័រ ៤០-៤២  ពលុសសបែានលើកឡើងថាបញ្ហាគឺអាស្រ័យទៅតាមរដូវទាំងស្រុង ដែលរួមមានភាពកង្វះខាតម្តងហើយម្តងទៀតមុនពេលដែលសំពៅចិនធ្វើដំណើរមកដល់ដោយមានដឹកកាក់ស្ព័ន  ប៉ុន្តែមានភស្តុតាងច្បាស់លាស់ថាយ៉ាងហោចណាស់ក៏ការសរសេរនេះមានរយៈពេលយូរអង្វែងដែរ ។

៦- Le May (សេចក្តីសម្រង់ឆ្នាំ ១៩៣២)បានស្ទង់មើលថាព្រះរាជា រាមាធិបតី (១៤៩១-១៥២៩)ប្រហែលជាបានបង្កើតប្រព័ន្ធលុយកាក់ស្តង់ដាបែបនេះឡើង ។ Le Mayបានរាប់ឃើញថាមានសញ្ញាសម្គាល់ ១៥ ប្រភេទផ្សេងៗគ្នាចំពោះដុំកាក់ដែលនៅសេសសល់នៅក្នុងទំងន់ជា តិកាលស្តង់ដា ហើយសន្និដ្ឋានថាកាក់ទាំងអស់នោះបោះដោយមេដឹកនាំនៅអយុធ្យានាសម័យក្រោយៗចំនួន ១៥ រូប ។ ទោះជាយ៉ាងនេះក្តី  គេមិនឃើញមានភស្តុតាងណាបង្ហាញថាសញ្ញាសម្គាល់នេះតំណាងអោយរដ្ឋកាលខុសៗគ្នាជាជាងតំណាងអោយឈ្មួញកណ្តាលផ្លូវការ ឬជាងប្រាក់ដែលជាអ្នកធានាអោយមានទំងន់ផ្លូវការរបស់កាក់ទាំងនោះទេ ។

៧- «ភាពបាត់បង់» លុយកាក់ជាក់ស្តែងស្រដៀងគ្នានេះដែរ  ក៏មានឃើញនៅក្នុងប្រទេសឥណ្ឌូនេស៊ីនាសតវត្សរ៍ទី ១៩ ក្នុងកំឡុងពេលដែលតម្លៃជំណាំពាណិជ្ជកម្មកើនឡើងខ្ពស់ហួសកម្រិត  ឧទាហរណ៍ដូចជាម្រេចនៅទីក្រុងអាចេ

*ភាគខាងលិច និង ស្ករ នៅភាគខាងកើតបង្អស់ប្រទេសជ្វាជាដើម ។* Elson*(បោះពុម្ពឆ្នាំ ១៩៨៤ ទំព័រ ១៦៦) បាន លើកឡើងអំពីភូមិមួយនៅ* Pasuruan *នាជំណាក់កាលរីកចម្រើននាទសវត្សរ៍ឆ្នាំ ១៨៥០ នៅពេលដែលគេរកឃើញ* guilder *ជាកាក់ស្ពាន់ចំនួន ៤.០០០ កាក់ នៅក្នុងផ្ទះជនជាតិជ្វាចំនួន ៤៣ ខ្នងដែលត្រូវបានដុត ចំណែកឯសាច់ផ្ទះ និង គ្រឿងសង្ហារិមផ្សេងៗ គេប៉ាន់ប្រមាណឃើញថាមានតម្លៃតែចំនួន ១.០៤៧* guilder *ប៉ុណ្ណោះ ។*

**៨**- *សំខាន់ជាងនេះទៅទៀត លាហា គឺមិនមែនជាពាក្យអារ៉ាប់ទេ តែជាពាក្យអូស្ត្រូនេស៊ី ទោះបីជាគេបកប្រែថា ការ ប្រាក់ នៅក្នុងវចនានុក្រម* Buenaventura Tagalog *នាសតវត្សរ៍ទី ១៦ ក៏ដោយ ។*

**៩**- *ខ្ញុំមានចំណាត់អារម្មណ៍ចំពោះវគ្គនេះដោយសារតែ* Denys Lombard*(១៩៨៨ : ១៨) ។*

**១០**- *ខ្ញុំសន្មត់នៅទីនេះដូចទៅនឹង* Thomaz *ដែរដែលថា* Naina Suradewana *របស់* Sejarah Melayu *ដូចទៅនឹង* Nina Curya Deva *របស់ពួកព័ទុយហ្គាល់ដែរ ។*

**១១**- Pires *បានប្រៀបធៀបឥរិយាបថប្រញាប់ប្រញាល់ធ្វើដំណើរទៅស្រុកកំណើតវិញរបស់ជនរួមជាតិរបស់គាត់ ជាមួយនឹងឥរិយាបថដូចគ្នានេះដែររបស់ពួកអាស៊ីអគ្នេយ៍ថា ÷ «ពួកយើងធ្វើជំនួញដូចពួកព័ទុយហ្គាល់ដែលមិន ស៊ាំទៅនឹងការធ្វើជំនួញដែរ... ហេតុដូច្នេះហើយ ពួកយើងប្រញាប់ប្រញាល់ធ្វើដំណើរត្រឡប់ទៅកាន់ស្រុកកំណើត វិញ» (១៥១៥: ២២០) ។*

## ជំពូកទី ៣

**១**- *តាមពិតទៅ មានការពិភាក្សាគ្នាយ៉ាងស្រស្រាក់ស្រស្រាំទៅលើតួនាទីរបស់កម្លាំងកត្តាក្នុងស្រុក និងកម្លាំងកត្តា ពីក្រៅមិនដាក់លាក់ ក្នុងការកំណត់អត្តសញ្ញាណផ្សេងៗគ្នានៃសង្គមអាស៊ីអាគ្នេយ៍ ។ ការបកស្រាយមួយក្នុងចំនោម ការបកស្រាយដំបូងបង្អស់ គឺរបស់* Ebnda Benda *(គ.ស. ១៩៦២) ។ ឯកសាររបស់ រីឌ* Reid *(គ.ស. ១៩៨៨) និង ឡំបាឌ* Lombard *(គ.ស. ១៩៩០) បានបង្កើតយ៉ាងច្បាស់អំពីរីសគល់របស់វប្បធម៌អាស៊ីអាគ្នេយ៍ និងសមត្ថភាពសម្រាប់ស្រូប យកឥទ្ធិពលខាងក្រៅរបស់សាសនាហិណ្ឌូ* Hinduism *អ៊ីស្លាម និង ស៊ីនីស៊ីស* Sincization *ដែលជះឥទ្ធិពលមក លើតំបន់នេះ ។ សំរាប់ការពិភាក្សាអំពីគោលគំនិតដើមនៃតំបន់អាស៊ីអាគ្នេយ៍អោយទូលំទូលាយជាងនេះ សូមអាន ឯកសាររបស់ អែមឺសាន់* Emerson*(គ.ស. ១៩៨៤) និង ឌឺ កូនីកខ៍* De Koninck.. *(គ.ស. ១៩៩៤) ។*

**២**- *សំរាប់ការបកស្រាយអំពីការប្រែប្រួលទាំងនេះសូមអានឯកសាររបស់ ឌីកែន* Dicken *(គ.ស. ១៩៩៨) ។*

**៣**- *មានឯកសារជាច្រើនបកស្រាយអំពីដើមកំណើតនិងការវិវឌ្ឍន៍របស់មជ្ឈមណ្ឌលតំបន់ទីក្រុងនៅអាស៊ីអាគ្នេយ៍ ។ សំរាប់ការបកស្រាយដ៏ល្អមួយក្នុងកំលុងឆ្នាំរហូតដល់ ១៤០០ នោះ សូមអានឯកសាររបស់ វីតលី* Wheatley *(គ.ស. ១៩៦២) ។ ការសិក្សាបុរាណនៃមជ្ឈមណ្ឌលមុនសម័យអណានិគម ត្រូវបានបង្ហាញដោយវូលទែរស៍* Wolters *(គ.ស. ១៩៦៧) ដែលធ្វើការសិក្សាទៅលើ ស្រីវ៉ាច្យាយ៉ា* Srivajaya *ដោយ រ៉ាបីបាដាណា* Rabibhadan *(គ.ស. ១៩៦០) ដែលធ្វើការសិក្សាទៅលើទីក្រុងបាងកកសម័យដើម និងដោយ កូដេស៍* Coedes *(គ.ស. ១៩៦៣) ដែលធ្វើការសិក្សា ទៅលើ អង្គរ ។ ការសិក្សាល្អិតល្អន់អំពីនគរូបនីយកម្មសម័យអណានិគម គឺមាននៅក្នុងឯកសាររបស់ រីឌ(គ.ស. ១៩៨០) តែក៏សូមអានឯកសាររបស់ម៉ាកហ្គី (គ.ស. ១៩៦៧) ដែរ ។ មានឯកសារសិក្សាអំពីតំបន់ទីក្រុងមួយៗនៅសម័យ អាណានិគមច្រើន ដែលក្នុងចំណោមនោះមាន ឯកសាររបស់ អាបីច្យាសេកែរ (គ.ស. ១៩៨៧) នៅច្យាកាតា ឯកសារ របស់ រ៉េដ (គ.ស. ១៩៧៨) នៅទីក្រុងមានីល និងរបស់ ស្គីណែរ (គ.ស. ១៩៥៧) នៅបាងកក ។*

*៤- សំរាប់ឯកសារស្តីអំពីការលើកស្ទួយវិស័យទេសចរណ៍សូមអានឯកសាររបស់ ឆាងChang (គ.ស. ១៩៩៨) ស្តីអំពីសិង្ហបូរី ។*

*៥- ហ្វ័បស៍* Forbes *ខិតខំកែតម្រូវពាក្យថា្យ«ទស្សនៈវិស័យថ្នាក់ខ្ពស់* Macro Vision» *ដោយប្រើពាក្យរបស់គាត់ ការបកស្រាយនៅសម័យមុនអាណានិគមរបស់តំបន់ទីក្រុងធំៗតាមរយៈការបង្ហាញនៅក្នុងខ្សែភាពយន្ត ។ ដោយធ្វើការវិភាគទៅលើខ្សែភាពយន្តចំនួនពីររបស់វៀតណាម (មានចំនងជើងថា ក្លិនក្រអូបរបស់ល្ហុងពណ៌បៃតង និង ស៊ីក្លូ)ដែលដឹកនាំរឿងដោយ ត្រាន់ អាញ់ ហ៊ូងTran Anh Hung ហ្វ័បស៍ បង្ហាញពីវិធីសាស្ត្រដែលអ្នកនិពន្ធអាចយកសកម្មភាពប្រចាំថ្ងៃនៃតួអង្គក្នុងរឿងដាក់ក្នុងក្របខណ្ឌដូចដំណើរការវប្បធម៌ នយោបាយ និងសេដ្ឋកិច្ចសកលលោក ដែលមានឥទ្ធពលមកលើក្រុងហូជីមិញ ។*

*៦- ឧទាហរណ៍នៃការស្រាវជ្រាវដែលផ្តោលទៅលើ«សកម្មភាពប្រចាំថ្ងៃ» របស់អ្នករស់នៅទីក្រុង នៅអាស៊ីអាគ្នេយ៍ មានដូចជា ការស្រាវជ្រាវរបស់ ដែលីណែកខ៍*Jellineck *(គ.ស. ១៩៩១) ហ្គីនណេស អ៊ិនសេស(គ.ស. ១៩៩២) និង ម៉ិយរ៉េ* Murray*(គ.ស. ១៩៩១។*

*៧- ព្រឹត្តិបត្តិស្តីអំពីសេដ្ឋកិច្ចនៅចុងបូព៌ា បោះពុម្ពនៅ ថ្ងៃទី ១៦ ខែមេសា គ.ស. ១៩៩៨ ។*

*៨- សារពត៌មាន* Traits Times*(នៅសិង្ហបូរី) បោះពុម្ពនៅថ្ងៃទី១៧ ខែឧសភា គ.ស. ១៩៩៨ ទំព័រ ៣៣ ។*

*៩- សូមអានឯកសាររបស់ លី* Lee *(គ.ស. ១៩៩៧) ទំព័រ ១៤០-៦០ សំរាប់បទសង្ខេបដ៏មានប្រយោជន៍មួយ ។*

## ឯកសារយោង


• *អាបីយ៉ាសេគែរ សេ.* (Abeyasekare, S.). *Jakarta: A History* [**យ៉ាការតា ប្រវត្តិសាស្ត្រ**] *បោះពុម្ពនៅសិង្ហបូរី ដោយរោងពុម្ព សាកលវិទ្យាល័យអុកស្វ័ដ* (Oxford University Press) *គ.ស. ១៩៨៧ ។*

• *អាស្គូវ អឹម និងដាបាយូ អែស ឡូហ្គែន* (Askew, M. and W. S. Logan) *អ្នកកែសម្រួល* *Cultural Identity and Urban Change in Southaest Asia:Interpretative Essays* [**អត្តសញ្ញាណវប្បធម៌និងបម្រែបម្រួលទីក្រុងនៅអាស៊ីអាគ្នេយ៍៖ តែងសេចក្តីវិភាគបែកញែក**] *បោះពុម្ពនៅ ហ្គីឡុង* (Geelong) *ដោយរោងពុម្ពសាកលវិទ្យាល័យឌីឃីន (ឌាកិន) គ.ស. ១៩៩៤។*

• *បង់ដា ហាស់* (Benda H.)"The Structure of Southeast Asia History" [**«រចនាសម្ព័ន្ធរបស់ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍**] *បោះពុម្ពនៅក្នុងព្រឹត្តិបត្តិ ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍* (*Journal of Southeast Asia History*) *លេខ៣ (គ.ស. ១៩៦២) ទំព័រ ១០៤-៣៨។*

• *ប្រ៊ូកខ៍ ស្យង់ អូ អឹម* (Broeck, Jan O. M.) "Diversity and Unity in Southeast Asia" [**«ភាពផ្សេងៗគ្នានិងសាមគ្គីភាពនៅអាស៊ីអាគ្នេយ៍**] *បោះពុម្ពនៅក្នុងព្រឹត្តិបត្តិ ភូមិសាស្ត្រGeographical Review. លេខ៣៤ (គ.ស. ១៩៤៤) ទំព័រ ១៧៥-៩៤ ។*

• *កាស្តែលស៍ អឹម* (Castells, M.) *The Informational City* [**ទីក្រុងពត៌មាន**] *បោះពុម្ពនៅអុកស្វ័ដ ដោយរោងពុម្ពប្លែកវែល* (Blackwell) *គ.ស. ១៩៨៩។*

• *កាស្តែលស៍ អឹម* (Castells, M.). *The Rise of the Network Society* [**ការរីកដុះលូតលាស់នៃសង្គមពោរពេញទៅដោយបណ្តាញ**] *បោះពុម្ពនៅអុកស្វ័ដ ដោយរោងពុម្ព ប្លែកវែល* (Blackwell) *គ.ស. ១៩៩៦។*

• *កាស្តែលស៍ អឹម* (Castells, M.). *The Power of Identity* [**ថាមពលនៃអត្តសញ្ញាណ**] *បោះពុម្ពនៅអុកស្វ័ដ ដោយរោងពុម្ព ប្លែកវែល* (Blackwell) *គ.ស. ១៩៩៧ ។*

• *ឆាង ទេ សេ* (Chang, T. C.)."Regionalism and Tourism: Exploring Integral Links in Singapore" [**«តំបន់និយម និងទេសចរណ៍៖ ស្វែងយល់អំពីបណ្តាញខាងក្នុងនៅសិង្ហបូរី**] *បោះពុម្ពនៅក្នុង ព្រឹត្តបត្តិ ទស្សនៈអាស៊ីប៉ាស៊ីភិច (Asia Pacific Viewpoint) លេខ៣៩ (១) (គ.ស. ១៩៩៨) ទំព័រ ៧៣–៩៤។*

• *កូដេស៍ ចចស៍* (Coedes, Georges). *Angkor: An Introduction* [**អង្គរ ៖ សេចក្តីផ្តើម**] *បោះពុម្ពនៅហុងកុង ដោយរោងពុម្ពសាកលវិទ្យាល័យអុកស្វ័ដ គ.ស. ១៩៦៣។*

• *ឌឺ កូនិកខ៍ អែ* (De Konick R.) *Singapore: An Atlas of the Revulotion of Territory* [**សិង្ហបូរី៖ ផែនទីនៃបដិវត្តន៍ផ្នែកដីសណ្ឋាន**] *បោះពុម្ពនៅម៉ុងពែលីយេ* (Montpellier) *ដោយរោងពុម្ព រឹកលូស* (Reclus) *គ.ស. ១៩៩២ ។*

• *ឌឺ កូនិកខ៍ អែ* (De Konick R.).*L'Asie du Sud-Est* *បោះពុម្ពនៅបារីស ដោយរោងពុម្ព ម៉ាសប៊ូរ៉ូ គ.ស. ១៩៩៤។*

• *ឌិកកែន ប៉េ* (Dicken P.) *Global Shift: Transforming the World Economy* [**បម្រែបម្រួលសកលលោក៖ ការប្រែប្រួលទិសដៅសេដ្ឋកិច្ចលើពិភពលោក**] *បោះពុម្ពនៅទីក្រុងឡុងដ៍* (London) *ដោយរោងពុម្ព ចាបម៉ង់* (Chapman) *គ.ស. ១៩៩៨ ។*

• *ឌូក្លាស អឹម* (Douglass M.) "The Environmental Sustainability of Development: Coordination, Incentives, and Political Will in Land Use Planning for the Jakarta Metropolis" [**«ភាពស្ថិតស្ថេរខាងបរិស្ថាននៃការអភិវឌ្ឍន៍៖ ការសម្របសម្រួល ការជំរុញលើកទឹកចិត្ត និងបំណងប្រាថ្នាខាងនយោបាយនៅក្នុងគម្រោងការការប្រើប្រាស់ដីសម្រាប់តំបន់ទីក្រុងធំនៅចាការតា»**] *ព្រឹត្តិបត្តិស្តីពីគម្រោងសំរាប់ប្រទេសក្រីក្រ លេខ ១១ (២) (គ.ស. ១៩៨៩) ទំព័រ ២១១–៣៨។*

• *ឌូក្លាស អឹម* (Douglass M.) "A Regional Network Strategy for Reciprocal Rural-Urban Linkages: An Agenda for Policy Research with Reference to Indonesia" [**«យុទ្ធសាស្ត្របណ្តាញក្នុងតំបន់សំរាប់ទំនាក់ទំនងទៅវិញទៅមករវាងជនបទ-ទីក្រុង៖ របៀបវីរៈមួយសំរាប់ការស្រាវជ្រាវគោលនយោបាយដោយយោងទៅលើប្រទេសឥណ្ឌូនេស៊ី»**] *បោះពុម្ពនៅក្នុងព្រឹត្តបត្តិផែនការសំរាប់ប្រទេសក្រីក្រ (Third World Planning Review) លេខ២០ (១) (គ.ស. ១៩៩៨) ទំព័រ ១–៣៣ ។*

• *ឌូក្លាស ម៉ៃយ៍ និង ចន ហ្វ្រាយម៉ង់* (Douglass Mike and John Friedmann) *អ្នកកែសម្រួល Cities for Citizens: Planning and the Rise of Civil Society in a Global Age* [**ទីក្រុងសំរាប់ប្រជាជន៖ គម្រោងផែនការនិងការរីកលូតលាស់នៃសង្គមស៊ីវិលនៅយុគសម័យភាវូបនីយកម្ម**] *បោះពុម្ពនៅទីក្រុងឡុងដ៍ ដោយរោងពុម្ព ចន វីឡេ* (John Wiley) *គ.ស. ១៩៩៨ ។*

• *អេមឺសាន់ ឌេ ខេ* (Emerson D. K.) "Southeast Asia: What's in a Name?" [**«អាស៊ីអាគ្នេយ៍៖ តើមានអ្វីនៅក្នុងឈ្មោះហ្នឹង? »**] *បោះពុម្ពនៅក្នុងព្រឹត្តបត្តិការសិក្សាអំពីអាស៊ីអាគ្នេយ៍ (Journal of Southeast Asia Studies) លេខ១៥ (១) (គ.ស. ១៩៨៤) ទំព័រ ១–២១។*

• *គណៈកម្មាធិការសង្គម និងសេដ្ឋកិច្ចសំរាប់អាស៊ី និងប៉ាស៊ីភិច* (Economic and Social Commission for Asia and Pacific—ESCAP) *State of Urbanization in Asia and the Pacific* [**សភាពនៃការធ្វើនគរូបនីយកម្មនៅអាស៊ី និងប៉ាស៊ីភិច**]

*បោះពុម្ពនៅបូរីញូយ៉ក ដោយអង្គការសហប្រជាជាតិ គ.ស. ១៩៩២។*

• *ហ្វៃម៉ឺន ទេ* (Fireman T.) "The Emergence of Extended Metropolitan Regions in Indonesia: Jabotabek and Bandung Metropolitan Area" [**«ការលេចចេញឡើងនូវតំបន់ទីក្រុងពង្រីកធំៗនៅឥណ្ឌូនេស៊ី៖ តំបន់ទីក្រុងធំៗ** Jabotabek **និង** Bandung] *បោះពុម្ពនៅក្នុង ព្រឹត្តិបត្តិការសិក្សាអំពីការអភិវឌ្ឍន៍តំបន់និងទីក្រុង (Review of Urban and Regional Development Studies) លេខ៧ (គ.ស. ១៩៩៥) ទំព័រ ១៦៧-៨៨។*

• *ហ្វៃម៉ឺន ទេ* (Fireman T.) "Urban Development in Bandung Metropolitan Region" [**«ការអភិវឌ្ឍន៍ទីក្រុងនៅតំបន់ទីក្រុងធំៗ បានឌុង**Bandug»] *បោះពុម្ពនៅក្នុងព្រឹត្តបត្តិ គផែនការសំរាប់ប្រទេសក្រីក្រ លេខ១៨ (១) (គ.ស. ១៩៩៦) ទំព័រ ១-២១។*

• *ហ្វីស្សឺរ ឆាលស៍ អា* (Fisher, Charles A.) *South-East Asia: A Social, Economic and Political Geography* [**អាស៊ីអាគ្នេយ៍៖ ភូមិសាស្ត្រផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយ**] *បោះពុម្ពនៅទីក្រុងឡុងដ៍ ដោយរោងពុម្ព មេសែន* (Methuen) *គ.ស. ១៩៦៤។*

• *ហ្វ័បស៍ ឌេ* (Forbes, D.) *Asian Metropolis Urbanization and the Southeast Asian City* [**នគរូបនីយកម្មតំបន់ទីក្រុងធំនៅអាស៊ី និងទីក្រុងអាស៊ីអាគ្នេយ៍**] *បោះពុម្ពនៅទីក្រុងមែលប៊ូន* (Melbourne) *ដោយរោងពុម្ពសាកលវិទ្យាល័យអុកស្វ័ដ គ.ស. ១៩៩៦។*

• *ហ្វ័បស៍ ឌេ* (Forbes, D.) "Metropolis and Megaurban Region in Pacific Asia" [**«តំបន់ទីក្រុងធំ និងទីក្រុងសំខាន់នៅអាស៊ីប៉ាស៊ីភិច**] *បោះពុម្ពនៅក្នុង ព្រឹត្តបត្តិ Tijdschrift voor Economische en Social Geographie លេខ៨៨ (៥) (គ.ស. ១៩៩៧) ទំព័រ ៤៥៧-៦៨។*

• *ហ្វ្រាយម៉ឹន ចេ* (Friedmann, J.) "The World City Hypothesis" [**«ការប៉ាន់ស្មានទុកអំពីទីក្រុងពិភពលោក»**] *បោះពុម្ពនៅក្នុងព្រឹត្តបត្តិ ការអភិវឌ្ឍន៍ និងការផ្លាស់ប្តូរ (Development and Change) លេខ១៧ (១) (គ.ស. ១៩៨៦) ទំព័រ ៦៩-៨៤ ។*

• *ហ្វ្រាយម៉ឹន ចេ Empowerment, the Politics of Alternative Development* [**ការបង្កើនអំណាចជានយោបាយនៃការអភិវឌ្ឍន៍មួយបែបទៀត**] *បោះពុម្ពនៅបូរីញូយ៉ក ដោយរោងពុម្ព ប្លែកវែល គ.ស. ១៩៩២។*

• RhVaym¨g´.ecü. "A Look Ahead: Urban Planning in Asia" [**«ការសំឡឹងទៅអនាគត ៖ ផែនការតំបន់ទីក្រុងនៅអាស៊ី»**] *សន្ទរកថាសំខាន់នៅក្នុងសមាគមន៍ផែនការអាស៊ី* (Asia Planning Association)*នៅទីក្រុង បានឌុង ប្រទេសឥណ្ឌូនេស៊ី គ.ស. ១៩៩៧a។*

• *ហ្វ្រាយម៉ឹន ចេ* "World City Futures: The Role of Urban and Regional Policies in the Asia-Pacific Region" [**«អនាគតទីក្រុងពិភពលោក៖ តួនាទីរបស់គោលនយោបាយតំបន់និងទីក្រុងនៅតំបន់អាស៊ីអាគ្នេយ៍»**] Occasional Paper *លេខ៥៦ បោះពុម្ពនៅហុងកុង ដោយវិទ្យាស្ថានហុងកុងសំរាប់ការសិក្សាអំពីអាស៊ីប៉ាស៊ីភិច.*(Hong Kong Institute of Asia-Pacific Studies) *គ.ស. ១៩៩៧ប។*

• *ហ្វ្រាយម៉ឹន ចេ និងស្សេរ្វហ្វ.*(Friedmann J. and G. Wolff) "World City Formation: An Agenda for Research and Action" [**«ការបង្កើតទីក្រុងពិភពលោក៖ របៀបវីរៈសំរាប់ការស្រាវជ្រាវនិងការអនុវត្តន៍»**] *បោះពុម្ពនៅក្នុងព្រឹត្តបត្តិអន្តរជាតិនៃការស្រាវជ្រាវតាមតំបន់និងតាមទីក្រុង (International Journal of Urban and Regional Research)*

លេខ១៦ (៣) (គ.ស. ១៩៨២) ទំព័រ ៣០៩-៤៥។

• ហ្វ្រាយើរ ឌេ ដាបាយូ (Fryer, D. W.) *Emerging South East Asia* [**អាស៊ីអាគ្នេយ៍ដែលកំពុងលេចឡើង**] បោះពុម្ពនៅទីក្រុង ឡុងដ៍ ដោយរោងពុម្ព វីឡេ គ.ស. ១៩៧៩ ។

• ហ្វូចស៍ អែ និង អឺ ពែរនៀ (Fuchs, R. and E. Pernia) “The Influence of Foreign Direct Investment on Spatial Concentration” [**«ឥទ្ធិពលនៃការវិនិយោគផ្ទាល់របស់បរទេសមកលើការគ្រប់គ្រងតំបន់»**] បោះពុម្ពនៅក្នុងសៀវភៅ *Urbanization in Asia: Spatial Dimensions and Policy Issues* [**នគរូបនីយកម្មនៅអាស៊ី៖ ផ្នែកតំបន់និងបញ្ហាគោលនយោបាយ**] កែសម្រួលដោយហ្វេវ ចេ កូស្តា អា កា ឌូត អិល ចេ សេ ម៉ា និងអា ស្សេ ណូបិល (F. J. Costa, A. K. Dutt, L. J. C. Ma, and A. G. Noble) បោះពុម្ពនៅហូនូលូលូ ដោយរោងពុម្ពសាកលវិទ្យាល័យហាវ៉ៃ គ.ស. ១៩៨៩។

• ហ្វឺនីវល ចេ អេស (Furnival, J. S.) *Colonial Policy and Practice: A Comparative Study of Burma and Netherlands India* [**គោលនយោបាយនិងការអនុវត្តន៍អាណានិគម៖ ការសិក្សាប្រៀបធៀបនៃភូមានិងឥណ្ឌា នីឌឺឡែន**]. បោះពុម្ពនៅបូរីញូយ៉ក ដោយរោងពុម្ពសាកលវិទ្យាល័យញូយ៉ក គ.ស. ១៩៤៨ ។

• ហ្គីលប៊ឺត អាឡាំង (Gilbert, Alan) អ្នកកែសម្រួល *The Mega-City in Latin America* [**ទីក្រុងធំៗនៅអាមេរិកឡាទីន**] បោះពុម្ពនៅទីក្រុងតូក្យូ ដោយរោងពុម្ពសាកលវិទ្យាល័យអង្គការសហរបជាជាតិ គ.ស. ១៩៩៦ ។

• ហ្គ្រាហាំ អេស (Graham, S.) “Cities in Real-Time Age: The Paradigm Challenge of Telecommunications to the Conception and Planning of Urban Space” [**«ទីក្រុងនៅក្នុងយុគសម័យផ្លេកបន្ទោល៖ ការប្រឈមជាគំរូនៃទូរគមនាគមន៍ចំពោះគំនិតនិងគម្រោងនៃលំហទីក្រុង»**] បោះពុម្ពនៅក្នុងព្រឹត្តិបត្តិបរិស្ថាន និងគម្រោង*Environment and Planning* លេខ២៩ (គ.ស. ១៩៩៧) ទំព័រ ១០៥-២៧។

• ហ្គីនណេស ប៉ាទ្រីកខ៍ (Guiness, Patrick) *On the Margines of Capitalism: People and Development in Mukim Plentong, Johor, Malaysia* [**ផ្នែកសំខាន់តិចបំផុតនៃមូលធននិយម៖ ប្រជាជននិងការអភិវឌ្ឍន៍នៅ ម៉ូឃីន ផ្លេន្តុង ចូហូរ ម៉ាឡេស៊ី**] បោះពុម្ពនៅសិង្ហបូរី ដោយរោងពុម្ពសាកលវិទ្យាល័យអុកស្វ័ដ គ.ស. ១៩៩២។

• ហែនឌឺសាន់ ស្ស៊ី (Henderson, J.) អា កុនកូរ៉ូ (A. Kuncoro) និង ឌេ ណាសូស្យុង (D. Nasution) “The Dynamics of Jabotabek Development” [**«ផ្នែកផ្សេងៗនៃការអភិវឌ្ឍន៍នៅចាបូតាបែក»**] បោះពុម្ពនៅក្នុង ព្រឹត្តិបត្តិស្តីពីការសិក្សាផ្នែកសេដ្ឋកិច្ចនៅឥណ្ឌូនេស៊ី លេខ៣២ (១) (គ.ស. ១៩៩៦)ទំព័រ៧១-៩៥។

• EhrIn.Ga.(Herrin, A.) និង អឺ ពែរនៀ (E. Pernia) “Factors Affecting the Choice of Location: A Survey of Foreign and Local Firms in the Philippines” [**«កត្តាជះឥទ្ធិពលទៅលើជម្រើសនៃទីតាំង៖ ការស្ទង់មតិរបស់ក្រុមហ៊ុនក្នុងស្រុក និងបរទេសនៅប្រទេសហ្វីលីពីន»**] បោះពុម្ពនៅដោយ វិទ្យាស្ថានហ្វីលីពីនសំរាប់ការសិក្សាអភិវឌ្ឍ (Philippine Institute for Development Studies) ជាឯកសារការងារ នៅគ.ស. ១៩៨៦ ទំព័រ ៨៦-១០៣។

•ហូ កា សេ (Ho, K. C.) “From Port City to City State: Forces Shaping Singapore’s Built Environment” [**«ពីទីក្រុងជាកំពុងផែមកជារដ្ឋទីក្រុង៖ កត្តាកំណត់បរិស្ថានរបស់សិង្ហបូរី»**] បោះពុម្ពនៅក្នុងសៀវភៅ វប្បធម៌និងទីក្រុងនៅអាស៊ីបូព៌ា កែសម្រួលដោយ ដាបាយូ-បេ ឃីម (W-B Kim) អឹម ឌូក្លាស.(M. Douglass) អេស-សេ ចូ (S-C. Choe) និង កា សេ ហូ (K. C. Ho) ទំព័រ ២១២-៣៣ នៅអុកស្វ័ដ ដោយរោងពុម្ពក្លារែនដុង គ.ស. ១៩៩៧។

• ហូហ្គូ ស្សេ ស្ស៊ី (Hugo, G. J.) “Population Mobility in West Java, Indonesia” [**«ភាពចល័តរបស់ប្រជាជន**

**នៅកោះជ្វាខាងលិចនៅឥណ្ឌូនេស៊ី»**] និក្ខេបបទថ្នាក់បណ្ឌិត នៅសាលកវិទ្យាល័យជាតិអូស្ត្រាលី រដ្ឋកាន់បឺរ៉ា Canberra គ.ស. ១៩៧៥។

• ជែលីណែក លៀ (Jellinek, Lea) *The Wheel of Fortune: The History of a Poor Community in Jakarta* [**កង់រទេះនៃជោគវាសនា ៖ ប្រវត្តិសាស្ត្រនៃសមាគមន៍ក្រីក្រមួយនៅទីក្រុងចាការតា**] បោះពុម្ពនៅទីក្រុងស៊ីនី ដោយរោងពុម្ពអាឡែន និងអាំងវាំង Allen and Unwin គ.ស. ១៩៩១។

•ចូនស៍ ហ្គាវាំង ឌុបដុយវេ (Jones, Gavin W.) “The Thooughgoing Urbanization of East and Southeast Asia” [«**នគរូបនីយកម្មដែលដំណើរទៅយ៉ាងប្រសើរ នៃអាស៊ីអាគ្នេយ៍និងអាស៊ីបូព៌ា»**] ព្រឹត្តិបត្តិ ទស្សនៈអាស៊ីប៉ាស៊ីភិច លេខ ៣៨ (៣) (គ.ស. ១៩៩៧) ទំព័រ ២៣៧-៤៩។

• ខែលី ប៉េ អែហ្វ (Kelly, P. F.) “Globalization Power and the Politics of Scale in the Philippines” [«**ថាមពលសកលភាវូបនីយកម្ម និងនយោបាយនៃកម្រិត នៅប្រទេសហ្វីលីពីន»**] ព្រឹត្តិបត្តិ វេទិកាភូមិសាស្ត្រ (Geoforum) លេខ ២៨ (២) (គ.ស. ១៩៩៧) ទំព័រ ១៥១-៧១។

• ខែលី ប៉េ អែហ្វ (Kelly, P. F.) “The Politics of Urban-Rural Relations: Land Use Conversion in the Philippines” [«**នយោបាយនៃទំនាក់ទំនងទីក្រុង_ជនបទ៖ បម្លាស់ប្តូរការប្រើប្រាស់ដីនៅក្នុងប្រទេសហ្វីលីពីន»**] ព្រឹត្តិបត្តិ បរិស្ថាននិងនគរូបនីយកម្ម លេខ១០ (១) (គ.ស. ១៩៩៨) ទំព័រ ៣៥-៥៤។

• ខែលី ប៉េ អែហ្វ (Kelly, P. F.) “Everyday Urbanization: The Social Dynamics of Development in Manila’s Extended Metropolitan Region” [«**នគរូបនីយកម្មប្រចាំថ្ងៃ៖ កម្លាំងសង្គមនៃការអភិវឌ្ឍន៍នៅតំបន់ទីក្រុងពង្រីកនៅទីក្រុងម៉ានីល»**] ព្រឹត្តិបត្តិអន្តរជាតិនៃការស្រាវជ្រាវតាមតំបន់និងតាមទីក្រុង លេខ២៣ (២) (គ.ស. ១៩៩៩) ទំព័រ ២៨៣-៣០៣។

• ណុកស៍ ប៉េ (Knox, P.) “World Cities and the Organization of Global Space” [«**ទីក្រុងល្បីល្បាញពិភពលោក និងការរៀបចំលំហសកលលោក»**] នៅក្នុងសៀវភៅភូមិសាស្ត្ររបស់ការប្រែប្រួលសកលលោក Geographies of Global Change កែសម្រួលដោយ អ៊ែ ស៊្យេ ចនសាន់ (R. J. Johnson) ប៉េ ស៊្យេ តៃលឺ (P. J. Taylor) និងអឹម ស៊្យេ វ៉ាតស៍ (M. J. Watts) បោះពុម្ពនៅអុកស្វ័ដ ដោយរោងពុម្ពប្លែកវែល គ.ស. ១៩៩៥។

• លីហ្វ អឹម (Leaf, M.) “The Suburbanization of Jakarta: A Concurrence of Economic and Ideology” [«**នគរូបនីយកម្មជាយក្រុងនៃទីក្រុងចាការតា៖ ការកកើតឡើងកំណាលគ្នានៃសេដ្ឋកិច្ចនិងមនោគមវិជ្ជា»**] ព្រឹត្តិបត្តិស្តីពីគម្រោងសំរាប់ប្រទេសក្រីក្រ លេខ១៦ (៤) (គ.ស. ១៩៩៤) ទំព័រ ៣៤១-៥៦។

• លីហ្វ អឹម (Leaf, M.) “Building the Road for the BMW: Culture, Vision, and the Extended Metropolitan Region of Jakarta” [«**ការសាងសង់ផ្លូវសំរាប់រថយន្ត ប៊េ អឹម ដុបឌុយវេ៖ វប្បធម៌ ទស្សនៈវិស័យ និងតំបន់ទីក្រុងធំៗពង្រីកនៅចាការតា»**] ព្រឹត្តិបត្តិ បរិស្ថាននិងគម្រោង លេខ អា ២៨ (៧២៨) (គ.ស. ១៩៩៦) ទំព័រ ១៦១៧-៣៥។

• លី អ៊ីហ្គារិច-អេស អេហ្វ (Lee, Y-S. F.) “Facing the Urban Environmental Challenge” [«**ការជួបប្រទះនឹងផលលំបាកផ្នែកបរិស្ថានទីក្រុង»**] នៅក្នុងសៀវភៅអាស៊ីប៉ាស៊ីភិច៖ ភូមិសាស្ត្រថ្មីៗរបស់មាត់គែមប៉ាស៊ីភិច *Asia Pacific: New Geographies of the Pacific Rim* កែសម្រួលដោយ អ៊ែរ អេហ្វ វ៉ាទែរស៍ (R. F. Watters) និង តេ ស៊្យេ ម៉ាក់ហ្គី (T. J. McGee) ទំព័រ ១៤០-១៦០ បោះពុម្ពនៅទីក្រុង ឡុងដ៍ ដោយរោងពុម្ព ហឺស្តត្ស៍ រសតគ.ស. ១៩៩៧ ។

• ឡឺហ្វែប្រឺ ហាស់ (Lefebvre, H.) *The Production of Space* [**ផលិតកម្មនៃលំហ**] បកប្រែដោយ ដូណាល់ នីកូសាន់-ស្មីត (Donald Nicholson-Smith) បោះពុម្ពនៅទីក្រុង អុកស្វ័ដ ដោយរោងពុម្ព ប្លែកវែល គ.ស. ១៩៩១។

• លីន ហ្សេ (Lin, G.) "Changing Theoretical Perspectives on Urbanisation in Asian Developing Countires" [«**ទស្សនៈខាងទ្រឹស្តីប្រែប្រួលទៅលើនគរូបនីយកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី**»] ព្រឹត្តិបត្តិស្តីពីគម្រោងសម្រាប់ប្រទេសក្រីក្រ លេខ១៦ (១) (គ.ស. ១៩៩៤) ទំព័រ ១–២៣។

• ឡំបាដ ឌេ (Lombard, D.) *Le Carrefour Javnais* ឡឺ ការ៉េហ្វ័រ ស្សាវណេស៍ ព្រឹត្តិបត្តិ តែងសេចក្តីនៃប្រវត្តិសាស្ត្រសកលលោក Essai D'Histoire Globale លេខ២៣ បោះពុម្ពនៅទីក្រុងបារីស ដោយរោងពុម្ព Editions de l'Ecole des Hautes Etudes en Science Sociale គ.ស. ១៩៩០។

• ម៉ាក់ក្លូដ ស្កុត់ និង តេ ហ្សេ ម៉ាក់ហ្គី (Macleod, Scott and T. G. McGee) "The Singapore-Johor-Riau Growth Triangle: An Emerging Extended Metropolitan Region" [«**តំបន់ត្រីកោណរីកលូតលាស់នៅសិង្ហបូរី-ចូហូរ-រីយ៉ាវ៖ តំបន់ទីក្រុងធំពង្រីកដែលកំពុងលេចចេញមក**»] នៅក្នុងសៀវភៅ ទីក្រុងពិភពលោកកំពុងលេចចេញមកនៅអាស៊ីប៉ាស៊ីភិចEmerging World Cities in Pacific Asia កែសម្រួលដោយ អេហ្វ-សេ ឡូ និង អ៊ីហ្គារិច-អឹម យ៉ឹង បោះពុម្ពនៅទីក្រុង តូក្យូ ដោយរោងពុម្ព សាកលវិទ្យាល័យអង្គការសហប្រជាជាតិ គ.ស. ១៩៩៦។

• ម៉ាក់ហ្គី តេ ហ្សេ (McGee, T. G.) *The Southeast Asia City: A Social Geography of the Primate Cities of Southeast Asia* [**ទីក្រុងនៅអាស៊ីអាគ្នេយ៍៖ ភូមិសាស្ត្រសង្គមរបស់ទីក្រុងសំខាន់ៗនៃអាស៊ីអាគេយ៍**] បោះពុម្ពនៅ ទីក្រុងឡុងដ៍ ដោយរោងពុម្ព អា បែល និងសាន់ស៍ លីមីតធីតៅ ពលេលានដ្លៀនសឡូតង គ.ស. ១៩៦៧។

• ម៉ាក់ហ្គី តេ ហ្សេ "The Changing Cities" [«**ទីក្រុងប្រែប្រួល**»] នៅក្នុងសៀវភៅ អាស៊ីអាគ្នេយ៍៖ ភូមិសាស្ត្រមានប្រព័ន្ធ Southeast Asia: A Systematic Geography កែសម្រួលដោយ អែរ ដេ ហីល R. D. Hill. បោះពុម្ពនៅទីក្រុងកូឡាឡាំពួរ ដោយរោងពុម្ព សាកលវិទ្យាល័យអុកស្វ័ដ គ.ស. ១៩៧៩។

• ម៉ាក់ហ្គី តេ ហ្សេ "Urbanisasi or Kotadesasi? Evolving Patterns of Urbanization in Asia" [«**ទ្រង់ទ្រាយវិវឌ្ឍឡើងនៃនគរូបនីយកម្មនៅអាស៊ី**»] នៅក្នុងសៀវភៅ នគរូបនីយកម្មនៅអាស៊ី៖ កត្តាលំហ និងបញ្ហាគោលនយោបាយ *Urbanization in Asia: Spatial Dimensions and Policy Issues* កែសម្រួលដោយ អេហ្វ ស្ស៊ី កូស្តា(F. J. Costa).Ga.ka.Dut.(A. K. Dutt) និង អា ហ្សេ ណូប៊្លឺ (A. G. Noble) បោះពុម្ពនៅហូនូលូលូ ដោយរោងពុម្ព សាកលវិទ្យាល័យហាវ៉ៃ គ.ស. ១៩៨៩។

• ម៉ាក់ហ្គី តេ ហ្សេ "The Emergence of Desakota Regions in Asia: Expanding a Hypothesis" [«**ការលេចចេញឡើងនៃតំបន់ ដេសាកូតា នៅអាស៊ី៖ ពង្រីកការប៉ាន់ស្មាន**»] នៅក្នុងសៀវភៅ តំបន់ទីក្រុងពង្រីកធំៗ៖បម្រែបម្រួលការតាំងទីលំនៅនៅអាស៊ី *Extended Metropolis: Settlement Transition in Asia* កែសម្រួលដោយ អិន ហ្គីនប៊ឺហ្គ (N. Ginsburg) ប៊ី កូបពែល (B. Koppel) និង តេ ស្ស៊ី ម៉ាក់ហ្គី (T. G. McGee) បោះពុម្ពនៅ ហូនូលូលូ ដោយរោងពុម្ពសាកលវិទ្យាល័យហាវ៉ៃ គ.ស. ១៩៩១។

• ម៉ាក់ហ្គី តេ ហ្សេ "The Urban Future of Vietnam" [«**អនាគតតំបន់ទីក្រុងនៅវៀតណាម**»]*Third World Planning Review* ព្រឹត្តិបត្តិស្តីពីគម្រោងសម្រាប់ប្រទេសក្រីក្រ លេខ ១៧ (គ.ស. ១៩៩៥a) ទំព័រ ២៥៣–៧៨ ។

• ម៉ាក់ហ្គី តេ ហ្សេ "Metrofitting the Emerging Mega-Urban Regions of ASEAN: An Overview" នៅក្នុងសៀវភៅ

តំបន់ទីក្រុងធំៗនៃអាស៊ីអាគ្នេយ៍ *The Mega-Urban Regions of Southeat Asia* កែសម្រួលដោយ តេ ស្ស ម៉ាក់ហ្គី (T. G. McGee) និងអ៊ីរ៉ា រ៉ូប៊ីនសាន់ (Ira Robinson) ទំព័រ ៣-២៦ បោះពុម្ពនៅវ៉ង់គូវែរ Vancouver ដោយរោងពុម្ពយូប៊ីស៊ី ពជ គ.ស. ១៩៩៥b។

• ម៉ាក់ហ្គី តេ ស្ស *Five Decades of Urbanisation in Southeast Asia: A personal Encounter* [**ប្រាំទសវត្សរ៍នៃនគរូបនីយកម្មនៅអាស៊ីអាគ្នេយ៍៖ បទពិសោធន៍ផ្ទាល់ខ្លួនមួយ**] បោះពុម្ពនៅទីក្រុងហុងកុង ដោយវិទ្យាស្ថាននៃការសិក្សាតំបន់អាស៊ីប៉ាស៊ីភិច និងសាកលវិទ្យាល័យចិននៃទីក្រុងហុងកុង គ.ស. ១៩៩៧ ។

• មេឌី ក្រុងកាវ ( Medhi Krongkaew) “The Changing Urban System in a Fast-Growing City and Economy: The Case of Bangkok and Thailand” [**«ប្រព័ន្ធទីក្រុងប្រែប្រួលនៅក្នុងទីក្រុង និងសេដ្ឋកិច្ចរីកលូតលាស់រហ័ស៖ ករណីនៅបាងកក និងថៃឡង់»**] នៅក្នុងសៀវភៅ ទីក្រុងលេចចេញឡើងនៅប៉ាស៊ីភិច អាស៊ី *Emerging Cities in Pacific Asia* កែសម្រួលដោយ អេហ្វូ-សេ ឡូ និង អ៊ីហ្គារិច-អឹម យឹង បោះពុម្ពនៅទីក្រុងតូក្យូ ដោយសាកលវិទ្យាល័យអង្គការសហប្រជាជាតិ គ.ស. ១៩៩៦ ។

• មួយរ៉េ អាលីសាន់ ស្សី (Murray, Alison J.) No Money, *No Honey: A Study of Street Traders and Prostitutes in Jakarta* [**គ្មានលុយ គ្មានទឹកឃ្មុំ៖ ការសិក្សាមួយស្ដីពីឈ្មួញតាមផ្លូវនិងស្រីពេស្យានៅទីក្រុងចាកាតា**] បោះពុម្ពនៅទីក្រុងអុកស្វ័ដ ដោយសាកលវិទ្យាល័យអុកស្វ័ដ គ.ស. ១៩៩១។

• ណេដា (អាជ្ញាធរសេដ្ឋកិច្ច និងអភិវឌ្ឍន៍ជាតិ National Econimic and Development Authority, NEDA) *Medium-Term Philippine Development Plan,* 1993-1998 [**គម្រោងផែនការអភិវឌ្ឍកម្រិតមធ្យមនៅប្រទេសហ្វីលីពីន សម្រាប់ គ.ស. ១៩៩៣-១៩៩៨**] បោះពុម្ពនៅប៉ាស៊ីក Pasig ដោយភ្នាក់ងារសេដ្ឋកិច្ចនិងអភិវឌ្ឍជាតិ គ.ស. ១៩៩៥។

• ណេស្ទ័រ សេ (Nestor, C.) “Foreign Investment and the Spatial Pattern of Growth in Vietnam” [**«វិនិយោគទុនបរទេស និងទ្រង់ទ្រាយបែបលំហនៃការរីកលូតលាស់នៅប្រទេសវៀតណាម»**] នៅក្នុងសៀវភៅ ការអភិវឌ្ឍមិនរលូតនៅអាស៊ីអាគ្នេយ៍ *Uneven Development in Southeast Asia* កែសម្រួលដោយ សេ ឌីកសាន់ (C. Dixon) និង ដេ ដ្រាកាកីស-ស្មីត (D. Drakakis-Smith) បោះពុម្ពនៅអាល់ឌឺស្សុត ដោយរោងពុម្ពអាវ៉ឺប៊ូរី គ.ស. ១៩៩៧។

• ប៉ានវែល អឹម និង អិល វង្សស្សូក្សាវ៉ាត់ (Parnwell, M. and L. Wongsuphsawat) “Between the Global and the Local: Extended Metropolitanisation and Industrial Location Decision Making in Thailand” [**«រវាងសកលលោកនិងតំបន់ក្នុងស្រុក៖ ការសម្រេចចិត្តទៅលើការបង្កើតឱ្យមានតំបន់ទីក្រុងពង្រីកធំៗនិងទីតាំងឧស្សាហកម្មនៅក្នុងប្រទេសថៃ»**] ព្រឹត្តិបត្តិស្ដីពីគម្រោងសំរាប់ប្រទេសក្រីក្រ លេខ១៩ (២) (គ.ស. ១៩៩៧) ទំព័រ ១១៩-៣៨។

• ពែនីយ៉ា អ៊ី និង សេ ប៉ាឌឺរ៉ង់ហ្គា (Pernia, E. and C. Paderanga) “The Spatial and Urban Dimensions of Development” [**«កត្តាលំហ និងទីក្រុងនៃការអភិវឌ្ឍន៍»**] នៅក្នុងសៀវភៅ កត្តាលំហនិងទីក្រុងនៃការអភិវឌ្ឍនៅប្រទេសហ្វីលីពីន*The Spatial and Urban Dimensions of Development in the Philippines* កែសម្រួលដោយ អ៊ី អឹម ពែនីយ៉ា (E. M. Pernia) សេ ដុបឌឺវេ ប៉ាឌឺរ៉ង់ហ្គា (C. W. Paderanga) និង វ៉េ ប៉េ ហែម៉ូស្សូ (V. P. Hermoso) បោះពុម្ពនៅទីក្រុង ម៉ានីល ដោយវិទ្យាស្ថានហ្វីលីពីនសំរាប់ការសិក្សាអភិវឌ្ឍ គ.ស. ១៩៨៣ ។

• ពែរី អឹម (Perry, M.) “Promoting Corporate Control in Singapore” [**«ការលើកកំពើនការត្រួតពិនិត្យសាជីវកម្មនៅប្រទេសសិង្ហបុរី»**] ព្រឹត្តិបត្តិ ការសិក្សាតាមតំបន់ លេខ២៦ (៣) (១៩៩២) ទំព័រ ២៨៩-៩៤ ។

• ពែរី អឹម (Perry, M.) “New Corporate Structures, Regional Offices and Singapore’s New Economic Directions” [**«រចនាសម្ព័ន្ធសាជីវកម្មថ្មីៗ ការិយាល័យតាមតំបន់ និងទិសដៅសេដ្ឋកិច្ចថ្មីៗរបស់ប្រទេសសិង្ហបូរី»**] ព្រឹត្តិបត្តិសិង្ហ-បូរីនៃភូមិសាស្ត្រនៅតំបន់ត្រូពិច លេខ១៦ (២) (គ.ស. ១៩៩៥) ទំព័រ ១៨១-៩៧ ។

• រ៉ាប៊ីបាដាណា អា (Rabibhadana, A.) *The Organization of Thai Society in the Early Bangkok Period 1782-1873* [**ការរៀបចំនៃសង្គមថៃនៅសម័យបាងកកបុរាណគំលូងពេល១៧៨២-១៨៧៣**] បោះពុម្ពនៅអ៊ីតាកាឹតហាចា ដោយរោងពុម្ពសាលកវិទ្យាល័យខរ៉ែនែល Cornel គ.ស. ១៩៦០។

• រីដ អែរ អែរ (Reed, R. R.) Colonial Manila [**ទីក្រុងម៉ានីលនៅក្រោមអណានិគម**] បោះពុម្ពនៅប៊ឺខែលី Berkeley ដោយសាកលវិទ្យាល័យកាលីហ្វ័រញ៉ា គ.ស. ១៩៧៨ ។

• រីដ អានតូនី (Reid, Anthony) “The Structure of Cities in South East Asia: Fifteenth to Seventeenth Centuries” [**«រចនាសម្ព័ន្ធនៃទីក្រុងនៅអាស៊ីអាគ្នេយ៍ពីសតវត្សទី១៥ដល់១៧»**] ព្រឹត្តិបត្តិស្តីពីការសិក្សាតំបន់អាស៊ីអាគ្នេយ៍ លេខ១២ (២) (១៩៨០) ទំព័រ ២៣៥-៥០។

• រ៉ូស ហាស់ និង អា ពូងសមលី (Ross, H. and A. Poungsomlee) “Environmental and Social Impact of Urbanisation in Bangkok” [**«ឥទ្ធិពលសង្គមនិងបរិស្ថាននៃនគរូបនីយកម្មនៅទីក្រុងបាងកក»**] នៅក្នុងសៀវភៅ រៀបរាប់ពីការចំណាយ *Counting the Costs* កែសម្រួលដោយ ស្ស៊ី រីហ្គ (J. Rigg) បោះពុម្ពនៅសិង្ហបូរី ដោយវិទ្យាស្ថាននៃការសិក្សាអាស៊ីអាគ្នេយ៍ គ.ស. ១៩៩៥។

• សាសែន អេស (Sassen, S.) *The Global City: New York, London, Tokyo* [**ទីក្រុងសកលលោក៖ ញូវយ៉ក ទីក្រុងឡុងដ៍ និងទីក្រុងតូក្យូ**] បោះពុម្ពនៅ ព្រីនស៍តុន Princeton ដោយសាកលវិទ្យាល័យព្រីនស៍តុន គ.ស. ១៩៩១។

• សាសែន អេស (Sassen, S.) *Cities in the World Economy* [**ទីក្រុងនៅក្នុងសេដ្ឋកិច្ចពិភពលោក**] បោះពុម្ពនៅ Thousand Oaksរដ្ឋកាលីហ្វ័រញ៉ា ដោយរោងពុម្ព ភិនរForge Press គ.ស. ១៩៩៤។

• សែតឆែល សេ (Setchell, C.) “The Growing Environmental Crisis in the World’s Mega-Cities: The Case of Bangkok” [**«វិបត្តិបរិស្ថានដែលកំពុងកើនឡើងនៅក្នុងទីក្រុងធំៗនៃពិភពលោក៖ ករណីនៅបាងកក»**] ព្រឹត្តិបត្តិស្តីពីគម្រោងសំរាប់ប្រទេសក្រីក្រ លេខ១៧ (១) (គ.ស. ១៩៩៥) ទំព័រ ១-៨ ។

• ស្គីននឺរ អេស ដុបឌឺវ (Skinner, S. W.) Chiese Society in Thailand: An Analytical History [**សង្គមចិននៅប្រទេសថៃ៖ ប្រវត្តិសាស្ត្របែបវិភាគថែតញ្ញែតមួយ»**] បោះពុម្ពនៅអ៊ីតាកា នៅញូយ៉ក ដោយសាកលវិទ្យាល័យខរ៉ណែល គ.ស. ១៩៥៧ ។

• សូជីចូកូ បេ តេ (Soegijoko, B. T.) “Jabotabek and Globalization” [**«ចាបូតាបែក និងសកលភាវូបនីយកម្ម»**] នៅក្នុងសៀវភៅ ទីក្រុងលេចចេញឡើងនៅប៉ាស៊ីភិចអាស៊ី *Emerging Cities in Pacific Asia.*កែសម្រួលដោយ អេហ្វ-សេ ឡូ (F-C. Lo).និង អ៊ីហ្គារិច-អឹម យឹង (Y-M Yeung) បោះពុម្ពនៅទីក្រុង តូក្យូ ដោយសកលវិទ្យាល័យអង្គការសហប្រជាជាតិ គ.ស. ១៩៩៦។

• ស្តរ័ពើរ អឹម (Storper, M.) “Territories, Flows, and Hierarchies in the Global Economy” [**«ទឹកដី លំហូរ និងឋានានុក្រមនៅក្នុងសេដ្ឋកិច្ចសលកលោក»**] នៅក្នុងសៀវភៅ លំហនៃសកលភាវូបនីយកម្ម៖ ការប្រកាសជាថ្មីម្តងទៀតនូវអំណាចនៃតំបន់ក្នុងស្រុក *Spaces of Globalization: Reasserting the Power of the Local* កែសម្រួលដោយ កា កូកស៍

*បោះពុម្ពនៅទីក្រុងឡុងដ៍ ដោយពេងពុម្ពហ៊្គីលហ្វ័ដ គ.ស. ១៩៩៧ ។*

• *ស្រីវត៍ អិន និង កា អូលដ្ស៍* (Thrift, N. and K. Olds) "Refiguring the Economic in Economic Geography" [**«ការគិតអំពីសេដ្ឋកិច្ចឡើងវិញនៅក្នុងភូមិសាស្ត្រសេដ្ឋកិច្ច»**] *ព្រឹត្តិបត្តិ ដំណើរទៅមុខនៅក្នុងភូមិសាស្ត្រមនុស្សជាតិ Progress in Human Geography លេខ២០ (៣) (គ.ស. ១៩៩៦) ទំព័រ ១៩៩-២០៩។*

• *ទ្រូម័ន៍ អឺ អឹម* (Truman, E. M.) "The Mexican Peso Crisis: Implications for International Finance" [**«វិបត្តិរូបិយប័ណ្ណ ប៉េសូ របស់ម៉ិចសិក្វូ៖ មេរៀនសំរាប់ហិរញ្ញវត្ថុអន្តរជាតិ»**] *ព្រឹត្តិបត្តិ Federal Reserve Bulletin (ខែមីនា គ.ស. ១៩៩៦)ទំព័រ ៣១១-២០៩ ។*

• *វីតលី ប៉េ* (Wheatley, P.) *The Golden Khersonese Studies in the Historical Geography of the Malaysian Peninsula before AD 1500* [**ការសិក្សាអំពី ដែនដីសុវណ្ណភូមិ ឃើសាន់នីស នៅក្នុងភូមិសាស្ត្របុរាណនៃឧបទ្វីបម៉ាឡេស៊ី មុនគ.ស. ១៥០០**] *បោះពុម្ពនៅទីក្រុងកូឡាឡាំពួរ ដោយសាកលវិទ្យាល័យម៉ាឡេស៊ី គ.ស. ១៩៦២។*

• *វូលទែរស៍ អូ ដុបឌឺវ៉េ* (Wolters, O. W.) *Early Indonesian Commerce: A Study of the Origins of Srivajaya* [**ពាណិជ្ជកម្មឥណ្ឌូនេស៊ីដើម៖ ការសិក្សាអំពីដើមកំណើតនៃស្រីវិជ័យ**] *បោះពុម្ពនៅអ៊ីតាកា ដោយសកលវិទ្យាល័យ ខរណែល គ.ស. ១៩៦៧។*

• *យ៉ឹង យូ-ម៉ាន់* (Yeung, Yue-man) "Pacific Asia's World Cities in the New Global Econcomy" [**«ទីក្រុងពិភពលោកនៅប៉ាស៊ីហ្វិច អាស៊ីនៅក្នុងយុគសម័យសេដ្ឋកិច្ចសកលលោកថ្មី»**] *ព្រឹត្តិបត្តិ អនាគតទីក្រុង Urban Futures លេខ១៩ (គ.ស. ១៩៩៥) ទំព័រ ៨១-៨៧។*

## ជំពូកទី ៤

*១- នៅក្នុងអត្ថបទនេះពាក្យថា «យុវជន» គឺសំដៅទៅលើក្រុមអាយុពី ១៥ ដល់២៤ ។ នេះគឺជាការប្រើប្រាស់ដែលគេទទួលស្គាល់គាតច្រើនថាជាអត្ថន័យទូទៅរបស់ពាក្យយុវជន ហើយមានភាពងាយស្រួលក្នុងការប្រមូលទិន្នន័យពិសេសពីឯកសារជំរឿន ។ សំរាប់អត្ថន័យក្នុងបរិបទផ្សេងពីនេះ ពាក្យ អាចមានន័យចំពោះក្រុមអាយុផ្សេងទៀត (យោងតាមឯកសាររបស់ ESCAគគ.ស. ១៩៩៧ ជុំវិញបន្ទាត់ទី ៧ និងយោងតាមឯកសាររបស់ ស្សែណូស និង កាបាម៉ាឡាន* (Xenos and Kabamalan) *គ.ស. ១៩៩៨b កំណត់សម្គាល់លេខ ៧ ។*

*២- ចំពោះការសិក្សាពីតំបន់បញ្ចឹមបូព៌ា សូមអានឯកសាររបស់ ក័រដេស៍មែន* Cordesman *(គ.ស. ១៩៩៨) និង ម៉ែនស៍*.Maynes*(គ.ស. ១៩៩៨)។*

*៣- សូមអានអត្ថបទរបស់គណៈកម្មការ ស្តីពី «សម្ពាធចំនួនប្រជាជន ÷ ការគំរាមកំហែងមកលើលទ្ធិប្រជាធិបតេយ្យ (ផែនទី និងស្ថិតិជាតិ)» គ.ស. ១៩៨៩។*

*៤- អ្នកដទៃទៀតក៏បានបកស្រាយសំរាប់តំបន់អាស៊ីដែរ ប៉ុន្តែតាមរបៀបផ្សេងពីនេះ ។ សូមអានឯកសាររបស់ ចូនស៍* J ones*(គ.ស. ១៩៩៧) ឯកសាររបស់ ហ្វូសសែល និងហ្គ្រីន ផុសសលោនដអរនេរ (គ.ស. ២០០២) និងរបស់ សាន់តា ម៉ារៀ* Santa Maria *(គ.ស. ២០០២)។*

*៥- និយមន័យនៃតំបន់ទីក្រុង ដូចជាការបែងចែកចេញជាតំបន់ទីក្រុងនិងជនបទ អាចប្រែប្រួលតាមពេលវេលាសម្រាប់ប្រទេសនីមួយៗ ហើយក៏ខុសគួរអោយកត់សម្គាល់ផងដែរនៅពេលខ្លះ នៅក្នុងចំណោម បណ្តាប្រទេស*

ផ្សេងៗ ។ ការប្រើប្រាស់ «និយមន័យថ្នាក់ជាតិ» ទាំងនេះនៅក្នុងការប្រៀបធៀបជាអន្តរជាតិ គឺជាវិធីសាស្ត្រដ៏ប្រសើរបំផុតដែលមាន (យោងតាមឯកសាររបស់អង្គការសហប្រជាជាតិ គ.ស.១៩៦៩ ពីជំពូក១-៣ ដែលផ្ទុយពីឯកសាររបស់អង្គការសហប្រជាជាតិ គ.ស. ១៩៨០ ជំពូក២) ពីព្រោះប្រព័ន្ធដាក់ឈ្មោះអោយតំបន់ទាំងនោះរបស់ជាតិ និងទំរង់នៃការតាំងទីលំនៅមានលក្ខណៈខុសគ្នាខ្លាំងណាស់ ។ ជាមួយគ្នានេះដែរ និយមន័យថ្នាក់ជាតិត្រូវតែទៅតាមពេលវេលាដែលមានការវិវឌ្ឍន៍លើ ទ្រង់ទ្រាយនៃនគរូបនីយកម្ម ។

**៦**_នៅក្នុងកាលៈទេសៈជាច្រើន (ជាអាទិ៍មានប្រទេសហ្វីលីពីន កូរ៉េខាងត្បូង និងថៃឡង់) បញ្ហានេះកើត សូម្បីតែពេលដែលបមាណភាគនៃចំនួនប្រជាជនសរុបនៅទីក្រុងធំៗបន្តកើនឡើងក៏ដោយ (យោងតាមឯកសាររបស់អង្គការសហប្រជាជាតិ គ.ស.២០០១) ការប្រៀបធៀបរវាងតារាង A១៥ និង A១៦ ។ មានករណីសិក្សាអំពីដ៏ល្អមួយនៅប្រទេសហ្វីលីពីនដែលធ្វើឡើងដោយ ហ្គូនស្សាលេស និងអ្នកផ្សេងទៀត Gonzales et al (គ.ស.២០០១) ជំពូកទី ១ ដែលពណ៌នាអំពី «ការថយចុះនៃនគរូបនីយកម្ម» និង«បម្រែបម្រួលដ៏សំខាន់» ។

**៧**_ នេះគឺជាការពិតសំរាប់ប្រទេសទាំងបួនដែលយើងបានបកស្រាយយ៉ាងលម្អិតនៅទីនេះ ។ ដោយប្រៀបធៀបការប៉ាន់ស្មានចំនួនប្រជាជននៅទីក្រុងនៅក្នុងចុងទសវត្សឆ្នាំ ៧០ (យោងតាមឯកសាររបស់អង្គការសហប្រជាជាតិ គ.ស.១៩៨០ តារាងទី ៤៨) និងនៅចុងទសវត្សឆ្នាំ ៩០ (យោងតាមឯកសាររបស់អង្គការសហប្រជាជាតិ គ.ស.១៩៨០) អត្រាធ្លាក់ចុះមានដូចតទៅ៖ នៅទីក្រុងបាងកកធ្លាក់ពី ១១,៩ លានមក ៧,៣លាន នៅទីក្រុងយ៉ាកាតា ពី ១៦,៦ លានមក ១១ លាន នៅទីក្រុងម៉ានីល ពី ១២,៣ លាន មក ១០,៩ លាន និងនៅទីក្រុងសេអ៊ូល ពី ១៤,២ លាន មក ៩,៩ លាន ។

**៨**_ ប្រភពនៃការប៉ាន់ស្មានទាំងនេះបានមកពីអង្គការសហប្រជាជាតិ (គ.ស. ២០០១)។ ការធ្លាក់ចុះនៃចំនួនប្រជាជននៅជនបទដំបូងគេនោះត្រូវបានគេប៉ាន់ស្មានឡើងដោយប្រើរូបមន្តពិជគណិតសាមញ្ញមួយនៃបម្រែបម្រួលកសិកម្ម (យោងតាមឯកសាររបស់ ម៉ែលឡឺ Mellor គ.ស.១៩៦៦ ទំ.២៥) ទៅលើបម្រែបម្រួលតាមតំបន់ជនបទ-ទីក្រុង ។ ការដែលមានភាពថយចុះជាក់លាក់មួយនៃនគរូបនីយកម្មដូចដែលបានពន្យល់នោះមិនមានន័យថាបិទបាំងការកើនឡើងនៃតំបន់ទីក្រុងក្នុងទំរង់ផ្សេងនោះទេ ពីព្រោះថាតំបន់ទីក្រុងទាំងនោះរួមគ្នាផ្តុំឡើងបង្កើតទៅជាតំបន់ធំៗ (យោងតាមឯកសាររបស់ ម៉ែកហ្គី McGeeគ.ស.១៩៩៥) ហើយទ្រង់ទ្រាយថ្មីនៃទំនាក់ទំនងរវាងតំបន់ជនបទ-ទីក្រុងកើតចេញឡើងពីការដឹកជញ្ជូននិងប្រាស្រ័យទាក់ទងម័យទំនើប ។ ខ្ញុំពុំអាចធ្វើការបកស្រាយអោយក្បោះក្បាយនៅទីនេះបានទេ ជាតួយ៉ាងដូចជាការឈានមកដល់នៃការប្រាស្រ័យទាក់ទងគ្នាទៅតាមតំបន់ទីក្រុងទំនើបៗក្នុងចំណោមយុវជននៅទូទាំងអាស៊ីនោះ ។

**៩**_បន្ថែមពីនេះ ព្រឹត្តិការណ៍ចំណាកស្រុកមិនមានគំនាបពីកត្តាជីវសាស្ត្រផ្ទាល់នោះទេ ក្នុងការកំណត់ទ្រង់ទ្រាយទាំងនេះ ។ ព្រឹត្តិការណ៍ទាំងនេះក៏អាចកើតឡើងម្តងហើយម្តងទៀតនៅពេលណាមួយ ហើយក៏អាចឡើងជាចលនាបញ្ច្រាស់មកវិញដែរ ។

**១០**_ ខ្ញុំពុំអាចរកបាននូវអត្ថបទសិក្សាដែលធ្វើការគណនាអត្រាទាំងសំរាប់ទសវត្សឆ្នាំ ៨០ ដោយផ្អែកលើជំរឿននៅគ.ស.១៩៩០បាននោះទេ ។ នៅជុំវិញអាស៊ី មានពត៌មានភាគតិចណាស់ដែលស្តីអំពីចំណាកស្រុកដែលត្រូវបានគេប្រមូលមកពីជំរឿននៅគ.ស.១៩៩០ ជាជាងពីជំរឿននៅគ.ស.មុនៗនោះមក (យោងតាមឯកសាររបស់ ស្កែលដុង Skeldonគ.ស.១៩៨៦) ។

**១១**_សំរាប់គោលបំណងនៅក្នុងជំពូកនេះ ប្រទេសជប៉ុនត្រូវបានដកចេញ ពីព្រោះប្រវត្តិប្រជាសាស្ត្ររបស់ប្រទេស

*នេះមានភាពស្មុគស្មាញខ្លាំងណាស់ ហើយអត្រាស្តីពីរលកអាយុវិញក៏មានប្រភពច្រើនណាស់ដែរ ។ ប្រទេសដែលយើងដកចេញពីការបកស្រាយមួយផ្សេងទៀត គឺប្រទេសវៀតណាម ពីព្រោះមិនមានទិន្នន័យចាំបាច់ ។ សូមអានឯកសាររបស់ ប៊ុងហ្គាអាតស៍ និងហ្វ៉ាត់គីនស៍* Bongaarts and Watkins*(គ.ស. ១៩៩៦)សំរាប់ការពិភាក្សាលើកស្តុតាងសំរាប់កាលបរិច្ឆេទតំបូងទាំងនេះ។*

**១២**- *អង្គការសហប្រជាជាតិ (គ.ស. ១៩៨៥ តារាងទី ៦) បង្ហាញអំពីការចូលរួមយ៉ាងសស្រាក់សស្រាំពីចំណាកស្រុកសំរុបនៅក្នុងកំណើនទីក្រុងជាច្រើន បន្ថែមលើទីក្រុងសេអ៊ូល (ទិន្នន័យទាំងនេះសម្រាប់តំបន់ ប៊ូសាន់ ពុសាន ដេហ្គូ* Daegu *និង* Incheon *អាំងឆេអុង)។*

# ឯកសារយោង

• *អាស៊ីស្កូ, ម៉ាក* (Askew, Marc) *គ.ស. ២០០២*Bangkok: *Place, Practice and Representation* [**ទីក្រុងបាងកក៖ ទីកន្លែង ការអនុវត្តន៍ និងការបង្ហាញអោយឃើញ**] *បោះពុម្ពនៅបូរីញូយ៉ក ដោយរោងពុម្ពរ៉ូលិដ្យ*(Routledge)។

• *បង់ហ្គាអាត្ស៍, ចន និង ស៊ូសាន កូតស៍ វ៉ាតគិនស៍* (Bongaarts, John, and Susan Cotts Watkins) *គ.ស. ១៩៩៦* Social Interactions and Contemporary Fertility Transition [**អន្តរកម្មសង្គម និងបម្រែបម្រួលអត្រាកំណើតសម័យទំនើប**] *ចេញផ្សាយនៅក្នុងព្រឹត្តិប័ត ការពិនិត្យឡើងវិញនូវចំនួនប្រជាជននិងការអភិវឌ្ឍន៍* (*Population and Development* *ប្រ៊ីវ៉ី) លេខ ២២(៤) ទំ. ៦៣៩៦៨២*។

• *ប្រ៊ឺណាន់-ហ្គាល់វិន, អេឡែន* (Brennan-Galvin, Ellen) *គ.ស. ២០០២* Crime and Violence in an Urbanizing World [**ឧក្រិដ្ឋកម្មនិងអំពើហឹង្សានៅលើពិភពលោកកំពុងធ្វើនគរូបនីយកម្ម**] *ចេញផ្សាយនៅក្នុងព្រឹត្តិប័ត កិច្ចការអន្តរជាតិ* (*Journal of International Affairs*) *លេខ ៥៦(១) ទំ. ១២៣១៤៥*។

• *ប្រ៊ុកគឺហូវ, ម៉ាតាំង ប៉េ.* (Brockerhoff, Martin P. ) *គ.ស. ២០០០* An Urbanizing World [**ពិភពលោកកំពុងធ្វើនគ-រូបនីយកម្មមួយ**] *ចេញផ្សាយនៅក្នុងព្រឹត្តិប័ត ចំនួនប្រជាជន* (*Population Bulletin*) *លេខ៥៥(៣) ទំ. ១៤៤ ។*

• *គូដេសម៉ែន, អាន់តូនី ហាស់.* (Cordesman, Anthony H. ) *គ.ស. ១៩៩៨ Demographic and the Coming Youth Explosion in the Gulf* [**ប្រជាសាស្ត្រនិងកំណើនយុវជនដែលកំពុងកើតឡើងនៅតំបន់ឈូងសមុទ្រ**] *បោះពុម្ពនៅក្រុងវ៉ាស៊ីងតោន* (Washington, D.C.) *ដោយមជ្ឈមណ្ឌលដើម្បីការសិក្សាអន្តរជាតិនិងយុទ្ធសាស្ត្រ*។

• *ឌុយរ៉ង់, ចន ដេ.* (Durand, John D. ) *គ.ស. ១៩៧៥ The Labor Force in Economic Development: A Comparison of International Census Data 1946—1966* [**កម្លាំងពលកម្មនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច៖ ការប្រៀបធៀបទិន្នន័យជំរឿនអន្តរជាតិពីគ.ស. ១៩៤៦ ទៅ ១៩៦៦**] *បោះពុម្ពនៅក្រុងព្រីនស្តុន រដ្ឋញូយ៉ក ដោយរោងពុម្ពរបស់សាកលវិទ្យាល័យព្រីនស្តុន*។

• *មជ្ឈមណ្ឌលបញ្ចឹម-បូព៌ា* (East-West Center) *គ.ស. ២០០២*The Future Population of Asia [**ចំនួនប្រជាជននៅអនាគតកាលនៅទ្វីបអាស៊ី**] *បោះពុម្ពនៅរាជធានី ហូនូលូលូ* (Honolulu) *ដោយមជ្ឈមណ្ឌលបញ្ចឹម-បូព៌ា*។

• *គណៈកម្មការសេដ្ឋកិច្ចនិងសង្គមដើម្បីតំបន់អាស៊ីនិងប៉ាស៊ីភិច* ESCAP (Economic and Social Commission for Asia and the Pacific) *គ.ស. ១៩៨៨*Trends in Migration and Urbanization in Selected ESCAP Countries [**និន្នាការនៅក្នុងដំណើរចំណាកស្រុកនិងនគរូបនីយកម្មនៅក្នុងប្រទេសមួយចំនួននៃគណៈកម្មការសេដ្ឋកិច្ច និងសង្គម**

**ដើម្បីតំបន់អាស៊ីនិងប៉ាស៊ីភិច**]បោះពុម្ពនៅទីក្រុងបាងកក ដោយអង្គការសហប្រជាជាតិ។

• គណៈកម្មការសេដ្ឋកិច្ចនិងសង្គមដើម្បីតំបន់អាស៊ីនិងប៉ាស៊ីភិច គ.ស. ១៩៩៧ *Review of the Youth Situation, Policies and Progammes in Asia and the Pacific* [**ការពិនិត្យឡើងវិញនូវស្ថានភាព នយោបាយ និងកម្មវិធីយុវជន**] បោះពុម្ពនៅទីក្រុងបាងកក ដោយគណៈកម្មការសេដ្ឋកិច្ចនិងសង្គមដើម្បីតំបន់អាស៊ីនិងប៉ាស៊ីភិច។

• អេស្ទី, ដានាល សេ., ជែក អា. ហ្គោលស្តូន, តិឌ រ៉ូប៊ែរ ហ្គួរ, ប៉ាមេឡា ទេ. ស្ទួកូ, និង អាឡាំង អិន. អាំងហ្គឺ (Esty, Daniel C., Jack A. Goldstone, Ted Robert Gurr, Pamela T. Surko, and Alan N. Unger) គ.ស. ១៩៩៥ State Failure Task Force Report [**របាយការណ៍របស់កងកម្លាំងពិសេសដើម្បីដោះស្រាយភាពបរាជ័យនៅតាមរដ្ឋ**]បោះពុម្ពនៅក្រុងវ៉ាស៊ីនតោន ដោយ ទីភ្នាក់ងារពត៌មានកណ្តាលរបស់សហ-រដ្ឋអាមេរិក (*U.S. Central Intelligence Agency*)។

• ហ្វូលឡឺ, ហ្គែរី (Fuller, Gary) គ.ស. ១៩៩៥ The Demographic Background to Ethnic Conflict: A Geographic Overview [**ប្រវត្តិប្រជាសាស្ត្រនៅក្នុងជម្លោះក្រុមជនជាតិភាគតិច៖ ការពណ៌នាទូទៅនៅលើភូមិ-សាស្ត្រ**] ចេញផ្សាយនៅក្នុងសៀវភៅផលលំបាកនៃក្រុមជនជាតិភាគតិចចំពោះសណ្តាប់ធ្នាប់ជាតិនិងអន្តរជាតិនៅក្នុងទសវត្សឆ្នាំ ៩០÷ ការយល់ឃើញផ្នែកភូមិសាស្ត្រ (The Challenge of Ethnic to National and International Order in the 1990's: *Geographic Perspectives RTT* 95-10039) កែសម្រួលដោយទីភ្នាក់ពត៌មានកណ្តាល បោះពុម្ពនៅរាជធានី វ៉ាស៊ីនតោន ដោយទីភ្នាក់ងារពត៌មានកណ្តាលរបស់សហរដ្ឋអាមេរិក។

• ហ្វុយសែល, អេលីស្សាប៊ែត, ម៉ាហ្គារ៉ែត អ៊ី. ហ្គ្រីន (Fussel, Elizabeth, and Margaret E. Greene) គ.ស. ២០០២ Demographic Trends Affecting Youth and the World [**និនាការប្រជាសាស្ត្រដែលជះឥទ្ធិពលនៅលើយុវជននិងពិភពលោក**]ចេញផ្សាយនៅក្នុងសៀវភៅ យុវជនរបស់ពិភពលោក÷ ក្មេងជំទង់ៗនៅក្នុងតំបន់ចំនួនប្រាំបីនៅលើពិភពលោក(The World's Youth: Adolescence in Eight Regions of the Globe) កែសម្រួលដោយប៊ី. ប្រាដហ្វ័ដប្រោន, រីដ ដាបាយូ. ឡាសាន់ និង ទេ. សេស. សារ៉ាស្វ័ទី (B. Bradford Brown, Reed W. Larson, and T. S. Saraswthi) បោះពុម្ពនៅទីក្រុង ខែមប្រ៊ិដយ៍ (Cambridge) ដោយរោងពុម្ពរបស់សាកល-វិទ្យាល័យ ខែមប្រ៊ិដយ៍។

• ហ្គោលស្តូន, ជែក អា. (Goldstone, Jack A.) គ.ស. ១៩៩១ Revolution and Rebellion in the Early Modern World [**បដិវត្តន៍និងការបះបោរប្រឆាំងនៅលើពិភពលោកដើមសម័យទំនើប**] បោះពុម្ពនៅទីក្រុង ប៊ឹកឃ្លី (Berkeley) ដោយរោងពុម្ពរបស់សាកលវិទ្យាល័យកាលីហ្វ័រញ៉ា។

• ហ្គោលស្តូន, ជែក អា. (Goldstone, Jack A.) គ.ស. ២០០២ *How Demographic Change Can Lead to Violent Conflict* [ថាតើបម្រែបម្រួលប្រជាសាស្ត្រអាចនាំអោយមានជម្លោះហឹង្សាបានយ៉ាងដូចម្តេច] ចេញផ្សាយនៅក្នុងព្រឹត្តិបត័កិច្ចការអន្តរជាតិ លេខ ៥៦(១) ទំ. ៣២១។

• ហ្គោនស្សាលេស្ស-ឡូអេស៍ និង ហ្គ្រេហ្គោរីយ៉ូ លូអីស អា. អ៊ីហ្គាយ៉ា (Gonzalez-Loez, and Gregorio Luis A. Igaya) គ.ស. ២០០១ Managing Urbanization under a Decentralized Governance Framework [**ការគ្រប់គ្រងនគរូបនីយកម្មនៅក្នុងក្របខណ្ឌអភិបាលកិច្ចវិមជ្ឍការ**] បោះពុម្ពនៅទីក្រុង ហ្គេស៊ុន (Quezon City) ដោយមូលនិធិអភិវឌ្ឍន៍និងស្រាវជ្រាវប្រជាសាស្ត្រ(Demographic Research and Development Foundation)

• ហាំម៉ែល, អឺហ្គែន អា. និង អេរិក ដេ. ស្មីតស៍ (Hammel, Eugene A., and Erik D. Smith) គ.ស. ២០០២ Population Dynamics and Political Instability [**កម្លាំងបម្រែបម្រួល និងអស្ថេរភាពខាងផ្នែកនយោបាយ**] ចេញផ្សាយនៅ

*ក្នុងសៀវភៅបញ្ឈប់ភេរវកម្ម៖ ឥទ្ធិពលខ្លះៗនៃព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា កែសម្រួលដោយ នាល ហ្ស៊ែ. ស្មេល-ស៊ឺរ និង ហ្វេតស៍ មិត្សែល*(Neil J. Smelser and Faith Mitchell) *បោះពុម្ពនៅរាជធានី វ៉ាស៊ីនតោនដោយវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រជាតិ* (*National Academy of Sciences*) ។

• *ហាន់ទីងទុង, សាមុយអែល ប៉េ.* (Hungtington, Samuel P.) *គ.ស. ១៩៩៦*The Clash of Civilizations and the Remaking of Word Order [**ការប៉ះទង្គិចគ្នារវាងអរិយធម៌និងការស្ដារសណ្ដាប់ធ្នាប់ពិភពលោកឡើងវិញ**] *បោះពុម្ពនៅទីក្រុងឡុងដុង* (London) *ដោយរោងពុម្ព ថាច់ស្តូនប៊ុកស៍*(*Touchstone Books*) ។

• *ចូនស៍, ហ្គាវីន ដាប់បាយូ.* (Jones, Gavin W.) *គ.ស. ១៩៩៧* Changing Age Structure, Educational Progress, Employment Patterns, the Environment, Mobility and Their Implications for Adolescents [**រចនាសម្ព័ន្ធក្រុមអាយុប្រែប្រួល វឌ្ឍនភាពនៃការអប់រំ ទ្រង់ទ្រាយអត្រាការងារ បរិស្ថាន ចល័តភាព និងឥទ្ធិពលរបស់កត្តាទាំងនេះមកលើក្មេងជំទង់ៗ**] *ឯកសាររៀបចំសំរាប់អង្គប្រជុំក្រុមអ្នកជំនាញខាងក្មេងជំទង់ ៖ ឥទ្ធិពលនៃនិន្នាការចំនួនប្រជាជន បរិស្ថាន និងការអភិវឌ្ឍន៍* (*Paper prepared for Expert Group Meeting on Adolescents: Implications of Population Trends, Environment, and Developmen*t) *ប្រព្រឹត្តទៅពីថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី២ ខែតុលា នៅទីក្រុងបាងកក* ។

• *កាល, កូលីន ហាស់.* (Kahl, Colin H.) *គ.ស. ២០០០*States, Scarcity, and Civil Strife in the Developing World [**រដ្ឋ ភាពខ្វះខាត និងជម្លោះស៊ីវិលនៅក្នុងពិភពលោកកំពុងអភិវឌ្ឍន៍**] *និក្ខេបបទថ្នាក់បណ្ឌិតដែលមិនចេញផ្សាយ ធ្វើឡើងនៅសាកលវិទ្យាល័យកូឡាំប៊ា* (Columbia) ។

• *គីហ្វីតស៍, ណាតាន់* (Keyfitz, Nathan) *គ.ស. ១៩៧១* On the Momentum of Population Growth [**ការសិក្សានៅលើការកើនឡើងនៃចំនួនប្រជាជន**] *ចេញផ្សាយក្នុងព្រឹត្តិប័ត ប្រជាសាស្ត្រ* (Demography) *លេខ ៨(១) ទំ. ៧១០-៧៨០* ។

• *គីហ្វីតស៍, ណាតាន់* (Keyfitz, Nathan) *គ.ស. ១៩៧៣*The Youth Cohort Revisited [**ការពិចារណាឡើងវិញនៅលើក្រុមពួកយុវជន**] *ចេញផ្សាយក្នុងសៀវភៅ ចំនួនប្រជាជន នយោបាយ និងអនាគតរបស់តំបន់អាស៊ីអាគ្នេយ៍* (*Population, Politics, and the Future of Southern Asia*) *កែសម្រួលដោយ ហ្វែរ. ហ្គូវុត(ផ អុយៀត)បោះពុម្ពនៅបូរីញូយ៉ក ដោយរោងពុម្ពសាកលវិទ្យាល័យកូឡាំប៊ា*។

• *គីហ្វីតស៍, ណាតាន់* (Keyfitz, Nathan) *គ.ស. ១៩៨៦* The Youth Cohort and Indonesian History [**ក្រុមយុវជន និងប្រវត្តិសាស្ត្ររបស់ប្រទេសឥណ្ឌូនេស៊ី**] *ចេញផ្សាយនៅក្នុងព្រឹត្តិប័ត ម៉ាស្យ៉ារ៉ាកាត់ឥណ្ឌូនេស៊ី* (Masyarakat Indonesia) *លេខ ១៣(១) ទំ. ១២០* ។

• *ណូដែល, ចន, អាហ្វីឆាត់ ចំរ៉ាត់រិទ្ធិរ៉ង់ និង និប៊ុន ដេបាវ៉ាលីយ៉ា* (Knodel, John, Aphichat Chamrathrithirong, and Nibhon Debavalya)*គ.ស. ១៩៨៧ Thailand's Reproductive Revolution: Rapid Fertility Decline in a Third-World Setting* [**បដិវត្តន៍អត្រាកំណើតនៅប្រទេសថៃ៖ ការធ្លាក់ចុះយ៉ាងរហ័សនៃអត្រាកំណើតនៅក្នុងបរិបទប្រទេសតតិយលោក**] *បោះពុម្ពនៅទីក្រុងម៉ាឌីសាន់*(Madison)*ដោយរោងពុម្ពសាកលវិទ្យាល័យវីស្គូស៊ីន* (University of Wisconsin Press) >

• *ម៉ែនស៍, ឆាលស៍ វីលៀម* (Maynes, Charles William) *គ.ស. ១៩៩៨* The Middle East in the Twenty-First Century [**តំបន់បញ្ជឹមបូព៌ានៅក្នុងសតវត្សទី ២១**] *ចេញផ្សាយក្នុងព្រឹត្តិប័ត បញ្ជឹមបូព៌ាលេខ ៥២(១) ទំ. ៩១៦*។

• ម៉ែកហ្គី, តេ. ហ្ស្ជ. និង អីរ៉ា, អឹម. រ៉ូប៊ីនសាន់ (McGee, T. G., and Ira M. Robinson) គ.ស. ១៩៩៥ *The Mega-Urban Regions of Southeast Asia* [**តំបន់ទីក្រុងធំៗនៅអាស៊ីអាគ្នេយ៍**] បោះពុម្ពនៅវ៉ែនគូវែ (Vancouver) ដោយពោធិ៍ពុម្ពសាកលវិទ្យាល័យកូឡាំប៊ាអង់គ្លេស(University of British Columbia Press) >

• ម៉ែឡឺ, ចន ដាប៊ាយូ. (Mellor, John W) គ.ស. ១៩៩៦ The Economics of Agricultural Development [**សេដ្ឋកិច្ចរបស់ការអភិវឌ្ឍន៍កសិកម្ម**] បោះពុម្ពនៅទីក្រុង អ៊ីតាកា (Ithaca) រដ្ឋញូយ៉ក ដោយពោធិ៍ពុម្ពសាកលវិទ្យាល័យខ័នណែល (Cornell University Press)។

• ព្រែស្តុន, សាមុយអែល ហាស់. (Preston, Samuel H.)គ.ស. ១៩៧៩ *Urban Growth in Developing Countries: A Demographic Reappraisal* [**កំណើនរនៅតំបន់ទីក្រុងនៅក្នុងប្រទេសកំពុងអភិវឌ្ឍ៖ ការពិចារណាយ៉ាងល្អិតល្អន់នៅលើប្រជាសាស្ត្រ**] ចេញផ្សាយនៅក្នុង ព្រឹត្តិប័ត៌ចំនួនប្រជាជននិងការអភិវឌ្ឍន៍ លេខ ៥(២)ទំ. ១៩៥២១៥ ។

• សាន់តា ម៉ារៀ, ម៉ាដែឡែន (Santa Maria, Madelene)គ.ស. ២០០២ Youth in Southeast Asia: Living within the Continuity of Tradition and the Turbulence of Change [**យុវជននៅអាស៊ីអាគ្នេយ៍៖ ការរស់នៅក្នុងដំណើរការអនុវត្តប្រពៃណីនិងបម្រែបម្រួលខ្លាំង**] ចេញផ្សាយក្នុងសៀវភៅ យុវជនពិភពលោក៖ ក្មេងវ័យជំទង់នៅក្នុងតំបន់ចំនួនប្រាំបីនៅលើពិភពលោក កែសម្រួលដោយ ប៊េ. ប្រែហ្វដ, រីដ ដាប៊ាយូ. ឡាសាន់ និងតេ. អេស. សារ៉ាវ៉ាត់ទី (B. Bradford Brown, Reed W. Larson, and T. S. Saraswathi) បោះពុម្ពនៅទីក្រុងខេមប្រ៊ីជ ដោយពោធិ៍ពុម្ពសាកលវិទ្យាល័យខេមប្រ៊ីជ។

• ស៊ិងហ្គែលម៉ាន់, ចូអ៊ីម (Singelmann, Joachim) គ.ស. ១៩៩៣ Levels and Trends of Female Internal Migration in Developing Countries, 1960—1980 [**កម្រិតនិងនិន្នាការនៃចំណាកស្រុករបស់នារីនៅក្នុងប្រទេសកំពុងអភិវឌ្ឍពីគ.ស. ១៩៦០ក១៩៨០**] ចេញផ្សាយនៅក្នុងសៀវភៅការធ្វើចំណាកស្រុករបស់នារីនៅក្នុងប្រទេសកំពុងអភិវឌ្ឍពីគ.ស. ១៩៦០១៩៨០ កែសម្រួលដោយអង្គការសហប្រជាជាតិ បោះពុម្ពនៅញូវយ៉ក ដោយអង្គការសហប្រជាជាតិ។

• ស្កែលដុន, រ៉ូណាល់ (Skeldon, Ronald)គ.ស. ១៩៨៦Migration Issues and the 1990 Round of Censuses: A Background Paper with Recommendations and Justification Based upon the Experience of the 1980 Round of Census [**បញ្ហាចំណាកស្រុកនិងជំរឿននៅគ.ស.១៩៩០៖ ការសិក្សានៅលើព្រឹត្តិការណ៍ជំងិញ ដោយមានផ្តល់ជាអនុសាសន៍ និងយុត្តិកម្មផ្អែកលើបទពិសោធន៍នៃជំរឿននៅគ.ស. ១៩៨០**] រៀបចំដោយមជ្ឈមណ្ឌលសិក្សាតំបន់ទីក្រុង និងផែនការតំបន់ទីក្រុង (Center of Urban Studies and Urban Planning, University of Hong Kong) ដែលជាអត្ថបទស្រាវជ្រាវលេខ ១៧ បោះពុម្ពនៅទីក្រុងហុងកុង ដោយពោធិ៍ពុម្ពសាកលវិទ្យាល័យហុងកុង។

• ស្មែលស៊ឺ, នាល ហ្ស៊ី. និង ហ្វេស្ស មិតឆែល (Smelser, Neil J., and Faith Mitchell) គ.ស. ២០០២Discouraging Terrorism: Some Implications of 9/11 [**បញ្ឈប់ភេរវកម្ម៖ ឥទ្ធិពលខ្លះៗនៃព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា**] បោះពុម្ពនៅរាជធានីវ៉ាស៊ីនតោន ដោយវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រជាតិ ។

• ស្តែមស្តាន់, ឡារី (Sternstein, Larry) គ.ស. ១៩៨៤ The Growth of Population of the World's Pre-eminent 'Primate City': Bangkok at Its Bicentenary [**កំណើនចំនួនប្រជាជននៅតំបន់ «ទីក្រុងសំខាន់» នៅលើពិភពលោក៖ ទីក្រុងបាងកកក្នុងឱកាសពិធីគំរប់ពីររយឆ្នាំ**] ចេញផ្សាយនៅក្នុង ព្រឹត្តិប័ត៌សិក្សាអំពីអាស៊ីអាគ្នេយ៍ (Journal of Southeast Asian Studies)លេខ ១៥ ទំ. ៤៣៦៨ ។

• ទីទែលបូម, មីឆែល (Teitelbaum, Michael)គ.ស. ២០០០Are North/South Population Growth Differentials a Prelude to Conflict? [**តើភាពខុសគ្នារវាងកំណើនចំនួនប្រជាជននៅខាងត្បូងនិងនៅខាងជើងគឺជាការចាប់ផ្ដើមទន្ទ-ឧជម្លោះមែនទឹ?**] អត្ថបទរៀបចំសំរាប់មជ្ឈមណ្ឌលសំរាប់អង្គប្រជុំនយោបាយការសិក្សាអន្តរជាតិនិងយុទ្ធសាស្ត្រស្ដីអំពីភាពវ័យចំណាស់ពិភពលោក(Paper prepared for the Center for Strategic and International Studies Policy Summit on Global Aging) ប្រព្រឹត្តិទៅនៅរាជធានីវ៉ាស៊ិនតោន នៅថ្ងៃទី ២៥-២៦ ខែមករា។

• ទុលយ្យាពុលការ៍, ស្រីបប៉ាដ (Tuljapulkar, Shripad) កំពុងបោះពុម្ពផ្សាយ Riding the Waves: Population Transitions and Their Impact [**ជិះលើរលក៖ បម្រែបម្រួលចំនួនប្រជាសាស្ត្រនិងឥទ្ធិពលរបស់បម្រែបម្រួលនោះ**]។

• អង្គការសហប្រជាជាតិ គ.ស. ១៩៦៩ *Growth of the World's Urban and Rural Population*, 1920—2000 [**កំណើននៃចំនួនប្រជាជននៅតំបន់ជនបទនិងទីក្រុងនៅលើពិភពលោក**] បោះពុម្ពនៅបូរីញូយ៉ក ដោយអង្គការសហប្រជាជាតិ ។

• អង្គការសហប្រជាជាតិ គ.ស. ១៩៨០Patterns of Urban and Rural Population Growth [**ទ្រង់ទ្រាយនៃកំណើនចំនួនប្រជាជននៅតាមជនបទនិងទីក្រុង**] ចេញផ្សាយក្នុងព្រឹត្តិប័ត សិក្សាពីចំនួនប្រជាជន លេខ ៦៨(Population Studies 68) បោះពុម្ពនៅបូរីញូយ៉ក ដោយអង្គការសហប្រជាជាតិ ។

• អង្គការសហប្រជាជាតិ គ.ស. ១៩៨៥Migration, Population Growth, and Employment in Metropolitan Areas of Selected Developing Countries [**ចំណាកស្រុក កំណើតចំនួនប្រជាជន និងកម្លាំងការងារនៅក្នុងតំបន់ទីក្រុងធំៗនៃបណ្ដាប្រទេសកំពុងអភិវឌ្ឍមួយចំនួន**] បោះពុម្ពនៅបូរីញូយ៉ក ដោយអង្គការសហប្រជាជាតិ ។

• អង្គការសហប្រជាជាតិ គ.ស. ២០០១ World Urbanization Prospects: The 1999 Revision [ទស្សនៈវិស័យទៅលើនគរូបនីយកម្មពិភពលោក] បោះពុម្ពនៅបូរីញូយ៉ក ដោយអង្គការសហ-ប្រជាជាតិ។

• មជ្ឈមណ្ឌលដើម្បីការតាំងទីលំនៅរបស់មនុស្សជាតិនៃអង្គការសហប្រជាជាតិ (United Nations Center for Human Settlements) គ.ស. ១៩៩៦ An Urbanizing World: Global Report on Human Settlements 1996 [**ពិភពលោកដែលកំពុងធ្វើនគរូបនីយកម្ម**] បោះពុម្ពនៅទីក្រុង អុក្សស្វ័ដ (ចក្រភពអង់គ្លេស)ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យអុក្សស្វ័ដ (Oxford University Press) ។

• ភ្នាក់ងារពត៌មានកណ្ដាលរបស់សហរដ្ឋអាមេរិក (U.S. Central Intelligence Agency) គ.ស. ១៩៩០ Youth Deficits: An Emerging Population Problem [**ឱនភាពរបស់យុវជន៖ បញ្ហាចំនួនប្រជាជនដែលកំពុងកើតឡើងមួយ**] ចេញផ្សាយក្នុងព្រឹត្តិប័ត អត្ថបទសិក្សាស្រាវជ្រាវ (A Research Paper) បោះពុម្ពនៅរាជធានីវ៉ាស៊ីនតោនដោយភ្នាក់ងារពត៌មានកណ្ដាលរបស់សហរដ្ឋអាមេរិក។

• ភ្នាក់ងារពត៌មានកណ្ដាលរបស់សហរដ្ឋអាមេរិក គ.ស. ២០០១ Long-Term Global Demographic Trends: Reshaping the Geopolitical Landscape [**និនាការប្រជាសាស្ត្រពិភពលោករយៈពេលវែង៖ កំណត់លក្ខណៈពិសេសរបស់ភូគព្ភនយោបាយ**] បោះពុម្ពនៅរាជធានីវ៉ាស៊ីនតោន ដោយភ្នាក់ងារពត៌មានកណ្ដាលរបស់សហរដ្ឋអាមេរិក ។

• រីគហ្គីនស៍, ហូវើដ ដាបាយូ. (Wriggins, Howard W.) គ.ស. ១៩៨៨ Youth Cohorts, Population Change, and Politics: Five Intervening Variables [**ក្រុមយុវជន បម្រែបម្រួលចំនួនប្រជាជន និងនយោបាយ៖ កត្តាពាក់ព័ន្ធចំនួនប្រាំ**] អត្ថបទរៀបចំសំរាប់សន្និសិទ្ធស្ដីអំពីការប្រែប្រួលនាពេលអនាគតទៅលើរចនាសម្ព័ន្ធក្រុមអាយុប្រជាជន (Paper prepared for a Conference on Future Changes in Population Age Structure)ប្រព្រឹត្តិទៅនៅទីក្រុង សុព្រុន (So-

pron) *ប្រទេសហុងគ្រី* (Hungary) *ពីថ្ងៃទី ១៨-២១ ខែតុលា ។*
• *រីងហ្គិនស៍, ហ្វរីដ ដាបាយូ.គ.ស. ១៩៨៩* Youth Cohorts, Population Growth, and Political Outcomes [**ក្រុមយុវជន កំណើនចំនួនប្រជាជន និងលទ្ធផលខាងនយោបាយ**] *ចេញផ្សាយក្នុងព្រឹត្តិប័ត* IIASA Working Papers *លេខ ៨៩(៣៧) ទំ.១១៥ ។*
• *ស៊េណូស, ពីតឺ និង សូកូរ៉ូ ហ្គាល់ទីយ៉ាណូ* (Xenos, Peter, and Soccoro Gultiano) *គ.ស. ២០០២*The Marriage Ratios of Asian Countries and Cohorts [**អនុបាតការរៀបអាពាហ៍ពិពាហ៍នៃបណ្ដាប្រទេស និងក្រុមយុវជនអាស៊ី**] *អត្ថបទរៀបចំសំរាប់ សន្និសិទ្ធប្រជាជនតាមតំបន់* IUSSP *គ.ស. ២០០២ ស្ដីអំពីចំនួនប្រជាជននៅតំបន់អាស៊ីអាគ្នេយ៍នៅក្នុងបរិបទអាស៊ីប្រែប្រួល* (Paper prepared for the 2002 IUSSP Regional Population Conference on Southeast Asia's Population in a Changing Asian Context) *ប្រព្រឹត្តិទៅនៅទីក្រុងបាងកក ពីថ្ងៃទី ១០-១៣ ខែមិថុនា ។*
• *ស៊េណូស, ពីតឺ និង មីឌីយ៉ា, កាហាម៉ាឡាន* (Xenos, Peter, and Midea Kahamalan) *គ.ស. ១៩៩៨*a The Changing Demographic and Social Profile of Youth in Asia [**បម្រែបម្រួលទំរង់សង្គម និងប្រជាសាស្ត្រនៃយុវជននៅអាស៊ី**] *ចេញផ្សាយក្នុងព្រឹត្តិប័ត របាយការណ៍ស្រាវជ្រាវអំពីចំនួនប្រជាជននៅអាស៊ី-ប៉ាស៊ីភិច* (Asia-Pacific Population Research Reports) *លេខ ១២ (ខែតុលា) ទំ.១២៤។*
• *ស៊េណូស, ពីតឺ គ.ស. ១៩៩៨*b The Social Demography of Asian Youth: A Reconstruction over 1950—1990 and Projection to 2025 [**ប្រជាសាស្ត្រសង្គមនៃយុវជនអាស៊ី៖ ការកសាងឡើងវិញពីគ.ស. ១៩៥០—១៩៩០ និងការប៉ាន់ស្មានទុកជាមុនសំរាប់គ.ស. ២០២៥**] *របាយការណ៍ស្ដីអំពីបម្រែបម្រួលមានរយៈពេលវែងនៃយុវជននៅអាស៊ី ។ កិច្ចសន្យារបស់ក្រុមប្រឹក្សាដោះស្រាយបញ្ហាចំនួនប្រជាជន លេខ សេ.អ៊ី. ៩៧.៦៣ អា.* (The Report on the Project Long-Term Transformations of Youth in Asia, Population Council Contract CI97.63A) *បោះពុម្ពនៅទីក្រុងហូណូលូលូដោយកម្មវិធីស្ដីពីចំនួនប្រជាជនរបស់មជ្ឈមណ្ឌលបញ្ចឹម-បូព៌ា* (Honolulu: Program on Population, East—West Center) ។
• *ស៊េណូស, ពីតឺ និង មីឌីយ៉ា, កាហាម៉ាឡាន* (Xenos, Peter and Midea Kabamalan)*កំពុងចេញផ្សាយ*A Comparative History of Age Structure and Social Transitions Among Asian Youth [**ប្រវត្តិសាស្ត្រប្រៀបធៀបមួយនៃរចនាសម្ព័ន្ធក្រុមអាយុ និងបម្រែបម្រួលសង្គមក្នុងចំណោមយុវជនអាស៊ី**] *នឹងចេញផ្សាយនៅក្នុងសៀវភៅជិះលើរលកៈ បម្រែបម្រួលចំនួនប្រជាជននិងឥទ្ធិពលរបស់បម្រែបម្រួលនោះ* (Riding the Waves: Population Transitions and their Impact) *កែសម្រួលដោយ ស្រីប៉ាដ ទុលយ៉ាពុលការ និងអ្នកនិពន្ធដទៃទៀត* (Shripad Tuljapulkar et al.) *បោះពុម្ពនៅទីក្រុងអុកស្វ័ដ ដោយរោងពុម្ពសាកលវិទ្យាល័យអុកស្វ័ដ ៕*

## Table of Contents

Preface 07

**Chapter 1: Material Culture** **09**

Light Houses, Noble Temples **11**

Furniture and Lighting **25**

The body beautiful **26**

Hair **32**

Clothing **37**

Textile Production and Trade **44**

Gold and Silver working **51**

Craft Specialization **55**

Ceramics **59**

Metalwork: the Key to power **61**

Iron **62**

Copper, Tin, and Lead **70**

**Chapter 2: City and its commerce** **75**

Port-cities and the Trade Network **79**

Urban Dimensions **83**

The structure of the Southeast Asian City **94**

Market **108**

Coinage and Commercialization- The Triumph of Silver **111**

Financial Organization **126**

Orangkaya- The Mercantile Elite **133**

Commercial Minorities and Ethnicity **144**

Urbanizm and Capitalism **151**

**Chapter 3: Changing Spaces-Southeast Asian Urbanization in an Era of Volatile Globalization** **155**

Introduction **157**

The historical Development of Urbanization in Southeast Asia **159**

Post-war Urbanization in Southeast Asia 1945-90 **161**

Phase one: Urbanization and the New Nationalism in Southeast Asia **161**

Phase two: Global Integration and Urbanization 1960-1990 **163**

Urbanization in the 1990s: Volatile Globalization and the Southeast Asian City **166**

Representing the Globalizing city in Southeast Asia **170**

World Cities **171**

Growth polygons **172**

Extended Metropolitan Regions and Corridors **172**

Urbanization and Multi-Scalar Dynamics **174**

Future directions: Urbanization and Volatile Globalization **175**

Conclusion: Policy implications **178**

**Chapter 4: Demographic Forces Shaping Youth Populations in Asian Cities** **181**

Asia's Urban Transformation and Youth **188**

Youth in National Migration Systems **192**

Demographic Transition and Youth Explosion **194**

The Urbanward Press of Youth **198**

The singular social profile of urban youth **203**

Conclusion **206**

**Note** **213**

Chapter 2 **213**

Chapter 3 **215**

Chapter 4 **223**